unesco

ichcap APCEIU

# ការបញ្ចូលបេតិកភណ្ឌរស់

## ទៅក្នុងការសិក្សា នៅអាស៊ីប៉ាស៊ីហ្វិក



បោះពុម្ពផ្សាយនៅឆ្នាំ ២០២៣ ដោយ
អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ (អង្គការយូណេស្កូ)
អគារលេខ ៧, place de Fontenoy, ៧៥៣៥២ Paris 0៧ SP ប្រទេសបារាំង
ការិយាល័យអង្គការយូណេស្កូ ប្រចាំទីក្រុងបាងកក
អគារលេខ ៩២០ ផ្លូវ សុខុម្វិត ព្រះខាណុង ខ្លងតើយ បាងកក ១០១១០ ប្រទេសថៃ
មជ្ឈមណ្ឌលព័ត៌មាន និងបណ្តាញអន្តរជាតិសម្រាប់បេតិកភណ្ឌវប្បធម៌អរូបី (ICHCAP)
៩៥ Seohak-ro, Wansan-gu, Jeonju, Jeollabuk-do ៥៥១០១ សាធារណរដ្ឋកូរ៉េ
និងមជ្ឈមណ្ឌលអប់រំអន្តរជាតិអាស៊ីប៉ាស៊ីហ្វិក (APCEIU)
១២០ Saemal-ro, Guro-gu, Seoul 0៨២៨៩ សាធារណរដ្ឋកូរ៉េ
© UNESCO ICHCAP និង APCEIU ឆ្នាំ២០២៣
ISBN: 978-92-3-000201-5

សៀវភៅនេះមានផ្សព្វផ្សាយនៅលើអ៊ីនធឺណិតក្រោមអាជ្ញាបណ្ណ Attribution-ShareAlike ៣.0 IGO (CC-BY-SA ៣.0 IGO) (http://creativecommons.org/licenses/by-sa/3.0/igo/)។ នៅពេលប្រើប្រាស់ខ្លឹមសារណាមួយចេញពីឯកសារនេះ អ្នកប្រើប្រាស់ត្រូវគោរពតាមលក្ខខណ្ឌប្រើប្រាស់របស់និហិតដ្ឋានអាចចូលប្រើប្រាស់បានដោយបើកចំហរបស់អង្គការ UNESCO (http://www.unesco.org/open-access/terms-use-ccbysa-en)។

ចំណងជើងដើម៖ Bringing Living Heritage to the Classroom in Asia-Pacific: A Resource Kit.។ បោះពុម្ពនៅឆ្នាំ ២០២២ ដោយអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ ប្រទេសបារាំង៖ ការិយាល័យអង្គការយូណេស្កូនៅទីក្រុងបាងកក ប្រទេសថៃ មជ្ឈមណ្ឌលព័ត៌មាន និងបណ្តាញអន្តរជាតិសម្រាប់បេតិកភណ្ឌវប្បធម៌អរូបីក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក (ICHCAP) សាធារណរដ្ឋកូរ៉េ និងមជ្ឈមណ្ឌលអប់រំអាស៊ីប៉ាស៊ីហ្វិកសម្រាប់ការអប់រំ និងការយល់ដឹងអន្តរជាតិ (APCEIU) សាធារណរដ្ឋកូរ៉េ។

រាល់ខ្លឹមសារនៅក្នុងសៀវភៅនេះ មិនមែនជាការបញ្ចេញមតិរបស់អង្គការយូណេស្កូ ចំពោះស្ថានភាពផ្លូវច្បាប់ ដែនដី ទីក្រុង ឬតំបន់ ឬរបស់អាជ្ញាធរនៃប្រទេសណាមួយ ឬពាក់ព័ន្ធនឹងព្រំប្រទល់ ឬព្រំដែនរបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ទាំងនោះឡើយ។

គំនិត និងទស្សនៈដែលបានលើកឡើងនៅក្នុងឯកសារនេះ គឺជាគំនិត និងទស្សនៈរបស់អ្នកនិពន្ធសុទ្ធសាធ ពោលគឺមិនមែនជាគំនិត និងទស្សនៈរបស់អង្គការយូណេស្កូនោះទេ។

រូបភាពដែលមានសញ្ញាផ្កាយ * មិនស្ថិតនៅក្រោមអាជ្ញាបណ្ណ CC-BY-SA ហើយមិនអាចប្រើ ឬថតចម្លងដោយគ្មានការអនុញ្ញាតជាមុនពីម្ចាស់កម្មសិទ្ធិបញ្ញាឡើយ។

សម្របសម្រួលគម្រោង៖ Duong Bich Hanh និង Hangying Li

ដឹកនាំការងារ៖ Vanessa Achilles

សម្របសម្រួលការផលិត៖ Waraporn K. Onnom និង Korapat Praputum

កែសម្រួលភាសាអង់គ្លេស៖ Ellen Meleisea

កែសម្រួលភាសាខ្មែរ៖ Makara Hong

រចនាក្រាហ្វិក (ភាសាអង់គ្លេស)៖ Patcharin Eak-Onsang និង Sirisak Chaiyasook

បកប្រែ និងរចនាក្រាហ្វិក (ភាសាខ្មែរ)៖ First-Class Solutions Ltd.

រូបភាពគម្រប និងខាងក្នុង៖ Gang of the Unicorn Co., Ltd.

រូបខាងក្នុង៖ Matanat Babayeva/Shutterstock.com *

TH/C3-6380/CLT/22/025

# សេចក្ដីសង្ខេប

## ផ្លាស់ប្ដូរការអប់រំ តាមរយៈការបញ្ចូលបេតិកភណ្ឌរស់នៅតាមសាលា

ការបញ្ចូលបេតិកភណ្ឌរស់ក្នុងការសិក្សា អាចជួយពង្រឹងគុណភាពអប់រំ ធ្វើឱ្យសកម្មភាពរបស់សិស្ស និងគ្រូកាន់តែមានភាពរស់រវើក ហើយរួមចំណែកក្នុងការថែរក្សាបេតិកភណ្ឌនេះឱ្យនៅមានជីវិតសម្រាប់មនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយ។ លើសពីនេះទៅទៀត ខណៈដែលជំងឺរាតត្បាតកូវីដ-១៩ កំពុងកើតមានឡើង បេតិកភណ្ឌរស់អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាឱ្យបាននូវសុខមាលភាព និងភាពស៊ាំរបស់សហគមន៍។

អង្គការយូណេស្កូ លើកទឹកចិត្តឱ្យប្រទេសនានាការពារបេតិកភណ្ឌរស់តាមរយៈការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។ ចាប់តាំងពីដំណាច់ឆ្នាំ២០១៩ ដល់ដើមឆ្នាំ២០២២ អង្គការយូណេស្កូ បាន និងកំពុងធ្វើការជាមួយដៃគូនានា ដើម្បីអនុវត្តគម្រោងសាកល្បង "ការសិក្សាបេតិកភណ្ឌរស់នៅតាមសាលា" នៅក្នុងប្រទេសចំនួនប្រាំមួយក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ដែលក្នុងនោះរួមមាន ប្រទេសកម្ពុជា កាហ្សាក់ស្ថាន គៀជីស្ថាន នេប៉ាល់ សាធារណរដ្ឋកូរ៉េ និងថៃ។ សិស្សជាង ១ ៩០០ នាក់មកពីសាលាចំនួន ២១ បានចូលរួមក្នុងគម្រោងនេះប្រកបដោយនវានុវត្តន៍។ នៅក្នុងដំណើរការនេះ គ្រូបង្រៀនចំនួន ៨៦ នាក់ ដែលក្នុងនោះ ស្ត្រីមានចំនួនជាងពីរភាគបីបានចូលរួមរៀបចំ និងធ្វើតេស្តមេរៀន និងសកម្មភាពចំនួន ១០១។

សិស្សចំនួន

1,900

នាក់បានទទួលផលពីគម្រោងសាកល្បងនេះ

សៀវភៅនេះ គឺជាមគ្គុទេសក៍ណែនាំជាជំហានៗ ហើយជាធនធានសំខាន់ថាតើហេតុអ្វីត្រូវបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងមេរៀននានា ក៏ដូចជាសកម្មភាពក្រៅកម្មវិធីសិក្សា ហើយត្រូវបញ្ចូលតាមរបៀបណា។

មិនថាអ្នកជាអ្នករៀបចំគោលនយោបាយ អ្នកគ្រប់គ្រងសាលា គ្រូបង្រៀន សិស្ស ឪពុកម្ដាយ អ្នកអនុវត្តបេតិកភណ្ឌនោះទេ អ្នកសុទ្ធតែមានតួនាទីសំខាន់នៅក្នុងដំណើរការនេះ។

unesco

*"ដោយសារតែសង្គ្រាមបានផ្ដើមចេញពីចិត្តមនុស្ស ដូច្នេះការកសាងសន្តិភាពក៏ត្រូវចាប់ផ្ដើមចេញពីចិត្តមនុស្សដែរ។"*

# ការបញ្ជ្រាបបេតិកភណ្ឌរស់

## ទៅក្នុងការសិក្សា នៅអាស៊ីប៉ាស៊ីហ្វិក

## សៀវភៅណែនាំ

# អារម្ភកថា

សៀវភៅនេះជាសមិទ្ធផលនៃគម្រោងរបស់អង្គការយូណេស្កូ "ការសិក្សាបេតិកភណ្ឌរស់នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក" ដែលបានអនុវត្តចន្លោះពីដំណាច់ឆ្នាំ២០១៩ ដល់ដើម ឆ្នាំ២០២២។ សៀវភៅនេះ បានដកស្រង់បទពិសោធន៍ និងមេរៀនដែលទទួលបានពីគម្រោងនានា ការសិក្សា និងការអង្កេតផ្សេងៗកាលពីពេលមុនៗ ដែលអនុវត្តនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងពីគម្រោងថ្មីៗរបស់អង្គការយូណេស្កូ "ការសិក្សាបេតិកភណ្ឌរស់នៅអឺរ៉ុប"។

គម្រោង "ការសិក្សាបេតិកភណ្ឌរស់នៅតំបន់អាស៊ីប៉ាស៊ីហ្វិក" មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃបេតិកភណ្ឌរស់តាមរយៈការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ និងជំរុញឱ្យបណ្ដាប្រទេសនៅតំបន់អាស៊ីប៉ាស៊ីហ្វិកធ្វើការអភិរក្សបេតិកភណ្ឌនេះ និងជំរុញការស្វែងយល់ពីគ្នាទៅវិញទៅមក និងភាពជាពលរដ្ឋសកលលោក។

តាមរយៈគម្រោងនេះ សកម្មភាពមានភាពច្នៃប្រឌិតនានាពាក់ព័ន្ធនឹងបេតិកភណ្ឌរស់ បានចងក្រង និងប្រើដោយគ្រូបង្រៀនចំនួន ៨៦ រូប ដែលក្នុងនោះមានស្ត្រីជាងពីរភាគបីនៅតាមសាលាចំនួន ២១ ក្នុងប្រទេសចំនួន ៦ រួមមានប្រទេសកម្ពុជា កាហ្សាក់ស្ថាន គៀជីស្ថាន នេប៉ាល់ សាធារណរដ្ឋកូរ៉េ និងថៃ ដោយមានការចូលរួមពីសំណាក់សិស្សានុសិស្ស និងអ្នកប្រតិបត្តិបេតិកភណ្ឌ។ ជារួម សិស្សចំនួន ១ ៩០០ នាក់បានទទួលផលពីមេរៀន និងសកម្មភាពចំនួន ១០១ ដែលបានរួមចំណែកដល់ការលើកកម្ពស់លទ្ធផលសិក្សារបស់ពួកគេ និងបង្កើតចំណាប់អារម្មណ៍ថ្មី និងការចូលរួមនៅក្នុងបេតិកភណ្ឌវប្បធម៌។ នៅក្នុងអំឡុងពេលផ្ទុះជំងឺរាតត្បាតកូវីដ-១៩ សកម្មភាពគម្រោងភាគច្រើនបានរៀបចំតាមអ៊ីនធឺណិត ហើយពេលខ្លះ ការសិក្សាបានរៀបចំតាមប្រព័ន្ធអ៊ីនធឺណិត ដែលបានបង្ហាញថា បេតិកភណ្ឌរស់អាចបញ្ចូលទៅក្នុងការអប់រំ ហើយមានលទ្ធផលវិជ្ជមាន ទោះបីជាស្ថិតក្នុងពេលមានបញ្ហាប្រឈមយ៉ាងណាក៏ដោយ។

គម្រោងនេះត្រូវបានអនុវត្តដោយមានកិច្ចសហការជាដៃគូរវាងយូណេស្កូ មជ្ឈមណ្ឌលព័ត៌មាន និងបណ្ដាញអន្តរជាតិសម្រាប់បេតិកភណ្ឌវប្បធម៌អរូបីនៅអាស៊ីប៉ាស៊ីហ្វិក (ICHCAP) និង មជ្ឈមណ្ឌលអប់រំអន្តរជាតិអាស៊ីប៉ាស៊ីហ្វិក (APCEIU) ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុបន្ថែមពីនាយកដ្ឋានវប្បធម៌ និងទេសចរណ៍ឆេងឌូ (Chengdu)។

គម្រោងដាក់បញ្ចូលបេតិកភណ្ឌរស់ក្នុងការអប់រំនេះ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងជាប្រព័ន្ធ និងយូរអង្វែងគ្រប់ជំហានទាំងអស់នឹងនាំយើងឆ្ពោះទៅរកអនាគតមួយ ដែលមានការគោរព និងស្រលាញ់ផ្នែកវប្បធម៌ ប្រព័ន្ធអប់រំត្រូវបានរៀបចំឱ្យស្របទៅតាមបរិបទ មានភាពប្រទាក់ក្រឡាគ្នា និងផ្តល់នូវគុណប្រយោជន៍សម្រាប់សិស្ស។ គម្រោងនេះក៏រួមចំណែកដល់ការអនុវត្តគម្រោង "រួមគ្នាដើម្បីសន្តិភាព" ជាគំនិតផ្តួចផ្តើមមួយរបស់អង្គការយូណេស្កូ ដែលមានបំណងកសាងអនាគត ប្រកបដោយសន្តិភាព និងនិរន្តរភាពនៅតំបន់អាស៊ីប៉ាស៊ីហ្វិក។

| | | |
|---|---|---|
| Shigeru Aoyagi | Ji Sung Kim | Hyun Mook Lim |
| *នាយក* | *នាយក* | *នាយក* |
| *អង្គការយូណេស្កូ បាងកក* | *មជ្ឈមណ្ឌល ICHCAP* | *មជ្ឈមណ្ឌល APCEIU* |

# សេចក្តីថ្លែងអំណរគុណ

ឯកសារមេរៀនអំពី "ការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការសិក្សានៅអាស៊ីប៉ាស៊ីហ្វិក" គឺជាលទ្ធផលនៃគំនិតផ្តួចផ្តើមរយៈពេលវែងដោយមានការសម្របសម្រួលដោយអង្គការ UNESCO ប្រចាំទីក្រុងបាងកក ក្រោមកិច្ចសហការជាមួយនឹងមជ្ឈមណ្ឌលប្រភេទទី ២ របស់អង្គការ UNESCO ហៅកាត់ថា ICHCAP និង APCEIU ដោយមានការសហការជាមួយនឹងការិយាល័យអង្គការ UNESCO ប្រចាំទីក្រុង Almaty, Kathmandu និងទីក្រុងភ្នំពេញ និងការិយាល័យផ្នែកបេតិកភណ្ឌរស់ប្រចាំនៅទីស្នាក់ការកណ្តាលរបស់អង្គការ UNESCO។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស មន្ត្រីអភិវឌ្ឍន៍គោលនយោបាយអប់រំ និងអ្នកគ្រប់គ្រង អ្នកជំនាញផ្នែកវប្បធម៌ និងអ្នកអនុវត្តការងារបេតិកភណ្ឌ និងសមាជិកសហគមន៍មកពីប្រទេសសាកល្បងទាំងប្រាំមួយ (កម្ពុជា កាហ្សាក់ស្ថាន គៀជីស្ថាន នេប៉ាល់ សាធារណរដ្ឋកូរ៉េ និងប្រទេសថៃ) ដែលបានចូលរួមក្នុងដំណើរការនេះ ប្រកបដោយភាពរីករាយ និងការប្តេជ្ញាចិត្តខ្ពស់។ អ្នកចូលរួមទាំងអស់ បានជួយកែលម្អវិធីសាស្ត្រនេះ ដើម្បីបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងថ្នាក់រៀន និងរួមចំណែកដល់ការកែលម្អគុណភាព និងការពារបេតិកភណ្ឌរស់ទាំងនៅក្នុងប្រទេសទាំងនេះ និងបណ្តាប្រទេសផ្សេងៗនៅលើពិភពលោក។

យើងក៏សូមថ្លែងអំណរគុណចំពោះការរួមចំណែកផ្តល់ឧទាហរណ៍ និងករណីសិក្សាពីគម្រោងដែលទទួលបានមូនិធិគាំទ្រពីប្រទេសជប៉ុនរបស់អង្គការ UNESCO "ការសិក្សាជាមួយបេតិកភណ្ឌអរូបីសម្រាប់អនាគតប្រកបដោយចីរភាព" (ឆ្នាំ២០១២-២០១៥) ដែលអនុវត្តនៅក្នុងប្រទេសចំនួនបួន (ប៉ាគីស្ថាន ផៅឡូ អ៊ូសបេគីស្ថាន និងប្រទេសវៀតណាម) ក៏ដូចជាពីការស្ទង់មតិថ្មីៗ "ការបង្រៀន និងការរៀនជាមួយ និងអំពីបេតិកភណ្ឌវប្បធម៌អរូបីនៅតំបន់អាស៊ីប៉ាស៊ីហ្វិក" ដែលអនុវត្តដោយសហការជាមួយនឹង ICHCAP (ឆ្នាំ២០១៩-២០២០)។

សម្រាប់ឈ្មោះបុគ្គលផ្សេងទៀត ដែលបានចូលរួមក្នុងគម្រោងនេះ សូមមើលបញ្ជីឈ្មោះពេញនៅចុងបញ្ចប់សៀវភៅនេះ។

# មាតិកា


កូនសៀវភៅទី១៖ តើបេតិកភណ្ឌរស់ជាអ្វី ? 11

កូនសៀវភៅទី ២៖ ហេតុអ្វីត្រូវបង្រៀនជាមួយបេតិកភណ្ឌរស់ ? 21

កូនសៀវភៅទី ៣៖ ការរៀបចំឱ្យត្រូវគ្នានឹងអាទិភាពអប់រំ 41

កូនសៀវភៅទី ៤៖ វិធីសាស្ត្រប្រាំមួយជំហានសម្រាប់ជាមគ្គុទេសក៍ដល់គ្រូបង្រៀន 61

កូនសៀវភៅទី ៥៖ តួនាទីរបស់ឪពុកម្ដាយអាណាព្យាបាល និងសមាជិកសហគមន៍ 115

កូនសៀវភៅទី ៦៖ តួនាទីរបស់ថ្នាក់គ្រប់គ្រងសាលា 123

កូនសៀវភៅទី ៧៖ តួនាទីរបស់អ្នករៀបចំគោលនយោបាយ 133

កូនសៀវភៅទី ៨៖ ឯកសារ និងធនធាន 141

កូនសៀវភៅទី ៩៖ សាច់រឿងរបស់គ្រូបង្រៀន 225

## អំពីសៀវភៅនេះ

ការដាក់បញ្ចូលបេតិកភណ្ឌរស់ក្នុងកម្មវិធីអប់រំ អាចធ្វើឱ្យការសិក្សាកាន់តែស្របទៅតាមបរិបទ មានភាពប្រទាក់ក្រឡាគ្នា និងមានការចូលរួមពីសិស្ស ហើយក៏ជួយលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការការពារបេតិកភណ្ឌរស់ផងដែរ។
ការអនុវត្តវិធីសាស្ត្រនេះតម្រូវឱ្យមានកិច្ចសហការពីភាគីពាក់ព័ន្ធជាច្រើន។ គ្រូបង្រៀនគឺជាបុគ្គលដែលមានតួនាទីដ៏សំខាន់។ ភាគីពាក់ព័ន្ធផ្សេងទៀត រួមមាន សិស្សានុសិស្ស ឪពុកម្ដាយ អាណាព្យាបាល សមាជិកសហគមន៍ និងគ្រឹះស្ថានវប្បធម៌។ ដើម្បីធ្វើការបញ្ជ្រាបវិធីសាស្ត្រនេះបានគ្រូបង្រៀនត្រូវមានការគាំទ្រពីថ្នាក់គ្រប់គ្រងសាលា និងអ្នករៀបចំគោលនយោបាយ។

## តើនរណាជាអ្នកប្រើសៀវភៅនេះ ?

សៀវភៅនេះគឺជាឯកសារ និងមគ្គុទេសក៍សម្រាប់អ្នកដែលចាប់អារម្មណ៍លើប្រធានបទនេះ។ សៀវភៅនេះអាចឱ្យយើងស្វែងយល់ថា តើហេតុអ្វីបានជាការបញ្ចូលបេតិកភណ្ឌទៅក្នុងការសិក្សា មានប្រយោជន៍សម្រាប់សិស្សានុសិស្ស គ្រូបង្រៀន និងសហគមន៍ពាក់ព័ន្ធ។ សៀវភៅនេះ ក៏មានឯកសារជួយដល់គ្រូបង្រៀន ក្នុងការបង្កើតសកម្មភាពនានា មិនថាសកម្មភាពនោះនៅក្នុងកម្មវិធីសិក្សា ឬក្រៅកម្មវិធីសិក្សានោះទេ ហើយសៀវភៅនេះក៏មានព័ត៌មានសម្រាប់មនុស្សផ្សេងទៀត ដើម្បីជួយគាំទ្រដល់គ្រូបង្រៀនក្នុងការអនុវត្តដំណើរការនេះ។

សៀវភៅនេះមានសារៈសំខាន់សម្រាប់៖

- **គ្រូបង្រៀន** ដោយមិនគិតពីកម្រិតនៃការបង្រៀនឡើយ (បឋមសិក្សា មធ្យមសិក្សា ឬលើសពីនេះ) និងមិនគិតពីមុខវិជ្ជា (មនុស្សសាស្ត្រ មុខវិជ្ជាវិទ្យាសាស្ត្រ វប្បធម៌ ។ល។)
- **ឪពុកម្ដាយ អាណាព្យាបាល** និង**សមាជិកសហគមន៍**
- **ថ្នាក់គ្រប់គ្រងសាលា**
- **អ្នករៀបចំគោលនយោបាយ** នៅតាមនាយកដ្ឋាន និងក្រសួងអប់រំ

នៅក្នុងការប្រើប្រាស់សៀវភៅនេះ មនុស្សគោលដៅមិនចាំបាច់ត្រូវតែស្គាល់ច្បាស់ពីអត្ថន័យនៃបេតិកភណ្ឌវប្បធម៌អរូបី (ICH) នេះឡើយ។

# តើសៀវភៅនេះបង្ហាញអំពីចំណុចអ្វីខ្លះ ?

**កូនសៀវភៅ 1**
### តើបេតិកភណ្ឌរស់ជាអ្វី ?
ពណ៌នាអំពីខ្លឹមសារសំខាន់ៗទាក់ទងនឹងបេតិកភណ្ឌរស់ និងកិច្ចការពារបេតិកភណ្ឌរស់ ហើយតើយើងម្នាក់ៗអាចធ្វើអ្វីខ្លះបាន ដើម្បីការពារបេតិកភណ្ឌទាំងនេះ។

**កូនសៀវភៅ 2**
### ហេតុអ្វីត្រូវបង្រៀនជាមួយបេតិកភណ្ឌរស់ ?
ពន្យល់អត្ថប្រយោជន៍នៃការបញ្ចូលបេតិកភណ្ឌរស់ក្នុងកម្មវិធីសិក្សា។

**កូនសៀវភៅ 3**
### ការរៀបចំឱ្យត្រូវគ្នាជាមួយអាទិភាពអប់រំ
ស្វែងយល់ថាតើ ការបង្រៀន និងការសិក្សាបេតិកភណ្ឌរស់ជួយគាំទ្រដល់អាទិភាពអប់រំផ្សេងទៀតដូចម្ដេចខ្លះ។

**កូនសៀវភៅ 4**
### វិធីសាស្ត្រប្រាំមួយជំហានសម្រាប់ជាមគ្គុទេសក៍ដល់គ្រូបង្រៀន
ជាមគ្គុទេសក៍ដល់គ្រូបង្រៀន ទៅតាមវិធីសាស្ត្រប្រាំមួយជំហាន ក្នុងការរៀបចំផែនការមេរៀន និងសកម្មភាពក្នុងថ្នាក់រៀន ដែលមានបញ្ចូលបេតិកភណ្ឌរស់។

**កូនសៀវភៅ 5**
### តួនាទីរបស់ឪពុកម្ដាយ អាណាព្យាបាល និងសមាជិកសហគមន៍
ពណ៌នាថា តើឪពុកម្ដាយ អាណាព្យាបាល និងសមាជិកសហគមន៍ អាចការពារបេតិកភណ្ឌរស់ និងជួយគាំទ្រដល់ការអប់រំរបស់កុមារតាមវិធីណាខ្លះ។

**កូនសៀវភៅ 6**
### តួនាទីរបស់ថ្នាក់គ្រប់គ្រងសាលា
ពន្យល់ថា តើថ្នាក់គ្រប់គ្រងសាលាធ្វើយ៉ាងណាអាចជួយគាំទ្រដល់គ្រូបង្រៀន រួចជួយផ្សារភ្ជាប់សាលាជាមួយនឹងសហគមន៍មូលដ្ឋាន។

**កូនសៀវភៅ 7**
### តួនាទីរបស់អ្នករៀបចំគោលនយោបាយ
ពន្យល់ថាតើអ្នករៀបចំគោលនយោបាយអាចធ្វើដូចម្ដេចខ្លះដើម្បីជួយគាំទ្របេតិកភណ្ឌរស់ និងលើកកម្ពស់គុណភាពអប់រំ។

**កូនសៀវភៅ 8**
### ឯកសារ និងធនធាន
ផ្តល់ឯកសារ ករណីសិក្សា និងឧទាហរណ៍ជាក់ស្តែង។

**កូនសៀវភៅ 9**
### សាច់រឿងរបស់គ្រូបង្រៀន
ផ្តល់ឧទាហរណ៍បង្ហាញពីបទពិសោធន៍របស់គ្រូបង្រៀន

នៅក្នុងសៀវភៅនេះ មានករណីសិក្សា និងឧទាហរណ៍អំពីជីវិតពិតជាច្រើន ដែលបានចងក្រងចេញពីតំបន់អាស៊ីប៉ាស៊ីហ្វិក ក៏ដូចជា ឯកសារ និងធនធានចាំបាច់ ដែលអ្នកប្រើប្រាស់អាចយោងតាម នៅពេលបន្តការងារឆ្ពោះទៅមុខជាមួយនឹងសៀវភៅនេះ។

វីដេអូភាគគំនូរជីវចលអំពី "***ការសិក្សាបេតិកភណ្ឌវប្បធម៌អរូបីនៅអាស៊ីប៉ាស៊ីហ្វិក***" Click និងកម្មវិធីសិក្សាអនឡាញដោយខ្លួនឯងអំពី "***ការបញ្ចូលបេតិកភណ្ឌរស់ក្នុងថ្នាក់រៀននៅអាស៊ីប៉ាស៊ីហ្វិក***" Click ត្រូវបានបង្កើតឡើង ដើម្បីជាការបំពេញបន្ថែមសម្រាប់សៀវភៅនេះ។

# របៀបប្រើប្រាស់សៀវភៅ

សៀវភៅនេះមានកូនសៀវភៅមួយចំនួនដែលអាចយកទៅប្រើប្រាស់សម្រាប់ការពិគ្រោះយោបល់ដាច់ដោយឡែក។ អ្នកអាចផ្តល់អាទិភាពលើកូនសៀវភៅណាមួយក៏បាន ដែលចាំបាច់បំផុតសម្រាប់អ្នកដោយផ្អែកលើតួនាទីរបស់អ្នក។ ប៉ុន្តែ ទោះជាយ៉ាងណា អ្នកត្រូវបានស្វាគមន៍ឱ្យប្រើប្រាស់សៀវភៅទាំងមូល។ ការស្វែងយល់បន្ថែមអំពីតួនាទីរបស់អ្នកដទៃនឹងជួយឱ្យអ្នកអាចស្វែងរកវិធីសាស្ត្រកាន់តែល្អប្រសើរក្នុងការសហការជាមួយនឹងពួកគេ។

អ្នកអាចទស្សនា ***វីដេអូគំនូរជីវចល*** CLICK វីដេអូគំនូរជីវចលសម្រាប់ការណែនាំខ្លីអំពីចំណុចសំខាន់ៗនៃសៀវភៅនេះ។

អ្នកអាចអនុវត្តតាម ***វគ្គសិក្សាអនឡាញ*** CLICK ដើម្បីធ្វើផែនការមេរៀនដំបូងរបស់អ្នក ទៅតាមជំហានម្តងមួយៗ។ នៅពេលបញ្ចប់ការសិក្សាវគ្គអនឡាញនេះ អ្នកនឹងទទួលបានវិញ្ញាបនបត្របញ្ជាក់ការសិក្សា។



ការបញ្ចូលបេតិកភណ្ឌរស់
ទៅក្នុងការសិក្សានៅអាស៊ីប៉ាស៊ីហ្វិក
សៀវភៅណែនាំ

កូនសៀវភៅ

1

# តើ
# បេតិកភណ្ឌរស់
# ជាអ្វី?

**សៀវភៅនេះ** មានបំណងជួយគាំទ្រគ្រូបង្រៀន អ្នកគ្រប់គ្រងក្នុងវិស័យអប់រំ និងសហគមន៍ ក្នុងការដាក់បញ្ចូលបេតិកភណ្ឌក្នុងស្រុក ទៅក្នុងសកម្មភាពសិក្សា ឲ្យកាន់តែមានភាពប្រទាក់ក្រឡាគ្នា និងមានការចូលរួមកាន់តែច្រើនពីសំណាក់សិស្សានុសិស្ស និងការពារបេតិកភណ្ឌវប្បធម៌។

សៀវភៅនេះ មានកូនសៀវភៅចំនួនប្រាំបួន៖

- កូនសៀវភៅ 1 **តើបេតិកភណ្ឌរស់ជាអ្វី?**
- កូនសៀវភៅ 2 ហេតុអ្វីត្រូវបង្រៀនជាមួយបេតិកភណ្ឌរស់?
- កូនសៀវភៅ 3 ការរៀបចំឱ្យត្រូវគ្នាជាមួយអាទិភាពអប់រំ
- កូនសៀវភៅ 4 វិធីសាស្ត្រប្រាំមួយជំហានសម្រាប់ជាមគ្គុទេសក៍ដល់គ្រូបង្រៀន
- កូនសៀវភៅ 5 តួនាទីរបស់ឪពុកម្ដាយ អាណាព្យាបាល និងសមាជិកសហគមន៍
- កូនសៀវភៅ 6 តួនាទីរបស់ថ្នាក់គ្រប់គ្រងសាលា
- កូនសៀវភៅ 7 តួនាទីរបស់អ្នករៀបចំគោលនយោបាយ
- កូនសៀវភៅ 8 ឯកសារ និងធនធាន
- កូនសៀវភៅ 9 សាច់រឿងរបស់គ្រូបង្រៀន

កូនសៀវភៅ

1

# តើបេតិកភណ្ឌរស់ជាអ្វី?

កូនសៀវភៅនេះមានការពន្យល់ថាតើបេតិកភណ្ឌរស់ជាអ្វី ហើយហេតុអ្វីបានជាត្រូវការពារបេតិកភណ្ឌរស់ និងអំពីរបៀបការពារ។

កូនសៀវភៅ "បេតិកភណ្ឌរស់ជាអ្វី?" មានបីផ្នែក៖

- តើបេតិកភណ្ឌរស់ជាអ្វី?
- សហគមន៍បេតិកភណ្ឌរស់
- កិច្ចការពារបេតិកភណ្ឌវប្បធម៌អរូបី



## ១.១ តើបេតិកភណ្ឌរស់ជាអ្វី?

បេតិកភណ្ឌគឺជាកេរតំណែលរបស់យើងពីអតីតកាល ជាអ្វីដែលយើងរស់នៅជាមួយសព្វថ្ងៃ ហើយជាអ្វីដែលយើងនឹងបញ្ជូនទៅឱ្យមនុស្សជំនាន់ក្រោយទៀត។ បេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិរបស់យើង គឺជាប្រភពដែលមិនអាចជំនួសបានឡើយសម្រាប់ជីវិត សុខុមាលភាព និងកម្លាំងចិត្តរបស់យើង។ និយាយម្យ៉ាងទៀត បេតិកភណ្ឌគឺជាអ្វីៗទាំងឡាយដែលអ្នកចង់ផ្សព្វផ្សាយទៅឱ្យកូនៗ និងចៅៗរបស់អ្នក។

### តើអ្វីខ្លះដែលអ្នកចាត់ទុកថាជា "បេតិកភណ្ឌ" របស់អ្នក?

បេតិកភណ្ឌវប្បធម៌មានភាពចម្រុះខ្លាំងណាស់ ប៉ុន្តែអាចយកមកចាត់ថ្នាក់ចេញជាពីរប្រភេទសំខាន់ៗ៖ (១) រូបី និង (២) អរូបី។

## បេតិកភណ្ឌវប្បធម៌រូបី៖

- បេតិកភណ្ឌវប្បធម៌ដែលអាចចល័តបាន៖ វត្ថុ គំនូរ ចម្លាក់ កាក់ សាស្ត្រាស្លឹករឹត ។ល។
- បេតិកភណ្ឌវប្បធម៌ដែលមិនអាចចល័តបាន៖ ប្រាសាទ ទីតាំងបុរាណវិទ្យា ។ល។
- បេតិកភណ្ឌវប្បធម៌ក្រោមទឹក៖ នាវាលិច សំណង់បាក់បែក និងទីក្រុងលិចក្រោមទឹក។ល។
- ទីតាំងធម្មជាតិ ដែលមានទំនាក់ទំនងជាមួយនឹងសកម្មភាពរបស់មនុស្ស ហើយដែលឆ្លុះបញ្ចាំងពីវប្បធម៌របស់ពួកគេ។



## បេតិកភណ្ឌវប្បធម៌អរូបី៖

- ...ជាទម្លាប់ ការនិយាយស្តី ចំណេះដឹង និងជំនាញ ដែល**កំពុងប្រតិបត្តិ** និង**ផ្ទេរ**ពីមួយជំនាន់ទៅមួយជំនាន់។ឧទាហរណ៍ រួមមាន៖ របាំ ពិធីសាសនា ពិធីបុណ្យ ការនិទានរឿង សិប្បកម្ម ។ល។.
- ...ជួយឱ្យមនុស្សស្គាល់ពី**ចីរភាព អត្តសញ្ញាណ** និង**ភាពជាចំណែកមួយ**នៅក្នុងសហគមន៍មួយ ឬច្រើន។.
- ...មាន**លក្ខណៈជាសហគមន៍**។ មានតែ សមាជិកសហគមន៍ប៉ុណ្ណោះ អាចសម្រេចចិត្តថាតើ ការនិយាយស្តីណាមួយ ជាផ្នែកមួយនៃបេតិកភណ្ឌរស់របស់ខ្លួនដែរ ឬអត់ ហើយថាតើពួកគេប្រតិបត្តិការនិយាយស្តីនោះ តាមរបៀបណា មិនមែនអ្នកជំនាញ ឬអាជ្ញាធរជាអ្នកសម្រេចនោះទេ។
- ...គឺជា**បេតិកភណ្ឌរស់**។ វាមានលក្ខណៈជាប្រពៃណី ប៉ុន្តែ ក៏ទាន់សម័យដែរ។ មានលក្ខណៈ**ប្រែប្រួល** ហើយរបៀបរបបនៃការប្រតិបត្តិ ក៏ប្រែប្រួលទៅតាមពេលវេលា ហើយត្រូវបានយកទៅបង្កើតឡើងវិញជាប្រចាំ។ បេតិកភណ្ឌរស់ពុំមានទម្រង់ "យថាភូត" ណាមួយនោះឡើយ។
- ...មាន**គ្រប់ទីកន្លែង**។ មនុស្សគ្រប់រូប មិនថារស់នៅទីណា ធ្វើអ្វី និងជានរណានោះទេ សុទ្ធតែមានបេតិកភណ្ឌវប្បធម៌អរូបី។ ពួកគេយកបេតិកភណ្ឌរស់តាមខ្លួន មិនថាពួកគេទៅទីណានោះឡើយ។
- ...ត្រូវបាន **ចែករំលែក**។ ធាតុផ្សំដែលស្រដៀងគ្នា អាចត្រូវបានយកទៅប្រតិបត្តិដោយមនុស្សនៅក្នុងសាសនា ឬប្រទេសផ្សេង។

**ពាក្យ "បេតិកភណ្ឌវប្បធម៌រូបី" និង "បេតិកភណ្ឌរស់" អាចប្រើជំនួសគ្នាបាន។**

## អនុសញ្ញាអង្គការយូណេស្កូឆ្នាំ២០០៣៖ អនុសញ្ញាអន្តរជាតិដើម្បីការពារបេតិកភណ្ឌរស់

កិច្ចការពារបេតិកភណ្ឌវប្បធម៌អរូបី ត្រូវបានកំណត់ច្បាប់ជាអន្តរជាតិតាមរយៈអនុសញ្ញា ឆ្នាំ២០០៣ សម្រាប់កិច្ចការពារបេតិកភណ្ឌវប្បធម៌អរូបី។

- យោងតាមអនុសញ្ញាឆ្នាំ២០០៣ (មាត្រា ២) បេតិកភណ្ឌវប្បធម៌អរូបី "មានន័យថា ជាទម្លាប់ការអនុវត្ត ការតំណាង ការនិយាយស្តី ចំណេះដឹង ជំនាញ ក៏ដូចជាឧបករណ៍ វត្ថុ សិប្បនិម្មិត និងលំហវប្បធម៌ ដែលពាក់ព័ន្ធនឹងចំណុចខាងដើម ដែលសហគមន៍នានា ក្រុមមនុស្ស ហើយពេលខ្លះ ក្រុមមនុស្សទទួលស្គាល់វាថា ជាផ្នែកមួយនៃបេតិកភណ្ឌវប្បធម៌របស់ពួកគេ។ បេតិកភណ្ឌវប្បធម៌អរូបីនេះ បានផ្ទេរពីមនុស្សមួយជំនាន់ទៅមួយជំនាន់ ហើយសហគមន៍ ឬប្រជាជន បានបង្កើតកែច្នៃឡើងវិញម្តងហើយម្តងទៀតជាប់ជាប្រចាំ ដើម្បីឆ្លើយតបទៅនឹងមជ្ឈដ្ឋានរបស់ខ្លួន និងទំនាក់ទំនងទៅវិញទៅមករបស់ពួកគេជាមួយនឹងធម្មជាតិ និងប្រវត្តិសាស្ត្រ ក៏ដូចជាជួយឱ្យពួកគេស្គាល់ពីអត្តសញ្ញាណ និងចីរភាព ហេតុដូច្នេះ ជួយជំរុញឱ្យមានការគោរពចំពោះភាពផ្សេងៗគ្នានៃវប្បធម៌ និងភាពច្នៃប្រឌិតរបស់មនុស្សជាតិ។
- រដ្ឋភាគី ពោលគឺ បណ្តាប្រទេសហត្ថលេខីនៃអនុសញ្ញានេះ មានទំនួលខុសត្រូវចាត់វិធានការនានាដើម្បីធ្វើយ៉ាងណាឲ្យប្រាកដថា សហគមន៍ ប្រជាជន និងក្រុមសម្ព័ន្ធនានា ដែលស្ថិតនៅលើទឹកដីរបស់ខ្លួន អាចបន្តប្រតិបត្តិ និងផ្ទេរបេតិកភណ្ឌវប្បធម៌អរូបីរបស់ពួកគេក្នុងលក្ខណៈប្រកបដោយអត្ថន័យ។

ដើម្បីស្វែងយល់ថាតើប្រទេសរបស់អ្នកបាន ឬមិនបានផ្តល់សច្ចាប័នលើអនុសញ្ញាឆ្នាំ២០០៣ ឬអត់នោះ សូមចូលមើលក្នុងគេហទំព័រផ្លូវការរបស់អនុសញ្ញានេះ៖ CLICK









# បេតិកភណ្ឌរស់គ្របដណ្តប់លើវិស័យជាច្រើន

អនុសញ្ញាឆ្នាំ២០០៣ ផ្តោតលើវិស័យធំៗចំនួនប្រាំរបស់បេតិកភណ្ឌវប្បធម៌អរូបី៖

***ប្រពៃណីប្រើពាក្យសម្តី៖*** សុភាសិត ពាក្យបណ្តៅ រឿងព្រេង ចម្រៀងកុមារ រឿងព្រេងនិទាន ទេវកថា ចម្រៀងវីរភាព និងកំណាព្យ មន្តស្នេហ៍ ធម៌អធិដ្ឋាន ស្មូត្រ ចម្រៀង ការសម្តែងល្ខោន។ល។

***សិល្បៈទស្សនីយភាព៖*** តន្ត្រីជាសំឡេង ឬឧបករណ៍ភ្លេង របាំ ល្ខោន ទម្រង់ភាសា សៀក ចម្រៀងតាមវគ្គ និងទម្រង់ខ្លះៗនៃការនិទានរឿង ។ល។

***ចំណេះដឹងអំពីធម្មជាតិ និងសកលលោក៖*** ចំណេះដឹងអំពីសត្វ និងរុក្ខជាតិក្នុងស្រុក ប្រព័ន្ធព្យាបាលបែបបុរាណ ទម្លាប់ប្រតិបត្តិដែលឆ្លុះបញ្ចាំងពីសាសនា និងទស្សនៈពិភពលោក។ល។

***ទម្លាប់អនុវត្តក្នុងសង្គម ពិធីសាសនា ពិធីបុណ្យផ្សេងៗ៖*** សកម្មភាព ដែលបង្កើតជារចនាសម្ព័ន្ធនៃជីវិតរស់នៅរបស់សហគមន៍ និងប្រជាជន ដែលផ្សារភ្ជាប់នឹងវដ្តជីវិតរបស់បុគ្គល និងប្រជាជន (ការកើត ការរៀបអាពាហ៍ពិពាហ៍ ពិធីទទួលស្គាល់ ឬពិធីបញ្ចុះសព) ក្បួនដង្ហែបុណ្យ ឬពិធីបុណ្យ កាលវិភាគកសិកម្ម និងប្តូរវេនរដូវកាល និងប្រព័ន្ធពេលវេលាផ្សេងទៀត។

***សិប្បកម្មប្រពៃណី៖*** ចំណេះដឹង និងជំនាញក្នុងការផលិត និងប្រើប្រាស់វត្ថុនានា រួមមាន តម្បាញ និងជំនាញសិប្បកម្មវាយនភ័ណ្ឌផ្សេងទៀត ការឆ្លាក់ ការស្មូន ជាងដែក និងបច្ចេកទេសសំណង់។ល។

បណ្តាប្រទេសមួយចំនួន កំណត់យកវិស័យសំខាន់ផ្សេងទៀតដូចជាកីឡា និងល្បែងប្រជាប្រិយ និងអាហារូបត្ថម្ភ ជាដើម។

ជាតុផ្សំ និងការអនុវត្តក្នុងបេតិកភណ្ឌរស់ជាច្រើនមាននៅក្នុងវិស័យមួយចំនួន។ ឧទាហរណ៍ "រ៉ាមលីឡា ជាការសម្តែងតាមបែបបុរាណពីរឿងរាមាយណៈ" ដែលប្រតិបត្តិច្រើននៅប្រទេសឥណ្ឌា នៅក្នុងវិស័យចំនួនប្រាំ។ សិល្បៈទស្សនីយភាពមួយប្រភេទដោយមាន **ចម្រៀង និងតន្ត្រី** ហើយក៏ស្ថិតក្រោមវិស័យ **ប្រពៃណីប្រើពាក្យសម្តី** ដែរ ពីព្រោះការបញ្ចូលសំឡេង ការនិយាយតាមរបៀបនិទានរឿង និងការសន្ទនា។ រឿងនេះក៏មានបញ្ចូលនូវទម្លាប់ប្រតិបត្តិដែលឆ្លុះបញ្ចាំងឱ្យឃើញពីសាសនា និងទស្សនៈពិភពលោក ដូច្នេះ វាក៏ជា **ចំណេះដឹងអំពីសកលលោក** ផងដែរ ហើយ ត្រូវបានយកទៅសម្តែងនៅទូទាំងភាគខាងជើងប្រទេសឥណ្ឌាអំឡុងពិធីបុណ្យ Dussehra ដែលរៀបចំជារៀងរាល់ឆ្នាំនៅសរទរដូវ ដូច្នេះវាក៏ជាផ្នែកមួយនៃ**វិស័យពិធីបុណ្យ**ដែរ។ ជាងនេះទៅទៀត ការរៀបចំសម្តែង តម្រូវឱ្យមាន **សិប្បកម្មប្រពៃណី** ជាពិសេស គឺចំណេះដឹង និងជំនាញ ទាក់ទងនឹងការផលិតរបាំងមុខ សម្លៀកបំពាក់ និងគ្រឿងតុបតែងឆាក ដែលចាំបាច់។

សូមមើល "កូនសៀវភៅទី ៨៖ ឯកសារ និងធនធាន" ដើម្បីស្វែងយល់អំពីជាតុផ្សំផ្សេងទៀតនៃបេតិកភណ្ឌរស់។



## ១.២ សហគមន៍បេតិកភណ្ឌរស់

នៅក្នុងបរិបទអនុសញ្ញាឆ្នាំ២០០៣ សហគមន៍គឺជាមនុស្សមួយក្រុម (ធំឬតូច) ដែលអនុវត្តប្រតិបត្តិ ឬមានអារម្មណ៍ផ្សារភ្ជាប់ទៅនឹងធាតុផ្សំជាក់លាក់ណាមួយនៃបេតិកភណ្ឌរស់។ បេតិកភណ្ឌនេះ គឺជាផ្នែកមួយនៃអត្តសញ្ញាណរបស់ពួកគេ។ ពួកគេប្រតិបត្តិ និងចម្លងបេតិកភណ្ឌនេះ ទៅកាន់មនុស្សជំនាន់ក្រោយ។

សហគមន៍ជាអ្នកសម្រេចចិត្តថាតើ ធាតុផ្សំណាមួយនៃបេតិកភណ្ឌវប្បធម៌អរូបីត្រូវប្រតិបត្តិយ៉ាងណា ថាតើបេតិកភណ្ឌនោះ គួរត្រូវបានការពារដែរឬទេ ហើយការពារតាមវិធីណា ហើយថាតើការកែប្រែអ្វីខ្លះដែលអាចទទួលយកបាន។

មនុស្សម្នាក់អាចជាផ្នែកមួយរបស់សហគមន៍មួយ ឬសហគមន៍ច្រើន។ ឧទាហរណ៍ បុគ្គលនោះអាចប្រារព្ធពិធីបានពេញមួយឆ្នាំជាមួយនឹងមនុស្សមកពីភូមិជាមួយគ្នា ហើយក៏អាចជាផ្នែកមួយនៃក្រុមកាន់តែតូចជាងនេះ ដែលមានជំនាញលើសិប្បកម្ម ឬសិល្បៈទស្សនីយភាពណាមួយ។

បេតិកភណ្ឌវប្បធម៌អរូបី មានសារៈសំខាន់ចំពោះការអភិវឌ្ឍប្រកបដោយចីរភាពក្នុងសហគមន៍ សម្រាប់គ្រប់វិស័យទាំងអស់ ដូចជា សង្គម សេដ្ឋកិច្ច និងបរិស្ថាន។ បេតិកភណ្ឌវប្បធម៌អរូបី មានទំនាក់ទំនងជាមួយនឹងការអភិវឌ្ឍប្រកបដោយចីរភាព ពីព្រោះ បេតិកភណ្ឌនេះ៖

- ផ្តល់ធនធានសម្រាប់ការសិក្សាពេញមួយជីវិត និងជំនាញ។
- រួមចំណែកដល់ការកសាងភាពស្អិតរមួតក្នុងសង្គម និងសន្តិភាព។
- លើកកម្ពស់សុខភាព និងសុខុមាលភាពឲ្យបានល្អប្រសើរ។
- ផ្តល់ដំណោះស្រាយដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមផ្នែកបរិស្ថាន។
- ជាកំណប់សម្រាប់នវានុវត្តន៍ និងភាពច្នៃប្រឌិត និងជាប្រភពនៃមុខរបរ។

**តើអ្នកអាចរៀបរាប់ពីទម្លាប់ប្រតិបត្តិណាខ្លះ ដែលមានសារៈសំខាន់សម្រាប់អ្នក? នរណាជាផ្នែកមួយនៃសហគមន៍របស់អ្នក?**

## ១.៣. កិច្ចការពារបេតិកភណ្ឌវប្បធម៌អរូបី

បេតិកភណ្ឌវប្បធម៌អរូបីមួយចំនួនកំពុងស្ថិតក្រោមការគំរាមកំហែង ជិតបាត់បង់ដោយសារៈ

- សកលភាវូបនីយកម្មវប្បធម៌ (ការធ្វើឱ្យវប្បធម៌មានលក្ខណៈដូចគ្នា ដែលធ្វើឱ្យវប្បធម៌មានឯកលក្ខណភាពទូទាំងសកលលោក)។
- កង្វះការគាំទ្រ ការយល់ដឹង និងការឱ្យតម្លៃចំពោះបេតិកភណ្ឌរស់។

ប្រសិនបើបេតិកភណ្ឌវប្បធម៌អរូបី ពុំត្រូវបានរក្សាការពារទេ វាអាចនឹងបាត់បង់ជារៀងរហូត ឬធ្វើឱ្យមានតែនៅក្នុងអតីតកាលប៉ុណ្ណោះ។

"កិច្ចការពារ" បេតិកភណ្ឌវប្បធម៌អរូបី មានន័យថា ជាការធានា និងការថែរក្សាបេតិកភណ្ឌឱ្យមានភាពរស់រវើក និងក្លាយជាផ្នែកមួយនៅក្នុងសកម្មភាពជីវិតរបស់សហគមន៍។ ការថែរក្សានេះមានគោលដៅធ្វើយ៉ាងណាឱ្យបេតិកភណ្ឌវប្បធម៌អរូបីមានភាពរស់រាន ពោលគឺ ការធានាថាបេតិកភណ្ឌ នេះអាចប្រតិបត្តិតាម និងធ្វើការសិក្សាបន្តជាប្រចាំ ហើយបន្តនៅមានអត្ថន័យសម្រាប់សហគមន៍ដែលប្រតិបត្តិបេតិកភណ្ឌនេះ។ ដូច្នេះ សកម្មភាពការពារ ត្រូវមានការចូលរួមពីសំណាក់សហគមន៍ ក្រុមនុស្ស ហើយក្នុងករណីសមស្របពីបុគ្គលនានាដែលមានកាតព្វកិច្ចការពារបេតិកភណ្ឌនោះ។

> ប្រសិនបើបេតិកភណ្ឌវប្បធម៌អរូបី ពុំត្រូវបានរក្សាការពារទេ វាអាចនឹងបាត់បង់ជារៀងរហូត ឬធ្វើឱ្យមានតែនៅក្នុងអតីតកាលប៉ុណ្ណោះ។

វិធានការរួមមានៈ

- ការចងក្រងជាឯកសារ បញ្ជីសារពើភ័ណ្ឌ និងការស្រាវជ្រាវ
- ការស្តារឡើងវិញនូវទិដ្ឋភាពមួយចំនួនរបស់បេតិកភណ្ឌរស់
- ការផ្សព្វផ្សាយពីអត្ថន័យ ចំណេះដឹង និងជំនាញអំពីបេតិកភណ្ឌរស់

ដើម្បីការពារបេតិកភណ្ឌវប្បធម៌អរូបី និងថែរក្សាវប្បធម៌ចម្រុះ យើងមិនត្រឹមតែគោរព និងឱ្យតម្លៃបេតិកភណ្ឌរស់របស់យើងតែប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវគោរព និងឱ្យតម្លៃបេតិកភណ្ឌរស់របស់មនុស្សដទៃទៀតផងដែរ។





## ការផ្សព្វផ្សាយពីអត្ថន័យ ចំណេះដឹង និងជំនាញ

គ្រប់ទីកន្លែងនៅក្នុងពិភពលោកនេះ សហគមន៍ ក្រុមមនុស្ស និងបុគ្គលម្នាក់ៗ ដែលអនុវត្ត តាមប្រពៃណី និងទំនៀមទម្លាប់នានា មានប្រព័ន្ធរៀងៗខ្លួនសម្រាប់ការផ្ទេរចំណេះដឹង និងជំនាញរបស់ពួកគេ (ក្នុងទម្រង់ជាការអប់រំក្រៅប្រព័ន្ធ)។ កាលពីអតីតកាល ការផ្សព្វផ្សាយ ជាធម្មតាធ្វើឡើងតាមរយៈការនិយាយតគ្នាពីមាត់មួយទៅមាត់មួយ (ជាជាងការប្រើប្រាស់អត្ថបទជាលាយលក្ខណ៍អក្សរ)។ សព្វថ្ងៃ ទម្រង់នៃការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ក៏ដើរតួនាទីជាមធ្យោបាយយ៉ាងសំខាន់សម្រាប់កិច្ចការពារ និងការផ្សព្វផ្សាយបេតិកភណ្ឌវប្បធម៌អរូបី។

"ដើម្បីការពារបេតិកភណ្ឌវប្បធម៌អរូបី និងថែរក្សាវប្បធម៌ចម្រុះ យើងមិនត្រឹមតែគោរព និងឱ្យតម្លៃបេតិកភណ្ឌរស់របស់យើងតែប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវគោរព និងឱ្យតម្លៃបេតិកភណ្ឌរស់របស់មនុស្សដទៃទៀតផងដែរ។"

## ការផ្សារភ្ជាប់សហគមន៍ និងសាលា ពង្រឹងដល់កិច្ចការពារ

ដើម្បីឱ្យការងារខិតខំប្រឹងប្រែងក្នុងកិច្ចការពារទទួលបានជោគជ័យ មនុស្សវ័យក្មេងចាំបាច់ត្រូវចេះចាប់អារម្មណ៍ចំពោះបេតិកភណ្ឌរស់របស់ខ្លួន ហើយស្គាល់ពីសារៈសំខាន់របស់វា។ សាលា និងគ្រូបង្រៀន ដើរតួនាទីសំខាន់នៅក្នុងការណែនាំមនុស្សវ័យក្មេង ឱ្យស្គាល់ពីបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងសហគមន៍របស់ខ្លួន និងនៅខាងក្រៅ ហើយលើកទឹកចិត្តឱ្យពួកគេមានចំណាប់អារម្មណ៍នៅក្នុងបេតិកភណ្ឌវប្បធម៌អរូបីរបស់ខ្លួន។ តួនាទីរបស់សាលា និងគ្រូបង្រៀនកាន់តែមានសារៈសំខាន់ខ្លាំង នៅពេលផ្សព្វផ្សាយក្នុងសហគមន៍មិនអាចធ្វើទៅបាន ឬមានភាពទន់ខ្សោយ។ ក្នុងពេលដែលអាចធ្វើទៅបាន ការផ្សារភ្ជាប់ទំនាក់ទំនងរវាងសាលា និងសហគមន៍គួរទទួលបានការលើកទឹកចិត្ត។ ឧទាហរណ៍ អ្នកប្រតិបត្តិពីសហគមន៍មូលដ្ឋានអាចទទួលការអញ្ជើញឱ្យមកសាលា ដើម្បីបង្ហាញជំនាញរបស់ពួកគាត់  ប្រាប់ពីដំណើររឿង និងចែករំលែកបទពិសោធន៍របស់ពួកគាត់។ ការជួបប្រាស្រ័យទាក់ទងគ្នានេះមិនត្រឹមតែជួយការពារ និងផ្សព្វផ្សាយអំពីបេតិកភណ្ឌវប្បធម៌អរូបីប៉ុណ្ណោះទេ ប៉ុន្តែក៏អាចមានប្រយោជន៍សម្រាប់សិស្ស ក្នុងការធ្វើឱ្យខ្លួនឯងស្គាល់ពីអត្តសញ្ញាណ និងតម្លៃរបស់ខ្លួន ហើយជួយឱ្យមានទស្សនៈវិជ្ជមានចំពោះពិភពលោក និងទម្លាប់វិជ្ជមានផងដែរ។



**គន្លឹះ សំខាន់ៗ**

- បេតិកភណ្ឌរស់មានសារៈសំខាន់។ បេតិកភណ្ឌរស់ជួយឱ្យយើងកំណត់អត្តសញ្ញាណរបស់យើង ហើយរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព។
- សហគមន៍ដែលអនុវត្តប្រតិបត្តិ និងផ្សព្វផ្សាយពីបេតិកភណ្ឌរបស់ខ្លួន គឺជាបេះដូងនៃកិច្ចការពារបេតិកភណ្ឌរស់។
- យើងចាំបាច់ត្រូវតែគោរពបេតិកភណ្ឌរបស់យើង ក៏ដូចជាបេតិកភណ្ឌរបស់អ្នកដទៃ។
- ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធដើរតួនាទីសំខាន់សម្រាប់ការពារបេតិកភណ្ឌរស់។


adidas



**ការបញ្ចូលបេតិកភណ្ឌរស់**
ទៅក្នុងការសិក្សានៅអាស៊ីប៉ាស៊ីហ្វិក
**សៀវភៅណែនាំ**

**កូនសៀវភៅ**

# 2

# ហេតុអ្វីត្រូវបង្រៀន ជាមួយបេតិកភណ្ឌរស់ ?

**សៀវភៅនេះ** មានបំណងជួយគាំទ្រគ្រូបង្រៀន អ្នកគ្រប់គ្រងក្នុងវិស័យអប់រំ និងសហគមន៍ ក្នុងការដាក់បញ្ចូលបេតិកភណ្ឌក្នុងស្រុក ទៅក្នុងសកម្មភាពសិក្សា ឲ្យកាន់តែមានភាពប្រទាក់ក្រឡាគ្នា និងមានការចូលរួមកាន់តែច្រើនពីសំណាក់សិស្សានុសិស្ស និងការពារបេតិកភណ្ឌវប្បធម៌។

សៀវភៅនេះ មានកូនសៀវភៅចំនួនប្រាំបួន៖

- កូនសៀវភៅ 1 តើបេតិកភណ្ឌរស់ជាអ្វី ?
- កូនសៀវភៅ 2 **ហេតុអ្វីត្រូវបង្រៀនជាមួយបេតិកភណ្ឌរស់ ?**
- កូនសៀវភៅ 3 ការរៀបចំឱ្យត្រូវគ្នាជាមួយអាទិភាពអប់រំ
- កូនសៀវភៅ 4 វិធីសាស្ត្រប្រាំមួយជំហានសម្រាប់ជាមគ្គុទេសក៍ដល់គ្រូបង្រៀន
- កូនសៀវភៅ 5 តួនាទីរបស់ឪពុកម្ដាយ អាណាព្យាបាល និងសមាជិកសហគមន៍
- កូនសៀវភៅ 6 តួនាទីរបស់ថ្នាក់គ្រប់គ្រងសាលា
- កូនសៀវភៅ 7 តួនាទីរបស់អ្នករៀបចំគោលនយោបាយ
- កូនសៀវភៅ 8 ឯកសារ និងធនធាន
- កូនសៀវភៅ 9 សាច់រឿងរបស់គ្រូបង្រៀន

កូនសៀវភៅ

2

# ហេតុអ្វីត្រូវបង្រៀនជាមួយបេតិកភណ្ឌរស់?

កូនសៀវភៅនេះ រៀបរាប់លម្អិតអំពីអត្ថប្រយោជន៍នៃការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងសាលា ហើយពន្យល់ពីភាពខុសគ្នារវាងការបង្រៀន ***អំពី*** បេតិកភណ្ឌវប្បធម៌អរូបី និងការបង្រៀន ***ជាមួយ*** វប្បធម៌អរូបី។

កូនសៀវភៅទីពីរ "ហេតុអ្វីត្រូវបង្រៀនជាមួយបេតិកភណ្ឌរស់?" មានបួនផ្នែក៖

- បេតិកភណ្ឌរស់នៅក្នុងវិស័យអប់រំ
- ការសិក្សាអំពីបេតិកភណ្ឌរស់
- ការសិក្សាជាមួយបេតិកភណ្ឌរស់
- អត្ថប្រយោជន៍នៃការបង្រៀន និងការសិក្សាអំពី និងជាមួយ បេតិកភណ្ឌរស់





## ២.១ បេតិកភណ្ឌរស់នៅក្នុងវិស័យអប់រំ

សាលាជួយឱ្យសិស្សទទួលបានជំនាញ និងចំណេះដឹង ដែលធ្វើឱ្យពួកគេអាចប្រើប្រាស់ សក្ដានុពលរបស់ខ្លួនបានពេញលេញ និងរួមចំណែកដល់សង្គមនាពេលក្រោយ។ ទោះជាយ៉ាងណា ការសិក្សាមិនមែនកើតឡើងតែនៅក្នុងសាលាប៉ុណ្ណោះទេ។ ការសិក្សាជាដំណើរការពេញមួយជីវិត ដូច្នេះ ការសិក្សាក៏កើតឡើងនៅផ្ទះ និងក្នុងសហគមន៍ផងដែរ។ បុគ្គលនានា ទាំងសិស្សានុសិស្ស និងអ្នកអប់រំ ទទួលបានជំនាញ និងចំណេះដឹងជាច្រើននៅខាងក្រៅសាលា ហើយថែមទាំងនាំយកចំណេះដឹង និងជំនាញទាំងនេះមកសាលាវិញផងដែរ។

ទោះជាយ៉ាងណា ប្រព័ន្ធអប់រំជាច្រើនមិនគិតដល់ចំណេះដឹង និងជំនាញដែលបានទទួលនៅផ្ទះឡើយ ដែលបង្កើតឱ្យមាននូវ "ការដាច់ពីគ្នា" រវាងខ្លឹមសារដែលបានបង្រៀននៅសាលា និងខ្លឹមសារដែលបានរៀននៅផ្ទះ និងក្នុងសហគមន៍។ ក្នុងនាមជាឃ្លាំងនៃចំណេះដឹង ជំនាញ និងគុណតម្លៃពាក់ព័ន្ធនៅមូលដ្ឋាន ហើយត្រូវបានផ្សព្វផ្សាយបន្តជាច្រើនជំនាន់ ដូច្នេះបេតិកភណ្ឌរស់នៅអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយការដាច់ពីគ្នានេះ។

**ដើម្បីអានពីសេចក្ដីសង្ខេបទូទៅ**អំពីគំនិតនៃការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការអប់រំក្នុងប្រព័ន្ធ សូមទស្សនាភាគវីដេអូជីវចលនេះ

Click



# ២.២ ការសិក្សាអំពីបេតិកភណ្ឌរស់

បេតិកភណ្ឌរស់បានបញ្ចូលរួចនៅក្នុងកម្មវិធីជាច្រើនរបស់សាលា ទាំងជាមេរៀន និងជាសកម្មភាពក្រៅកម្មវិធីសិក្សា។ នៅតាមសាលាដែលមិនទាន់បានបញ្ចូលបេតិកភណ្ឌរស់នៅក្នុងការបង្រៀន និងរៀន ដូច្នេះ មេរៀនស្តីពីបេតិកភណ្ឌរស់អាចដាក់បញ្ចូលយ៉ាងងាយស្រួលដើម្បីធ្វើជាផ្នែកមួយនៃខ្លឹមសារមេរៀនសម្រាប់ប្រើប្រាស់នៅក្នុងស្រុក។

មុខវិជ្ជាមួយចំនួនតាមកម្មវិធីសិក្សារបស់សាលា មានការភ្ជាប់ទំនាក់ទំនងយ៉ាងច្បាស់លាស់ជាមួយនឹងបេតិកភណ្ឌរស់។ ឧទាហរណ៍ រួមមាន៖

- ការអប់រំតន្ត្រី៖ ចម្រៀងប្រជាប្រិយ និងឧបករណ៍បុរាណ
- អប់រំសិល្បៈ៖ របាំ និងសិប្បកម្មបុរាណក្នុងស្រុក
- ការអប់រំភាសា៖ អក្សរសាស្ត្រក្នុងស្រុក និងកំណាព្យ
- អប់រំកាយ និងសុខភាព៖ កីឡា និងល្បែងបុរាណ

> ខ្ញុំចូលចិត្តមេរៀនទាំងអស់ ពីព្រោះមេរៀននីមួយៗ បានបង្រៀនពីប្រវត្តិនៃសិល្បៈ និងភាពច្នៃប្រឌិត។ ខ្ញុំមិនដែលធ្លាប់បានរៀនបែបនេះសោះពីមុនមក។
>
> *– កុមារី ចាន់ ពេជ្រលីកា សិស្ស កម្ពុជា*

នៅក្នុងមុខវិជ្ជាទាំងនេះ សិស្សានុសិស្សអាចរៀនអំពីប្រវត្តិ និងអត្ថន័យរបស់បេតិកភណ្ឌរស់ ហើយក៏អាចរៀនជំនាញបច្ចេកទេសផងដែរ។ ជួនកាល គេក៏អាចអនុវត្តបេតិកភណ្ឌរស់ក្នុងទម្រង់ជាការសម្តែង ពិធីបុណ្យ ការប្រកួត។ល។ ពួកគេក៏អាចចូលរួមនៅក្នុងពិធីបុណ្យក្នុងស្រុក ឬការប្រារព្ធពិធីផ្សេងៗ ដើម្បីជាផ្នែកមួយនៃកម្មវិធីសិក្សាក្នុងសាលា។

សកម្មភាពក្រៅកម្មវិធីសិក្សាគឺជាច្រកប្រាកដជាក់ស្តែងមួយទៀតសម្រាប់ការសិក្សាអំពីបេតិកភណ្ឌរស់។ ឧទាហរណ៍ នៅក្នុងក្លឹបក្រៅម៉ោងសិក្សា សិស្សអាចរៀនលេងឧបករណ៍បុរាណ ហ្វឹកហាត់កីឡាក្នុងស្រុក ហើយរៀនអក្សរផ្ចង់ជាដើម។

### កម្មវិធីសិក្សាថ្មី អប់រំវប្បធម៌ និងសិល្បៈ (ប្រទេសកម្ពុជា)

នៅថ្នាក់ទី ៧, ៨ និង ៩ សិស្សានុសិស្សរៀនអំពីល្ខោនបុរាណ គំនូរបុរាណ កំណាព្យ សុភាសិត និងពាក្យសម្តីផ្សេងទៀត កីឡា និងល្បែងផ្សេងៗ ក៏ដូចជា ផ្នែកផ្សេងៗជាច្រើនទៀតនៃវប្បធម៌របស់ខ្លួន។ មេរៀននានាមានបញ្ចូលនូវប្រវត្តិ និងទ្រឹស្តី។ សិស្សទស្សនាវីដេអូសៀវភៅ ដែលក្នុងនោះ ប្រជាជនមូលដ្ឋានបង្ហាញស្នាដៃរបស់ខ្លួន ហើយសិស្សចូលរួមនៅក្នុងសកម្មភាពអនុវត្តជាក់ស្តែង ក៏ដូចជាសកម្មភាពសប្បាយៗ ដើម្បីបានស្វែងយល់ពីបេតិកភណ្ឌរបស់ខ្លួនកាន់តែច្បាស់ ដូចជាការធ្វើខ្លែង និងក្បាំងមុខសម្រាប់ល្ខោន ការត្បាញកន្ទេល និងការលេងទាញព្រ័ត្រ និងការលេងពាក្យបណ្តៅ។



## ចម្រៀងប្រជាប្រិយនៅក្នុងថ្នាក់តន្ត្រីតាមសាលា (ប្រទេសអ៊ុសបេគីស្ថាន)

នៅក្នុងប្រទេសអ៊ុសបេគីស្ថាន ចម្រៀងប្រជាប្រិយជាផ្នែកមួយនៃកម្មវិធីអប់រំតន្ត្រី។ សិស្សរៀនចម្រៀង ច្រៀងរួមគ្នា ហើយវិភាគពីអត្ថន័យនៃទំនុកច្រៀង។ ឧទាហរណ៍ នៅក្នុងចម្រៀងប្រជាប្រិយ "Qayoqqaketding, Mahliyo" ពួកគេរៀនអំពីផ្ការាសីចក្រ និងពិធីដែលពាក់ព័ន្ធ។ នៅពេលរៀន សិស្សកាន់តែដឹងអំពីបេតិកភណ្ឌរបស់ខ្លួន។ ការអនុវត្តរបស់ពួកគេទៅតាមចម្រៀងនេះ ក៏បានរួមចំណែកដល់ការផ្សព្វផ្សាយបេតិកភណ្ឌនេះដែរ។





"ខ្ញុំចូលរៀនលេង Komuz [ឧបករណ៍ខ្សែរបស់ប្រជាជនគៀជីស្ថាន] ក្រោយម៉ោងសិស្សានៅសាលា។ ឪពុកម្តាយរបស់ខ្ញុំនិយាយថា ខ្ញុំត្រូវតែរៀនលេង Komuz ពីព្រោះ ពួកគាត់ចង់ឃើញខ្ញុំឡើងសម្តែងនៅលើឆាកថ្ងៃណាមួយ។ នៅពេលរៀននៅសាលា គ្រូរបស់យើងបានពន្យល់ថា ប្រជាជនគៀជីស្ថានតែងតែគោរពតន្ត្រីករ ហើយថាសិល្បករតែងទទួលបានការអញ្ជើញឱ្យចូលរួមក្នុងកម្មវិធី និងពិធីអបអរនានា។ នៅពេលនេះ ខ្ញុំមានអារម្មណ៍ថាមានទឹកចិត្តក្នុងការរៀនឧបករណ៍តន្ត្រីមួយនេះ។"

– *សិស្សនៅប្រទេសគៀជីស្ថាន*

## ល្បែងប្រជាប្រិយ ធ្វើជាម៉ូឌុលអប់រំកាយ (អ៊ុសបេគីស្ថាន)

សាលាបង្រៀនសាកល្បងនៅក្នុងប្រទេសអ៊ុសបេគីស្ថានបានបង្កើតម៉ូឌុលមួយដើម្បីស្វែងយល់ពីល្បែងប្រជាប្រិយជាច្រើន រាប់បញ្ចូលទាំងល្បែងដែលមានទំនាក់ទំនងនឹងធម្មជាតិ និងរដូវកាលផង ឧទាហរណ៍ ល្បែងដែលលេងជាពិសេសអំឡុងពិធីបុណ្យ *Navruz* (ឬហៅថា *Nowrooz* ក៏បាន ដែលជាពិធីបុណ្យសមរាត្រីនិទាឃរដូវ) ហើយនិងល្បែងដែលមានចលនាសកម្ម ឬដែលប្រើប្រាស់វត្ថុផ្សេងៗ។ ល្បែងទាំងអស់នេះ មានគោលបំណង និងទិដ្ឋភាពផ្សេងៗគ្នា រួមមានការបន្ធូរអារម្មណ៍ ការកម្សាន្ត ការប្រកួត ភាពរហ័សរហួន និងភាពរឹងមាំផ្នែករាងកាយ ដែលធ្វើឱ្យម៉ូឌុលនេះសក្តិសមជាផ្នែកមួយនៃកម្មវិធីអប់រំកាយ។ ទន្ទឹមនឹងនេះ កុមារក៏បានរៀនអំពីទិដ្ឋភាពសង្គមផងដែរ ដូចជា ឥរិយាបថនៅក្នុងក្រុម និងស្មារតី នៃកិច្ចសហប្រតិបត្តិការ។

# ២.៣ ការសិក្សាជាមួយបេតិកភណ្ឌរស់

ចំណេះដឹង និងការអនុវត្តទាក់ទងនឹងបេតិកភណ្ឌរស់អាចបញ្ចូលទៅក្នុងមេរៀនទៅតាមមុខវិជ្ជា ក្នុងកម្មវិធីសិក្សារបស់សាលា ដែលមិនមានទំនាក់ទំនងជាក់ស្តែងជាមួយនឹងបេតិកភណ្ឌនេះ ដូចជាគណិតវិទ្យា ការរចនាតាមកុំព្យូទ័រ វិទ្យាសាស្ត្រ និងភូមិវិទ្យាជាដើម។ នៅក្នុងបែបបទនេះ ទម្រង់នានានៃបេតិកភណ្ឌវប្បធម៌អរូបី មានផ្សារភ្ជាប់ជាមួយមេរៀនដើម្បីធ្វើជាឯកសារ និងវិធីសាស្ត្របង្រៀន ធ្វើឱ្យដំណើរការនៃការសិក្សាកាន់តែត្រូវតាមបរិបទ និងមានភាពសម្បូរបែប។ ធ្វើដូច្នេះ មិនត្រឹមតែអាចជួយបង្រៀនមុខវិជ្ជាប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយលើកកម្ពស់ការយល់ដឹងសម្រាប់សិស្សានុសិស្ស អំពីបេតិកភណ្ឌ និងគុណតម្លៃពាក់ព័ន្ធ ដែលអាចជំរុញទឹកចិត្តឱ្យសិស្សរៀនកាន់តែច្រើនទៀតអំពីបេតិកភណ្ឌនេះ តាមរយៈមធ្យោបាយផ្សេងៗ។

គ្រប់មុខវិជ្ជានៅសាលា ឬយ៉ាងហោចណាស់ មានមេរៀនខ្លះៗនៅក្នុងគ្រប់មុខវិជ្ជាទាំងអស់ អាចយកមកបង្រៀនជាមួយនឹងបេតិកភណ្ឌរស់បាន។ ហើយរាល់ធាតុរបស់បេតិកភណ្ឌរស់ អាចរួមចំណែកដល់ការបង្រៀនយ៉ាងហោចណាស់ក៏មួយមុខវិជ្ជារបស់សាលាដែរ។

**ការបង្រៀន និងរៀនគណិតវិទ្យា និងវិទ្យាសាស្ត្រជាមួយបេតិកភណ្ឌរស់**

ឧទាហរណ៍ពិតៗអំពីបេតិកភណ្ឌរស់អាចយកមកប្រើសម្រាប់លំហាត់ដោះស្រាយចំណោទ។ ឧទាហរណ៍៖

- ការគណនាចំនួនគ្រឿងផ្សំដែលត្រូវការសម្រាប់ចម្អិនអាហារ ឬបរិមាណនៃវត្ថុធាតុដើមក្នុងស្រុក សម្រាប់ផលិតផលសិប្បកម្មណាមួយ - ដើម្បីពង្រឹងជំនាញលេខនព្វន្ត។
- ប្រើប្រាស់ផ្ទត់ក្រឡាវាយនភ័ណ្ឌដើម្បីបង្រៀនពីគោលគំនិតផ្សេងៗនៃធរណីមាត្រ។
- ប្រើប្រាស់ប្រព័ន្ធរង្វាស់រង្វាល់ក្នុងស្រុក និងឧបករណ៍នានាដើម្បីបង្រៀនការគណនា និងជំនាញវាស់វែង។
- ប្រើប្រាស់ឧបករណ៍តន្ត្រីក្នុងស្រុក ដើម្បីពិសោធន៍ពីសំឡេង រំញ័រ និងរំយោល។
- ការប្រើប្រាស់រដូវ និងវដ្តជីវិតរបស់រុក្ខជាតិ និងសត្វក្នុងស្រុកដើម្បីបង្រៀនអំពីគោលគំនិតផ្សេងៗនៃជីវវិទ្យា។

### ការរៀនគណិតវិទ្យាជាមួយវត្ថុសក្តិសិទ្ធិធ្វើពីឫស្សី (ប្រទេសថៃ)

នៅប្រទេសថៃភាគខាងជើង ប្រជាជនបានយកបន្ទះឫស្សី មកត្បាញទៅជារាងស៊ីមេទ្រីយ៉ាងល្អិត ហើយដាក់វត្ថុនោះនៅតាមទ្វារដើម្បីការពារក្រុមគ្រួសាររបស់ខ្លួនពីឧបទ្រព្យចង្រៃ ដូចជា ជំងឺ ឬសត្វចង្រៃនៅក្នុងស្រែជាដើម។ គ្រូបង្រៀនម្នាក់ និងថ្នាក់រៀនរបស់គាត់បានសង្កេតទម្រង់ក្រឡាផ្សេងៗគ្នានៃតម្បាញឫស្សីនេះ ដើម្បីរៀនអំពីមេរៀនស៊ីមេទ្រីនៅក្នុងមុខវិជ្ជាគណិតវិទ្យា។ សិស្សក៏បានស្វែងយល់ពីពូជផ្សេងៗរបស់ឫស្សី នៅក្នុងថ្នាក់ជីវវិទ្យាផងដែរ។



## ការសិក្សាអក្សរសាស្ត្រជាមួយបេតិកភណ្ឌរស់

បេតិកភណ្ឌរស់អាចយកទៅបញ្ចូលក្នុងថ្នាក់រៀនភាសា អក្សរសាស្ត្រ និងសិក្សាសង្គម ទៅតាមវិធីផ្សេងៗជាច្រើន៖

- ចម្រៀងក្នុងស្រុក កំណាព្យ រឿងនិទាន និងរឿងព្រេង អាចយកទៅប្រើដើម្បីរៀនវាក្យសព្ទ ឬនៅក្នុងការវិភាគអត្ថបទ។
- សិស្សអាចធ្វើលំហាត់នៃការសម្ដែងអារម្មណ៍ចេញជាលាយលក្ខណ៍អក្សរទាក់ទងនឹងប្រធានបទផ្សេងៗ តាមរយៈការអនុវត្តក្បួនអក្សរសាស្ត្របុរាណ។
- សិស្សក៏អាចចងក្រងព័ត៌មាន និងរៀបរាប់អំពីពិធីបុណ្យក្នុងស្រុក ឬដំណើរការនៃការធ្វើសិប្បកម្ម ក្នុងភាសាណាមួយក៏បាន ដែលពួកគេកំពុងរៀននៅសាលា។



### ការសិក្សាអក្សរសាស្ត្រជាមួយមុខម្ហូប Nooruz (ប្រទេសគៀជីស្ថាន)

នៅក្នុងប្រទេសគៀជីស្ថាន មេរៀនអក្សរសាស្ត្រមួយត្រូវបានបង្កើតឡើងជុំវិញម្ហូប *Sumolok* ជាមុខម្ហូបមួយដែលរៀបចំឡើងអំឡុងពិធីអបអរ Nooruz ជារៀងរាល់ឆ្នាំ។ មេរៀននេះ អភិវឌ្ឍជំនាញប្រាស្រ័យទាក់ទងទាំងការសរសេរ និងនិយាយស្ដីរបស់សិស្ស។ មេរៀននេះក៏លើកទឹកចិត្តឱ្យសិស្សគិតកាន់តែហ្មត់ចត់អំពីមុខម្ហូបមួយនេះ (*Sumolok*) ដែលពួកគេទទួលទានជារៀងរាល់ឆ្នាំនិងអត្ថន័យនៃមុខម្ហូបនេះចំពោះជីវិតរបស់ខ្លួន និងសហគមន៍របស់ពួកគេ។ សិស្សានុសិស្សពណ៌នាអំពីគ្រឿងផ្សំ និងដំណើរការនៃការរៀបចំមុខម្ហូប។ ពួកគេក៏បានស្ដាប់ និងពិភាក្សាអំពីរឿងព្រេងទាក់ទងនឹងការបង្កើតមុខម្ហូបនេះ ហើយសម្ភាសន៍ក្រុមគ្រួសាររបស់ខ្លួន ដើម្បីប្រមូលសាច់រឿង និងសុភាសិតផ្សេងៗ។

## ការបង្រៀន និងការសិក្សាសង្គម និងប្រវត្តិវិទ្យាជាមួយបេតិកភណ្ឌរស់

តាមរយៈការប្រើប្រាស់បេតិកភណ្ឌរស់នៅក្នុងមុខវិជ្ជាសិក្សាសង្គម សិស្សានុសិស្សអាច៖

- វិភាគ និងប្រៀបធៀបបរិបទប្រវត្តិសាស្ត្រ សង្គម និងនយោបាយ នៃធាតុបេតិកភណ្ឌរស់កាលពីអតីតកាល និងបច្ចុប្បន្ន។
- ស្វែងយល់ថាតើ ពិធីបុណ្យមួយ ហេតុអ្វីត្រូវបានសហគមន៍ប្រារព្ធអបអរយ៉ាងដូចម្ដេចខ្លះ។
- ឆ្លុះបញ្ចាំងអំពីការវិវត្តន៍នៃតួនាទីយេនឌ័រ និងរចនាសម្ព័ន្ធសង្គម តាមរយៈការអនុវត្ត។
- រៀនធ្វើបទសម្ភាសន៍សមាជិកគ្រួសារ និងសមាជិកសហគមន៍។





### ការបង្រៀនប្រវត្តិសាស្ត្រតាមរយៈសិល្បៈទស្សនីយភាព (សាធារណរដ្ឋកូរ៉េ)

នៅប្រទេសកូរ៉េ សិស្សរៀនអំពីទម្រង់មួយនៃសិល្បៈទស្សនីយភាព ហៅថា *Namsadang Nori*។ កាលពីអតីតកាល ក្រុមរបាំធ្វើដំណើរតាមទីជនបទក្នុងប្រទេស ដើម្បីផ្តល់ការកម្សាន្តដល់ប្រជាជនតាមរយៈសិល្បៈទស្សនីយភាពមួយនេះ។ បន្ថែមលើការសម្តែងបែបកាយសម្ព័ន្ធ ល្ខោនពាក់ក្បាំងមុខ និងរបាំអាយ៉ង ដែលមានបញ្ចូលការតិះដៀល និងការរិះគន់ចំពោះលក្ខខណ្ឌសង្គមផ្សេងៗ។ នៅក្នុងថ្នាក់រៀនមុខវិជ្ជាប្រវត្តិសាស្ត្រ និងសិក្សាសង្គម សិស្សក្រឡេកមើលពីរបៀបរបបរស់នៅរបស់មនុស្សពីមុន អំឡុងរជ្ជកាលរាជវង្សចូសឹង។ ពួកគេស្រាវជ្រាវហេតុអ្វី *Namsadang Nori* មានប្រជាប្រិយភាពកាលពីពេលនោះ ហើយប្រៀបធៀបលទ្ធផលដែលពួកគេរកឃើញជុំវិញបញ្ហាកាលពីអតីតកាលជាមួយនឹងបញ្ហាសង្គមនាពេលបច្ចុប្បន្ន។

## ការកែលម្អជំនាញទន់តាមរយៈបេតិកភណ្ឌរស់

ការប្រើប្រាស់បេតិកភណ្ឌរស់នៅក្នុងថ្នាក់រៀនក៏អាចជួយកែលម្អជំនាញទន់ផងដែរ ដូចជា របៀបធ្វើការជាក្រុម របៀបប្រាស្រ័យទាក់ទងនៅក្នុងក្រុម និងជំនាញសម្ភាសន៍។ ការប្រើប្រាស់បេតិកភណ្ឌរស់នៅក្នុងថ្នាក់រៀនក៏អាចជួយសិស្សានុសិស្សឱ្យទទួលបានចំណេះដឹង និងជំនាញផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) ថែមទៀតផង។

### ការនិទានរឿងបែបឌីជីថលក្នុងប្រទេសថៃ



នៅប្រទេសថៃ សិស្សបានប្រើបេតិកភណ្ឌរស់ (រូបមន្តធ្វើម្ហូបក្នុងស្រុក) ដើម្បីរៀនអំពីបច្ចេកទេសនិទានរឿងបែបឌីជីថល។ ពួកគេបានប្រមូលព័ត៌មានអំពីប្រភេទអាហារចម្រុះដែលបានរៀបចំនៅក្នុងខេត្តរបស់ពួកគេ និងផលិតជាឯកសារសោតទស្សន៍អំពីអាហារនោះ។ ឯកសារទាំងនេះត្រូវបានបង្ហោះនៅលើកម្មវិធីបណ្តាញផ្សព្វផ្សាយសង្គមដោយមានកូអរដោណេភូមិសាស្ត្រ GPS ដើម្បីកំណត់ផែនទីពួកគេ។ គ្រូបង្រៀន និងសិស្សក្នុងថ្នាក់ក៏បានរៀបចំសៀវភៅអេឡិចត្រូនិកដែលមានរៀបរាប់រូបមន្តធ្វើម្ហូបក្នុងស្រុកផងដែរ។

ជាធម្មតា ការរៀន ***ជាមួយ*** បេតិកភណ្ឌរស់ក៏មានពាក់ព័ន្ធនឹងការរៀន ***អំពី*** បេតិកភណ្ឌរស់ក្នុងកម្រិតណាមួយផងដែរ ដូច្នេះជាការលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃកិច្ចការពារបេតិកភណ្ឌ និងការរួមចំណែកដល់ការផ្សព្វផ្សាយអំពីបេតិកភណ្ឌផងដែរ។

ស្រដៀងគ្នានឹងវិធីសាស្ត្រដែលបានរៀបរាប់ខាងលើដែរ ពេលគឺការសិក្សា ***ជាមួយ*** បេតិកភណ្ឌរូបី ( ឧទាហរណ៍ ស្ថាបត្យកម្មក្នុងស្រុកដើម្បីរៀនអំពីភូមិវិទ្យា ឬសម្ភារៈសំណង់ក្នុងស្រុក ដើម្បីរៀនអំពីគីមីវិទ្យា ) ក៏អាចអនុវត្តចំពោះការរៀន ***អំពី*** បេតិកភណ្ឌរូបីផងដែរ ( ឧទាហរណ៍ ការស្វែងយល់ពីប្រវត្តិសាស្ត្រ លក្ខណៈពិសេស គុណតម្លៃផ្នែកសង្គម និងសេដ្ឋកិច្ច របស់ប្រាសាទមួយ )។

## ២.៤ អត្ថប្រយោជន៍នៃការបង្រៀន និងការសិក្សាអំពី និងជាមួយបេតិកភណ្ឌរស់

មានអត្ថប្រយោជន៍ជាច្រើនដែលបាន ពីការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងសកម្មភាពអប់រំរបស់សាលា។ ចម្លើយសក្ខីភាព និងរឿងរ៉ាវដែលបានបង្ហាញនៅក្នុងសៀវភៅនេះ បង្ហាញពីអត្ថប្រយោជន៍ជាច្រើនដែលបេតិកភណ្ឌរស់ផ្តល់ជូនដល់វិស័យអប់រំ។ អត្ថប្រយោជន៍រយៈពេលវែង និងរយៈពេលខ្លីជាក់លាក់មួយចំនួនត្រូវបានរៀបរាប់នៅក្នុងផ្នែកខាងក្រោមនេះ។

### រួមចំណែកការពារបេតិកភណ្ឌរស់

ការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការអប់រំ ធានាថាការអនុវត្ត ចំណេះដឹង ឬជំនាញត្រូវបានបញ្ជូនបន្តទៅឱ្យមនុស្សជំនាន់ក្រោយ។ ជាការពិតណាស់ ការឱ្យសិស្សានុសិស្សស្គាល់អំពីបេតិកភណ្ឌរស់តាមរយៈសាលា ឬកន្លែងផ្សេងទៀត គឺជាវិធីសាមញ្ញបំផុតក្នុងការលើកកម្ពស់ការយល់ដឹងរបស់យុវជនអំពីសារៈសំខាន់នៃបេតិកភណ្ឌរស់។ ជាញឹកញាប់ ការយល់ដឹងអាចលើកទឹកចិត្តគ្រូ និងសិស្សឱ្យស្វែងយល់បន្ថែមអំពីបេតិកភណ្ឌរស់ និងស្វែងរកឱកាសបន្ថែមទៀតដើម្បីអនុវត្តបេតិកភណ្ឌរស់ទាំងនេះ។ ការយល់ដឹងក៏អាចជំរុញយុវជនឱ្យចែករំលែកចំណេះដឹង និងបទពិសោធន៍របស់ខ្លួនជាមួយអ្នកដទៃផងដែរ។ ទីបំផុត ការអប់រំផ្តល់សិទ្ធិអំណាចដល់សិស្ស និងគ្រូបង្រៀនឱ្យក្លាយជាតួអង្គក្នុងកិច្ចការពារបេតិកភណ្ឌ។



> “ខ្ញុំបានស្វែងយល់យ៉ាងច្រើនអំពីក្រុមគ្រួសាររបស់ខ្ញុំ។ ជាធម្មតា នៅសាលា អ្នកទទួលបានចំណេះដឹងទូទៅ មិនមែនចំណេះដឹងអំពីក្រុមគ្រួសាររបស់អ្នកឡើយ! ចំណេះដឹងបែបនេះស្រាប់តែមានសារៈសំខាន់ខ្លាំងសម្រាប់ខ្លួនខ្ញុំផ្ទាល់។
>
> *– សិស្ស ថ្នាក់ទី ៩ សាលាអន្តរជាតិ Dostar International School Lyceum ប្រទេសកាហ្សាក់ស្ថាន*”

## កែលម្អលទ្ធផលសិក្សា និងគុណភាពអប់រំ

ការសិក្សាពីបេតិកភណ្ឌរស់នៅសាលា ជួយធានាថាការអប់រំមានភាពប្រទាក់ក្រឡាគ្នា និងមានការចូលរួមពីសិស្សានុសិស្ស។ នេះក៏ព្រោះតែការបង្រៀន និងការសិក្សាបែបនេះ ភ្ជាប់ចំណេះដឹងទ្រឹស្តីជាមួយនឹងស្ថានភាពជីវិតពិត។ ទន្ទឹមនឹងនេះ នៅពេលដែលមេរៀនមួយត្រូវបានរៀបចំឡើងពាក់ព័ន្ធនឹងបេតិកភណ្ឌរស់ នោះទិដ្ឋភាពទ្រឹស្តីរបស់មេរៀនអាចបំពេញបន្ថែមដោយប្រើប្រាស់ឧទាហរណ៍នៅក្នុងការរស់នៅជាក់ស្តែង។




តាមរយៈការបញ្ចូលធាតុមួយចំនួននៃបេតិកភណ្ឌវប្បធម៌ក្នុងស្រុក ទៅក្នុងសកម្មភាពរបស់សាលាដូច្នេះគ្រូបង្រៀនភ្ជាប់ទំនាក់ទំនងរវាងសាលា និងជីវិតសហគមន៍ ហើយលើកទឹកចិត្តសិស្សានុសិស្សឱ្យដឹងថា គ្រប់ទម្រង់នៃការសិក្សាសុទ្ធតែរួមចំណែកធ្វើឲ្យពួកគេ ទៅជាមនុស្សពេញវ័យ និងជាពលរដ្ឋ។ តាមរយៈការភ្ជាប់ជីវិតនៅសាលា និងជីវិតនៅផ្ទះ សិស្សអាចមានឱកាសចែករំលែកបទពិសោធន៍របស់ពួកគេនៅក្នុងថ្នាក់ ឬអនុវត្តនូវអ្វីដែលខ្លួនបានសិក្សាថ្មីៗនៅផ្ទះរបស់ខ្លួន។

> បេតិកភណ្ឌវប្បធម៌អរូបី (ICH) គឺជាប្រធានបទថ្មីទាំងស្រុងសម្រាប់មនុស្សគ្រប់គ្នា សម្រាប់យើងខ្ញុំផង និងសម្រាប់សិស្សផង។ ការបញ្ចូលមុខវិជ្ជាបេតិកភណ្ឌវប្បធម៌អរូបីទៅជាមុខវិជ្ជាសិក្សា ពិតជាបណ្តុះឱ្យមានការគិតបែបថ្មីឱ្យកាន់តែស៊ីជម្រៅ និងជាក់ស្តែងជាងមុន។ វាធ្វើឱ្យយើងងាកទៅចោទសួរលើវិធីសាស្ត្រចាស់នៃការបង្រៀនមេរៀនអំពីសំណុំនៅក្នុងគណិតវិទ្យា ពីព្រោះយើងអាចបង្រៀនមេរៀនដដែលនេះ ក្នុងលក្ខណៈដែលសប្បាយៗជាងមុន និងមានការចូលរួមជាងមុន និងបង្រៀនដោយប្រើឧទាហរណ៍ដែលយើងឃើញក្នុងជីវិតប្រចាំថ្ងៃរបស់យើង។
>
> *– Sabitree Maharjan គ្រូបង្រៀនគណិតវិទ្យា សាលាមធ្យមសិក្សា Mangal នេប៉ាល់*

នៅពេលមេរៀនមួយផ្តែកលើ ចំណេះដឹង ឬការអនុវត្តក្នុងមូលដ្ឋាន ដូច្នេះសិស្សបានស្គាល់រួចហើយនូវផ្នែកមួយចំនួននៃមេរៀននោះ ហើយអាចភ្ជាប់ទំនាក់ទំនងយ៉ាងងាយជាមួយនឹងប្រធានបទរបស់មេរៀន។ ដូច្នេះសិស្សានុសិស្សយល់ថា ការសិក្សានៅសាលា មានភាពចាំបាច់រឹតតែខ្លាំង ហើយមានភាពពាក់ព័ន្ធជាងមុនចំពោះជីវិតរស់នៅប្រចាំថ្ងៃរបស់សិស្ស។ សិស្សដែលចូលរួម ងាយនឹងមានទឹកចិត្តក្នុងការសិក្សា ចេះប្រាស្រ័យទាក់ទងជាមួយនឹងគ្រូបង្រៀន និងមិត្តរួមថ្នាក់របស់ខ្លួន ក៏ដូចជាទទួលបានលទ្ធផលសិក្សាកាន់តែល្អប្រសើរ។

ជាងនេះទៅទៀត ការបង្រៀនដោយការបញ្ជ្រាបបេតិកភណ្ឌរស់ ត្រូវមានគរុកោសល្យសកម្ម ដែលជំរុញការសិក្សាដោយសហការ និងផ្តោតលើបញ្ហា។ សិស្សរៀន ក្នុងលក្ខណៈដែលមានការអនុវត្តជាក់ស្តែងជាងមុន។ ពួកគេអាចស្វែងយល់ពីការអនុវត្តជាក់ស្តែង ហើយរៀនតាមរយៈការសាកល្បង និងកំហុសឆ្គង។ វិធីសាស្ត្របែបនេះ អាចនាំទៅរកការលើកកម្ពស់យូរអង្វែងសម្រាប់លទ្ធផលសិក្សា។





## ការរៀនគណិតវិទ្យាជាមួយនឹងរឿងនិទាន (ប្រទេសប៉ាគីស្ថាន)

ដើម្បីបង្ហាញពីអត្ថន័យផ្នែកគណិតវិទ្យាស្តីពី ប្រជុំ ប្រសព្វ និង ភាពខុសគ្នានៃសំណុំ គ្រូចាប់ផ្តើមមេរៀនរបស់គាត់តាមរយៈការនិទានរឿងនិទានដ៏មានប្រជាប្រិយមួយ។ ក្រោយពេលនិទានរឿងរួច សិស្សត្រូវបានបែងចែកជាពីរក្រុម ដោយក្រុមមួយត្រូវគាំទ្រតួអង្គសំខាន់ណាមួយនៅក្នុងចំណោមតួទាំងពីរនាក់។ សិស្សរមៃឃើញពីអត្ថន័យនៃពាក្យ ប្រជុំ (ដែលតំណាងដោយក្រុមទាំងពីរ) និងប្រសព្វ (តួអង្គដែលជាការជ្រើសរើសរបស់ក្រុមទាំងពីរ) នៅក្នុងដ្យាក្រាម វ៉ែន។ បន្ទាប់មក ពួកគេបន្តស្វែងយល់ពីអត្ថន័យទាំងអស់នេះ ជាមួយនឹងស៊េរីលេខអរូបី។



ខ្ញុំបានសិក្សាច្រើន។ ខ្ញុំនឹងចងចាំរឿងទាំងអស់នេះពេញមួយជីវិតរបស់ខ្ញុំ។ ខ្ញុំយល់ពីរបៀបដែលមនុស្សពីអតីតកាលប្រើប្រាស់ត្រីកោណមាត្រផងដែរ។ ខ្ញុំចេះវិធីធ្វើដំណើរបានល្អ។ ខ្ញុំសូមឱ្យមុខវិជ្ជាផ្សេងទៀតប្រើប្រាស់វិធីសាស្ត្របែបនេះផងដែរ ដើម្បីឱ្យយើងងាយយល់។ ខ្ញុំដឹងថា ការធ្វើដូច្នេះ នឹងលើកកម្ពស់ការសិក្សា ក៏ដូចជាជីវិតរស់នៅប្រចាំថ្ងៃ។ គ្រប់គ្នានឹងអាចកែលម្អ។

*– សិស្សមកពីគម្រោងសាកល្បង ប្រទេសនេប៉ាល់*

តាមរយៈការកែលម្អលទ្ធផលសិក្សា ការសិក្សាបេតិកភណ្ឌវប្បធម៌អរូបី រួមចំណែកដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ (SDG ៤)៖ ដើម្បីធានាបាននូវការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

## ការផ្តល់អំណាចដល់សិស្ស

វាជារឿងសំខាន់ក្នុងការយល់ពីខ្លួនឯង និងទីតាំងខ្លួនឯងនៅក្នុងសង្គម។ ដោយសារតែ បេតិកភណ្ឌរស់កំណត់ថាតើយើងជានរណា យើងឱ្យតម្លៃលើអ្វី តើយើងយល់ឃើញបែបណាចំពោះពិភពលោក ហើយតើយើងធ្វើទង្វើបែបណា ដូច្នេះ ការរៀនជាមួយនឹងបេតិកភណ្ឌរស់ ជួយមនុស្សវ័យក្មេងឱ្យស្វែងយល់ពីអត្តសញ្ញាណរបស់ខ្លួន សូម្បីនៅក្នុងមជ្ឈដ្ឋានចម្រុះដោយវប្បធម៌ក្តី។ ការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការអប់រំភ្ជាប់ទំនាក់ទំនងសិស្សជាមួយនឹងអតីតកាល និងបច្ចុប្បន្នកាលរបស់គេ ជាមួយនឹងគ្នាទៅវិញទៅមក និងជាមួយនឹងពិភពលោកកាន់តែទូលំទូលាយជាងមុន ហើយអាចពង្រឹងការឱ្យតម្លៃខ្លួនឯង និងភាពជាម្ចាស់។ ដូច្នេះ ការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការអប់រំរួមចំណែកដល់ការកសាងសង្គមដែលស្អិតរមួត និងពិភពលោកដែលមានសន្តិភាព។

ការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងការអប់រំក៏ជួយឱ្យមនុស្សវ័យក្មេងក្នុងការកសាងជំនាញអារម្មណ៍សង្គម និងទស្សនៈចំពោះពិភពលោក និងទម្លាប់វិជ្ជមាន។ ជាងនេះទៅទៀត ការបង្រៀន និងការរៀនជាមួយបេតិកភណ្ឌរស់នៅក្នុងសាលា នាំឱ្យកុមារអាចទទួលបាននូវជំនាញនាសម័យសតវត្សរ៍ទី ២១ ដូចជាការយល់ចិត្ត ការគិតស៊ីជម្រៅ និងការសហការក្នុងលក្ខណៈដែលពួកគេទទួលបានការបណ្តុះបណ្តាលទៅតាមបរិបទក្នុងស្រុករបស់ខ្លួន ហើយត្រូវបានភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងអត្តសញ្ញាណរបស់គេ។

ការសិក្សាបេតិកភណ្ឌរស់ ក៏លើកទឹកចិត្តដល់ការសិក្សាតាមការអប់រំមិត្តផងដែរ ដែលសិស្សអាចចែករំលែកចំណេះដឹងរបស់ពួកគេអំពីបេតិកភណ្ឌរស់របស់ខ្លួនជាមួយមិត្តរួមថ្នាក់របស់ពួកគេ។

## ការបណ្តុះកិច្ចសហការ និងភាពច្នៃប្រឌិតសម្រាប់គ្រូបង្រៀន

នៅពេលគ្រូបង្រៀនបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការបង្រៀនជាញឹកញាប់ ពួកគាត់ត្រូវការការសហការជាមួយគ្រូផ្សេងទៀត និងជាមួយបុគ្គលធនធានពីខាងក្រៅ ហើយស្វែងរកប្រភពនៃការបំផុសម្រាំងចិត្ត និងព័ត៌មានផ្សេងៗជាច្រើន ដើម្បីស្វែងយល់បន្ថែមអំពីបេតិកភណ្ឌណាមួយ និងបង្កើតមេរៀនត្រូវតាមបរិបទ និងពាក់ព័ន្ធ ឬគម្រោងដែលត្រូវតាមមូលបទ។ ទន្ទឹមនឹងនេះ វិធីសាស្ត្រនេះ ជារឿយៗ ទាមទារការស្វែងយល់ពីគរុកោសល្យប្រកបដោយនវានុវត្តន៍។ តាមរយៈដំណើរការនេះ គ្រូនឹងពង្រីកបណ្តាញរបស់ខ្លួន ហើយកាន់តែមានធនធាន និងច្នៃប្រឌិត។

> វាសំខាន់សម្រាប់សិស្សក្នុងការដែលមានឱកាសថ្មី ហើយប្លែក ដើម្បីចូលរួម ក្នុងការសិក្សា។ សិស្សដែលធម្មតា ធ្លាប់តែខ្សោយការសិក្សា បែរជាមានភាពសកម្មនៅក្នុងការបង្ហាញអំពីបេតិកភណ្ឌវប្បធម៌អរូបីរបស់ខ្លួន នៅក្នុងថ្នាក់រៀន ហើយបច្ចុប្បន្នកំពុងចូលរួមយ៉ាងសកម្ម។
>
> *– Pabitra Shakya គ្រូបង្រៀន សាលាមធ្យមសិក្សា Janasewa ប្រទេសនេប៉ាល់*





## ការសហការលើគម្រោងចាក់ស្រេះស្តីពីមូលបទទឹក ( ម៉ុងហ្គោល )

គ្រូបង្រៀនមុខវិជ្ជាភូមិវិទ្យា បច្ចេកវិទ្យា គីមីរូបវិទ្យា និងជីវវិទ្យា ធ្វើការរួមគ្នាដើម្បី អនុវត្តគម្រោងពហុវិស័យមួយឈ្មោះថា "មេរៀនក្នុងធម្មជាតិ"។ គម្រោងនេះ ពាក់ព័ន្ធនឹងការបញ្ចូលធាតុផ្សំផ្នែកបរិស្ថាន និងវប្បធម៌ទាក់ទងនឹងទឹកទៅក្នុងមុខវិជ្ជារបស់គេរៀងៗខ្លួន។ សិស្សសិក្សាអំពីការថែមថយនៃការផ្គត់ផ្គង់ទឹក និងសកម្មភាពមនុស្សដែលរួមចំណែកដល់ដំណើរការប្រែជាវាលរហោស្ថាន ហើយនិងរៀនអំពីពិធីសាសនា ដើម្បីធ្វើឱ្យទន្លេស្ងប់ស្ងាត់ ហើយនិងពិធីសម្រាប់ការឧទ្ទិសបូជាដល់ភ្នំ និងផ្លូវទឹកក្នុងស្រុក។

> ការប្រើប្រាស់បេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងសកម្មភាពសាលា មិនត្រឹមតែបង្កើនចំណាប់អារម្មណ៍របស់សិស្សនៅក្នុងដំណើរការនៃការសិក្សា ហើយលើកកម្ពស់គុណភាពអប់រំប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយពង្រីកលទ្ធភាពរបស់គ្រូបង្រៀន ហើយផ្តល់ឱកាសឱ្យពួកគាត់ក្នុងការចែករំលែកបទពិសោធន៍ និងបន្តសិក្សាតទៅទៀត។
>
> *– Elena Glaubentz គ្រូបង្រៀន គៀរជីស្ថាន*



## ការលើកកម្ពស់ចម្រុះភាព ជំរុញបរិយាបន្ន អធ្យាស្រ័យល្អ និងការសន្ទនាអន្តរវប្បធម៌

ការសិក្សាបេតិកភណ្ឌរស់ ជំរុញឱ្យមានការឱ្យតម្លៃចំពោះភាពចម្រុះគ្នានៃវប្បធម៌ និងលើកកម្ពស់ភាពជាពលរដ្ឋពិភពលោក។ បេតិកភណ្ឌរស់ឆ្លុះបញ្ចាំងពីតម្លៃ និងបទដ្ឋានរបស់ក្រុមមនុស្សជាច្រើន។ ភាពចម្រុះត្រូវបានស្តែងចេញ តាមរយៈប្រវត្តិសាវតារសង្គម វប្បធម៌ និងសាសាសនា របស់ពួកគេ ប៉ុន្តែក៏ស្តែងចេញតាមរយៈ ភេទ និងអាយុរបស់បុគ្គលជាអ្នកអនុវត្តប្រតិបត្តិផងដែរ។



គ្រូបង្រៀនអាចបង្ហាញពីបេតិកភណ្ឌរស់របស់សហគមន៍ផ្សេងៗគ្នានៅក្នុងមេរៀនរបស់ពួកគេ ដើម្បីលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរក្នុងន័យស្ថាបនា និងការយោគយល់គ្នាទៅវិញទៅមករវាងសិស្ស និងសិស្ស។ គ្រូបង្រៀនក៏អាចលើកទឹកចិត្តសិស្សឱ្យដោះដូរ និងប្រៀបធៀបព័ត៌មាន ទាក់ទងនឹងការប្រតិបត្តិរបស់ពួកគេរៀងៗខ្លួន។ សាលាអាចរៀបចំព្រឹត្តិការណ៍ផ្សេងៗ ដែលមានបង្ហាញឱ្យឃើញពីទម្លាប់ប្រតិបត្តិខុសៗគ្នារបស់សិស្សានុសិស្ស។ វិធីសាស្ត្របែបនេះ ជួយលើកកម្ពស់ដល់ការរៀនបែបបរិយាបន្ន ហើយមានតម្លៃយ៉ាងពិសេសនៅក្នុងមជ្ឈដ្ឋានសាលាដែលមានវប្បធម៌ចម្រុះ។



### ការអភិវឌ្ឍការយល់ដឹងអំពីភាពចម្រុះគ្នានៃវប្បធម៌ (ប្រទេសប៉ាគីស្ថាន)

នៅសាលាមួយដែលមានទីតាំងនៅជើងភ្នំនៃតំបន់ភ្នំមួយ មេរៀនសិក្សាសង្គមផ្តោតលើការប៉ាក់ឱន និងសម្លៀកបំពាក់របស់ជនជាតិដើមភាគតិច ដើម្បីបង្ហាញពីភាពចម្រុះនៃវប្បធម៌ក្នុងតំបន់នេះ។ នៅក្នុងមេរៀននេះ សិស្សបានរៀនពីប្រភេទផ្សេងៗនៃសម្លៀកបំពាក់ប្រពៃណីក្នុងតំបន់ បានពិនិត្យមើលវត្ថុគំរូនៃការប៉ាក់ឱន ហើយក៏បានពិភាក្សាពីលក្ខណៈខុសគ្នានៃសម្លៀកបំពាក់របស់បុរស និងនារី ក៏ដូចជាការប្រើប្រាស់សម្លៀកបំពាក់ទាំងនោះ។ ពួកគេក៏បានស្លៀក សម្លៀកបំពាក់ជនជាតិខ្លួនទៅសាលាផងដែរ ហើយបានពន្យល់ពីលក្ខណៈពិសេស អត្ថន័យ និងគុណតម្លៃនៃប្រភេទសម្លៀកបំពាក់នីមួយៗ។សកម្មភាពនេះ បានជំរុញលើកទឹកចិត្តឱ្យមានការផ្តោះប្តូរផ្នែកវប្បធម៌ និងការយោគយល់គ្នាទៅវិញទៅមក ក្នុងចំណោមសិស្សានុសិស្ស។

“ខ្ញុំនឹងផ្លាស់ទៅរស់នៅប្រទេសកូរ៉េឆាប់ៗ ហើយខ្ញុំគិតថា ខ្ញុំចាំបាច់ត្រូវស្គាល់ឱ្យបានច្រើនបន្ថែមទៀត អំពីបេតិកភណ្ឌវប្បធម៌អរូបីរបស់ប្រទេសគៀជីស្ថាន ដើម្បីឱ្យខ្ញុំអាចពន្យល់សិស្សដទៃទៀតក្នុងប្រទេសកូរ៉េអំពីប្រពៃណី និងទម្លាប់ប្រតិបត្តិរបស់យើងដែលឆ្លុះបញ្ចាំងឱ្យឃើញពីបេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែបនៃប្រទេសរបស់យើង។”

*– Torayim សិស្សថ្នាក់ទី ១១*
*ប្រទេសគៀជីស្ថាន*

## ជំរុញសមភាពយេនឌ័រ

ទម្លាប់អនុវត្ត និយាម និងគុណតម្លៃវប្បធម៌អាចផ្លាស់ប្តូរតាមពេលវេលា ដូច្នេះការបង្រៀនជាមួយបេតិកភណ្ឌរស់អាច ក្លាយជាមធ្យោបាយនៃការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងសាលា និងការពង្រឹងតួនាទីយេនឌ័រជាវិជ្ជមានបាន តាមរយៈការស្វែងយល់ពីភាពលម្អៀងផ្នែកយេនឌ័រ ដែលអាចកើតមាន នៅក្នុងការអនុវត្តនៅក្នុងស្រុក។ សកម្មភាពបែបនេះរបស់សាលា ក៏អាចឆ្លុះបញ្ចាំងឱ្យឃើញថាតើ ការប្រតិបត្តិវប្បធម៌មានការវិវត្តន៍ប៉ុណ្ណាហើយ។ ជាក់ស្តែង នៅក្នុងប្រទេសគៀជីស្ថាន ស្រ្តីមានជំនាញផ្នែកសិប្បកម្ម ដែលកាលពីអតីតកាល ជាការងារដែលភាគច្រើនបុរសជាអ្នកធ្វើ ដូចជាការងារជាងប្រាក់ជាដើម។ ទន្ទឹមនឹងនេះ គ្រូបង្រៀនអាចលើកទឹកចិត្តក្មេងស្រី និងក្មេងប្រុសឱ្យសហការគ្នាក្នុងលក្ខណៈដែលមានអព្យាក្រឹតភាពផ្នែកយេនឌ័រ សម្រាប់គម្រោងមួយដែលទាក់ទងនឹងបេតិកភណ្ឌរស់ ទោះបីជាទម្លាប់ដែលត្រូវបានយកមកសិក្សានោះ អាចមានទំនាក់ទំនងស៊ីជម្រៅជាមួយនឹងតួនាទីយេនឌ័រដាច់ដោយឡែកពីគ្នានៅក្នុងសហគមន៍ក្តី។

### ការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងមេរៀនជាមួយបេតិកភណ្ឌរស់ (ប្រទេសនេប៉ាល់)

ក្នុងប្រទេសនេប៉ាល់ គ្រូដឹងថាទម្លាប់ប្រតិបត្តិនៃបេតិកភណ្ឌវប្បធម៌អរូបីខ្លះៗ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយតួនាទីជាក់លាក់ផ្នែកយេនឌ័រនៅក្នុងសហគមន៍។ ឧទាហរណ៍ ចម្រៀងមួយចំនួន ភាគច្រើនបំផុតច្រៀងដោយនារី។ ការងារខ្លះត្រូវបានកំណត់ថាជាការងារសម្រាប់មនុស្សប្រុស ហើយពិធីសាសនាខ្លះតម្រូវឱ្យស្រ្តីគោរពបូជាដល់មនុស្សប្រុស។ ទោះបីជាមានការបែងចែកតួនាទីបែបនេះក្តី គ្រូបានចែកកិច្ចការក្នុងលក្ខណៈដែលមានអព្យាក្រឹតភាពផ្នែកយេនឌ័រ។ សិស្សរបស់ពួកគេ មានឆន្ទៈក្នុងការសាកល្បងនូវបទពិសោធន៍ថ្មីៗ។ ការរៀន និងការធ្វើការជាមួយគ្នា ដើម្បីសម្រេចតាមគោលដៅ ជួយឱ្យពួកគេអាចឆ្លងកាត់នូវភាពលម្អៀងដែលកើតមាននៅក្នុងការអនុវត្តប្រតិបត្តិជាក់ស្តែង។







## ពង្រឹងការសន្ទនានៅក្នុងសហគមន៍ និងរវាងមនុស្សជំនាន់ផ្សេងៗគ្នា

ការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការអប់រំក្នុងប្រព័ន្ធ អាចពង្រឹងការប្រាស្រ័យទាក់ទងរវាងសាលានិងសហគមន៍ជុំវិញបាន ក៏ដូចជាការប្រាស្រ័យទាក់ទងរវាងមនុស្សផ្សេងជំនាន់គ្នា។ តាមរយៈសកម្មភាពបែបនេះ សិស្សមានឱកាសក្នុងការកសាងចំណងទាក់ទងកាន់តែរឹងមាំជាមួយនឹងក្រុមគ្រួសារ និងសហគមន៍ធំរបស់គេ។ ការនាំសមាជិកសហគមន៍ និងឪពុកម្តាយ ចូលទៅក្នុងដំណើរការនៃការអប់រំក៏អាចធ្វើឱ្យការសិក្សាកាន់តែមានភាពប្រទាក់ក្រឡាគ្នា និងសប្បាយផងដែរ។

### ការសម្ភាសន៍អ្នកជំនាញក្នុងស្រុក (ប្រទេសប៉ាគីស្ថាន)

ជាផ្នែកមួយនៃលំហាត់សិក្សាសង្គម សិស្សបានកំណត់រកសមាជិកសហគមន៍ដែលពាក់ព័ន្ធនឹងមុខរបរបុរាណ។ ឧទាហរណ៍ ជាងឈើ ជាងដែក ជាងកំបោរ អ្នកត្បាញ និងជាងស្បែកជើង។ សិស្សបានសម្ភាសន៍ពួកគាត់ ដើម្បីប្រមូលព័ត៌មានអំពីជីវិត និងការងាររបស់គាត់ (ដូចជា តើពួកគាត់រៀនការងារនោះតាមវិធីណា តើមានការប្រែប្រួលទៅតាមពេលវេលាដែរ ឬទេ និងសារៈសំខាន់នៃការងារនោះនៅក្នុងសហគមន៍)។ ពួកគេក៏បានរៀបចំបញ្ជីឧបករណ៍ និងគូរឧបករណ៍ ដែលប្រើប្រាស់ក្នុងមុខរបរនីមួយៗផងដែរ។ សកម្មភាពប្រភេទនេះ ជួយឱ្យសិស្សយល់កាន់តែច្បាស់ និងឱ្យតម្លៃលើមុខរបរចម្រុះនៅក្នុងសហគមន៍របស់ខ្លួន។

“ជីតារបស់មិត្តភក្តិខ្ញុំគឺជាអ្នកជំនាញក្នុងការធ្វើឧបករណ៍តន្ត្រី។ ប្រាកដណាស់ ខ្ញុំត្រូវតែទៅរៀនពីគាត់។”

*– សិស្ស ថ្នាក់ទី ៦ សាលាបណ្តុះបណ្តាល លេខ ១៥៣ ដែលដាក់ឈ្មោះតាមលោក Abdulla Rozybakiev ប្រទេសកាហ្សាក់ស្ថាន*





## ការស្វែងរកដំណោះស្រាយក្នុងស្រុកចំពោះបញ្ហាបរិស្ថានសកល

សហគមន៍ប្រមូលផ្តុំចំណេះដឹង និងការប្រតិបត្តិ ជាច្រើនទាក់ទងនឹងធនធានធម្មជាតិក្នុងស្រុករបស់ខ្លួន។ ការបង្រៀនជាមួយបេតិកភណ្ឌរស់ អាចរួមចំណែកដល់ការលើកកម្ពស់ការយល់ដឹងអំពីបេតិកភណ្ឌធម្មជាតិ ហើយរួមចំណែកដល់កិច្ចការពារបេតិកភណ្ឌនេះបាន។ នៅក្នុងបរិបទសាលា សិស្សអាចរៀនអំពីវិធីសាស្ត្រក្នុងស្រុកបែបបុរាណ នៅក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ការទប់ស្កាត់ភាពសឹករិចរិល និងគ្រោះធម្មជាតិ ការការពារជីវចម្រុះ និងការកសាងភាពស៊ាំ (ឧទាហរណ៍ បច្ចេកទេសអភិរក្សទឹកក្នុងស្រុក)។ ការធ្វើដូច្នេះ ជួយឱ្យសិស្សរៀនពីរបៀបទប់ស្កាត់ការបំផ្លិចបំផ្លាញបន្ថែម ទៅលើបេតិកភណ្ឌធម្មជាតិក្នុងស្រុក និងបេតិកភណ្ឌវប្បធម៌ដែលពាក់ព័ន្ធ ហើយក្លាយជាពលរដ្ឋសកលលោក។

> ខ្ញុំបានរៀនអំពីទម្លាប់វប្បធម៌ក្នុងស្រុករបស់ខ្ញុំ តាមរយៈមេរៀនអនុវត្តជាក់ស្តែង។ នៅពេលនេះ ខ្ញុំចេះពីរបៀបប្រើប្រាស់សម្ភារៈធម្មជាតិនៅក្នុងពិធីប្រពៃណីរបស់យើង ជំនួសឱ្យសម្ភារៈសំយោគ។
>
> *– សិស្ស ប្រទេសថៃ*

### ការអង្កេតដែលបង្ហាញពីអត្ថប្រយោជន៍របស់ខ្លឹមសារក្នុងស្រុកអំពីបេតិកភណ្ឌរស់ (សាធារណរដ្ឋកូរ៉េ)

គ្រូបង្រៀនម្នាក់បានបែងចែកសិស្សនៅក្នុងថ្នាក់សិក្សាសង្គម ស្តីអំពីបេតិកភណ្ឌវប្បធម៌ និង 'រឿងកន្លែងរបស់យើង' ជាពីរក្រុម។ សិស្សមួយក្រុមរៀនខ្លឹមសារចេញពីសៀវភៅពុម្ព។ សិស្សមួយក្រុមទៀតសិក្សាអំពី "Yeondeungho" (ពិធីបុណ្យភ្លើងគោម) ដែលពិធីបុណ្យនេះកំពុងប្រព្រឹត្តទៅក្នុងពេលតែមួយនៃការរៀន។ អំឡុងពិធីបុណ្យនេះ ប្រជាជនដុតទៀននៅខាងក្រៅផ្ទះ ហើយចូលរួមនៅក្នុងពិធីពុទ្ធសាសនា ក្បួនដង្ហែរ និងព្រឹត្តិការណ៍វប្បធម៌ផ្សេងៗ។ ក្នុងផ្នែកមួយនៃការសិក្សារបស់ខ្លួន អំពីបេតិកភណ្ឌវប្បធម៌ក្នុងតំបន់របស់ខ្លួន សិស្សានុសិស្សនៅក្នុងក្រុមទីពីរ បានស្វែងយល់ពីរបៀបការពារបេតិកភណ្ឌទាក់ទងនឹងពិធីបុណ្យ "Yeondeungho" របៀបធ្វើភ្លើងគោម និងការរៀបចំលិខិតអញ្ជើញសម្រាប់ពិធីបុណ្យនោះ។ បើទោះបីជាសិស្សទាំងពីរក្រុម មានឥរិយាបថវិជ្ជមានចំពោះវប្បធម៌ក្តី ប៉ុន្តែ ៨៧% នៃសិស្សក្នុងក្រុមទីពីរអាចពន្យល់ពីអត្ថន័យនៃពិធីបុណ្យ ចំណែកឯក្រុមផ្សេងទៀត មានតែ ២១% ប៉ុណ្ណោះអាចពន្យល់បាន។ ទន្ទឹមនឹងនេះ ៨៥% នៃក្រុមទីពីរមានការចាប់អារម្មណ៍ខ្លាំងលើការការពារបេតិកភណ្ឌក្នុងស្រុករបស់ខ្លួន ដែលជាចំនួនមួយខ្ពស់ជាងរហូតដល់ទៅពីរដងធៀបនឹងក្រុមម្ខាងទៀត។ ការពិសោធន៍នេះ មានការចូលរួមពីសិស្សក្នុងចំនួនតិចក៏ពិតមែន ប៉ុន្តែវាបានបង្ហាញយ៉ាងច្បាស់ថា ខ្លឹមសារមេរៀនដែលកែច្នៃនាំមកនូវចំណេះដឹងច្រើនជាង ក៏ដូចជាឆន្ទៈខ្លាំងជាងក្នុងការចូលរួមដោយសកម្ម ក្នុងការការពារវប្បធម៌ក្នុងស្រុក។



## បេតិកភណ្ឌរូបី ជាចំណុចចាប់ផ្តើមសម្រាប់ការធ្វើបរិបទនីយកម្ម

ការយោងលើទីតាំងវប្បធម៌ ប្រាសាទ និងវត្ថុក្នុងស្រុក នៅក្នុងមេរៀនអាចធ្វើបរិបទនីយកម្មនៃការរៀន ធ្វើឱ្យកាន់តែពាក់ព័ន្ធ និងលើកកម្ពស់លទ្ធផលសិក្សាផងដែរ។ ទន្ទឹមនឹងនេះ សិស្ស និងក្រុមគ្រួសាររបស់គេដែលស្គាល់បេតិកភណ្ឌក្នុងស្រុកអាចចែករំលែកចំណេះដឹង និងបទពិសោធន៍ របស់ខ្លួនទៅដល់សិស្សផ្សេងទៀត។ ការប្រើប្រាស់បេតិកភណ្ឌរូបី នៅក្នុងការបង្រៀន និងការសិក្សា ក៏អាចបំផុសទឹកចិត្តឱ្យមានការរៀន និងការពិភាក្សាតាមមូលបទអន្តរវិន័យទាក់ទងនឹងបញ្ហាបរិស្ថាន និងសង្គមថែមទៀតផង។

**គន្លឹះ** សំខាន់ៗ

- សាលាអាចបង្រៀន អំពី បេតិកភណ្ឌរស់ (បេតិកភណ្ឌវប្បធម៌អរូបី ជាមុខវិជ្ជាសិក្សា) និង ជាមួយបេតិកភណ្ឌរស់ (បេតិកភណ្ឌវប្បធម៌អរូបីគឺជាសម្ភារៈឧបទេស)។
- ការនាំបេតិកភណ្ឌរស់មកក្នុងថ្នាក់រៀន រួមចំណែកដល់ការការពារបេតិកភណ្ឌរស់។
- វិធីសាស្ត្រនេះរួមចំណែកដល់ការកាត់បន្ថយគម្លាតរវាងអ្វីដែលបានរៀននៅសាលា និងអ្វីដែលបានរៀននៅក្នុងសហគមន៍ ធ្វើឱ្យការសិក្សាកាន់តែមានភាពពាក់ព័ន្ធ។ វិធីសាស្ត្រនេះ បញ្ចូល វិធីសាស្ត្របង្រៀន និងខ្លឹមសារមេរៀនដែលមានគុណភាពខ្ពស់ ដូច្នេះ ជួយនាំមកនូវអត្ថប្រយោជន៍សម្រាប់សិស្ស គ្រូ និងសហគមន៍ ក៏ដូចជារួមចំណែកដល់ការសម្រេចបាននូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទី ៤ (SDG ៤) ផងដែរ។



ការបញ្ចូលបេតិកភណ្ឌរស់
ទៅក្នុងការសិក្សានៅអាស៊ីប៉ាស៊ីហ្វិក
សៀវភៅណែនាំ

កូនសៀវភៅ

3

# ការរៀបចំឱ្យត្រូវគ្នា
# នឹងអាទិភាពអប់រំ

**សៀវភៅនេះ** មានបំណងជួយគាំទ្រគ្រូបង្រៀន អ្នកគ្រប់គ្រងក្នុងវិស័យអប់រំ និងសហគមន៍ ក្នុងការដាក់បញ្ចូលបេតិកភណ្ឌក្នុងស្រុក ទៅក្នុងសកម្មភាពសិក្សា ឲ្យកាន់តែមានភាពប្រទាក់ក្រឡាគ្នា និងមានការចូលរួមកាន់តែច្រើនពីសំណាក់សិស្សានុសិស្ស និងការពារបេតិកភណ្ឌវប្បធម៌។

សៀវភៅនេះ មានកូនសៀវភៅចំនួនប្រាំបួន៖

- កូនសៀវភៅ 1 តើបេតិកភណ្ឌរស់ជាអ្វី ?
- កូនសៀវភៅ 2 ហេតុអ្វីត្រូវបង្រៀនជាមួយបេតិកភណ្ឌរស់ ?
- កូនសៀវភៅ 3 **ការរៀបចំឱ្យត្រូវគ្នាជាមួយអាទិភាពអប់រំ**
- កូនសៀវភៅ 4 វិធីសាស្រ្តប្រាំមួយជំហានសម្រាប់ជាមគ្គុទេសក៍ដល់គ្រូបង្រៀន
- កូនសៀវភៅ 5 តួនាទីរបស់ឪពុកម្តាយ អាណាព្យាបាល និងសមាជិកសហគមន៍
- កូនសៀវភៅ 6 តួនាទីរបស់ថ្នាក់គ្រប់គ្រងសាលា
- កូនសៀវភៅ 7 តួនាទីរបស់អ្នករៀបចំគោលនយោបាយ
- កូនសៀវភៅ 8 ឯកសារ និងធនធាន
- កូនសៀវភៅ 9 សាច់រឿងរបស់គ្រូបង្រៀន

កូនសៀវភៅ
3

# ការរៀបចំឱ្យត្រូវគ្នានឹង អាទិភាពអប់រំ

កូនសៀវភៅនេះពន្យល់ថាតើ ការបង្រៀនជាមួយបេតិកភណ្ឌរស់ ការអប់រំពលរដ្ឋសកល (GCED) និងអាទិភាពអប់រំផ្សេងទៀត ដូចជាការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (ESD) ការសិក្សាអារម្មណ៍សង្គម (SEL) និងការអប់រំតាមភាសាកំណើត (MTBE) អាចបំពេញឱ្យគ្នាទៅវិញទៅមកដូចម្ដេចខ្លះដើម្បីលើកកម្ពស់គុណភាពអប់រំ។

កូនសៀវភៅនេះមានបួនផ្នែក៖

- ការបង្រៀន និងការរៀនជាមួយបេតិកភណ្ឌរស់ដើម្បីលើកកម្ពស់ភាពជាពលរដ្ឋសកល
- ការបង្រៀន និងការរៀនជាមួយបេតិកភណ្ឌរស់ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព
- ការបង្រៀន និងការរៀនជាមួយបេតិកភណ្ឌរស់ និងការសិក្សាអារម្មណ៍សង្គម (SEL)
- ការបង្រៀន និងការរៀនជាមួយបេតិកភណ្ឌរស់ និងការអប់រំតាមភាសាកំណើត (MTBE)



# ៣.១ ការបង្រៀន និងការរៀនជាមួយបេតិកភណ្ឌរស់ដើម្បីលើកកម្ពស់ភាពជាពលរដ្ឋសកល

សកលភាវូបនីយកម្ម និងភាពទាក់ទងគ្នាទៅវិញទៅមក គឺជារឿងជាក់ស្តែងនៅក្នុងសង្គមយើងសព្វថ្ងៃ ដែលនាំមកនូវទាំងអត្ថប្រយោជន៍ផង និងបញ្ហាប្រឈមផង។ អន្តរកម្ម និងការប្រាស្រ័យទាក់ទងគ្នាផ្ទាល់ និងតាមអនឡាញមានសក្តានុពលធ្វើឱ្យកាន់តែខ្លាំងក្នុងវិស័យជាច្រើន (សេដ្ឋកិច្ច សង្គម អារម្មណ៍ វប្បធម៌។ល)។ ប៉ុន្តែ ទន្ទឹមនឹងនេះ ពួកវាក៏នាំមកនូវកំណើននៃការប្រកួតប្រជែង ភាពតានតឹង និងជម្លោះផងដែរ។ នៅក្នុងបរិបទបែបនេះ វាជារឿងចាំបាច់ដែលត្រូវរៀនពីរបៀបថែរក្សាសង្គមដែលមានសន្តិភាព និងប្រកបដោយកិច្ចសហប្រតិបត្តិការ។

## ការអប់រំភាពជាពលរដ្ឋសកល

ការអប់រំភាពជាពលរដ្ឋសកល (GCED) គឺជាវិធីសាស្រ្តអប់រំបែបផ្លាស់ប្តូរ ដែលមានគោលបំណងអប់រំមនុស្សជាពិសេសមនុស្សជំនាន់ក្មេងៗ ឱ្យក្លាយជាពលរដ្ឋសកល។ កម្មវិធីនេះមានបំណងកសាងចំណេះដឹង ជំនាញ គុណតម្លៃ និងឥរិយាបថ ដែលមនុស្សត្រូវការដើម្បីអាចរួមចំណែកធ្វើឱ្យពិភពលោកមានបរិយាបន្ន យុត្តិធម៌ និងសន្តិភាពជាងមុន។ និយាយដោយខ្លី កម្មវិធីនេះជួយឱ្យយើងរៀនរស់នៅជាមួយគ្នា។

ពលរដ្ឋសកល៖

- យើងដឹងពីភាពស្មុគ និងការពឹងផ្អែកគ្នាទៅវិញទៅមក នៅក្នុងពិភពលោកសព្វថ្ងៃ។
- យើងមានអារម្មណ៍ថា យើងស្ថិតក្នុងចំណោមមនុស្សជាតិរួមតែមួយ ហើយបង្ហាញឱ្យឃើញពីសាមគ្គីភាព។
- យើងគោរពចំពោះភាពចម្រុះគ្នា ។
- យើងព្យាយាមដោយឆន្ទៈក្នុងការក្លាយជាភ្នាក់ងារផ្លាស់ប្តូរជាវិជ្ជមាន។



## គោលការណ៍គរុកោសល្យសំខាន់នៃការអប់រំភាពជាពលរដ្ឋសកល (GCED)

ការអប់រំនេះ លើកកម្ពស់គោលការណ៍គរុកោសល្យចំនួនប្រាំមួយ៖

- ការសន្ទនា និងការចូលរួម
- វិធីសាស្ត្រសន្តនិយម និងអន្តរវិន័យ
- វិធីសាស្ត្រចម្រុះ
- ការបង្កើតគុណតម្លៃ
- ការផ្តល់អំណាច និងជំនាញសំខាន់ក្នុងការដោះស្រាយបញ្ហា
- ខ្លឹមសារដែលអាចអនុវត្តបាន និងពាក់ព័ន្ធទាំងនៅក្នុងស្រុក និងសកលលោក

> ការអប់រំភាពជាពលរដ្ឋសកលជួយលើកកម្ពស់វិធីសាស្ត្របែបផ្លាស់ប្តូរ និងសន្តនិយមនៅក្នុងការបង្រៀន ហើយដូច្នេះ គឺតម្រូវឱ្យមានគរុកោសល្យប្រកបដោយភាពបត់បែន និងច្នៃប្រឌិត។

***ការសន្ទនា និងការចូលរួម៖*** ដើម្បី សម្រេចបាននូវអត្ថប្រយោជន៍ពេញលេញរបស់ការអប់រំភាពជាពលរដ្ឋសកល (GCED) យកល្អគួរបង្កើតបរិយាកាសសិស្សមជ្ឈមណ្ឌល ដែលក្នុងនោះ សិស្ស និងគ្រូបង្រៀន អាចពិភាក្សាលើបញ្ហានានា រួមគ្នាបង្កើតចំណេះដឹង និងរៀនអ្វីៗរួមគ្នា។ ការបញ្ចូលបេតិកភណ្ឌរស់មកក្នុងសាលា អាចបង្កើតបរិយាកាសបែបនេះបាន។ ឧទាហរណ៍ សិស្សអាចផ្តោះប្តូរបទពិសោធន៍ផ្ទាល់ខ្លួនរបស់គេទាក់ទងនឹងធាតុនានានៃបេតិកភណ្ឌរស់ណាមួយ៖ តើពួកគេប្រតិបត្តិដូចម្តេច តើគេឱ្យតម្លៃប៉ុណ្ណា ហើយហេតុអ្វី តើទម្លាប់នៃការអនុវត្តពីដូនតានាសព្វថ្ងៃនេះ មានអត្ថន័យដូចម្តេច ហើយតើគេអាចធ្វើអ្វីបានខ្លះដើម្បីការពារបេតិកភណ្ឌនោះ។ តាមរយៈដំណើរការនេះ ពួកគេអាចរៀន និងពិចារណាលើទស្សនៈពីមិត្តរួមថ្នាក់របស់ពួកគេបាន។

***វិធីសាស្ត្រសន្តនិយម និងអន្តរវិន័យ៖*** ការអប់រំភាពជាពលរដ្ឋសកល (GCED) មានបំណងពង្រឹងការយល់ដឹងរបស់សិស្សអំពីទិដ្ឋភាព និងកម្រិតផ្សេងទៀតនៃការភ្ជាប់ទំនាក់ទំនងគ្នា (រវាងមនុស្សនិងមនុស្ស មនុស្សនិងបរិស្ថាន មូលដ្ឋានជាមួយជាតិ ជាតិជាមួយសកលលោក។ល។) បេតិកភណ្ឌរស់ភាគច្រើន ពាក់ព័ន្ធនឹងវិស័យជាច្រើន ហើយត្រូវការជំនាញឯកទេសចម្រុះ ដូច្នេះ បេតិកភណ្ឌរស់ទាំងនោះអាចយកមកប្រើដើម្បីសិក្សាពីការភ្ជាប់ទំនាក់ទំនងបាន។ ឧទាហរណ៍ ការធ្វើកន្ត្រក តម្រូវឱ្យប៉ិនដៃ ចំណេះដឹងអំពីធរណីមាត្រ ដើម្បីបង្កើតក្រឡា និងរាង ក៏ដូចជាការដឹងអំពីបរិស្ថានដើម្បីប្រមូលវត្ថុធាតុដើមសមស្រប។ ដូច្នេះ ការធ្វើកន្ត្រកអាចយកទៅប្រើប្រាស់ដើម្បីស្វែងយល់ពីការភ្ជាប់ទំនាក់ទំនងរវាងវិស័យផ្សេងៗគ្នាទាំងនេះ។

***វិធីសាស្ត្រពហុទម្រង់៖*** ទាំងការអប់រំភាពជាពលរដ្ឋសកល (GCED) និងការបង្រៀនជាមួយបេតិកភណ្ឌរស់មិនមែនជាលំហាត់សិក្សាដែលត្រូវបានកំណត់ឱ្យធ្វើតែនៅក្នុងថ្នាក់រៀននោះឡើយ។ អ្នកប្រតិបត្តិបេតិកភណ្ឌអាចចូលរួម ហើយចែករំលែកគំនិត និងបទពិសោធន៍របស់ខ្លួន។ សិស្សានុសិស្ស និងក្រុមគ្រួសាររបស់គេ និងសហគមន៍ អាចធ្វើការរួមគ្នាដើម្បីស្វែងយល់ និងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមក្នុងស្រុក និងបញ្ហាប្រឈមសកលលោក។

***ការបង្កើតគុណតម្លៃ៖*** តាមរយៈ ការអប់រំភាពជាពលរដ្ឋសកល (GCED) សិស្សរៀនអំពីគុណតម្លៃសំខាន់ៗជាសកល នៃការគោរពសិទ្ធិមនុស្ស ការអត់ឱន ការគោរពចំពោះចម្រុះភាព យុត្តិធម៌សង្គម សមភាព និងនិរន្តរភាពបរិស្ថាន។ ការស្វែងយល់ពីបេតិកភណ្ឌរស់នៅក្នុងថ្នាក់រៀន អាចបង្កើតឱ្យមានការត្រិះរិះទៅលើគុណតម្លៃទាំងអស់នេះ និងអត្ថន័យនៃគុណតម្លៃទាំងនេះ សម្រាប់សមាជិកនានារបស់សហគមន៍ ដែលអនុញ្ញាតឱ្យសិស្សអភិវឌ្ឍគុណតម្លៃ និងគោលការណ៍វិជ្ជមាន នៅក្នុងកម្រិតមួយដែលទូលំទូលាយ។

***ការផ្តល់អំណាច និងជំនាញសំខាន់ក្នុងការដោះស្រាយបញ្ហា៖*** ការអប់រំភាពជាពលរដ្ឋសកល (GCED) បង្រៀនសិស្សអំពីបញ្ហាប្រឈមសកល ហើយផ្តល់សមត្ថភាពដល់ពួកគេក្នុងការវាយតម្លៃបញ្ហាប្រឈមបានស៊ីជម្រៅ និង



រៀបចំបង្កើត និងអនុវត្តវិធានការ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ។ ការសិក្សាបេតិកភណ្ឌរស់ អនុញ្ញាតឱ្យសិស្សគិតស៊ីជម្រៅ អំពីក្តីកង្វល់ក្នុងស្រុក ហើយតើកង្វល់ទាំងនេះមានទំនាក់ទំនងយ៉ាងណាជាមួយនឹងបញ្ហាជាតិ និងសកលលោក។ សិស្សអាចវិភាគ និងពិភាក្សាថាតើសកលភាវូបនីយកម្មគំរាមកំហែងដូចម្តេចខ្លះមកលើវប្បធម៌របស់ពួកគេ ហើយថាតើវាជួយពង្រឹងវប្បធម៌របស់គេដូចម្តេចខ្លះ (តាមរយៈការផ្លោះប្តូរ) និងពិភាក្សាថាតើពួកគេមានចក្ខុវិស័យដូចម្តេចទៅថ្ងៃអនាគតសម្រាប់ការប្រតិបត្តិបេតិកភណ្ឌនោះ។

***ខ្លឹមសារដែលអាចអនុវត្តបាន និងពាក់ព័ន្ធទាំងនៅក្នុងស្រុក និងសកលលោក៖*** ការអប់រំភាពជាពលរដ្ឋសកល (GCED) ទទួលស្គាល់ថា ការបញ្ចូលចំណេះដឹង និងជំនាញពាក់ព័ន្ធនៅក្នុងថ្នាក់រៀន ផ្តល់លទ្ធភាពឱ្យសិស្សអាចអនុវត្តនូវអ្វីដែលគេបានរៀន នៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ទាំងនៅសាលា និងនៅផ្ទះ។ ស្រដៀងគ្នានេះ បេតិកភណ្ឌរស់ ត្រូវបានបញ្ចូលទៅក្នុងបរិបទក្នុងស្រុក/ជាតិ និងតថភាពជាក់ស្តែង។ នៅពេលដែលបេតិកភណ្ឌរស់ត្រូវបានបញ្ចូលទៅក្នុងសាលា វាជាចំណុចដែលគេស្គាល់ សម្រាប់ជួយដល់ទិដ្ឋភាពទ្រឹស្តីនៃកម្មវិធីសិក្សា។ គ្រូបង្រៀនអាចធ្វើបរិបទនីយកម្មមេរៀនរបស់ខ្លួន ហើយសិស្សអាចចូលរួមកាន់តែសកម្ម។

---

តារាង ៣.១ ទិដ្ឋភាពផ្នែកយល់ដឹង អារម្មណ៍សង្គម និងឥរិយាបថនៃ ការអប់រំភាពជាពលរដ្ឋសកល (GCED)




ឯកសារយោង៖ UNESCO, 2016, Schools in Action: Global Citizens for Sustainable Development - A Guide for Teachers CLICK

## ការបង្រៀនជាមួយបេតិកភណ្ឌរស់ និងការអប់រំភាពជាពលរដ្ឋសកល (GCED)៖ ការភ្ជាប់មូលបទសិក្សា

ដូចមានបង្ហាញនៅក្នុងតារាង ៣.១ ការអប់រំភាពជាពលរដ្ឋសកល (GCED) ត្រូវបានគ្របដណ្តប់ដោយទិដ្ឋភាពទស្សនាទានចំនួនបីដែលជាប់ទាក់ទងគ្នា៖ ការយល់ដឹង អារម្មណ៍សង្គម និងឥរិយាបថ។

តារាង ៣.១ ទិដ្ឋភាពផ្នែកយល់ដឹង អារម្មណ៍សង្គម និងឥរិយាបថនៃការអប់រំភាពជាពលរដ្ឋសកល (GCED)

| **ទិដ្ឋភាពនៃការយល់ដឹង** | |
|---|---|
| **គោលដៅនៃការអប់រំភាពជាពលរដ្ឋសកល** (GCED) | **ឆ្ពោះទៅរកការអប់រំភាពជាពលរដ្ឋសកលជាមួយនឹងបេតិកភណ្ឌវប្បធម៌អរូបី** (ICH) |
| ទទួលបានចំណេះដឹង និងជំនាញគិតដែលចាំបាច់សម្រាប់ស្វែងយល់ឱ្យកាន់តែច្បាស់អំពីពិភពលោក និងភាពស្មុគស្មាញរបស់ពិភពលោក។ | ដឹងពីតួនាទីរបស់បេតិកភណ្ឌវប្បធម៌អរូបី នៅក្នុងបញ្ហាក្នុងស្រុក ជាតិ និងសកលលោក។<br><br>រៀន និងគិតស៊ីជម្រៅអំពីបេតិកភណ្ឌវប្បធម៌អរូបី គុណតម្លៃ និងវិធីដើម្បីការពារ។ |
| **បុគ្គលិកលក្ខណៈសម្បត្តិរបស់សិស្សត្រូវបានអភិវឌ្ឍន៍តាមរយៈ ការអប់រំភាពជាពលរដ្ឋសកល** (GCED) | **ឧទាហរណ៍បង្ហាញអំពីការត្រិះរិះទាក់ទងនឹងបេតិកភណ្ឌវប្បធម៌អរូបី ដែលរួមចំណែកដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈសម្បត្តិទាំងអស់នេះ។** |
| **សិស្សត្រូវតែដឹងពីព័ត៌មាន និងចេះអក្សរជ្រៅជ្រះ** | |
| ស្គាល់អំពីបញ្ហាក្នុងស្រុក ជាតិ និងសកលលោក ប្រព័ន្ធអភិបាលកិច្ច និងវេទនាសម្ព័ន្ធនានា | យល់ពីប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន និងការសម្រេចចិត្ត។<br><br>កំណត់រកយន្តការដោះស្រាយជម្លោះ ដែលសមស្របតាមវប្បធម៌ សម្រាប់សហគមន៍មូលដ្ឋាន និងសកលលោក។ |
| យល់ពីការពឹងផ្អែកគ្នាទៅវិញទៅមក និងទំនាក់ទំនងរវាងក្តីកង្វល់សកលលោក ក្តីកង្វល់ជាតិ និងក្នុងមូលដ្ឋាន។ | ធ្វើបញ្ជីបេតិកភណ្ឌវប្បធម៌អរូបី ដែលអាចនឹងផុតរលត់ ហើយពិនិត្យមើលថាតើការការពារបេតិកភណ្ឌទាំងនោះ រងផលប៉ះពាល់ដោយសារបញ្ហាសកលលោក ឬយ៉ាងណា។<br><br>ធ្វើបញ្ជីស្តីពីភាពស្រដៀងគ្នា និងភាពខុសគ្នានៃបេតិកភណ្ឌវប្បធម៌អរូបី ដែលបានមកពីសហគមន៍ និងបណ្តាប្រទេសនានា។<br><br>សិក្សាមើលថាតើចំណេះដឹង និងការប្រតិបត្តិទាក់ទងនឹងបេតិកភណ្ឌវប្បធម៌អរូបី អាចដោះស្រាយបញ្ហាធំៗមួយចំនួននៅកម្រិតមូលដ្ឋានបានដូចម្តេចខ្លះ។ |

| **បុគ្គលិកលក្ខណៈសម្បត្តិរបស់សិស្សត្រូវបានអភិវឌ្ឍន៍តាមរយៈ ការអប់រំភាពជាពលរដ្ឋសកល** (GCED) | **ឧទាហរណ៍បង្ហាញអំពីការត្រិះរិះទាក់ទងនឹងបេតិកភណ្ឌវប្បធម៌អរូបី ដែលរួមចំណែកដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈសម្បត្តិទាំងអស់នេះ។** |
|---|---|
| អភិវឌ្ឍជំនាញសម្រាប់ការសាកសួរ និងការវិភាគស៊ីជម្រៅ។ | អនុវត្តការស្រាវជ្រាវ និងការវិភាគអំពីបេតិកភណ្ឌវប្បធម៌អរូបី។<br><br>រៀនវិធីសាស្ត្រក្នុងស្រុកក្នុងការប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយព័ត៌មាន និងចំណេះដឹងផ្សេងៗ ដល់សហគមន៍ រាប់បញ្ចូលទាំង អនុក្រុម និងក្រុមបាត់ឱកាស និងងាយរងគ្រោះផងនៅក្នុងសហគមន៍។<br><br>នៅក្នុងសហគមន៍មូលដ្ឋាន ចូរកំណត់រកបុគ្គលយោងដែលអាចជឿជាក់បាន (ដែលមានចំណេះដឹង និង/ឬអំណាចមានការទទួលស្គាល់។ល។) និងប្រភពព័ត៌មានទៅតាមជំនាញឯកទេស<br>ផ្សេងៗ (ឧទាហរណ៍ សុខាភិបាល បរិស្ថាន សេដ្ឋកិច្ច អភិបាលកិច្ច វប្បធម៌។ល។) ជាពិសេសអ្នកដែលពាក់ព័ន្ធនឹងការចេះដឹង និងការប្រតិបត្តិនៅក្នុងមូលដ្ឋាន។ |
| **ទិដ្ឋភាពនៃអារម្មណ៍សង្គម** | |
| **គោលដៅ នៃការអប់រំភាពជាពលរដ្ឋសកល** (GCED) | **ឆ្ពោះទៅរកការអប់រំភាពជាពលរដ្ឋសកល ជាមួយនឹងបេតិកភណ្ឌរស់** |
| ស្គាល់ពីភាពជាផ្នែកមួយនៃមនុស្សជាតិជារួម ដែលមានគុណតម្លៃ និងទំនួលខុសត្រូវ ការយល់ចិត្ត សាមគ្គីភាព និងការគោរពចំពោះភាពផ្សេងគ្នា និងភាពចម្រុះគ្នា។ | កសាងឥរិយាបថដើម្បីឱ្យតម្លៃ និងគោរពចំពោះបេតិកភណ្ឌវប្បធម៌អរូបីរបស់ខ្លួនឯងក៏ដូចជារបស់អ្នកដទៃ។ |
| **បុគ្គលិកលក្ខណៈសម្បត្តិរបស់សិស្សត្រូវបានអភិវឌ្ឍន៍តាមរយៈ ការអប់រំភាពជាពលរដ្ឋសកល** (GCED) | **ឧទាហរណ៍បង្ហាញអំពីសកម្មភាពទាក់ទងនឹងបេតិកភណ្ឌវប្បធម៌អរូបី ដែលរួមចំណែកដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈសម្បត្តិទាំងអស់នេះ** |
| សិស្សត្រូវតែមានទំនាក់ទំនងសង្គម ហើយចេះគោរពចំពោះចម្រុះភាព។ | |
| បណ្តុះ និងគ្រប់គ្រងអត្តសញ្ញាណទំនាក់ទំនង និងអារម្មណ៍នៃភាពជាម្ចាស់។ | កំណត់ពីគុណតម្លៃ ជំនាញ និងចំណេះដឹង ដែលជួយបង្កើតអត្តសញ្ញាណរបស់មនុស្សម្នាក់ នៅក្នុងសហគមន៍ មួយ (ហើយប្រៀបធៀបចំណុចខាងលើជាមួយនឹងមនុស្សនៅក្នុងសហគមន៍ផ្សេងទៀត) ហើយកំណត់មើលថាតើចំណុចខាងលើនេះផ្សារភ្ជាប់យើងជាមួយនឹងសហគមន៍ផ្សេងទៀតតាមរបៀបណា។ |
| ចែករំលែកគុណតម្លៃ និងទំនួលខុសត្រូវផ្អែកលើសិទ្ធិមនុស្ស។ | កំណត់រក គុណតម្លៃ និងជំនាញសំខាន់ៗដែលមនុស្សលើកកម្ពស់ ដើម្បីរស់នៅប្រកបដោយសន្តិភាព នៅក្នុងសហគមន៍របស់ខ្លួន និងជាមួយអ្នកដទៃ (ការគោរព ការអត់ឱន និងការយោគយល់ សាមគ្គីភាព ការយល់ចិត្ត ការយកចិត្តទុកដាក់ សមភាព បរិយាបន្ន និងសេចក្តីថ្លៃថ្នូរបស់មនុស្ស)។ |

| **បុគ្គលិកលក្ខណៈសម្បត្តិរបស់សិស្សត្រូវបានអភិវឌ្ឍន៍តាមរយៈ ការអប់រំភាពជាពលរដ្ឋសកល** (GCED) | **ឧទាហរណ៍បង្ហាញអំពីសកម្មភាពទាក់ទងនឹងបេតិកភណ្ឌវប្បធម៌អរូបី ដែលរួមចំណែកដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈសម្បត្តិទាំងអស់នេះ** |
|---|---|
| អភិវឌ្ឍឥរិយាបថនៅក្នុងការឱ្យតម្លៃ និងគោរពចំពោះភាពផ្សេងៗគ្នា និងភាពចម្រុះគ្នា។ | កំណត់រកសហគមន៍ ដែលប្រតិបត្តិតាមបេតិកភណ្ឌវប្បធម៌អរូបីដែលដូចគ្នា ឬស្រដៀងគ្នា នឹងសហគមន៍របស់អ្នកដែរ។<br>ស្វែងយល់ និងឱ្យតម្លៃ ថាតើបេតិកភណ្ឌវប្បធម៌អរូបីខុសគ្នា បំពេញគោលបំណងដូចគ្នា ដូចម្តេចខ្លះ ឬលើកកម្ពស់គុណតម្លៃដូចគ្នានៅតាមសហគមន៍ផ្សេងគ្នាដូចម្តេចខ្លះ។ |
| **ទិដ្ឋភាពផ្នែកឥរិយាបថ** | |
| **គោលដៅ នៃការអប់រំភាពជាពលរដ្ឋសកល** (GCED) | **ឆ្ពោះទៅរកការអប់រំភាពជាពលរដ្ឋសកល** (GCED) **ជាមួយនឹងបេតិកភណ្ឌរស់** |
| ប្រព្រឹត្តទង្វើដែលមានប្រសិទ្ធភាព និងទំនួលខុសត្រូវនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងកម្រិតសកលលោក ដើម្បីឱ្យពិភពលោកកាន់តែមានសន្តិភាព និងនិរន្តរភាព។ | ផ្តួចផ្តើមសកម្មភាព និងគម្រោងនានាដែលរួមចំណែកដល់ការប្រតិបត្តិ និងការការពារបេតិកភណ្ឌវប្បធម៌អរូបី។<br>ផ្តួចផ្តើមសកម្មភាព និងគម្រោងនានាដែល ក្នុងនោះ ការប្រតិបត្តិបេតិកភណ្ឌវប្បធម៌អរូបីជួយពង្រឹងឥរិយាបថប្រកបដោយទំនួលខុសត្រូវស្របតាមក្រមសីលធម៌។ |
| **បុគ្គលិកលក្ខណៈសម្បត្តិរបស់សិស្សត្រូវបានអភិវឌ្ឍន៍តាមរយៈ ការអប់រំភាពជាពលរដ្ឋសកល** (GCED) | **ឧទាហរណ៍បង្ហាញអំពីសកម្មភាពទាក់ទងនឹងបេតិកភណ្ឌវប្បធម៌អរូបី ដែលរួមចំណែកដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈសម្បត្តិទាំងអស់នេះ** |
| **សិស្សត្រូវតែមានទំនួលខុសត្រូវ និងចូលរួមប្រកបដោយក្រមសីលធម៌។** | |
| ប្រើប្រាស់ជំនាញ គុណតម្លៃ ជំនឿ និងអាកប្បកិរិយាសមស្រប | ពិនិត្យមើលថាតើបុគ្គល ឬប្រជាជននានា បានជួយកែលម្អសហគមន៍របស់ខ្លួន និងពិភពលោកដែលយើងរស់នៅតាមរបៀបណា  តាមរយៈការប្រតិបត្តិបេតិកភណ្ឌវប្បធម៌អរូបីផ្សេងៗ។ |
| បង្ហាញឱ្យឃើញពីទំនួលខុសត្រូវផ្ទាល់ខ្លួន និងសង្គម ដើម្បីឱ្យពិភពលោកមានសន្តិភាព និងនិរន្តរភាព។ | អនុវត្តយន្តការស្តីពីការសហការ ការសម្រេចចិត្ត និងជំនាញដោះស្រាយបញ្ហាដោយគោរពតាមគំរូនៅក្នុងស្រុក ប្រសិនបើគំរូទាំងអស់នោះជួយបន្ថែមគុណតម្លៃដល់ដំណើរការខាងដើមនេះ។ |
| កសាងកម្លាំងចិត្ត និងឆន្ទៈ ដើម្បីយកចិត្តទុកដាក់ចំពោះអត្ថប្រយោជន៍រួម។ | ចូលរួមក្នុងសកម្មភាពជាមួយសហគមន៍ ជាពិសេសដើម្បីការការពារបេតិកភណ្ឌវប្បធម៌អរូបី។ ផ្សព្វផ្សាយ និងបង្ហាញបេតិកភណ្ឌរស់ ជាមួយនឹងឥទ្ធិពលវិជ្ជមានផ្នែកសង្គម និងបរិស្ថាន ហើយជំរុញលើកទឹកចិត្តប្រជាជនឱ្យអនុវត្ត និងផ្សព្វផ្សាយមរតកវប្បធម៌អរូបី ទាំងអស់នេះ។ |

តារាងនេះត្រូវបានដកស្រង់ចេញពី UNESCO ឆ្នាំ 2015 ការអប់រំភាពពលរដ្ឋសកល៖ ប្រធានបទ និងកម្មវត្ថុនៃការសិក្សា ដែលបានសម្របសម្រួលទៅតាមទំនាក់ទំនងរវាង GCED និងការបង្រៀនបេតិកភណ្ឌរស់ក្នុងថ្នាក់រៀន។



## តើការអប់រំភាពជាពលរដ្ឋសកល (GCED) ទទួលបានអត្ថប្រយោជន៍ពីការបង្រៀនជាមួយបេតិកភណ្ឌរស់ដូចម្តេចខ្លះ?

ការអប់រំភាពជាពលរដ្ឋសកល (GCED)អាចទទួលអត្ថប្រយោជន៍ច្រើនយ៉ាង ពីការបង្រៀនជាមួយបេតិកភណ្ឌរស់ ដែលមានដូចជា៖

- ការអប់រំអំពីបេតិកភណ្ឌ ជួយឱ្យយើងដឹងអំពីវប្បធម៌របស់យើង និងវប្បធម៌ផ្សេងទៀត។ សិស្សចេះឱ្យតម្លៃចំពោះភាពចម្រុះនៃវប្បធម៌ នៅពេលបានរៀន និងដឹងថាពួកគេជាផ្នែកមួយនៃមនុស្សជាតិជារួម ដែលមានគុណតម្លៃស្រដៀងគ្នា។
- ការអប់រំពីបេតិកភណ្ឌ ជួយបង្ហាញឱ្យឃើញពីដំណោះស្រាយនៅមូលដ្ឋាន ចំពោះបញ្ហាប្រឈមជាសាកលក្នុងវិស័យនានាដូចជាភាពស្អិតរមួតក្នុងសង្គម ការអប់រំ សន្តិសុខស្បៀង សុខភាព និងការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃធនធានធម្មជាតិ។
- ការអប់រំពីបេតិកភណ្ឌ នាំមកនូវទិដ្ឋភាពមូលដ្ឋានសម្រាប់ការអប់រំភាពជាពលរដ្ឋសកល (GCED) ជាមួយនឹងខ្លឹមសារមេរៀន និងគរុកោសល្យ សមស្របទៅតាមបរិបទ។
- ការអប់រំអំពីបេតិកភណ្ឌ ជួយសម្រួលឱ្យមានវិធីសាស្ត្រគរុកោសល្យប្រកបដោយប្រសិទ្ធភាព ព្រមជាមួយនឹងសកម្មភាពបែបសហការ និងអនុវត្តផ្ទាល់។ គោលការណ៍ នៃការអប់រំភាពជាពលរដ្ឋសកល (GCED) អាចអនុវត្តចំពោះការបង្រៀនជាមួយបេតិកភណ្ឌរស់ ហើយអាចដាក់បញ្ចូលទៅក្នុងការធ្វើកិច្ចតែងការបង្រៀនទៅតាមបរិបទផ្សេងៗគ្នា និងណែនាំផ្លូវគ្រូបង្រៀនក្នុងការបង្កើតយុទ្ធសាស្ត្រ និងវិធីសាស្ត្រក្នុងថ្នាក់រៀនដែលសមស្រប។
- តាមរយៈការអប់រំអំពីបេតិកភណ្ឌ សិស្សដឹងថាបេតិកភណ្ឌរស់របស់ពួកគេអាចវិវត្ត ហើយ លើកទឹកចិត្តឱ្យធ្វើយ៉ាងណា រក្សាសារៈសំខាន់នៃបេតិកភណ្ឌ តាមរយៈការបន្តអនុវត្តប្រតិបត្តិ។
- ការអប់រំពីបេតិកភណ្ឌអនុញ្ញាតឱ្យសិស្សស្វែងយល់ និងឱ្យតម្លៃថាតើការប្រតិបត្តិបេតិកភណ្ឌ វប្បធម៌អរូបី អាចរួមចំណែកដូចម្តេចខ្លះ ដល់ការដោះស្រាយបញ្ហាសកលបច្ចុប្បន្ន។
- ការអប់រំពីបេតិកភណ្ឌ អនុញ្ញាតឱ្យសិស្សស្វែងយល់ពីបេតិកភណ្ឌរស់ ដែលត្រូវបានប្រតិបត្តិពីបុរាណ ដោយក្រុមជនជាតិភាគតិច ឬមានតែបុរសជាអ្នកប្រតិបត្តិ ឬមានតែស្ត្រីជាអ្នកប្រតិបត្តិ។ ចំណេះដឹងនេះលើកកម្ពស់ដល់បរិយាបន្ន និងពង្រីកឱកាសសម្រាប់ការផ្សព្វផ្សាយ ដែលមានទំនាក់ទំនងយ៉ាងល្អជាមួយការអប់រំភាពជាពលរដ្ឋសកល (GCED) ព្រោះការអប់រំនេះលើកកម្ពស់សមធម៌ និងយុត្តិធម៌សង្គម រួមទាំងក្នុងការប្រតិបត្តិវប្បធម៌ផងដែរ។





## *ការធ្វើគីមឈី* ជាចំណុចចូលដើម្បីស្វែងយល់ពីមូលបទ អប់រំភាពជាពលរដ្ឋសកល (សាធារណរដ្ឋកូរ៉េ)

សាលាមធ្យមសិក្សា Geunyoung ជាសាលានៅក្នុង បណ្តាញគម្រោងសាលាយូណេស្កូ (ASPnet) លើកកម្ពស់ភាពជាពលរដ្ឋសកល និងការអភិវឌ្ឍប្រកបដោយចីរភាព។ សាលានេះបានចាប់ផ្តើមអនុវត្តគម្រោងស្រាវជ្រាវមួយ ស្តីពីគីមឈី និង*kimjang*។ *គីមឈី* គឺជាមុខម្ហូបដ៏ល្បី ធ្វើពីបន្លែប្រៃ និងអប់ឱ្យជូរ។ *Kimjang* គឺជាដំណើរការនៃការធ្វើគីមឈី នៅក្នុងសហគមន៍ ហើយនិងការចែករំលែកគីមឈីនេះ ដើម្បីធានាថាគ្រប់ក្រុមគ្រួសារទាំងអស់ មានម្ហូបអាហារគ្រប់គ្រាន់ដើម្បីទទួលទានពេញមួយរដូវរងារ។ សាលានេះបានជ្រើសរើសយកបេតិកភណ្ឌរស់មួយនេះ ពីព្រោះ *គីមឈី* គឺជាអាហារតំណាងឱ្យប្រទេសកូរ៉េ។ ទន្ទឹមនឹងនេះដែរឬ នៅក្នុងប្រទេសកូរ៉េ គីមឈីខុសគ្នាពីតំបន់មួយទៅតំបន់មួយ ហើយវិធីធ្វើវិញមានពេលខ្លះ ថែមទាំងខុសគ្នាទៅតាមគ្រួសារនីមួយៗ សូម្បី នៅក្នុងតំបន់តែមួយក៏ដោយ។

*គីមឈី*ជាប្រធានបទមួយល្អសម្រាប់ការស្វែងរកគំនិតស្តីពីចម្រុះភាពផ្នែកវប្បធម៌។ ថ្វីដ្បិតសកម្មភាពធំនៃការធ្វើគីមឈី ប្រព្រឹត្តទៅនៅក្នុងរដូវស្លឹកឈើជ្រុះក្តី ប៉ុន្តែក្រុមគ្រួសារនានាដើរទិញគ្រឿងផ្សំពេញមួយឆ្នាំ។ តាមរយៈការសិក្សាអំពី*គីមឈី* និង *kimjang* សិស្សបានទទួលការយល់ដឹងអំពីសារៈសំខាន់នៃការធ្វើកសិកម្ម និងផលផលប្រកបដោយនិរន្តរភាព ការរស់នៅប្រកបដោយសុខដុមរមនាជាមួយនឹងធម្មជាតិ និងទម្លាប់នៃការទទួលទានអាហារសុខភាព។ សិស្សក៏បានដឹងថា កិច្ចសហប្រតិបត្តិការជារឿងសំខាន់នៅក្នុងសហគមន៍ ហើយអាចជួយកាត់បន្ថយបញ្ហាទាក់ទងនឹងភាពក្រីក្របាន។

# ៣.២ ការបង្រៀន និងការរៀនជាមួយបេតិកភណ្ឌរស់ដើម្បីលើកកំពស់ការអភិវឌ្ឍប្រកបដោយចីរភាព

## ការអភិវឌ្ឍដោយចីរភាព និងការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព( ESD )

### ការអភិវឌ្ឍដោយចីរភាព

ការអភិវឌ្ឍដោយចីរភាព គឺជាប្រភេទនៃការអភិវឌ្ឍដែលយើងលើកកម្ពស់គុណភាពជីវិតសម្រាប់មនុស្សជំនាន់យើង ទន្ទឹមនឹងនោះក៏ធានាបានថាធនធានធម្មជាតិ និងវប្បធម៌នឹងមានវត្តមានដើម្បីលើកកម្ពស់គុណភាពជីវិតរបស់មនុស្សជំនាន់ក្រោយ។

ក្នុងឆ្នាំ២០១៥ រដ្ឋសមាជិកទាំងអស់របស់អង្គការសហប្រជាជាតិបានអនុម័តរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍដោយចីរភាព រួមទាំងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (SDGs) ចំនួន ១៧ គោលដៅ ដោយមានគោលបំណងបញ្ចប់ភាពក្រីក្រ កិច្ចការពារភពផែនដី និងការកែលម្អជីវិត និងការរំពឹងទុករបស់មនុស្សគ្រប់រូបនៅគ្រប់ទីកន្លែង។ ដើម្បីសម្រេចបាននូវរបៀបវារៈឆ្នាំ២០៣០ និងគោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDGs) អ្នកពាក់ព័ន្ធទាំងអស់ដូចជា យុវជន សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ វិស័យឯកជន សាលា និងរដ្ឋាភិបាលជាដើម ត្រូវចាត់វិធានការនៅកម្រិតពិភពលោក ថ្នាក់ជាតិ និងមូលដ្ឋាន។

### ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព

ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD) គឺជាវិធីសាស្ត្រផ្លាស់ប្តូរពេញមួយជីវិតដែលមានគោលបំណងធ្វើឱ្យមនុស្សគ្រប់រូបទទួលបាននូវចំណេះដឹង ជំនាញ អាកប្បកិរិយា និងគុណតម្លៃដែលចាំបាច់សម្រាប់ការបង្កើត



សង្គមប្រកបដោយនិរន្តរភាព។ ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD) គ្របដណ្តប់លើ ការសិក្សាអន្តរវិស័យ សម្រាប់មុខវិជ្ជាផ្សេងៗ ដូចជាចម្រុះភាពផ្នែកវប្បធម៌ សមភាពយេនឌ័រ សុខាភិបាល ជីវចម្រុះ និងផលិតកម្ម និងការប្រើប្រាស់ដោយនិរន្តរភាព។

ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាពនេះ ព្យាយាមផ្តល់លទ្ធភាពឱ្យសិស្សអាចធ្វើការសម្រេចចិត្តដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ ហើយចាត់វិធានការជាលក្ខណៈបុគ្គល ឬជាសមូហភាព ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគត ដើម្បីកែប្រែសង្គមរបស់យើង ហើយយកចិត្តទុកដាក់ចំពោះភពផែនដី។ ការធ្វើដូច្នេះបានតម្រូវឱ្យសិស្សរៀនដើម្បីមានសមត្ថភាពនានា ដូចជាការគិតស៊ីជម្រៅ ការស្រមៃមើលសេណារីយ៉ូទៅថ្ងៃអនាគត និងការធ្វើគោលនយោបាយដោយកិច្ចសហការ។ ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD) គឺផ្អែកលើវិធីសាស្ត្រនៃការបង្រៀន និងការរៀនបែបចូលរួម ដែលជំរុញទឹកចិត្ត និងផ្តល់អំណាចដល់សិស្សក្នុងការផ្លាស់ប្តូរឥរិយាបថរបស់ខ្លួន ហើយចាត់វិធានការដើម្បីឱ្យមានការអភិវឌ្ឍដោយចីរភាព។

ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD) ផ្តោតលើបញ្ហានានាចំនួនបីដែលមានភាពពាក់ព័ន្ធគ្នា៖

- ***សង្គម៖*** សិទ្ធិមនុស្ស សន្តិភាព និងសន្តិសុខមនុស្ស សមភាពយេនឌ័រ សុខាភិបាល អភិបាលកិច្ច ភាពចម្រុះផ្នែកវប្បធម៌ បេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌសំណង់ ព្រមទាំងចំណេះដឹង និងជំនាញក្នុងមូលដ្ឋាន។
- ***បរិស្ថាន៖*** ជីវចម្រុះ ធនធានធម្មជាតិ បរិស្ថានធម្មជាតិ និងអាកាសធាតុរបស់ផែនដី។
- ***សេដ្ឋកិច្ច៖*** ភាពក្រីក្រ របាយប្រាក់ចំណូល ការងារធ្វើ និងមុខរបរ។

> " គោលដៅអភិវឌ្ឍន៍ដោយនិរន្តរភាព (SDGs) ផ្តល់នូវក្របខ័ណ្ឌដែលមានភាពបត់បែន ដើម្បីបញ្ចូលប្រធានបទនានាទៅក្នុងថ្នាក់រៀន និងសកម្មភាពសាលារៀន។ "

**តើការបង្រៀនជាមួយបេតិកភណ្ឌរស់ រួមចំណែកដូចម្តេចដល់ការសម្រេចបាននូវការអភិវឌ្ឍដោយចីរភាព?**

បេតិកភណ្ឌរស់រួមចំណែកដល់ការសម្រេចបាននូវផ្នែកជាច្រើន នៃការអភិវឌ្ឍដោយចីរភាព ដូចដែលបានរៀបរាប់ខាងក្រោម។

***និរន្តរភាពសង្គម៖***

- ទម្លាប់ប្រតិបត្តិសង្គម ពិធីសាសនា និងពិធីបុណ្យនានា → ភាពស្អិតរមួតរបស់សង្គមក្នុងសហគមន៍។
- វិធីសាស្ត្រគរុកោសល្យ និងខ្លឹមសារក្នុងស្រុក → ការអប់រំដែលមានគុណភាព។
- ទម្លាប់ព្យាបាលសុខភាពបែបបុរាណ → សុខុមាលភាព និងសេវាថែទាំសុខភាពដែលមានគុណភាព និងតម្លៃសមរម្យ ដែលបំពេញបន្ថែមឱ្យប្រព័ន្ធសុខាភិបាលជាតិ។
- ការវិវត្តន៍នូវតួនាទីនៅក្នុងសហគមន៍ → ឱកាសក្នុងការកាត់បន្ថយការរើសអើងដោយសារយេនឌ័រ។
- ការដាំដុះ នេសាទ បរបាញ់ និងការអភិរក្សចំណីអាហារបែបបុរាណ → សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

***និរន្តរភាពផ្នែកសេដ្ឋកិច្ច៖***

- របៀបរស់នៅបែបប្រពៃណី → ការផលិត និងការប្រើប្រាស់ប្រកបដោយទំនួលខុសត្រូវនៃផលិតផលដែលផលិតពីវត្ថុធាតុដើមក្នុងស្រុក និងដំណើរការដែលមិនប៉ះពាល់ដល់បរិស្ថាន។
- កសិកម្ម និងការធ្វើសិប្បកម្មបែបប្រពៃណី → បង្កើតប្រាក់ចំណូល និងការងារសមរម្យសម្រាប់មនុស្សជាច្រើន។



- ប្រពៃណី និងចំណេះដឹងក្នុងស្រុក ➔ ការបំផុសគំនិតសម្រាប់វិចិត្រករក្នុងឧស្សាហកម្មវប្បធម៌ និងច្នៃប្រឌិត។
- ផលិតផលក្នុងស្រុក សកម្មភាព ពិធីសាសនា ពិធីបុណ្យ ➔ ប្រាក់ចំណូលពីទេសចរណ៍វប្បធម៌។

***និរន្តរភាពផ្នែកបរិស្ថាន៖***

- ចំណេះដឹង និងជំនាញក្នុងស្រុក ដែលកែសម្រួលទៅតាមកាលៈទេសៈនៅក្នុងស្រុក ឧទាហរណ៍៖ វិធីសាស្ត្រក្នុងស្រុកក្នុងការអភិរក្សជីវចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ដូចជាការអនុវត្តការគ្រប់គ្រងទឹកបែបប្រពៃណី ដែលនាំទៅដល់ការប្រើប្រាស់ទឹកប្រកបដោយនិរន្តរភាព កិច្ចការពារប្រភពទឹកក្នុងស្រុក និងការទទួលបានទឹកស្អាតដោយសមធម៌។
- យុទ្ធសាស្ត្រក្នុងស្រុកដើម្បីកាត់បន្ថយហានិភ័យទាក់ទងនឹងគ្រោះមហន្តរាយធម្មជាតិ និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

***សន្តិភាព៖***

ទម្លាប់នៃការសន្ទនាបែបសង្គមក្នុងស្រុក និងដំណោះស្រាយជម្លោះ (ការទប់ស្កាត់វិវាទ និងដំណោះស្រាយចំពោះវិវាទ)។

- បទប្បញ្ញត្តិក្នុងស្រុកទាក់ទងនឹងការចូលទៅប្រើទីធ្លារួម និងធនធានធម្មជាតិ។
- វិធីសាស្ត្របុរាណសម្រាប់សហគមន៍ និងការគាំទ្រសាសនា។
- បច្ចេកទេសក្នុងស្រុកដើម្បីកសាងភាពស៊ាំ និងសមត្ថភាពដើម្បីប្រឈមមុខ និងជំនះលើបញ្ហាប្រឈម។





## ការបញ្ចូលបេតិកភណ្ឌរស់ និងការអភិវឌ្ឍដោយចីរភាពទៅក្នុងមេរៀន

ការសិក្សាអំពីបេតិកភណ្ឌវប្បធម៌អរូបី (ជាប្រធានបទមួយនៅក្នុងមុខវិជ្ជាមួយ ឬច្រើននៅសាលា ឬការសិក្សាដោយផ្ទាល់អំពីបេតិកភណ្ឌរស់) រួមចំណែកដល់ ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD)។ ការសិក្សាអំពីបេតិកភណ្ឌរស់ និងអត្ថន័យនៃការអភិវឌ្ឍដោយចីរភាពគឺជាមធ្យោបាយមួយក្នុងការបញ្ចូលទាំងឫសគល់ និងអនាគតនៃសិស្សរបស់អ្នក។

មានចំណុចចាប់ផ្ដើមជាច្រើន ដែលគ្រូបង្រៀនអាចប្រើបានដើម្បី បញ្ចូលបេតិកភណ្ឌរស់ទៅក្នុងមេរៀន ដើម្បីបង្រៀនអំពីការអភិវឌ្ឍដោយចីរភាព៖

- គ្រូបង្រៀនអាចលើកទឹកចិត្តសិស្សឱ្យពិនិត្យមើលគ្រប់ជ្រុងជ្រោយ លើការប្រតិបត្តិបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងសហគមន៍របស់ខ្លួន។ ធ្វើដូច្នេះនឹងជួយឱ្យសិស្សយល់អំពីវិស័យសង្គម បរិស្ថាន និងសេដ្ឋកិច្ច ក្នុងជីវិតរបស់ពួកគេ និងការជាប់ទាក់ទងគ្នារវាងវិស័យទាំងអស់នេះ។ ការសិក្សាស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយទៅលើបេតិកភណ្ឌវប្បធម៌អរូបី ក៏ជួយអ្នកសិក្សាឱ្យពិនិត្យមើលថាតើរបៀបរបបវប្បធម៌ គុណតម្លៃ និងសកម្មភាពរបស់ពួកគេ ជួយលើកកម្ពស់គុណភាពជីវិតជារួមដែរ ឬយ៉ាងណា ហើយថាតើពួកគេមានទំនួលខុសត្រូវ និងសមធម៌ដែរឬទេ។
- គ្រូបង្រៀនអាចប្រើប្រាស់មូលបទនានា ទាក់ទងនឹងការអភិវឌ្ឍដោយចីរភាព គោលដៅអភិវឌ្ឍន៍ដោយនិរន្តរភាព (SDGs) ទាំង ១៧ ឬគោលដៅនិរន្តរភាពដែលបានកំណត់ក្នុងមូលដ្ឋានជាចំណុចចាប់ផ្ដើម។ ឧទាហរណ៍ សិស្សក្នុងថ្នាក់អាចអានអំពីគោលដៅអភិវឌ្ឍន៍ដោយនិរន្តរភាព (SDGs) ណាមួយ ហើយពិនិត្យមើលថាតើមានបេតិកភណ្ឌរស់ណាមួយ ឬច្រើន ដែលទាក់ទងនឹងគោលដៅនេះដែរ ឬទេ។ បេតិកភណ្ឌរស់មួយ ជារឿយៗ រួមចំណែកដល់ការសម្រេចគោលដៅលើសពីមួយ។
- គ្រូបង្រៀនអាចកំណត់រកអត្ថន័យ និងគុណតម្លៃនៃបេតិកភណ្ឌរស់ណាមួយ ជាមួយសិស្ស និងសមាជិកសហគមន៍។ ឧទាហរណ៍ ធ្វើជាបញ្ជីសម្រាប់ធាតុផ្សំ និងដំណើរការផ្សេងៗដែលពាក់ព័ន្ធអំឡុងពេលប្រតិបត្តិបេតិកភណ្ឌវប្បធម៌អរូបីនោះ។ បន្ទាប់មករួមគ្នាធ្វើការវិភាគថាតើលទ្ធផលរកឃើញនោះ មានទំនាក់ទំនងដូចម្ដេចជាមួយនឹងអត្ថន័យនៃការអភិវឌ្ឍដោយចីរភាពជាទូទៅ ឬជាមួយនឹងគោលដៅណាមួយជាក់លាក់។
- គ្រូបង្រៀនអាចបង្កើតសកម្មភាពស្វែងរកវិធីសាស្ត្រនានាដែលមាននិរន្តរភាពនៅមូលដ្ឋាន និងផ្អែកលើវប្បធម៌ ដែលជួយដោះស្រាយបញ្ហាប្រឈមផ្នែកអភិវឌ្ឍន៍ ដែលសហគមន៍កំពុងប្រឈមមុខបច្ចុប្បន្ន។ ឧទាហរណ៍៖ របៀបគ្រប់គ្រងធនធានធម្មជាតិក្នុងមូលដ្ឋានប្រកបដោយនិរន្តរភាព ទប់ស្កាត់ការហូរច្រោះដី និងគ្រោះមហន្តរាយធម្មជាតិ ការពារជីវចម្រុះក្នុងតំបន់ កសាងភាពធន់ និងលើកកម្ពស់សុខភាព។
- គ្រូបង្រៀនអាចពិភាក្សាជាមួយនឹងសិស្ស និងសហគមន៍អំពីរបៀបដើរតួនាទីនៅក្នុងការគាំទ្រដល់ភាពរស់រាននៃបេតិកភណ្ឌរស់ និងរួមចំណែកដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ដោយនិរន្តរភាព (SDGs)។

### មេរៀនគីមីវិទ្យាដើម្បីលើកកម្ពស់ការយល់ដឹងអំពីការបំពុលទឹក ( ប្រទេសវៀតណាម )

ក្នុងប្រទេសវៀតណាម សហគមន៍ជាច្រើន រាប់បញ្ចូលទាំងសហគមន៍មួង ( Muong ) ផងពឹងផ្អែកលើការដាំដុះដំណាំស្រូវ និងនេសាទ។ អំឡុងពេលបុណ្យចូលឆ្នាំប្រជាជនមួងរៀបចំពិធីបុណ្យផ្សេងៗដើម្បីគោរពបូជាដល់អ្នកតាប្រភពទឹក។

នៅក្នុងថ្នាក់គីមីវិទ្យា សិស្សធ្វើការពិសោធន៍ផ្សេងៗដើម្បីស្វែងយល់ថាតើធម្មជាតិរបស់ទឹកផ្លាស់ប្តូរដែរឬទេ នៅពេលដែលទឹកប៉ះពាល់ជាមួយនឹងភ្នាក់ងារផ្សេងៗដូចជាលោហៈ អុកស៊ីតបាស និងអុកស៊ីតអាស៊ីដ។ សកម្មភាពនេះបាននាំទៅរកកិច្ចពិភាក្សាមួយស្តីពីបុព្វហេតុ និងផលប៉ះពាល់នៃការបំពុលទឹក ដែលមានទំនាក់ទំនងនឹងគោលដៅអភិវឌ្ឍន៍ដោយនិរន្តរភាព ( SDG ) ទី ៦ ( ទឹកស្អាត និងអនាម័យ )។ បន្ទាប់មកសិស្សបានសិក្សាថាតើប្រជាជនមួង ធ្វើដូចម្តេចក្នុងកិច្ចការពារប្រភពទឹករបស់ខ្លួនមិនឱ្យមានជាតិពុល ឧទាហរណ៍ តាមរយៈការហាមឃាត់ ការពិឃាតសត្វ និងការបោះចោលសត្វស្លាប់ទៅក្នុងប្រភពទឹកជាដើម។

## ៣.៣ ការបង្រៀន និងការរៀនជាមួយបេតិកភណ្ឌរស់ និងការសិក្សាអារម្មណ៍សង្គម ( SEL )

### ការសិក្សាសង្គម និងអារម្មណ៍

អង្គការ កិច្ចសហការសម្រាប់ការសិក្សាសង្គម និងអារម្មណ៍ ( CASEL ) បានកំណត់និយមន័យនៃការសិក្សាអារម្មណ៍សង្គម ( SEL ) ថាជាដំណើរការមួយ ដែលមនុស្សទទួលបាន និងអនុវត្តចំណេះដឹង ជំនាញ និងអាកប្បកិរិយាដែលចាំបាច់សម្រាប់អភិវឌ្ឍន៍អត្តសញ្ញាណល្អ គ្រប់គ្រងអារម្មណ៍ មានអារម្មណ៍ និងបង្ហាញពីការយល់ចិត្តចំពោះអ្នកដទៃ កសាង និងថែទាំទំនាក់ទំនងដែលចេះជួយគ្នា ហើយធ្វើការសម្រេចចិត្តប្រកបដោយការទទួលខុសត្រូវ និងយកចិត្តទុកដាក់ និងសម្រេចបាននូវគោលដៅផ្ទាល់ខ្លួន និងគោលដៅសមូហភាព។ ដូច្នេះ ការសិក្សាអារម្មណ៍



សង្គម (SEL) គឺមានសារៈសំខាន់សម្រាប់លើកកម្ពស់សុខុមាលភាព ដែលជាផ្នែកមួយដ៏សំខាន់នៃការទទួលបានជីវិតរស់នៅប្រកបដោយគុណភាពល្អ។

សិស្សដែលចូលរួមនៅក្នុងការសិក្សាអារម្មណ៍សង្គម (SEL) ក៏មានមិត្តភក្តិច្រើន ហើយដូច្នេះ ពួកគេមានអន្តរកម្មប្រកបដោយវិជ្ជមាននៅក្នុងសាលា។

វិទ្យាស្ថានអប់រំដើម្បីសន្តិភាព និងការអភិវឌ្ឍដោយចីរភាព មហាត្មៈ គន្ធី (MGIEP) ដែលជាវិទ្យាស្ថានស្រាវជ្រាវយូណេស្កូប្រភេទ ១ កំណត់និយមន័យនៃការសិក្សាអារម្មណ៍សង្គម (SEL) ស្រដៀងគ្នានឹងអង្គការកិច្ចសហការសម្រាប់ការសិក្សាសង្គម និងអារម្មណ៍ (CASEL) ដែរ ដោយបានកំណត់ថា៖ ការសិក្សាណាដែលជួយអ្នកសិក្សាឱ្យមានសមត្ថភាពកំណត់ និងគ្រប់គ្រងអារម្មណ៍របស់ខ្លួន អនុវត្តការប្រុងប្រយ័ត្ន និងស្តែងចេញនូវឥរិយាបថគាំទ្រសង្គម ដើម្បី ឱ្យមនុស្សរលូតលាស់ ឆ្ពោះទៅរកភពផែនដីមួយដែលមានសន្តិភាព និងនិរន្តរភាព។

អត្ថប្រយោជន៍នៃការសិក្សាអារម្មណ៍សង្គម (SEL) រួមមានដូចខាងក្រោម៖

- សិស្សរៀនសម្គាល់ពីអ្វីដែលកំពុងកើតឡើងនៅក្នុងខ្លួនរបស់ពួកគេ។ ធ្វើដូច្នេះ ជួយឱ្យពួកគេទប់អារម្មណ៍ដែលឡើងខ្លាំង ដើម្បីឱ្យពួកគេអាចគិតមុនពេលប្រព្រឹត្តទង្វើតាមសន្ទុះផ្លូវចិត្ត។
- សិស្សរៀនកំណត់ពីអារម្មណ៍ និងទស្សនៈរបស់អ្នកដទៃ។ ការធ្វើដូច្នេះ ជួយឱ្យពួកគេបង្ហាញនូវក្តីមេត្តា ចេះប្រាស្រ័យទាក់ទងកាន់តែល្អប្រសើរ ហើយដោះស្រាយបញ្ហាតាមសន្តិវិធី។
- សិស្សដែលចូលរួមនៅក្នុងការសិក្សាអារម្មណ៍សង្គម (SEL) ទទួលបានលទ្ធផលសិក្សា និងឥរិយាបថល្អប្រសើរជាងគេ។
- សិស្សដែលចូលរួមនៅក្នុងការសិក្សាអារម្មណ៍សង្គម (SEL) ក៏មានមិត្តភក្តិច្រើន ហើយដូច្នេះ ពួកគេមានអន្តរកម្មប្រកបដោយវិជ្ជមាននៅក្នុងសាលា។

ការបង្រៀនជាមួយបេតិកភណ្ឌរស់ និងការសិក្សាអារម្មណ៍សង្គម (SEL) ជាការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ហើយមានអត្ថប្រយោជន៍ទៅវិញទៅមក។ នេះក៏ព្រោះតែ៖

- ការប្រើប្រាស់បេតិកភណ្ឌរស់ក្នុងថ្នាក់រៀន អាចជួយយើងលើកកម្ពស់សុខុមាលភាពបាន ពីព្រោះបេតិកភណ្ឌរស់ជួយឱ្យយើងស្គាល់ពីអត្តសញ្ញាណ ចីរភាព និងភាពជាម្ចាស់ និងផ្តល់អត្ថន័យក្នុងជីវិតរស់នៅរបស់យើង។
- ការអប់រំពីបេតិកភណ្ឌរស់ គឺចាំបាច់សម្រាប់ទទួលបាននូវការឱ្យតម្លៃ ចំពោះប្រវត្តិសាស្ត្រ និងវប្បធម៌របស់យើងផ្ទាល់ ក៏ដូចជារបស់អ្នកជិតខាងរបស់យើង។ ការអប់រំនេះជួយយើងក្នុងការជំរុញឱ្យមានការចេះយល់ចិត្ត និងការយល់ដឹងកាន់តែប្រសើរឡើងអំពីមនុស្សជាតិ គុណតម្លៃ និងជំនឿរបស់យើង ដែលជាជំនាញសំខាន់របស់ការសិក្សាអារម្មណ៍សង្គម (SEL)។
- នៅពេលដែលសិស្សប្រៀបធៀបការអនុវត្តន៍ប្រតិបត្តិរបស់ពួកគេ និងចូលរួមក្នុងព្រឹត្តិការណ៍វប្បធម៌ផ្សេងៗ ពួកគេកាន់តែយល់ដឹងអំពីជំនឿរបស់ពួកគេ និងរៀនបង្ហាញដោយខ្លួនឯង អំពីវប្បធម៌របស់ពួកគេ។ ពួកគេក៏ប្រាស្រ័យទាក់ទងកាន់តែច្រើនជាមួយមិត្តរួមសាលារបស់ពួកគេផងដែរ ដែលជួយពួកគេបង្កើតទំនាក់ទំនងកាន់តែរឹងមាំ។
- បរិបទគ្រួសារ និងសហគមន៍ដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់និយាមឥរិយាបថនិងការប្រាស្រ័យទាក់ទងរបស់យើង និងរបៀបរបបដែលយើងបង្ហាញពីអារម្មណ៍របស់យើង។ កិច្ចសហការរវាងគ្រូ និងគ្រួសារតាមរយៈការអប់រំបេតិកភណ្ឌអាចអនុញ្ញាតឱ្យពួកគេយល់កាន់តែច្បាស់ពីគ្នាទៅវិញទៅមក និងផ្តល់សារដែលកាន់តែស៊ីសង្វាក់គ្នាជាងមុន ដើម្បីជួយយុវជនអភិវឌ្ឍជំនាញអារម្មណ៍-សង្គមរឹងមាំ។

នៅពេលបង្រៀនជាមួយបេតិកភណ្ឌរស់ ដំបូងឡើយគ្រូបង្រៀនខ្លួនឯងគួរដឹងជាមុនអំពីការអនុវត្តប្រតិបត្តិបេតិកភណ្ឌរស់នៅក្នុងមូលដ្ឋានរបស់សិស្សខ្លួន ដូចជាសិល្បៈក្នុងស្រុក ពិធីបុណ្យចំណេះដឹង និងការអនុវត្តប្រតិបត្តិទាក់ទងនឹងធម្មជាតិ និងសកលលោក និងនិយាមវប្បធម៌។ និយាម វប្បធម៌មានឥទ្ធិពលលើរបៀបរបបដែលសិស្សបង្ហាញអារម្មណ៍ខ្លួនឯង និងរបៀបរបបនៃការគ្រប់គ្រងអារម្មណ៍របស់ពួកគេ។ នៅពេលដែលអ្នកអប់រំយល់អំពីបរិបទវប្បធម៌ ពួកគេអាចចូលរួមក្នុងការពិភាក្សាអំពីអារម្មណ៍ជាមួយសិស្សប្រកបដោយប្រសិទ្ធភាព។ ពួកគេក៏អាចប្រើបេតិកភណ្ឌវប្បធម៌អរូបី ដើម្បីជួយសិស្សរៀនជំនាញ សិក្សាអារម្មណ៍សង្គម (SEL) ផងដែរ។

## ៣.៤ ការបង្រៀន និងការរៀនជាមួយបេតិកភណ្ឌរស់ និងការអប់រំតាមភាសាកំណើត

កុមាររៀនភាសាមួយ ឬច្រើននៅក្នុងផ្ទះរបស់ពួកគេ នៅពេលពួកគេប្រាស្រ័យទាក់ទងជាមួយគ្រួសាររបស់ខ្លួន។ ភាសាដែលកុមាររៀននៅផ្ទះគឺ ‵ភាសាកំណើត′ (ឬហៅផងដែរថា ‵ភាសាផ្ទះ′)។ ក្រៅពីរៀនភាសា កុមារក៏រៀនអំពីវប្បធម៌ និងបេតិកភណ្ឌរបស់ខ្លួននៅតាមផ្ទះផងដែរ គឺជាការរៀនក្រៅផ្លូវការ ហើយភាគច្រើនតាមរយៈការសង្កេត និងការចូលរួម។ នៅពេលការអប់រំបែបនេះកើតឡើង កុមារចាប់ផ្តើមអភិវឌ្ឍការគិត និងពិចារណាលើដំណើរការទាក់ទងនឹងពិភពលោកទៅតាមភាសាកំណើតរបស់ពួកគេ និងវប្បធម៌ដែលពាក់ព័ន្ធរបស់គេ។

### ការអប់រំតាមភាសាកំណើត

គោលដៅនៃការអប់រំតាមភាសាកំណើត (MTBE) គឺដើម្បីប្រើភាសាតាមផ្ទះរបស់សិស្សសម្រាប់ការណែនាំក្នុងការបង្រៀន ការរៀន និងអក្ខរភាព ដើម្បីកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការសិក្សាទៅថ្ងៃអនាគត។

> គោលដៅនៃការអប់រំតាមភាសាកំណើត (MTBE) គឺដើម្បីប្រើភាសាតាមផ្ទះរបស់សិស្សសម្រាប់ការណែនាំក្នុងការបង្រៀន ការរៀន និងអក្ខរភាព ដើម្បីកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការសិក្សាទៅថ្ងៃអនាគត។

### អត្ថប្រយោជន៍នៃការអប់រំតាមភាសាកំណើត

- ការប្រើប្រាស់ភាសាផ្ទះធានាបាននូវអន្តរកាលយ៉ាងរលូនរវាងផ្ទះ និងសាលា។ សិស្សចេះវាក្យសព្ទដែលត្រូវការដើម្បីចូលរៀនក្នុងសាលា ហើយអាចប្រើប្រាស់ចំណេះដឹង និងជំនាញដែលពួកគេបានរៀននៅផ្ទះ។
- ការបង្រៀន និងការរៀននៅសាលា ទៅតាមភាសាកំណើតរបស់សិស្សជួយបង្កើតជំនាញចងចាំ និងយល់ដឹង ដែលកុមារបានចាប់ផ្តើមអភិវឌ្ឍនៅក្នុងផ្ទះរបស់ខ្លួន។ បន្ទាប់មក ជំនាញមូលដ្ឋានគ្រឹះទាំងនេះអាចផ្ទេរទៅភាសាថ្មី ដូចជាភាសាជាតិ ខណៈពេលដែលនៅតែប្រើភាសាកំណើតរបស់ខ្លួនដដែល។
- ការអប់រំតាមភាសាកំណើត (MTBE) លើកទឹកចិត្តសិស្សឱ្យចូលរួមកាន់តែច្រើននៅក្នុងថ្នាក់ ឆ្លើយតបទៅនឹងសំណួររបស់គ្រូ និងចូលរួមដោយស្មើភាពគ្នា។ ទាំងអស់នេះនាំឱ្យការសិក្សាជារួមទទួលបានលទ្ធផលកាន់តែប្រសើរឡើង អត្រាបោះបង់ចោលការសិក្សាមានកម្រិតទាប និងកម្រិតស្ទាត់ជំនាញកាន់តែខ្ពស់សម្រាប់គ្រប់ភាសានៅក្នុងសាលា។
- នៅពេលដែលភាសាផ្ទះ និងភាសាសាលាគឺដូចគ្នា ឪពុកម្តាយអាចចូលរួមក្នុងការសិក្សារបស់កូនៗ និងចូលរួមក្នុងសកម្មភាពសាលាបាន។



- តាមរយៈការបន្តប្រើប្រាស់ភាសាកំណើត សមាជិកនៃសហគមន៍វប្បធម៌ដូចគ្នាអាចរក្សាបាននូវអត្តសញ្ញាណភាសា និងវប្បធម៌ផ្ទាល់ខ្លួនរបស់ពួកគេ ហើយចូលរួមយ៉ាងបុរេសកម្មក្នុងវប្បធម៌ក្នុងតំបន់ និងវប្បធម៌ជាតិកាន់តែទូលំទូលាយ។

## តើការសិក្សាជាមួយបេតិកភណ្ឌរស់ និងការអប់រំដោយប្រើភាសាកំណើត (MTBE) ជួយបំពេញបន្ថែមឱ្យគ្នាដូចម្តេចខ្លះ?

ភាសាកំណើត (ភាសាតាមផ្ទះ) គឺជាផ្នែកមួយយ៉ាងជិតស្និទ្ធនៃបេតិកភណ្ឌរស់។ ភាសាគឺជាផ្នែកមួយនៃវប្បធម៌ដែលបង្កើតជាបេតិកភណ្ឌរបស់យើង។ ដូចគ្នានឹងការប្រតិបត្តិវប្បធម៌ ជំនាញ និងចំណេះដឹងដូច្នោះដែរ គឺថាភាសាត្រូវបានរៀនសូត្រ បញ្ជូនបន្ត និងវិវត្តទៅគ្រប់ជំនាន់។ ទន្ទឹមនឹងនេះ ភាសាគឺជាមធ្យោបាយនៃការសិក្សាអំពីវប្បធម៌ផ្ទាល់ខ្លួន និងជាវិធីសម្រាប់គិត និងដឹង។

ដើម្បីសម្របសម្រួលដល់ការសិក្សាបេតិកភណ្ឌរស់ និងការអប់រំតាមភាសាកំណើត (MTBE) វាជារឿងសំខាន់ក្នុងការចាត់តាំងគ្រូបង្រៀនដែលមកពីសហគមន៍មូលដ្ឋាន ពីព្រោះគ្រូបង្រៀនទាំងអស់នេះ និយាយភាសាក្នុងស្រុក ហើយក៏យល់ដឹងយ៉ាងជិតស្និទ្ធអំពីវប្បធម៌មូលដ្ឋានផងដែរ។

គ្រូបង្រៀនទាំងនេះ នឹងអាចប្រើប្រាស់បេតិកភណ្ឌរបស់សិស្សដើម្បីបង្រៀនប្រធានបទមេរៀននៅក្នុងថ្នាក់។ ឧទាហរណ៍ ការប្រើប្រាស់បច្ចេកទេសដាំដុះ ដែលមានស្រាប់នៅក្នុងសហគមន៍ មូលដ្ឋានដើម្បីយកមកបង្រៀនមេរៀនអំពីបញ្ហាបរិស្ថាន ឬការអភិវឌ្ឍវាក្យសព្ទអំពីការអនុវត្តប្រតិបត្តិផ្នែកវប្បធម៌ នៅក្នុងថ្នាក់រៀនភាសា។

ការប្រើប្រាស់ភាសាកំណើតជាភាសាក្នុងការបង្រៀន និងការប្រើប្រាស់ជាតុវប្បធម៌ក្នុងស្រុកធ្វើជាផ្នែកណាមួយនៃសម្ភារៈឧបទេស ផែនការមេរៀន និងកម្មវិធីសិក្សា ក៏អាចជាការជំរុញឱ្យឈានដល់វត្ថុបំណងនៃការសិក្សាផង

ដែរ។ បន្ថែមលើនេះ មាតិកាក្នុងស្រុកផ្តល់ជាគ្រឹះដ៏មានជីជាតិសម្រាប់ការលើកកម្ពស់ភាសាក្នុងស្រុកផង និងវប្បធម៌ក្នុងស្រុកផង។

ជារឿយៗ ដោយសារតែការរៀនភាសាថ្មី មានន័យថា នឹងត្រូវជួបនឹងវប្បធម៌ផ្សេងទៀត ដូច្នេះ តាមរយៈការរៀនភាសាថ្មី សិស្សអាចស្វែងយល់អំពីការគិត និងការរស់នៅខុសៗគ្នា ដូចជា ភាពខុសគ្នាដែលទាក់ទងនឹងភាសាជាតិរបស់ប្រទេសណាមួយជាដើម។ ក្នុងលក្ខណៈនេះ ការចាប់ផ្តើមដោយប្រើភាសាផ្ទះរបស់សិស្ស ហើយបន្ទាប់មកសិក្សាពីមាតិកាផ្សេងទៀត ដូចជាភាសាបន្ថែមជាដើម សម្រួលឱ្យមានការយល់ដឹងកាន់តែច្រើនជាងមុន ក៏ដូចជាមានការគោរពខ្លាំងជាងមុនចំពោះភាពចម្រុះផ្នែកវប្បធម៌ ប្រៀបបាននឹងជួយលើកកម្ពស់ភាពស្អិតរមួតក្នុងសង្គម និងកសាងសង្គមដែលមានបរិយាបន្ន។

នៅពេលណាដែលអាចធ្វើទៅបាន គ្រូបង្រៀនគួរតែសហការជាមួយសមាជិកសហគមន៍ ជាពិសេសអ្នកដែលនិយាយភាសាកំណើតរបស់សិស្ស។ អ្នកដែលមានចំណេះដឹងទាំងនេះ អាចចែករំលែកឱ្យដឹងអំពីការប្រតិបត្តិបេតិកភណ្ឌរស់របស់ខ្លួន និងចំណេះដឹងដោយផ្ទាល់ទៅតាមភាសារបស់គេ។ ទន្ទឹមនឹងនេះ ការអប់រំតាមភាសាកំណើត (MTBE) ផ្តល់លទ្ធភាពឱ្យសហគមន៍ កាន់តែដឹងថាភាសា និងការអនុវត្តរបស់ពួកគេ គឺពាក់ព័ន្ធនឹងមនុស្សជំនាន់ថ្មី ហើយពួកគេនឹងរឹតតែឱ្យតម្លៃថែមទៀត។

**គន្លឹះ** សំខាន់ៗ

ការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងសកម្មភាពគរុកោសល្យ អាចជួយបំពេញបន្ថែម និងពង្រឹងដល់វិធីសាស្ត្រអប់រំផ្សេងទៀត ដែលប្រើប្រាស់នៅតាមសាលា រាប់បញ្ចូលទាំង GCED, ESD, SEL និង MTBE។





## ការបញ្ចូលបេតិកភណ្ឌរស់
## ទៅក្នុងការសិក្សានៅអាស៊ីប៉ាស៊ីហ្វិក
### សៀវភៅណែនាំ

កូនសៀវភៅ

4

# វិធីសាស្ត្រប្រាំមួយជំហាន សម្រាប់ជាមគ្គុទេសក៍ ដល់គ្រូបង្រៀន

**សៀវភៅនេះ** មានបំណងជួយគាំទ្រគ្រូបង្រៀន អ្នកគ្រប់គ្រងក្នុងវិស័យអប់រំ និងសហគមន៍ ក្នុងការដាក់បញ្ចូលបេតិកភណ្ឌក្នុងស្រុក ទៅក្នុងសកម្មភាពសិក្សា ឲ្យកាន់តែមានភាពប្រទាក់ក្រឡាគ្នា និងមានការចូលរួមកាន់តែច្រើនពីសំណាក់សិស្សានុសិស្ស និងការពារបេតិកភណ្ឌវប្បធម៌។

សៀវភៅនេះ មានកូនសៀវភៅចំនួនប្រាំបួន៖

- កូនសៀវភៅ 1 តើបេតិកភណ្ឌរស់ជាអ្វី ?
- កូនសៀវភៅ 2 ហេតុអ្វីត្រូវបង្រៀនជាមួយបេតិកភណ្ឌរស់ ?
- កូនសៀវភៅ 3 ការរៀបចំឱ្យត្រូវគ្នាជាមួយអាទិភាពអប់រំ
- ▶ កូនសៀវភៅ 4 **វិធីសាស្ត្រប្រាំមួយជំហានសម្រាប់ជាមគ្គុទេសក៍ដល់គ្រូបង្រៀន**
- កូនសៀវភៅ 5 តួនាទីរបស់ឪពុកម្ដាយ អាណាព្យាបាល និងសមាជិកសហគមន៍
- កូនសៀវភៅ 6 តួនាទីរបស់ថ្នាក់គ្រប់គ្រងសាលា
- កូនសៀវភៅ 7 តួនាទីរបស់អ្នករៀបចំគោលនយោបាយ
- កូនសៀវភៅ 8 ឯកសារ និងធនធាន
- កូនសៀវភៅ 9 សាច់រឿងរបស់គ្រូបង្រៀន

កូនសៀវភៅ

4

# វិធីសាស្ត្រ ៦ ជំហានសម្រាប់ជាមគ្គុទេសក៍ដល់គ្រូបង្រៀន

កូនសៀវភៅនេះ លើកឡើងពីជំហានជាក់ស្តែងចំនួនប្រាំមួយ ដែលគ្រូបង្រៀនអាចអនុវត្តតាមដើម្បីបង្រៀនមរតករស់នៅក្នុងថ្នាក់រៀនរបស់ពួកគាត់ ដោយចាប់ផ្តើមជាមួយនឹងការស្វែងរកគំនិត បន្ទាប់មក ឈានទៅរកការធ្វើផែនការមេរៀន ការបង្រៀន និងបន្ទាប់មក ការវាយតម្លៃលើលទ្ធផល។

ជំហានទាំងប្រាំមួយដែលមានបង្ហាញនៅក្នុងវគ្គនេះ ស្នើឱ្យមានដំណើរវិវត្តន៍ ដើម្បីនាំផ្លូវអ្នកឱ្យស្គាល់ពីដំណើរការនេះ។ ជំហានទាំងនេះត្រូវបានយកមកសាកល្បងនៅក្នុងគម្រោងសាកល្បងមួយចំនួន ហើយកែសម្រួលដើម្បីបំពេញតាមតម្រូវការរបស់គ្រូបង្រៀនឱ្យបានសមស្របបំផុត។

ដូចគ្នានឹងវិធីសាស្ត្របង្រៀនភាគច្រើនដែរ មិនមានវិធីសាស្ត្រណាមួយដែលត្រូវគ្រប់រឿងទាំងអស់នោះទេ នៅក្នុងការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីក្នុងសាលារបស់អ្នក។ អ្នកអាចជួយកែសម្រួលដំណើរការ និងលំដាប់លំដោយ ដើម្បីឆ្លើយតបទៅនឹងបរិបទ និងតម្រូវការរបស់អ្នកផ្ទាល់ ហើយដើម្បីអាចបម្រើដល់សិស្សរបស់អ្នក និងបំពេញតាមវត្ថុបំណងមេរៀនរបស់អ្នក។

មានវិធីជាច្រើនដែលអាចធ្វើបាន នៅក្នុងការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងបរិបទអប់រំតាមសាលា។ អ្នកអាចធ្វើដោយខ្លួនឯង ឬធ្វើរួមគ្នាជាមួយនឹងគ្រូបង្រៀនផ្សេងទៀត នៅក្នុងថ្នាក់រៀន ឬធ្វើជាសកម្មភាពក្រៅកម្មវិធីសិក្សា ហើយធ្វើជាមេរៀនតែមួយ ឬមេរៀនជាភាគក៏បាន។ សូមមើលគំរូវិភាគបរិបទនៅក្នុងកូនសៀវភៅទី ៨៖ ឯកសារ និងធនធាន ដើម្បីជួយណែនាំអ្នកឱ្យស្គាល់ពីដំណើរការនេះ។

អ្នកក៏អាចចូលមើលវគ្គ ***សិក្សាតាមអនឡាញ*** CLICK ខ្លួនឯង "ការបញ្ចូលបេតិកភណ្ឌរស់ក្នុងថ្នាក់រៀននៅអាស៊ីប៉ាស៊ីហ្វិក" ដើម្បីស្វែងយល់ពីជំហាន និងធ្វើផែនការមេរៀនដោយខ្លួនឯង។

"យើងរស់នៅលើភពផែនដីដ៏ស្រស់ស្អាត ដែលមានប្រពៃណី និងទំនៀមទម្លាប់ចម្រុះ។ យើងមានភារកិច្ចនៅក្នុងកិច្ចការពារ លើកកម្ពស់ និងផ្សព្វផ្សាយទៅឱ្យមនុស្សជំនាន់ក្រោយ។ បេតិកភណ្ឌជារឿងល្អបំផុតដែលយើងមាន។"

*– Elmira Sarkulova គ្រូបង្រៀន គៀជីស្ថាន*






- កំណត់រកបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងមជ្ឈដ្ឋាន
- ប្រភេទសកម្មភាព
- ដៃគូ (នៅសាលា សហគមន៍ និងផ្សេងពីនេះ)
- រៀបកាលវិភាគមេរៀន/សកម្មភាពមានបេតិកភណ្ឌវប្បធម៌អរូបី

- បេតិកភណ្ឌវប្បធម៌អរូបី ឬ មុខវិជ្ជាសាលាធ្វើជាចំណុចចាប់ផ្ដើម
- ចំណាប់អារម្មណ៍របស់សិស្ស
- ប្រមើលមើលធនធាន និងការរឹតត្បិត

- ព័ត៌មានចាំបាច់
- វិធីសាស្ត្រប្រមូល៖ សម្ភាសន៍ ការស្រាវជ្រាវឯកសារ
- ចុះទស្សនកិច្ច

- គោលដៅ និងវត្ថុបំណងមេរៀន
- ភាពលេចធ្លោរបស់បេតិកភណ្ឌវប្បធម៌អរូបីក្នុងមេរៀន/សកម្មភាព
- វិធីសាស្ត្រនៃការបង្រៀន/ការរៀន...
- សម្ភារៈគរុកោសល្យ ឆ្លុះបញ្ចាំងពីបេតិកភណ្ឌវប្បធម៌អរូបី
- ការបង្រៀន និងការលើកទឹកចិត្តឱ្យមានការគោរពចំពោះសមភាពយេនឌ័រ ភាពចម្រុះ និងការអត់ឱន

- នៅសាលារៀន
- តាមបណ្ដាញ
- តាមអនឡាញ
- ការចែករំលែកបទពិសោធន៍

- លទ្ធផលសិក្សារបស់សិស្ស
- ត្រិះរិះលើដំណើរការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបី

## ៤.១ ជំហានទី ១ - យល់ពីបរិបទរបស់អ្នក

ជំហានទីមួយនេះ ដើរតួនាទីជាដំណាក់កាលរៀបចំ ដើម្បីឆ្លើយតបទៅនឹងសំណួរដូចខាងក្រោម៖

- តើបេតិកភណ្ឌរស់ក្នុងស្រុកណាខ្លះដែលអ្នកអាចបញ្ចូលទៅក្នុងមេរៀនរបស់អ្នកបាន?
- តើសកម្មភាពប្រភេទណាខ្លះ ដែលអ្នកអាចរៀបចំឡើងនៅក្នុងសាលារបស់អ្នកដោយប្រើប្រាស់បេតិកភណ្ឌរស់?
- តើអ្នកអាចសុំព័ត៌មាន ឬជំនួយពីអ្នកណាខ្លះ?
- តើអ្នកអាចរៀបចំកាលវិភាគមេរៀនដែលប្រើបេតិកភណ្ឌរស់តាមរបៀបណា និងពេលណា?

### តើបេតិកភណ្ឌរស់អ្វីខ្លះដែលមានវត្តមានក្នុងតំបន់របស់អ្នក?

- សង្កេតមើលបរិបទមូលដ្ឋាន ជជែកជាមួយសិស្ស ឬគ្រូផ្សេងទៀត ហើយសំឡឹងរកមើលបេតិកភណ្ឌវប្បធម៌អរូបីដោយផ្ទាល់ ទាក់ទងនឹងជីវិតរស់នៅរបស់សិស្ស និងមានការប្រតិបត្តិយ៉ាងទូលំទូលាយនៅក្នុងសហគមន៍មូលដ្ឋាន នៅក្នុងតំបន់របស់សាលា ដូចជាពិធីបុណ្យក្នុងស្រុក ការអបអរសាទរឆ្នាំថ្មី របាំកីឡាបែបប្រពៃណី ឧបករណ៍តន្ត្រីក្នុងស្រុក សិប្បកម្ម។ល។ សិស្ស និងក្រុមគ្រួសាររបស់គេ  នឹងបានស្គាល់ច្បាស់រួចទៅហើយអំពីការប្រតិបត្តិទាំងអស់នេះ ហើយនឹងអាចផ្តល់នូវមតិយោបល់ខ្លះៗ។ អ្នកប្រតិបត្តិនៅមូលដ្ឋាន និងសមាជិកសហគមន៍ សមាគមវប្បធម៌ បុគ្គលិកជំនាញដែលធ្វើការក្នុងវិស័យវប្បធម៌ (ដូចជាមជ្ឈមណ្ឌលវប្បធម៌ បណ្ណាល័យ សារមន្ទីរ។ល។) ក៏ជាប្រភពដ៏ល្អឥតខ្ចោះសម្រាប់ព័ត៌មានផងដែរ។ ត្រង់នេះអាចនឹងមានការពាក់ព័ន្ធយ៉ាងពិសេសនៅក្នុងថ្នាក់ ដែលមានសិស្សដែលមានសាវតារវប្បធម៌ចម្រុះ ពីព្រោះវានឹងផ្តល់ឱកាសឱ្យសិស្សបានចែករំលែក និងសិក្សាអំពីបេតិកភណ្ឌរស់របស់ខ្លួនទៅវិញទៅមក។

#### ការកំណត់ផែនទីរុក្ខជាតិឱសថសម្រាប់ថ្នាក់ភូមិវិទ្យា (ប្រទេសគៀជីស្ថាន)

នៅក្នុងលំហាត់សម្រាប់សិស្សម្នាក់ៗនៅក្នុងថ្នាក់ភូមិវិទ្យា សិស្សម្នាក់បានជ្រើសរើសយកប្រធានបទមួយទាក់ទងនឹងការកំណត់ផែនទីរុក្ខជាតិឱសថ។ ម្តាយរបស់សិស្សនោះ ធ្វើការនៅក្នុងបណ្ឌិតសភាវិទ្យាសាស្ត្រ ហើយសិក្សាអំពីឱសថបុរាណ។ សិស្សនោះជួយម្តាយរបស់នាង និងយាយក្នុងការប្រមូលរុក្ខជាតិឱសថ។ សម្រាប់លំហាត់របស់នាង សិស្សនោះធ្វើការព្យាបាលដោយរុក្ខជាតិឱសថ ជាមួយនឹងក្រុមគ្រួសារ ហើយរៀបចំសាប៊ូដុះខ្លួនធ្វើនៅផ្ទះ។





- កំណត់រកបេតិកភណ្ឌវប្បធម៌អរូបី ដែលទាក់ទងនឹងជីវិតរបស់អ្នក ឬជីវិតសហការីរបស់អ្នក។ ដំបូងឡើយ អ្នកអាចចែករំលែកបទពិសោធន៍ជាក់ស្តែង និងព័ត៌មាននានា ហើយពន្យល់ដោយផ្ទាល់ថាតើហេតុអ្វីទើបការប្រតិបត្តិនេះមានសារៈសំខាន់សម្រាប់រូបអ្នក។



### ការសិក្សាអំពីការទុកដាក់ទឹកបែបបុរាណ (ប្រទេសនេប៉ាល់)

គ្រូបង្រៀនម្នាក់មកពីប្រទេសនេប៉ាល់ បានកត់សម្គាល់ឃើញក្រឡទឹកបុរាណនៅក្នុងតំបន់របស់គាត់ ហើយក៏កើតជាគំនិតមួយ ក្នុងការធ្វើមេរៀនស្តីពីក្រឡដាក់ទឹកបែបបុរាណ សម្រាប់មុខវិជ្ជារបស់គាត់ស្តីពី "មុខរបរ អាជីវកម្ម និងការអប់រំបច្ចេកវិទ្យា"។ គ្រូបង្រៀននោះ បានប្រើប្រាស់ចំណេះដឹងផ្ទាល់ខ្លួន ដើម្បីរៀបចំមាតិកាមេរៀន។ សិស្សបានត្រិះរិះលើអត្ថប្រយោជន៍ប្រៀបធៀបរវាងវិធីសាស្ត្របែបបុរាណ និងសម័យ ក្នុងការរក្សាទុកទឹក ហើយបង្កើតកូនក្រឡដោយខ្លួនឯងធ្វើពីដីឥដ្ឋ។

- ស្វែងរកបេតិកភណ្ឌវប្បធម៌អរូបី ដែលបានចងក្រងជាឯកសារ នៅក្នុងបញ្ជីសារពើភ័ណ្ឌក្នុងស្រុក ឬថ្នាក់ជាតិ និងនៅលើបញ្ជីរបស់អង្គការយូណេស្កូ។



### ប្រើប្រាស់បេតិកភណ្ឌដែលបានចុះក្នុងបញ្ជីអនុសញ្ញាឆ្នាំ២០០៣ (សាធារណរដ្ឋកូរ៉េ)

សាលានានានៅក្នុងប្រទេសកូរ៉េបានបង្កើតមេរៀនពី Yeondeunghoe (ពិធីបុណ្យភ្លើងគោម) *kimjang* (ការផលិត និងចែករំលែកគីមឈី) និង Namsadang Nori (សិល្បៈទស្សនីយភាពប្រជាប្រិយពហុវិស័យ)។ ប្រធានបទទាំងបីនេះ សុទ្ធតែត្រូវបានបញ្ចូលទៅក្នុងបញ្ជីរបស់អនុសញ្ញាឆ្នាំ ២០០៣ នៃបេតិកភណ្ឌវប្បធម៌អរូបីរបស់មនុស្សជាតិ ហើយសុទ្ធតែត្រូវបានចងក្រងជាឯកសារយ៉ាងល្អ។ ដូច្នេះហើយ វាមានភាពងាយស្រួលសម្រាប់គ្រូបង្រៀន ក្នុងការស្វែងរកព័ត៌មានអំពីប្រធានបទទាំងនេះ ដើម្បីជួយដល់ការរៀបចំ និងបង្រៀនមេរៀនរបស់ខ្លួន។

បេតិកភណ្ឌរូបី ដូចជាទីកន្លែង ឬប្រាសាទ ដែលមានសារៈសំខាន់ផ្នែកសំខាន់ ឬផ្នែកប្រវត្តិសាស្ត្រ គឺជាបេតិកភណ្ឌដែលអាចមើលឃើញ ហើយងាយស្រួលក្នុងការកំណត់រកនៅក្នុងតំបន់។ បេតិកភណ្ឌអរូបីជាច្រើនមានទំនាក់ទំនងផ្សារភ្ជាប់នឹងបេតិកភណ្ឌរូបី។ ឧទាហរណ៍ ការអនុវត្តប្រតិបត្តិក្នុងសង្គមជាច្រើនប្រព្រឹត្តទៅនៅទីកន្លែងមួយ ហើយទីកន្លែងនោះមានន័យ ឬសិល្បៈដែលពាក់ព័ន្ធ (ឧទាហរណ៍ ការប្រារព្ធពិធីក្នុងទីតាំងសាសនា ជាធម្មតា មានតន្ត្រី និងការច្រៀង) ឬចំណេះដឹង និងជំនាញជាប្រពៃណី ត្រូវបានប្រើប្រាស់ដើម្បីបង្កើតទីតាំងបេតិកភណ្ឌនោះ (ឧទាហរណ៍ ប្រាសាទ) ឬដើម្បីធ្វើវត្ថុទាំងអស់នោះ (សិប្បកម្ម)។ ក្នុងករណីបែបនេះ បេតិកភណ្ឌរូបី អាចជាចំណុចចាប់ផ្ដើមសម្រាប់ការពិភាក្សា និងសិក្សាបាន។

ពិចារណាលើការបញ្ចូលសិស្សរបស់អ្នកក្នុងដំណើរការនៃការកំណត់រកបេតិកភណ្ឌរស់នៅក្នុងមូលដ្ឋាន សម្រាប់ធ្វើជាសកម្មភាពនៅក្នុងសាលា។ អ្នកអាចរិះគិតជាមួយនឹងសិស្សានុសិស្សទាំងនោះ ដើម្បីរកមើលថាតើគេស្គាល់បេតិកភណ្ឌវប្បធម៌អរូបីអ្វីខ្លះ តាមរយៈការប្រើប្រាស់បញ្ជីសារពើភ័ណ្ឌដែលមានស្រាប់ ឬបញ្ជីយូណេស្កូ ឬតាមរយៈការឱ្យពួកគេលើកឡើងអំពីទម្លាប់ប្រតិបត្តិក្នុងក្រុមគ្រួសាររបស់ខ្លួន។ អ្នកក៏អាចឱ្យពួកគេធ្វើការស្រាវជ្រាវ ឬការអង្កេតបែបចូលរួមណាមួយក្នុងចំណោមក្រុមគ្រួសារ និងសហគមន៍ក៏បាន។

ទោះជាយ៉ាងណា បេតិកភណ្ឌវប្បធម៌អរូបីមួយចំនួនមិនមានទំនាក់ទំនងនឹងបេតិកភណ្ឌរូបីឡើយ (ឧទាហរណ៍ ទម្លាប់ព្យាបាលតាមមូលដ្ឋាន ដែលប្រើប្រាស់រុក្ខជាតិដែលគេដាំទូទៅ និងសិល្បៈទស្សនីយភាពមួយចំនួន មិនត្រូវការទីតាំងណាមួយពិសេស ដើម្បីប្រតិបត្តិឡើយ)។

ស្រដៀងគ្នានេះដែរ បេតិកភណ្ឌរូបីមួយចំនួនអាចមានសារៈសំខាន់ផ្នែកប្រវត្តិសាស្ត្រ ប៉ុន្តែប្រហែលជាមិនឆ្លុះបញ្ចាំងពីអត្តសញ្ញាណ និងគុណតម្លៃរបស់សហគមន៍ដែលបច្ចុប្បន្នរស់នៅក្បែរនោះឡើយ (ឧទាហរណ៍ ពីព្រោះទីតាំង ឬប្រាសាទនោះត្រូវបានបង្កើតឡើងដោយសហគមន៍ផ្សេង ដែលលែងមានវត្តមាននៅទីនោះទៀតហើយ ឬដោយសារពិធីសាសនា និងសកម្មភាពដែលពាក់ព័ន្ធនឹងទីតាំងនោះ លែងត្រូវបានប្រតិបត្តិទៀតឡើយ)។

### ការផ្សារភ្ជាប់រវាងបេតិកភណ្ឌរូបីជាមួយនឹងអរូបី ទស្សនកិច្ចរបស់សាលាទៅកាន់សួន Shalamar Gardens (ប្រទេសប៉ាគីស្ថាន)



សួន Shalamar Gardens ក្នុងទីក្រុង ឡាហ័រ (Lahore) ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ១៩៨១។ ទីតាំងនេះមានព្រះពន្លាដ៏ប្រណីត ទឹកជ្រោះ និងស្រះតុបតែងលម្អធំៗ។ សួននេះ តំណាងឱ្យភាពសុខុដុមរមនា និងកំពូលទឹកដីសិល្បៈបុរាណ។ សិស្សបានចូលទៅមើលទីតាំងនេះជាមួយនឹងអ្នកថែរក្សា ដើម្បីស្វែងយល់ពីសារៈសំខាន់ផ្នែកប្រវត្តិសាស្ត្ររបស់ទីតាំងនេះ។ ពួកគេសង្កេតឃើញស្ថាបត្យកម្មផ្នែកធរណីមាត្រ បានគូររូបគំនូរផ្កា ហើយកំណត់មើលដើមឈើ និងរុក្ខជាតិ។ កំពូលតន្ត្រីករមួយរូបបានពន្យល់ពីទំនាក់ទំនងរវាងតន្ត្រី គណិតវិទ្យា សំណេរដោយដៃ ធរណីមាត្រ និងរឿងប្រជាប្រិយ។ បន្ទាប់មក គាត់ក៏បានបង្ហាញថាតើគេអាចទាញពីពេលវេលាក្នុងថ្ងៃនោះ និងមនោរម្មណ៍ផ្សេងៗតាមបានដូចម្ដេចតាមរយៈតន្ត្រី។ សិស្សនាំគ្នាច្រៀងចម្រៀងក្នុងមូលដ្ឋាន ទាក់ទងនឹងសួន និងធម្មជាតិនោះ។

## តើសកម្មភាពអ្វីខ្លះដែលអ្នកអាចធ្វើបាន ?




ពិនិត្យមើលជម្រើសនានា នៅតាមសាលារបស់អ្នក ហើយកំណត់យកជម្រើសណាដែលសមស្រប និងអាចធ្វើទៅបានជាងគេ។ អាចមានជម្រើសមួយចំនួន៖

- ជារឿងមានប្រសិទ្ធភាពខ្លាំងណាស់ក្នុងការបញ្ចូលមាតិកាបេតិកភណ្ឌរស់ទៅក្នុងកម្មវិធីសិក្សាសាលាដែលមានស្រាប់ មុខវិជ្ជានានា ដូចជាប្រវត្តិវិទ្យា វិទ្យាសាស្ត្រសង្គម តន្ត្រី សិល្បៈ និងភាសា ជារឿយៗអាចបញ្ចូលប្រធានបទនានាទាក់ទងនឹងបេតិកភណ្ឌរស់នៅក្នុងមូលដ្ឋានបាន ហើយមានភាពងាយស្រួលក្នុងការពង្រឹងផែនការមេរៀនដែលមានមាតិកាបេតិកភណ្ឌវប្បធម៌អរូបី។ បេតិកភណ្ឌវប្បធម៌អរូបីអាចធ្វើឱ្យមេរៀនរស់រវើក ហើយទាក់ទាញការយកចិត្តទុកដាក់ពីសិស្សនៅក្នុងមុខវិជ្ជាទាំងអស់ រាប់បញ្ចូលទាំង គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងសេដ្ឋកិច្ច។
- សកម្មភាពក្រៅកម្មវិធីសិក្សាដូចជាក្លឹបសាលា ព្រឹត្តិការណ៍ពិសេសៗ ការធ្វើដំណើរទស្សនកិច្ចសិក្សាពិសេស និងការបោះជំរំរដូវក្តៅ គឺជាវិធីសាស្ត្រងាយៗសម្រាប់បញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការសិក្សា ពីព្រោះ សកម្មភាពទាំងអស់នេះអាចផ្តល់នូវភាពបត់បែន ហើយពុំមានភាពតឹងរ៉ឹងដែលទាក់ទងនឹងការប្រលងឡើយ។
- លំហាត់នៅផ្ទះ ដូចជាលំហាត់ធ្វើជាលក្ខណៈបុគ្គល និងការសម្ភាសន៍ជាមួយក្រុមគ្រួសារ និងសមាជិកសហគមន៍ ក៏ផ្តល់នូវឱកាសសម្រាប់សិស្សបានរៀនបន្ថែមអំពីបេតិកភណ្ឌវប្បធម៌អរូបីថែមទៀតផង។



### ការពិភាក្សាពេញមួយសាលាអំពីសិល្បៈនៃពង្សាវតារ ( ប្រទេសកាហ្សាក់ស្ថាន )

ក្នុងប្រទេសកាហ្សាក់ស្ថាន *Shezhire* គឺជាប្រពៃណីនៃការសិក្សាអំពីពង្សាវតាររបស់មនុស្សម្នាក់យ៉ាងហោចណាស់ ៧ ជំនាន់។ សាលា Dostar International School – Lyceum បានរៀបចំសកម្មភាពក្រៅកម្មវិធីសិក្សាពេញមួយសាលា ទៅលើមូលបទមួយនេះ។ សិស្សបានរៀនអំពីបេតិកភណ្ឌរស់ និងអនុសញ្ញាឆ្នាំ២០០៣ បន្ទាប់មក ពួកគេបានចាប់ផ្តើមការពិភាក្សា ថាតើ *Shezhire* គួរតែបញ្ចូលទៅក្នុងបញ្ជីរបស់អង្គការយូណេស្កូសម្រាប់បេតិកភណ្ឌវប្បធម៌អរូបីរបស់មនុស្សជាតិ ដែរ ឬយ៉ាងណា។ នៅពេលដែលរៀបចំធ្វើការពិភាក្សាដេញដោល សិស្សបានដឹងអំពីការប្រតិបត្តិមួយនេះ ហើយវាមានសារៈសំខាន់សម្រាប់សហគមន៍ផ្សេងៗ ហើយក៏ឆ្លុះបញ្ចាំងពីមធ្យោបាយដែលអាចធ្វើបានដើម្បីការពារបេតិកភណ្ឌនេះផងដែរ។




## ការប្រើប្រាស់រូបមន្តម្ហូបបុរាណដើម្បីរៀនគណិតវិទ្យា ( ប្រទេសនេប៉ាល់ )

នៅអំឡុងពិធីពិសេសៗ ដូចជាចូលឆ្នាំជាដើម សហគមន៍ Tamang ធ្វើនំទំហំប៉ុនមួយមាត់ជាច្រើន ដែលហៅថានំ *Khapse*។ បេតិកភណ្ឌវប្បធម៌មួយនេះ ស៊ីគ្នាយ៉ាងខ្លាំងជាមួយនឹងមុខវិជ្ជាគណិតវិទ្យា។ អំឡុងពេលរៀនគណិតវិទ្យា សិស្សបានវាស់វែងចំណុះ និងបរិមាណនៃគ្រឿងផ្សំ ដែលត្រូវការសម្រាប់រៀបចំធ្វើនំនេះ។ ពួកគេក៏បានវាស់វែងពីផ្ទៃក្រឡារបស់ឧបករណ៍ ដែលយកទៅប្រើដើម្បីធ្វើនំនេះ ហើយជាលទ្ធផលបានធ្វើនំនេះរួចនៅសាលា។ ដើម្បីរៀបចំមេរៀននេះ សិស្សបានកំណត់ពីប្រភេទមុខម្ហូបដែលពាក់ព័ន្ធនឹងពិធីនានា ដែលគេអបអរប្រារព្ធឡើងនៅក្នុងសហគមន៍របស់ខ្លួន ហើយពួកគេបានចងក្រងជាឯកសារនូវរូបមន្តធ្វើម្ហូបដោយមានការជួយជ្រោមជ្រែងពីក្រុមគ្រួសាររបស់ខ្លួន។

## ស្វែងយល់ពីគុណតម្លៃរបស់បេតិកភណ្ឌវប្បធម៌អរូបី តាមរយៈបេតិកភណ្ឌតន្ត្រី ( ប្រទេសគៀជីស្ថាន )

ក្នុងប្រទេសគៀរជីស្ថាន គ្រូបង្រៀនតន្ត្រីម្នាក់ និងសិស្សរបស់គាត់បាននាំគ្នារិះគិតទៅដល់បេតិកភណ្ឌរស់ ហើយបានរៀបចំបញ្ជីសំណួរ ទាក់ទងនឹងបេតិកភណ្ឌនោះ។ ក្រោយចប់មេរៀន សិស្សបានសម្ភាសន៍មិត្តរួមសាលារបស់ខ្លួន និងគ្រូបង្រៀន នៅក្នុងសាលាដោយប្រើកម្រងសំណួរនោះ។ អ្នកឆ្លើយតបមួយចំនួនបានឆ្លើយតបទៅនឹងកម្រងសំណួរដោយនិយាយថា បេតិកភណ្ឌវប្បធម៌អរូបី ធ្វើឱ្យពួកគេស្គាល់ពីអត្តសញ្ញាណរបស់ខ្លួន ហើយត្រូវតែមានកិច្ចការពារ និងផ្សព្វផ្សាយទៅឱ្យមនុស្សជំនាន់ក្រោយ។ អ្នកឆ្លើយតបមួយចំនួនមិនសូវជាស្គាល់បេតិកភណ្ឌវប្បធម៌អរូបីឡើយ ហើយបានដឹងពីពាក្យនេះ ដោយសារតែសកម្មភាពមួយនេះ។ លំហាត់ថ្នាក់រៀនមួយនេះ បានផ្តួចផ្តើមឱ្យមានការផ្លាស់ប្តូរគំនិតគ្នាក្នុងចំណោមសិស្ស ហើយនិងពិចារណាទៅលើប្រធានបទនេះនៅក្នុងសាលា ហើយបានរួមចំណែកដល់ការលើកកម្ពស់ការយល់ដឹងអំពីគុណតម្លៃនៃបេតិកភណ្ឌវប្បធម៌។



## ការចែករំលែកអំពីប្រតិបត្តិវប្បធម៌ (ប្រទេសហ្វីលីពីន)

ជារៀងរាល់ឆ្នាំ វិទ្យាល័យ Pres. Sergio Osmeña, Sr. រៀបចំពិធីបុណ្យ MAPEH (តន្ត្រី សិល្បៈ អប់រំកាយ និងសុខភាព)។ សម្រាប់ពិធីបុណ្យនេះ ថ្នាក់រៀននីមួយៗ រៀបចំក្បាច់រាំទៅតាមរបាំប្រពៃណីរបស់សិស្សណាម្នាក់។ សិស្សមួយរូបនោះ ជាអ្នកដឹកនាំ នៅក្នុងការបង្រៀនមិត្តរួមថ្នាក់របស់ខ្លួន ដែលសកម្មភាពនេះជាការផ្តល់អំណាចយ៉ាងខ្លាំង។ ដោយសារតែសិស្សជាអ្នកមកពីគ្រប់ទិសទីក្នុងប្រទេស ដូច្នេះពិធីបុណ្យ MAPEH គឺជាឱកាសមួយដើម្បីស្វែងរករបាំ និងចម្រៀងពីតំបន់ផ្សេងៗ និងពីបណ្តាជាតិពន្ធនានារបស់ប្រទេស។ ពិធីបុណ្យនេះលើកទឹកចិត្តឱ្យសិស្សចែករំលែកអំពីបេតិកភណ្ឌរបស់ខ្លួនទៅឱ្យបណ្តាមិត្តរួមថ្នាក់របស់គេ ផ្តល់អំណាចឱ្យគេបានបង្រៀន ហើយពិតណាស់ជួយលើកកម្ពស់ភាពចម្រុះគ្នាផ្នែកវប្បធម៌ និងការអត់ឱនក្នុងចំណោមមិត្តរួមថ្នាក់។

## បង្កើនវត្តមាននៅសាលាតាមរយៈការអប់រំអំពីបេតិកភណ្ឌ (ប្រទេសនេប៉ាល់)

អស់រយៈពេលជាងដប់ឆ្នាំសាលា Panshakanya បាន និងកំពុងអភិវឌ្ឍកម្មវិធីក្រៅកម្មវិធីសិក្សាមួយដែលផ្តោតលើបេតិកភណ្ឌរស់របស់សិស្ស។ ឧទាហរណ៍ នៅថ្ងៃសុក្រសិស្សអាចរៀន អំពីចម្រៀង និងរបាំក្នុងស្រុក។ ជួនកាល ពួកគេថែមទាំងចូលរួមនៅក្នុងការប្រកួតថែមទៀតផង ហើយពួកគេឡើងសម្តែងអំឡុងពេលពិធីបុណ្យផ្សេងៗ។ នាយកសាលាបានសង្កេតឃើញថា ចាប់តាំងពី ការបញ្ចូលកម្មវិធីក្រៅកម្មវិធីសិក្សាអំពីបេតិកភណ្ឌរស់នោះមក សិស្សមកសាលាជាប្រចាំជាងមុន។ សិស្សធ្វើការរួមគ្នា កាន់តែមានភាពសុខដុម នៅក្នុងថ្នាក់រៀន និងអំឡុងសកម្មភាពក្រៅកម្មវិធីសិក្សា ដែលបានជួយឱ្យពួកគេអភិវឌ្ឍជំនាញ នៃការប្រើប្រាស់ភាសាជាតិសម្រាប់ការនិយាយ និងសរសេរបានកាន់តែប្រសើរជាងមុន។ សិស្សក៏បានអភិវឌ្ឍការគោរពចំពោះគ្នាទៅវិញទៅមកកាន់តែខ្លាំងជាងមុនផងដែរ។

### តើអ្នកណាអាចធ្វើជាដៃគូរបស់អ្នកនៅតាមសាលា សហគមន៍ និងកន្លែងផ្សេងពីនេះ ?

ការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងកម្មវិធីអប់រំតាមសាលា កាន់តែមានភាពងាយស្រួល ប្រសិនបើអ្នកអាចស្វែងរកដៃគូគាំទ្រដំណើរការនេះបាន។ អ្នកនឹងអាចចែករំលែកនូវចំណេះដឹង ធនធាន គំនិត ទស្សនៈ និងបន្ទុកការងាររបស់អ្នកជាមួយពួកគេបាន។

#### ដៃគូនៅតាមសាលា៖

- សហការីមួយចំនួន ប្រហែលជាធ្លាប់មានបទពិសោធន៍អំពីការបង្រៀនបេតិកភណ្ឌរស់ ហើយអាចចែករំលែកបទពិសោធន៍ និងកិច្ចតែងការបង្រៀនរបស់ពួកគេបាន។
- សហការីដែលបង្រៀនមុខវិជ្ជាដូចគ្នានេះ អាចផ្តល់នូវគំនិតយោបល់ និងមតិកែលម្អដែលទាក់ទងនឹងខ្លឹមសារមេរៀន ហើយជួយវាយតម្លៃថា តើបេតិកភណ្ឌរស់ដែលអ្នកយល់ឃើញ នៅក្នុងចិត្តរបស់អ្នក មានភាពទាក់ទងគ្នាជាមួយនឹងគោលបំណងសិក្សាដែរឬយ៉ាងណា។
- នៅពេលយើងមានសហការីដែលមានជំនាញឯកទេសក្នុងមុខវិជ្ជាផ្សេងទៀត អ្នកអាចស្វែងយល់អំពីចំណុចផ្សេងៗនៃបេតិកភណ្ឌវប្បធម៌អរូបី ហើយអនុវត្តគម្រោងរួមគ្នា ឬភ្ជាប់មេរៀនរបស់អ្នកជាមួយគ្នា។
- សហការីដែលទទួលខុសត្រូវចំពោះក្លឹប ឬសមាគមប្រហែលជាមានចំណាប់អារម្មណ៍ក្នុងការចូលរួមចំណែកបញ្ចូលបេតិកភណ្ឌរស់ដែលបានកំណត់អត្តសញ្ញាណទៅក្នុងសាលា ដោយផ្តល់ទីកន្លែងសម្រាប់អនុវត្តសកម្មភាពដែលពាក់ព័ន្ធ រៀបចំដំណើរកម្សាន្ត ឬព្រឹត្តិការណ៍នានា និងធ្វើបទបង្ហាញដល់សិស្សានុសិស្សជាដើម។

" មិនមែនគ្រប់សហការីទាំងអស់ សុទ្ធតែចង់ចូលរួមពីដំណាក់កាលចាប់ផ្តើមដំបូងនោះទេ ប៉ុន្តែលទ្ធផលវិជ្ជមានរបស់ក្រុមតូចៗដែលមានការប្តេជ្ញាចិត្តខ្ពស់នោះ អាចទាក់ទាញសហការីបានកាន់តែច្រើនឡើងៗបន្ថែមទៀតនៅពេលក្រោយមក។ "

មិនមែនគ្រប់សហការីទាំងអស់ សុទ្ធតែចង់ចូលរួមពីដំណាក់កាលចាប់ផ្តើមដំបូងនោះទេ ប៉ុន្តែលទ្ធផលវិជ្ជមានរបស់ក្រុមតូចៗដែលមានការប្តេជ្ញាចិត្តខ្ពស់នោះ អាចទាក់ទាញសហការីបានកាន់តែច្រើនឡើងៗបន្ថែមទៀតនៅពេលក្រោយមក។



ការគាំទ្រពីគណៈគ្រប់គ្រងសាលាអាចបញ្ចុះបញ្ចូល និងលើកទឹកចិត្តសហការីរបស់អ្នកឱ្យចូលរួមជាមួយអ្នកក្នុងការបង្រៀនអំពីបេតិកភណ្ឌរស់បាន។



### កិច្ចសហការជាមួយសហការី ដើម្បីបង្កើតមេរៀនពហុជំនាញដ៏សម្បូរបែប (កូរ៉េ)

គ្រូបង្រៀនភាសាកូរ៉េ សិក្សាសង្គម និងអប់រំកាយ បានធ្វើការងាររួមគ្នាដើម្បីស្នើឡើងនូវមេរៀនមួយចំនួនពាក់ព័ន្ធក្រុម *Namsadang Nori*។ ទម្រង់សិល្បៈទស្សនីយភាពតាមបែបប្រពៃណីនេះ រួមបញ្ចូលនូវសមាសធាតុជាច្រើនដូចជាតន្ត្រី របាំពាក់ក្បាំងមុខ ល្ខោនតុក្កតា ការដើរខ្សែពួរ និងការសម្តែងកាយសម្ព័ន្ធព្រមទាំងការបង្វិលចានជាដើម។ នៅក្នុងថ្នាក់ភាសាកូរ៉េ សិស្សបានធ្វើការវិភាគឯកសារពាក់ព័ន្ធនឹងសិល្បៈទស្សនីយភាពនេះ ដើម្បីស្វែងយល់អំពីអត្ថន័យនៃផ្នែកផ្សេងៗ និងបានសិក្សាពីប្រវត្តិរបស់វាជាដើម។ នៅក្នុងថ្នាក់អប់រំកាយ ការដើរលើខ្សែពួរ និងការបង្វិលចានបានផ្តល់ជាសកម្មភាពថ្មីៗសម្រាប់សិស្សានុសិស្ស។ ហើយដោយសារតែក្រុម *Namsadang Nori* បង្ហាញអំពីការរិះគន់ចំពោះសង្គម និងប្រព័ន្ធសង្គមដែលមានការរើសអើង សិល្បៈទស្សនីយភាពនេះគឺជាចំណុចចាប់ផ្តើមដ៏គួរឱ្យចាប់អារម្មណ៍មួយដើម្បីណែនាំសិស្សអំពីប្រធានបទស្តីពីសិទ្ធិមនុស្ស។ ការសិក្សានេះអនុញ្ញាតឱ្យសិស្សអនុវត្តជំនាញសំខាន់ៗ ថែមទាំងស្វែងយល់ពីសិល្បៈទស្សនីយភាពនេះ ទាក់ទងនឹងចំណុចផ្សេងៗគ្នាផងដែរ។

### ការនាំយកក្រុម ការងារផ្នែករដ្ឋបាលឱ្យចូលរួមក្នុងដំណើរការការងារនេះ (ប្រទេសកាហ្សាក់ស្ថាន)

នៅក្នុងប្រទេសកាហ្សាក់ស្ថាន ក្រុមការងារផ្នែករដ្ឋបាលរបស់សាលាសាកល្បងទាំងបី បានសហការគ្នាយ៉ាងខ្លាំង។ ពួកគេបានជួយរៀបចំសកម្មភាពក្នុងសាលាទាំងអស់ ដូចជា មហោស្រព "Spring of Zhetisu" * ឆ្នាំ២០២១ ជាដើម និងបានផ្តល់ការគាំទ្រក្នុងការអញ្ជើញអ្នកអនុវត្តមកកាន់សាលាសម្រាប់ការចូលរួមក្នុងព្រឹត្តិការណ៍ទាំងនេះ។ គណៈគ្រប់គ្រងសាលាបានផ្តល់កន្លែងទំនេរតាមការជាក់ស្តែង និងវេទិកាអនឡាញសម្រាប់គ្រូបង្រៀន និងសិស្សក្នុងការជួបគ្នាដោយសុវត្ថិភាពជាមួយអ្នកអនុវត្ត សូម្បីតែក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ-១៩ ក៏ដោយ។



## ដៃគូនៅតាមសហគមន៍៖

ការធ្វើការងារជាមួយអ្នកអនុវត្តបានបន្ថែមគុណតម្លៃដល់ដំណើរការសិក្សាជាខ្លាំងតាមរយៈការភ្ជាប់ សិស្សានុសិស្សវ័យក្មេងជាមួយនឹងមនុស្សចាស់ និងសម្របសម្រួលឱ្យមានការផ្ទេរចំណេះដឹងអត្ថន័យ និងជំនាញ។

អ្នកអនុវត្តអាច៖

- ជួយកំណត់បេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងសហគមន៍មូលដ្ឋាន
- ផ្តល់ព័ត៌មានបន្ថែមអំពីការអនុវត្តបេតិកភណ្ឌវប្បធម៌អរូបីដែលបានលើកឡើង និងអត្ថន័យរបស់វា ដើម្បីជំរុញអំពីរបៀបដែលធាតុផ្សំនេះអាចប្រើប្រាស់នៅក្នុងបរិបទសាលា ឬដើម្បីបង្កើតឯកសារគរុកោសល្យ
- ឱ្យខ្ចីឧបករណ៍ ជំនាញ ឬវត្ថុមួយចំនួនទាក់ទងនឹងការអនុវត្ត ដែលគ្រូ និងសិស្សអាចប្រើប្រាស់ក្នុងអំឡុងពេលសិក្សា
- ត្រូវបានអញ្ជើញឱ្យធ្វើជាវាគ្មិន ដឹកនាំផ្នែកជាក់ស្តែងណាមួយក្នុងមេរៀន ហើយថែមទាំងដឹកនាំថ្នាក់ពិសេសដែលពួកគាត់ធ្វើបទបង្ហាញអំពីការអនុវត្ត ឬបង្ហាញសកម្មភាពផ្ទាល់
- ទទួលសិស្សនៅតាមកន្លែងផ្ទាល់ខ្លួន (ឧទាហរណ៍ រោងជាង ទីតាំងបេតិកភណ្ឌ សារមន្ទីរ ឬ បណ្ណាល័យ)
- ជួយពិនិត្យមើលកិច្ចតែងការបង្រៀន និងផ្តល់ការណែនាំ ប្រសិនបើខ្លឹមសារមេរៀនដែលទាក់ទងនឹងបេតិកភណ្ឌវប្បធម៌អរូបីឆ្លុះបញ្ចាំងអំពីគុណតម្លៃរបស់សហគមន៍
- ណែនាំសិស្សក្នុងអំឡុងពេលមានព្រឹត្តិការណ៍វប្បធម៌នានា ឧទាហរណ៍ ក្នុងអំឡុងពេលរៀបចំមហោស្រព និងជួយពន្យល់ពួកគេឱ្យយល់ដឹងកាន់តែច្បាស់អំពីវប្បធម៌ទាំងនោះ។

ការធ្វើការងារជាមួយអ្នកអនុវត្តបានបន្ថែមគុណតម្លៃដល់ដំណើរការសិក្សាជាខ្លាំងតាមរយៈការភ្ជាប់សិស្សានុសិស្សវ័យក្មេងជាមួយនឹងមនុស្សចាស់ និងសម្របសម្រួលឱ្យមានការផ្ទេរចំណេះដឹងអត្ថន័យ និងជំនាញ។



មនុស្សនៅក្នុងសហគមន៍ដែលគ្រូបង្រៀនអាចជួបបាន ដើម្បីទទួលបានព័ត៌មានអំពីបេតិកភណ្ឌរស់គឺៈ

- សមាជិកគ្រួសាររបស់សិស្ស រួមមាន មាតាបិតា ជីដូនជីតា និងសាច់ញាតិផ្សេងទៀត
- អ្នកជំនាញ និងអ្នកអនុវត្តបេតិកភណ្ឌវប្បធម៌អរូបី
- សមាគម និងសហព័ន្ធក្នុងស្រុក (វប្បធម៌ កីឡា សាសនា ។ល។)
- អ្នកជំនាញវប្បធម៌ អ្នកសិក្សា និងវិចិត្រករ
- តំណាងមជ្ឈមណ្ឌលវប្បធម៌ សារមន្ទីរ បណ្ណាល័យ បណ្ណសារដ្ឋាន សាលាសិល្បៈ ។ល។
- មន្ត្រីរាជការ (វប្បធម៌ បេតិកភណ្ឌ និងទេសចរណ៍)
- សិប្បករក្នុងស្រុក និងម្ចាស់អាជីវកម្មផ្សេងទៀតដែលទាក់ទងទៅនឹងបេតិកភណ្ឌវប្បធម៌អរូបី

> សមាជិកសហគមន៍មានតួនាទីយ៉ាងសំខាន់ ព្រោះថាបើគ្មានពួកគាត់ទេនោះ យើងមិនអាចដឹងព័ត៌មានបានឡើយ។ យើងគ្រាន់តែដឹងអំពីផ្នែកខាងក្រៅនៃបេតិកភណ្ឌវប្បធម៌អរូបីប៉ុណ្ណោះ ប៉ុន្តែនៅពេលយើងពិភាក្សាជាមួយពួកគាត់ យើងបានដឹងអំពីព័ត៌មានលម្អិតបន្ថែមអំពីមហោស្រព Jatra។ ការសហការគ្នាបានជួយខ្ញុំឱ្យដឹងកាន់តែច្រើនអំពីវប្បធម៌របស់យើង។
>
> *– Pabitra Shakya គ្រូបង្រៀននៅប្រទេសនេប៉ាល់*





## ការអញ្ជើញអ្នកជំនាញឱ្យមកកាន់សាលា ( ប្រទេសថៃ នេប៉ាល់ និងកាហ្សាក់ស្ថាន )

នៅក្នុងភូមិ Ban Thawai ប្រទេសថៃ សាលាបានសហការជាប់ជានិច្ចជាមួយសិប្បករដែលមានជំនាញនៅក្នុងភូមិនេះ។ សិប្បករម្នាក់ក្នុងចំណោមសិប្បករទាំងនោះគឺលោក Anant Thao ដែលធ្លាប់រៀននៅទីនោះកាលពីគាត់នៅក្មេង បានបង្រៀនអំពីការឆ្លាក់ឈើនៅសាលានេះជាច្រើនឆ្នាំមកហើយ។ គាត់មានភាពរីករាយយ៉ាងខ្លាំងក្នុងការចែករំលែកចំណេះដឹងរបស់គាត់ដល់សិស្ស ហើយសង្ឃឹមថា ពួកគេមួយចំនួននឹងចាប់អារម្មណ៍ក្នុងការបន្តការងារហត្ថកម្មនេះតទៅមុខទៀត។ ជារៀងរាល់មួយឆ្នាំម្តងនៅជ្រលងភ្នំ Kathmandu ក្នុងប្រទេសនេប៉ាល់ សហគមន៍ Newa បានធ្វើការគោរពវិញ្ញាណក្ខន្ធដល់អ្នកស្លាប់តាមរយៈការដើរហែរជាក្បួន។ ហើយនៅក្នុងគ្រួសារដែលមានអ្នកទទួលមរណភាពក្នុងអំឡុងឆ្នាំនោះ សមាជិកវ័យក្មេងម្នាក់ក្នុងគ្រួសារត្រូវស្លៀកពាក់តុបតែងជាសត្វគោ ហើយពាក់របាំងមុខក្រដាសនៅក្នុងក្បួនដង្ហែនោះ។ សិប្បករក្នុងស្រុកម្នាក់ឈ្មោះលោក Rupendra Maharjan ដែលជាសមាជិករបស់គ្រួសារមួយក្នុងចំណោមគ្រួសារដែលបានបង្កើតគំរូរូបភាពសម្រាប់របាំងមុខក្រដាសជារូបសត្វគោជាច្រើនជំនាន់មកហើយ។ គ្រូបង្រៀនម្នាក់គឺលោកស្រី Pabitra Shakya បានអញ្ជើញគាត់ឱ្យដឹកនាំវគ្គសិក្សាចំនួនពីរនៅសាលានេះក្នុងអំឡុងពេលដែលសិស្សបានរៀនអំពីការធ្វើរបាំងមុខ និងធ្វើវាបានមួយចំនួនផងដែរ។  នៅទីក្រុង Almaty ប្រទេសកាហ្សាក់ស្ថាន អ្នកជំនាញឧបករណ៍ *Dombyra Kuy* [ឧបករណ៍ខ្សែ] បានចុះមកកាន់សាលាកាយសម្ព័ន្ធ Abdulla Rozybakiev លេខ ១៥៣ ហើយបានធ្វើបទបង្ហាញអំពីរបៀបលេងឧបករណ៍នោះ។







## ដៃគូស្ថាប័ន និងវិស័យឯកជន៖

ស្ថាប័នវប្បធម៌ដូចជា សារមន្ទីរ បណ្ណាល័យ មជ្ឈមណ្ឌលសហគមន៍ ក្លឹបវប្បធម៌ និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) គឺជាប្រភពព័ត៌មានដ៏មានតម្លៃ ក៏ដូចជាដៃគូដ៏មានសក្តានុពលផងដែរ។ ប្រសិនបើសាលារបស់អ្នកសហការជាមួយស្ថាប័នទាំងនេះរួចហើយ សូមពិចារណាពង្រឹងភាពជាដៃគូដែលមានស្រាប់ទាំងនេះ។ ពួកគេអាចផ្តល់ព័ត៌មាន និងជួយអ្នកក្នុងការសិក្សាស្រាវជ្រាវបាន។ ដៃគូភាគច្រើនមានកម្មវិធីអប់រំ ដែលអ្នកអាចទាញយកបាន។ អ្នកជំនាញផ្នែកវប្បធម៌អាចយល់ព្រមគាំទ្រអ្នកក្នុងការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងបរិបទសាលា និងជួយរៀបចំកិច្ចតែងការបង្រៀន និងបង្កើតសម្ភារៈគរុកោសល្យផងដែរ។ វិស័យឯកជនអាចបរិច្ចាគជាសម្ភារៈបរិក្ខារដែលជាការរួមចំណែកតាមរយៈកម្មវិធីទំនួលខុសត្រូវសង្គមរបស់ពួកគេបាន។ បេតិកភណ្ឌរស់គឺមានភាពចម្រុះគ្នា និងផ្សារភ្ជាប់ទៅនឹងប្រធានបទជាច្រើន ហើយពេលខ្លះគឺហួសពីអ្វីដែលយើងគិតដល់ នៅពេលដែលយើងនិយាយអំពីវប្បធម៌ រួមទាំងប្រធានបទមួយចំនួន ដូចជាសុខភាព និងបរិស្ថានជាដើម។ ស្វែងរកស្ថាប័នណាដែលធ្វើការក្នុងវិស័យទាំងនេះ។ ស្ថាប័នទាំងនោះអាចជាសមាគមសុខាភិបាល សហព័ន្ធកីឡា ក្រុមបរិស្ថានសាកលវិទ្យាល័យ និងមហាវិទ្យាល័យក្នុងតំបន់។

### កិច្ចសហការជាមួយសមាគម និងសហព័ន្ធ (ប្រទេសគៀជីស្ថាន)

គ្រូបង្រៀនមកពីសាលា លេខ ៩៥ គឺជាសមាជិករបស់សហព័ន្ធកីឡា និងល្បែងប្រជាប្រិយ *Salbuurun*។ នៅពេលដែលសាលានេះបានរៀបចំការប្រារព្ធពិធី *Nooruz* ដែលជាពិធី សមរាត្រី (equinox) និទាឃរដូវ ពួកគេបានអញ្ជើញសហព័ន្ធនេះឱ្យចូលរួម។ ក្នុងពិធីនេះ សមាជិកសហព័ន្ធបានផ្តល់ព័ត៌មានអំពីល្បែងប្រជាប្រិយ និងរៀបចំការធ្វើបទបង្ហាញមួយចំនួន និងបង្រៀនដល់សិស្សានុសិស្ស។

### កិច្ចសហការជាមួយស្ថាប័នមិនមែនវប្បធម៌ ( ប្រទេសចិន )

នៅប្រទេសចិន គ្រូបង្រៀននៅវិទ្យាល័យមួយ បានសហការជាមួយសាកលវិទ្យាល័យឱសថបុរាណចិនដើម្បីរៀបចំមេរៀនអំពីឱសថបុរាណ។ ថ្នាក់រៀននីមួយៗត្រូវបង្រៀនដោយគ្រូវិទ្យាល័យទាំងនោះ ដោយមានការណែនាំពីសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យនេះ។

## តើអ្នកអាចរៀបចំកាលវិភាគមេរៀនដោយប្រើប្រាស់បេតិកភណ្ឌរស់យ៉ាងដូចម្ដេច និងនៅពេលណា ?

ការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងមេរៀន និងសកម្មភាពរបស់អ្នក អាចអនុវត្តនៅពេលណាក៏បានក្នុងអំឡុងឆ្នាំសិក្សា។ អ្នកអាចចាប់ផ្ដើមពីសកម្មភាពតូចៗ ដូចជាចាប់ផ្ដើមជាមួយនឹងមេរៀនមួយ ឬពីរ ឬចាប់ផ្ដើមដោយគម្រោងតូចមួយដែលអាចនឹងពង្រីកបន្ថែមបាននៅឆ្នាំក្រោយៗទៀត។ ប៉ុន្តែ ការអនុវត្តបេតិកភណ្ឌរស់មួយចំនួនគឺទាក់ទងទៅនឹងពេលវេលាជាក់លាក់ ឬរយៈពេលវេលាក្នុងឆ្នាំនោះ។ ការអនុវត្តទាំងនេះរួមបញ្ចូលមហោស្រព ពិធីសាសនា និងការប្រារព្ធពិធីផ្សេងៗ និងការអនុវត្តទាក់ទងនឹងការប្រែប្រួលរដូវកាល ឬវដ្តកសិកម្ម។ ព្រឹត្តិការណ៍បែបនេះអាចជាឱកាសសម្រាប់ឱ្យសិស្សានុសិស្សទទួលបានបទពិសោធន៍ថ្មីៗអំពីបេតិកភណ្ឌរស់ ការពិចារណាអំពីបេតិកភណ្ឌរស់ និងអាចបន្តការផ្ទេរទៅថ្ងៃអនាគត។ ការចូលរួមក្នុងព្រឹត្តិការណ៍នេះក៏នឹងផ្ដល់ឱ្យពួកគេនូវឱកាសដើម្បីធ្វើការអង្កេត និងចងក្រងឯកសារពីការអនុវត្តនោះផងដែរ។ ក្នុងករណីដែលការចូលរួមក្នុងព្រឹត្តិការណ៍នេះគឺជាផ្នែកមួយនៃផែនការសម្រាប់ការបញ្ចូលធាតុផ្សំទៅក្នុងដំណើរការសិក្សាធ្វើផែនការ គួរតែចាប់ផ្ដើមឱ្យបានល្អជាមុន ដើម្បីត្រៀមខ្លួនឱ្យបានគ្រប់គ្រាន់ និងបង្កើនការយល់ដឹងរបស់សិស្សានុសិស្សអំពីព្រឹត្តិការណ៍នេះ។

ត្រូវប្រាកដថា អ្នកក៏បានពិចារណាផងដែរថាតើសមាជិកសហគមន៍អាចនឹងមានពេលចូលរួម ដែរឬទេ ( ឧ. សម្រាប់ដំណើរកម្សាន្ត ការបង្ហាញអំពីការអនុវត្ត ការសម្ភាសន៍ជាដើម។ល។ ) ហើយស្នើសុំការយល់ព្រមជាមុន មុនពេលរៀបចំផែនការអំពីការចូលរួមរបស់ពួកគេ។ នៅក្នុងពេលវេលាជាក់លាក់ណាមួយនៅក្នុងឆ្នាំនោះ ពួកគេអាចមានភាពមមាញឹកខ្លាំង។





## ការរៀបចំកាលវិភាគមេរៀនពាក់ព័ន្ធការប្រារព្ធពិធីក្នុងស្រុក (គៀជីស្ថាន កាហ្សាក់ស្ថាន)

*Nooruz* (ត្រូវបានគេហៅថា *Nowruz*) គឺជាការប្រារព្ធពិធី equinox និទាឃរដូវ និងជាថ្ងៃឈប់សម្រាកបុណ្យជាតិដ៏សំខាន់បំផុតមួយនៅក្នុងបណ្ដាប្រទេសជាច្រើន រួមទាំងនៅប្រទេសគៀជីស្ថាន និងប្រទេសកាហ្សាក់ស្ថានផងដែរ ដោយសារតែគេមានការរៀបចំប្រារព្ធពិធីបុណ្យ និងពិធីសាសនាផ្សេងៗ។ សាលាជាច្រើនបានរៀបចំព្រឹត្តិការណ៍នានា ដើម្បីប្រារព្ធពិធីនេះ។ នេះ។ នៅក្នុងសាលា Kyrgyz ប៉ុន្មានសប្ដាហ៍មុនថ្ងៃឈប់សម្រាក គ្រូបានរៀបចំមេរៀនអំពីបេតិកភណ្ឌរស់សម្រាប់សិស្សគ្រប់ថ្នាក់ទាំងអស់ ពោលគឺចាប់ពីកម្រិតបឋមសិក្សាដល់ថ្នាក់វិទ្យាល័យតែម្ដង។ សិស្សបានជ្រើសរើសបេតិកភណ្ឌរស់ដែលពួកគេចាប់អារម្មណ៍ (ឧ. រឿងព្រេងនិទាន Kyrgyz និងការធ្វើកម្រាលព្រំជាដើម) ហើយបានសិក្សាអំពីរឿងនេះ។ ក្នុងអំឡុងពេលនៃការប្រារព្ធពិធី ពួកគេបានចែករំលែកព័ត៌មានដែលពួកគេប្រមូលបាន ជាមួយគ្នាទៅវិញទៅមក។ នៅពេលដែលសិស្សថ្នាក់បឋមសិក្សារៀបរាប់លទ្ធផលរបស់ពួកគេអំពីរឿងព្រេងនិទាន Kyrgyz សិស្សវិទ្យាល័យម្នាក់បានពន្យល់អំពីចំណេះដឹង និងជំនាញប្រពៃណីដែលពាក់ព័ន្ធនឹងការធ្វើកម្រាលព្រំ។ សកម្មភាពនេះជួយបង្កើនការប្រាស្រ័យទាក់ទងគ្នា រវាងសិស្សានុសិស្សនៅតាមថ្នាក់រៀនផ្សេងៗគ្នា និងធ្វើឱ្យដំណើរការសិក្សាកាន់តែមានភាពរីករាយ ហើយធ្វើឱ្យការប្រារព្ធពិធីនេះកាន់តែគួរឱ្យចងចាំថែមមួយកម្រិតទៀត។ នៅសាលាមួយផ្សេងទៀត សិស្សបានលេងល្បែងប្រជាប្រិយ និងតន្ត្រី ពិសារអាហាររួមគ្នា ច្រៀងចម្រៀង Manas epic និងការសាងសង់ខ្ទមជាដើម។

### ចំណុចគ្រូគពិនិត្យ

នៅចុងបញ្ចប់នៃជំហានទាំងនេះ អ្នកប្រហែលជាបានកំណត់អំពី៖

- ✓ បញ្ជីបេតិកភណ្ឌរស់ដែលអាចប្រើប្រាស់បានក្នុងការបង្រៀន និងការរៀន ដែលត្រូវស្វែងយល់បន្ថែម
- ✓ ប្រភេទនៃសកម្មភាពសាលា (កម្មវិធីសិក្សា និង/ឬកម្មវិធីសិក្សាក្រៅម៉ោង) ដែលស័ក្ដិសមសម្រាប់បញ្ចូលបេតិកភណ្ឌរស់ទៅក្នុងនោះ
- ✓ បញ្ជីឈ្មោះដៃគូសក្ដានុពលនៅក្នុង និងក្រៅសាលា
- ✓ រយៈពេលសមស្របនៅក្នុងប្រតិទិនសាលាដើម្បីបញ្ចូលសកម្មភាពដែលផ្សារភ្ជាប់ជាមួយបេតិកភណ្ឌរស់






## ៤.២ ជំហានទី ២ - ផ្សារភ្ជាប់បេតិកភណ្ឌរស់ជាមួយមុខវិជ្ជាសិក្សា

ជំហានដំបូង ផ្តល់នូវព័ត៌មានអំពីបេតិកភណ្ឌរស់ដែលមាននៅជុំវិញអ្នក និងអ្វីដែលអាចបញ្ចូលទៅក្នុងបរិបទសាលារបស់អ្នកបាន។ ជំហានបន្ទាប់នេះ មានគោលបំណងបង្រួមព័ត៌មាននេះឱ្យកាន់តែមានភាពជាក់លាក់ជាមុន ហើយធ្វើការសម្រេចថាតើបេតិកភណ្ឌវប្បធម៌អរូបីជាក់លាក់មួយណា ដែលអ្នកនឹងយកមកធ្វើជាផ្នែកមួយនៃបទពិសោធន៍សិក្សារបស់សិស្ស មេរៀនដែលអ្នកចង់បង្រៀនជាមួយបេតិកភណ្ឌរស់ និងសកម្មភាពដែលអ្នកចង់រៀបចំ។

> “ការគ្រប់គ្រងចំណេះដឹងបែបបុរាណគឺងាយស្រួលក្នុងការសិក្សា ដោយសារចំណេះដឹងនោះគឺនៅជុំវិញខ្លួនយើង។ សិស្សមានភាពសប្បាយរីករាយក្នុងការធ្វើកិច្ចការដែលជួយអភិវឌ្ឍដល់ជំនាញគិតពិចារណាត្រិះរិះ និងសមត្ថភាពផ្សេងៗទៀត។ វាធ្វើឱ្យពួកគេមានភាពអត់ធ្មត់ និងឧស្សាហ៍ព្យាយាម។ គុណភាពទាំងនេះបង្កើតនូវចំណេះដឹង និងជំនាញដ៏មានអត្ថប្រយោជន៍។ វាធ្វើឱ្យពួកគេទទួលស្គាល់នូវតម្លៃនៃបេតិកភណ្ឌក្នុងស្រុក និងតម្រូវការក្នុងការអភិរក្ស។
>
> *-លោកស្រី Sasiwan Kaewon គ្រូបង្រៀនសាកល្បង សាលា Ton Kaew Phadung Pittayalai ប្រទេសថៃ* ”

ជំហានទីពីរនេះមានបួនផ្នែកគឺ៖

- ការជ្រើសរើសបេតិកភណ្ឌរស់ដើម្បីផ្សារភ្ជាប់ទៅនឹងមេរៀន និងសកម្មភាពរបស់សាលា
- ការបំពេញបន្ថែមទៅលើចំណុចអាទិភាពនៃប្រព័ន្ធអប់រំរបស់សាលា
- ការរៀបចំផែនការសកម្មភាពជោគជ័យជាមួយបេតិកភណ្ឌរស់
- ការពិចារណាអំពីសមិទ្ធលទ្ធភាពនៃសកម្មភាព

## ការជ្រើសរើសបេតិកភណ្ឌរស់ ដើម្បីផ្សារភ្ជាប់ទៅនឹងមេរៀន និងសកម្មភាពរបស់សាលា

វិធីសាស្ត្រសំខាន់គឺមានចំនួនពីរ៖

- ចាប់ផ្តើមដោយការកំណត់អត្តសញ្ញាណបេតិកភណ្ឌរស់ ហើយពិនិត្យមើលថាតើសកម្មភាពរបស់សាលាណាដែលគាំទ្របេតិកភណ្ឌនេះ។
- ចាប់ផ្តើមជាមួយនឹងមុខវិជ្ជាសិក្សា ហើយកំណត់អត្តសញ្ញាណបេតិកភណ្ឌវប្បធម៌អរូបីដែលអាចបន្ថែមតម្លៃដល់ការបង្រៀន។




ប្រសិនបើអ្នកជ្រើសរើសប្រើប្រាស់បេតិកភណ្ឌវប្បធម៌អរូបីជាចំណុចចាប់ផ្តើម ដំបូងអ្នកត្រូវពិនិត្យមើលបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីដែលអ្នកបានកំណត់នៅក្នុងជំហានមុនៗ ហើយជ្រើសរើសជំហានមួយដែលអ្នកចាប់អារម្មណ៍។

អ្នកអាចជ្រើសរើសបេតិកភណ្ឌវប្បធម៌អរូបីណាមួយ (ICH) ដោយសារតែ៖

- មនុស្សជាច្រើនអនុវត្តវានៅក្នុងមូលដ្ឋាន។
- សិស្សចាប់អារម្មណ៍លើវានេះ។
- សមាជិកសហគមន៍មានចំណាប់អារម្មណ៍ក្នុងការសហការជាមួយសាលាអំពី ICH នេះ។
- ICH នេះត្រូវបានអនុវត្តតាមរបៀបមួយ ឬនៅពេលដែលសមស្របទៅនឹងប្រតិទិនសាលា។
- សហការីរបស់អ្នក ឬខ្លួនអ្នកផ្ទាល់ចាប់អារម្មណ៍លើជាតុផ្សំនេះ ហើយដឹងអំពី ICH នេះ។
- អ្នក ឬសហការីរបស់អ្នកស្គាល់អ្នកអនុវត្ត ឬសមាគមវប្បធម៌ ដែលអាចជួយផ្តល់ខ្លឹមសារមេរៀន។
- ធនធានជាច្រើនអំពី ICH នេះអាចរកបាន ហើយអាចប្រើប្រាស់ដើម្បីរៀបចំសកម្មភាពរបស់សាលា។

ដំណើរការជ្រើសរើសនេះអាចធ្វើឡើងបានជាមួយនឹងសហគមន៍សាមី សិស្ស គ្រូបង្រៀន និង/ឬគណៈគ្រប់គ្រងសាលា។ បន្ទាប់មក អ្នកអាចពិនិត្យមើលមុខវិជ្ជា និងសកម្មភាពសិក្សាដើម្បីរកមើលថាតើសកម្មភាពមួយណាដែលទាក់ទងនឹងបេតិកភណ្ឌដែលបានជ្រើសរើស។

ម្យ៉ាងទៀត អ្នកអាចចាប់ផ្តើមជាមួយនឹងមុខវិជ្ជាសិក្សាដែលអ្នកបង្រៀន ឬជាមួយមេរៀន ឬសកម្មភាពជាក់លាក់ ហើយពិនិត្យមើលថាតើបេតិកភណ្ឌរស់មួយណាអាចភ្ជាប់ជាមួយវាបាន។វិធីសាស្ត្រនេះទាមទារឱ្យអ្នកមានការយល់ដឹងច្បាស់លាស់អំពីកម្មវិធីសិក្សា។ វិធីសាស្ត្រនេះមានលក្ខណៈជាប្រព័ន្ធជាងមុនផងដែរ។ ប្រសិនបើអ្នកស្គាល់ច្បាស់នូវបេតិកភណ្ឌរស់ ជាពិសេសធាតុផ្សំដែលត្រូវបានអនុវត្តនៅតាមសាលា អ្នកនឹងមើលឃើញយ៉ាងងាយស្រួលនូវទំនាក់ទំនងរវាងធាតុផ្សំទាំងនេះ និងមុខវិជ្ជារបស់អ្នក។

> ការចាប់ផ្តើមជាមួយនឹងមុខវិជ្ជាសិក្សាទាមទារឱ្យអ្នកមានការយល់ដឹងច្បាស់លាស់អំពីកម្មវិធីសិក្សា។

បណ្តាប្រទេសមួយចំនួន បានបញ្ចូលមុខវិជ្ជាខ្លះដែលពាក់ព័ន្ធច្រើននឹងបេតិកភណ្ឌទៅក្នុងកម្មវិធីសិក្សារួចទៅហើយ ដែលការណ៍នេះជួយសម្រួលដល់ដំណើរការដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា។ ក្រៅពីនេះ ការណ៍នេះមានប្រយោជន៍សម្រាប់ការរៀបចំកម្មវិធីសិក្សាដែរ។

ឧទាហរណ៍ អ្នកអាចពិនិត្យ៖

- ប្រធានបទនៃមេរៀន ឬសកម្មភាពដែលបានបញ្ចូលទៅក្នុងកម្មវិធីសិក្សា
- គោលបំណងសិក្សាចម្បង ឬសមត្ថភាពគោលដៅនៃមុខវិជ្ជារបស់អ្នក
- តម្លៃដែលត្រូវបានលើកកម្ពស់ដោយកម្មវិធីទូលំទូលាយ ដូចជាការអប់រំពលរដ្ឋសាកល (GCED) ឬការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (ESD)

បន្ទាប់មក អ្នកអាចកំណត់ថាតើបេតិកភណ្ឌរស់ណាដែលអាចជួយគាំទ្រដល់ការយល់ដឹងអំពីមេរៀននេះ ឬការទទួលបានសមត្ថភាពដ៏ជាក់លាក់នេះ។ ដើម្បីជួយអ្នកក្នុងការជ្រើសរើសបេតិកភណ្ឌរស់ សៀវភៅណែនាំទី ៨ ផ្តល់នូវគោលគំនិតអំពីទំនាក់ទំនងរវាងមុខវិជ្ជាសិក្សា និងបេតិកភណ្ឌរស់។ សូមចងចាំថា ធាតុផ្សំបេតិកភណ្ឌរស់មួយ ជារឿយៗអាចពាក់ព័ន្ធទៅនឹងមុខវិជ្ជាសិក្សាមួយចំនួនទៀត។

### សហគមន៍ដើរតួនាទីនាំមុខគេ (ប្រទេសចិន)

សហគមន៍អាចដើរតួនាទីឈានមុខគេ តាមរយៈការលើកឡើងអំពីសកម្មភាពដែលផ្សារភ្ជាប់ទៅនឹងទម្រង់នៃបេតិកភណ្ឌរស់ដែលមានសារៈសំខាន់យ៉ាងខ្លាំងចំពោះពួកគេ។ ដើម្បីរៀបចំកម្មវិធីបេតិកភណ្ឌវប្បធម៌អរូបីរបស់ខ្លួន វិទ្យាល័យ Shanghai Zhongguo បានបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសហគមន៍ក្បែរខាងរបស់ខ្លួន។ សហគមន៍មូលដ្ឋានបានស្នើឡើងនូវគម្រោងមួយអំពីការបង្កើត *pankou* (អំបោះប៉ាក់ប្រពៃណី) នៅសាលា។ ភាពជោគជ័យនៃគម្រោងនេះបាននាំឱ្យសាលាដាក់សំណើសុំបញ្ចូលមុខវិជ្ជាផ្សេងបន្ថែមទៀត។ កត្តានេះបាននាំឱ្យមានវគ្គសិក្សាស្តីពីការធ្វើអំបោះប៉ាក់ *pankou* ការកាត់ក្រដាស និងការត្បាញស្លឹកត្នោត ត្រូវបានបង្រៀននៅសាលានេះដោយអ្នកជំនាញមកពីសហគមន៍ជុំវិញ និងថ្នាក់បង្រៀនស្តីពីឱសថចិនដោយគ្រូបង្រៀនក្រោមការណែនាំរបស់សាស្ត្រាចារ្យមកពីសាកលវិទ្យាល័យឱសថបុរាណចិនសៀងហៃ។



## ស្គរយក្សថៃភាគខាងជើងជាចំណុចចាប់ផ្តើម ( ប្រទេសថៃ )

សាលា Ban Sala ក្នុងខេត្តឈៀងម៉ៃ បានជ្រើសរើសការផលិត និងសម្តែង *Klong Luang* ( ស្គរយក្ស ) ដ៏ល្បីល្បាញជាចំណុចចាប់ផ្តើម ដោយផ្អែកលើការផ្តល់យោបល់របស់សហគមន៍ក្នុងមូលដ្ឋាន។ ស្គរយក្ស គឺសិល្បៈតំណាងឱ្យវប្បធម៌ និងប្រវត្តិសាស្ត្ររបស់ភូមិ Ban Phrachao Nang Kon ប្រជាជននៅទីនោះ ប្រើប្រាស់ស្គរយក្សនេះនៅក្នុងកម្មវិធីប្រកួតប្រជែងស្គរយក្សខេត្តប្រចាំឆ្នាំរបស់ពួកគេ។ ទម្រង់បេតិកភណ្ឌរស់មួយចំនួនត្រូវបានបង្ហាញនៅក្នុងប្រពៃណីនេះ។ ប្រធានបទជាច្រើនបានផ្សារភ្ជាប់ទៅនឹងស្គរយក្ស *Klong Luang* នេះ។ នៅក្នុងថ្នាក់ជីវវិទ្យា សិស្សបានសិក្សាអំពីប្រភេទដើមឈើជាក់លាក់មួយចំនួន ដែលប្រើសម្រាប់ធ្វើជាស្គរ និងប្រភេទសត្វគោដែលផ្តល់ស្បែកសម្រាប់ធ្វើជាស្បែកស្គរ។ នៅក្នុងថ្នាក់គណិតវិទ្យា ពួកគេអាចគណនារង្វង់ស្គរ។ នៅក្នុងថ្នាក់សិល្បៈ ពួកគេបានចម្លងការរចនាដ៏ស្មុគស្មាញរបស់ស្គរ។ នៅក្នុងថ្នាក់ភាសាថៃ និងប្រវត្តិសាស្ត្រ ពួកគេបានសិក្សាអំពីប្រវត្តិសហគមន៍ និងស្គរ ហើយសរសេរជាអត្ថបទអំពីស្គរនោះ។ ក្នុងថ្នាក់សិល្បៈទស្សនីយភាព អ្នកអនុវត្តជាន់ខ្ពស់មកពីសហគមន៍នោះ បានផ្ទេរចំណេះដឹងដោយផ្ទាល់ និងបង្ហាត់សិស្សឱ្យចេះប្រើប្រាស់ឧបករណ៍ភ្លេងបុរាណ និងសម្តែងរបាំប្រពៃណី។ បេតិកភណ្ឌរស់ ( *Klong Luang* ) នេះ ត្រូវបានដាក់បញ្ចូលទៅគ្រប់មេរៀនសិក្សាទាំងអស់តែម្តង។

## ការស្វែងរកបេតិកភណ្ឌរស់ ដើម្បីពង្រឹងកម្មវិធីគណិតវិទ្យា ( ប្រទេសថៃ )

កម្មវិធីគណិតវិទ្យាថៃ រួមមានការទទួលស្គាល់ និងកំណត់អត្តសញ្ញាណរូបរាងធរណីមាត្រផ្សេងៗជាច្រើន។ គ្រូបង្រៀនម្នាក់នៅសាលា Ban Mae Ai បានកត់សម្គាល់ឃើញថា វាយនភណ្ឌប្រពៃណី មានទម្រង់ធរណីមាត្រផ្សេងៗគ្នា។ លោកបានចាត់ឱ្យសិស្សរបស់លោកសិក្សាអំពីការរចនា និងលំនាំទាំងនេះ។ សិស្សបានប្រមូលគំរូសម្លៀកបំពាក់ត្បាញដោយដៃពីជនជាតិដើមផ្សេងៗក្នុងតំបន់ ហើយសិស្សបានចែករំលែកការរកឃើញរបស់ពួកគេតាមរយៈការតាំងពិព័រណ៍គំនូរចម្រុះពណ៌។ ពួកគេមិនត្រឹមតែសិក្សាអំពីគណិតវិទ្យាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរៀនអំពីវប្បធម៌ក្នុងស្រុក និងរឿងរ៉ាវនៅពីក្រោយវាយនភណ្ឌដ៏ស្រស់ស្អាតផងដែរ។

## ការបំពេញបន្ថែមទៅលើចំណុចអាទិភាពនៃប្រព័ន្ធអប់រំរបស់សាលា

ពេលខ្លះ ប្រធានបទក៏អាចជាចំណុចចាប់ផ្ដើមផងដែរ។ ឧទាហរណ៍ ប្រសិនបើសាលាកំពុងផ្សព្វផ្សាយការអប់រំអំពីសន្តិភាព និងសង្កត់ធ្ងន់ទិដ្ឋភាពពហុវប្បធម៌ មុខវិជ្ជាសិក្សាអំពីវប្បធម៌អាចជាចំណុចចាប់ផ្ដើមដ៏សមស្របមួយសម្រាប់ការដាក់បញ្ចូលបេតិកភណ្ឌរស់នៅទៅក្នុងការអប់រំ។ ថ្នាក់រៀននីមួយៗ អាចណែនាំអំពីការអនុវត្តវប្បធម៌ចម្រុះដើម្បីលើកកម្ពស់ភាពចម្រុះនៃវប្បធម៌បាន។ ស្រដៀងគ្នានេះដែរ ប្រសិនបើប្រធានបទក្នុងថ្នាក់រៀន និយាយអំពីការអភិវឌ្ឍប្រកបដោយចីរភាព នោះចំណុចចាប់ផ្ដើមអាចជាចំណេះដឹងក្នុងស្រុកអំពីការអភិរក្សជីវចម្រុះ។

កម្មវិធីអប់រំមួយចំនួនផ្ដល់អាទិភាពដល់ភាពជាពលរដ្ឋសកល។ ក្នុងករណីនេះ មុខវិជ្ជាដូចជាភាសា ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រសង្គម និងការសិក្សាអំពីវប្បធម៌ អាចជាចំណុចចាប់ផ្ដើមដើម្បីស្វែងយល់អំពីបេតិកភណ្ឌរស់ ទន្ទឹមនឹងការលើកកម្ពស់សិទ្ធិមនុស្ស ការគោរពភាពចម្រុះ និងគោលការណ៍ GCED សំខាន់ៗផ្សេងទៀត។

> ខ្ញុំធ្លាប់ចូលរួមក្នុងពិធីសាសនា *Tushookesuu* ដែលកំណត់អំពីជីវិតដំបូងរបស់ទារក។ ខ្ញុំឃើញគេយកខ្សែចងកជើងទារក ប៉ុន្តែខ្ញុំមិនដឹងថាហេតុអ្វីបានជាគេចងខ្សែពណ៌ខ្មៅ និងសនោះទេ។ ក្នុងអំឡុងពេលបង្រៀនមេរៀន គ្រូបានពន្យល់យើងអំពីអត្ថន័យនៃពិធីនេះ និងព័ត៌មានលម្អិតផ្សេងទៀតទាំងអស់។ បន្ទាប់ពីនោះមក ខ្ញុំបានសម្រេចថា នេះគឺជាទំនៀមទម្លាប់ Kyrgyz ដ៏ល្អបំផុត។
>
> *– Bogdan Zmeev សិស្សមកពីគម្រោងសាកល្បង គៀជីស្ថាន*

> បញ្ញាប្រកបដោយគតិបណ្ឌិតក្នុងតំបន់គឺជាមូលដ្ឋានគ្រឹះនៃវប្បធម៌ ដែលបង្ហាញឱ្យឃើញអំពីរបៀបរស់នៅរបស់យើង។ តម្លៃរបស់វាលើសពីតម្លៃរូបិយវត្ថុ។ ជាមួយនឹងប្រវត្តិសាស្ត្រដ៏យូរអង្វែងរបស់វានៅលើទឹកដីរបស់យើង យើងគួរតែសិក្សា និងធានាអនាគតរបស់ប្រវត្តិសាស្ត្រនេះផងដែរ។
>
> *- លោកស្រី Puangphet Meema គ្រូបង្រៀនសាលា Ban Mae Ngon Khi Lek ប្រទេសថៃ*

## រៀបចំផែនការសកម្មភាពជោគជ័យជាមួយបេតិកភណ្ឌរស់

ត្រូវធ្វើការពិចារណាអំពីចំណាប់អារម្មណ៍ និងតម្រូវការសិស្សរបស់អ្នក នៅពេលអ្នកជ្រើសរើសបេតិកភណ្ឌរស់ដែលអ្នកនឹងបង្រៀន។ សិស្សនឹងកាន់តែចូលរួមក្នុងសកម្មភាពសិក្សា ប្រសិនបើពួកគេចាប់អារម្មណ៍នឹងប្រធានបទនោះ។ សិស្សខ្លះជាអ្នកអនុវត្តបេតិកភណ្ឌរស់ ហើយប្រហែលជាមានមោទនភាពខ្លាំងចំពោះការអនុវត្តមួយចំនួននៅក្នុងសហគមន៍របស់ពួកគេ។ ពួកគេអាចចែករំលែកបទពិសោធន៍របស់ខ្លួនជាមួយមិត្តរួមសាលារបស់ពួកគេផ្សេងទៀតបាន។ បើមិនដូច្នោះទេ ពួកគេប្រហែលជាចង់ដឹងចង់ឃើញយ៉ាងខ្លាំងអំពីបេតិកភណ្ឌរបស់សហគមន៍ផ្សេងទៀត។

ការធ្វើការវិភាគរហ័សនៅដំណាក់កាលនេះ មុននឹងចំណាយពេលវេលាក្នុងការបង្កើតកិច្ចតែងការបង្រៀន ដែលប្រហែលជាមិនអាចអនុវត្តបាន គឺពិតជាមានអត្ថប្រយោជន៍ជាខ្លាំង។ មេរៀន និងសកម្មភាពភាគច្រើនអាចរៀបចំឡើងដោយមានការផ្គត់ផ្គង់តិចតួច ប៉ុន្តែកម្មវិធីផ្សេងទៀតអាចត្រូវការធនធាន ភស្តុភារ និងការវិនិយោគបន្ថែមទៀត។ អ្នកនឹងត្រូវកំណត់ថាតើធនធានអ្វីខ្លះដែលត្រូវការសម្រាប់មេរៀន ឬសកម្មភាពនីមួយៗ ដូចជា ព័ត៌មានកន្លែងសិក្សា ការផ្គត់ផ្គង់ ឯកសារសោតទស្សន៍ ការដឹកជញ្ជូន ភាពជាដៃគូជាមួយស្ថាប័នផ្សេងៗ ការផ្តល់មូលនិធិ និងពេលវេលា។ ធនធានដែលអាចរកបាននឹងកំណត់អំពីសកម្មភាពដែលអ្នកអាចអនុវត្តបាន។




## រៀបចំការស្ទង់មតិដើម្បីវាយតម្លៃអំពីចំណាប់អារម្មណ៍របស់សិស្ស (អ៊ូសបេគីស្ថាន គៀជីស្ថាន)

គ្រូបង្រៀននៅសាលានានានៅអ៊ូសបេគីស្ថាន និងគៀជីស្ថាន បានលើកឡើងអំពីបញ្ជីបេតិកភណ្ឌរស់ដល់សិស្សរបស់ខ្លួន។ បន្ទាប់មក ពួកគេបានរៀបចំការស្ទង់មតិដើម្បីកំណត់ថាតើបេតិកភណ្ឌរស់មួយណាដែលសិស្សចាប់អារម្មណ៍ជាងគេ។



តារាង ៤.១ ភារកិច្ច និងលក្ខខណ្ឌពាក់ព័ន្ធមេរៀនស្តីពីបេតិកភណ្ឌវប្បធម៌អរូបី

| ភារកិច្ច | លក្ខខណ្ឌតម្រូវ |
|---|---|
| រៀបចំកិច្ចតែងការបង្រៀន រៀបចំឯកសារចែកជូន និងប្រភពសម្រាប់សកម្មភាព | ព័ត៌មានអំពី ICH និងកិច្ចសហប្រតិបត្តិការជាមួយសមាជិកសហគមន៍ និងដៃគូ |
| ទទួលវាគ្មិន រៀបចំព្រឹត្តិការណ៍ ពិព័រណ៍ និងសកម្មភាពនានា | កន្លែងសមរម្យ |
| ដំណើរការសកម្មភាពមួយចំនួននៅក្នុងថ្នាក់រៀន | សម្ភារៈការិយាល័យ និងសម្ភារៈបរិក្ខារ វត្ថុទាក់ទងនឹងការអនុវត្តបេតិកភណ្ឌវប្បធម៌អរូបី |
| ដាក់តាំងសម្ភារៈសោតទស្សន៍ (រូបថត រូបភាព វីដេអូ ។ល។) | ឯកសារសោតទស្សន៍ (ឧបករណ៍បញ្ចាំងស្លាយដ៍ អេក្រង់ ។ល។) |
| រៀបចំដំណើរកម្សាន្ត និងជួបជាមួយអ្នកជំនាញក្នុងមូលដ្ឋាន | ស្ថាប័ន ឬសហគមន៍ដែលត្រូវចុះទៅជួប (ឧ. កន្លែងវប្បធម៌ សារមន្ទីរ បណ្ណាល័យ បណ្ណសារដ្ឋាន រោងជាងរបស់វិចិត្រករ មជ្ឈមណ្ឌលសិល្បៈទស្សនីយភាព សមាគមវប្បធម៌ក្នុងមូលដ្ឋាន)<br>ការដឹកជញ្ជូន៖ សាធារណៈ (រថភ្លើង/រថយន្តក្រុង) ឬឯកជន (រថយន្ត រថយន្តក្រុង) |
| កត់ត្រាជាឯកសារការអនុវត្ត និងធ្វើការសម្ភាសន៍ | សៀវភៅកត់ត្រា កាមេរ៉ា ម៉ាស៊ីនថតវីដេអូ(ឬទូរសព្ទដៃ) ។ល។ |
| រៀបចំដំណើរកម្សាន្ត និងផ្គត់ផ្គង់សម្ភារៈ ព័ត៌មាន និងធនធានមនុស្ស | ស្ថាប័ននានា (ឧ. សារមន្ទីរ បណ្ណាល័យ បណ្ណសារដ្ឋាន មជ្ឈមណ្ឌលសិល្បៈទស្សនីយភាព សមាគមវប្បធម៌ក្នុងមូលដ្ឋាន) |
| បង់ថ្លៃចូលទស្សនា និងទិញសម្ភារៈផ្គត់ផ្គង់ | ការឧបត្ថម្ភថវិកា |
| ធ្វើការស្រាវជ្រាវ រៀបចំសំណួរសម្ភាសន៍ រៀបចំផែនការសកម្មភាព រៀបចំការផ្លាស់ប្ដូរយោបល់រវាងសិស្ស គ្រូ សហគមន៍មូលដ្ឋាន | រយៈពេល |

ត្រូវពិចារណាលើទិដ្ឋភាពផ្សេងទៀតដែលទាក់ទងនឹងបេតិកភណ្ឌវប្បធម៌អរូបី ហើយពិចារណាលើគោលនយោបាយនានា (នៅសាលា ថ្នាក់មូលដ្ឋាន ឬថ្នាក់ជាតិ) ដែលអាចប៉ះពាល់ដល់សកម្មភាពរបស់អ្នក។ ឧទាហរណ៍៖

- ***ភាសា៖*** ក្នុងបរិយាកាសពហុវប្បធម៌ តើសិស្សអាចប្រាស្រ័យទាក់ទងជាមួយអ្នកជំនាញ ឬអានឯកសារជាភាសាផ្សេងៗបានទេ?
- ***បទប្បញ្ញត្តិសុវត្ថិភាព៖*** តើច្បាប់អ្វីខ្លះដែលអ្នកត្រូវអនុវត្តតាម ដើម្បីរៀបចំដំណើរកម្សាន្ត ឬអញ្ជើញមនុស្សពីខាងក្រៅមកកាន់សាលារបស់អ្នក? តើអ្នកទទួលបានការអនុញ្ញាតឱ្យដឹកជញ្ជូនសិស្សតាមយានជំនិះផ្ទាល់ខ្លួនរបស់អ្នកដែរឬទេ?
- ***ការអនុញ្ញាតពីមាតាបិតា៖*** តើអ្នកត្រូវជូនដំណឹងដល់មាតាបិតា ឬស្នើសុំការយល់ព្រមជាលាយលក្ខណ៍អក្សរជាផ្លូវការពីពួកគាត់ មុនពេលអ្នកចាប់ផ្តើមសកម្មភាពមួយចំនួនមែនដែរឬទេ?

## ការពិចារណាអំពីសមិទ្ធលទ្ធភាពនៃសកម្មភាពការងារ

នៅក្នុងតារាងមួយដែលស្រដៀងគ្នាជាមួយនឹងតារាង ៤.១ ដែរ ចូររៀបរាប់អំពីតម្រូវការសកម្មភាពអប់រំរបស់អ្នក រួមជាមួយនឹងបញ្ហាប្រឈមផងដែរ។ ប្រសិនបើអ្នកខ្វះខាតធនធានមួយចំនួន ឬប្រសិនបើអ្នកប្រឈមនឹងឧបសគ្គមួយចំនួន សូមសួរខ្លួនឯងថាតើមានជម្រើសណាមួយផ្សេងទៀត ដើម្បីសម្រេចគោលដៅរបស់អ្នកដែរឬទេ ហើយប្រសិនបើមេរៀននេះនៅតែមានប្រសិទ្ធភាព សូមលើកឡើងអំពីជម្រើសទាំងនេះ។ ដំណើរការនេះនឹងជួយអ្នកក្នុងការកំណត់ថាតើវាមានលក្ខណៈសមស្របជាមួយបេតិកភណ្ឌវប្បធម៌អរូបីដែលអ្នកបានជ្រើសរើស ឬប្រសិន បើវាចាំបាច់ក្នុងការជ្រើសរើសបេតិកភណ្ឌវប្បធម៌អរូបីផ្សេងទៀត ដើម្បីអនុវត្តសកម្មភាពរបស់អ្នកដោយជោគជ័យ ឬប្រភេទនៃសកម្មភាពផ្សេងទៀត។

### ស្វែងរកឱកាសទទួលបានជំនួយថវិកា (ប្រទេសចិន)

រដ្ឋាភិបាលសៀងហៃគាំទ្រយ៉ាងសកម្មនូវគំនិតផ្ដួចផ្ដើម ក្នុងការលើកកម្ពស់បេតិកភណ្ឌរស់នៅតាមសាលា។ ការិយាល័យវប្បធម៌ និងអប់រំក្រុង និងការិយាល័យបេតិកភណ្ឌវប្បធម៌អរូបីស្រុក បានផ្ដល់ការណែនាំសម្រាប់បង្កើតកម្មវិធីអប់រំ ដែលលើកកម្ពស់បេតិកភណ្ឌរស់។ សាលាក៏អាចដាក់ពាក្យស្នើសុំមូលនិធិពិសេសសម្រាប់ជំនួយហិរញ្ញវត្ថុប្រចាំឆ្នាំ និងជួលអ្នកអនុវត្តបេតិកភណ្ឌ ដើម្បីបង្រៀនក្នុងវគ្គសិក្សាមួយចំនួនរបស់ខ្លួនផងដែរ។

### ការរៀបចំបណ្ដាញដើម្បីធានានូវធនធានមិនមែនហិរញ្ញវត្ថុ (ប្រទេសថៃ)

សាលា Ban Ku Ku មានថវិកាតិចតួចបំផុតក្នុងការរៀបចំសកម្មភាពវប្បធម៌សម្រាប់សិស្សរបស់ខ្លួន។ គ្រូបង្រៀនបានបង្កើតបណ្ដាញស្ថាប័នគ្រប់គ្រងក្នុងតំបន់ និងអង្គការផ្សេងទៀតដើម្បីជួយពួកគេក្នុងការខ្ចីឧបករណ៍តន្ត្រី និងសម្ភារៈផ្សេងៗ និងដើម្បីឱ្យសិស្សរបស់ពួកគេចូលរួមក្នុងការប្រារព្ធពិធីវប្បធម៌។

### ចំណុចត្រួតពិនិត្យ

នៅចុងបញ្ចប់នៃជំហានទាំងនេះ អ្នកប្រហែលជាបានកំណត់អំពី៖

- ជ្រើសរើសបេតិកភណ្ឌរស់ដែលអ្នកនឹងធ្វើការ ដោយខ្លួនឯង ឬជាមួយគ្រូផ្សេងទៀត។
- ជ្រើសរើសប្រភេទនៃសកម្មភាព (មុខវិជ្ជា ឬសកម្មភាពកម្មវិធីសិក្សាក្រៅម៉ោង) ដែលអ្នកនឹងភ្ជាប់ជាមួយបេតិកភណ្ឌរស់នោះ។
- ដឹងអំពីលក្ខខណ្ឌតម្រូវ និងបញ្ហាប្រឈមនានាដើម្បីប្រាកដថា អ្នកអាចអនុវត្តសកម្មភាពរបស់អ្នកដោយជោគជ័យ។

## ៤.៣. ជំហានទី ៣ - ស្វែងយល់បន្ថែមអំពីចំណាប់អារម្មណ៍ដែលបានជ្រើសរើស

សម្រាប់មេរៀនដែលបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបី អ្នកនឹងត្រូវប្រមូលធនធានក្រៅពីអ្វីដែលមានរួចហើយនៅក្នុងសាលា និងក្នុងសៀវភៅសិក្សា។




ការប្រមូលព័ត៌មាន អាចធ្វើតាមវិធីសាស្ត្រជាច្រើន។ វិធីសាស្ត្រទូទៅបំផុតគឺជាការស្រាវជ្រាវឯកសារ និងការសម្ភាសន៍ ដែលការសម្ភាសន៍នេះមានសារៈសំខាន់ជាខ្លាំងសម្រាប់ការស្វែងយល់អំពីអត្ថន័យនៃបេតិកភណ្ឌរស់សម្រាប់សហគមន៍។

ក្នុងអំឡុងពេលស្រាវជ្រាវឯកសារ អ្នកប្រមូលព័ត៌មាន ដែលចងក្រងដោយអ្នកដទៃដែលមាននៅក្នុងសៀវភៅ អត្ថបទ និងការចុះផ្សាយផ្សេងទៀត ក៏ដូចជាព័ត៌មានពីសារមន្ទីរ និងបណ្ណសារដ្ឋានក្នុងស្រុក មជ្ឈមណ្ឌលសិក្សាសហគមន៍ និងស្ថាប័នផ្សេងទៀត ឬព័ត៌មានដែលអាចទុកចិត្តបាន ដែលអាចរកបាននៅលើប្រព័ន្ធអ៊ីនធឺណិត។

ក្នុងអំឡុងពេលសម្ភាសន៍ អ្នកត្រូវប្រមូលព័ត៌មានដោយខ្លួនឯង ពីអ្នកដែលមានបទពិសោធន៍ផ្ទាល់អំពីបេតិកភណ្ឌរស់ ដូចជាសិស្ស និងសមាជិកគ្រួសាររបស់ពួកគេ មនុស្សមកពីសហគមន៍ តំណាងសមាគមវប្បធម៌ជាដើម។ ដំណើរការសម្ភាសន៍នេះគឺតម្រូវឱ្យអ្នកចូលរួម រួមចំណែកក្នុងកម្រិតជាច្រើន៖ ការស្តាប់ ការអង្កេត ការបង្ហាញ និងក្នុងករណីខ្លះ ដោយការអនុវត្តបេតិកភណ្ឌរស់នោះ។ អ្នកសម្ភាសន៍សួរសំណួរដើម្បីពង្រឹងការយល់ដឹងរបស់ពួកគេអំពីបេតិកភណ្ឌរស់នោះ និងអ្នកអនុវត្ត។ បើទោះជាការសម្ភាសន៍មនុស្ស ត្រូវចំណាយពេលច្រើនជាងការចុះស្រាវជ្រាវផ្ទាល់ក៏ដោយ ក៏វាអាចជាប្រភពព័ត៌មានដ៏សម្បូរបែបជាងគេផងដែរ។ ការសម្ភាសន៍ជាមួយអ្នកអនុវត្ត ក៏អាចជាសកម្មភាពបង្កើនចំណេះដឹងផងដែរ ជាពិសេសសម្រាប់សិស្សានុសិស្ស។

សៀវភៅណែនាំស្តីពីឧបករណ៍ និងធនធាន (សៀវភៅណែនាំទី ៨) ផ្តល់ដំបូន្មានដ៏មានសារៈ ប្រយោជន៍ អំពីរបៀបធ្វើបទសម្ភាសន៍ប្រកបដោយប្រសិទ្ធភាព និងប្រកបដោយក្រមសីលធម៌។ សៀវភៅនេះក៏ណែនាំអំពីសំណួរដែលអ្នកអាចសួរ ដើម្បីស្វែងយល់បន្ថែមអំពីបេតិកភណ្ឌរស់ និងវិធីកត់ត្រាព័ត៌មានផងដែរ។





ត្រូវចងចាំជានិច្ចថា ការស្រាវជ្រាវ និងការប្រមូលទិន្នន័យនៅក្នុងសហគមន៍អាចមានភាពរសើប ហើយចាំបាច់ត្រូវធ្វើដោយការគោរពបំផុត។ "គោលការណ៍ក្រមសីលធម៌ចំនួន ១២ សម្រាប់កិច្ចការពារបេតិកភណ្ឌវប្បធម៌អរូបី" អាចផ្ដល់ការណែនាំដ៏មានសារៈប្រយោជន៍។ សូមមើល៖ CLICK

អ្នកក៏ប្រហែលជាចង់អនុវត្តតាមគន្លឹះខាងក្រោមផងដែរ៖

- ពិនិត្យគុណភាពព័ត៌មាន៖ តើវិធីសាស្ត្រក្នុងការធ្វើបទបង្ហាញអំពីព័ត៌មានស្ដីពីបេតិកភណ្ឌវប្បធម៌អរូបីនោះ អាចទទួលយកបានដោយសហគមន៍ដែរឬទេ ? តើវាឆ្លុះបញ្ចាំងពីគុណតម្លៃសហគមន៍ដែរឬទេ ?
- ទទួលយកការបកស្រាយផ្សេងៗគ្នា៖ ព័ត៌មានដែលប្រមូលបានពីមនុស្សម្នាក់ ឬពីរបីនាក់ ប្រហែលជាមិនតំណាងឱ្យការអនុវត្ត ឬជំនឿរបស់សហគមន៍ទាំងមូលនោះទេ។
- ជៀសវាងការរើសអើង និងភាពលម្អៀង៖ ត្រូវដឹងថា បុគ្គលដែលអ្នកសម្ភាសន៍អាចមានគំនិតគិតទុកជាមុនពាក់ព័ន្ធនឹងតួនាទីយេនឌ័រ សាសនា ប្រទេសកំណើត ជាតិសាសន៍ ។ល។ ហើយអ្នកក៏អាចមានគំនិតគិតទុកជាមុនបែបនេះផងដែរ។

បេតិកភណ្ឌរស់អាចឆ្លុះបញ្ចាំង នៅគ្រប់គ្រប់ទិដ្ឋភាពនៃការរៀបចំសកម្មភាពទាំងអស់មិនត្រឹមតែនៅក្នុងការបង្រៀនប៉ុណ្ណោះទេ។ ដើម្បីស្វែងយល់បន្ថែមអំពីបេតិកភណ្ឌវប្បធម៌អរូបី ដែលអ្នកបានជ្រើសរើស ថែមទាំងបង្កើតបទពិសោធន៍គួរឱ្យចងចាំ និងទាក់ទាញសម្រាប់សិស្សនោះ អ្នកអាច៖

- រៀបចំផែនការសកម្មភាពដែលអ្នក និងសិស្សរបស់អ្នកត្រូវប្រមូលព័ត៌មានអំពីការអនុវត្តដែលបានជ្រើសរើស។ ឧទាហរណ៍ ការសម្ភាសន៍ជាមួយសមាជិកគ្រួសារ និងសហគមន៍ និងការវិភាគភាពយន្តឯកសារ ភាពយន្តព័ត៌មានអនឡាញ និងអត្ថបទនានា ។ល។
- រៀបចំដំណើរទស្សនកិច្ចសម្រាប់សិស្សានុសិស្សទៅកាន់សមាជិកសហគមន៍ និងអ្នកអនុវត្តនៅតាមផ្ទះ និងរោងជាងរបស់ពួកគាត់ ឬអញ្ជើញពួកគាត់ឱ្យណែនាំអំពីបេតិកភណ្ឌវប្បធម៌អរូបីរបស់ពួកគាត់ដល់សិស្សដោយផ្ទាល់នៅក្នុងសាលា។ ហើយក៏ស្នើសុំឱ្យពួកគាត់ផ្ដល់មតិកែលម្អផងដែរអំពីព័ត៌មាន ដែលអ្នកប្រមូលពីពួកគាត់ផងដែរ។
- រៀបចំផែនការដំណើរកម្សាន្ត និងដំណើរទៅកាន់ស្ថាប័នវប្បធម៌ សមាគមវិជ្ជាជីវៈ។ល។ ដើម្បីប្រមូលព័ត៌មានអំពីការអនុវត្ត និង/ឬអំពីការអភិរក្សបេតិកភណ្ឌរស់នោះ។

ប្រសិនបើអ្នកសហការជាមួយគ្រូផ្សេងទៀត ត្រូវបែងចែកកិច្ចការ និងសិក្សាអំពីបេតិកភណ្ឌវប្បធម៌អរូបីតាមទស្សនៈជាច្រើន។ ជាឧទាហរណ៍ គ្រូរូបវិទ្យាអាចស្រាវជ្រាវពីមុខវិជ្ជាវិទ្យាសាស្ត្រអំពីធាតុផ្សំនោះ ចំណែកគ្រូបង្រៀនមុខវិជ្ជាមនុស្សសាស្ត្រអាចស្វែងរកព័ត៌មានទាក់ទងនឹងទិដ្ឋភាពប្រវត្តិសាស្ត្រ និងសង្គម ឧទាហរណ៍ តួនាទីយេនឌ័រជាក់លាក់ទាក់ទងនឹងការអនុវត្តជាដើម។ ការងារជាក្រុមបែបនេះជួយបង្កើនការយល់ដឹងកាន់តែស៊ីជម្រៅអំពីធាតុផ្សំបេតិកភណ្ឌ និងអាចឈានទៅដល់ការអភិវឌ្ឍសកម្មភាពសិក្សាបន្ថែមលើមុខវិជ្ជាផ្សេងៗ។

## ការស្រាវជ្រាវឯកសារ (សាធារណរដ្ឋកូរ៉េ)




សាលាសាកល្បងក្នុងប្រទេសកូរ៉េបានរៀបចំមេរៀនអំពី *Yeondeunghoe* (ពិធីបុណ្យបង្ហោះគោម) ក៏ដូចជាអំពី *kimjang* ការធ្វើ និងចែករំលែក *គីមឈី*និងអំពី *Namsadang Nori*ដែលជាសិល្បៈទស្សនីយភាពប្រជាប្រិយចម្រុះ។ បេតិកភណ្ឌវប្បធម៌អរូបីទាំងបីនេះត្រូវបានចុះក្នុងបញ្ជី បេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ។ បេតិកភណ្ឌវប្បធម៌អរូបីនេះត្រូវបានស្រាវជ្រាវ និងចងក្រងទុកបានយ៉ាងល្អដោយស្ថាប័នវប្បធម៌ និងអ្នកសិក្សា។ ដូច្នេះ គ្រូអាចស្វែងរកព័ត៌មាន និងឯកសារសោតទស្សន៍ ដើម្បីជួយពួកគេរៀបចំ និងធ្វើមេរៀនរបស់ពួកគេ។ ចំណុចនេះមានសារៈសំខាន់ជាពិសេសក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ-១៩ នៅពេលដែលគ្រូមិនអាចជួបជាមួយអ្នកអនុវត្តបានយ៉ាងងាយស្រួលនោះ។

## គ្រូបង្រៀនធ្វើការស្រាវជ្រាវតាមសហគមន៍ (ប្រទេសវៀតណាម)

ក្នុងដំណាក់កាលនៃការរៀបចំមេរៀនរបស់ខ្លួន គ្រូបង្រៀនជនជាតិវៀតណាមមួយក្រុម រួមជាមួយនឹងអ្នកជំនាញមកពីសារមន្ទីរជាតិពន្ធវិទ្យាវៀតណាម បានចុះទៅកាន់សហគមន៍មួយចំនួន ដើម្បីប្រមូលព័ត៌មានអំពីបេតិកភណ្ឌរស់ក្នុងស្រុក។ ពួកគេបានសម្ភាសន៍អ្នកអនុវត្តអំពីការងាររបស់ពួកគេ ហើយបានថតរូបភាព និងថតវីដេអូទុក។ នេះបានធ្វើឱ្យចំណេះដឹង និងការយល់ដឹងរបស់ពួកគេកាន់តែមានភាពស៊ីជម្រៅអំពីការអនុវត្តក្នុងតំបន់ ហើយវាអនុញ្ញាតឱ្យពួកគេកំណត់គោលគំនិតសម្រាប់មេរៀន និងជ្រើសរើសព័ត៌មានដែលពាក់ព័ន្ធបំផុត ដើម្បីចែករំលែកជាមួយសិស្សរបស់ពួកគេ។ ឯកសារសោតទស្សន៍ដែលពួកគេបានរៀបចំ ក្រោយមកបានប្រែក្លាយទៅជាភាពយន្តខ្លីៗដែលអាចដាក់បញ្ចាំងនៅក្នុងថ្នាក់រៀន។





### សិស្សសម្ភាសន៍សមាជិកគ្រួសារ ឬសហគមន៍ (ប្រទេសថៃ)

គ្រូបង្រៀនមកពីសាលាមួយក្នុងប្រទេសថៃ ដោយមានការគាំទ្រពីសហគមន៍ បានរៀបចំការស្ទង់មតិផ្ទាល់សម្រាប់សិស្សានុសិស្ស ដើម្បីឱ្យសិស្សអាចស្វែងយល់បន្ថែមអំពី talaew របាំងការពារធ្វើពីឫស្សី។ សិស្សបានចុះតាមផ្ទះ និងសួរសំណួរអំពីអត្ថន័យ គុណតម្លៃ មុខងារ សម្ភារៈ និងការធ្វើ *talaew*។ ពួកគេបានសរសេរកំណត់សម្គាល់ ហើយបានថតរូបភាព និងវីដេអូដើម្បីកត់ត្រាជាព័ត៌មានទុក។ ពួកគេក៏បានរៀនបង្កើត *talaew* ហើយម្នាក់ៗយកមកផ្ទះមួយទុកជាអនុស្សាវរីយ៍។ លំហាត់ការងារចុះផ្ទាល់មានលក្ខណៈសាមញ្ញ ប៉ុន្តែមានប្រសិទ្ធភាព ដែលនាំឱ្យមានការទទួលបានព័ត៌មានគ្រប់គ្រាន់ សម្រាប់គ្រូក្នុងការបង្កើតមេរៀនដែលផ្សារភ្ជាប់ជាមួយនឹង *talaew* នៅក្នុងមុខវិជ្ជាសិក្សាចំនួនប្រាំបី។

### ចំណុចគ្រួតពិនិត្យ

នៅចុងបញ្ចប់នៃជំហាននេះ អ្នកប្រហែលជាបាន៖

- ចងក្រងព័ត៌មាន និងឯកសារសោតទស្សន៍អំពីបេតិកភណ្ឌរស់ដែលបានជ្រើសរើស






## ៤.៤. ជំហានទី ៤ - រៀបចំកិច្ចតែងការបង្រៀនរបស់អ្នក ហើយបង្រៀនដោយប្រើប្រាស់បេតិកភណ្ឌវប្បធម៌អរូបី

នៅពេលរៀបចំកិច្ចតែងការបង្រៀន សូមចងចាំថា៖

- កិច្ចតែងការបង្រៀនអាចបង្កើតឡើងសម្រាប់សកម្មភាពមេរៀនស្របតាមកម្មវិធីសិក្សា និងសកម្មភាពក្រៅកម្មវិធីសិក្សា។
- ប្រើប្រាស់ទម្រង់កិច្ចតែងការបង្រៀនស្តង់ដាររបស់អ្នក។ បន្ទាប់មកភ្ជាប់ខ្លឹមសារមេរៀនទៅនឹងបេតិកភណ្ឌរស់។
- មិនមែនគោលបំណងសិក្សាទាំងអស់ទេ សកម្មភាព គរុកោសល្យ និងសម្ភារៈចាំបាច់ត្រូវសំដៅទៅលើបេតិកភណ្ឌរស់។

> “មេរៀនគឺមានភាពសប្បាយរីករាយ ពីព្រោះយើងមិនចាំបាច់កត់ចំណាំអ្វីទាំងអស់។ យើងគ្រាន់តែអនុវត្តតាមអ្នកសម្របសម្រួលរបស់យើង ដែលប្រសព្វនិយាយបែបកំប្លែង។
>
> *– សិស្សមកពីគម្រោងសាកល្បងប្រទេសថៃ*”

### កំណត់គោលដៅមេរៀន និងគោលបំណងសិក្សា

**គោលដៅ៖** គោលដៅសិក្សា ច្រើនតែជាប្រយោគដែលបញ្ជាក់អំពីទិសដៅរួមរបស់មេរៀន។

**គោលបំណង៖** គោលបំណងសិក្សារៀបរាប់អំពីអ្វីដែលសិស្សត្រូវដឹង ឬអាចធ្វើបាននៅពេលបញ្ចប់ មេរៀន។

> “បើកចិត្តឱ្យទូលាយ ហើយពិសោធន៍ជាមួយវិធីសាស្ត្របង្រៀនចម្រុះ ដូច្នេះអ្នកអាចរៀនរួមគ្នាជាមួយសិស្សរបស់អ្នក។
>
> *– លោកស្រី Orawan Kanthanon គ្រូបង្រៀនសាលា Mai Ai Wittayakom ប្រទេសថៃ*”

មេរៀនរបស់អ្នកប្រហែលជាមានគោលដៅ និងគោលបំណងសិក្សារួចហើយ។ នៅក្នុងមេរៀនពាក់ព័ន្ធនឹងបេតិកភណ្ឌរស់ អ្នកប្រហែលជាចង់កែសម្រួលគោលដៅ និងគោលបំណងដើម្បីរំលេចអំពីរបៀប ដែលបេតិកភណ្ឌវប្បធម៌អរូបីជួយសម្រេចឱ្យបាន និងនាំមកនូវតម្លៃបន្ថែមដល់សកម្មភាពរបស់អ្នក។

អ្នកក៏ប្រហែលជាចង់បន្ថែមគោលបំណងសិក្សាមួយទៀត ដើម្បីវាស់ស្ទង់អំពីវិសាលភាពដែលក្នុងនោះមេរៀននេះជួយលើកកម្ពស់ការយល់ដឹងអំពីបេតិកភណ្ឌរស់ និងការអភិរក្សបេតិកភណ្ឌ។



## គោលដៅមេរៀនសម្រាប់មេរៀនអំពីការអប់រំសុខភាព និងការអប់រំកាយ (ប្រទេសនេប៉ាល់)

មេរៀនស្តីពីការអប់រំសុខភាព និងការអប់រំកាយនេះផ្តោតទៅលើពិធីចូលឆ្នាំថ្មីពិសេសមួយនៅក្នុងសហគមន៍ Newa ក្នុងប្រទេសនេប៉ាល់ ដែលក្នុងនោះ *mandala* ត្រូវបានបង្កើតឡើងសម្រាប់មនុស្សម្នាក់ៗ។ សិស្សបានចាត់ថ្នាក់ប្រភេទអាហារផ្សេងៗគ្នា ដែលផ្តល់ជូនក្នុងអំឡុងពេលពិធីបុណ្យ Puja និងពិភាក្សាអំពីរបបអាហារដែលមានតុល្យភាព។ ដើម្បីបង្កើត *mandala* សិស្សម្នាក់ៗបានរៀបចំក្រដាសស្អិនស៊ីល និងស្វែងយល់អំពីគំនូររាងធរណីមាត្រ និងគំនូរតាមខ្នាត។ គ្រូបានបង្ហាញគោលដៅដូចជា៖ "រៀនអំពីរបបអាហារមានតុល្យភាពនៅក្នុងវប្បធម៌ចម្រុះដែលបំផុសគំនិតដោយការបង្កើត *mandala* នៅក្នុង Mha Puja"។ "ការសិក្សាអំពីរបបអាហារដែលមានតុល្យភាពនៅក្នុងវប្បធម៌ចម្រុះ" ត្រូវបានភ្ជាប់ដោយផ្ទាល់ទៅនឹងគោលបំណងកម្មវិធីសិក្សាមួយ "ត្រូវបានបំផុសគំនិតដោយការបង្កើត mandala ធ្វើនៅ Mha Puja" ភ្ជាប់មេរៀនទៅនឹងពិធី Newa។

## គោលបំណងសិក្សាសម្រាប់មេរៀនរូបវិទ្យាស្តីពីសូរសព្ទតន្ត្រី (ប្រទេសវៀតណាម)

គោលបំណងនៃការសិក្សាអំពីសូរសព្ទតន្ត្រី ជាញឹកញាប់ត្រូវបានរកឃើញនៅក្នុងកម្មវិធីរូបវិទ្យា។ គ្រូបង្រៀនម្នាក់បានដាក់បញ្ចូលតន្ត្រីបុរាណទៅក្នុងមេរៀនរូបវិទ្យារបស់គាត់ដោយកំណត់គោលបំណងដូចខាងក្រោម៖ "ដើម្បីចង់ស្វែងយល់ពីភាពខុសប្លែកគ្នានៃសំឡេងខ្ពស់ និងសំឡេងជ្រៅដោយប្រើឧបករណ៍តន្ត្រី Ca Trù" ។ គោលបំណងនេះសង្កត់ធ្ងន់ទៅលើចំណុចមួយថា ការទទួលបានជំនាញនេះ នឹងកើតឡើងដោយសារឧបករណ៍ភ្លេងក្នុងស្រុក។ វាបង្ហាញពីទំនាក់ទំនងរវាងមេរៀន និងបេតិកភណ្ឌរស់។

## គោលបំណងសិក្សាសម្រាប់មេរៀនអក្សរសិល្ប៍ដែលភ្ជាប់ទៅនឹងសិល្បៈនៃពង្សាវិទ្យា (ប្រទេសកាហ្សាក់ស្ថាន)






គោលបំណងនៃការសិក្សាសម្រាប់មេរៀនស្តីពីវាក្យសព្ទទំនាក់ទំនងញាតិសន្តានរបស់ប្រជាជនកាហ្សាក់ស្ថាន ត្រូវបានកំណត់ដូចខាងក្រោម៖

***វិជ្ជាសម្បទា***

- កំណត់ការបង្កើតក្រមវប្បធម៌ និងហៀនរបស់ប្រជាជនកាហ្សាក់ស្ថានតាមរយៈឧទាហរណ៍នៃពង្សាវតារគ្រួសាររបស់ពួកគេ (*shezhire*)
- រៀនពាក្យ និងវាក្យសព្ទថ្មីៗ ពង្រីកវាក្យសព្ទ

***បំណិនសម្បទា***

- អនុវត្តជំនាញស្រាវជ្រាវ និងធ្វើបទបង្ហាញ

***ចរិយាសម្បទា***

- បង្កើតសុភនិច្ឆ័យពីភាពជាសមាជិករបស់សហគមន៍មួយ តាមរយៈចំណេះដឹងអំពីប្រវត្តិ និងពង្សាវិទ្យារបស់ពួកគេ
- ពង្រឹងទំនាក់ទំនងអន្តរជំនាន់

នៅក្នុងមេរៀននេះ គោលបំណងទីមួយសំដៅដោយផ្ទាល់លើការអនុវត្ត *shezhire* ក្នុងការស្គាល់បុព្វបុរសរបស់ខ្លួនជាងប្រាំពីរជំនាន់។

គោលបំណងទីពីរ និងទីបី លើការប្រមូលវាក្យសព្ទ និងជំនាញស្រាវជ្រាវ និងការធ្វើបទបង្ហាញ ជាទូទៅមាននៅក្នុងមេរៀនភាសា។ នេះបង្ហាញឱ្យឃើញថា មិនមែនគោលបំណងសិក្សាទាំងអស់ត្រូវសំដៅលើបេតិកភណ្ឌនោះទេ។

គោលបំណងពីរចុងក្រោយស្តីពីការផ្សារភ្ជាប់គ្នារវាងជំនាន់ និងការអភិវឌ្ឍសុភនិច្ឆ័យនៃភាពជាសមាជិកក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងអាកប្បកិរិយារបស់សិស្សចំពោះបេតិកភណ្ឌរស់របស់ពួកគេ។

**កូនសៀវភៅ 8**

សៀវភៅណែនាំទី ៨រួមមានឧទាហរណ៍អំពីកិច្ចតែងការបង្រៀន ដែលរៀបចំគោលបំណងសិក្សាទៅជា៖ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ប៉ុន្តែមានវិធីជាច្រើនទៀតក្នុងការរៀបចំគោលបំណងសិក្សា។ អ្នកអាចប្រើទម្រង់កិច្ចតែងការបង្រៀនស្តង់ដារ ដែលបានប្រើនៅក្នុងសាលារបស់អ្នក។

**កូនសៀវភៅ 3**

ប្រសិនបើសាលារបស់អ្នកបានប្រើប្រាស់កម្មវិធីដូចជា GCED, ESD, SEL ឬ MTBE នោះ គោលបំណងសិក្សាក៏អាចឆ្លុះបញ្ចាំងពីគុណតម្លៃទាំងនេះផងដែរ។ សូមមើលសៀវភៅណែនាំទី ៣ អំពីរបៀបភ្ជាប់កម្មវិធីទាំងនេះជាមួយបេតិកភណ្ឌរស់។

## ជ្រើសរើសវិធី តើខ្លឹមសារណាខ្លះស្តីពីបេតិកភណ្ឌរស់ ដែលមេរៀនរបស់អ្នកគួរដាក់បញ្ចូល

ការបង្រៀនជាមួយបេតិកភណ្ឌរស់មិនមែនមានន័យថាអ្នកនឹងនិយាយអំពីវប្បធម៌ក្នុងអំឡុងពេលបង្រៀនទាំងមូលនោះទេ។ អាស្រ័យលើប្រធានបទនៃមេរៀន ខ្លឹមសារដែលទាក់ទងនឹងបេតិកភណ្ឌរស់អាចជាផ្នែកតូចមួយ ឬជាធាតុផ្សំសំខាន់នៃមេរៀន។

វិធីផ្សេងៗនៃការដាក់បញ្ចូលបេតិកភណ្ឌរស់ទៅក្នុងមេរៀន៖

- បេតិកភណ្ឌវប្បធម៌អរូបីអាចនឹងត្រូវលើកឡើង នៅពេលចាប់ផ្តើមសកម្មភាព ដើម្បីផ្តល់នូវ បរិបទមួយចំនួន និងទាក់ទាញការចាប់អារម្មណ៍ពីសិស្ស។
- មេរៀនទាំងមូលអាចតាក់តែងឡើងពាក់ព័ន្ធបេតិកភណ្ឌរស់។
- បេតិកភណ្ឌវប្បធម៌អរូបីអាចជាប្រធានបទសង្ខេប ក្នុងចំណោមមេរៀនជាច្រើនដើម្បីស្វែងយល់ពីទិដ្ឋភាព និងទស្សនៈផ្សេងៗ។
- បេតិកភណ្ឌវប្បធម៌អរូបី អាចជួយដល់ការសិក្សា ដោយមិនចាំបាច់ភ្ជាប់ទៅខ្លឹមសារនៃមេរៀន ដោយប្រើវាជាឧបករណ៍គរុកោសល្យ។ ឧទាហរណ៍ បច្ចេកទេសសិប្បកម្មក្នុងស្រុកអាចដាក់បញ្ចូលទៅក្នុងសកម្មភាពដែលយើងអាចមើលឃើញ និងរាយការណ៍បាន។ តន្ត្រី និងចង្វាក់អាចប្រើប្រាស់ ដើម្បីជួយទន្ទេញឱ្យចាំមាត់អំពីហេតុការណ៍ តួលេខ និងរូបមន្ត។





### បេតិកភណ្ឌរស់ជាការណែនាំសម្រាប់មេរៀនសិក្សាសង្គម ( ប្រទេសប្រ៊ុយណេដារ៉ូសាឡឹម )

នៅដើមមេរៀនសិក្សាសង្គមស្តីពីតន្ត្រីដំពេញនិយម សិស្សបានមើលឃ្លីបនៃតន្ត្រី *Keroncong* ឥណ្ឌូនេស៊ីឆ្នាំ១៩២០។ គ្រូបានប្រើតន្ត្រីប្រពៃណីឥណ្ឌូនេស៊ីនេះជាការណែនាំ។ បន្ទាប់មក ថ្នាក់រៀនបានពិភាក្សាអំពីរបៀបដែលឧស្សាហកម្មតន្ត្រីនិងជាពិសេសកម្មវិធីប្រកួតប្រជែងជ្រើសរើសអ្នកដែលគេស្រឡាញ់តាមស្ថានីយទូរទស្សន៍នៅអាស៊ីអាគ្នេយ៍ មានឥទ្ធិពលចម្រុះក្នុងស្រុក និងពិភពលោក។

### បេតិកភណ្ឌរស់ជាផ្នែកសំខាន់នៃមេរៀនរូបវិទ្យា ( ប្រទេសវៀតណាម )

សិស្សបានរៀនអំពីគងក្នុងស្រុក និងអត្ថន័យរបស់វាសម្រាប់សហគមន៍មូលដ្ឋាន។ បន្ទាប់មក ពួកគេបានប្រើប្រាស់គងទាំងនេះ ដើម្បីស្វែងយល់ពីលំយោលក្នុងថ្នាក់រូបវិទ្យា។ ឧបករណ៍នេះត្រូវបានប្រើប្រាស់ក្នុងមេរៀនភាគច្រើន ដើម្បីធ្វើជាការពិសោធន៍។



### បេតិកភណ្ឌរស់ជាជំនួយគរុកោសល្យ (ប្រទេសឡាវ)

គ្រូបង្រៀនគណិតវិទ្យាម្នាក់បានប្រើបទភ្លេងដ៏ល្បីក្នុងស្រុក ដើម្បីជួយសិស្សរបស់គាត់រៀនរូបមន្តគណិតវិទ្យា។ គំរូនៃការច្រៀងបានជួយឱ្យសិស្សចងចាំនូវលំដាប់លំដោយនៃព័ត៌មាន។

## ជ្រើសរើសវិធីសាស្ត្របង្រៀន/រៀន

ការដាក់បញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងកម្មវិធីសិក្សា គឺមិនត្រឹមតែដើម្បីផ្ទេរចំណេះដឹងនិងការអភិរក្សបេតិកភណ្ឌរស់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យមេរៀនកាន់តែមានភាពសប្បាយរីករាយ និងគួរឱ្យចាប់អារម្មណ៍ថែមទៀតផង។ គរុកោសល្យសកម្មជារឿយៗដំណើរការបានល្អនៅក្នុងមេរៀនដែលបំផុសគំនិតដោយបេតិកភណ្ឌវប្បធម៌អរូបី ព្រោះវាផ្តល់កន្លែងបន្ថែមទៀតសម្រាប់ការស្វែងយល់ និងការផ្លាស់ប្តូរជាក់ស្តែង។

តើសកម្មភាពប្រភេទណាខ្លះដែលអ្នកអាចប្រើដើម្បីសម្រេចគោលបំណងសិក្សា? ជម្រើសមានច្រើន ហើយរួមមាន៖ ការងារជាក្រុម និងកិច្ចការផ្ទះ ការពិភាក្សា និងការជជែកដេញដោល ការលេងហ្គេម ការសម្តែងតួ ការបង្រៀនលក្ខណៈបុគ្គល និងការធ្វើបាឋកថាខ្លីៗ ការធ្វើបទបង្ហាញក្នុងថ្នាក់ ឯកសារសោតទស្សន៍ សកម្មភាព និងការពិសោធន៍ផ្ទាល់។

សកម្មភាពតាក់តែងដែលដាក់បញ្ចូលការអនុវត្តដែលបានជ្រើសរើសតាមរបៀប ដែលសម្របទៅនឹងប្រធានបទ និងវិធីសាស្ត្ររបស់អ្នក។ អ្នកដឹងច្បាស់នូវអ្វីដែលនឹងទាក់ទាញសិស្សរបស់អ្នក និងសមស្របនឹងទស្សនៈរបស់សាលាអ្នក។



### *សកម្មភាពក្នុងថ្នាក់៖*

- សកម្មភាព និងការពិសោធន៍ដោយផ្ទាល់ ដើម្បីអនុវត្តបេតិកភណ្ឌរស់។
- សកម្មភាពទំនាក់ទំនង៖ ការងារជាក្រុម ការសម្តែងតួ ការធ្វើត្រាប់តាម ការដើរក្នុងវិចិត្រសាល ការធ្វើបទបង្ហាញ។

### *សកម្មភាពក្រៅថ្នាក់៖*

- គម្រោងស្រាវជ្រាវ
- ដំណើរកម្សាន្តទៅកាន់សារមន្ទីរក្នុងស្រុក និងរោងជាងរបស់សិប្បករ។

### *អ្នកជំនាញខាងក្រៅ និងសមាជិកសហគមន៍៖*

- មនុស្សទាំងនេះអាចចូលរួមក្នុងថ្នាក់ ឬក្រៅថ្នាក់ ដើម្បីធ្វើបទបង្ហាញ និង/ឬបង្រៀនអំពីបេតិកភណ្ឌរស់។

បេតិកភណ្ឌរស់ផ្ទេរពីមួយជំនាន់ទៅមួយជំនាន់ ដែលមានន័យថាការអនុវត្តនេះត្រូវបានបង្រៀនជាផ្លូវការ និង/ឬ ក្រៅផ្លូវការ ហើយអ្នកមានចំណេះដឹងតែងតែប្រើវិធីសាស្ត្រគរុកោសល្យដែលប្រកបដោយអព្ភន្តរញ្ញាណ និងការបំផុសគំនិត ដូចជាការនិទានរឿង ការសិក្សាដោយការអនុវត្ត ការហ្វឹកហាត់ (កូនជាង) ជាដើម។ អ្នកប្រហែលជាចង់ដាក់បញ្ចូលវិធីសាស្ត្របែបនេះ ទៅក្នុងថ្នាក់ផ្ទាល់ខ្លួនរបស់អ្នក។

## ការសម្តែងតួជាវិធីសាស្ត្របង្រៀន (ប្រទេសប៉ាគីស្ថាន)

ការនិទានរឿង និងការច្រៀងគឺជាទម្រង់ប្រពៃណីតាមការចងចាំដ៏ពេញនិយម នៅក្នុងប្រទេសប៉ាគីស្ថាន។ នៅពេលបង្រៀនសិស្សរបស់នាងសូត្រកំណាព្យ Urdu បុរាណ *Rawalpindi Se Ayi Khyber Rail* គ្រូបង្រៀនអក្សរសិល្ប៍បានប្រើវិធីសាស្ត្រគរុកោសល្យដោយការសម្តែងតួ។ ដំបូង សិស្សអានអត្ថបទកំណាព្យខណៈពេលកំពុងស្តាប់ការចាក់កាសែត។ Khyber Rail គឺជាខ្សែផ្លូវរថភ្លើងនៅក្នុងប្រទេសប៉ាគីស្ថាន ដូច្នេះគ្រូបង្រៀនបានសុំឱ្យសិស្សដាក់កៅអីជាជួរ ហើយអង្គុយហាក់ដូចជាពួកគេនៅក្នុងរថភ្លើងអញ្ចឹង។ បន្ទាប់មកសិស្សបានប្រើឧបករណ៍ដើម្បីបង្ហាញពីសកម្មភាពផ្សេងៗដែលត្រូវបាននិទាននៅក្នុងកំណាព្យ។ ដំណើរការនេះបានជួយពួកគេស្រមៃមើលលំហូរនៃសាច់រឿង និងទន្ទេញចាំមាត់នូវជើងកាព្យ។




## សកម្មភាពផ្ទាល់ជាវិធីសាស្ត្រនៃការបង្រៀន (ប្រទេសនេប៉ាល់)

នៅអនុវិទ្យាល័យ Mangal គ្រូបង្រៀនគណិតវិទ្យាម្នាក់បានចងក្រងឯកសារ *Janku* ដែលជាប្រពៃណីនៃការប្រារព្ធខួបលើកទី ៧៧ ខែ ៧ ថ្ងៃ ៧ និង ម៉ោង ៧ នៃជីវិតរបស់នរណាម្នាក់។ ក្នុងអំឡុងពេលនៃការប្រារព្ធពិធី *Janku* សមាជិកក្រុមគ្រួសារមកជុំគ្នាដើម្បីសម្តែងការគោរពដល់ចាស់ទុំ។ គ្រូបង្រៀនរូបនេះបានភ្ជាប់ប្រពៃណីនេះទៅនឹងមេរៀនគណិតវិទ្យារបស់គាត់អំពីសំណុំ (ការប្រមូលធាតុផ្សំ និងទំនាក់ទំនងរបស់ពួកគេ)។ សិស្សបានបង្កើតការប្រារព្ធពិធី *Janku* ឡើងវិញ ដោយពួកគេពីរនាក់ដើរតួជាចាស់ទុំ។ នេះបានផ្តល់មូលដ្ឋានសម្រាប់កំណត់សំណុំ (ក្រុម)នៃសមាជិកគ្រួសារ និងការកំណត់ពីទំនាក់ទំនងគ្រួសារដើម្បីស្វែងយល់អំពីសញ្ញាណដូចជាសំណុំត្រួតស៊ីគ្នាជាដើម។

## ការងារជាក្រុម និងការដើរតាមវិចិត្រសាលជាវិធីសាស្ត្រនៃការបង្រៀន (ប្រទេសឥណ្ឌូនេស៊ី)

ដើម្បីបង្កើនជំនាញទំនាក់ទំនងភាសាអង់គ្លេសរបស់ខ្លួន សិស្សបានស្វែងយល់ និងកត់ត្រាជាឯកសារអំពីរបៀបរៀបចំឱសថធម្មជាតិ និងគ្រឿងសម្អាងដោយប្រើរុក្ខជាតិ។ សិស្សបានកំណត់អត្តសញ្ញាណរុក្ខជាតិដែលកំពុងដាំដុះនៅក្នុងសាលារបស់ពួកគេ និងនៅក្បែរនោះ ដោយមានជំនួយពីកម្មវិធីមួយ។ លក្ខណៈជាក្រុម ពួកគេបានស្រាវជ្រាវពីលក្ខណសម្បត្តិរបស់រុក្ខជាតិ ហើយបន្ទាប់មកស្រមៃគិតដល់ផលិតផលមួយ ហើយបង្កើតវាឡើង។ បន្ទាប់មក ពួកគេបានបង្កើតជាផ្ទាំងរូបភាព និងរៀបចំការដើរមើល ដើម្បីចែករំលែកព័ត៌មានជាមួយមិត្តរួមថ្នាក់របស់ខ្លួន។ ដំណើរការនេះបានលើកទឹកចិត្តសិស្សឱ្យយល់ដឹងអំពីប្រាជ្ញារបស់ចាស់ទុំ និងពិនិត្យមើលអ្វីៗពីទស្សនៈអេកូឡូស៊ី និងសេដ្ឋកិច្ច ទន្ទឹមនឹងនោះក៏អភិវឌ្ឍជំនាញក្នុងការនិយាយ និងសរសេរ ក៏ដូចជាជំនាញរបស់ពួកគេក្នុងការសហការ និងការដោះស្រាយបញ្ហាផងដែរ។

## បញ្ចូលចំណេះដឹងថ្មីៗតាមរយៈការលេងហ្គេម (ប្រទេសគៀជីស្ថាន)

ក្នុងអំឡុងពេលរៀនមេរៀនអំពីសិល្បៈនៃការនិទានរឿង និងអំពី *Manas* (ជាកំណាព្យវីរភាពបែបប្រពៃណីរបស់ប្រទេសគៀជីស្ថាន) សិស្សបានធ្វើការជាក្រុមដើម្បីប្រមូលព័ត៌មានអំពីអ្នកនិទានរឿងល្បីៗ ហើយបន្ទាប់មកបង្ហាញលទ្ធផលរកឃើញរបស់ពួកគេដល់សិស្សក្នុងថ្នាក់រៀន។ បន្ទាប់មក សិស្សបានលេងហ្គេមមួយដែលមានឈ្មោះថា "Trojan Horse" ដែលក្នុងនោះសិស្សបានកាន់ដៃគ្នាបង្កើតជារាងរង្វង់។ សិស្សបីនាក់នៅក្នុងរង្វង់។ សិស្សមកពីក្នុងរង្វង់បានសួរសំណួរទាក់ទងនឹងប្រធានបទនៃមេរៀន។ សិស្សដែលឆ្លើយបានត្រឹមត្រូវ នៅក្នុងរង្វង់បន្ត។ សិស្សដែលផ្តល់ចម្លើយមិនត្រឹមត្រូវ បានផ្លាស់ប្តូរកន្លែងរបស់ខ្លួនជាមួយនឹងអ្នកដែលបានសួរសំណួរ។ ល្បែងនេះអនុញ្ញាតឱ្យសិស្សពិនិត្យមើលព័ត៌មានមេរៀន និងប្រមូលចំណេះដឹងរបស់ពួកគេតាមរបៀបគួរឱ្យសប្បាយរីករាយ។

ដំណើរទៅកាន់តំបន់បេតិកភណ្ឌ ឬសំណង់បុរាណដ៏ល្បីល្បាញ ជារឿយៗជាបទពិសោធន៍ដ៏គួរឱ្យរំភើប និងរីករាយសម្រាប់សិស្ស ក្នុងពេលកំពុងសិក្សា។ ក្នុងអំឡុងពេលនៃដំណើរកម្សាន្តនេះ លើកទឹកចិត្តសិស្សឱ្យស្វែងរកកន្លែង និងប្រមូលព័ត៌មាន ក៏ដូចជាដើម្បីពិចារណាពីបេតិកភណ្ឌវប្បធម៌នៃកន្លែងនោះ ក្រៅពីលក្ខណៈរូបី និងលក្ខណៈដែលអាចមើលឃើញ។

ដំណើរទៅកាន់តំបន់បេតិកភណ្ឌ ឬសំណង់បុរាណដ៏ល្បីល្បាញ ជារឿយៗជាបទពិសោធន៍ដ៏គួរឱ្យរំភើប និងរីករាយសម្រាប់សិស្ស ក្នុងពេលកំពុងសិក្សា។ ក្នុងអំឡុងពេលនៃដំណើរកម្សាន្តនេះ លើកទឹកចិត្តសិស្សឱ្យស្វែងរកកន្លែង និងប្រមូលព័ត៌មាន ក៏ដូចជាដើម្បីឆ្លុះបញ្ចាំងពីបេតិកភណ្ឌវប្បធម៌នៃកន្លែងនោះ ក្រៅពីលក្ខណៈរូបី និងលក្ខណៈដែលអាចមើលឃើញ។

### ជ្រើសរើស និងបង្កើតសម្ភារៈគរុកោសល្យ

ក្រៅពីការប្រើសៀវភៅសិក្សា គ្រូក៏អាចបង្កើតសម្ភារៈផ្សេងៗទៀត សម្រាប់មេរៀនរបស់ពួកគេផងដែរ។ គ្រូបង្រៀនត្រូវការធនធាន ដែលដឹងព័ត៌មានច្រើនដែលជួយសិស្សឱ្យស្វែងយល់ និងក្រេបជញ្ជក់នូវចំណេះដឹងបានកាន់តែងាយស្រួល និងជួយសិស្សឱ្យវាយតម្លៃការអនុវត្តបេតិកភណ្ឌរស់ ដោយមិនចាំបាច់ធ្វើការលម្អិតខ្លាំងពេក។ បេតិកភណ្ឌរស់ផ្តល់នូវប្រភពដ៏សម្បូរបែបនៃការបំផុសគំនិត ហើយជាញឹកញាប់មានព័ត៌មានជាច្រើនដើម្បីគាំទ្របេតិកភណ្ឌរស់ទាំងនេះរួមមានដូចខាងក្រោម៖

- ឯកសារសោតទស្សន៍ (ឧ. រូបថត រូបភាពវីដេអូ ភាពយន្តឯកសារ គំនូរស្តីពីបេតិកភណ្ឌវប្បធម៌អរូបី ឬការអនុវត្ត) រឿង (ឧ. ការសម្ភាសន៍ជាមួយសមាជិកគ្រួសារ ឬសហគមន៍) ។ល។
- កម្មវិធីអនឡាញទាំងនេះអាចធ្វើឱ្យបទបង្ហាញមានភាពរស់រវើក និងអាចប្រើជាប្រភពក្នុងអំឡុងពេលធ្វើសកម្មភាព។
- វត្ថុ និងឧបករណ៍ទាក់ទងនឹងការអនុវត្ត អាចធ្វើការអង្កេត រៀបចំ និងផលិតឡើងវិញក្នុងអំឡុងពេលរៀនមេរៀន។
- សៀវភៅ និងឯកសារផ្សេងៗ ដែលផ្តល់នូវឯកសារស៊ីជម្រៅបន្ថែមសម្រាប់ការស្រាវជ្រាវ និងកិច្ចការ។
- ឯកសារចែកជូន ទាំងនេះអាចធ្វើការបំផុសគំនិតដោយបេតិកភណ្ឌវប្បធម៌អរូបី ដែលបានជ្រើសរើស និងផ្លាស់ប្តូរតាមបំណងសម្រាប់ថ្នាក់ និងក្រុមសិស្សជាក់លាក់។



### ពីវត្ថុទៅជាឯកសារសោតទស្សន៍៖ ឯកសារ និងវិធីសាស្ត្រដែលអាចប្រើក្នុងការបង្រៀន (ប្រទេសកាហ្សាក់ស្ថាន)

នៅក្នុងថ្នាក់ភាសា និងប្រវត្តិសាស្ត្រ សិស្សបានវិភាគ និងប្រៀបធៀបឧបករណ៍ភ្លេងពីរ គឺ៖ Uyghur *Dutar* និង Kazakh *Dombra*។ ពួកគេបានមើលវីដេអូអំពីឧបករណ៍នោះ ដើម្បីស្វែងយល់អំពីតួនាទីរបស់វានៅក្នុងវប្បធម៌រៀងៗខ្លួន ហើយប្រៀបធៀបដំណើរការដែលឧបករណ៍នោះត្រូវបានបង្កើតឡើង។ សំខាន់ជាងនេះទៅទៀត សិស្សបានចូលរួមក្នុងការធ្វើបទបង្ហាញដោយគ្រូភ្លេង និងប្រើឧបករណ៍ទាំងនេះដើម្បីស្គាល់ពីសំឡេងរបស់វា។ ការប្រើប្រាស់វត្ថុទាំងនេះបង្កើតចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងចំណោមសិស្ស។

> “ខ្ញុំគិតថា ឧបករណ៍បុរាណគួរឱ្យធុញទ្រាន់ ប៉ុន្តែផ្ទុយទៅវិញ វាមិនដូច្នោះឡើយ។”
>
> *– សិស្សថ្នាក់ទី ១ នៃសាលា - កន្លែងកាយសម្ព័ន្ធនៅសាលា លេខ ១៥៣ ដាក់ឈ្មោះតាម Abdulla Rozybakiev*





## ឯកសារចែកជូនដែលប្រើក្នុងមេរៀន ( កម្ពុជា )

ឯកសារចែកជូនដែលបង្កើតឡើងដោយគ្រូបង្រៀនអំពីការតម្បាញបានសង្ខេបពីដំណាក់កាលសំខាន់ៗនៃដំណើរការត្បាញកន្ទេល ហើយបានស្នើរឱ្យមានសកម្មភាពសម្រាប់សិស្សអនុវត្តដោយខ្លួន ឯង។ មានការគាំទ្រដោយឯកសារលម្អិត ដែលសិប្បករពន្យល់ពីដំណើរការ និងតម្លៃនៃការងាររបស់ពួកគេ។

## រៀនបច្ចេកទេសប្រពៃណីក្នុងរោងជាងនៅសាលា ( ប្រទេសម៉ុងហ្គោលី )៖

វគ្គបច្ចេកវិទ្យាកែច្នៃឈើជាកាតព្វកិច្ចនៅក្នុងសាលា Khan-Uul Complex អនុញ្ញាតឱ្យសិស្សស្វែងយល់ពីវិធីសាស្ត្រ និងបច្ចេកទេសដែលសិប្បករបុរាណប្រើប្រាស់។ គ្រូបង្ហាញវីដេអូ និងការបង្កើតដោយសិប្បករ។ សិស្សពិភាក្សានិងពិសោធន៍យ៉ាងសកម្មជាមួយក្រដាស mâché ហត្ថកម្មស្បែក សិល្បៈធ្វើពីឈើ សិល្បៈធ្វើពីលីណូលូម និងការឆ្លាក់។ វគ្គនេះមានគោលបំណងផលិតបំណែកពិតៗ ហើយការចូលរួមនៅក្នុងវគ្គសិក្សានេះផ្តល់ឱ្យសិស្សនូវអារម្មណ៍ជាទីពេញចិត្ត និងមានការចូលរួមយ៉ាងច្រើនកុះករ។

រូបថត និងរូបភាពវីដេអូពីបេតិកភណ្ឌវប្បធម៌អរូបី ដែលបានលើកឡើង មាននៅក្នុងអនុសញ្ញាឆ្នាំ២០០៣ អាចទាញយកបានពីគេហទំព័ររបស់អង្គការយូណេស្កូ៖ Click





## ជ្រើសរើសកន្លែងដែលអ្នកនឹងរៀបចំមេរៀនរបស់អ្នក

ការបង្រៀនភាគច្រើនធ្វើឡើងនៅក្នុងថ្នាក់រៀន ព្រោះជាទីកន្លែងដែលមានសុវត្ថិភាព និងមានការរៀបចំទុកជាស្រេច។ នៅទីនោះ អ្នកអាចនាំយកឧបករណ៍ផ្សេងៗពីការអនុវត្តបេតិកភណ្ឌវប្បធម៌អរូបីដើម្បីបង្កើនការចូលរួម។ សិស្សអាចមានវគ្គអន្តរកម្ម ការពិសោធន៍ និងការធ្វើបទបង្ហាញនៅក្នុងថ្នាក់រៀន។ ទោះជាយ៉ាងណា ទីធ្លាក្នុងថ្នាក់រៀនអាចកម្រិតដល់ការបម្លាស់ទី  ហើយក្រៅពីនេះ ការសិក្សាមិនចាំបាច់ធ្វើឡើងតែនៅក្នុងថ្នាក់រៀននោះទេ។ ប្រសិនបើការពិចារណាផ្នែកភស្តុភារ និងវិធានសុវត្ថិភាព នោះបរិវេណសាលា និងតំបន់ជុំវិញក៏អាចប្រើប្រាស់ជាបរិយាកាសសិក្សាបានដែរ។ អ្នកក៏អាចរៀបចំគម្រោងស្រាវជ្រាវ និង/ឬ ដំណើរកម្សាន្តទៅកាន់ទីកន្លែងដែល ICH នេះត្រូវបានអនុវត្ត និងបង្កើនការយល់ដឹងកាន់តែស៊ីជម្រៅអំពីមេរៀន។ នេះអនុញ្ញាតឱ្យសិស្សទទួលបានបទពិសោធន៍ពីបេតិកភណ្ឌវប្បធម៌អរូបីកាន់តែពេញលេញ ជាមួយនឹងសុភនិច្ឆ័យត្រឹមត្រូវរបស់ពួកគេ។ ដូចគ្នានេះដែរ ទីធ្លាសាលាអាចប្រើប្រាស់ជាទីកន្លែងសិក្សាសម្រាប់ការលេងល្បែងប្រជាប្រិយ និងកីឡា ឬកន្លែងទាំងនេះអាចធ្វើឡើងនៅខាងក្រៅសាលាក៏បាន។ ការសិក្សានៅក្រៅថ្នាក់រៀនជារឿយៗតម្រូវឱ្យមានការរៀបចំផែនការ និងការរៀបចំបន្ថែមមួយចំនួនទៀត ព្រោះថាទីធ្លានោះលែងជាបរិយាកាសគ្រប់គ្រងបានទៀតហើយ ប៉ុន្តែបរិយាកាសខាងក្រៅអាចកែលម្អលទ្ធផលសិក្សាបាន។

### ការសិក្សានៅក្នុងសារមន្ទីរបេតិកភណ្ឌវប្បធម៌អរូបីរបស់សាលា (ប្រទេសគៀជីស្ថាន)

មជ្ឈមណ្ឌលអប់រំ "Ilim" ដែលជាសាលា UNESCO ASPnet បានបង្កើត "សារមន្ទីរបេតិកភណ្ឌវប្បធម៌អរូបី" នៅក្នុងបរិវេណសាលា ដោយដាក់តាំងនូវវត្ថុដែលត្រូវបានបរិច្ចាគដោយមាតាបិតា និងសមាជិកសហគមន៍។ សកម្មភាពទាក់ទងនឹងមុខវិជ្ជា ដូចជា ភាសា ប្រវត្តិសាស្ត្រ តន្ត្រី និងមេរៀនវិទ្យាសាស្ត្រសង្គម ត្រូវបានរៀបចំនៅក្នុងទីធ្លានេះ។ សិស្សានុសិស្សបានបញ្ចេញមតិថា ពួកគេអាច "ស្វែងយល់ពីបេតិកភណ្ឌវប្បធម៌អរូបី" បានកាន់តែប្រសើរឡើង ដោយសារបរិយាកាសនៅក្នុងសារមន្ទីរ។ សូមអានករណីសិក្សាសម្រាប់ព័ត៌មានបន្ថែមអំពីសកម្មភាពនេះ។

## អនុវត្តការបង្រៀន និងការសិក្សាជាមួយបេតិកភណ្ឌរស់

បន្ទាប់ពីការងារត្រៀមរៀបចំរួចហើយ បន្ទាប់មកដល់ពេលត្រូវអនុវត្តសកម្មភាពជាមួយសិស្សសហការី និងសមាជិកសហគមន៍ និងដៃគូដែលបានកំណត់។

សូមចងចាំថា ការពិភាក្សា ការងារជាក្រុម និង/ឬកិច្ចការលក្ខណៈបុគ្គលនៅក្នុងមេរៀនបែបនេះ ទំនងជាលើកទឹកចិត្តសិស្សឱ្យបង្ហាញការអនុវត្តរបស់ពួកគេ និងបង្ហាញពីគំនិត និងទស្សនៈរបស់ពួកគេ។ សូម្បីតែនៅពេលដែលពួកគេទាំងអស់គ្នាស៊ាំជាមួយបេតិកភណ្ឌវប្បធម៌អរូបី ដែលត្រូវបានប្រើប្រាស់ក្នុងមេរៀនក៏ដោយ ក៏បទពិសោធន៍ ចំណេះដឹង និងជំនឿរបស់សិស្សអាចប្រែប្រួលដែរ ហើយភាពចម្រុះគ្នានេះនឹងបង្កើនដំណើរការសិក្សា។ ក្នុងអំឡុងពេលរៀនមេរៀនបែបនេះ សិស្សអាចចែករំលែកបទពិសោធន៍របស់ពួកគេ សូម្បីតែក្រៅពីអ្វីដែលបានគិតស្រមៃនៅក្នុងកិច្ចតែងការបង្រៀនក៏ដោយ។ នេះអាចបង្កើតវគ្គមេរៀនដែលមានភាពទាក់ទាញខ្លាំង។

ទោះយ៉ាងណា ក្នុងពេលជាមួយគ្នានេះ សិស្ស និងអ្នកអនុវត្តមួយចំនួនអាចមានអារម្មណ៍មិនស្រណុកក្នុងចិត្តឡើយ ឬថែមទាំងស្ទាក់ស្ទើរ ក្នុងការចូលរួមក្នុងសកម្មភាព ដែលភ្ជាប់ទៅនឹងបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងសាលាទៀតផង។ នេះក៏ព្រោះតែបេតិកភណ្ឌរស់មួយចំនួនត្រូវបានអនុវត្តតាមប្រពៃណីដោយក្រុមណាមួយក្នុងសហគមន៍តែប៉ុណ្ណោះ។ ក្រុមទាំងនេះច្រើនតែកំណត់ដោយអាយុ ភេទ មុខងារសង្គម។ល។ ក្នុងករណីនេះត្រូវបញ្ជាក់ប្រាប់ដល់ថ្នាក់រៀនថា ការអនុវត្តបេតិកភណ្ឌវប្បធម៌អរូបីអាចវិវត្តតាមពេលវេលា។ គ្រូបង្រៀនក៏គួរលើកទឹកចិត្តឱ្យមានការពិភាក្សាអំពីគោលគំនិតអំពីសមភាព ការរើសអើង និងភាពលម្អៀងផងដែរ ( ឧទាហរណ៍ ភាពលម្អៀងយេនឌ័រ ) ជាដើម។ គ្រប់ករណីទាំងអស់ មេរៀនត្រូវបញ្ជាក់ពីតម្រូវការក្នុងការគោរព និងវាយតម្លៃពីជំនឿ និងបទពិសោធន៍របស់អ្នកដទៃ។

### ចំណុចមួយចំនួនដែលត្រូវចងចាំនៅពេលអ្នកអនុវត្តសកម្មភាពរបស់អ្នក៖

- អនុញ្ញាតឱ្យសិស្សបង្ហាញពីគំនិតរបស់ពួកគេ និងចែករំលែកបទពិសោធន៍របស់ពួកគេ។
- មានភាពបត់បែន៖ សកម្មភាពជាក្រុមអាចនាំទៅរកការផ្លាស់ប្តូរដ៏សម្បូរបែប ដែលអាចលើសពីអ្វីដែលអ្នកបានគិតស្រមៃនៅក្នុងកិច្ចតែងការបង្រៀន។
- ត្រូវប្រាកដថា អ្នកចូលរួមទាំងអស់បង្ហាញការគោរព និងការអត់ឱនចំពោះមតិយោបល់របស់អ្នកដទៃ។



### ការអបអរសាទរដល់ភាពចម្រុះរបស់សិស្សជាមួយនឹងបទចម្រៀងប្រជាប្រិយ ( ប្រទេសនេប៉ាល់ )

នៅក្នុងថ្នាក់សិក្សាសង្គម គ្រូបង្រៀន Prakash Dhakal បានបង្ហាញបទចម្រៀងប្រជាប្រិយពីសហគមន៍Tamang ក្នុងពិធីបុណ្យចូលឆ្នាំថ្មីគឺបទ៖ Sonam Lhosar ។ បទចម្រៀងនេះគឺជាឧទាហរណ៍ដ៏សំខាន់នៅក្នុងមេរៀន ប៉ុន្តែវាបានបង្កើតឱកាសសម្រាប់ថ្នាក់រៀនដើម្បីសិក្សាពីប្រភេទផ្សេងៗគ្នានៃបទចម្រៀងប្រជាប្រិយពីសហគមន៍ផ្សេងៗគ្នា ដោយការគោរព និងការអបអរសាទរដល់ភាពចម្រុះរបស់សិស្ស។ សិស្សច្រៀងចម្រៀងរួមគ្នា ហើយពិភាក្សាអំពីអត្ថន័យនៃបទចម្រៀងនីមួយៗជាក្រុម និងជាមួយនឹងថ្នាក់រៀនទាំងមូល។

> “បេតិកភណ្ឌវប្បធម៌អរូបីបានក្លាយជាស្ពានរវាងខ្ញុំនិងសិស្សរបស់ខ្ញុំ ហើយបានជួយបង្កើតទំនាក់ទំនង ទោះបីជាពួកយើងជួបគ្នាតែតាមអនឡាញ និងមិនដែលបានជួបគ្នាផ្ទាល់ក៏ដោយ។
>
> *– Madina Nurakhanova សាលាកាយសម្ព័ន្ធលេខ ៨*”



## ចំណុចគ្រូតពិនិត្យ

នៅចុងបញ្ចប់នៃជំហាននេះ អ្នកប្រហែលជាបាន៖

- រៀបចំគោលបំណងសិក្សាសម្រាប់មេរៀនដែលភ្ជាប់ជាមួយបេតិកភណ្ឌរស់។
- បង្កើតបណ្តុំសកម្មភាពដើម្បីធ្វើឱ្យមេរៀនកាន់តែមានការចាប់អារម្មណ៍ និងការចូលរួមសម្រាប់សិស្ស រួមទាំងសកម្មភាពដែលភ្ជាប់ទៅនឹងបេតិកភណ្ឌរស់។
- រៀបចំឯកសារគរុកោសល្យមួយចំនួនដែលជួយដល់ការសិក្សា និងលើកកម្ពស់ការយល់ដឹងអំពីបេតិកភណ្ឌរស់។
- បង្កើតកិច្ចតែងការបង្រៀនដែលអនុញ្ញាតឱ្យសិស្សទាំងអស់ចូលរួមក្នុងថ្នាក់បាន ហើយមានអារម្មណ៍ថា មានទំនាក់ទំនងជាមួយមេរៀននេះ។

## ៤.៥. ជំហានទី ៥ - កត់ត្រាជាឯកសារ និងចែករំលែកបទពិសោធន៍របស់អ្នក

ការបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបីគឺជាវិធីសាស្ត្រថ្មីមួយសម្រាប់គ្រូបង្រៀនជាច្រើន។ ទោះបីជាវាទាមទារការវិនិយោគខ្លះទាក់ទងនឹងពេលវេលាក៏ដោយ ក៏ការចងក្រងឯកសារមេរៀនរបស់អ្នក និងដំណើរការការងារនេះនឹងជួយបង្ហាញអ្នកពីអ្វីដែលអ្នកអាចធ្វើតាមរបៀបផ្សេងបាន និងចំណេញពេលវេលានៅពេលបន្ទាប់ នៅពេលដែលអ្នករៀបចំសកម្មភាព ស្រដៀងគ្នានេះ។

គ្រូបង្រៀនគឺជាប្រភពដ៏ល្អបំផុតនៃការបំផុសគំនិតសម្រាប់គ្រូបង្រៀនដទៃទៀត។ ការចងក្រងឯកសារគ្រប់ដំណាក់កាលនៃបទពិសោធន៍របស់អ្នកអាចផ្តល់នូវធនធានដ៏មានតម្លៃ គឺមិនត្រឹមតែសម្រាប់មេរៀននាពេលអនាគតរបស់អ្នកប៉ុណ្ណោះទេ ប៉ុន្តែក៏អាចជាមូលដ្ឋានសម្រាប់មេរៀនដោយសហការីរបស់អ្នក និងប្រើជាឯកសារយោងសម្រាប់សមាជិកសហគមន៍បានផងដែរ។

> ការធ្វើជាគ្រូបង្រៀនមានន័យថា ស្វែងរកគំនិតថ្មីៗ ព័ត៌មាន និងការបំផុសគំនិតឥតឈប់ឈរ។ ដូច្នេះ កុំបញ្ឈប់ការអភិវឌ្ឍ ខិតខំរៀនអ្វីដែលថ្មីជារៀងរាល់ថ្ងៃ។
>
> *– Bakytbekkyzy Aisezim គ្រូបង្រៀន Kyrgyzstan*

### តើការចងក្រងឯកសារមានសារៈសំខាន់ដូចម្តេច?

- ការលើកទឹកចិត្តដំបូងរបស់អ្នក ហេតុផល និងការរំពឹងទុកអំពីការចូលរួមក្នុងការបង្រៀនជាមួយបេតិកភណ្ឌរស់។
- ជំហានរៀបចំការងារដែលអ្នកបានធ្វើ។
- កិច្ចតែងការបង្រៀន សកម្មភាពបង្រៀន និងសម្ភារៈដែលអ្នកបានរៀបចំ។
- បញ្ហាប្រឈមដែលអ្នកបានជួបប្រទះ និងរបៀបដែលអ្នកបានពុះពារជម្នះ។
- លទ្ធផលនៃសកម្មភាព៖ សម្រាប់សិស្ស សហគមន៍ ជាតុផ្សំបេតិកភណ្ឌរស់ និងខ្លួនអ្នកផ្ទាល់។

### តើអ្នកអាចកត់ត្រាបទពិសោធន៍របស់អ្នកដោយរបៀបណា?

- រក្សាទិនានុប្បវត្តិ៖ សរសេរអ្វីដែលដំណើរការបានល្អឬអត់ និងគំនិតថ្មីៗដើម្បីសាកល្បង
- ធ្វើបញ្ជីសម្រាប់ទំនាក់ទំនង និងសម្ភារៈប្រើប្រាស់នៅពេលរៀបចំ និងពេលបង្រៀន
- ប្រមូលមតិកែលម្អពីសិស្ស សហការី និងសហគមន៍របស់អ្នក
- កត់ត្រាសកម្មភាពរបស់អ្នកជាមួយរូបថត និងរូបភាពវីដេអូ
- ចូលរួមជាមួយសិស្សរបស់អ្នកក្នុងដំណើរការចងក្រងឯកសារ។ បន្ថែមពីលើតម្លៃគរុកោសល្យនៃដំណើរការកត់ត្រាជាឯកសារ សម្ភារៈទាំងនេះនឹងធ្វើឱ្យមេរៀននាពេលអនាគតមានភាពរស់រវើកឡើងវិញនិងផ្តល់នូវការបង្ហាញពីអត្ថន័យនៃបទពិសោធន៍របស់អ្នកសម្រាប់អ្នកដទៃ។

### គោលការណ៍ណែនាំសម្រាប់ការសរសេរអំពីកិច្ចតែងការបង្រៀន បេតិកភណ្ឌវប្បធម៌អរូបី (ប៉ាឡូ)

សៀវភៅនេះដែលរៀបចំដោយក្រសួងអប់រំប៉ាឡូ លើកទឹកចិត្តគ្រូបង្រៀនឱ្យសរសេរពីចំណាប់អារម្មណ៍របស់ពួកគេ បន្ទាប់ពីមេរៀននីមួយៗត្រូវបានបញ្ចប់ រួមទាំងអ្វីដែលបានធ្វើ អ្វីមិនបានធ្វើ របៀបដែលពួកគេគ្រោងនឹងបន្ត និងអ្វីដែលពួកគេប្រហែលជាត្រូវបង្រៀនឡើងវិញជាដើម។ កំណត់ចំណាំទាំងនេះណែនាំគ្រូបង្រៀនឱ្យកែលម្អកិច្ចតែងការបង្រៀនរបស់ខ្លួន។ សូមមើល៖ CLICK

## ចែករំលែកបទពិសោធន៍របស់អ្នកជាមួយអ្នកដទៃ

បទពិសោធន៍របស់អ្នកមានតម្លៃណាស់ ពីព្រោះវាអាចផ្តល់ឱ្យសហការីរបស់អ្នកនូវការបំផុសគំនិត គំនិតជាក់ស្តែង និងគំរូសម្រាប់មេរៀនផ្ទាល់ខ្លួន។ ជាពិសេស កិច្ចតែងការបង្រៀន និងសម្ភារៈសិក្សារបស់អ្នកគឺជាប្រភពដ៏មានប្រយោជន៍សម្រាប់គ្រូផ្សេងទៀត។ ភាពជោគជ័យរបស់អ្នកនឹងជំរុញ និងលើកទឹកចិត្តអ្នកដទៃ។ ពួកគេអាចរៀនពីការលំបាកដែលអ្នកបានជួបប្រទះ។ ម្យ៉ាងវិញទៀត ពួកគេអាចនឹងផ្ញើនូវមតិកែលម្អ ដែលមានប្រយោជន៍មួយចំនួនដល់អ្នកដើម្បីកែលម្អមេរៀនដែលមានស្រាប់របស់អ្នក ឬជំរុញអ្នកឱ្យបង្កើតមេរៀនថ្មីៗ។

" បទពិសោធន៍របស់អ្នកមានតម្លៃណាស់ ពីព្រោះវាអាចផ្តល់ឱ្យសហការីរបស់អ្នកនូវការបំផុសគំនិត គំនិតជាក់ស្តែង និងគំរូសម្រាប់មេរៀនផ្ទាល់ខ្លួន "

មានវិធីជាច្រើនដែលអ្នកអាចចែករំលែកកិច្ចតែងការបង្រៀន និងសម្ភារៈសិក្សារបស់អ្នក ចាប់ពីឯកសារសាមញ្ញៗដែលរក្សាទុកក្នុងបណ្ណាល័យសាលាទៅជាព្រឹត្តិបត្រព័ត៌មាន និងកន្លែងរក្សាទុកតាមប្រព័ន្ធអ៊ីនធឺណិតដែលគ្រប់គ្រងដោយសាលា ឬដោយក្រសួងអប់រំ។ កិច្ចតែងការបង្រៀនរបស់អ្នកអាចរក្សាទុកនៅក្នុងបណ្ណុំនៃធនធាននៅក្នុងសាលារបស់អ្នក ដែលគ្រូផ្សេងទៀតអាចចូលប្រើប្រាស់បាន ហើយពួកគេអាចផ្លាស់ប្តូរតាមបំណងបាន ដើម្បីបង្កើតសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេ។ ហើយអ្នកក៏អាចផ្លាស់ប្តូរព័ត៌មានតាមរយៈវេទិកាពិភាក្សា និងអំឡុងពេលរៀបចំព្រឹត្តិការណ៍ និងសន្និសីទជាដើម។

អ្នកអាចចែករំលែកបទពិសោធន៍របស់អ្នកជាមួយគ្រូ និងសិស្សផ្សេងទៀតនៅក្នុងសាលារបស់អ្នក ជាមួយសាលាផ្សេងទៀតនៅក្នុងតំបន់ និងប្រទេសរបស់អ្នក






និងជាមួយសាលានានានៅក្រៅប្រទេសរួមទាំងតាមរយៈបណ្ដាញសាលាដែលពាក់ព័ន្ធរបស់អង្គការយូណេស្កូ (ASPnet)។

អ្នកក៏អាចបង្ហាញពីបទពិសោធន៍របស់អ្នកនៅលើ UNESCO Clearinghouse ស្ដីពីបេតិកភណ្ឌរស់ និងការអប់រំបានដែរតាមរយៈ៖ CLICK

### ចែករំលែកកិច្ចតែងការបង្រៀនលើកម្មវិធីរបស់ក្រសួង (ប្រទេសវៀតណាម)

នៅពេលបញ្ចប់គម្រោងសាកល្បងនៅប្រទេសវៀតណាម កិច្ចតែងការបង្រៀនត្រូវបានដាក់ចូលក្នុងគេហទំព័ររបស់ក្រសួងអប់រំ។ កម្មវិធីនេះគឺជាធនធានដ៏ល្បីសម្រាប់គ្រូបង្រៀន។ គ្រូខ្លះក៏ថតមេរៀនរបស់ខ្លួនជាវីដេអូ ហើយបង្ហោះវីដេអូនេះនៅលើប្រព័ន្ធ YouTube។ វិធីនេះ គ្រូផ្សេងទៀតមិនត្រឹមតែអាចចូលប្រើកិច្ចតែងការបង្រៀនតាមរយៈគេហទំព័រក្រសួងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមើលឧទាហរណ៍ជាក់ស្ដែងនៃថ្នាក់រៀនតាមអនឡាញផងដែរ។ មេរៀនគំរូទាំងនេះមានអក្សររត់ពីក្រោមជាភាសាអង់គ្លេស ដូច្នេះវាអាចជំរុញទឹកចិត្តដល់គ្រូបង្រៀននៅក្រៅប្រទេសវៀតណាមផងដែរ។

### ការចងក្រងឯកសារសម្រាប់អភិរក្សបេតិកភណ្ឌរស់

ក្នុងអំឡុងពេលនៃការរៀបចំ និងការបង្រៀនមេរៀនរបស់អ្នក អ្នកប្រហែលជាបាន៖

- ចងក្រងព័ត៌មានអំពីបេតិកភណ្ឌរស់។
- ភ្ជាប់ជាមួយមនុស្សដែលអនុវត្តបេតិកភណ្ឌរស់។
- លើកទឹកចិត្តសិស្សឱ្យធ្វើការពិចារណា និងអនុវត្ត។
- ធ្វើការវាយតម្លៃ ឬកសាងចំណេះដឹងផ្ទាល់ខ្លួនរបស់អ្នកអំពីបេតិកភណ្ឌរស់។

នេះបង្កើតបានជាធនធានដ៏សម្បូរបែប ដែលរួមចំណែកដល់ការលើកកម្ពស់ការយល់ដឹងអំពីបេតិកភណ្ឌរស់ និងចំពោះការផ្ទេរចំណេះដឹងអំពីបេតិកភណ្ឌរស់។

សូមចងចាំថា បេតិកភណ្ឌរស់បានវិវឌ្ឍឥតឈប់ឈរ ហើយថាសម្ភារៈដែលអ្នកប្រមូលបានឆ្លុះបញ្ចាំងពីការអនុវត្តវប្បធម៌នៅចំណុចជាក់លាក់ណាមួយក្នុងពេលនោះ។ ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការត្រួតពិនិត្យ និងបំពេញបន្ថែមដល់ធនធានរបស់អ្នក មុនពេលអ្នកប្រើប្រាស់វាជាថ្មី។ ប៉ុន្តែបន្ទាប់ពីមួយរយៈមក ឯកសាររបស់អ្នកអាចក្លាយជាកំណត់ត្រានៃអតីតកាល និងជាប្រភពនៃព័ត៌មានដែលបង្ហាញពីការផ្លាស់ប្ដូរចំពោះបេតិកភណ្ឌរស់តាមពេលវេលា។

## ចែករំលែកស្នាដៃរបស់អ្នកដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ និងដៃគូ




ការសិក្សាបេតិកភណ្ឌវប្បធម៌អរូបី ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍និងដៃគូផ្សេងទៀតដើម្បីស្វែងរកចំណេះដឹងរបស់ខ្លួន និងបង្កើតបទពិសោធន៍សិក្សាដ៏គួរឱ្យរំភើបជាមួយគ្នា។ ការចែករំលែកវឌ្ឍនភាពរបស់អ្នក ក៏ដូចជាការងារសិស្ស និងលទ្ធផលសិក្សាជាមួយពួកគេក៏ជាផ្នែកសំខាន់នៃដំណើរការនេះផងដែរ។ ដោយមើលឃើញនូវអ្វីដែលអ្នក និងថ្នាក់រៀនរបស់អ្នកបានរៀបចំ សមាជិកសហគមន៍នឹងដឹងច្បាស់ថា ការរួមចំណែករបស់ពួកគេពិតជាមានតម្លៃ។ ហើយសិស្សនឹងមានមោទនភាពក្នុងការបង្ហាញពីស្នាដៃរបស់ពួកគេ។

ឧទាហរណ៍ កម្មវិធី ឬការតាំងពិពណ៌ដែលរៀបចំដោយសាលា គឺជាឱកាសមួយដើម្បីភ្ជាប់ទំនាក់ទំនង និងទទួលស្គាល់ពីការរួមចំណែករបស់សហគមន៍។ ព្រឹត្តិការណ៍បែបនេះបានបង្ហាញពីតម្លៃនៃការអនុវត្តបេតិកភណ្ឌរស់ និងរួមចំណែកដល់កិច្ចការពារ។ ព្រឹត្តិការណ៍នេះក៏អបអរដល់ការសិក្សា និងការខិតខំប្រឹងប្រែងរបស់សិស្សផងដែរ។ ព្រឹត្តិការណ៍បែបនេះក៏អាចជាឱកាសសម្រាប់សមាជិកសហគមន៍ក្នុងការបង្ហាញពីស្នាដៃរបស់ពួកគេផងដែរ។

### ចែករំលែកជាមួយអ្នកណា និងចែករំលែកដោយរបៀបណា៖



- ចែករំលែកជាមួយសហការីនៅសាលារបស់អ្នក។
- ចែករំលែកជាមួយសាលាផ្សេងទៀត។
- ចែករំលែកជាមួយដៃគូក្នុងសហគមន៍មូលដ្ឋាន និងក្រៅពីនេះ។
- ចែករំលែកបទពិសោធន៍តាមរយៈការធ្វើបទបង្ហាញ។
- ចែករំលែកកិច្ចតែងការបង្រៀន និងសម្ភារៈឧបទេសតាមបណ្ដាញសង្គម កន្លែងរក្សាទុកតាមប្រព័ន្ធអ៊ីនធឺណិត និងបណ្ណាល័យសាលា។
- ចែករំលែកកិច្ចការរបស់សិស្ស និងការរួមចំណែករបស់សហគមន៍តាមរយៈការតាំងពិពណ៌
- ចែករំលែកតាមរយៈបណ្ដាញជាតិ និងអន្តរជាតិ។

### កំណត់ចំណាំស្ដីពីការចែករំលែកឯកសារសោតទស្សន៍

អ្នកត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីសិស្ស សមាជិកសហគមន៍ ឬអ្នកផ្សេងទៀត នៅពេលអ្នកថតរូប និងចែករំលែករូបថត ឬរូបភាពវីដេអូដែលបង្ហាញពីពួកគេ។

ចំពោះសិស្សដែលមានអាយុក្រោម១៨ ឆ្នាំ អ្នកនឹងត្រូវការការយល់ព្រមជាលាយលក្ខណ៍អក្សរពីឪពុកម្ដាយរបស់ពួកគេជាមុន។ សូមពិនិត្យមើលគោលការណ៍សាលាលើបញ្ហានេះ ដើម្បីធានាថាអ្នកអនុវត្តបានត្រឹមត្រូវ។



**ចំណុចគ្រួតពិនិត្យ**

នៅចុងបញ្ចប់នៃជំហាននេះ អ្នកប្រហែលជាបាន៖

- ចងក្រងឯកសារ និងពិចារណាពីដំណើរការតាក់តែងមេរៀន និងសកម្មភាព ដែលអាចណែនាំសកម្មភាពសាលានាពេលអនាគតដែលភ្ជាប់ជាមួយបេតិកភណ្ឌរស់ ដោយអ្នក និងគ្រូបង្រៀនដទៃទៀត។
- កំណត់ពីបណ្តាញដើម្បីចែករំលែកបទពិសោធន៍នេះ។

## ៤.៦. ជំហានទី ៦ - វាយតម្លៃលទ្ធផល

បន្ទាប់ពីបានបញ្ចប់មេរៀន វាជាការសំខាន់ក្នុងការវាយតម្លៃពីលទ្ធផល ដើម្បីវាស់វែងអត្ថប្រយោជន៍សម្រាប់សិស្ស គ្រូ និងសាលា។ ការវាយតម្លៃនេះអាចធ្វើឡើងនៅចុងបញ្ចប់នៃសកម្មភាព ឬអំឡុងពេលដំណើរការបង្រៀន និងការរៀន។ វាអាចអនុវត្តបានដោយខ្លួនឯង ឬដោយមានជំនួយពីសិស្ស និងសហការីរបស់អ្នក ឧទាហរណ៍ ដោយទទួលបានមតិកែលម្អពីគ្រូផ្សេងទៀតលើមេរៀនជាដើម។

គោលបំណងគឺដើម្បីវាយតម្លៃលើកម្រិត៖

- គោលដៅសិក្សាដែលត្រូវសម្រេចឱ្យបាន។ នេះអាចរួមបញ្ចូលការវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្សជាដើម។ សិស្សក៏អាចវាយពីតម្លៃពីខ្លួនឯង ឬមិត្តភក្តិរបស់ពួកគេផងដែរ។
- មេរៀនគឺទាក់ទងនឹងមុខវិជ្ជា និងកម្មវិធីសិក្សា។
- មេរៀននាំមកនូវអត្ថប្រយោជន៍ដល់អ្នកចូលរួមទាំងអស់ (រួមទាំងអ្នកជំនាញពីខាងក្រៅ)។
- សកម្មភាពមានឥទ្ធិពលវិជ្ជមានលើបេតិកភណ្ឌរស់។
- សកម្មភាពបានរួមចំណែកដល់ការជំរុញភាពជាពលរដ្ឋសាកល និងគោលដៅផ្សេងទៀត ដូចជា ESD, SEL និង MTBE។



## ការវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្ស

សំណួរដែលត្រូវសួរគឺ៖ តើសិស្សបានឈានដល់គោលដៅសិក្សាហើយឬនៅ?

មេរៀនដែលមានខ្លឹមសារអំពីបេតិកភណ្ឌវប្បធម៌អរូបី រួមចំណែកដល់ការលើកកម្ពស់ការយល់ដឹង និងការអភិរក្សបេតិកភណ្ឌរស់។ អ្នកប្រហែលជាបានកំណត់គោលដៅសិក្សាដែលទាក់ទងនឹងការយល់ដឹងនេះ។ ការវាយតម្លៃមេរៀនដែលភ្ជាប់ទៅនឹងបេតិកភណ្ឌរស់អាចអនុវត្តតាមទម្រង់ដូចគ្នានេះ និងវិធីសាស្ត្រវាយតម្លៃសង្ខេប ដែលត្រូវបានប្រើសម្រាប់មេរៀនផ្សេងទៀតនៅក្នុងបរិបទសិក្សារបស់អ្នក ហើយដែលសមស្របសម្រាប់តម្រូវការកម្មវិធីសិក្សា។

សំណួរដែលអ្នកអាចសួរដើម្បីវាយតម្លៃការសិក្សាអំពីបេតិកភណ្ឌរស់ រួមមាន ដូចខាងក្រោម៖

- តើសិស្សបានយល់ពីព័ត៌មានដែលបង្ហាញអំពីបេតិកភណ្ឌវប្បធម៌អរូបី ក្នុងអំឡុងពេលធ្វើសកម្មភាពដែរឬទេ?
- តាមរយៈសកម្មភាពនេះ តើសិស្សបានយល់ដឹងកាន់តែច្រើនអំពីបេតិកភណ្ឌរស់នេះ ឬអំពីបេតិកភណ្ឌវប្បធម៌អរូបីជាទូទៅដែរឬទេ ហើយហេតុអ្វីត្រូវអភិរក្ស?
- តើវិធីដែលបេតិកភណ្ឌវប្បធម៌អរូបីត្រូវបានបង្ហាញ និងប្រើប្រាស់ក្នុងអំឡុងពេលសកម្មភាពសាលា គោរពតម្លៃសហគមន៍ និងឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការអនុវត្តដែរឬទេ?
- តើសកម្មភាពនេះបានជំរុញសិស្សឱ្យអនុវត្ត និងចូលរួមក្នុងការផ្ទេរជាតុផ្សំបេតិកភណ្ឌរស់នេះដែរឬទេ?

អ្នកអាចសុំឱ្យសិស្សវាយតម្លៃកិច្ចការរបស់ពួកគេផ្ទាល់ខ្លួន ឬវាយតម្លៃកិច្ចការមិត្តភក្តិរបស់ពួកគេ ឬអ្នកអាចវាយតម្លៃលទ្ធផលនៃការសិក្សាដោយខ្លួនឯងបាន។ មានឧបករណ៍ជាច្រើនដែលអាចជួយអ្នកក្នុងការវាយតម្លៃការយល់ដឹងរបស់សិស្សអំពីបេតិកភណ្ឌរស់បាន។

“គម្រោងនៃការដាក់បញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងការអប់រំគឺមានសារៈសំខាន់ និងផ្តល់ផលិតភាពសម្រាប់ការអប់រំរបស់សិស្ស ក៏ដូចជាសម្រាប់ការលូតលាស់ផ្ទាល់ខ្លួនរបស់ខ្ញុំក្នុងនាមជាគ្រូបង្រៀនផងដែរ។

*– Dilbar Aitakhunova សាលា - កន្លែងកាយសម្ព័ន្ធនៅសាលាលេខ ១៥៣ ដាក់ឈ្មោះតាម Abdulla Rozybakiev កាហ្សាក់ស្ថាន*”

“សិស្សបានចូលរួមយ៉ាងពេញលេញនៅគ្រប់វគ្គសិក្សា ដែលជួយពួកគេឱ្យយល់អំពី Gaijatra ។ នេះជាវិធីរៀនដោយការអនុវត្ត។ សូម្បីតែសិស្សមកពីថ្នាក់ផ្សេងក៏ស្នើសុំឱ្យអនុវត្តវគ្គនេះនៅក្នុងថ្នាក់រៀនរបស់ពួកគេផងដែរ។ សូម្បីជាគ្រូបង្រៀន យើងក៏អាចរៀនអំពីបេតិកភណ្ឌវប្បធម៌អរូបី និងរបៀបដាក់បញ្ចូលនៅក្នុងមុខវិជ្ជាសិក្សា និងមេរៀនរបស់យើងបានដែរ។ ដូច្នេះ វាពិតជាបានជួយ ទាំងសិស្ស និងគ្រូ។

*– Pabitra Shakya គ្រូបង្រៀន អនុវិទ្យាល័យ Janasewa ប្រទេសនេប៉ាល់*”

ឈ្មោះ ____________________ កាលបរិច្ឆេទ __________

# ទម្រង់ KNOW-WANT-LEARN (KWL)

| K អ្វីដែលខ្ញុំ បានដឹង អំពី ICH នេះ | W អ្វីដែលខ្ញុំ ចង់ដឹង អំពី ICH នេះ | L អ្វីដែលខ្ញុំ បានរៀន អំពី ICH នេះ |
| --- | --- | --- |
| | | |

ឈ្មោះ ____________________ កាលបរិច្ឆេទ __________

# ៣-២-១ ទម្រង់ផ្ទេរចំណេះដឹង

3 ចំណុចថ្មីដែលខ្ញុំបានរៀន អំពី ICH នេះ

2 ហេតុអ្វីបានជាវាសំខាន់សម្រាប់សហគមន៍របស់ខ្ញុំ និងរូបខ្ញុំ

1 វិធីក្នុងការអភិរក្ស ការអនុវត្ត ICH នេះ



## ការវាយតម្លៃអំពីដំណើរការ៖ ពិចារណាលើការបង្រៀនជាមួយបេតិកភណ្ឌរស់

ការលើកកម្ពស់គុណភាពនៃការអប់រំគឺជាដំណើរការមួយ ហើយទាមទារការវិនិយោគទាក់ទងពេលវេលា និងធនធាន។ ខាងក្រោមនេះគឺជាសំណួរមួយចំនួនដែលអ្នកអាចសួរខ្លួនឯង សហការី ឬសិស្សរបស់អ្នកដើម្បីវាយតម្លៃអត្ថប្រយោជន៍នៃការវិនិយោគនេះ (ឧ. ផលប៉ះពាល់នៃដំណើរការនេះ)៖

- តើការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីបន្ថែមតម្លៃទៅលើមេរៀនរបស់អ្នកទេ?
- តើការប្រើប្រាស់បេតិកភណ្ឌវប្បធម៌អរូបីធ្វើឱ្យមេរៀន ឬសកម្មភាពកាន់តែមានការចូលរួម កាន់តែគួរឱ្យចាប់អារម្មណ៍ កាន់តែមានន័យ និង/ឬអាចចូលប្រើបានកាន់តែច្រើនឡើងសម្រាប់សិស្សដែរឬទេ?
- តើវាបង្កើតការផ្លាស់ប្តូរកាន់តែច្រើន និង/ឬទំនាក់ទំនងកាន់តែបើកទូលាយរវាងសិស្ស និងគ្រូដែរឬទេ?
- តើវាពង្រឹង ឬបង្កើនទំនាក់ទំនងវិជ្ជមាន និងការផ្លាស់ប្តូររវាងសិស្សដែរឬទេ?
- តើសិស្សបានចូលរួមយ៉ាងសកម្មក្នុងមេរៀនដែរឬទេ?
- តើខ្លឹមសារមេរៀននៃបេតិកភណ្ឌរស់ និងវិធីសាស្ត្រសិក្សាប្រកបដោយនវានុវត្តន៍បង្កើតឱកាសសម្រាប់អ្នកសិក្សាប្រភេទផ្សេងៗគ្នាដើម្បីចូលរួម និងបញ្ចេញមតិដោយខ្លួនឯងដែរឬទេ?

អ្នកក៏ប្រហែលជាចង់សាកសួរជាមួយសាលារបស់អ្នក និងមនុស្សមកពីសហគមន៍ ហើយវាយតម្លៃផលប៉ះពាល់នៃសកម្មភាពសិក្សា ដោយប្រើសំណួរដូចខាងក្រោម៖

- តើបេតិកភណ្ឌរស់ត្រូវបានបង្ហាញនិងប្រើប្រាស់បានត្រឹមត្រូវ និងដោយការគោរពក្នុងអំឡុងពេលធ្វើសកម្មភាពដែរឬទេ?
- តើមេរៀនណាខ្លះដែលបានរៀន និងទទួលបានជោគជ័យដែរឬទេ?
- តើមានបញ្ហាប្រឈមដែរឬទេ ហើយតើយើងអាចជម្នះវាបានដោយរបៀបណា?
- តើយើងអាចពង្រឹងកិច្ចសហការរវាងសាលា និងសហគមន៍ និងអ្នកអនុវត្តដោយរបៀបណា?
- តើសាលាអាចគាំទ្រដំណើរការសិក្សានេះនៅពេលអនាគតយ៉ាងដូចម្តេច និង/ឬតើត្រូវមានវិធានការអ្វីខ្លះ ដើម្បីលើកកម្ពស់ការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងមេរៀនដែរឬទេ?

នៅក្នុងក្រុមសិក្សាមេរៀន ក្រុមគ្រូបង្រៀនអាចធ្វើការរួមគ្នាដើម្បីរៀបចំផែនការ បង្រៀន អង្កេត កែលម្អ និងពិនិត្យមេរៀន ដើម្បីបង្កើនការសិក្សារបស់សិស្សនៅក្នុងថ្នាក់។

គេហទំព័រអំពីការសិក្សាមេរៀន ដូចជាគេហទំព័រដែលមានលើកឡើងខាងក្រោមអាចផ្តល់ការណែនាំសម្រាប់គ្រូបង្រៀនដើម្បីស្វែងយល់ និងអនុវត្តៈ

- សហព័ន្ធគ្រូបង្រៀនអាមេរិក ឆ្នាំ២០០៤ តើការសិក្សាមេរៀនជាអ្វី? CLICK
- វិទ្យាស្ថានអូស្ត្រាលីសម្រាប់ការបង្រៀននិងភាពជាអ្នកដឹកនាំសាលា (AITSL) "របៀប" ណែនាំអំពីការសិក្សាមេរៀន CLICK
- ការសិក្សាមេរៀនចក្រភពអង់គ្លេស។ ការសិក្សាមេរៀនៈ សៀវភៅណែនាំ (ក៏មានជាភាសាអាល្លឺម៉ង់ និង ភាសាផ្សេងទៀតផងដែរ) CLICK







**ចំណុចត្រួតពិនិត្យ**

នៅចុងបញ្ចប់នៃជំហាននេះ អ្នកប្រហែលជាបានៈ

- កំណត់វិធីសាស្ត្រវាយតម្លៃ និងបានធ្វើការវាយតម្លៃថា តើគោលដៅសិក្សាសម្រេចបានឬនៅ។
- កំណត់វិធីសាស្ត្រវាយតម្លៃ និងបានធ្វើការវាយតម្លៃថា តើសកម្មភាពនេះមានផលជះជាវិជ្ជមានលើបេតិកភណ្ឌរស់ និងការអភិរក្សដែរឬទេ។
- ពិចារណាលើចំណុចខ្លាំងនៃវិធីសាស្ត្រនេះ និងវិធីដើម្បីកែលម្អបន្ថែមទៀត។



## បន្ទាប់មក សូមអនុវត្តវាម្តងទៀត!

កម្មវិធីសិក្សារបស់អ្នកគឺទូលំទូលាយណាស់ ហើយបេតិកភណ្ឌរស់គឺសម្បូរបែបខ្លាំងណាស់។ មានលទ្ធភាពជាច្រើនសម្រាប់ការស្វែងរកការភ្ជាប់ទំនាក់ទំនងរវាងបេតិកភណ្ឌវប្បធម៌អរូបី និងសកម្មភាពនៅសាលារបស់អ្នក។

វាទាមទារភាពក្លាហាននិងពេលវេលាច្រើនដើម្បីសាកល្បងវិធីសាស្ត្របង្រៀន និងការសិក្សាបែបថ្មី និងរៀបចំមេរៀនដំបូង។ ទោះជាយ៉ាងណា ជាធម្មតាការព្យាយាមជាបន្តបន្ទាប់ គឺកាន់តែមានភាពងាយស្រួល។

ពេលក្រោយ អ្នកអាច៖

- ស្វែងយល់ពីបេតិកភណ្ឌវប្បធម៌អរូបីផ្សេងទៀត។
- ចាប់ដៃគូជាមួយគ្រូផ្សេងៗសម្រាប់ការសហការអន្តរកម្មសិក្សាថ្មី។
- សាកល្បងវិធីសាស្ត្រ និងមធ្យោបាយផ្សេងៗ។
- ស្នើគម្រោងថ្មី ឬសកម្មភាពនានាក្រៅកម្មវិធីសិក្សា។

> កុំខ្លាចក្នុងការបើកចិត្តទូលាយ ទទួលយកអ្វីដែលថ្មី។
>
> *– Aizharkyn Kozhomberdieva*
> *គ្រូបង្រៀនសាកល្បង កៀហ្ស៊ីស្ថាន*

**សិស្សរបស់អ្នកក៏ប្រហែលជាមានគំនិតខ្លះៗផងដែរ។ ដូច្នេះ ត្រូវមានគំនិតច្នៃប្រឌិតហើយអនុវត្តវាម្តងទៀត!**

**គន្លឹះ** សំខាន់ៗ

- វិធីសាស្ត្រដែលបានលើកឡើងរៀបរាប់នៅទីនេះ ណែនាំអ្នកក្នុងការរៀបចំកិច្ចតែងការបង្រៀន និងសកម្មភាពដែលភ្ជាប់ទៅនឹងបេតិកភណ្ឌរស់។ ជំហានទាំងប្រាំមួយអនុវត្តតាមវឌ្ឍនកម្មដែលសមហេតុសមផល ប៉ុន្តែអាចផ្លាស់ប្តូរតាមតម្រូវការរបស់អ្នក។
- ចូលរួមជាមួយសិស្សរបស់អ្នក និងសហការជាមួយដៃគូមកពីសាលា និងសហគមន៍មូលដ្ឋាន ដើម្បីសម្រាលបន្ទុកការងាររបស់អ្នក និងពង្រឹងដំណើរការនេះ។
- រៀបចំសកម្មភាពដើម្បីផ្តល់ការអប់រំប្រកបដោយគុណភាព និង ដើម្បីបង្កើនការយល់ដឹង និងចំណេះដឹងអំពីបេតិកភណ្ឌវប្បធម៌អរូបី។
- ការបង្រៀនជាមួយបេតិកភណ្ឌរស់ត្រូវការការចំណាយពេលវេលាខ្លះ។ ត្រូវពិចារណាលើតម្លៃបន្ថែមរបស់វា។









## ការបញ្ចូលបេតិកភណ្ឌរស់
ទៅក្នុងការសិក្សានៅអាស៊ីប៉ាស៊ីហ្វិក
សៀវភៅណែនាំ

កូនសៀវភៅ

5

# តួនាទីរបស់មាតាបិតា
# និង
# សមាជិកសហគមន៍

**សៀវភៅនេះ** មានបំណងជួយគាំទ្រគ្រូបង្រៀន អ្នកគ្រប់គ្រងក្នុងវិស័យអប់រំ និងសហគមន៍ក្នុងការដាក់បញ្ចូលបេតិកភណ្ឌក្នុងស្រុក ទៅក្នុងសកម្មភាពសិក្សា ឲ្យកាន់តែមានភាពប្រទាក់ក្រឡាគ្នា និងមានការចូលរួមកាន់តែច្រើនពីសំណាក់សិស្សានុសិស្ស និងការពារបេតិកភណ្ឌវប្បធម៌។

សៀវភៅនេះ មានកូនសៀវភៅចំនួនប្រាំបួន៖

- កូនសៀវភៅ 1 តើបេតិកភណ្ឌរស់ជាអ្វី ?
- កូនសៀវភៅ 2 ហេតុអ្វីត្រូវបង្រៀនជាមួយបេតិកភណ្ឌរស់ ?
- កូនសៀវភៅ 3 ការរៀបចំឱ្យត្រូវគ្នាជាមួយអាទិភាពអប់រំ
- កូនសៀវភៅ 4 វិធីសាស្ត្រប្រាំមួយជំហានសម្រាប់ជាមគ្គុទេសក៏ដល់គ្រូបង្រៀន
- ▶ **កូនសៀវភៅ 5 តួនាទីរបស់ឪពុកម្ដាយ អាណាព្យាបាល និងសមាជិកសហគមន៍**
- កូនសៀវភៅ 6 តួនាទីរបស់ថ្នាក់គ្រប់គ្រងសាលា
- កូនសៀវភៅ 7 តួនាទីរបស់អ្នករៀបចំគោលនយោបាយ
- កូនសៀវភៅ 8 ឯកសារ និងធនធាន
- កូនសៀវភៅ 9 សាច់រឿងរបស់គ្រូបង្រៀន

កូនសៀវភៅ

5

# តួនាទីរបស់មាតាបិតា និងសមាជិកសហគមន៍

សៀវភៅណែនាំនេះផ្តល់នូវការណែនាំអំពីរបៀបដែលមាតាបិតា និងសមាជិកសហគមន៍អាចធ្វើការជាមួយសាលា គ្រូបង្រៀន និងកូនៗរបស់ពួកគាត់ផ្ទាល់ ដើម្បីគាំទ្រដល់ការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការអប់រំ។

សាលាអាចបង្រៀនអំពី បេតិកភណ្ឌវប្បធម៌អរូបី (ICH) និង ជាមួយ បេតិកភណ្ឌវប្បធម៌អរូបី។ ការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបី (ត្រូវបានគេស្គាល់ថាជាបេតិកភណ្ឌរស់) នៅតាមសាលា ធ្វើឱ្យការសិក្សារបស់សិស្សកាន់តែភ្ជាប់ជាមួយនឹងវប្បធម៌ និងបរិបទក្នុងតំបន់ដ៏វិសេសរបស់ពួកគេ ជួយឱ្យពួកគេមានចំណាប់អារម្មណ៍លើបេតិកភណ្ឌរបស់ខ្លួន និងកែលម្អលទ្ធផលនៃការសិក្សារបស់ពួកគេ។ ដើម្បីស្វែងយល់បន្ថែមអំពីបេតិកភណ្ឌរស់ និងរបៀបដែលការបញ្ចូលវានៅតាមសាលា អាចជួយអភិរក្សបេតិកភណ្ឌរបស់សហគមន៍ និងលើកកម្ពស់គុណភាពនៃការអប់រំ សូមមើលសៀវភៅណែនាំទី ១ និងសៀវភៅណែនាំទី ២ នៃសៀវភៅនេះ។



**សម្រាប់ទិដ្ឋភាពទូទៅ** ទាក់ទងគោលគំនិតនៃការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការអប់រំក្នុងប្រព័ន្ធ សូមទស្សនាស៊េរីគំនូរជីវចលតាមរយៈ៖ Click

ស៊េរីគំនូរជីវចលត្រូវបានបង្កើតឡើងសម្រាប់គ្រូបង្រៀន មាតាបិតា និងសមាជិកសហគមន៍ អ្នកគ្រប់គ្រងការអប់រំ និងសិស្សានុសិស្ស។



### របៀបដែលអ្នកអាចសហការជាមួយសាលា និងគ្រូ

ក្នុងនាមជាសមាជិកសហគមន៍ អ្នកដឹងថា អ្វីជាបេតិកភណ្ឌរស់របស់អ្នក និងហេតុអ្វីបានជាវាសំខាន់។ តាមរយៈការចែករំលែកចំណេះដឹង និងព័ត៌មាននេះ អ្នកនិងសមាជិកសហគមន៍ផ្សេងទៀតអាចចូលរួមចំណែកយ៉ាងធំធេងក្នុងការអភិរក្ស និងការផ្ទេរបេតិកភណ្ឌរស់របស់អ្នកទៅមនុស្សជំនាន់ក្រោយ។

វិធីមួយចំនួនដែលអ្នកអាចជួយដល់សាលានិងគ្រូបង្រៀនក្នុងការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការអប់រំ រួមមាន៖

- ចែករំលែកព័ត៌មាន
- ចែករំលែកឯកសារ និងវត្ថុដែលមានស្រាប់
- រៀបចំ ឬចាត់ចែងដំណើរកម្សាន្តរបស់សិស្ស
- សហការជាមួយគ្រូដើម្បីរៀបចំមេរៀន
- មកបង្រៀនមួយថ្ងៃ
- ដាក់ស្នើគម្រោង
- ណែនាំអ្នកជំនាញ និងអង្គការនានា

> គ្រប់ស្ថានភាពទាំងអស់ គ្រូបង្រៀន និងសមាជិកសហគមន៍នឹងមានអារម្មណ៍ថាមានភាពងាយស្រួលក្នុងការសហការគ្នាទៅវិញទៅមក។ ការផ្លាស់ប្តូរត្រូវមានការគោរពចំពោះមនុស្សទាំងអស់ដែលពាក់ព័ន្ធ និងការអនុវត្តបេតិកភណ្ឌវប្បធម៌អរូបី។



### ចែករំលែកព័ត៌មាន

គ្រូបង្រៀនមិនមែនសុទ្ធតែជាអ្នកជំនាញខាងបេតិកភណ្ឌក្នុងស្រុកនោះទេ។ អ្នកអាចជួបជាមួយគ្រូនានា និងពន្យល់ថា តើបេតិកភណ្ឌនេះជាអ្វី ហើយហេតុអ្វីបានជាវាមានសារៈសំខាន់សម្រាប់សហគមន៍ និងចំពោះរូបអ្នក។ ជាពិសេស អ្នកអាចចែករំលែកព័ត៌មានលម្អិតអំពីបេតិកភណ្ឌវប្បធម៌របស់អ្នកជាមួយគ្រូបង្រៀន សាលា និងសិស្ស។ ប្រសិនបើគ្រូមានព័ត៌មានបែបនេះ និងអំពី ICH ដែលសិស្សបានដឹងច្បាស់ ពួកគេនឹងអាចបង្កើតមេរៀនគួរឱ្យចាប់អារម្មណ៍និងធានាបាននូវលទ្ធផលសិក្សាកាន់តែប្រសើរសម្រាប់សិស្ស។



## ចែករំលែកឯកសារ និងវត្ថុដែលមានស្រាប់

អ្នកអាចចែករំលែកសៀវភៅ រូបថត ខ្សែអាត់សំឡេង និងវត្ថុវប្បធម៌ជាមួយគ្រូ និងសិស្ស។ វត្ថុទាំងនេះអាចប្រើដើម្បីធ្វើឱ្យមេរៀន និងសកម្មភាពកាន់តែមានការចាប់អារម្មណ៍។ វត្ថុទាំងនេះក៏អាចដាក់តាំងបង្ហាញ ឬប្រើនៅថ្ងៃពិសេស ឬព្រឹត្តិការណ៍នានានៅសាលាផងដែរ។

## រៀបចំ ឬចាត់ចែងដំណើរកម្សាន្តរបស់សិស្ស

ការបន្តដំណើរកម្សាន្ត ឬការធ្វើដំណើរនានារបស់សាលាជាញឹកញាប់ ជាសកម្មភាពដ៏គួរឱ្យទាក់ទាញសម្រាប់សិស្ស។ ក្នុងដំណើរកម្សាន្តបែបនេះ ពួកគេអាចទទួលបានបទពិសោធន៍ពីការអនុវត្តវប្បធម៌ ឬស្វែងរកចំណេះដឹងថ្មីៗនៅក្នុងបរិបទការសិក្សាដូច្នេះហើយធ្វើឱ្យការរៀន និងការចងចាំបានកាន់តែប្រសើរជាងមុន។

អ្នកអាចគាំទ្រដំណើរកម្សាន្តបែបនេះ ដោយការអញ្ជើញសិស្សានុសិស្ស ទៅកន្លែងអនុវត្តផ្ទាល់ (ឧ. វត្តអារាម រោងជាង មហោស្រព ។ល។) ឬអញ្ជើញសិស្សឱ្យចូលរួមក្នុងព្រឹត្តិការណ៍វប្បធម៌ជាដើម។ នៅពេលដែលមានឱកាសបែបនេះសម្រាប់សិស្សានុសិស្សចូលរួមក្នុងការអនុវត្តវប្បធម៌ ពួកគេនឹងស្វែងយល់បន្ថែមអំពីវប្បធម៌នេះ។

ដោយសារមនុស្សមួយចំនួនប្រហែលជាមិនដឹងទាំងអស់អំពីប្រពៃណីរបស់អ្នក គួរជូនដំណឹងដល់ពួកគាត់អំពីបំរាម ការរឹតបន្តឹង ច្បាប់ ទំនៀមទម្លាប់ក៏ដូចជាអ្វីដែលគួរធ្វើ និងអ្វីដែលមិនគួរធ្វើនៅក្នុងវប្បធម៌របស់អ្នក។ នេះនឹងលើកកម្ពស់ទំនាក់ទំនងប្រកបដោយការគោរព និងទប់ស្កាត់ការប្រព្រឹត្តល្មើសដោយអចេតនាចំពោះសហគមន៍របស់អ្នក។ ប្រសិនបើអ្នកមិនសប្បាយចិត្តក្នុងការចែករំលែកព័ត៌មានអំពីការអនុវត្ត ឬទិដ្ឋភាពមួយចំនួន អ្នកមានសិទ្ធិបដិសេធសំណើសុំព័ត៌មានណាមួយបាន។







## ការទស្សនារោងជាង *batik* ( ឥណ្ឌូនេស៊ី )

*Batik* គឺជាបច្ចេកទេសនៃការធ្វើគោមលើវាយនភណ្ឌដោយប្រើក្រមួនក្ដៅ និងថ្នាំជ្រលក់ពណ៌។ នៅទីក្រុង Pasuruan ប្រទេសឥណ្ឌូនេស៊ី វិចិត្រករ *batik* ស្វាគមន៍សិស្សានុសិស្សឱ្យចូលក្នុងរោងជាងរបស់ខ្លួនដើម្បីបង្ហាញ និងបង្រៀនពួកគេអំពីសិល្បៈរបស់ខ្លួន។ ក្នុងអំឡុងពេលដំណើរទាំងនេះ សិស្សរៀនបង្កើតក្រណាត់ *Batik* ដោយខ្លួនរបស់ពួកគេផ្ទាល់ និងរៀបចំការពិពណ៌នាលម្អិតអំពីដំណើរការផលិតក្រណាត់ *Batik*។

មេរៀនទាំងនេះផ្ដល់ឱ្យសិស្សនូវបទពិសោធន៍ផ្ទាល់ និងជំរុញការផ្ទេរជាតុផ្សំបេតិកភណ្ឌវប្បធម៌ពីសិប្បករទៅសិស្ស។ ការធ្វើការងារជាមួយសិប្បករដែលមានក្ដីមេត្តាក៏ជួយសិស្សឱ្យអភិវឌ្ឍចំណេះដឹងនិងស្រឡាញ់បេតិកភណ្ឌរបស់ពួកគេផងដែរ។

## សហការជាមួយគ្រូដើម្បីបង្កើតមេរៀន

ប្រសិនបើអ្នកដឹងច្រើនអំពីបេតិកភណ្ឌរស់ណាមួយ ឬបើមិនដូច្នោះទេ អ្នកអនុវត្តវា វាពិតជាមានតម្លៃ ប្រសិនបើអ្នកធ្វើការជាមួយគ្រូ ដើម្បីបង្កើតមេរៀន។ ឧទាហរណ៍ អ្នកអាចជួយគ្រូឱ្យជ្រើសរើសព័ត៌មានដែលគួរឱ្យចាប់អារម្មណ៍បំផុត ដែលត្រូវចែករំលែកនៅក្នុងថ្នាក់រៀន។ អ្នកក៏អាចផ្តល់ដំបូន្មានផងដែរ អំពីថាតើសកម្មភាពដែលបានស្នើឡើងនៅក្នុងមេរៀន នឹងសមស្របសម្រាប់អ្នកអនុវត្ត និងសហគមន៍ដែរឬទេ ហេតុនេះហើយវាជួយបញ្ចៀសការយល់ខុស ឬការប្រព្រឹត្តកំហុសណាមួយ។

### បង្រៀនពីសិល្បៈខាងធ្វើម្ហូបក្នុងស្រុក (ប្រទេសនេប៉ាល់)

គ្រូបង្រៀនគណិតវិទ្យាម្នាក់បានបង្កើតមេរៀនមួយ ដោយផ្អែកលើធាតុផ្សំបេតិកភណ្ឌ ដែលហៅថា *Khapse* ជាបង្អែមពិសេសដែលធ្វើក្នុងអំឡុងពិធីបុណ្យចូលឆ្នាំ Tamang *Lhosar*។ គ្រូបានបង្រៀនមេរៀននេះដោយជោគជ័យ ពីព្រោះនៅពេលរៀបចំមេរៀន គាត់បានប្រឹក្សាជាមួយសមាជិកគ្រួសាររបស់សិស្ស និងរៀនពីរបៀបធ្វើបង្អែម *Khapse*។ ចំណេះដឹងដោយផ្ទាល់លើកដំបូងនេះបានជួយគាត់ឱ្យចែកចាយព័ត៌មាន ដោយផ្អែកលើចំណេះដឹងស៊ីជម្រៅ និងធានាថាមេរៀននេះ គឺត្រឹមត្រូវតាមហេតុការណ៍ពិត។





## មកបង្រៀនមួយថ្ងៃ

អ្នកអាចបង្ហាញពីការអនុវត្តវប្បធម៌ ឬជួយក្នុងការបង្រៀនអំពីការអនុវត្តនោះ ឬមេរៀនដែលទាក់ទងនឹងការអនុវត្ត។

### ផ្តល់ចំណេះដឹងអំពីការបោះពុម្ពផ្ទាំងរូបភាព (ប្រទេសនេប៉ាល់)

Rupendra Maharjan ផលិតផ្ទាំងរូបភាព និងរបាំងមុខសម្រាប់អ្នកដែលចូលរួមពិធីបុណ្យ *Gaijatra* ដ៏ពេញនិយម។ លោកបានទទួលជំនាញនេះពីគ្រួសាររបស់លោក។ លោក Maharjan ត្រូវបានអញ្ជើញឱ្យទៅសាលាមួយក្នុងស្រុកដើម្បីផ្តល់បាឋកថាខ្លីៗអំពីការងាររបស់គាត់ ដោយពន្យល់ពីបច្ចេកទេសទាក់ទងនឹងហត្ថកម្មរបស់គាត់ និងនិយាយទៅកាន់សិស្សអំពីពិធីបុណ្យនេះ។ ក្រោមការមើលការខុសត្រូវរបស់គាត់ សិស្សបានលាបពណ៌ និងបត់កង្ហារក្រដាស និងតុបតែងរបាំងមុខ។








## ស្នើគម្រោង

ប្រសិនបើអ្នកមានគំនិត ដែលជួយលើកកម្ពស់ដល់បេតិកភណ្ឌវប្បធម៌របស់អ្នក អ្នកអាចមានភាពសកម្ម ហើយទាក់ទងនាយកសាលា គ្រូបង្រៀន ឬសមាជិកនៃក្រុមមាតាបិតា។ វាអាចជាព្រឹត្តិការណ៍រយៈពេលមួយថ្ងៃ ឬសកម្មភាពរយៈពេលវែង។

## ណែនាំអ្នកជំនាញ និងអង្គការនានា

ប្រសិនបើអ្នកមិនមានអារម្មណ៍ល្អក្នុងការចែករំលែកព័ត៌មានដោយផ្ទាល់ទេ អ្នកអាចណែនាំមនុស្សផ្សេងទៀត និងអ្នកមានចំណេះដឹងផ្សេងទៀតដែលអាចមានឆន្ទៈដើម្បីជួយក្នុងរឿងនេះ។ ទាំងនេះអាចជាអ្នកមានជំនាញពីប្រភេទជាក់លាក់នៃការអនុវត្តបេតិកភណ្ឌរស់ អ្នកអនុវត្តផ្សេងទៀតមកពីក្លឹបដូចគ្នា ប្រជាជនផ្សេងទៀតនៅក្នុងតំបន់របស់អ្នក និងអ្នកជំនាញវប្បធម៌ដែលអ្នកបានសហការជាមួយ។ ឬអ្នកអាចណែនាំទៅកាន់សាលាថា ពួកគេទាក់ទងអង្គការវប្បធម៌ ឬសមាគមដែលអ្នកបានទំនាក់ទំនងជាមួយក្នុងអំឡុងពេលនៃការអនុវត្តបេតិកភណ្ឌរស់របស់អ្នក។



**ការបញ្ចូលបេតិកភណ្ឌរស់**
ទៅក្នុងការសិក្សានៅអាស៊ីប៉ាស៊ីហ្វិក
**សៀវភៅណែនាំ**

**កូនសៀវភៅ**

# 6

# តួនាទីរបស់ អ្នកគ្រប់គ្រងសាលា

**សៀវភៅនេះ** មានបំណងជួយគាំទ្រគ្រូបង្រៀន អ្នកគ្រប់គ្រងក្នុងវិស័យអប់រំ និងសហគមន៍ ក្នុងការដាក់បញ្ចូលបេតិកភណ្ឌក្នុងស្រុក ទៅក្នុងសកម្មភាពសិក្សា ឲ្យកាន់តែមានភាពប្រទាក់ក្រឡាគ្នា និងមានការចូលរួមកាន់តែច្រើនពីសំណាក់សិស្សានុសិស្ស និងការពារបេតិកភណ្ឌវប្បធម៌។

សៀវភៅនេះ មានកូនសៀវភៅចំនួនប្រាំបួន៖

- កូនសៀវភៅ 1 តើបេតិកភណ្ឌរស់ជាអ្វី ?
- កូនសៀវភៅ 2 ហេតុអ្វីត្រូវបង្រៀនជាមួយបេតិកភណ្ឌរស់ ?
- កូនសៀវភៅ 3 ការរៀបចំឱ្យត្រូវគ្នាជាមួយអាទិភាពអប់រំ
- កូនសៀវភៅ 4 វិធីសាស្ត្រប្រាំមួយដំបានសម្រាប់ជាមគ្គុទេសក៍ដល់គ្រូបង្រៀន
- កូនសៀវភៅ 5 តួនាទីរបស់ឪពុកម្ដាយ អាណាព្យាបាល និងសមាជិកសហគមន៍
- **កូនសៀវភៅ 6 តួនាទីរបស់ថ្នាក់គ្រប់គ្រងសាលា**
- កូនសៀវភៅ 7 តួនាទីរបស់អ្នករៀបចំគោលនយោបាយ
- កូនសៀវភៅ 8 ឯកសារ និងធនធាន
- កូនសៀវភៅ 9 សាច់រឿងរបស់គ្រូបង្រៀន

កូនសៀវភៅ

6

# តួនាទីអ្នកគ្រប់គ្រងសាលា

សៀវភៅណែនាំនេះផ្តល់នូវការណែនាំអំពីរបៀបដែលនាយកសាលា និងអ្នកគ្រប់គ្រងសាលាអាចធ្វើការជាមួយគ្រូបង្រៀន និងសមាជិកសហគមន៍ ដើម្បីគាំទ្រដល់ដំណើរការនៃការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការអប់រំ។

ដើម្បីស្វែងយល់បន្ថែមអំពីបេតិកភណ្ឌរស់ និងរបៀបបញ្ចូលវានៅតាមសាលា អាចជួយលើកកម្ពស់គុណភាពនៃការអប់រំ និងការអភិរក្សបេតិកភណ្ឌរបស់សហគមន៍ សូមមើលកូនសៀវភៅណែនាំទី១ និងកូនសៀវភៅណែនាំទី ២ នៃសៀវភៅនេះ។

**សម្រាប់ទិដ្ឋភាពទូទៅ** អំពីវិធីសាស្ត្របញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការអប់រំក្នុងប្រព័ន្ធ សូមទស្សនាស៊េរីគំនូរជីវចលនេះតាមរយៈ៖ CLICK







## អ្នកគ្រប់គ្រងសាលាជាអ្នកជួយសម្រួល និងជាអ្នកសម្របសម្រួល

ការបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបីជាវិធីសាស្រ្ត ដែលមានប្រយោជន៍សម្រាប់សិស្ស ប៉ុន្តែការអនុវត្តវាទាមទារការរៀបចំ ហើយជារឿយៗក៏ទាមទារឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗ រួមទាំងអ្នកគ្រប់គ្រងសាលាផងដែរ។

ក្រុមគណៈគ្រប់គ្រងសាលាមានទិដ្ឋភាពទូទៅអំពីឱកាសនិងឧបសគ្គរបស់សាលារួមទាំងក្របខ័ណ្ឌគោលនយោបាយ ប្រវត្តិ និងបន្ទុកការងាររបស់ក្រុមបង្រៀន ស្ថានភាពសិស្ស និងបរិបទមូលដ្ឋាន។ ដូចនេះ វាអាចដើរតួនាទីសម្របសម្រួលក្នុងការរៀបចំវិធីសាស្រ្តគរុកោសល្យថ្មីៗ ដូចជា ការបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបីជាដើម។

កិច្ចខិតខំប្រឹងប្រែងសម្របសម្រួល ដែលដឹកនាំដោយក្រុមគណៈគ្រប់គ្រងសាលាអាចធ្វើឱ្យដំណើរការនៃការបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបីកាន់តែរលូន។ ឧទាហរណ៍ ការផ្តល់ជំនួយផ្នែករដ្ឋបាល និងភស្តុភារនឹងអនុញ្ញាតឱ្យគ្រូបង្រៀន ដែលមានភាពមមាញឹក មានពេលវេលាច្រើនដើម្បីផ្តោតការខិតខំប្រឹងប្រែងរបស់ពួកគាត់លើការបង្កើតមេរៀន និងការចែកចាយមេរៀន។ ដូចគ្នានេះផងដែរ ការសម្របសម្រួលនឹងទប់ស្កាត់ការងារត្រួតគ្នា និងការធ្វើជាថ្មីម្តងទៀត។ ឧទាហរណ៍ ដោយសារបេតិកភណ្ឌវប្បធម៌អរូបីមួយ អាចដាក់បញ្ចូលទៅក្នុងមុខវិជ្ជាជាច្រើន ប្រសិនបើមិនមានការសម្របសម្រួល គ្រូបង្រៀនជាច្រើននាក់មកពីសាលាមួយអាចព្យាយាមទាក់ទងទៅអ្នកជំនាញដដែលពីសហគមន៍ ឬ ស្ថាប័នមួយ។



ខាងក្រោមនេះគឺជាការផ្តល់យោបល់ជាក់ស្តែងមួយចំនួន សម្រាប់អ្វីៗដែលអ្នកគ្រប់គ្រងសាលា និងអ្នកបង្កើតគោលនយោបាយអាចធ្វើបាន ដើម្បីគាំទ្រគ្រូបង្រៀន និងអ្នកដែលពាក់ព័ន្ធ។ បញ្ជីសំណូមពរនេះគឺមិនទូលំទូលាយទេ។ ការនិយាយជាមួយគ្រូអំពីបញ្ហានេះអាចជួយកំណត់ពីតម្រូវការ ឬយុទ្ធសាស្រ្តផ្សេងទៀត។

## គាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូ

គ្រូបង្រៀនបង្កើនជំនាញរបស់ខ្លួន តាមរយៈការបណ្តុះបណ្តាលនៅក្នុងស្ថាប័ន ការបណ្តុះបណ្តាលលើការងារ និងការសិក្សាផ្ទាល់ខ្លួន និងការអាន។ បច្ចុប្បន្ននេះ មានឱកាសក្នុងការបណ្តុះបណ្តាលតិច ដើម្បីរៀនអំពីការបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបី។ លទ្ធផលនៃការសិក្សាអាចប្រសើរឡើងនៅពេលដែលគ្រូប្រើប្រាស់គរុកោសល្យប្រកបដោយបរិយាបន្ន (ឧ. ការសិក្សាសកម្ម ដែលត្រូវបានសម្របតាមបានយ៉ាងល្អទៅនឹងវិធីសាស្ត្រនេះ) ហើយនៅពេលដែលពួកគេរៀនអំពីប្រធានបទដូចជា បេតិកភណ្ឌ និងវប្បធម៌ក្នុងតំបន់ បច្ចេកទេសកំណត់អំពីវប្បធម៌ការអប់រំអំពីភាពជាពលរដ្ឋសាកល និងការចូលរួមក្នុងសង្គមជាដើម។ ប៉ុន្តែ គ្រូបង្រៀនមួយចំនួនប្រហែលជាមិនមានអារម្មណ៍ស្រណុកក្នុងចិត្តក្នុងការពិសោធន៍សាកល្បងដោយខ្លួនឯងនោះឡើយ។

> កិច្ចខិតខំប្រឹងប្រែងសម្របសម្រួល ដែលដឹកនាំដោយក្រុមគណៈគ្រប់គ្រងសាលាអាចធ្វើឱ្យដំណើរការនៃការបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបីកាន់តែរលូន។

ដើម្បីលើកទឹកចិត្តគ្រូបង្រៀននៅលើមាគ៌ានេះ អ្នកគ្រប់គ្រងសាលាអាច៖

- លើកកម្ពស់ការយល់ដឹងក្នុងចំណោមគ្រូបង្រៀនអំពីអត្ថប្រយោជន៍នៃការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការអប់រំ។
- ដោយមានការរួមចំណែកពីគ្រូបង្រៀន និងអ្នកជំនាញក្នុងស្រុក ចងក្រងធនធានគួរឱ្យចាប់អារម្មណ៍ (ឧ. អំពីវប្បធម៌ក្នុងស្រុក ឬអំពីបច្ចេកទេសបង្រៀន) និងឧទាហរណ៍ល្អៗ ពីការបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបី។ ធ្វើឱ្យធនធានទាំងអស់នេះអាចរកបាននៅមជ្ឈមណ្ឌលធនធានសាលា។
- ប្រសិនបើសមាជិកមួយចំនួននៃក្រុមបានបង្រៀនជាមួយ ឬអំពីបេតិកភណ្ឌរួចហើយ ឬបានព្យាយាមធ្វើដូច្នេះ សូមគាំទ្រការងាររបស់ពួកគាត់ និងលើកទឹកចិត្តពួកគាត់ឱ្យចែករំលែកបទពិសោធន៍របស់ពួកគាត់ជាមួយសហការីរបស់ខ្លួន។ គ្រូមកពីសាលាផ្សេងទៀតក៏អាចនឹងត្រូវអញ្ជើញឱ្យចូលរួមក្នុងការពិភាក្សាអំពីការងារ និងការជំរុញទឹកចិត្តរបស់ពួកគាត់ផងដែរ។
- លើកទឹកចិត្តគ្រូបង្រៀនឱ្យចូលរួមក្នុងក្រុមសិក្សា និង ការផ្លាស់ប្តូរមតិយោបល់រវាងមិត្តភក្តិដើម្បីបង្កើតមេរៀនថ្មីៗជាមួយគ្នា ឬស្វែងរកវិធីសាស្ត្រគរុកោសល្យថ្មីៗ។
- កំណត់ឱកាសកសាងសមត្ថភាពដែលពាក់ព័ន្ធដោយផ្ទាល់ ឬតាមអនឡាញ រៀបចំនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។ អញ្ជើញគ្រូបង្រៀនឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលទាំងនេះ។



## ការសម្របសម្រួលផ្នែកភស្តុភារ និងតម្រូវការរដ្ឋបាល

សកម្មភាពដូចជា ដំណើរកម្សាន្ត និងការធ្វើដំណើរទៅកាន់សាលាដោយសិប្បករ និងការប្រារព្ធព្រឹត្តិការណ៍វប្បធម៌ ផ្តល់ឱកាសសិក្សាដ៏គួរឱ្យទាក់ទាញសម្រាប់សិស្សានុសិស្ស និងជាសកម្មភាពដែលសមស្របបំផុតនៅពេលបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបី។ ទោះជាយ៉ាងណាជាធម្មតា ពួកគេពាក់ព័ន្ធនឹងការរៀបចំផ្នែកភស្តុភារ និងរដ្ឋបាលដែលចំណាយពេលច្រើន ហើយជួនកាលក៏ពាក់ព័ន្ធនឹងការចំណាយផងដែរ។

ដើម្បីជួយដល់គ្រូបង្រៀន អ្នកគ្រប់គ្រងសាលាអាច៖

- ផ្តល់កាលវិភាគដែលអាចបត់បែនបានដើម្បីឱ្យគ្រូបង្រៀនអាចបំពេញបាន និងធ្វើការរួមគ្នាដើម្បីរៀបចំសកម្មភាព ឬគម្រោងតាមប្រធានបទរួមគ្នាផ្សេងទៀត។
- រៀបចំនីតិវិធីងាយស្រួលសម្រាប់ការរៀបចំដំណើរកម្សាន្ត និងការអញ្ជើញភ្ញៀវឱ្យមកកាន់សាលា (ឧ. នីតិវិធីចុះឈ្មោះ ឧបករណ៍ ឬនីតិវិធីកក់យានយន្ត នីតិវិធីសុវត្ថិភាពជាដើម ។ល។) គ្រូត្រូវពិគ្រោះយោបល់ ដើម្បីកំណត់ពីជំហានដែលពួកគាត់យល់ឃើញថាមានភាពស្មុគស្មាញ និងចំណាយពេលច្រើនបំផុត។
- បែងចែកមូលនិធិ និង/ឬកំណត់ពីប្រភពមូលនិធិខាងក្រៅដើម្បីរ៉ាប់រងការចំណាយលើសកម្មភាពបែបនេះ។ ត្រូវរៀបចំថវិការួមគ្នាដោយគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលា។
- កំណត់ទីកន្លែងដើម្បីឱ្យគ្រូបង្រៀនមានការជួបប្រជុំ រៀបចំសកម្មភាព និងបង្ហាញលទ្ធផល ។

### បង្កើតគោលនយោបាយទូទាំងសាលា (ប្រទេសម៉ុងហ្គោលី)

សាលា Khan-Uul Complex បានបង្កើតគោលនយោបាយនៅតាមសាលាមួយចំនួនដើម្បីលើកកម្ពស់ការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការអប់រំ ដូចជាការដាក់បញ្ចូលសកម្មភាពបេតិកភណ្ឌវប្បធម៌អរូបីមួយចំនួនទៅក្នុងផែនការការងារប្រចាំឆ្នាំរបស់សាលា ការកែសម្រួលបន្ទុកការងាររបស់គ្រូ និងបង្កើតបរិយាកាសសមស្របដើម្បីជំរុញការសិក្សារបស់សិស្សជាដើម (ឧ. ទីកន្លែងទាក់ទងនឹងប្រធានបទផ្សេងៗ រួមទាំងសាលលេងល្បែងប្រជាប្រិយ និងសាលសម្រាប់អានរឿងព្រេងនិទាន) ជាដើម។



# ភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍មូលដ្ឋាន



សមាជិកសហគមន៍គឺជាអ្នកថែរក្សាដ៏សំខាន់នៃបេតិកភណ្ឌវប្បធម៌អរូបីរបស់ពួកគាត់។ ពួកគាត់ដឹងអំពីវា ហើយអាចពន្យល់ពីគុណតម្លៃ និងអត្ថន័យរបស់វាបានទៀតផង។ ទោះបីជាពួកគាត់ប្រហែលជាមិនមានបទពិសោធន៍ក្នុងការបង្រៀននៅតាមសាលាក៏ដោយ ប៉ុន្តែពួកគាត់ច្រើនតែមានចំណេះដឹងទូលំទូលាយអំពីបេតិកភណ្ឌវប្បធម៌ដែរ ហើយគ្រូបង្រៀនអាចទទួលបានអត្ថប្រយោជន៍ពីការសហការរបស់ពួកគាត់តាមវិធីជាច្រើន (ការចែករំលែកព័ត៌មាន ការដាក់បញ្ចូលទៅក្នុងការរៀបចំកិច្ចតែងការបង្រៀន ការបង្រៀនរួមគ្នា ។ល។ ដូចដែលបានរៀបរាប់នៅក្នុងកូនសៀវភៅណែនាំទី ៥)។

ជាធម្មតា នឹងមានការផ្លាស់ប្តូរយោបល់ដ៏សំខាន់រវាងគ្រូ និងអ្នកអនុវត្តបេតិកភណ្ឌវប្បធម៌អរូបី ប៉ុន្តែក្រុមគណៈគ្រប់គ្រងអាចជួយរៀបចំការប្រជុំ និងដំណើរកម្សាន្តបែបនេះ។

ជារឿយៗ មានទំនាក់ទំនងរួចហើយរវាងសាលា និងសហគមន៍ ដូចជាសមាគមមាតាបិតាសិស្ស និងគ្រូបង្រៀន ប៉ុន្តែកិច្ចសហការអាចពង្រឹង ឬធ្វើឱ្យមានលក្ខណៈជាប្រព័ន្ធបន្ថែមទៀត។

ដើម្បីជួយឱ្យសមាជិកសហគមន៍ចូលរួមក្នុងសកម្មភាពអប់រំ អ្នកគ្រប់គ្រងសាលា អាច៖

- ចូលរួមជាមួយមាតាបិតាសិស្សនៅក្នុងដំណើរការធ្វើការសម្រេចចិត្ត និងដំណើរការសិក្សា។ ឧទាហរណ៍ គេអាចអញ្ជើញមាតាបិតាសិស្សឱ្យចូលរួម ក្នុងការរៀបចំព្រឹត្តិការណ៍ពិសេសនៅតាមសាលាជាដើម។
- បង្កើតប្រតិទិនពីព្រឹត្តិការណ៍សហគមន៍សំខាន់ៗ និងតាមពេលវេលា (ឧ. ពិធីបុណ្យ រដូវច្រូតកាត់។ល។)។ ប្រតិទិននេះអាចជំរុញសកម្មភាពរបស់សាលា។ វាក៏អាចកំណត់ពីកំឡុងពេលមមាញឹក ដែលក្នុងនោះ គ្រួសាររបស់សិស្សប្រហែលជាមិនសូវមានពេលដើម្បីចូលរួមក្នុងសកម្មភាពសាលានោះឡើយ។
- ទាក់ទងប្រធានសហគមន៍ ឬមនុស្សចាស់ជាទៀងទាត់។ ឧទាហរណ៍ បន្តធ្វើបច្ចុប្បន្នភាពលើគំនិតផ្តួចផ្តើមរបស់សាលា សួរពួកគាត់សម្រាប់ព័ត៌មានអំពីព្រឹត្តិការណ៍នៅក្នុងសហគមន៍និងផ្លាស់ប្តូរព័ត៌មាន និងគំនិតយោបល់ជាមួយពួកគាត់ជាដើម។
- ចងក្រងបញ្ជីឈ្មោះសមាជិកសហគមន៍ដែលមានជំនាញខាងបេតិកភណ្ឌ និងវប្បធម៌ ដែលគ្រូអាចប្រឹក្សាយោបល់បាន។
- រៀបចំការជួបជុំគ្នាសម្រាប់គ្រូបង្រៀន និងសមាជិកសហគមន៍ ដើម្បីជំរុញការសន្ទនា និងកិច្ចសហប្រតិបត្តិការ និងបង្កើតគំនិតសម្រាប់គម្រោងសាលាទាក់ទងនឹងបេតិកភណ្ឌ។
- អញ្ជើញសមាជិកសហគមន៍ឱ្យមកចូលរួមថ្ងៃពិសេសនៅសាលា។ ភ្ញៀវអាចបង្ហាញពីសិល្បៈ និងហត្ថកម្មរបស់ខ្លួន ធ្វើជាវាគ្មិន និយាយអំពីបទពិសោធន៍ទាក់ទងនឹងបេតិកភណ្ឌរបស់ពួកគេជាមួយសិស្ស និង/ឬចូលរួមក្នុងមេរៀនទាក់ទងនឹងផ្នែកជំនាញរបស់ពួកគេជាដើម។
- រៀបចំតាំងពិព័រណ៌នៅក្នុងសាលាក្រោមប្រធានបទទាក់ទងនឹងបេតិកភណ្ឌក្នុងស្រុកដោយមានការចូលរួមចំណែកពីសិស្ស គ្រួសាររបស់ពួកគេ និងសមាជិកសហគមន៍ដទៃទៀត។
- លើកទឹកចិត្តដល់គ្រូបង្រៀន និងសិស្សានុសិស្សឱ្យចូលរួមក្នុងការប្រារព្ធពិធីវប្បធម៌នៅក្នុងសហគមន៍ ដើម្បីស្វែងយល់បន្ថែមអំពីការអនុវត្តក្នុងស្រុក។



## ការបង្កើតសារមន្ទីរបេតិកភណ្ឌវប្បធម៌អរូបីនៅតាមសាលា (ប្រទេសគៀជីស្ថាន)

តាមសំណើរបស់គ្រូបង្រៀន នាយកសាលា "Ilim" ដែលជាសាលា UNESCO ASPnet បានបង្កើតសារមន្ទីរបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងបន្ទប់រៀនមួយក្នុងបរិវេណសាលា។ មាតាបិតាសិស្ស និងសមាជិកសហគមន៍បានបរិច្ចាគវត្ថុ និងផ្ដល់ព័ត៌មានអំពីសារមន្ទីរ និងការប្រើប្រាស់។ សារមន្ទីរនេះបានក្លាយជាកន្លែងដ៏ពេញនិយមសម្រាប់គ្រូបង្រៀន និងសិស្សានុសិស្ស ដែលក្នុងនោះបានរៀបចំមេរៀន និងធ្វើសកម្មភាពផ្សេងៗ។



## បង្កើតបណ្ដាញ និងការគាំទ្រពីស្ថាប័ន

បណ្ដាញគ្រូបង្រៀន និងអ្នកជំនាញផ្នែកបេតិកភណ្ឌក្នុងស្រុក ថ្នាក់ជាតិ និងអន្តរជាតិផ្ដល់ ឱកាសសម្រាប់គ្រូបង្រៀនក្នុងការចែករំលែកគំនិតយោបល់ និងពិភាក្សាអំពីវិធីបញ្ចូលបេតិកភណ្ឌអរូបីទៅក្នុងការអប់រំ។

អ្នកជំនាញមកពីសារមន្ទីរ បណ្ណាល័យ សមាគមក្នុងស្រុក រដ្ឋាភិបាល និងនាយកដ្ឋានសិក្សាអាចជាប្រភពចំណេះដឹង និងធនធានដ៏មានសារៈប្រយោជន៍អំពីបេតិកភណ្ឌវប្បធម៌ក្នុងស្រុកដែលអាចជួយគ្រូបង្កើតខ្លឹមសារមេរៀនថ្មី។ ស្ថាប័នទាំងនេះក៏អាចរៀបចំដំណើរកម្សាន្តរបស់សិស្ស និងផ្ដល់ឱ្យសាលានូវឯកសារសោតទស្សន៍ និងសម្ភារៈផ្សេងៗទៀតផងដែរ។ ស្ថាប័នមួយចំនួនក្នុងចំណោមស្ថាប័នទាំងនេះអាចមានបទពិសោធន៍ជាមួយកម្មវិធីអប់រំបេតិកភណ្ឌរួចមកហើយ ដូចជា ការអប់រំបេតិកភណ្ឌពិភពលោក និងការអប់រំសិល្បៈជាដើម ឬប្រហែលជាបានបង្កើតសកម្មភាពអប់រំផ្ទាល់ខ្លួនរបស់ពួកគេ ដូចដែលសារមន្ទីរជាច្រើនទៀតបានធ្វើដែរ។

> បណ្ដាញគ្រូបង្រៀន និងអ្នកជំនាញផ្នែកបេតិកភណ្ឌក្នុងស្រុក ថ្នាក់ជាតិ និងអន្តរជាតិផ្ដល់ ឱកាសសម្រាប់គ្រូបង្រៀនក្នុងការចែករំលែកគំនិតយោបល់ និងពិភាក្សាអំពីវិធីបញ្ចូលបេតិកភណ្ឌអរូបីទៅក្នុងការអប់រំ។

អ្នកគ្រប់គ្រងសាលា អាច៖

- ភ្ជាប់ទំនាក់ទំនងជាមួយ **បណ្ដាញសាលា** ដែលមានចំណាប់អារម្មណ៍លើប្រធានបទបេតិកភណ្ឌ (ឧ. សាលា UNESCO Associated បណ្ដាញ GCED អាស៊ីប៉ាស៊ីហ្វិក APCEIU NEST [បណ្ដាញសម្រាប់សាលា និងគ្រូបង្រៀន] បណ្ដាញ SEAMEO ។ល។)។
- ប្រមូល និងផ្សព្វផ្សាយព័ត៌មានអំពី**សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ គម្រោង និងកម្មវិធីផ្លាស់ប្ដូរការសិក្សា**។ លើកទឹកចិត្តឱ្យមានការចូលរួមរបស់គ្រូបង្រៀន ដើម្បីឱ្យពួកគេអាចជួបជាមួយសហការី និងចែករំលែកបទពិសោធន៍។
- ចងក្រង **បញ្ជីឈ្មោះដៃគូសក្ដានុពល** (ឧ. សារមន្ទីរ បណ្ណាល័យ ។ល។) ភ្ជាប់ជាមួយបេតិកភណ្ឌវប្បធម៌ ដែលគ្រូអាចប្រឹក្សាយោបល់ និងទាក់ទងពួកគេដើម្បីរៀបចំកិច្ចប្រជុំជាមួយគ្រូអំពីសកម្មភាពសក្ដានុពល។

### ភ្ជាប់ទំនាក់ទំនងជាមួយសាកលវិទ្យាល័យសារមន្ទីរ និងសាលា (ប្រទេសប៉ាគីស្ថាន)

នៅទីក្រុង Lahore និស្សិតដែលកំពុងសិក្សាដើម្បីធ្វើជាមគ្គុទ្ទេសក៍ទេសចរណ៍នៅមហាវិទ្យាល័យសិល្បៈជាតិ ស្ម័គ្រចិត្តជួយសម្របសម្រួលដល់ដំណើរកម្សាន្តទៅកាន់សារមន្ទីរ Lahore។ មគ្គុទ្ទេសក៍ដែលមានសេចក្ដីប្រាថ្នានេះអនុវត្តជំនាញរបស់ពួកគេ នៅក្នុងការកំណត់ជាក់ស្តែង

ខណៈពេលដែលសិស្សទទួលបានអត្ថប្រយោជន៍ពីដំណើរកម្សាន្ត ដែលគួរឱ្យចាប់អារម្មណ៍ហើយអាចទទួលបានព័ត៌មានដែលមានប្រយោជន៍។







**ការបញ្ចូលបេតិកភណ្ឌរស់**

ទៅក្នុងការសិក្សានៅអាស៊ីប៉ាស៊ីហ្វិក

**សៀវភៅណែនាំ**

**កូនសៀវភៅ**

**7**

# តួនាទីរបស់ អ្នករៀបចំ គោលនយោបាយ

**សៀវភៅនេះ** មានបំណងជួយគាំទ្រគ្រូបង្រៀន អ្នកគ្រប់គ្រងក្នុងវិស័យអប់រំ និងសហគមន៍ ក្នុងការដាក់បញ្ចូលបេតិកភណ្ឌក្នុងស្រុក ទៅក្នុងសកម្មភាពសិក្សា ឲ្យកាន់តែមានភាពប្រទាក់ក្រឡាគ្នា និងមានការចូលរួមកាន់តែច្រើនពីសំណាក់សិស្សានុសិស្ស និងការពារបេតិកភណ្ឌវប្បធម៌។

សៀវភៅនេះ មានកូនសៀវភៅចំនួនប្រាំបួន៖

- កូនសៀវភៅ 1 តើបេតិកភណ្ឌរស់ជាអ្វី ?
- កូនសៀវភៅ 2 ហេតុអ្វីត្រូវបង្រៀនជាមួយបេតិកភណ្ឌរស់ ?
- កូនសៀវភៅ 3 ការរៀបចំឱ្យត្រូវគ្នាជាមួយអាទិភាពអប់រំ
- កូនសៀវភៅ 4 វិធីសាស្ត្រប្រាំមួយជំហានសម្រាប់ជាមគ្គុទេសក៍ដល់គ្រូបង្រៀន
- កូនសៀវភៅ 5 តួនាទីរបស់ឪពុកម្ដាយ អាណាព្យាបាល និងសមាជិកសហគមន៍
- កូនសៀវភៅ 6 តួនាទីរបស់ថ្នាក់គ្រប់គ្រងសាលា
- ▶ **កូនសៀវភៅ 7 តួនាទីរបស់អ្នករៀបចំគោលនយោបាយ**
- កូនសៀវភៅ 8 ឯកសារ និងធនធាន
- កូនសៀវភៅ 9 សាច់រឿងរបស់គ្រូបង្រៀន

កូនសៀវភៅ
7

# តួនាទីរបស់អ្នកបង្កើតគោលនយោបាយ

សៀវភៅណែនាំនេះផ្តល់ការណែនាំអំពីរបៀប ដែលអ្នកបង្កើតគោលនយោបាយអាចគាំទ្រដល់ការបញ្ចូលបេតិកភណ្ឌរស់ទៅក្នុងការអប់រំ។

ការស្វែងយល់បន្ថែមអំពីបេតិកភណ្ឌរស់ និងរបៀបដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សា អាចជួយលើកកម្ពស់គុណភាពនៃការអប់រំ និងការអភិរក្សបេតិកភណ្ឌរបស់សហគមន៍ សូមមើលសៀវភៅណែនាំទី ១ និងសៀវភៅណែនាំទី ២។

**សម្រាប់ទិដ្ឋភាពទូទៅ** អំពីវិធីសាស្ត្រនៃការដាក់បញ្ចូលបេតិកភណ្ឌរស់ ទៅក្នុងការអប់រំក្នុងប្រព័ន្ធ សូមទស្សនាស៊េរីគំនូរជីវចលនេះតាមរយៈ Click





## ហេតុអ្វីបានជាច្បាប់ និងគោលនយោបាយទាំងនេះមានសារៈប្រយោជន៍?

ប្រទេស តំបន់ និងសាលាបង្កើតច្បាប់ និងគោលនយោបាយអប់រំ ដើម្បីណែនាំដល់ការប្រព្រឹត្តទៅនៃប្រព័ន្ធអប់រំ និងសាលា ព្រមទាំងបង្កើតបរិបទសិក្សាដែលមានប្រសិទ្ធភាព និងមានការចូលរួម និងបរិយាកាសប្រកបដោយសុវត្ថិភាពសម្រាប់សិស្ស គ្រូបង្រៀន និងបុគ្គលិកសាលា។

គោលនយោបាយទាំងនេះមានឥទ្ធិពលលើការបង្រៀននិងការសិក្សាបេតិកភណ្ឌវប្បធម៌អរូបីតាមវិធីផ្សេងៗ។ គោលនយោបាយមួយចំនួនមានឥទ្ធិពលវិជ្ជមាន ឧទាហរណ៍ នៅពេលដែលវា៖

- លើកកម្ពស់ការដាក់បញ្ចូលទៅក្នុងមេរៀនក្នុងមូលដ្ឋាន ទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ ដូច្នេះ ជួយសម្រួលដល់មេរៀន ដែលផ្សារភ្ជាប់ទៅនឹងបេតិកភណ្ឌវប្បធម៌អរូបីរបស់សហគមន៍មូលដ្ឋាន។
- លើកទឹកចិត្តឱ្យមានការអប់រំក្នុងភាសាកំណើត ដូច្នេះវាផ្តល់ឱកាសសម្រាប់ទម្រង់អក្សរសាស្ត្រក្នុងស្រុក និងការបញ្ចេញមតិយោបល់តាមការចងចាំ។
- លើកកម្ពស់ការគោរពចំពោះភាពចម្រុះគ្នានៃវប្បធម៌ (នៅក្នុងសាលា និងក្នុងបរិបទដ៏ទូលំទូលាយ)។
- ដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា ដែលទទួលស្គាល់អំពីសារៈសំខាន់នៃការគោរពវប្បធម៌ចម្រុះ ដូចជាការអប់រំអំពីពលរដ្ឋសាកល និងការអប់រំពីការអភិវឌ្ឍប្រកបដោយចីរភាព។
- លើកទឹកចិត្តឱ្យមានភាពបត់បែន និងភាពច្នៃប្រឌិតក្នុងដំណើរការបង្រៀន និងការរៀន។
- ជំរុញកិច្ចសហប្រតិបត្តិការអន្តរក្រសួង (ឧ. កិច្ចសហប្រតិបត្តិការរវាងក្រសួងអប់រំ និងក្រសួងវប្បធម៌ បរិស្ថាន និងក្រសួងសុខាភិបាល) ការបើកទ្វារសម្រាប់គម្រោង និងភាពជាដៃគូដែលគ្របដណ្តប់លើវិស័យជាច្រើន (ឧ. ជាមួយសារមន្ទីរ តំបន់បេតិកភណ្ឌ សមាគមព្យាបាលបែបបុរាណ ។ល។)



ទោះជាយ៉ាងណា គោលនយោបាយមួយចំនួនអាចមានឥទ្ធិពលអវិជ្ជមាន។ ឧទាហរណ៍នៅពេលដែលវា៖

- នាំឱ្យមានកម្មវិធីសិក្សាលើសកម្រិត។ ក្នុងស្ថានភាពបែបនេះ គ្រូបង្រៀនមានពេលវេលា ផ្តោតតែលើមុខវិជ្ជា ដែលត្រូវបានសាកល្បង ហើយទំនងជាមិនសូវធ្វើសកម្មភាពក្រៅពីការងារក្នុងថ្នាក់ដែលបានអនុវត្តតាមកម្មវិធីនោះឡើយ។
- ដាក់ខ្លឹមសារកម្មវិធីសិក្សាដែលមិនឆ្លុះបញ្ចាំងពីបេតិកភណ្ឌ ឬភាពចម្រុះវប្បធម៌របស់ប្រទេស។ សិស្សមកពីក្រុម ដែលមិនមានតំណាងអាចមានអារម្មណ៍ថា មិនត្រូវបានដាក់បញ្ចូល ហើយអាចបាត់បង់ការលើកទឹកចិត្តក្នុងការចូលរួមសកម្មភាពនៅតាមសាលា ឬសូម្បីតែការចូលរៀន។ ឧទាហរណ៍ នៅពេលដែលសិស្សមិនអាចរៀនក្នុងភាសាកំណើតរបស់ខ្លួនបាន ពួកគេទំនងជាមានការលំបាកក្នុងការសិក្សា ហើយទំនងជាបោះបង់ការសិក្សាក៏ថាបាន។
- កំណត់ភាពច្នៃប្រឌិត និង/ឬភាពបត់បែនរបស់គ្រូ។ កម្មវិធីសិក្សាដែលមានការរៀបចំតាមរចនាសម្ព័ន្ធ និងលម្អិត និងមេរៀនតាមការគ្រោងទុក គឺជាទម្រង់គាំទ្រដ៏មានប្រយោជន៍សម្រាប់គ្រូបង្រៀន។ ទោះជាយ៉ាងណា គ្រូបង្រៀនអាចមានអារម្មណ៍ថា មានការរឹតត្បិតនៅពេលដែលមានការគ្រប់គ្រងខ្លាំងពេក (ឧទាហរណ៍ ការសង្កត់ធ្ងន់ខ្លាំងលើលទ្ធផលប្រឡង)ជាដើម។ ក្នុងករណីបែបនេះ គ្រូបង្រៀនទំនងជាមិនធ្វើការផ្លាស់ប្តូរមេរៀន ដើម្បីបំពេញតម្រូវការរបស់សិស្សជាក់លាក់នោះទេ។
- កំណត់ដំណើរកម្សាន្ត និងដំណើរនានាពីអ្នកជំនាញ។ ថវិកាមានកម្រិត វិធាន និងបទប្បញ្ញត្តិសុវត្ថិភាពតឹងរ៉ឹងខ្លាំងពេកអាចកំណត់ឱកាសសម្រាប់សិស្សដើម្បីស្វែងយល់អំពីបេតិកភណ្ឌវប្បធម៌អរូបី និងរៀនតាមរបៀបថ្មី។
- មិនទទួលស្គាល់តួនាទីរបស់សហគមន៍ ក្នុងការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី។ នៅពេលដែលគោលនយោបាយនិងវិធានការអប់រំមិនស្របគ្នានឹងអាទិភាពនិងតម្រូវការរបស់សហគមន៍ ហើយសំឡេងរបស់អ្នកអនុវត្តមិនត្រូវបានគេឮទៀតនោះ សហគមន៍នឹងមិនអាចចែករំលែកចំណេះដឹងរបស់ពួកគេជាមួយសាលាបានឡើយ ដូច្នេះហើយចំណេះដឹងបែបនេះមិនត្រូវបានផ្ទេរទៅឱ្យក្មេងៗជំនាន់ក្រោយឡើយ។



សំណូមពរខាងក្រោមមានគោលបំណងបង្កើនប្រសិទ្ធភាពនៃគោលនយោបាយ និងច្បាប់។

### ការកំណត់ និងការវិភាគគោលនយោបាយសម្រាប់ការរៀបចំផែនការរយៈពេលវែង

រដ្ឋាភិបាល អាចរៀបចំ**គម្រោងកំណត់ និងការវិភាគគោលនយោបាយពហុវិស័យ** ដើម្បីកំណត់ឱកាស និងឧបសគ្គសម្រាប់កិច្ចសហប្រតិបត្តិការរវាងវិស័យនានា។ ផ្អែកលើលទ្ធផលនៃការវិភាគនេះ ក្រសួងអប់រំអាចរៀបចំ**យុទ្ធសាស្ត្រ និងផែនការ**រយៈពេលវែងសម្រាប់ការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីនៅតាមសាលា និងកែសម្រួលបរិយាកាសសិក្សាឱ្យស្របទៅតាមនោះ។

គោលនយោបាយទាំងអស់ចាំបាច់ត្រូវស្វែងយល់ និងអនុវត្ត ប្រសិនបើចង់ឱ្យគោលនយោបាយទាំងនោះមានឥទ្ធិពលវិជ្ជមាន។

### ការលើកកម្ពស់ការយល់ដឹងអំពីគោលនយោបាយដែលអនុញ្ញាតឱ្យមានការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងការអប់រំ

គោលនយោបាយទាំងអស់ចាំបាច់ត្រូវស្វែងយល់ និងអនុវត្ត ប្រសិនបើចង់ឱ្យគោលនយោបាយទាំងនោះមានឥទ្ធិពលវិជ្ជមាន។ ដូច្នេះវាចាំបាច់ណាស់ ដែលក្រសួងអប់រំបង្កើត**យុទ្ធនាការលើកកម្ពស់ការយល់ដឹង** និង/ឬ**ការប្រាស្រ័យទាក់ទងទៀងទាត់** ជាមួយសាលាដើម្បីពន្យល់អំពីខ្លឹមសារនៃគោលនយោបាយ និងការរំពឹងទុករបស់ពួកគេ។ ឧទាហរណ៍ ប្រសិនបើគោលនយោបាយថ្មីស្តីពីខ្លឹមសារមេរៀនក្នុងស្រុក ឬលើការបង្រៀនជាមួយបេតិកភណ្ឌត្រូវបានដាក់ឱ្យដំណើរការនោះ ក្រសួង ឬសាលាត្រូវផ្សព្វផ្សាយនូវសារសំខាន់ៗជាមុន។ គោលនយោបាយនេះអាចធ្វើឡើងតាមរយៈការប្រជុំ ការចែកខិត្តបណ្ណ ផ្ទាំងរូបភាព ខ្លឹមសារប្រព័ន្ធផ្សព្វផ្សាយសង្គម ការផ្ញើសំបុត្រទៅមាតាបិតាសិស្ស។ល។ លើសពីនេះ អាជ្ញាធរមូលដ្ឋានអាចអញ្ជើញគ្រូបង្រៀន អ្នកជំនាញក្នុងមូលដ្ឋាន សិស្សានុសិស្ស និងសមាជិកគ្រួសាររបស់ពួកគេមកផ្តល់យោបល់ និងផ្តល់ព័ត៌មាន ដើម្បីជួយបង្កើតកម្មវិធីអប់រំថ្មី។ ដូចគ្នានេះផងដែរ អ្នកគ្រប់គ្រងសាលាអាចពិនិត្យមើលគោលនយោបាយក្នុងមូលដ្ឋាន និងថ្នាក់ជាតិនៅក្នុងបរិបទនៃការសិក្សារបស់ពួកគេដើម្បីពិនិត្យមើលពីរបៀបដែលសិស្សអាចទទួលបានអត្ថប្រយោជន៍ប្រសើរបំផុតពីគោលនយោបាយនេះ។



### គោលនយោបាយលើកកម្ពស់បេតិកភណ្ឌរស់នៅតាមសាលា (ប្រទេសចិន)

រដ្ឋាភិបាលសៀងហៃគាំទ្រយ៉ាងសកម្មនូវគំនិតផ្តួចផ្តើម ដើម្បីលើកកម្ពស់បេតិកភណ្ឌរស់នៅតាមសាលា។ ជាពិសេស ការិយាល័យវប្បធម៌ និងអប់រំក្រុង និងការិយាល័យបេតិកភណ្ឌវប្បធម៌អរូបីស្រុកផ្តល់ការណែនាំសម្រាប់ការអភិវឌ្ឍកម្មវិធីអប់រំ ដែលលើកកម្ពស់បេតិកភណ្ឌរស់។ សាលាក៏អាចដាក់ពាក្យស្នើសុំមូលនិធិពិសេស សម្រាប់ជំនួយហិរញ្ញវត្ថុប្រចាំឆ្នាំផងដែរ និងជួលអ្នកអនុវត្តបេតិកភណ្ឌឱ្យមកបង្រៀនសម្រាប់វគ្គសិក្សាមួយចំនួន។

## អនុញ្ញាតឱ្យមានភាពបត់បែន និងភាពប្រែប្រួលនៃគោលនយោបាយ

គោលនយោបាយត្រូវមានភាពបត់បែន ត្រូវធ្វើការកែសម្រួលនៅពេលដែលស្ថានភាពផ្លាស់ប្តូរ ឬនៅពេលដែលមានតម្រូវការថ្មីកើតឡើង។ ដូច្នេះ ក្រសួងអប់រំគួរបង្កើតយន្តការ ដើម្បីប្រមូល**មតិកែលម្អ** និងសំណូមពរ (លើគោលនយោបាយដែលមានស្រាប់ និងការអនុវត្តរបស់ពួកគេ) ចាប់ពីគ្រូបង្រៀន និងបុគ្គលិកសាលា និងពីសិស្សានុសិស្ស និងក្រុមគ្រួសាររបស់ពួកគេ។ យន្តការផ្តល់មតិកែលម្អនេះអាចរួមបញ្ចូល **ការស្ទង់មតិលើគ្រូបង្រៀន**ប្រចាំឆ្នាំបង្កើត**ក្រុមការងារតាមប្រធានបទ** ឬ **វេទិកាអនឡាញ**ជាដើម ដើម្បីប្រមូលមតិកែលម្អ និងជំរុញឱ្យសាលារៀបចំ**ការប្រជុំប្រមូលព័ត៌មាន**ជាមួយបុគ្គលិករបស់ពួកគេ។

> គោលនយោបាយត្រូវមានភាពបត់បែន ត្រូវធ្វើការកែសម្រួលនៅពេលដែលស្ថានភាពផ្លាស់ប្តូរ ឬនៅពេលដែលមានតម្រូវការថ្មីកើតឡើង។

ព័ត៌មានដែលប្រមូលបានតាមវិធីទាំងនេះនឹងជួយកំណត់ថា តើគួរធ្វើការកែសម្រួល ឬមិនគួរចំពោះគោលនយោបាយនេះ។ ឧទាហរណ៍ បើទោះជាសុវត្ថិភាពសាលាមានសារៈសំខាន់បំផុតក្តី ក៏វិធាននិងគោលនយោបាយសុវត្ថិភាព ជួនកាលអាចកាត់បន្ថយឱកាសអនុវត្តសកម្មភាព និងការសិក្សាផងដែរ។ ដូច្នេះ គោលនយោបាយសុវត្ថិភាពគួរត្រូវបានពិនិត្យជាប្រចាំដោយ**ក្រុមការងារ**ដែលរួមមានអ្នកជំនាញខាងគោលនយោបាយ គ្រូបង្រៀន និងបុគ្គលិកសាលា។ ក្រុមទាំងនេះត្រូវធ្វើការវាយតម្លៃអំពីតម្រូវការនិងហានិភ័យក្នុងតំបន់ ហើយធានាឱ្យមានតុល្យភាព រវាងបរិយាកាសប្រកបដោយសុវត្ថិភាព និងសកម្មភាពសិក្សា ដែលមានការចូលរួម និងសកម្មភាពសិក្សាប្រកបដោយប្រសិទ្ធភាព។

## គាំទ្រវិធីសាស្ត្រ និងយន្តការចែករំលែកធនធាន

**វេទិកាព័ត៌មាន** អាចជាមធ្យោបាយដ៏មានសារៈប្រយោជន៍សម្រាប់គ្រូបង្រៀនក្នុងការចែករំលែកមេរៀនរបស់ពួកគេ រួមទាំងមេរៀនប្រកបដោយនវានុវត្តន៍ ដែលទាក់ទងនឹងបេតិកភណ្ឌវប្បធម៌អរូបី។ វេទិកាបែបនេះក៏មានប្រយោជន៍សម្រាប់ការរក្សាទុកធនធាននៅកន្លែងតែមួយ និងសម្រាប់ការផ្សព្វផ្សាយព័ត៌មានស្តីពីឱកាសកសាងសមត្ថភាពផងដែរ។ ដូចនេះវេទិកាទាំងនេះ គឺជាអ្វីដែលក្រសួងអប់រំគួរគាំទ្រ។

ក្រសួងក៏គួរជំរុញដល់អ្នកអនុវត្ត ដែលមកពីវិស័យវប្បធម៌ឱ្យសហការជាមួយវិស័យអប់រំដោយបង្កើត**មូលដ្ឋានទិន្នន័យ**សម្រាប់អ្នកអនុវត្តបេតិកភណ្ឌវប្បធម៌ដែលលើកឡើងពីជំនាញរបស់ពួកគេ និងកម្មវិធីអប់រំដែលមានស្រាប់ណាមួយដែលពួកគេបានផ្តល់ជូន។ មូលដ្ឋានទិន្នន័យនេះនឹងក្លាយជាប្រភពដ៏មានសារៈប្រយោជន៍ ដែលសាលាអាចពិគ្រោះយោបល់នៅពេលស្វែងរកដៃគូសម្រាប់សកម្មភាពអប់រំអំពីបេតិកភណ្ឌ។



**ការបញ្ចូលបេតិកភណ្ឌរស់**

ទៅក្នុងការសិក្សានៅអាស៊ីប៉ាស៊ីហ្វិក

សៀវភៅណែនាំ

**កូនសៀវភៅ**

**8**

# ឯកសារ និងធនធាន

**សៀវភៅនេះ** មានបំណងជួយគាំទ្រគ្រូបង្រៀន អ្នកគ្រប់គ្រងក្នុងវិស័យអប់រំ និងសហគមន៍ក្នុងការដាក់បញ្ចូលបេតិកភណ្ឌក្នុងស្រុក ទៅក្នុងសកម្មភាពសិក្សា ឲ្យកាន់តែមានភាពប្រទាក់ក្រឡាគ្នា និងមានការចូលរួមកាន់តែច្រើនពីសំណាក់សិស្សានុសិស្ស និងការពារបេតិកភណ្ឌវប្បធម៌។

សៀវភៅនេះ មានកូនសៀវភៅចំនួនប្រាំបួន៖

- កូនសៀវភៅ 1 តើបេតិកភណ្ឌរស់ជាអ្វី ?
- កូនសៀវភៅ 2 ហេតុអ្វីត្រូវបង្រៀនជាមួយបេតិកភណ្ឌរស់ ?
- កូនសៀវភៅ 3 ការរៀបចំឱ្យត្រូវគ្នាជាមួយអាទិភាពអប់រំ
- កូនសៀវភៅ 4 វិធីសាស្រ្តប្រាំមួយជំហានសម្រាប់ជាមគ្គុទេសក៍ដល់គ្រូបង្រៀន
- កូនសៀវភៅ 5 តួនាទីរបស់ឪពុកម្ដាយ អាណាព្យាបាល និងសមាជិកសហគមន៍
- កូនសៀវភៅ 6 តួនាទីរបស់ថ្នាក់គ្រប់គ្រងសាលា
- កូនសៀវភៅ 7 តួនាទីរបស់អ្នករៀបចំគោលនយោបាយ
- ▶ កូនសៀវភៅ 8 **ឯកសារ និងធនធាន**
- កូនសៀវភៅ 9 សាច់រឿងរបស់គ្រូបង្រៀន

កូនសៀវភៅ

8

# ឯកសារ និងធនធាន

សៀវភៅណែនាំនេះផ្តល់នូវឯកសារនិងធនធានដែលអ្នកអាចប្រើបាននៅពេលអនុវត្តវិធីសាស្ត្រនៃការបញ្ចូលបេតិកភណ្ឌរស់នៅតាមសាលា។

**សៀវភៅណែនាំនេះមានផ្នែកដូចខាងក្រោម៖**

- ធនធាន
- ឯកសារទី១៖ ផែនការមេរៀនគំរូ៖ តើបេតិកភណ្ឌរស់ជាអ្វី?
- ឯកសារទី២៖ការផ្តល់យោបល់មួយចំនួនសម្រាប់ការភ្ជាប់ប្រធានបទសិក្សាបេតិកភណ្ឌរស់ និងការអប់រំអំពីភាពជាពលរដ្ឋសាកល
- ឯកសារទី ៣៖ ឧទាហរណ៍នៃផែនការមេរៀនដែលបានសាកល្បង និងធ្វើតេស្ត
- ឯកសារទី ៤៖ ការប្រមូលព័ត៌មាន
- ឯកសារទី ៥៖ ការបង្រៀនជាមួយបេតិកភណ្ឌរស់នៅក្នុងថ្នាក់រៀនពហុវប្បធម៌
- ឯកសារទី ៦៖ ចម្លើយចំពោះសំណួរដែលអ្នកប្រហែលជាមាន
- ឯកសារទី៧៖សន្លឹកកិច្ចការ៖ បង្កើតផែនការមេរៀនផ្ទាល់ខ្លួនរបស់អ្នកដោយភ្ជាប់បេតិកភណ្ឌរស់ និងសកម្មភាពរបស់សាលា



# ធនធាន

## ICH ប្រភពព័ត៌មានអំពីបេតិកភណ្ឌវប្បធម៌អរូបី

ព័ត៌មានអំពីបេតិកភណ្ឌរស់ និងកម្មវិធីការពារអាចរកបានពីប្រភពខាងក្រោម៖

***គេហទំព័រយូណេស្កូ***

- CLICK តើបេតិកភណ្ឌវប្បធម៌អរូបីជាអ្វី?
- CLICK បញ្ជីរបស់អង្គការយូណេស្កូ៖ បេតិកភណ្ឌរស់ ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។
- CLICK សូមចូលមើល UNESCO ដាក់បញ្ចូលទៅក្នុងបេតិកភណ្ឌវប្បធម៌អរូបី

***តំណភ្ជាប់ ICHCAP***

- CLICK ICHCAP

## ប្រភពនៃការតភ្ជាប់បេតិកភណ្ឌវប្បធម៌អរូបី និងការអប់រំ

វីដេអូឃ្លីបពីគម្រោងបេតិកភណ្ឌវប្បធម៌អរូបីនៅតាមសាលានៅតំបន់អឺរ៉ុប

- CLICK Glöcklerlauf in physics and computer aided design classes
- CLICK O Merdeiro in geography, music and art classes
- CLICK Japanese Hanga printing in art and math classes

- CLICK ស៊េរីវីដេអូគំនូរជីវចល៖
  វីដេអូទាំងនេះមានជាភាសា: [អង់គ្លេស] [ខ្មែរ] [កូរ៉េ] [នេប៉ាល់] [រុស្ស៊ី] [ថៃ] [ឡាវ] [ភូមា]
- CLICK វគ្គសិក្សាតាមអនឡាញ (រៀនដោយខ្លួនឯង ដោយឥតគិតថ្លៃនៅលើវេទិកា GCED Online Campus)
- CLICK កន្លែងរក្សាទុកមេរៀនដោយការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបី
- CLICK ការបង្រៀន និងរៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបីនៅតំបន់អាស៊ីប៉ាស៊ីហ្វិក៖ របាយការណ៍ស្ទង់មតិ
- CLICK ការសិក្សាបេតិកភណ្ឌអរូបីសម្រាប់អនាគតប្រកបដោយចីរភាព៖ គោលការណ៍ណែនាំសម្រាប់អ្នកអប់រំនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក [អង់គ្លេស] [រុស្ស៊ី] [អ៊ូសបេគីស្ថាន]

CLICK គោលការណ៍ណែនាំសម្រាប់គម្រោង "ការរួមចំណែករបស់បេតិកភណ្ឌវប្បធម៌អរូបីឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព" សម្រាប់ការអប់រំក្នុងប្រព័ន្ធនៅប្រទេសវៀតណាម

CLICK ការស្រាវជ្រាវលើការរួមចំណែករបស់បេតិកភណ្ឌវប្បធម៌អរូបីចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព៖ របាយការណ៍គម្រោងស្តីពីការអប់រំ និងការអភិវឌ្ឍសហគមន៍ឆ្នាំ 2020-2021

## ប្រភពព័ត៌មានអំពីការអប់រំពលរដ្ឋសាកល

CLICK មូលដ្ឋានទិន្នន័យអនឡាញរបស់អង្គការយូណេស្កូស្តីពីការអប់រំពលរដ្ឋសាកល

CLICK ការអប់រំពលរដ្ឋសាកល៖ ប្រធានបទ និងវត្ថុបំណងនៃការសិក្សា

CLICK ការរៀបចំគ្រូបង្រៀនសម្រាប់ការអប់រំជាពលរដ្ឋសាកល៖ ទម្រង់គំរូ

CLICK ការអប់រំជាពលរដ្ឋសកល៖ មគ្គុទ្ទេសក៍សម្រាប់អ្នកបណ្តុះបណ្តាល

### ធនធាន APCEIU

CLICK ការផ្សារភ្ជាប់ភាពជាពលរដ្ឋសាកល និងបេតិកភណ្ឌពិភពលោក

CLICK ការរស់នៅជាមួយនឹងទឹក បេតិកភណ្ឌ និងហានិភ័យ៖ ឯកសារជំនួយស្មារតីរបស់អ្នកអប់រំសម្រាប់ភាពជាពលរដ្ឋសាកល

CLICK ការយល់ដឹងអំពី GCED នៅអាស៊ីប៉ាស៊ីហ្វិក៖ ការណែនាំអំពីរបៀបនៃ "ការអនុវត្តក្នុងស្រុក" (APCEIU ឆ្នាំ២០២០)

CLICK ការគិត ការសង្កត់ធ្ងន់ ការធ្វើសកម្មភាព៖ ប្រជាពលរដ្ឋសាកល ការប្រមូលផ្តុំ! (APCEIU ឆ្នាំ ២០២១) សៀវភៅណែនាំសម្រាប់គ្រូ និងសៀវភៅកិច្ចការសម្រាប់សិស្សជាភាសាអង់គ្លេស ឥណ្ឌូនេស៊ី ខ្មែរ ឡាវ ម៉ុងហ្គោលី
[សៀវភៅណែនាំសម្រាប់គ្រូ] [សៀវភៅកិច្ចការសម្រាប់សិស្ស]

CLICK GCED Online Campus

CLICK បើកវគ្គសិក្សាស្តីពី GCED

CLICK ការបង្រៀនពិសេស (ស្តីពី GCED និងប្រធានបទពាក់ព័ន្ធ)

CLICK GCEDផ្តោតលើកំណត់ហេតុ (ខ្លឹមសារខ្លីៗស្តីពី GCED និងប្រធានបទដែលពាក់ព័ន្ធដូចជាវីដេអូឃ្លីប ឯកសារផ្ទាំងរូបភាព ។ល។)

CLICK តើការអប់រំពលរដ្ឋសាកលគឺជាអ្វី?

CLICK គោលការណ៍គរុកោសល្យនៃ GCED

CLICK GCED ក្នុងការអនុវត្ត (ឧទាហរណ៍ស្តីពីការអនុវត្ត GCED)

## ប្រភពព័ត៌មានអំពីដំណើរការអប់រំ

ព័ត៌មានអំពីវិធីសាស្ត្របង្រៀនអាចរកបានពីប្រភពដូចខាងក្រោម៖

***កម្មវិធីគរុកោសល្យសកម្ម***

មជ្ឈមណ្ឌលស្រាវជ្រាវអំពីសកម្មភាពរៀន និងបង្រៀន (CRLT)៖

- CLICK យុទ្ធសាស្ត្របង្រៀន៖
- CLICK តើសកម្មភាពរៀនសកម្មគឺជាអ្វី?
- CLICK Teach.com

Teach Thought:

- CLICK Miriam Clifford, សំខាន់សិក្សាបែបសហការ និងយុទ្ធសាស្ត្រសម្រាប់គ្រូទាំង ២០៖
- CLICK វិធីបង្កើតសកម្មភាពសិក្សាបែបរិះរកនៅក្នុងថ្នាក់រៀន

ចក្ខុវិស័យរបស់គ្រូ៖

- CLICK ការរៀនបែបសហការ៖

***ការគ្រប់គ្រងថ្នាក់រៀន***

- CLICK អង្គការយូណេស្កូ ឆ្នាំ២០០៦៖ សកម្មភាពជាក់ស្តែងសម្រាប់ការបង្រៀនថ្នាក់ដែលមានសិស្សច្រើន៖ សៀវភៅណែនាំសម្រាប់គ្រូ
- CLICK អង្គការយូណេស្កូ ឆ្នាំ២០០៩៖ ការទទួលយកភាពចម្រុះគ្នា៖ ឯកសារជំនួយស្មារតីសម្រាប់បង្កើតបរិយាកាសប្រកបដោយបរិយាបន្ន និងអំណោយផលដល់ការសិក្សា

***សមភាពយេនឌ័រនៅក្នុងថ្នាក់រៀន***

- CLICK អង្គការយូណេស្កូ ឆ្នាំ២០១៩៖ ឯកសារជំនួយស្មារតីស្តីពីយេនឌ័រក្នុងការអប់រំនៅតំបន់អាស៊ីប៉ាស៊ីហ្វិក (GENIA)៖ ការលើកកម្ពស់សមភាពយេនឌ័រក្នុងការអប់រំ

## ឯកសារទី ១៖ គំរូកិច្ចតែងការបង្រៀន៖ តើបេតិកភណ្ឌរស់ជាអ្វី ?

| | |
|---|---|
| **គំនិតសំខាន់** | បេតិកភណ្ឌរស់នៅមានលក្ខណៈចម្រុះផ្សេងៗគ្នា។<br>យើងត្រូវថែរក្សាបេតិកភណ្ឌនេះឱ្យនៅមានជីវិតរស់ជានិច្ច ពីព្រោះបេតិកភណ្ឌនេះអាចជួយសហគមន៍ឱ្យកំណត់អត្តសញ្ញាណរបស់ខ្លួនបាន។ |
| **ទស្សនាទានសំខាន់** | • **បេតិកភណ្ឌរូបី៖** ប្រសាទ ទីកន្លែង និងវត្ថុនានាដែលដូនតាយើងបានបន្សល់ទុកឱ្យ ហើយយើងចង់ថែរក្សាឱ្យបានគង់វង្សយូរអង្វែងបន្តទៀត។<br>• **បេតិកភណ្ឌវប្បធម៌អរូបី (ICH) = បេតិកភណ្ឌរស់៖** ប្រពៃណី ចំណេះដឹងជំនាញដែលយើងមាន ជាបេតិកភណ្ឌបន្តពីដូនតាយើង ដែលយើងកំពុងតែអនុវត្តតាម និងផ្ទេរបន្តទៅអ្នកជំនាន់ក្រោយ ពីព្រោះវាមានសារៈសំខាន់សម្រាប់យើង និងសហគមន៍របស់យើងជាខ្លាំង។<br>• **សហគមន៍៖** ជាមនុស្សមួយក្រុម មិនថា ក្រុមតូចក្ដី ឬធំក្ដី ដែលប្រតិបត្តិតាម ឬមានអារម្មណ៍ថាមានទំនាក់ទំនងជិតជាប់ជាមួយនឹងបេតិកភណ្ឌរស់ជាក់លាក់ណាមួយ។<br>• **កិច្ចគាំពារ៖** ធានាថា សហគមន៍ទាំងអស់អាចបន្តអនុវត្ត និងផ្ទេរបេតិកភណ្ឌវប្បធម៌អរូបីរបស់ខ្លួនក្នុងលក្ខណៈមួយដែលមានអត្ថន័យសម្រាប់ពួកគេ។ |
| **ចំនួនវគ្គ/ចំនួនមេរៀន** | ១ ទៅ ៣ វគ្គ (១ វគ្គ ប្រហែល ៥០ នាទី) |
| **កម្រិត** | បឋមសិក្សាទុតិយភូមិ/មធ្យមសិក្សាបឋមភូមិ |
| **សម្ភារៈនិងឧបករណ៍ចាំបាច់** | • ផ្ទាំងក្រដាស ឬក្ដារខៀន<br>• ក្រដាសបិទតូចៗ ឬកាត់<br>• ហ្វឺត ស្កុត<br>• ឧបករណ៍វីដេអូ និងប្រព័ន្ធអ៊ីនធឺណិតសម្រាប់បញ្ចាំងរូបភាព និង/ឬចាក់វីដេអូឃ្លីប ប្រសិនបើត្រូវការប្រើប្រាស់ (ឬឯកសារជាក្រដាសដែលមានខ្លឹមសារស្រដៀងគ្នា)<br>• ឯកសារចែកជូនសម្រាប់ប្រើប្រាស់ ឬចែកជូនក្នុងថ្នាក់<br>• វត្ថុដែលជាបេតិកភណ្ឌ (មានក៏បានអត់ក៏បាន) |
| **ចំណេះដឹងដែលត្រូវមានជាមុន** | មិនចាំបាច់មានចំណេះដែលត្រូវដឹងជាមុននោះទេ។ |

## គោលបំណងមេរៀន

### *វិជ្ជាសម្បទា*

- យល់ដឹងថាអ្វីជាបេតិកភណ្ឌ និងស្គាល់ទម្រង់ផ្សេងៗគ្នារបស់សម្បត្តិបេតិកភណ្ឌ
- យល់ដឹងអំពីបេតិកភណ្ឌរស់របស់ខ្លួន
- ពន្យល់អំពីសារសំខាន់នៃការថែរក្សាការពារសម្បត្តិបេតិកភណ្ឌ

### *បំណិនសម្បទា*

- ចេះបែងចែកប្រភេទបេតិកភណ្ឌទៅតាមលក្ខណវិនិច្ឆ័យផ្សេងៗគ្នាជាច្រើន
- ប្រមូលព័ត៌មាន (តាមរយៈការសម្ភាសន៍) និងធ្វើបទបង្ហាញអំពីព័ត៌មាន

### *ចរិយាសម្បទា*

- ផ្តល់តម្លៃដល់ភាពចម្រុះគ្នារបស់បេតិកភណ្ឌរស់
- មានការចំណាប់អារម្មណ៍ចំពោះបេតិកភណ្ឌរស់ ហើយបើកចិត្តទូលាយចំពោះបេតិកភណ្ឌរស់របស់ខ្លួន និងអ្នកដទៃ

## សកម្មភាព

### វគ្គទី ១៖

កំណត់សម្គាល់៖ វគ្គនេះអាចនឹងបន្ថែមម៉ោងទៅជាពីរវគ្គបន្ថែមទៀត ដើម្បីដាក់បញ្ចូលនូវការទស្សនាវីដេអូមួយចំនួនស្តីពីសមាសធាតុរបស់បេតិកភណ្ឌវប្បធម៌អរូបី និងការស្វែងយល់អំពីគេហទំព័រ "Dive into ICH"។ ម៉ោងសម្រាប់លេងល្បែងតម្រៀប និងការពិភាក្សាក៏ត្រូវបន្ថែមផងដែរ។

| # | សកម្មភាព | ឯកសារគាំទ្រ |
|---|---|---|
| 1<br>៥ នាទី | **សកម្មភាពទាញចំណាប់អារម្មណ៍៖ បេតិកភណ្ឌ**<br>១.១ ឱ្យសិស្សពន្យល់ថាតើពាក្យថា "បេតិកភណ្ឌ" មានអត្ថន័យយ៉ាងដូចម្តេចចំពោះពួកគេ<br>១.២ សិស្សម្នាក់ៗត្រូវសរសេរឧទាហរណ៍យ៉ាងតិចចំនួនបីអំពីបេតិកភណ្ឌនៅលើក្រដាសបិទតូចៗ ឬនៅលើកាត។<br>១.៣ សិស្សយកក្រដាសបិទតូចៗ ឬកាតរបស់ខ្លួនទៅបិទនៅលើក្តារខៀន | • ផ្ទាំងក្រដាស ឬក្តារខៀន<br>• ក្រដាសបិទតូចៗ ឬកាត និងស្កុត<br>• ហ្វឺត |

| # | សកម្មភាព | ឯកសារគាំទ្រ |
| --- | --- | --- |
| 2<br>១០ នាទី | **គ្រូពន្យល់មេរៀន៖ បេតិកភណ្ឌ**<br>២.១ តើបេតិកភណ្ឌជាអ្វី?<br>២.២ ភាពខុសគ្នារវាងបេតិកភណ្ឌរូបី និង បេតិកភណ្ឌអរូបី<br>៣.៣ លក្ខណសម្បត្តិរបស់បេតិកភណ្ឌវប្បធម៌អរូបី (ICH) | • កំណត់ត្រារបស់គ្រូទី ១<br>• បញ្ជីតំបន់បេតិកភណ្ឌពិភពលោក៖ Click<br>• ប្រាសាទប្រវត្តិសាស្ត្រនៅក្នុងប្រទេសរបស់អ្នក<br>• បញ្ជីសមាសធាតុបេតិកភណ្ឌវប្បធម៌អរូបីក្រោមអនុសញ្ញាឆ្នាំ២០០៣<br>• បញ្ជីសារពើភណ្ឌស្តីពីបេតិកភណ្ឌវប្បធម៌អរូបីថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន |
| 3<br>១៥ នាទី | **ល្បែងតម្រៀប៖ បេតិកភណ្ឌរូបី និងអរូបី**<br>៣.១ រៀបចំផ្នែកចំនួនពីរផ្សេងគ្នា (ឧ. ខណ្ឌជញ្ជាំងជាពីរ ឬគូរកូឡោនបញ្ឈរពីរនៅលើក្តារខៀន) ដែលមានចំណងជើងថា "បេតិកភណ្ឌរូបី" និង "បេតិកភណ្ឌអរូបី"<br>៣.២ អានចម្លើយដែលសិស្សបានសរសេរនៅលើកាតក្នុងពេលធ្វើសកម្មភាពទាញចំណាប់អារម្មណ៍ ឬចម្លើយដែលអ្នកបានរៀបចំទុកមុន<br>៣.៣ បន្ទាប់មកឱ្យសិស្សដាក់សមាសធាតុនោះនៅក្រោមប្រភេទទាំងពីរ៖ បេតិកភណ្ឌវប្បធម៌រូបី និងបេតិកភណ្ឌវប្បធម៌អរូបី<br>3.4 ការពិភាក្សា ការសួរសំណួរ ឧទាហរណ៍៖<br>– តើការដាក់សមាសធាតុរូបី និង អរូបីឱ្យនៅដាច់ដោយឡែកពីគ្នាមានភាពងាយស្រួលឬទេ?<br>– តើប្រភេទទាំងពីរនេះមានភាពខុសគ្នាខ្លាំងដែរឬទេ ឬក៏មានភាពដូចគ្នាដែរ? | • សញ្ញាចំនួនពីរ៖ បេតិកភណ្ឌរូបី / បេតិកភណ្ឌអរូបី<br>• ចម្លើយនៅលើកាតដែលសិស្សបានសរសេរក្នុងអំឡុងពេលសកម្មភាពទាញចំណាប់អារម្មណ៍<br>• បន្ថែមពីនេះ ត្រូវត្រៀមរៀបចំកាត ទុកជាមុន ដោយមានសរសេរឧទាហរណ៍អំពីសមាសធាតុបេតិកភណ្ឌខ្លះៗដែលសិស្សធ្លាប់បានស្គាល់ ដូចជា វត្ថុសិល្បៈល្បីៗ ការដំណាលតៗគ្នា រឿងនិទាន និងចម្រៀង សិប្បកម្ម ក្នុងមូលដ្ឋាន ប្រាសាទ ឬកន្លែងណាមួយ។ល។<br>ឬ<br>• ឯកសារចែកជូនទី ១៖ តើមួយណាដែលអាចពង្រីក ឬផលិតឡើងវិញបាន។ |

| # | សកម្មភាព | ឯកសារគាំទ្រ |
|---|---|---|
| 4<br>១០ នាទី | **គ្រូពន្យល់មេរៀន៖ បេតិកភណ្ឌវប្បធម៌អរូបី (បេតិកភណ្ឌរស់)**<br>៤.១ បេតិកភណ្ឌរស់មានភាពចម្រុះច្រើន<br>៤.២ កិច្ចការពារបេតិកភណ្ឌរស់៖ ហេតុអ្វី និង ដោយរបៀបណា?<br>– ពិភាក្សាបំផុសគំនិតសិស្សថាតើ ហេតុអ្វីបានជាបេតិកភណ្ឌរស់មាន សារៈសំខាន់ចំពោះពួកគេ<br>៤.៣ តួនាទីរបស់សហគមន៍ | • កំណត់ត្រារបស់គ្រូទី ២<br>• រូបថត ឬឃ្លីបវីដេអូខ្លីៗដែល បង្ហាញអំពីផ្នែកទាំងប្រាំ (ឬ ច្រើនជាងនេះ) នៃបេតិកភណ្ឌ វប្បធម៌អរូបី<br>• វីដេអូគំនូរជីវចល (រហូតដល់ ០១:៣៩) ម៉ោង (មានក៏បាន អត់ក៏បាន) CLICK<br>• ឯកសារចែកជូនទី ២៖ តើ បេតិកភណ្ឌរស់ជាអ្វី? (យកល្អ គួរតែប្រើរូបថតនៃ ការអនុវត្តបេតិកភណ្ឌវប្បធម៌ អរូបីក្នុងស្រុក) |
| 5<br>១០ នាទី | **បេតិកភណ្ឌរស់ដ៏សម្បូរបែបរបស់យើង**<br>៥.១ ជ្រើសរើសឧទាហរណ៍ពីមុនៗមកប្រើ (ឧទាហរណ៍នៅក្នុងល្បែងតម្រៀប) ហើយ ធ្វើការពិភាក្សាថាតើផ្នែកនោះ ស្ថិតនៅក្នុង ប្រភេទណាខ្លះ។<br>៥.២ ពន្យល់ថាបេតិកភណ្ឌរស់មួយចំនួនអាច ចាត់ថ្នាក់ទៅតាមផ្នែកជាច្រើន។<br>៥.៣ បំផុសឱ្យសិស្សលើកឧទាហរណ៍បន្ថែម អំពីបេតិកភណ្ឌរស់នៅក្នុងផ្នែកជាច្រើន ខុសគ្នា។<br>៥.៤ ប្រសិនបើមានពេលគ្រប់គ្រាន់ សូម ស្វែងរកតាមគេហទំព័រ ICH ។ សិស្សអាច លើកឡើងអំពីប្រធានបទ ឬប្រទេសដែល ពួកគេចាប់អារម្មណ៍។ | • សូមចូលមើលបេតិកភណ្ឌ វប្បធម៌អរូបីតាមរយៈ៖ CLICK |

| # | សកម្មភាព | ឯកសារគាំទ្រ |
| --- | --- | --- |
| 6<br>៥ នាទី | **បិទវគ្គ**<br>៦.១ សង្ខេបចំណុចសំខាន់ៗក្នុងមេរៀនឡើងវិញ<br>- ភាពខុសគ្នារវាងបេតិកភណ្ឌរូបី និង បេតិកភណ្ឌអរូបី<br>- បេតិកភណ្ឌអរូបី គឺជាបេតិកភណ្ឌរស់ និងមានលក្ខណៈចម្រុះផ្សេងៗគ្នា<br>- តួនាទីរបស់សហគមន៍ (ជាចំណុចអន្តរកាលក្នុងការណែនាំអំពីសកម្មភាពបន្តធ្វើនៅផ្ទះដោយមានសហគមន៍ចូលរួម)<br>៦.២ កិច្ចការផ្ទះ៖ គម្រោង "បេតិកភណ្ឌរស់របស់ខ្ញុំ"<br>- ណែនាំអំពីសកម្មភាពបន្តធ្វើនៅផ្ទះដែលបានស្នើឡើង៖ សកម្មភាពទី ១ គម្រោង "បេតិកភណ្ឌរស់របស់ខ្ញុំ"<br>- ចែកឯកសារទី ៣ ការណែនាំអំពីការប្រមូលព័ត៌មាន និងបទបង្ហាញដែលសិស្សត្រូវធ្វើតាមក្រុម។<br>- ពន្យល់ថា កិច្ចការផ្ទះនេះគឺជាលំហាត់នៃការចងក្រងឯកសារ ដែលរួមចំណែកដល់ការលើកកម្ពស់ការយល់ដឹង និងកិច្ចការពារថែរក្សាបេតិកភណ្ឌរស់។ | • ឯកសារចែកជូនទី ៣៖ "បេតិកភណ្ឌរស់របស់ខ្ញុំ"<br>• ឯកសារទី ៤៖ ការប្រមូលព័ត៌មាន |

**វគ្គទី ២៖**

| # | សកម្មភាព | ឯកសារគាំទ្រ |
|---|---|---|
| 7<br>៥ - ១០ នាទី | **សកម្មភាព**<br>៧.១ សិស្សម្នាក់ៗត្រូវសរសេរពាក្យបំពេញចន្លោះក្នុងឃ្លាលើឯកសារចែកជូនទី ៤<br>៧.២. សិស្សត្រូវពិនិត្យចម្លើយជាមួយដៃគូ និង/ឬពិភាក្សាចម្លើយក្នុងថ្នាក់ទាំងមូល<br>ចម្លើយ៖ *រស់ / ជំនាន់ / ជំនាន់ / ប្រែប្រួល / មានអត្ថន័យ / ជារបស់ខ្លួន / សហគមន៍ / ត្រូវបានការពារ / ធម្មជាតិ / ទម្លាប់អនុវត្តក្នុងសង្គម*<br>៧.៣ បញ្ជាក់អំពីការយល់ឃើញមួយចំនួនដែលសិស្សមិនទាន់យល់ច្បាស់ | • ឯកសារចែកជូនទី ៤៖ លំហាត់បំពេញចន្លោះក្នុងឃ្លាស្ដីពីបេតិកភណ្ឌវប្បធម៌អរូបី |
| 8<br>៣០ - ៣៥ នាទី | បទបង្ហាញអំពីបេតិកភណ្ឌវប្បធម៌អរូបី<br>៨.១ សិស្សទាំងអស់ ឬក្រុមនីមួយៗ ត្រូវធ្វើបទបង្ហាញអំពីសមាសធាតុរបស់បេតិកភណ្ឌវប្បធម៌អរូបីដែលត្រូវបានជ្រើសរើស<br>៨.២ ការពិភាក្សាក្នុងថ្នាក់<br>– សិស្សដែលយល់អំពីសមាសធាតុបេតិកភណ្ឌវប្បធម៌អរូបីដែលសិស្សក្រុមផ្សេងបានធ្វើបទបង្ហាញ អាចចែករំលែកបទពិសោធន៍របស់ខ្លួនបាន<br>– សិស្សដែលយល់ដឹងអំពីសមាសធាតុស្រដៀងគ្នា ឬខុសគ្នាបន្តិចបន្តួចដែលសហគមន៍ផ្សេងៗកំពុងអនុវត្តអាចចែករំលែកចំណេះដឹងរបស់ពួកគេ និងពិភាក្សាអំពីភាពស្រដៀងគ្នា និងភាពខុសគ្នានោះ<br>*កំណត់សម្គាល់៖ ជាការសំខាន់ សិស្សត្រូវចែករំលែកគំនិតយោបល់របស់ខ្លួនក្នុងលក្ខណៈមួយបើកចំហ និងមានការគោរពគ្នាទៅវិញទៅមក។* | • បទបង្ហាញរបស់សិស្ស<br>*មុននឹងចាប់ផ្ដើមមេរៀន សិស្សត្រូវប្រាប់គ្រូឱ្យបានដឹងថា តើបរិក្ខារពិសេសអ្វីខ្លះដែលគេត្រូវការចាំបាច់សម្រាប់ធ្វើបទបង្ហាញរបស់ខ្លួន។* |

| # | សកម្មភាព | ឯកសារគាំទ្រ |
|---|---|---|
| 9<br>១០ នាទី | **បិទវគ្គ**<br>៩.១ សង្ខេបអំពីចំណុចសំខាន់ៗក្នុងមេរៀនឡើងវិញ<br>- បេតិកភណ្ឌរស់មានលក្ខណៈចម្រុះ<br>- សហគមន៍មានតួនាទីមួយដ៏សំខាន់៖ ពួកគេអនុវត្ត និងផ្ទេរបេតិកភណ្ឌរបស់ខ្លួនទៅអ្នកជំនាន់ក្រោយ<br>- យើងទាំងអស់គ្នាមានបេតិកភណ្ឌរស់ដ៏សម្បូរបែប៖ វាជួយយើងក្នុងការកំណត់អត្តសញ្ញាណរបស់យើង។ យើងត្រូវតែថែរក្សាការពារបេតិកភណ្ឌរបស់យើង។<br>- យើងក៏ត្រូវគោរព និងឱ្យតម្លៃដល់បេតិកភណ្ឌរស់របស់មនុស្សដទៃផងដែរ<br>៩.២ ពិភាក្សាជាមួយសិស្សថាតើពួកគេចង់អនុវត្តគម្រោងណាមួយដែលបានស្នើឡើងក្នុងអំឡុងពេលធ្វើបទបង្ហាញជាក្រុមដែរឬទេ | |

## ការវាយតម្លៃ

ការវាយតម្លៃអាចធ្វើឡើងដោយផ្អែកលើ៖

- ការចូលរួមក្នុងសកម្មភាពនានាក្នុងថ្នាក់រៀន (ល្បែងតម្រៀប ផ្នែក ។ល។)
- ចម្លើយចំពោះសកម្មភាពនោះ
- លទ្ធផលនៃការធ្វើបទបង្ហាញ

## សកម្មភាពសម្រាប់បន្តធ្វើនៅផ្ទះដែលបានណែនាំ៖

### *១. គម្រោង៖ "បេតិកភណ្ឌរស់របស់ខ្ញុំ"*

សិស្សត្រូវបែងចែកជាក្រុមតូចៗ រួចជ្រើសរើសបេតិកភណ្ឌរស់ណាមួយរៀងៗខ្លួន ហើយសម្ភាសន៍សមាជិកក្រុមគ្រួសារ ឬសហគមន៍របស់ខ្លួន ដោយសួរសំណួរដូចខាងក្រោម៖ (១) តើបេតិកភណ្ឌរស់ជាអ្វី? (២) តើមានការអនុវត្តបេតិកភណ្ឌរស់បែបណាខ្លះនៅក្នុងសហគមន៍? (៣) ហេតុអ្វីបានជាបេតិកភណ្ឌរស់មានសារៈសំខាន់ចំពោះសហគមន៍ និងចំពោះពួកគេ និង (៤) តើត្រូវធ្វើដូចម្ដេចដើម្បីធានាថាសមាសធាតុនេះអាចបន្តអនុវត្តតទៅមុខទៀតបាន (សិស្សអាច គិតអំពីសកម្មភាព ឬគម្រោងណាមួយដែលពួកគេអាចរៀបចំឡើងបាន)។ បន្ទាប់មក ពួកគេត្រូវធ្វើបទបង្ហាញរយៈពេល ៥ នាទី ដោយផ្អែកលើការឆ្លើយតបទៅនឹងសំណួរ និងព័ត៌មានផ្សេងទៀតដែលប្រមូលបាន។

សិស្សក៏អាចបង្កើតឃ្លីបវីដេអូ ផ្ទាំងរូបភាព ឬទម្រង់ច្នៃប្រឌិតផ្សេងទៀត ដើម្បីបង្ហាញអំពីលទ្ធផលរបស់ពួកគេ។

កំណត់សម្គាល់៖ នៅក្នុងបរិបទដែលមានវប្បធម៌ចម្រុះ សិស្សអាចរៀបចំបទបង្ហាញរបស់ពួកគេទៅតាមចំណង់ចំណូលចិត្តជាលក្ខណៈបុគ្គលជាជាងការធ្វើបទបង្ហាញជាក្រុម ឧទាហរណ៍ ក្នុងករណីដែលបេតិកភណ្ឌរស់របស់ពួកគេម្នាក់ៗមានលក្ខណៈខុសពីបេតិកភណ្ឌរបស់មិត្តរួមថ្នាក់ឯទៀត។

### *២. ពិព័រណ៍បេតិកភណ្ឌរស់*

លទ្ធផលនៃគម្រោង "បេតិកភណ្ឌរស់របស់ខ្ញុំ" អាចយកមកចងក្រងដាក់តាំងពិព័រណ៍នៅថ្ងៃពិសេសណាមួយរបស់សាលា ឧ. ការប្រារព្ធពិធីនៅថ្ងៃបញ្ចប់ឆ្នាំសិក្សាជាដើម។ ការប្រារព្ធទិវាពិភពលោកស្តីពីវប្បធម៌ចម្រុះសម្រាប់ការសន្ទនា និងការអភិវឌ្ឍ (ថ្ងៃទី២១ ខែឧសភា) ជាដើម ឬសម្រាប់ថ្ងៃពិសេសណាមួយនៅក្នុងសហគមន៍។

## ធនធានសម្រាប់ការសិក្សា

- សូមមើលពីបេតិកភណ្ឌវប្បធម៌អរូបីតាមរយៈ៖ CLICK
- បេតិកភណ្ឌវប្បធម៌អរូបី និងបញ្ជីអនុវត្តល្អៗក្រោមអនុសញ្ញាឆ្នាំ២០០៣ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌អរូបី CLICK
- បញ្ជីបេតិកភណ្ឌពិភពលោក៖ CLICK
- បញ្ជីតំបន់បេតិកភណ្ឌការពារ និងប្រាង្គប្រាសាទប្រវត្តិសាស្ត្រនៅក្នុងប្រទេសរបស់អ្នក
- បញ្ជីសារពើភណ្ឌស្តីពីបេតិកភណ្ឌវប្បធម៌អរូបីថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន

## កំណត់ត្រារបស់គ្រូ

### កំណត់ត្រារបស់គ្រូទី ១

***តើបេតិកភណ្ឌជាអ្វី?***

កំណត់សម្គាល់៖ ព័ត៌មាននេះ ដកស្រង់ចេញពីឯកសារ World Heritage in Young Hands៖ កញ្ចប់ធនធានអប់រំសម្រាប់គ្រូបង្រៀន (អង្គការយូណេស្កូ ឆ្នាំ២០០២)។

និយមន័យនៃបេតិកភណ្ឌ៖ បេតិកភណ្ឌគឺជាកេរដំណែលពីអតីតកាលរបស់យើង ជាអ្វីដែលយើងកំពុងរស់នៅជាមួយក្នុងពេលបច្ចុប្បន្ន និងជាអ្វីដែលយើងនឹងផ្ទេរបន្តទៅឱ្យមនុស្សជំនាន់ក្រោយទៀត។ បេតិកភណ្ឌវប្បធម៌ និងធម្មជាតិរបស់យើងសុទ្ធតែជាធនធានមិនអាចជំនួសបានសម្រាប់ការរស់នៅ និងក្តីសង្ឃឹមរបស់យើង។

អ្នកអាចចាត់ទុកបេតិកភណ្ឌនេះថាជាទីកន្លែង វត្ថុ ប្រពៃណីដែលយើងចង់ថែរក្សាផងដែរ។ យើងផ្តល់តម្លៃដល់បេតិកភណ្ឌទាំងនេះ ពីព្រោះបេតិកភណ្ឌគឺបានមកពីបុព្វការីជនរបស់យើង ហើយដោយសារវាជាផ្នែកដ៏សំខាន់មួយក្នុងជីវិតរស់នៅរបស់យើង ហើយយើងសង្ឃឹមថា កូនចៅរបស់យើងនឹងផ្តល់តម្លៃដល់សម្បត្តិទាំងអស់នេះផងដែរ។ សម្បត្តិទាំងនេះសុទ្ធតែមានសោភ័ណភាព មានសារៈសំខាន់ផ្នែកវិទ្យាសាស្ត្រ ឬសង្គម និង/ឬក៏ជាធនធានសម្រាប់ការរស់នៅ និងសេចក្តីសង្ឃឹមផងដែរ។ បេតិកភណ្ឌជាចំណុចដែលយើងតែងសម្លឹងឆ្ពោះទៅរកនៅក្នុងការគិត របស់យើង ហើយភ្ជាប់យើងទៅនឹងអត្តសញ្ញាណដែលសម្គាល់ថាយើងជាអ្នកណា។

***ភាពខុសគ្នារវាងបេតិកភណ្ឌរូបី និងបេតិកភណ្ឌអរូបី***

បេតិកភណ្ឌវប្បធម៌ចែកចេញជាពីរប្រភេទសំខាន់ៗ៖

- **បេតិកភណ្ឌវប្បធម៌រូបី៖** រូបី = អ្វីដែលយើងអាចប៉ះ ឬកាន់បាន
  - បេតិកភណ្ឌវប្បធម៌ចល័ត (ផ្ទាំងគំនូរ រូបចម្លាក់ កាក់ កម្រងសំណេរ)
  - បេតិកភណ្ឌវប្បធម៌អចល័ត (ប្រាង្គប្រាសាទ ទីតាំងបុរាណវិទ្យា និងទីតាំងផ្សេងៗទៀត)
  - បេតិកភណ្ឌវប្បធម៌ក្រោមទឹក (នាវាលិចទឹក ប្រាសាទបាក់បែក និងទីក្រុងលិចទឹក)
- **បេតិកភណ្ឌវប្បធម៌អរូបី៖** អរូបី = អ្វីដែលយើងមិនអាចប៉ះ ឬកាន់បាន
  - ប្រពៃណី ចំណេះដឹង ជំនាញ ដែលយើងមានជាមរតកពីបុព្វការីជនរបស់យើង ដែលយើងនៅតែប្រតិបត្តិតាម និងចង់ផ្ទេរបន្ត ដោយសារថា បេតិកភណ្ឌនេះមានសារៈសំខាន់ចំពោះយើង និងចំពោះសហគមន៍របស់យើង។

បេតិកភណ្ឌវប្បធម៌មួយប្រភេទទៀតគឺហៅថា**បេតិកភណ្ឌធម្មជាតិដែលបានបង្កើតឡើងដោយសកម្មភាពរបស់មនុស្ស ឬជាផ្នែកសំខាន់នៃវប្បធម៌របស់មនុស្ស**។

- រមណីយដ្ឋានធម្មជាតិទាំងនេះមានលក្ខណសម្បត្តិវប្បធម៌ផ្សេងៗគ្នា ឧទាហរណ៍៖
  - ទេសភាពវប្បធម៌៖ ទីតាំងធម្មជាតិដែលបានកែប្រែដោយសារមនុស្ស។ រមណីយដ្ឋានទាំងនេះមានតម្លៃផ្នែកវប្បធម៌ សាសនា ឬសង្គម។
  - ការកកើតឡើងផ្នែករូបសាស្ត្រ ជីវសាស្ត្រ ឬភូមិសាស្ត្រសំខាន់ៗ ដែលឆ្លុះបញ្ចាំងឱ្យឃើញនូវការឆ្លងកាត់ដំណាក់កាលសំខាន់ៗក្នុងការកកើត ឬក្នុងដំណើរវិវត្តន៍របស់ភពផែនដី ឬការកកើតជាទ្រង់ទ្រាយនានាដែលមានជីវៈចម្រុះសម្បូរបែប។

### លក្ខណសម្បត្តិរបស់បេតិកភណ្ឌវប្បធម៌អរូបី

និយមន័យនៃបេតិកភណ្ឌវប្បធម៌អរូបី៖ ការអនុវត្ត ការតំណាង ការនិយាយ ចំណេះដឹង ជំនាញ ក៏ដូចជាសម្ភារៈ គ្រឿងប្រដាប់ បុរាណវត្ថុ និងលំហវប្បធម៌ពាក់ព័ន្ធនានា ដែលបណ្ដាសហគមន៍ ក្រុម និងក្នុងករណីខ្លះ ដែលបុគ្គលច្រើនគ្នាទទួលស្គាល់ថាជាផ្នែកមួយនៃបេតិកភណ្ឌវប្បធម៌របស់ពួកគេជាដើម។

បេតិកភណ្ឌអរូបី៖

… ជា**បេតិកភណ្ឌរស់**៖ មនុស្សម្នាប្រតិបត្តិវាជាទម្លាប់ប្រចាំថ្ងៃ

… ត្រូវបាន**ផ្ទេរបន្ត** ពីមនុស្សមួយជំនាន់ទៅឱ្យមនុស្សមួយជំនាន់ទៀត៖ មនុស្សជំនាន់ថ្មីរៀនបន្តពីមនុស្សជំនាន់ចាស់។

… មានលក្ខណៈ**សកម្ម** និងប្រែប្រួលតាមពេលវេលា៖ អាចថាសភាពដែលមានថ្ងៃនេះមិនដូចសភាពដែលធ្លាប់មានក្នុងជំនាន់បុព្វការីជនរបស់យើងទេ ឬមួយសភាពក្នុងពេលនេះក៏នឹងមិនអាចនៅដដែលសម្រាប់មនុស្សរាប់ជំនាន់ក្រោយដែរ (អាស្រ័យហេតុនេះហើយទើបគ្មានបេតិកភណ្ឌរស់ណាដែលនៅរក្សាភាពដើមទាំងស្រុងនោះទេ។ ភាពដើមមានន័យថាមានរបៀបតែមួយគត់ដែលជាទម្លាប់ប្រតិបត្តិត្រឹមត្រូវ។ យើងគ្រប់គ្នាប្រហែលជាចង់ប្រតិបត្តិទៅតាមរបៀបមួយខុសពីអ្វីដែលជីដូនជីតាយើងធ្លាប់ធ្វើ ហើយការធ្វើបែបនោះមិនមែនជាការខុសឆ្គងនោះទេ។

… ផ្ដល់នូវស្មារតីអំពី**ការបន្តវេន** និង**អត្តសញ្ញាណ**៖ ចំណុចនេះមានសារៈសំខាន់ និងអត្ថន័យសម្រាប់មនុស្សដែលអត្តសញ្ញាណរបស់ខ្លួនផ្សារភ្ជាប់ជាមួយបេតិកភណ្ឌអរូបីនោះ។

… ប្រទាក់ក្រឡាគ្នាជាមួយនឹងជីវភាពរស់នៅរបស់សហគមន៍ ដែលប្រតិបត្តិតាមបេតិកភណ្ឌអរូបីនោះ ព្រោះវាជាស់ស្មារតី និង**អារម្មណ៍របស់អ្នកថាបេតិកភណ្ឌនោះជារបស់អ្នក**។ អ្នកគឺជាផ្នែកមួយនៃក្រុមដែលអនុវត្តតាមទម្លាប់នោះ។

… **មិនអាចកំណត់**ឱ្យនៅតែក្នុងរង្វង់ព្រំដែនរបស់រដ្ឋមួយបានទេ។ សមាសធាតុមួយរបស់បេតិកភណ្ឌវប្បធម៌អរូបី អាចមានមនុស្សប្រើជាទម្លាប់នៅតាមតំបន់ និងប្រទេសផ្សេងៗគ្នា។ ជាក់ស្ដែង ជនចំណាកស្រុកប្រតិបត្តិតាមបេតិកភណ្ឌរស់របស់ខ្លួននៅកន្លែងណាដែលគេបានទៅដល់ រាប់ទាំងប្រទេសផ្សេងដែលគេកំពុងស្នាក់នៅដែរ (ដូច្នេះហើយ គ្មានទេអ្វីដែលហៅថា បេតិកភណ្ឌរស់របស់ "ជាតិ" មួយៗនោះ)។

## កំណត់ត្រារបស់គ្រូទី ២

*បេតិកភណ្ឌរស់មានលក្ខណៈចម្រុះ*

បេតិកភណ្ឌរស់មានច្រើនទម្រង់ផ្សេងៗគ្នា ដែលគេហៅថា ផ្នែក។

ផ្នែកសំខាន់ៗគឺមានចំនួនប្រាំ៖

- **ប្រពៃណីតាមការចងចាំ** (សុភាសិត រឿងព្រេង ចម្រៀងបន់ស្រន់ និងកំណាព្យ ។ល។)
- **សិល្បៈទស្សនីយភាព** (ការប្រគំតន្ត្រីដោយសំឡេង និងឧបករណ៍ របាំ ល្ខោន ការសម្ដែងសៀក។ល។)
- **ទម្លាប់សង្គម និងពិធីសាសនា** ដើម្បីប្រារព្ធពិធីឆ្លងរដូវកាល ឬស្វាគមន៍ការចាប់កំណើតរបស់មនុស្សម្នាក់។ល។

- **ចំណេះដឹងពាក់ព័ន្ធនឹងធម្មជាតិ និងសកលលោក** (ចំណេះដឹងអំពីសត្វព្រៃ និងរុក្ខជាតិ ប្រព័ន្ធព្យាបាលតាមបែបបុរាណ ការប្រតិបត្តិដែលឆ្លុះបញ្ចាំងអំពីជំនឿសាសនា និងទស្សនាទានពិភពលោក។ល។)
- **ជំនាញ និងចំណេះដឹង** ទាក់ទងទៅនឹង**សិប្បកម្ម**

ប្រទេសជាច្រើនក៏បានបញ្ជាក់អំពីផ្នែកផ្សេងទៀតផងដែរ ឧទាហរណ៍ **កីឡា** និង**ល្បែងកម្សាន្ត**ជាដើម។

### *កិច្ចការពារបេតិកភណ្ឌរស់៖ ហេតុអ្វី និងដោយរបៀបណា?*

វិធានកិច្ចការពារ គឺជាសកម្មភាពដែលមានគោលបំណងជួយមនុស្សដែលកំពុងប្រតិតបត្តិតាមនេះ ឱ្យចេះផ្ទេរបេតិកភណ្ឌរស់ប្រកបទៅដោយអត្ថន័យទៅឱ្យអ្នកជំនាន់ក្រោយ។

ឧទាហរណ៍មួយចំនួនអំពីវិធានកិច្ចការពារ រួមមាន៖

- ការចងក្រងជាឯកសារ និងការស្រាវជ្រាវ៖ ស្វែងយល់ថាតើបេតិកភណ្ឌរស់ជាអ្វី អ្នកណាខ្លះប្រតិបត្តិតាមនៅកន្លែងណា ពេលណា ដោយរបៀបណា និងហេតុអ្វីបានជាគេប្រតិបត្តិតាម តើទម្លាប់ប្រតិបត្តិនោះចាំបាច់ត្រូវការពារដែរឬទេ។
- ការចងក្រងបញ្ជីសារពើភណ្ឌ៖ ការចុះបញ្ជីបេតិកភណ្ឌរស់នៅតាមតំបន់។
- ការលើកកម្ពស់៖ ឧ. ការរៀបចំបាឋកថា ឬការតាំងពិព័រណ៍សមាសធាតុបេតិកភណ្ឌវប្បធម៌អរូបី។
- ការផ្ទេរចំណេះដឹង និងជំនាញ៖ ឧ. ការរៀបចំថ្នាក់បណ្តុះបណ្តាល ការធ្វើបទបង្ហាញអំពីការប្រតិបត្តិតាម ។ល។
- ការអប់រំ អំពី ឬ ជាមួយ បេតិកភណ្ឌវប្បធម៌អរូបី៖ ការបង្រៀនអំពីបេតិកភណ្ឌវប្បធម៌អរូបី ឬការប្រើបេតិកភណ្ឌវប្បធម៌អរូបីជាឯកសារសម្រាប់បង្រៀនមុខវិជ្ជាផ្សេងៗទៀតជាដើម។

### *តួនាទីរបស់សហគមន៍*

**សហគមន៍** គឺជាក្រុមមនុស្សមួយក្រុម មិនថាជាក្រុមតូចក្តីធំក្តី ដែលមានទម្លាប់ប្រតិបត្តិ ឬ ផ្សារភ្ជាប់ខ្លួនទៅនឹងសមាសធាតុណាមួយនៃបេតិកភណ្ឌរស់។ ឧទាហរណ៍ ប្រសិនបើអ្នកលេងឧបករណ៍តន្ត្រីបុរាណណាមួយ ចូលរួមក្នុងក្បួនហែរបុណ្យណាមួយ ឬក៏ប្រកបការងារតម្បាញឬចម្លាក់ណាមួយដែលអ្នកបានរៀនចេះពីជីដូនជីតារបស់អ្នក នោះអ្នកគឺជាសមាជិកនៃសហគមន៍របស់អ្នកហើយ។ អ្នកអាចជាសមាជិកនៃសហគមន៍ជាច្រើនទៀតក្នុងពេលតែមួយ។

ជារឿយៗ ការផ្ទេរចំណេះដឹង និងជំនាញពីមួយទៅមួយ តែងតែកើតឡើងនៅក្នុងរង្វង់សហគមន៍ ឬនៅក្នុងគ្រួសារតែម្តង។

សមាជិកសហគមន៍ខ្លួនឯង ជាអ្នកដែលមានសំឡេងសម្រេចចុងក្រោយថាតើអ្វីខ្លះដែលជាផ្នែកនៃបេតិកភណ្ឌរស់ ការផ្ទេរបន្តទៅមនុស្សជំនាន់ថ្មី ហើយប្រសិនបើបេតិកភណ្ឌនោះត្រូវទទួលបានការការពារ តើត្រូវការពារដោយរបៀបណា។

## ឯកសារចែកជូន

### ឯកសារចែកជូនទី ១៖ ល្បែងតម្រៀប

ចូរបែងចែកសមាសធាតុបេតិកភណ្ឌចំនួនប្រាំបី ទៅតាមប្រភេទរូបី និង អរូបី។



**រូបី**



**អរូបី**

| | |
|---|---|
| តន្ត្រីប្រពៃណី | រឿងព្រេងនិទានក្នុងស្រុក |
| វត្ថុមួយពីសារមន្ទីរ | រូបចម្លាក់របស់បុគ្គលសំខាន់ណាម្នាក់ |
| ជំនាញវេញខ្សែ | ពិធីអបអរសាទរឆ្នាំថ្មី |
| វិហារ | រមណីយដ្ឋានបុរាណវិទ្យា |

## ឯកសារចែកជូនទី ២៖ តើបេតិកភណ្ឌរស់ជាអ្វី?

និយមន័យ៖ *ទម្លាប់អនុវត្ត ការតំណាង ការនិយាយ ចំណេះដឹង ជំនាញ រួមទាំងវត្ថុ គ្រឿងប្រដាប់ បុរាណវត្ថុ និងលំហវប្បធម៌ពាក់ព័ន្ធនានា ដែលបណ្ដាសហគមន៍ ក្រុម និង បុគ្គលច្រើនគ្នាទទួលស្គាល់ថាជាផ្នែកមួយនៃបេតិកភណ្ឌវប្បធម៌របស់ពួកគេ។*

បេតិកភណ្ឌអរូបី៖

...ជាបេតិកភណ្ឌ**រស់**៖ មនុស្សម្នាប្រតិបត្តិវាជាទម្លាប់ប្រចាំថ្ងៃ

...ត្រូវបាន**ផ្ទេរបន្ត**ពីមនុស្សមួយជំនាន់ទៅមនុស្សមួយជំនាន់ទៀត៖មនុស្សជំនាន់ថ្មីរៀនបន្តពីមនុស្សជំនាន់ចាស់។

...មាន**លក្ខណៈសកម្ម** និងប្រែប្រួលតាមពេលវេលា៖ អាចថាសភាពដែលមានថ្ងៃនេះមិនដូចសភាពដែលធ្លាប់មានក្នុងជំនាន់បុព្វការីជនរបស់យើងទេ ឬមួយសភាពក្នុងពេលនេះក៏នឹងមិនអាចនៅដដែលសម្រាប់មនុស្សរាប់ជំនាន់ក្រោយដែរ (អាស្រ័យហេតុនេះហើយទើបគ្មានបេតិកភណ្ឌរស់ណាដែលនៅរក្សាភាពដើមទាំងស្រុងនោះទេ។ ភាពដើមមានន័យថាមានរបៀបតែមួយគត់ដែលជាទម្លាប់ប្រតិបត្តិត្រឹមត្រូវ។ យើងគ្រប់គ្នាប្រហែលជាចង់ប្រតិបត្តិទៅតាមរបៀបមួយខុសពីអ្វីដែលជីដូនជីតាយើងធ្លាប់ធ្វើ ហើយការធ្វើបែបនោះមិនមែនជាការខុសឆ្គងនោះទេ។

... ផ្ដល់នូវស្មារតីអំពីការ**បន្តវេន** និង**អត្តសញ្ញាណ**៖ ចំណុចនេះមានសារៈសំខាន់ និងអត្ថន័យសម្រាប់មនុស្សដែលអត្តសញ្ញាណរបស់ខ្លួនផ្សារភ្ជាប់ជាមួយបេតិកភណ្ឌអរូបីនោះ។

... ប្រទាក់ក្រឡាគ្នាជាមួយនឹងជីវភាពរស់នៅរបស់សហគមន៍ ដែលប្រតិបត្តិតាមបេតិកភណ្ឌអរូបីនោះ ព្រោះវាជាស់ស្មារតី និង**អារម្មណ៍របស់អ្នកថាបេតិកភណ្ឌនោះជារបស់អ្នក**។ អ្នកគឺជាផ្នែកមួយនៃក្រុមដែលអនុវត្តតាមទម្លាប់នោះ។

... **មិនអាចកំណត់**ឱ្យនៅតែក្នុងវង្វង់ព្រំដែនរបស់រដ្ឋមួយបានទេ។ សមាសធាតុមួយរបស់បេតិកភណ្ឌវប្បធម៌អរូបី អាចមានមនុស្សប្រើជាទម្លាប់នៅតាមតំបន់ និងប្រទេសផ្សេងៗគ្នា។ ជាក់ស្ដែង ជនចំណាកស្រុកប្រតិបត្តិតាមបេតិកភណ្ឌរស់របស់ខ្លួននៅកន្លែងណា ដែលគេបានទៅដល់ រាប់ទាំងប្រទេសផ្សេងដែលគេកំពុងស្នាក់នៅដែរ (ដូច្នេះហើយ គ្មានទេអ្វីដែលហៅថា បេតិកភណ្ឌរស់របស់ "ជាតិ" មួយៗនោះ)។

បេតិកភណ្ឌរស់មានច្រើនទម្រង់ផ្សេងៗគ្នា ដែលគេហៅថា ផ្នែក។ ផ្នែកសំខាន់ៗគឺមានចំនួនប្រាំ៖

- **ប្រពៃណីតាមការចងចាំ** (សុភាសិត រឿងព្រេង ចម្រៀងបន់ស្រន់ និងកំណាព្យ ។ល។)
- **សិល្បៈទស្សនីយភាព** (ការប្រគំតន្ត្រីដោយសំឡេង និងឧបករណ៍ របាំ ល្ខោន ការសម្ដែងសៀក។ល។)
- **ទម្លាប់សង្គម និងពិធីសាសនា** ដើម្បីប្រារព្ធពិធីឆ្លងរដូវកាល ឬស្វាគមន៍ការចាប់កំណើតរបស់មនុស្សម្នាក់។ល។
- **ចំណេះដឹងពាក់ព័ន្ធនឹងធម្មជាតិ និងសកលលោក** (ចំណេះដឹងអំពីសត្វព្រៃ និងរុក្ខជាតិ ប្រព័ន្ធព្យាបាលតាមបែបបុរាណ ការប្រតិបត្តិដែលឆ្លុះបញ្ចាំងអំពីជំនឿសាសនា និងទស្សនាទានពិភពលោក។ល។)
- ជំនាញ និងចំណេះដឹង ទាក់ទងទៅនឹង**សិប្បកម្ម**

ប្រទេសជាច្រើនក៏បានបញ្ជាក់អំពីផ្នែកផ្សេងទៀតផងដែរ ឧទាហរណ៍ កីឡា និងល្បែងកម្សាន្តជាដើម។

## ឯកសារចែកជូនទី ៣៖ "បេតិកភណ្ឌរស់របស់ខ្ញុំ"

នេះជាកិច្ចការផ្ទះសម្រាប់សិស្សធ្វើរៀងៗខ្លួន ឬធ្វើជាក្រុមតូចៗ។

១. ចូរជ្រើសរើសសមាសធាតុណាមួយនៃបេតិកភណ្ឌរស់របស់អ្នក។

២. ចូរសម្ភាសន៍សមាជិកគ្រួសារ ឬសមាជិកក្នុងសហគមន៍របស់អ្នក ហើយសួរពួកគាត់នូវសំណួរខាងក្រោមនេះ៖

- តើបេតិកភណ្ឌរស់**ជាអ្វី**?
- តើគ្រួសារ ឬសហគមន៍របស់អ្នកមានទម្លាប់អនុវត្តបេតិកភណ្ឌរស់នោះដោយរបៀប **ណាខ្លះ**? (កាលពីមុន និងពេលបច្ចុប្បន្ន? ពេលណា កន្លែងណា និងដោយអ្នកណាខ្លះ?)
- **ហេតុអ្វី**បានជាបេតិកភណ្ឌរស់មានសារៈសំខាន់ចំពោះសហគមន៍ និងខ្លួនអ្នកផ្ទាល់?
- តើត្រូវធ្វើដូចម្ដេច ដើម្បីឱ្យសមាសធាតុទាំងនោះនៅតែបន្តអនុវត្តបាន?

៣. ធ្វើបទបង្ហាញរយៈពេល **៥ នាទី** អំពីព័ត៌មានដែលអ្នកប្រមូលបាន។ អ្នកក៏អាចបង្ហាញពីសកម្មភាព ឬគម្រោងដែលអ្នកអាចរៀបចំឡើងដើម្បីការពារបេតិកភណ្ឌរស់នេះផងដែរ។

ចូរធ្វើបទបង្ហាញអំពីលទ្ធផលនៃកិច្ចការរបស់អ្នកពេលជួបគ្នាលើកក្រោយ។ បទបង្ហាញនោះអាចធ្វើក្នុងទម្រង់ណាក៏បានដែរ៖ អាចជាទម្រង់វីដេអូ ជាផ្ទាំងក្រដាសធំ ឬជាទម្រង់ច្នៃប្រឌិតណាផ្សេងទៀតដែលសមស្រប។

**ដំបូន្មានសម្រាប់ការសម្ភាសន៍៖**

- ប្រាប់ទៅអ្នកតបសម្ភាសន៍ឱ្យបានដឹងជាមុនអំពីគោលបំណងនៃការសម្ភាសន៍ និងថាតើអ្នកនឹងយកព័ត៌មាននោះទៅធ្វើអ្វី
- ត្រូវប្រាកដថា អ្នកតបសម្ភាសន៍ម្នាក់ៗត្រូវយល់ព្រមឱ្យធ្វើការសម្ភាសន៍ជាមុនសិន។ លើសពីនេះ សូមកុំភ្លេចសុំការអនុញ្ញាតថតសំឡេង ឬថតវីដេអូពួកគាត់
- ត្រៀមសំណួរទុកជាមុន
- ស្ដាប់
- កត់ត្រាព័ត៌មាន (កំណត់ហេតុជាលាយលក្ខណ៍អក្សរ និងថតសំឡេង)
- ប្រសិនបើអាច សូមថតរូប ឬថតវីដេអូ
- ត្រូវរក្សាឥរិយាបថគោរព និងកុំវិនិច្ឆ័យ

## ឯកសារចែកជូនទី ៤៖ លំហាត់បំពេញចន្លោះស្ដីពីបេតិកភណ្ឌវប្បធម៌អរូបី

### ចូរបំពេញពាក្យខាងក្រោមទៅក្នុងចន្លោះឃ្លានីមួយៗ

- *ប្រែប្រួល*
- *ត្រូវបានការពារ*
- *ជំនាន់*
- *មានអត្ថន័យ*
- *រស់*
- *ធម្មជាតិ*
- *ជារបស់ខ្លួន*
- *ជំនាន់*
- *សហគមន៍*
- *ទម្លាប់អនុវត្តន៍សង្គម*

បេតិកណ្ឌអរូបី គឺជាបេតិកភណ្ឌ ________________ ដែលមនុស្សម្នាប្រតិបត្តិតាមជារៀងរាល់ថ្ងៃ។

បេតិកណ្ឌអរូបីត្រូវបានផ្ទេរបន្តពី _________________ ទៅ __________________.

បេតិកណ្ឌអរូបីនេះ _________________ យូរមកហើយ។

វាជាស់សតិ និងអារម្មណ៍ឱ្យដឹងអំពីការបន្តវេន និងអំពីអត្តសញ្ញាណ៖ វាមានសារៈសំខាន់ ហើយវាជា ________________ សម្រាប់មនុស្សដែលអនុវត្តវាជាទម្លាប់។

វាជាស់សតិ និងអារម្មណ៍ឱ្យគេបានដឹងពី ___________________.

_____________________ កំណត់ឱ្យឃើញថា អ្វីខ្លះជាបេតិកភណ្ឌរស់របស់ពួកគេ។

បេតិកភណ្ឌរស់ចាំបាច់ត្រូវ _________________ សម្រាប់មនុស្សអាចបន្តអនុវត្តវាជាទម្លាប់តទៅមុខទៀត។

ចំណេះដឹងអំពី _____________________ ជាផ្នែកមួយនៃបេតិកភណ្ឌរស់។

របៀបដែលយើងប្រារព្ធពិធីមង្គលការ និង _________________________ក៏ជាផ្នែកមួយនៃបេតិកភណ្ឌអរូបីដែរ។

# ឯកសារទី ២៖ អំពីការភ្ជាប់ប្រធានបទសិក្សា បេតិកភណ្ឌរស់ និង ការអប់រំអំពីភាពជាពលរដ្ឋសកល

បញ្ជីនៅក្នុងតារាង T២ ផ្តល់នូវគោលគំនិតមួយចំនួនអំពីវិធីសាស្ត្រក្នុងការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងមុខវិជ្ជាផ្សេងៗរបស់សាលា។ សកម្មភាពមួយចំនួននៅក្នុងតារាងនេះទាក់ទងនឹងការអនុវត្តផ្ទាល់ (ឧ. ការប្រារព្ធពិធី ប្រភេទនៃសិល្បៈទស្សនីយភាព ការអនុវត្តកសិកម្មដែលប្រើចំណេះដឹងអំពីធម្មជាតិ) ចំណែកឯសកម្មភាពផ្សេងទៀតទាក់ទងនឹងវត្ថុដែលទាក់ទងនឹងការអនុវត្ត (ឧ. សម្លៀកបំពាក់ ឧបករណ៍តន្ត្រី) និង / ឬសម្ភារៈប្រើប្រាស់ក្នុងអំឡុងពេលអនុវត្ត ឬផលិតវត្ថុដែលពាក់ព័ន្ធមួយចំនួន (ឧទាហរណ៍ វត្ថុធាតុដើមសម្រាប់ហត្ថកម្ម គ្រឿងផ្សំសម្រាប់ម្ហូបអាហារដែលបានរៀបចំឡើងទាក់ទងនឹងទំនៀមទម្លាប់សង្គមជាដើម)។ គ្រប់ករណីទាំងអស់ដំណើរការសិក្សាគួរផ្តល់ឱកាសដល់សិស្សស្វែងយល់អំពីផ្នែកចម្រុះគ្នានៃសមាសធាតុបេតិកភណ្ឌវប្បធម៌អរូបី និងសារៈសំខាន់របស់វាចំពោះសហគមន៍។

បើទោះជាការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងមេរៀន ឬសកម្មភាពដែលសិស្សតែងតែបានស្គាល់ក៏ដោយ ក៏វិធីសាស្ត្រនៃភាពជាពលរដ្ឋសកលជំរុញឱ្យមានការពង្រីកការពិចារណា ទៅលើអ្វីដែលមិនសូវស្គាល់ផងដែរ។ នៅពេលដែលខ្លឹមសារបរិបទត្រូវបានប្រើប្រាស់ សិស្សអាចប្រៀបធៀប និងរកឱ្យឃើញពីភាពខុសគ្នាស្តីពីការអនុវត្ត និងចំណេះដឹងជាមួយអ្នកដទៃ ហើយពិចារណាអំពីការរួមចំណែករៀងៗខ្លួនចំពោះសន្តិភាព ការគោរពសិទ្ធិមនុស្ស និងភាពចម្រុះ និងការកសាងពិភពលោកប្រកបដោយចីរភាព។

ដូចដែលបានបង្ហាញនៅក្នុងតារាង T២ ឥរិយាបថជាពលរដ្ឋសកលត្រូវបានបញ្ចូលទៅក្នុងមុខវិជ្ជាណាមួយ ក្នុងគម្រោងអន្តរកម្មសិក្សា ក្នុងថ្នាក់ និងតាមរយៈសកម្មភាពបន្តធ្វើនៅផ្ទះ និងសកម្មភាពនានាក្រៅពីកម្មវិធីសិក្សា។

តារាង T២៖ វិធីបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងមុខវិជ្ជាសិក្សា

| មុខវិជ្ជាសិក្សា | ការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងមុខវិជ្ជាសិក្សា<br>ឧទាហរណ៍មួយចំនួន៖ | ជំរុញឥរិយាបថជាពលរដ្ឋសកលនៅពេលបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបី<br>ឧទាហរណ៍មួយចំនួន៖ |
|---|---|---|
| **ភាសានិង អក្សរសាស្ត្រ** | អានទំនុកចម្រៀងបែបប្រពៃណី អត្ថបទរឿងនិទាន រឿងព្រេង រូបមន្ត និង<br>បណ្ណសារដែលភ្ជាប់ជាមួយសមាសធាតុ និងការអនុវត្ត។ វិភាគរចនាបថ រចនាសម្ព័ន្ធ និងលក្ខណៈនៃអត្ថបទទាំងនេះ។<br>ស្វែងរក សិក្សា និងបកប្រែពាក្យ កន្សោម និងសុភាសិតដែលទាក់ទងនឹងសមាសធាតុ និងអត្ថន័យរបស់វា។<br>ប្រៀបធៀបពាក្យដែលប្រើក្នុងតំបន់ផ្សេងៗគ្នា ឬនៅសម័យកាលផ្សេងៗគ្នា។<br>សរសេរកំណាព្យ របាយការណ៍ ឬការផ្សាយពាណិជ្ជកម្មសម្រាប់សមាសធាតុនោះ។<br>បង្កើតអត្ថបទតាមនីតិវិធីដែលពន្យល់អំពីរបៀបអនុវត្តការងារហត្ថកម្មជាក់លាក់ណាមួយ របៀបរៀបចំពិធីបុណ្យជាក់លាក់ណាមួយ ឬជំហាននៃពិធីបែបសាសនា។ | ការយល់ដឹង៖ កំណត់អំពីគុណតម្លៃសំខាន់ៗសម្រាប់សហគមន៍ និងរបៀបក្នុងការផ្សព្វផ្សាយគុណតម្លៃទាំងនេះ តាមរយៈការបង្ហាញវប្បធម៌ក្នុងតំបន់ ជាពិសេសការលើកកម្ពស់តម្លៃនៃកិច្ចសហប្រតិបត្តិការ សាមគ្គីភាព និងការអត់ឱន ក៏ដូចជាតម្លៃដែលអាចជំរុញឱ្យមានការរើសអើង ឬមានផលប៉ះពាល់អវិជ្ជមានលើសិទ្ធិរបស់ក្រុមមួយចំនួន។<br>អារម្មណ៍សង្គម៖ អានអត្ថបទចម្រៀង អត្ថបទ រឿងនិទាន រឿងព្រេងពីសហគមន៍ផ្សេងទៀតលើប្រធានបទស្រដៀងគ្នា៖ ពិភាក្សា ប្រៀបធៀប និងរកឱ្យឃើញពីភាពខុសគ្នា។<br>វិភាគពីរបៀបដែលទំនាក់ទំនងសង្គមនៅក្នុងសហគមន៍ និងរវាងសហគមន៍នានាត្រូវបានពិពណ៌នា។<br>អាកប្បកិរិយា៖ សរសេរ និងផ្សព្វផ្សាយអត្ថបទលើប្រធានបទទាក់ទងនឹងភាពជាពលរដ្ឋសកលដោយប្រើប្រាស់រចនាបថអក្សរសិល្ប៍ក្នុងស្រុក។ |
| **គណិតវិទ្យា** | ការដោះស្រាយបញ្ហា៖ ប្រើប្រាស់ប្រព័ន្ធ និងឧបករណ៍ក្នុងស្រុកសម្រាប់ការគណនា វាស់វែង និងកត់ត្រា។<br>បំលែងឯកតារង្វាស់នៃប្រវែង ទម្ងន់ បរិមាណ។ គណនាសមាមាត្រ (សម្រាប់គ្រឿងផ្សំក្នុងការចម្អិនម្ហូបអាហារ ការប្រើប្រាស់វត្ថុធាតុដើម)។ គណនាបរិមាណនៃវត្ថុធាតុដើមដែលត្រូវការ សម្រាប់ទំហំជាក់លាក់/អង្កត់ផ្ចិតនៃផលិតផល។ | ការយល់ដឹង៖ វិភាគតម្លៃ និងផលប៉ះពាល់ - វិជ្ជមាន និងអវិជ្ជមាន - នៃជំនឿ និងការអនុវត្តក្នុងស្រុកមួយចំនួន។ កំណត់គុណសម្បត្តិ និងគុណវិបត្តិនៃការអនុវត្តទាំងនេះ បើប្រៀបធៀបជាមួយនឹងជំនឿ និងការអនុវត្តបែបវិទ្យាសាស្ត្រសហសម័យ។ |

| មុខវិជ្ជាសិក្សា | ការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងមុខវិជ្ជាសិក្សា<br>ឧទាហរណ៍មួយចំនួន៖ | ជំរុញឥរិយាបថជាពលរដ្ឋសកលនៅពេលបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបី<br>ឧទាហរណ៍មួយចំនួន៖ |
|---|---|---|
| **គណិតវិទ្យា** | **ធរណីមាត្រ៖** គណនាវិមាត្រ អង្កត់ផ្ចិត ឬរង្វង់នៃវត្ថុហត្ថកម្មជាក់លាក់មួយ (ឧ. កន្ត្រកដែលត្បាញដោយដៃ)។ ស្វែងយល់ពីរាងធរណីមាត្រនៃគោមមូលដ្ឋាន (ការបង្វិល ការបកស្រាយ ការឆ្លុះបញ្ចាំង) ស៊ីមេទ្រី។ ស្វែងរកសមីការបន្ទាត់ កំណត់ជម្រាល និងគណនាមុំរវាងបន្ទាត់ពីរ (ឧ. ប្រើលំនាំក្រណាត់ប៉ាក់ ត្បាញ ឆ្លាក់ លាបពណ៌)។<br>**ការគិតបែបតក្កវិទ្យា៖** ស្វែងយល់ពីលំដាប់លំដោយនៃគោម (សម្រាប់សិប្បកម្ម) ឬចង្វាក់ និងទំនុក (ប្រពៃណីតាមការចងចាំ) និងណោតភ្លេង ឬជំហានរាំបាំ។ | សង្គមអារម្មណ៍៖ ប្រៀបធៀបព័ត៌មានទាក់ទងនឹងបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងតំបន់ផ្សេងៗគ្នា (ដោយប្រើលេខ<br>សមាមាត្រ ភាគរយ ស្ថិតិ ។ល។)<br>អាកប្បកិរិយា៖ លើកទឹកចិត្តឱ្យមានការពិភាក្សាជាក្រុម ដើម្បីផ្តល់ឱកាសឱ្យសិស្សអនុវត្តជំនាញដោះស្រាយបញ្ហា និងគោលគំនិតគណិតវិទ្យាក្នុងបរិបទប្រកបដោយអត្ថន័យ។ |
| **វិទ្យាសាស្ត្រ** | **រូបវិទ្យា៖** ស្វែងយល់អំពីលក្ខណៈរបស់វត្ថុ ឬសម្ភារៈប្រើប្រាស់ក្នុងការអនុវត្តវប្បធម៌ក្នុងស្រុក (ឧ. ទាក់ទងនឹងសំឡេង៖ ឧបករណ៍តន្ត្រី ដួង ចរន្តកម្តៅ៖ គ្រឿងស្មូន គ្រឿងដែក<br>វាយនភណ្ឌ កាំរស្មីពន្លឺ៖ ការងារកេញ្ចក់)<br>វាស់ល្បឿន និងការកកិតនៃវត្ថុផ្លាស់ទី (ដោយប្រើប្រដាប់ក្មេងលេងតាមលក្ខណៈប្រពៃណី ហត្ថកម្ម និងឧបករណ៍កសិកម្ម ។ល។ | ការយល់ដឹង៖ វិភាគតម្លៃ និងផលប៉ះពាល់ - វិជ្ជមាន និងអវិជ្ជមាន - នៃជំនឿនិងការអនុវត្តក្នុងស្រុកមួយចំនួន។ កំណត់គុណសម្បត្តិ និងគុណវិបត្តិនៃការអនុវត្តទាំងនេះ បើប្រៀបធៀបជាមួយនឹងជំនឿ និងការអនុវត្តបែបវិទ្យាសាស្ត្រសហសម័យ។<br>អារម្មណ៍សង្គម៖ ប្រៀបធៀបការអនុវត្ត និងជំនឿទាក់ទងនឹងវិស័យវិទ្យាសាស្ត្រនៅក្នុងសហគមន៍ចម្រុះ។ កំណត់អំពីភាពស្រដៀងគ្នានិងភាពខុសគ្នាណាមួយ ហើយពិភាក្សាអំពីហេតុផលសម្រាប់ភាពខុសគ្នាទាំងនេះ។ |

| មុខវិជ្ជាសិក្សា | ការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងមុខវិជ្ជាសិក្សា<br>ឧទាហរណ៍មួយចំនួន៖ | ជំរុញឥរិយាបថជាពលរដ្ឋសកលនៅពេលបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបី<br>ឧទាហរណ៍មួយចំនួន៖ |
| --- | --- | --- |
| **វិទ្យាសាស្ត្រ** | បង្កើតគំរូ (ឧ. គំរូនៃអាតូម) ដោយប្រើជំនាញក្នុងស្រុកទាក់ទងនឹងការសាងសង់ ឬហត្ថកម្ម ឬពិពណ៌នាអំពីគំរូបែបនេះដោយប្រើរចនាបថអក្សរសិល្ប៍ក្នុងស្រុក កំណាព្យ។ល។<br>**គីមីវិទ្យា៖** ប្រើចង្វាក់ក្នុងស្រុកដើម្បីរៀនតារាងសមាសធាតុ។<br>វាស់កម្រិត pH នៃសារធាតុដែលប្រើក្នុងស្រុក (ឧ. ថ្នាំជ្រលក់ពណ៌ អាហារ សម្ភារៈសំណង់)។<br>សិក្សាអំពីលក្ខណៈរបស់គ្រឿងផ្សំដែលប្រើក្នុងម្ហូបក្នុងស្រុក។ ពន្យល់ពីដំណើរការបំលែងនៅពេលដែលសមាសធាតុទាំងនេះបានលាយបញ្ចូលគ្នា កម្តៅ (ឧ. ក្នុងអាហារ ថ្នាំជ្រលក់ពណ៌) ។ល។<br>កសាងរចនាសម្ព័ន្ធម៉ូលេគុលដោយប្រើជំនាញហត្ថកម្មក្នុងស្រុក។ ល។<br>**វិទ្យាសាស្ត្រធម្មជាតិ និងជីវវិទ្យា៖** សិក្សាវដ្តជីវិតរបស់រុក្ខជាតិនិងសត្វក្នុងស្រុក។<br>សង្កេតមើលការផ្លាស់ប្តូរក្នុងស្រុកតាមរដូវ។<br>ស្វែងយល់អំពីកន្លែងដែលវត្ថុធាតុដើមដូចជា (ជាតិសរសៃ សារធាតុពណ៌ អាហារ) សម្រាប់ប្រភពផលិតផលក្នុងស្រុក របៀបប្រមូលផល និងកែច្នៃ និងបញ្ហាបរិស្ថានដែលអាចកើតមានទាក់ទងនឹងការប្រមូលផល។<br>ស្វែងយល់អំពីតម្លៃអាហារូបត្ថម្ភ និង ឱសថនៃរុក្ខជាតិក្នុងស្រុក។ | ឥរិយាបថ៖ ការកសាងផ្អែកលើការវិភាគចំណុចខ្លាំង និងចំណុចខ្សោយអំពីចំណេះដឹងមូលដ្ឋាន កំណត់សកម្មភាពក្នុងការប្រើប្រាស់ថាមពល និងទឹកប្រកបដោយនិរន្តរភាព និងរបៀបអភិរក្សជីវចម្រុះក្នុងតំបន់។ |

| មុខវិជ្ជាសិក្សា | ការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងមុខវិជ្ជាសិក្សា<br>ឧទាហរណ៍មួយចំនួន៖ | ជំរុញឥរិយាបថជាពលរដ្ឋសកលនៅពេលបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបី<br>ឧទាហរណ៍មួយចំនួន៖ |
|---|---|---|
| **ប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រសង្គម** | សម្ភាសន៍អ្នកអនុវត្តអំពីវត្តបេតិកភណ្ឌវប្បធម៌។ ប្រៀបធៀបការអនុវត្តកន្លងមក និងបច្ចុប្បន្ន និងវិធីសាស្ត្រផលិត។ កំណត់ការប្រើប្រាស់ក្នុងសកម្មភាពប្រចាំថ្ងៃ ឬក្នុងពិធីសាសនា។<br><br>វិភាគ និងប្រៀបធៀបបរិបទប្រវត្តិសាស្ត្រ សង្គម និងនយោបាយនៃការអនុវត្តដែលបានជ្រើសរើស (រួមទាំងតំណភ្ជាប់ទៅនឹងតួនាទីយេនឌ័រ និងរចនាសម្ព័ន្ធសង្គម) កាលពីអតីតកាល និងបច្ចុប្បន្ន។<br><br>ប្រៀបធៀបការអនុវត្តក្នុងអតីតកាលនិងបច្ចុប្បន្ន ដោយប្រើបទចម្រៀង រឿងនិទាន និងសិល្បៈទស្សនីយភាពជាឯកសារយោង។ | ការយល់ដឹង៖ ពិចារណាពីរបៀបដែលការបកស្រាយអំពីសិទ្ធិមនុស្សជាពិសេសសិទ្ធិវប្បធម៌ ត្រូវបានបកស្រាយនៅក្នុងសហគមន៍មូលដ្ឋាន និងរបៀបដែលវាបានផ្លាស់ប្តូរតាមពេលវេលាពីមួយជំនាន់ទៅមួយជំនាន់។<br>តាមរយៈប្រវត្តិសាស្ត្រ កំណត់ពីរបៀបដែលការអនុវត្តវប្បធម៌មួយចំនួនអាចជំរុញឱ្យមានកិច្ចសហការ ឬបង្កើតវិសមភាពនៅក្នុងសហគមន៍ (ក្រុមមានសិទ្ធិអំណាច ទល់និងក្រុមទន់ខ្សោយ) និងរបៀបដែលស្ថានភាពបានវិវត្តតាមពេលវេលា។<br>អារម្មណ៍សង្គម៖ ពិនិត្យពីភាពខុសគ្នានៃតម្លៃរវាងសហគមន៍ និងរបៀបដែលកត្តាទាំងនេះអាចនាំឱ្យមានជម្លោះក្នុងអតីតកាល និងក្នុងពេលថ្មីៗនេះផងដែរ។ ឆ្លុះបញ្ចាំងពីវិធីដើម្បីជម្នះរាល់បញ្ហារវាងសហគមន៍ និងរបៀបលើកកម្ពស់តម្លៃនិងទំនួលខុសត្រូវរួម។<br>អាកប្បកិរិយា៖ បង្កើតយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីមេរៀនពីប្រវត្តិសាស្ត្រ និងតម្លៃរួម ដោយប្រើសមាសធាតុបេតិកភណ្ឌវប្បធម៌អរូបីក្នុងស្រុក។ |
| **ភូមិវិទ្យា** | មើលផែនទី ហើយគូរ៖ កំណត់ទីតាំងនៅលើផែនទី (បច្ចុប្បន្ននិងអតីតកាល) កន្លែងសមាសធាតុបេតិកភណ្ឌវប្បធម៌អរូបីដែលបានជ្រើសរើស ឬបានអនុវត្ត ជាកន្លែងដែលសិប្បកម្ម និង/ឬរចនាបថតន្ត្រីផ្សេងៗមានប្រភពមកពីកន្លែងដែលវត្ថុធាតុដើមត្រូវបានប្រមូលសម្រាប់ម្ហូបអាហារក្នុងស្រុក ការផលិតឧបករណ៍តន្ត្រី។ ឧបករណ៍ សិប្បកម្ម សម្ភារៈសំណង់។ល។ វិភាគថាតើ និងហេតុអ្វីបានជាទីតាំងនេះទៅជាជួរច្នេះឬស័ក្តិសមទេ ហើយហេតុអ្វីបានជាវានៅដដែលឬផ្លាស់ប្តូរតាមពេលវេលា។ | ការយល់ដឹង៖ អាន និងពិភាក្សាអំពីរបៀបដែលបេតិកភណ្ឌក្នុងស្រុកអាចបញ្ជូនព័ត៌មានអំពីបរិស្ថាន និងរបៀបគ្រប់គ្រង។ ការលើកឡើងតាមការចងចាំ និងចំណេះដឹងក្នុងស្រុក ដូចជាវិធីសាស្ត្រសង្កេតមើលមេឃមានប្រយោជន៍សម្រាប់វាស់វែងពីពេលវេលា និង រដូវដែលកន្លងផុតទៅ។ |

| មុខវិជ្ជាសិក្សា | ការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងមុខវិជ្ជាសិក្សា<br>ឧទាហរណ៍មួយចំនួន៖ | ជំរុញឥរិយាបថជាពលរដ្ឋសកលនៅពេលបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបី<br>ឧទាហរណ៍មួយចំនួន៖ |
|---|---|---|
| **ភូមិវិទ្យា** | សង្កេត វិភាគ និងពន្យល់ពីសញ្ញាធម្មជាតិ (ឧ. ទាក់ទងនឹងអាកាសធាតុ ឱកាសកសិកម្ម គ្រោះមហន្តរាយធម្មជាតិ ។ល។) យោងតាមចំណេះដឹងក្នុងស្រុក។<br>វិភាគសំណង់ និងបច្ចេកទេសស្ថាបត្យកម្មក្នុងស្រុកទាក់ទងនឹងបរិស្ថាន។<br>អាន និងវិភាគរឿង និងចម្រៀងក្នុងស្រុកអំពីធម្មជាតិ និងបរិស្ថាន។ | កំណត់គុណសម្បត្តិ និងគុណវិបត្តិនៃការអនុវត្តទាំងនេះ បើប្រៀបធៀបជាមួយនឹងជំនឿ និងការអនុវត្តបែបវិទ្យាសាស្ត្រសហសម័យ។<br>កំណត់ប្រភពអាហារនិងវត្ថុធាតុដើមក្នុងស្រុក និងមូលហេតុដែលអាហារទាំងនេះសមស្រប (ឬមិន) សមស្របចំពោះបរិស្ថានក្នុងតំបន់។<br>អារម្មណ៍សង្គម៖ វិភាគ និងប្រៀបធៀបផលប៉ះពាល់បរិស្ថាន លក្ខណៈវិជ្ជមាន និងអវិជ្ជមាននៃការអនុវត្តផ្សេងៗទាក់ទងនឹងកសិកម្ម និងការគ្រប់គ្រងដីធ្លី ដែលបំផុសគំនិតតាមរយៈចំណេះដឹងក្នុងស្រុកនិងតាមបែបវិទ្យាសាស្ត្រ។<br>ពិភាក្សាអំពីទំនាក់ទំនងរវាងមនុស្ស និងបរិស្ថានក្នុងបរិបទផ្សេងៗ។<br>អាកប្បកិរិយា៖ បង្កើតសកម្មភាព គម្រោង ឬក្លឹបដើម្បីលើកកម្ពស់អន្តរកម្មប្រកបដោយនិរន្តរភាពបន្ថែមទៀតរវាងមនុស្ស និងបរិស្ថាន។ |
| **សេដ្ឋកិច្ច** | កំណត់លទ្ធភាពហិរញ្ញវត្ថុនៃសមាសធាតុវប្បធម៌ ឬសកម្មភាពដែលពាក់ព័ន្ធ (ឧ. ពិធីបុណ្យ ផលិតកម្មហត្ថកម្ម ការអនុវត្តកសិកម្មក្នុងស្រុក និងឧស្សាហកម្មពាក់ព័ន្ធ)។<br>គណនាថ្លៃដើមផលិតកម្ម។ ប្រៀបធៀបចំណូលធៀបនឹងការចំណាយ។ ប្រៀបធៀបប្រាក់ចំណូលសក្តានុពល និងតម្លៃបន្ថែមនៃឧស្សាហកម្មដែលគ្រប់គ្រងដោយបុរសតាមបែបប្រពៃណី ជាមួយនឹងឧស្សាហកម្មដែលគ្រប់គ្រងដោយស្ត្រីតាមបែបប្រពៃណី។ | ការយល់ដឹង៖ វិភាគគំរូសេដ្ឋកិច្ចនៃការអនុវត្តក្នុងស្រុកមួយចំនួនធៀបនឹងការអនុវត្តសហសម័យ។ ពិនិត្យមើលពីរបៀបដែលសកម្មភាពប្រពៃណីអាច ផ្តល់នូវជីវភាពរស់នៅប្រកបដោយនិរន្តរភាពសម្រាប់សមាជិកសហគមន៍។<br>សង្គមអារម្មណ៍៖ ប្រៀបធៀបគំរូសេដ្ឋកិច្ចនៃសហគមន៍ផ្សេងៗ។ កំណត់ភាពស្រដៀងគ្នានៅក្នុងជំនាញសហគ្រិនភាពដ៏មានតម្លៃបំផុត។ |

| មុខវិជ្ជាសិក្សា | ការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងមុខវិជ្ជាសិក្សា ឧទាហរណ៍មួយចំនួនៈ | ជំរុញឥរិយាបថជាពលរដ្ឋសកលនៅពេលបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបី ឧទាហរណ៍មួយចំនួនៈ |
|---|---|---|
| **សេដ្ឋកិច្ច** | សិក្សាការផ្លាស់ប្តូរការផ្តោតអារម្មណ៍សេដ្ឋកិច្ចនៃសកម្មភាពបង្កើតប្រាក់ចំណូលបែបប្រពៃណី (ឧ. ផ្តោតលើការចិញ្ចឹមជីវិតកាលពីអតីតកាលធៀបនឹងការផ្តោតទៅលើការបង្កើតប្រាក់ចំណូលតាមរយៈទេសចរណ៍ ផលិតកម្មទ្រង់ទ្រាយធំ និងការនាំចេញនាពេលបច្ចុប្បន្ន)។<br>វិភាគជំនាញពាណិជ្ជកម្ម និងសហគ្រិនដែលទាក់ទងនឹងការផលិតប្រកបដោយនិរន្តរភាពនៃផលិតផលប្រពៃណី។ | អាកប្បកិរិយាៈចូលរួមក្នុងសកម្មភាពបង្កើតប្រាក់ចំណូលដែលភ្ជាប់ជាមួយបេតិកភណ្ឌវប្បធម៌អរូបី ឧ. ក្នុងអំឡុងពេលពិព័រណ៍នៅសាលា ឬតាមរយៈសកម្មភាពនានាក្រៅពីកម្មវិធីសិក្សា ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងដែលលើកកម្ពស់តម្លៃ និងប្រធានបទនៃភាពជាពលរដ្ឋសកល។<br>រៀបចំព្រឹត្តិការណ៍មួយដែលសិស្សមកពីសហគមន៍នានាអាចលក់ផលិតផលនិងសេវាកម្មប្រពៃណី។ |
| **ពលរដ្ឋវិទ្យា** | សិក្សាពីវិធាននិង/ឬច្បាប់មូលដ្ឋាន និងផលវិបាកសម្រាប់ទំនៀមទម្លាប់វប្បធម៌ពិសេស និង/ឬផលប៉ះពាល់នៃច្បាប់ទាំងនោះលើផលិតផលនោះ (ឧ. សិទ្ធិកម្មសិទ្ធិបញ្ញាសម្រាប់ហត្ថកម្ម សិល្បៈទស្សនីយភាព ឱសថបុរាណ ការគ្រប់គ្រងដីធ្លី និងកម្មសិទ្ធិ អនាម័យសម្រាប់ធ្វើម្ហូបអាហារដោយដើម)។<br>ប្រៀបធៀបយន្តការច្បាប់ប្រពៃណីនិងសហសម័យ។<br>សិក្សារចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋានៈ កំណត់ថាអ្នកណាធ្វើការសម្រេច អ្នកណាចូលរួម អ្នកណាមិនចូលរួម និងមូលហេតុអ្វី (ទន្ទឹមនឹងការយកចិត្តទុកដាក់ជាពិសេសចំពោះតួនាទី និងសិទ្ធិរបស់ស្ត្រី និងក្រុមជនជាតិភាគតិច)។<br>វិភាគគុណតម្លៃ និងក្រមសីលធម៌នៅក្នុងប្រព័ន្ធជំនឿក្នុងស្រុក។ | ការយល់ដឹងៈ ឆ្លុះបញ្ចាំងអំពីការគោរពសិទ្ធិមនុស្សនៅក្នុងសហគមន៍របស់អ្នក។ ពិនិត្យថាតើសិទ្ធិជាមូលដ្ឋានមានភាពស្របគ្នានឹងសិទ្ធិមនុស្សអន្តរជាតិដែរឬទេ។<br>កំណត់អំពីរបៀបដែលសមាសធាតុបេតិកភណ្ឌវប្បធម៌អរូបីមួយចំនួនលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ឬថា តើវាបង្កើតវិសមភាព និង/ឬការរើសអើងដែរឬទេ។ គិតអំពីហេតុផលដែលអាចកើតមានចំពោះវិសមភាពទាំងនេះ។<br>ឆ្លុះបញ្ចាំងអំពីរបៀបដែលយន្តការដោះស្រាយវិវាទក្នុងតំបន់អាចលើកកម្ពស់សន្តិភាពនៅកម្រិតមូលដ្ឋាន និងលើសពីនេះ។<br>ពិនិត្យមើលថាតើការអនុវត្តក្នុងស្រុកអាចរួមចំណែកដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) នៅកម្រិតជាតិដែរឬទេ។ |

| មុខវិជ្ជាសិក្សា | ការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងមុខវិជ្ជាសិក្សា<br>ឧទាហរណ៍មួយចំនួន៖ | ជំរុញឥរិយាបថជាពលរដ្ឋសកលនៅពេលបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបី<br>ឧទាហរណ៍មួយចំនួន៖ |
|---|---|---|
| **ពលរដ្ឋវិទ្យា** | អនុវត្តវិធីសាស្ត្រក្នុងស្រុកសម្រាប់ដំណើរការធ្វើសេចក្ដីសម្រេចចិត្ត ឬដំណោះស្រាយវិវាទ។ | អារម្មណ៍សង្គម៖ ប្រៀបធៀបប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានជាមួយនឹងប្រព័ន្ធអភិ បាលកិច្ចនៅថ្នាក់ជាតិ និងក្នុងសហគមន៍ផ្សេងទៀត។ ពិនិត្យមើលពីរបៀបដែលជាន់គ្នា និងឱកាសរៀងៗខ្លួនដែលវាផ្ដល់សម្រាប់លទ្ធិប្រជាធិបតេយ្យ សមភាព និងយុត្តិធម៌។<br>អាកប្បកិរិយា៖ បង្កើតគម្រោងដែលពង្រឹងការអនុវត្ត និងចំណេះដឹងក្នុងមូលដ្ឋានដើម្បីរួមចំណែកយ៉ាងសកម្មដល់ប្រព័ន្ធត្រឹមត្រូវ និងយុត្តិធម៌ និងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ |
| **សិល្បៈនិងវប្បធម៌** | សង្កេតនិងវិភាគបេតិកភណ្ឌរស់ដែលបានជ្រើសរើស (ឧ.តម្លៃសោភ័ណភាព ការតុបតែង ចលនា លំដាប់លំដោយ និមិត្តសញ្ញា។ល។)។ ប្រៀបធៀបការប្រែប្រួលនៃសមាសធាតុ<br>(ការរចនាហត្ថកម្ម ចម្រៀង តន្ត្រី សាច់រឿង ។ល។) តាមរយៈពេលវេលា និងក្នុងសហគមន៍ផ្សេងៗគ្នា។<br>សូមក្រឡេកមើលពីការបង្ហាញនៃសមាសធាតុ (ឧ. សិល្បៈទស្សនីយភាព ហត្ថកម្ម ម្ហូបអាហារ ការប្រារព្ធពិធី) នៅក្នុងស្នាដៃសិល្បៈដែលមានស្រាប់ - ប្រសិនបើអាចធ្វើទៅបាន- ស្នាដៃសិល្បៈដ៏ល្បីល្បាញ។ ប្រើជាប្រភពនៃការបំផុសគំនិតដើម្បីបង្កើតស្នាដៃសិល្បៈថ្មី។<br>បញ្ជីសារពើភណ្ឌមានលំនាំផ្សេងៗគ្នា។ លាយថ្នាំពណ៌។<br>រចនាសម្លៀកបំពាក់សម្រាប់ទំនៀមទម្លាប់។ បង្កើតផ្ទាំងរូបភាពសម្រាប់ព្រឹត្តិការណ៍។ បង្កើតការផ្សាយពាណិជ្ជកម្មសម្រាប់វត្ថុ ឬផលិតផលអាហារ។ | ការយល់ដឹង៖ ទទួលស្គាល់សិទ្ធិវប្បធម៌ជាផ្នែកនៃសិទ្ធិមនុស្ស និងតម្រូវការក្នុងការគោរពវប្បធម៌ផ្សេងទៀត។<br>ស្វែងយល់ថាតើសិទ្ធិវប្បធម៌ត្រូវបានគោរពនៅគ្រប់ទីកន្លែងតាមរបៀបដូចគ្នាឬក៏អត់។<br>សម្របសម្រួលការយល់ដឹង និងការសន្ទនាជាមួយមនុស្សមកពីវប្បធម៌ផ្សេងៗ គ្នា។<br>អារម្មណ៍សង្គម៖ បង្ហាញពីអត្ថន័យនៃភាពជាសមាជិករបស់សហគមន៍មួយឬច្រើន។<br>កំណត់ភាពស្រដៀងគ្នា និងភាពខុសគ្នានៃសិល្បៈ និងការបង្ហាញវប្បធម៌នៅក្នុង<br>លក្ខណៈបច្ចេកទេស ក៏ដូចជាអត្ថន័យ និងគុណតម្លៃ។ ទទួលស្គាល់ថា ភាពខុសគ្នាគឺជាប្រភពនៃការបំផុសគំនិត និងបង្កើតភាពច្នៃប្រឌិត។ ជាលទ្ធផល រៀនឱ្យតម្លៃលើភាពចម្រុះនៃវប្បធម៌ និងលើកទឹកចិត្តឱ្យមានការអត់ឱន។ |

| មុខវិជ្ជាសិក្សា | ការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងមុខវិជ្ជាសិក្សា<br>ឧទាហរណ៍មួយចំនួន៖ | ជំរុញឥរិយាបថជាពលរដ្ឋសកលនៅពេលបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបី<br>ឧទាហរណ៍មួយចំនួន៖ |
|---|---|---|
| **សិល្បៈនិងវប្បធម៌** | ស្វែងយល់ពីចម្រៀងក្នុងស្រុក និងតន្ត្រីទាក់ទងនឹងទំនៀមទម្លាប់។ | អាកប្បកិរិយា៖ បង្កើត ឬចូលរួមសកម្មភាព ឬក្រុមដើម្បីចែករំលែកសិល្បៈ និងវប្បធម៌សហគមន៍របស់ខ្លួនជាមួយអ្នកដទៃ ( ឧ. ការប្រារព្ធថ្ងៃពិសេស ក្លឹបវប្បធម៌ )។<br>ជំរុញសមត្ថភាពសម្រាប់ការបង្ហាញពីខ្លួនឯង។<br>រៀបចំការច្នៃប្រឌិតសិល្បៈអន្តរវប្បធម៌រួមគ្នា។ |
| **ការអប់រំកាយ** | រៀន និងទម្លាប់ហាត់សម (របាំ<br>ការសម្តែងសៀក ការសម្តែងល្ខោន។ល។)។<br>លេងល្បែងប្រជាប្រិយ<br>ហាត់កីឡាប្រពៃណី<br>ចូលរួមក្នុងការងារកសិកម្មបែបប្រពៃណី | ការយល់ដឹង៖ស្វែងយល់ពីច្បាប់ ទម្លាប់និងប្រវត្តិល្បែងពីសហគមន៍មូលដ្ឋាន និងក្រៅពីនេះ។<br>លើកទឹកចិត្តសិស្សឱ្យចែករំលែកជំនាញ និងចំណេះដឹងរបស់ពួកគេអំពីកីឡា និងល្បែងក្នុងស្រុកជាមួយមិត្តភក្តិរបស់ពួកគេ ដើម្បីជួយគ្នាទៅវិញទៅមក និងស្វែងរកវិធីដើម្បីរីកចម្រើនជាមួយគ្នា។<br>ពិចារណាពីអត្ថប្រយោជន៍ខាងផ្លូវកាយ សង្គម និងផ្លូវអារម្មណ៍នៃកីឡា និងល្បែងក្នុងស្រុក និងលើជំនាញ និងតម្លៃដែលត្រូវបានផ្សព្វផ្សាយតាមរយៈការអនុវត្ត ( ឧ. ភាពក្លាហាន ការសហការ ភាពសមសួន ការអត់ធ្មត់ ការតស៊ូ ការបង្ហាញ និងយុទ្ធសាស្ត្រល្បឿន និងកម្លាំង។ល។ )។<br>អារម្មណ៍សង្គម៖ លើកកម្ពស់ការងារជាក្រុម ភាពស្អិតរមួតក្នុងសង្គម និងភាពយុត្តិធម៌ និងការឱ្យតម្លៃលើភាពចម្រុះតាមរយៈការលេងកីឡា និងការលេងល្បែងប្រពៃណី។<br>អាកប្បកិរិយា៖ បង្កើត ឬចូលរួមសកម្មភាព ឬក្រុមដើម្បីចែករំលែកកីឡា និងល្បែងសហគមន៍ក្នុងតំបន់ជាមួយអ្នកដទៃ។ រៀបចំការប្រកួតលក្ខណៈមិត្តភាព។ |

| មុខវិជ្ជាសិក្សា | ការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងមុខវិជ្ជាសិក្សា<br>ឧទាហរណ៍មួយចំនួន៖ | ជំរុញឥរិយាបថជាពលរដ្ឋសកលនៅពេលបង្រៀនជាមួយបេតិកភណ្ឌវប្បធម៌អរូបី<br>ឧទាហរណ៍មួយចំនួន៖ |
|---|---|---|
| **ការរៀបរាប់សង្ខេប៖ ជំនាញ និង តម្លៃសង្គម** | ការងារជាក្រុម និងការសហការ<br>ការសង្កេត និងការយកចិត្តទុកដាក់ចំពោះព័ត៌មានលម្អិត<br>អត់ធ្មត់<br>ការឱ្យតម្លៃភាពចម្រុះ (ភេទ ជាតិសាសន៍ សាសនា ជំនាន់។ល។)។<br>ការយល់ដឹងអំពីទំនាក់ទំនងសង្គមដែលភ្ជាប់ទៅនឹងការអនុវត្ត (ជាពិសេសនៅពេលដែលស្ត្រី និងក្រុមជនជាតិភាគតិចចូលរួម)។ | ការយល់ដឹង៖ កំណត់ជំនាញ និងគុណតម្លៃសង្គមដែលមានសារៈសំខាន់នៅក្នុងសហគមន៍របស់សិស្ស។ ឆ្លុះបញ្ចាំងពីភាពរស់រវើកក្រុមក្នុងតំបន់ និងយន្តការដោះស្រាយវិវាទ។<br>អារម្មណ៍សង្គម៖លើកទឹកចិត្តឱ្យមានការពិភាក្សា និងការផ្លាស់ប្តូរយោបល់។<br>ផ្តល់អាទិភាពដល់សកម្មភាពដែលដឹកនាំដោយសិស្ស ដូច្នេះតម្លៃដែលមានសារៈសំខាន់នៅក្នុងសហគមន៍របស់ពួកគេ និងចំពោះពួកគេនឹងត្រូវបានបង្ហាញតាមរយៈទំនាក់ទំនងជាក្រុម។<br>អាកប្បកិរិយា៖ អញ្ជើញភ្ញៀវមកពីមជ្ឈមណ្ឌលវប្បធម៌ចម្រុះដើម្បីចែករំលែកចំណេះដឹង និងទស្សនៈរបស់ពួកគេអំពីបេតិកភណ្ឌវប្បធម៌អរូបីជាមួយសិស្ស។<br>ស្នើឱ្យសិស្សឱ្យបង្កើតគម្រោងដែលទាក់ទងនឹងបេតិកភណ្ឌវប្បធម៌អរូបីរបស់ខ្លួន ដែលលើកកម្ពស់សន្តិភាព និរន្តរភាព និងក្រមសីលធម៌ (ផ្តោតលើការអនុវត្តបេតិកភណ្ឌវប្បធម៌អរូបីដោយផ្ទាល់ និងកិច្ចការពារ ឬរួមបញ្ចូលចំណេះដឹងនិងការអនុវត្ត)។ |

# ឯកសារទី ៣៖ ឧទាហរណ៍កិច្ចតែងការបង្រៀនដែលបានសាកល្បង និងធ្វើតេស្ត

ផ្នែកនេះ ផ្តល់នូវឧទាហរណ៍អំពីកិច្ចតែងការបង្រៀនដែលគ្រូបានប្រើប្រាស់។ គំរូឧទាហរណ៍នេះអាចជួយឱ្យអ្នកបង្កើតកិច្ចតែងការបង្រៀនផ្ទាល់ខ្លួនបាន។

តារាង T៣ បង្ហាញអំពីកិច្ចតែងការបង្រៀនចំនួន ១៤ ដែលមានផ្តល់ជូននៅក្នុងផ្នែកនេះ ដោយបែងចែកតាមមុខវិជ្ជានីមួយៗ។

តារាង T៣ ៖ មុខវិជ្ជា និងកិច្ចតែងការបង្រៀន

| មុខវិជ្ជា | ប្រធានបទកិច្ចតែងការបង្រៀន |
|---|---|
| ភាសា និងអក្សរសាស្ត្រ | *Dutar* – the Ballad of Abdugopur Kutlukov |
| | ការនិទានរឿង |
| គណិតវិទ្យា | ការគុណ និងចែកដោយប្រើគ្រាប់ឡុកឡាក់ |
| | ត្រីកោណមាត្រជាមួយនឹងការធ្វើជណ្តើរបែបបុរាណ |
| វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា | បច្ចេកវិទ្យាបុរាណទាក់ទងនឹងទឹក |
| | ចំណេះដឹងប្រពៃណីទាក់ទងនឹងរុក្ខជាតិ និងការធ្វើសាប៊ូ |
| ប្រវត្តិសាស្ត្រ និង វិទ្យាសាស្ត្រសង្គម | ប្រវត្តិគ្រួសារ៖ ការរៀបចំមែកធាងគ្រួសារ |
| | កាហ្សាក់ស្ថានក្នុងអំឡុងពេលសង្គ្រាមលោកលើកទីពីរ |
| | ក្រឡេកមើលវប្បធម៌ *Kimjang*៖ គម្រោងកម្មវិធីសិក្សាបន្ថែម |
| ពលរដ្ឋវិទ្យា | អ្នកសុបិន តើក្រុម *Namsadang Nori* សុបិនអំពីអ្វី? គម្រោងថ្នាក់រៀនមួយ |
| សិល្បៈ និងវប្បធម៌ | ចម្លាក់ឈើ Lanna ថៃ |
| | ការរចនាខ្លែង |
| អប់រំសុខភាព និងអប់រំកាយ | ល្បែងប្រពៃណី Kyrgyz |
| | គោរពស្ថាប័នរបស់យើង - ការបង្កើត mandala សម្រាប់ *Mha: Puja* |

ឧទាហរណ៍បន្ថែមមាននៅក្នុងកន្លែងរក្សាទុកនៅបណ្តាញ UNESCO clearinghouse អំពីបេតិកភណ្ឌរស់ និងការអប់រំ៖ Click

## ភាសា និងអក្សរសាស្ត្រ

**កិច្ចតែងការបង្រៀនទី ១៖** *Dutar* – the Ballad of Abdugopur Kutlukov

| មុខវិជ្ជាសិក្សា | ថ្នាក់ | សមាសធាតុ ICH | ប្រទេស | រយៈពេល |
|---|---|---|---|---|
| ភាសា និងអក្សរសាស្ត្រ Uyghur តន្ត្រី | 7 | ប្រពៃណីតាមការចងចាំ / សិល្បៈ<br>ទស្សនីយភាព / សិប្បកម្មបុរាណ | កាហ្សាក់ស្ថាន | ១ វគ្គ |

### គោលបំណងមេរៀន៖

| | |
|---|---|
| **វិជ្ជាសម្បទា** | • ស្វែងយល់អំពី Ballad of Abdugopur Kutlukov។<br>• ស្វែងយល់អំពីតួនាទីរបស់ឧបករណ៍ពីរ៖ Uyghur *Dutar* និង Kazakh *Dombra* នៅក្នុងវប្បធម៌រៀងៗខ្លួន។ |
| **បំណិនសម្បទា** | • វិភាគផែនការ និងកំណត់លក្ខណៈសំខាន់ៗរបស់តួអក្សរនៅក្នុងពាក្យកាព្យ។<br>• រៀនទាញសេចក្ដីសន្និដ្ឋានអំពីព័ត៌មានដែលទទួលបាន។<br>• ប្រៀបធៀបឧបករណ៍ពីរគឺ Uyghur *Dutar* និង Kazakh *Dombra*។<br>• អភិវឌ្ឍជំនាញក្នុងការទំនាក់ទំនង៖ ផ្លាស់ប្ដូរគំនិតយោបល់លើអត្ថន័យនៃសាច់រឿង។ |
| **ចរិយាសម្បទា** | • យល់ដឹងអំពីសារៈសំខាន់ និងតម្លៃនៃបេតិកភណ្ឌរស់។ |

**សម្ភារៈពិសេសដែលត្រូវការ៖** ការបង្ហាញអមដោយរូបភាពសម្រាប់ពាក្យកាព្យ វីដេអូអំពីដំណើរការនៃការបង្កើតឧបករណ៍ *Dombra* និង *Dutar*។

### គោលបំណងមេរៀន៖

- គ្រូណែនាំថាតើបេតិកភណ្ឌរស់ជាអ្វី។
- សិស្សពិភាក្សាក្នុងថ្នាក់៖ តើបេតិកភណ្ឌរស់អ្វីខ្លះដែលបុព្វការីបានបន្សល់ទុកឱ្យយើង? អាចជាឧបករណ៍ភ្លេង និង *mukam* ១២ (បទភ្លេង ការតែងនិពន្ធបទភ្លេង ឬការច្នៃប្រឌិត) ត្រូវបានគេហៅថាជាបេតិកភណ្ឌរស់? ហេតុអ្វី?
- ជាក្រុម សិស្សអានអត្ថបទអំពី Ballad of Abdugopur Kutlukov។ សិស្សត្រូវវិភាគអំពីរចនាសម្ព័ន្ធនៃអត្ថបទ និងសង្ខេបខ្លឹមសារ។
- សិស្សមើលវីដេអូអំពីដំណើរការបង្កើតឧបករណ៍ Uyghur *Dutar* និង Kazakh *Dombra*
- សិស្សប្រៀបធៀបបេតិកភណ្ឌរូបី និងអរូបីដោយមានជំនួយពីរូបភាព។



## គោលបំណងមេរៀន៖

- សិស្សត្រូវសរសេរចម្លើយសម្រាប់សំណួរខាងក្រោម៖ តើអ្នកគិតថា មនុស្សទាំងអស់អាចបង្កើតឧបករណ៍ភ្លេង ដូចជា Uyghur *Dutar* ឬ Kazakh *Dombra* បានដែរឬទេ ? តើត្រូវការជំនាញអ្វីខ្លះ ? តាមគំនិតរបស់អ្នក តើអ្វីជាភាពខុសគ្នានិងភាពស្រដៀងគ្នារវាង *Dutar* និង *Dombra*? សិស្សអាចរៀបចំបទបង្ហាញជារូបភាពអំពីភាពស្រដៀងគ្នា និងភាពខុសគ្នានៃឧបករណ៍ភ្លេងពីរនៅក្នុងដ្យាក្រាម Venn។

## កិច្ចតែងការបង្រៀនទី ២៖ ការនិទានរឿង

| មុខវិជ្ជាសិក្សា | ថ្នាក់ | សមាសធាតុ ICH | ប្រទេស | រយៈពេល |
|---|---|---|---|---|
| ភាសាថៃ ភាសាអង់គ្លេស សម្រាប់ទេសចរណ៍ ICT ការសិក្សាសង្គម គម្រោងរបស់សិស្ស | ទី ៦ | អាហារក្នុងស្រុក និងទម្លាប់ក្នុងស្រុក | ថៃ | ១ ខែ |

### គោលបំណងមេរៀន៖

| | |
|---|---|
| **វិជ្ជាសម្បទា** | • ស្វែងយល់អំពីប្រពៃណី វប្បធម៌ ជំនឿ និងរបៀបរស់នៅរបស់ជនជាតិដើមចំនួនប្រាំបីក្រុមនៅក្នុងស្រុក។ |
| **បំណិនសម្បទា** | • វិភាគ និងបង្ហាញអំពីគំនិតក្នុងទម្រង់ផ្សេងៗ។<br>• ប្រើប្រព័ន្ធផ្សព្វផ្សាយមួយចំនួនដើម្បីបង្ហាញអំពីគំនិតច្នៃប្រឌិត (រូបថតនិង វីដេអូ)។ |
| **ចរិយាសម្បទា** | • មានមោទនភាពចំពោះបេតិកភណ្ឌរស់របស់អ្នក ហើយចាប់អារម្មណ៍លើការអភិរក្ស និងការផ្ទេរចំណេះដឹងវប្បធម៌។<br>• បង្កើតចំណាប់អារម្មណ៍លើវប្បធម៌របស់អ្នកដទៃ។ |

**សម្ភារៈពិសេសដែលត្រូវការ៖** ឧបករណ៍វីដេអូសម្រាប់អំណាន និងទស្សនាដោយសកម្ម។ ទូរសព្ទ ឬកាមេរ៉ារបស់សិស្ស កុំព្យូទ័រដែលមានកម្មវិធីសមស្របសម្រាប់ការកែសម្រួលវីដេអូ។

### សកម្មភាព៖

#### វគ្គទី ១៖

- គ្រូផ្តល់ការណែនាំអំពីគម្រោង និងពន្យល់អំពីទំនៀមទម្លាប់ វប្បធម៌ ជំនឿ និងរបៀបរស់នៅមួយចំនួនរបស់ជនជាតិដើមចំនួនប្រាំបីក្រុមនៅក្នុងស្រុក Mae Ai ដូចជា៖ Lahu, Karen, Akha, Lisu, Palaung, Tai Lue, Shan, Chinese Hor។
- សិស្សមើលវីដេអូឯកសារខ្លីមួយ ដោយវីដេអូនោះបង្ហាញអំពីស្ត្រីវ័យក្មេងម្នាក់បានចុះទៅកាន់សហគមន៍មួយចំនួន និងស្វែងយល់អំពីវិធីប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់ ដោយរៀបរាប់អំពីសកម្មភាពប្រចាំថ្ងៃរបស់ពួកគេ និងការសម្ភាសន៍សមាជិកសហគមន៍។ បន្ទាប់មកសិស្សអនុវត្តការមើលសកម្មនិងបង្កើតផែនទីគំនិតដើម្បីសង្ខេបខ្លឹមសារ។ ពួកគេចែករំលែកលទ្ធផលរកឃើញរបស់ពួកគេជាមួយមិត្តរួមថ្នាក់របស់ខ្លួន។

### វគ្គទី ២៖

- សិស្សអានរឿងនិទានអំពីបេតិកភណ្ឌរស់ និងអនុវត្តការអានសកម្ម។ ពួកគេបញ្ចេញមតិយោបល់របស់ពួកគេអំពីរឿងនិទានជាមួយមិត្តរួមថ្នាក់របស់ពួកគេ។ ជាក្រុមតូចៗ ពួកគេបង្កើតផែនទីគំនិត ដើម្បីសង្ខេបចំណុចសំខាន់ៗនៃការនិទានរឿង៖ ប្រធានបទ បញ្ហា ចំណុចដែលធ្វើឱ្យសាច់រឿងនេះគួរឱ្យចាប់អារម្មណ៍។ បន្ទាប់មកពួកគេចែករំលែកផែនទីរបស់ពួកគេជាមួយថ្នាក់រៀន។

### វគ្គទី ៣៖

- ដោយធ្វើការជាក្រុម សិស្សត្រូវកំណត់រកប្រធានបទមួយសម្រាប់រឿងនិទានផ្ទាល់ខ្លួនរបស់ពួកគេអំពីប្រពៃណី វប្បធម៌ ជំនឿ របៀបរស់នៅរបស់ជនជាតិចំនួនប្រាំបីក្រុមនៅក្នុងស្រុក Mae Ai ។
- គ្រូណែនាំអំពីបច្ចេកទេសសម្ភាសន៍ និងការប្រមូលព័ត៌មានប្រកបដោយក្រមសីលធម៌។
- សិស្ស (ជាក្រុម) បង្កើតផែនការស្រាវជ្រាវ។
- គ្រូជួយក្រុមក្នុងការកែលម្អផែនការស្រាវជ្រាវរបស់ពួកគេ និងធានាថា សិស្សអនុវត្តវិធីសាស្ត្រស្រាវជ្រាវប្រកបដោយក្រមសីលធម៌។

### ការងារស្រាវជ្រាវ (បន្ទាប់ពីការសិក្សានៅសាលា)៖

- សិស្សធ្វើកិច្ចការស្រាវជ្រាវរបស់ពួកគេអំឡុងពេលទំនេរ។ ពួកគេសម្ភាសន៍មនុស្សអំពីអនុវត្តបេតិកភណ្ឌរបស់ខ្លួន ហើយកត់ត្រាព័ត៌មាន និងថតរូប។ បន្ទាប់មក ពួកគេបង្កើតសាច់រឿង ដើម្បីប្រែក្លាយព័ត៌មានទៅជាសាច់រឿង។
- សិស្សក្នុងក្រុមនីមួយៗពិភាក្សាអំពីវឌ្ឍនភាពរបស់ពួកគេជាមួយគ្រូ ហើយកែសម្រួលកិច្ចការរបស់ពួកគេស្របតាមការផ្តល់មតិយោបល់ និងមតិកែលម្អពីគ្រូ។

### វគ្គទី ៤៖

- នៅក្នុងថ្នាក់រៀន សិស្សក្នុងក្រុមនីមួយៗធ្វើបទបង្ហាញអំពីកិច្ចការចុងក្រោយរបស់ពួកគេដល់មិត្តរួមថ្នាក់។ ពួកគេពន្យល់អំពីមូលហេតុដែលពួកគេជ្រើសរើសប្រធានបទនោះ ក៏ដូចជាបញ្ហា និងបទពិសោធន៍គួរឱ្យចាប់អារម្មណ៍ដែលពួកគេមានក្នុងអំឡុងពេលធ្វើកិច្ចការ។ សិស្សផ្សេងទៀតផ្តល់មតិកែលម្អ និងសំណូមពរ ដើម្បីកែលម្អផលិតផលចុងក្រោយនោះ។
- សិស្សបានបង្ហោះលទ្ធផលរកឃើញរបស់ពួកគេនៅលើទំព័រហ្វេសប៊ុកដើម្បីចែករំលែកឱ្យកាន់តែទូលំទូលាយ និងបង្កើតសៀវភៅអេឡិចត្រូនិកដែលមានសាច់រឿងមួយចំនួនរបស់ពួកគេផងដែរ។

## គណិតវិទ្យា

### កិច្ចតែងការបង្រៀនទី ៣៖ ការគុណ និងចែកដោយប្រើគ្រាប់ឡុកឡាក់

| មុខវិជ្ជាសិក្សា | ថ្នាក់ | សមាសធាតុ ICH | ប្រទេស | រយៈពេល |
|---|---|---|---|---|
| គណិតវិទ្យា | 2 | លេងល្បែងប្រជាប្រិយ | គៀជីស្ថាន | ១ វគ្គ |

### គោលបំណងមេរៀន៖

| | |
|---|---|
| **វិជ្ជាសម្បទា** | • ស្វែងយល់អំពីច្បាប់នៃល្បែងគ្រាប់ឡុកឡាក់បែបប្រពៃណី ឧ. Chuko Atmai។<br>• បង្កើតវាក្យសព្ទទាក់ទងនឹងល្បែង។<br>• ដោះស្រាយបញ្ហាគណិតវិទ្យាទូទៅ។ |
| **បំណិនសម្បទា** | • អនុវត្តការគុណ និងការចែក។<br>• ហាត់បោះគ្រាប់ឡុកឡាក់ដើម្បីលេងល្បែងប្រពៃណី Chuko Atmai ។<br>• អភិវឌ្ឍជំនាញផ្តោតអារម្មណ៍យកចិត្តទុកដាក់។ |
| **ចរិយាសម្បទា** | • ដឹងអំពីសារៈសំខាន់នៃល្បែងប្រពៃណី។<br>• យល់ថា គណិតវិទ្យាត្រូវបានប្រើប្រាស់ក្នុងជីវិតប្រចាំថ្ងៃ រួមទាំងក្នុងការលេងល្បែងផងដែរ។ |

**សម្ភារៈពិសេសដែលត្រូវការ៖** សៀវភៅគណិតវិទ្យា សៀវភៅលំហាត់ បន្ទាត់ ឯកសារវីដេអូដែលបានជ្រើសរើស ថង់ដាក់គ្រាប់ឡុកឡាក់។

### សកម្មភាព៖

- គ្រូបង្ហាញថង់មួយដល់សិស្ស (ហៅថា kurzhun ជាភាសា Kyrgyz) ហើយឱ្យពួកគេទាយថាតើមានអ្វីនៅក្នុងថង់នោះ។
- សិស្សត្រូវទាយរបស់នៅក្នុងនោះ។
- បន្ទាប់មក គ្រូបង្ហាញគ្រាប់ឡុកឡាក់នៅក្នុងថង់នោះ ហើយពន្យល់អំពីថង់ និងរបៀបលេងគ្រាប់ឡុកឡាក់ក្នុងល្បែងប្រពៃណី។ សិស្សប្រាប់មិត្តរួមថ្នាក់របស់ពួកគេអំពីឈ្មោះល្បែងគ្រាប់ឡុកឡាក់ដែលពួកគេបានលេងរួចហើយ ហើយមួយណាដែលពួកគេចូលចិត្តជាងគេ។
- គ្រូបង្ហាញការគុណ និងចែកដោយប្រើគ្រាប់ឡុកឡាក់។(ឧទាហរណ៍៖ ខ្ញុំមានគ្រាប់ឡុកឡាក់ចំនួន ២០ នៅក្នុងថង់របស់ខ្ញុំ ប្រសិនបើខ្ញុំចែកឱ្យសិស្សចំនួន ៥ នាក់ សិស្សម្នាក់ៗនឹងទទួលបានគ្រាប់ឡុកឡាក់ចំនួន ៤។ ២០:៥=៤ ។ល។)

- តាមរយៈការធ្វើការជាគូ សិស្សត្រូវដោះស្រាយលំហាត់មួយចំនួនដោយប្រើលេខគុណ និងលេខចែក ដោយមានជំនួយពីគ្រាប់ឡុកឡាក់។
- ក្រោយពីបញ្ចប់កិច្ចការនេះរួច សិស្សក៏លេងល្បែង Chuko Atmai។

**កិច្ចការផ្ទះ៖** សិស្សដោះស្រាយបញ្ហាគណិតវិទ្យានៅក្នុងសៀវភៅរបស់ពួកគេ។ ពួកគេត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់វត្ថុក្នុងស្រុកដែលមាននៅតាមផ្ទះ ដើម្បីធ្វើកិច្ចការផ្ទះរបស់ពួកគេ។

Chuko Atmai ត្រូវលេងជាមួយគ្រាប់ឡុកឡាក់ (*alchik*) អ្នកចូលរួមគូសរង្វង់ដែលមានអង្កត់ផ្ចិតពី ៣ ទៅ ៥ ម៉ែត្រ។ ត្រូវដាក់ *alchik* នៅចំកណ្ដាលរង្វង់។ ត្រូវគូសបន្ទាត់ពីឃ្លាតចម្ងាយមួយម៉ែត្រពីរង្វង់នៅសងខាង។ ប្រសិនបើ *alchik* ត្រូវបានវាយចេញពីបន្ទាត់បន្ទាប់ពីការវាយដោយជោគជ័យលើកដំបូង ការវាយផ្សេងទៀតត្រូវបានធ្វើឡើងចេញពីបន្ទាត់រង្វង់។ ក្នុងករណីវាយមិនបានសម្រេច អ្នកលេងម្នាក់ទៀតត្រូវចូលមកលេងម្ដង។ អ្នកលេងដែលវាយចេញលេខធំជាងគេនៃ *alchik* គឺជាអ្នកឈ្នះ។

## កិច្ចតែងការបង្រៀនទី ៤៖ ត្រីកោណមាត្រជាមួយនឹងការធ្វើជណ្ដើរបែបបុរាណ

| មុខវិជ្ជាសិក្សា | ថ្នាក់ | សមាសធាតុ ICH | ប្រទេស | រយៈពេល |
|---|---|---|---|---|
| គណិតវិទ្យា (ត្រីកោណមាត្រ) | ទី ៩ | ការធ្វើជណ្ដើរបែបបុរាណ | នេប៉ាល់ | ១២ វគ្គ |

### សកម្មភាព៖

| | |
|---|---|
| **វិជ្ជាសម្បទា** | • គណនាសមាមាត្រត្រីកោណមាត្រជាមួយត្រីកោណដែលមានមុំនៅខាងស្ដាំ។ |
| **បំណិនសម្បទា** | • អភិវឌ្ឍជំនាញដោះស្រាយចំណោទ។<br>• ទទួលបានជំនាញជាងឈើមូលដ្ឋានដើម្បីសាងសង់ជណ្ដើរដែលមានកម្ពស់ និងមុំខុសៗគ្នា។ |
| **ចរិយាសម្បទា** | • គោរពវិជ្ជាជីវៈនីមួយៗ។<br>• អភិវឌ្ឍស្មារតីក្រុម និងកិច្ចសហប្រតិបត្តិការ។ |

**សម្ភារៈពិសេសដែលត្រូវការ៖** ឧបករណ៍វីដេអូ បន្ទះក្ដារ រណារ ដែកគោល ថ្នាំលាប និងដក់។

## សកម្មភាព៖

### វគ្គទី ១៖

- គ្រូណែនាំអំពីត្រីកោណមាត្រ និងពន្យល់អំពីការប្រើប្រាស់វាក្នុងជីវិតប្រចាំថ្ងៃ។ គាត់បង្ហាញរូបមន្តសមាមាត្រ ដើម្បីគណនាប្រវែងជណ្ដើរទៅតាមកម្ពស់ជញ្ជាំង និងមុំដែលចង់បាន។
- សិស្សអនុវត្តលំហាត់គណនាមួយចំនួន។

### វគ្គទី ២-៦៖ ដំណើររកម្សាន្ត

- សិស្សស្វែងរកព័ត៌មានអំពីការធ្វើជណ្ដើរបែបប្រពៃណីនៅក្នុងតំបន់ជិតខាងរបស់ពួកគេ។
- ពួកគេសម្ភាសន៍សិប្បករក្នុងស្រុក និងសង្កេតមើលការងាររបស់ពួកគាត់។
- ពួកគេវាស់ជណ្ដើរដែលមានស្រាប់ និងកត់ត្រាព័ត៌មាន។
- ពួកគេពិភាក្សាអំពីមូលហេតុដែលកាំជណ្ដើរនីមួយៗគួរតែស្របទៅនឹងកម្រិតដី ហើយតើអ្វីជាភាពខុសគ្នារវាងមុំនៃជណ្ដើរប្រពៃណី និងជណ្ដើរបេតុង។ ពួកគេប្រៀបធៀបរូបមន្តទ្រឹស្ដី និងតាមការសង្កេតផ្ទាល់របស់ពួកគេ។

### វគ្គទី ៧-១២៖ ការអនុវត្តជាក់ស្ដែង

- ជាក្រុម សិស្សបានធ្វើជណ្ដើរដែលមានទំហំប៉ុនការចង់បានរបស់ពួកគេ ដោយប្រើបន្ទះក្ដារ។ ក្រុមមួយធ្វើជណ្ដើរដែលមានមុំ ៤៥ ដឺក្រេ។ ក្រុមមួយទៀតធ្វើជណ្ដើរដែលមានមុំ ៦០ ដឺក្រេ។ លំហាត់អនុវត្តជាក់ស្ដែងរួមមាន៖
  - ការគណនាប្រវែង និងមុំ និងបង្កើតប្លង់មេ ដោយប្រើសមាមាត្រត្រីកោណមាត្រ។
  - កាត់បន្ទះក្ដារតាមប្រវែងដែលចង់បាន។
  - លាបថ្នាំឈើនោះ។
  - ការផ្គុំជណ្ដើរ។
- សិស្សប្រៀបធៀបជណ្ដើររបស់ពួកគេ ហើយពិភាក្សាអំពីភាពខុសគ្នា

## វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

### កិច្ចតែងការបង្រៀនទី ៥៖ បច្ចេកវិទ្យាបុរាណទាក់ទងនឹងទឹក

| មុខវិជ្ជាសិក្សា | ថ្នាក់ | សមាសធាតុ ICH | ប្រទេស | រយៈពេល |
|---|---|---|---|---|
| ការអប់រំបច្ចេកវិទ្យា | ទី ៨ | Tya:pa (ផើងដី) ការប្រើប្រាស់ផុងទឹកប្រពៃណី | នេប៉ាល់ | ៣ វគ្គ + ការតាំងពិព័រណ៍ |

### គោលបំណងមេរៀន៖

| | |
|---|---|
| **វិជ្ជាសម្បទា** | • យល់ពីរបៀបប្រើប្រាស់ *tya:pa*។<br>• កំណត់អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ *tya:pa*។<br>• ប្រៀបធៀបបច្ចេកវិទ្យាបុរាណ និងទំនើប។ |
| **បំណិនសម្បទា** | • បង្ហាញទស្សនៈ និងមតិយោបល់ក្នុងក្រុម។<br>• បង្ហាញព័ត៌មាននៅលើផ្ទាំងរូបភាព។<br>• អភិវឌ្ឍជំនាញច្នៃប្រឌិត និងការបង្កើត *tya:pa*។ |
| **ចរិយាសម្បទា** | • ទទួលបានការគោរពចំពោះយោបល់របស់អ្នកដទៃ។<br>• បង្កើតឥរិយាបថវិជ្ជមានចំពោះការប្រើប្រាស់បច្ចេកវិទ្យាបុរាណ។ |

**សម្ភារៈពិសេសដែលត្រូវការ៖** ក្រដាសគំនូសតាង បន្ទាត់ ខ្មៅដៃ ប៊ិចពណ៌ ហ្វឺត ការបិទ ជីឥដ្ឋ តារាង KWL និងក្រដាសចម្លើយរបស់សិស្ស *tya:pa* មួយចំនួន (ផើងដាក់ទឹកធ្វើពីដី) សម្រាប់ដាក់តាំងក្នុងថ្នាក់ ឧបករណ៍វីដេអូ។

### សកម្មភាព៖

#### វគ្គទី ១៖

- សិស្សបំពេញក្នុងបន្ទាត់ចំនួន ២ ដំបូងក្នុងតារាង "ដឹង-ចង់ដឹង-សិក្សា" (KWL) ដើម្បីបង្ហាញអំពីអ្វីដែលពួកគេដឹង (K) និងចង់ដឹង (W) អំពី *tya:pa*។ បន្ទាប់មកពួកគេចែករំលែកវាជាមួយសិស្សក្នុងថ្នាក់។
- គ្រូបង្រៀនចាប់ផ្តើមធ្វើបាឋកថាខ្លីមួយ និងចាក់វីដេអូដើម្បីផ្តល់ចម្លើយចំពោះសំណួរ៖ តើអ្វីទៅជា tya:pa? តើសហគមន៍មួយណាប្រើប្រាស់វា? តើ *tya:pa* បង្កើតឡើងពីអ្វី? តើការប្រើប្រាស់ *tya:pa* មានអត្ថប្រយោជន៍អ្វីខ្លះ?
- សិស្សពិភាក្សាអំពីអត្ថប្រយោជន៍ ដោយការប្រើប្រាស់ *tya:pa* ឬវត្ថុស្រដៀងគ្នានៅក្នុងផ្ទះរបស់ពួកគេ។ ពួកគេអាចមើលទិដ្ឋភាពផ្សេងៗដូចជា៖ សេដ្ឋកិច្ច បរិស្ថាន ភាពជាក់ស្តែង។ល។



**វគ្គទី ២៖**

- គ្រូបង្រៀនធ្វើបាឋកថាខ្លីមួយនិងបង្ហាញឧបករណ៍វីដេអូអំពីបច្ចេកវិទ្យាបុរាណ និងទំនើប។
- សិស្សពិភាក្សាអំពីប្រភេទនៃបច្ចេកវិទ្យាដែលប្រើនៅក្នុងផ្ទះឬក្នុងតំបន់របស់ពួកគេ ហើយកំណត់អំពីចំណុចខុសគ្នាយ៉ាងតិចចំនួនបីរវាងធុងទឹក *tya:pa* បុរាណ និងធុងទឹកទំនើប។
- សិស្សបំពេញក្នុងបន្ទាត់ចុងក្រោយនៃតារាង KWL៖ L អ្វីដែលពួកគេបានរៀន។

**វគ្គទី ៣៖**

- គ្រូផ្តល់ការណែនាំអំពីសកម្មភាពជាក់ស្តែងនេះ (ការគូរ និងការបង្កើត *tya:pa* និងការបង្កើតផ្ទាំងរូបភាព)។
- សិស្សគូរធុងទឹក *tya:pa* បុរាណ និងធុងទឹកទំនើប។
- សិស្សត្រូវធ្វើការជាក្រុម ដើម្បីរៀបចំផ្ទាំងរូបភាព សម្រាប់បង្ហាញអំពី *tya:pa* និងអត្ថប្រយោជន៍របស់វា។
- សិស្សបង្កើត *tya:pa* តូចៗធ្វើពីដីឥដ្ឋ។

**ការតាំងពិព័រណ៍៖**

- ត្រូវរៀបចំការតាំងពិព័រណ៍ *tya:pa* តូចៗដែលពួកគេបានបង្កើតឡើង និងផ្ទាំងរូបភាពដែលពួកគេបានរចនាឡើងនៅក្នុងថ្នាក់។
- សិស្សបង្ហាញអំពីការងាររបស់ខ្លួន និងរៀបរាប់អំពីការងាររបស់ពួកគេទៅកាន់អ្នកទស្សនា។

### កិច្ចតែងការបង្រៀនទី ៦៖ ចំណេះដឹងបែបប្រពៃណីទាក់ទងនឹងរុក្ខជាតិ និងការធ្វើសាប៊ូ

| មុខវិជ្ជាសិក្សា | ថ្នាក់ | សមាសធាតុ ICH | ប្រទេស | រយៈពេល |
|---|---|---|---|---|
| ជីវវិទ្យា គីមីវិទ្យា ភូមិវិទ្យា គម្រោងរបស់សិស្ស | ទី ៩ | ចំណេះដឹងបែបប្រពៃណីទាក់ទងនឹងរុក្ខជាតិ និងការធ្វើសាប៊ូ | គៀជីស្ថាន | ១ ខែ |

## គោលបំណងមេរៀន៖

| | |
|---|---|
| **វិជ្ជាសម្បទា** | • ស្វែងយល់អំពីចំណេះដឹងបែបប្រពៃណីទាក់ទងនឹងរុក្ខជាតិ និងការធ្វើសាប៊ូ។<br>• ទទួលបានព័ត៌មានមូលដ្ឋានអំពីការសិក្សាពីរុក្ខជាតិក្នុងស្រុក។<br>• ស្វែងយល់អំពីប្រវត្តិនៃការធ្វើសាប៊ូនៅគៀជីស្ថាន។ |
| **បំណិនសម្បទា** | • រៀនធ្វើសាប៊ូ។<br>• អនុវត្តជំនាញពិភាក្សា។ |
| **ចរិយាសម្បទា** | • ស្វែងយល់អំពីសារៈសំខាន់នៃរុក្ខជាតិក្នុងស្រុក និងការប្រើប្រាស់របស់វា ។<br>• យល់ដឹងអំពីសារៈសំខាន់នៃការថែរក្សាចំណេះដឹងបែបប្រពៃណីទាក់ទងនឹងរុក្ខជាតិក្នុងស្រុក។ |

**សម្ភារៈពិសេសដែលត្រូវការ៖** ឯកសារវីដេអូ រុក្ខជាតិ និងសម្ភារៈផ្សេងទៀតដែលត្រូវការសម្រាប់ផលិតសាប៊ូ។

## សកម្មភាព៖

សកម្មភាពនេះត្រូវបានធ្វើឡើងក្នុងរយៈពេលមួយខែ។

- គ្រូចាប់ផ្តើមដោយការបង្ហាញព័ត៌មានអំពីចំណេះដឹងបែបប្រពៃណីទាក់ទងនឹងរុក្ខជាតិ និងប្រវត្តិនៃការធ្វើសាប៊ូ។ សិស្សមើលវីដេអូស្តីពីប្រធានបទ។
- សិស្សត្រូវធ្វើការរៀងៗខ្លួនដើម្បីស្រាវជ្រាវអំពីរុក្ខជាតិឱសថនៅក្នុងទឹកដីនៃប្រទេសគៀជីស្ថាន (ឧ. កន្លែងដែលរុក្ខជាតិលូតលាស់ និងលក្ខណៈសម្បត្តិរបស់រុក្ខជាតិ)។
- នៅផ្ទះ៖ សិស្សប្រមូលរុក្ខជាតិ និងសម្ភារៈផ្សេងទៀតដែលត្រូវការសម្រាប់ធ្វើសាប៊ូ Kyrgyz បែបបុរាណ។ ពួកគេព្យាយាមស្វែងរកបច្ចេកវិទ្យាទំនើបដែលអាចប្រើជំនួសនូវបច្ចេកវិទ្យាបែបបុរាណដែលមិនមានប្រើក្នុងការផលិតសាប៊ូ Kyrgyz។ ពួកគេធ្វើសាប៊ូដោយខ្លួនឯងដោយប្រើរុក្ខជាតិ (រុក្ខជាតិឱសថ) ។ ជាពិសេស ពួកគេបង្កើតវីដេអូអំពីដំណើរការនេះ។
- នៅក្នុងថ្នាក់រៀន សិស្សត្រូវបង្ហាញសាប៊ូរបស់ពួកគេ (និងវីដេអូ ប្រសិនបើមាន) ឆ្លើយសំណួររបស់មិត្តរួមថ្នាក់ និងពិភាក្សាអំពីបច្ចេកទេសរបស់ខ្លួន។

## ប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រសង្គម

### កិច្ចតែងការបង្រៀនទី ៧៖ ប្រវត្តិគ្រួសារ៖ ការរៀបចំមែកធាងគ្រួសារ

| មុខវិជ្ជាសិក្សា | ថ្នាក់ | សមាសធាតុ ICH | ប្រទេស | រយៈពេល |
|---|---|---|---|---|
| ប្រវត្តិវិទ្យា | ទី ៩ | *Shezhire*៖ គូរមែកធាងគ្រួសារ | កាហ្សាក់ស្ថាន | ៣ វគ្គ |

### គោលបំណងមេរៀន៖

| | |
|---|---|
| **វិជ្ជាសម្បទា** | • ស្វែងយល់អំពីវិធីសាស្ត្រសំខាន់ៗក្នុងការសិក្សាពីតំណពូជរបស់មនុស្ស។<br>• ស្វែងយល់ថាតើកូដហ្សែន និង DNA ជាអ្វី។<br>• ស្វែងយល់ពីវិធីរៀបចំមែកធាងគ្រួសារ ។ |
| **បំណិនសម្បទា** | • ប្រមូលនិងជ្រើសរើសព័ត៌មាន កំណត់វិធីសាស្ត្របណ្ដុះបណ្ដាលសមស្របសម្រាប់ខ្លួនអ្នក។<br>• សហការជាមួយសិស្សផ្សេងទៀត មាតាបិតា គ្រួសារដែលមានសមាជិកច្រើន សហគមន៍។ |
| **ចរិយាសម្បទា** | • ទទួលស្គាល់អំពីសារៈសំខាន់នៃប្រពៃណីគ្រួសារ។<br>• ទទួលបានការគោរពចំពោះបេតិកភណ្ឌរបស់អ្នកនិងបេតិកភណ្ឌរបស់អ្នកដទៃ។<br>• យល់ដឹងពីសារៈសំខាន់នៃចំណេះដឹងបែបប្រពៃណី ការអភិរក្ស និងការផ្ទេរបន្តដល់ក្មេងជំនាន់ក្រោយ។ |

**សម្ភារៈពិសេសដែលត្រូវការ៖** ក្រដាសគំនូរ ខ្មៅដៃ ឬហ្វឺត កាវ បន្ទាត់ ប៊ិច

### សកម្មភាពត្រៀមរៀបចំ៖

- សិស្សសម្ភាសន៍សាច់ញាតិរបស់ខ្លួន ដើម្បីប្រមូលព័ត៌មានអំពីគ្រួសារ ត្រកូល និងកុលសម្ព័ន្ធ ហើយថតរូប។ ពួកគេស្រាវជ្រាវពីប្រពៃណី ទំនៀមទម្លាប់ និងពិធីសាសនារបស់គ្រួសារពួកគេ។ ពួកគេចងក្រងរឿងនិទាន សុភាសិត និងពាក្យចាស់ដែលទាក់ទងនឹងគ្រួសារ ឬត្រកូលរបស់ពួកគេ។

### សកម្មភាព៖

- គ្រូបង្ហាញវិធីសាស្ត្រសិក្សាពីតំណពូជរបស់មនុស្ស និងកត់ត្រាពីទំនាក់ទំនងគ្រួសារ ។
- គ្រូណែនាំពីមែកធាងគ្រួសារ ហើយពន្យល់ថា មែកធាងបែបនេះត្រូវបានរៀបចំតាំងពីបុរាណកាលមកម្ល៉េះ។ គ្រូបង្ហាញមែកធាងគ្រួសាររបស់បុគ្គលល្បីៗ (ឧ. Abay, Kurmangazy, Queen Victoria ជាដើម)។
- គ្រូណែនាំអំពីច្បាប់និងនិមិត្តសញ្ញាដែលប្រើក្នុងពង្សាវិទ្យា ដើម្បីតំណាងឱ្យប្រវត្តិគ្រួសារតាមរយៈហ្សែន។

- សិស្សវិភាគពីក្រុមគ្រួសាររបស់បុគ្គលល្បីៗ ដោយផ្តោតការយកចិត្តទុកដាក់លើការផ្ទេរលក្ខណៈពិសេសនៃហ្សែន។
- គ្រូពន្យល់ថា shezire អនុញ្ញាតឱ្យមនុស្សគោរពដល់ការចងចាំរបស់បុព្វបុរសរបស់ខ្លួន មិនត្រឹមតែជាការគោរពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានកូនមានចៅដែលមានសុខភាពល្អ និងរឹងមាំទៀតផង។ សិស្សប្រើឧទាហរណ៍ផ្ទាល់ខ្លួនរបស់ពួកគេ និងឧទាហរណ៍របស់គ្រូដើម្បីវិភាគ និងពិភាក្សាអំពីអត្ថប្រយោជន៍នៃប្រពៃណីនេះ។
- សិស្សគូរមែកធាងគ្រួសាររបស់ខ្លួន រួមទាំងព័ត៌មានអំពីត្រកូល និងកុលសម្ព័ន្ធរបស់ពួកគេ។ ពួកគេបង្ហាញការងាររបស់ខ្លួនដល់សិស្សក្នុងថ្នាក់។

## កិច្ចតែងការបង្រៀនទី ៨៖ កាហ្សាក់ស្ថាន អំឡុងសង្គ្រាមលោកលើកទីពីរ

| មុខវិជ្ជាសិក្សា | ថ្នាក់ | សមាសធាតុ ICH | ប្រទេស | រយៈពេល |
|---|---|---|---|---|
| ប្រវត្តិវិទ្យា | ទី ៩ | *Shezire* (ចំណេះដឹងអំពីពង្សាវិទ្យា) | កាហ្សាក់ស្ថាន | ១ វគ្គ |

### គោលបំណងមេរៀន៖

| | |
|---|---|
| **វិជ្ជាសម្បទា** | • ស្វែងយល់អំពីការចូលរួមរបស់កាហ្សាក់ស្ថាន ក្នុងសង្គ្រាមលោកលើកទីពីរ។<br>• ប្រមូលព័ត៌មានពីបណ្ណសារគ្រួសាររបស់ពួកគេអំពីសាច់ញាតិដែលបានចូលរួមក្នុងសង្គ្រាមលោកលើកទីពីរ។ |
| **បំណិនសម្បទា** | • អភិវឌ្ឍជំនាញស្រាវជ្រាវជាក់ស្តែង និងការធ្វើបទបង្ហាញ។ |
| **ចរិយាសម្បទា** | • ទទួលបានអត្តន័យនៃភាពជាសមាជិកដោយសារតែការដឹងពីប្រវត្តិគ្រួសាររបស់ខ្លួន ។<br>• គោរពបេតិកភណ្ឌរបស់ខ្លួន និងបេតិកភណ្ឌរបស់អ្នកដទៃ។ |

### សកម្មភាពត្រៀមរៀបចំ៖

- ក្នុងការរៀបចំសម្រាប់ថ្នាក់រៀន សិស្សប្រមូលព័ត៌មានអំពីសាច់ញាតិរបស់ពួកគេដែលបានចូលរួមក្នុងសង្គ្រាមលោកលើកទីពីរ។ គ្រូត្រូវបែងចែកពេលវេលាគ្រប់គ្រាន់ដើម្បីទាក់ទង និងសម្ភាសន៍សាច់ញាតិ។ កំណត់សម្គាល់៖ មិនមែនសិស្សទាំងអស់នឹងមានបណ្ណសារគ្រួសារ ឬការចូលប្រើព័ត៌មានបែបនេះបាននោះទេ។

### សកម្មភាព៖

- គ្រូណែនាំអំពីរចនាសម្ព័ន្ធសម្រាប់ការធ្វើបទបង្ហាញលើប្រធានបទ "សាច់ញាតិរបស់ខ្ញុំក្នុងអំឡុងសង្គ្រាមលោកលើកទីពីរ"។

- ជាលក្ខណៈបុគ្គល សិស្សចាត់ថ្នាក់ព័ត៌មាន ដែលពួកគេប្រមូលបានតាមរចនាសម្ព័ន្ធដែលបានស្នើឡើង។
- ជាក្រុម  សិស្សរៀបចំបទបង្ហាញដែលពួកគេត្រូវពន្យល់អំពីសាច់ញាតិរបស់ខ្លួនដែលបានចូលរួមក្នុងសង្គ្រាមលោកលើកទីពីរ។

**កិច្ចតែងការបង្រៀនទី ៩៖ ក្រឡេកមើលរបៀបធម៌ *Kimjang*៖ គម្រោងសិក្សាក្រៅកម្មវិធីសិក្សា**

| មុខវិជ្ជាសិក្សា | ថ្នាក់ | សមាសធាតុ ICH | ប្រទេស | រយៈពេល |
|---|---|---|---|---|
| ប្រវត្តិវិទ្យា | ៧-៩ | *Kimjang*៖ ដំណើរការរួមនៃការបង្កើត និងចែករំលែកគីមឈី | សាធារណរដ្ឋកូរ៉េ | ៣ វគ្គក្នុងថ្នាក់ + ពេលវេលាស្រាវជ្រាវសម្រាប់សិស្ស |



## សកម្មភាពត្រៀមរៀបចំ៖

| | |
|---|---|
| **វិជ្ជាសម្បទា** | • ស្វែងយល់ពីប្រវត្តិនៅពីក្រោយបញ្ហាដែលសហគមន៍ជួបប្រទះសព្វថ្ងៃនេះ។<br>• ស្វែងយល់អំពីវប្បធម៌ ប្រពៃណី និងតម្លៃនៅក្នុងពេលវេលា និងទីកន្លែងផ្សេងៗគ្នា។ |
| **បំណិនសម្បទា** | • ពង្រឹងសមត្ថភាពក្នុងការប្រើប្រាស់ វិភាគ ប្រៀបធៀប និងរួមបញ្ចូលសម្ភារៈសិក្សា។<br>• ស្វែងយល់ពីវិធីការពារ និងផ្ទេរវប្បធម៌។ |
| **ចរិយាសម្បទា** | • ទទួលបានអត្តន័យនៃភាពជាសមាជិកដោយសារតែការដឹងពីប្រវត្តិគ្រួសាររបស់ខ្លួន ។<br>• គោរពបេតិកភណ្ឌរបស់ខ្លួន និងបេតិកភណ្ឌរបស់អ្នកដទៃ។ |

## សកម្មភាព៖

គម្រោងនេះបានធ្វើឡើងក្នុងរយៈពេលបីខែ។

- សិស្សមើលវីដេអូ និងផ្លាស់ប្តូរបទពិសោធន៍របស់ពួកគេអំពីគីមឈី និងអំពីដំណើរការរួមនៃការបង្កើត និងចែករំលែក *គីមឈី* នៅក្នុងសហគមន៍។
- គ្រូបង្ហាញព័ត៌មានអំពីអ្វីដែលជាបេតិកភណ្ឌរស់។
- ជាក្រុម សិស្សស្រាវជ្រាវពីការអនុវត្តផ្សេងៗគ្នា ទាក់ទងនឹងសិល្បៈខាងធ្វើម្ហូបនិងជាពិសេសការធ្វើ *គីមឈី*។ ពួកគេក៏ស្វែងយល់ពីទំនាក់ទំនងរវាងការផលិតគីមឈី និងការអភិវឌ្ឍ បរិស្ថាន និងសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។
- សិស្សបង្កើតវីដេអូខ្លីៗពីការរកឃើញរបស់ពួកគេ ហើយបង្ហាញវាដល់សិស្សក្នុងថ្នាក់។
- នៅក្នុងថ្នាក់ សិស្សពិភាក្សាអំពីបញ្ហាខាងក្រោម៖
  - អត្តសញ្ញាណ និងភាពចម្រុះនៃវប្បធម៌របស់យើង៖ តើនេះមានន័យយ៉ាងណាសម្រាប់ថ្នាក់រៀន សាលា និងសហគមន៍មូលដ្ឋានរបស់យើង។
  - តើយើងអាចអភិរក្សវប្បធម៌ *Kimjang* បានទេ ? តើយើងអាចធ្វើវាដោយរបៀបណា ?

## ប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រសង្គម

### កិច្ចតែងការបង្រៀនទី១០៖ អ្នកសុបិន តើក្រុម Namsadang Nori សុបិនអំពីអ្វី?

| មុខវិជ្ជាសិក្សា | ថ្នាក់ | សមាសធាតុ ICH | ប្រទេស | រយៈពេល |
|---|---|---|---|---|
| ភាសាកូរ៉េ ការសិក្សាសង្គម ពលរដ្ឋវិទ្យា ការអប់រំកាយ | ៥ | *Namsadang Nori*<br>សិល្បៈទស្សនីយភាព | សាធារណរដ្ឋកូរ៉េ | ៥ វគ្គ |

### គោលបំណងមេរៀន៖

| | |
|---|---|
| **វិជ្ជាសម្បទា** | • ស្វែងយល់អំពីការផ្ទេរ និងប្រវត្តិរបស់ *Namsadang Nori* និងរចនាសម្ព័ន្ធទូទៅរបស់វា។<br>• ស្វែងយល់ពីរបៀបដែលមនុស្សកាលពីអតីតកាលប្រើប្រាស់ *Namsadang Nori* ដើម្បីលើកកម្ពស់សិទ្ធិមនុស្ស។ |
| **បំណិនសម្បទា** | • ជំនាញរូបវន្ត៖ ប្រើខ្សែយឺត និងចានបង្វិលដើម្បីស្វែងយល់បន្ថែមអំពីរបៀបដែល *Namsadang Nori* ត្រូវបានអនុវត្ត។<br>• ជំនាញពិភាក្សា៖ ណែនាំសកម្មភាពដែលអាចលើកកម្ពស់សិទ្ធិមនុស្ស ដែលបំផុសគំនិតដោយការខិតខំប្រឹងប្រែងរបស់មនុស្សក្នុងអតីតកាល។ |
| **ចរិយាសម្បទា** | • ឱ្យតម្លៃលើសារៈសំខាន់នៃសិទ្ធិមនុស្ស និងប្រព្រឹត្តទៅតាមនោះ។ |

**សម្ភារៈពិសេសដែលត្រូវការ៖** ធនធានវីដេអូ ខ្សែយឺត និងចានបង្វិល ការតុបតែងសម្រាប់ការសម្តែង។

### សកម្មភាព៖

- គ្រូណែនាំពីគោលគំនិតនៃសិទ្ធិមនុស្ស។
- សិស្សស្គាល់ច្បាស់ពីអ្វីដែលជាបេតិកភណ្ឌរស់ តាមរយៈការមើលវីដេអូ និងស្វែងរកព័ត៌មានអំពី *Namsadang Nori*។ ពួកគេសង្ខេបការរកឃើញរបស់ខ្លួនដោយការសរសេរជាលាយលក្ខណ៍អក្សរ។
- សិស្សអនុវត្តជាមួយនឹងខ្សែយឺតនិងចានបង្វិល ដើម្បីទទួលបានបទពិសោធន៍ពីសិល្បៈទស្សនីយភាពមួយចំនួនដែលបានប្រើនៅ *Namsadang Nori*។
- សិស្សចែករំលែកចំណាប់អារម្មណ៍របស់ពួកគេចំពោះ *Namsadang Nori*។
- សិស្សពិចារណាពី *Namsadang Nori* ដ៏ល្បីល្បាញដែលដកស្រង់ចេញពីទស្សនៈសិទ្ធិមនុស្ស ហើយប្រៀបធៀបវាជាមួយនឹងទំនុកចម្រៀងពីក្រុមK-popដ៏ពេញនិយម(តន្ត្រីប៉ុបកូរ៉េ) សហសម័យ។
- សិស្សបង្កើតសារដែលពួកគេចង់ចែករំលែក ប្រសិនបើពួកគេធ្លាប់ជាផ្នែកនៃកងទ័ព *Namsadang Nori* ក្នុងរជ្ជកាល Joseon។

- ជាក្រុមសិស្សស្រាវជ្រាវអំពីបេតិកភណ្ឌវប្បធម៌អរូបីស្រដៀងនឹង *Namsadang Nori* ដែលត្រូវបានអនុវត្តនៅកន្លែងផ្សេងៗគ្នា ក្នុងប្រទេសកូរ៉េ ឬក្នុងបណ្តាប្រទេសផ្សេងទៀត។ ពួកគេប្រៀបធៀបលក្ខណៈរបស់ពួកគេជាមួយនឹងរឿងរ៉ាវសំខាន់ៗ និងសាររបស់ពួកគេ។
- ជាក្រុមសិស្សសិក្សាអំពីបេតិកភណ្ឌវប្បធម៌អរូបីស្រដៀងនឹង *Namsadang Nori* ដែលត្រូវបានអនុវត្តក្នុងអំឡុងពេលផ្សេងៗគ្នា កាលពីអតីតកាល និងអ្វីដែលត្រូវបានអនុវត្តនាពេលបច្ចុប្បន្ននេះ។ ពួកគេប្រៀបធៀបលក្ខណៈរបស់ពួកគេ និងរឿងរ៉ាវសំខាន់ៗនិងសាររបស់ពួកគេ។
- ជាក្រុមសិស្សប្រមូលឧទាហរណ៍ពីការរំលោភសិទ្ធិមនុស្ស (នៅផ្ទះ សាលា ក្នុងសហគមន៍ ឬក្នុងប្រទេស)។ ពួកគេបង្កើត និងអនុវត្ត *Namsadang Nori* រយៈពេលខ្លីដើម្បីបង្ហាញពីអារម្មណ៍របស់ពួកគេអំពីការរំលោភសិទ្ធិមនុស្សនេះ។



## សិល្បៈ និងវប្បធម៌

### កិច្ចតែងការបង្រៀនទី១១៖ ចម្លាក់ឈើ Lanna របស់ថៃ

| មុខវិជ្ជាសិក្សា | ថ្នាក់ | សមាសធាតុ ICH | ប្រទេស | រយៈពេល |
|---|---|---|---|---|
| សិប្បកម្ម Lanna | ៤-៦ | ចម្លាក់ឈើបែបបុរាណLannaនិងការឆ្លាក់តាមការចេះដឹងក្នុងស្រុក | ថៃ | ៣ ម៉ោង(សរុប ១៥ ម៉ោង) ម៉ោង(សរុប១៥ ម៉ោង) |

**សម្ភារៈពិសេសដែលត្រូវការ៖** សម្ភារៈសោតទស្សន៍ដែលបានជ្រើសរើស ជាមួយនឹងក្បាច់ចម្លាក់ ឈើ និងឧបករណ៍សម្រាប់ឆ្លាក់ឈើ។

### គោលបំណងមេរៀន៖

| | |
|---|---|
| **វិជ្ជាសម្បទា** | • ស្វែងយល់ពីសិប្បករដែលត្រូវការសម្រាប់ការធ្វើចម្លាក់ឈើ និងលំនាំតុបតែង។<br>• ស្វែងយល់ពីប្រវត្តិនៃលំនាំចម្លាក់ឈើបុរាណ។ |
| **បំណិនសម្បទា** | • រចនា និងឆ្លាក់តាក្បាច់លើឈើ។ |
| **ចរិយាសម្បទា** | • មានមោទនភាព និងចាប់អារម្មណ៍លើការអភិរក្ស និងការផ្ទេរតម្លៃវប្បធម៌។<br>• បង្កើតអត្តសញ្ញាណនៃភាពជាសមាជិករបស់សហគមន៍។ |

### សកម្មភាព៖

- គ្រូបង្ហាញរូបភាពសិប្បកម្មឈើ ហើយសួរសិស្សពីរបៀបដែលសិប្បកម្មនេះទាក់ទងជាមួយពួកគេ។
- គ្រូបង្ហាញឃ្លីប YouTube ក្នុងថ្នាក់រៀនអំពីប្រពៃណីចម្លាក់ឈើរបស់ភូមិ Ban Thawai ហើយសុំឱ្យសិស្សកំណត់សិប្បកម្មពីឃ្លីបទាំងនេះ តាមដែលអាចធ្វើបាន។ បន្ទាប់មកពួកគេពិភាក្សាអំពីដំណើរការបង្កើត សារៈសំខាន់ និងសមាសធាតុនៃវប្បធម៌ដែលបានបង្ហាញនៅក្នុងសិប្បកម្មប្រពៃណី។
- គ្រូ និងអ្នកជំនាញចម្លាក់ឈើក្នុងស្រុកផ្តល់ព័ត៌មានបន្ថែមអំពីការឆ្លាក់ឈើ និងការធ្វើលំនាំតុបតែង។
- សិស្សរៀនពីរបៀបឆ្លាក់តាមលំនាំបុរាណ និងក្បាច់នៅលើបន្ទះឈើ។ គ្រូ និងអ្នកជំនាញចម្លាក់ឈើក្នុងស្រុកធ្វើការត្រួតពិនិត្យ និងបង្ហាត់បង្រៀនពីរបៀបធ្វើក្បាច់។

## កិច្ចតែងការបង្រៀនទី ១២៖ ការរចនាខ្លែង

| មុខវិជ្ជាសិក្សា | ថ្នាក់ | សមាសធាតុ ICH | ប្រទេស | រយៈពេល |
|---|---|---|---|---|
| វប្បធម៌ និងសិល្បៈអប់រំ | ទី ៧ | ការរចនាខ្លែងបុរាណ | កម្ពុជា | ១ វគ្គ |

### គោលបំណងមេរៀន៖

| | |
|---|---|
| **វិជ្ជាសម្បទា** | • ស្វែងយល់ពីលំនាំខ្លែងប្រពៃណីខ្មែរ។ |
| **បំណិនសម្បទា** | • សិក្សាពីបច្ចេកទេសដែលប្រើក្នុងការរចនា និងផលិតខ្លែង<br>• អភិវឌ្ឍជំនាញច្នៃប្រឌិត។<br>• អភិវឌ្ឍជំនាញការងារជាក្រុម។ |
| **ចរិយាសម្បទា** | • ឱ្យតម្លៃសិល្បៈជាមូលដ្ឋានសម្រាប់ការសិក្សាអំពីសាសនាព្រះពុទ្ធ។ |

**សម្ភារៈពិសេសដែលត្រូវការ៖** សម្ភារៈវីដេអូ និងសៀវភៅសិក្សា ក្រដាសពណ៌ ក្រដាសស កន្ត្រៃ កាំបិត ឈើ ស្ទីគ័រ គំនូរលំនាំ។

### សកម្មភាព៖

- លោកគ្រូបង្ហាញរូបភាពខ្លែងខ្មែរដល់សិស្សក្នុងថ្នាក់ និងខ្លែងប្រទេសផ្សេងៗ ហើយពន្យល់ពីប្រវត្តិខ្លែងខ្មែរបុរាណ។
- សិស្សមើលវីដេអូអំពីខ្លែងខ្មែរ។ ពួកគេពិភាក្សាអំពីរូបរាង និងលំនាំផ្សេងៗ។
- លោកគ្រូណែនាំពីវត្ថុធាតុដើម ដែលបានប្រើតាមលក្ខណៈប្រពៃណីសម្រាប់ធ្វើខ្លែង និងបង្ហាញពីបច្ចេកទេសធ្វើខ្លែងមួយជំហានម្តងៗ។
- សិស្សអនុវត្តតាមជំហាន និងធ្វើខ្លែងដោយខ្លួនឯង។ ពួកគេបង្ហាញខ្លែងរបស់ពួកគេនៅក្នុងថ្នាក់រៀន ហើយដើរជុំវិញដើម្បីមើល និងពិភាក្សាអំពីស្នាដៃរបស់មិត្តរួមថ្នាក់។

## អប់រំសុខភាព និងអប់រំកាយ

### កិច្ចតែងការបង្រៀនទី ១៣៖ ល្បែងប្រពៃណីជនជាតិគៀជីស្ថាន

| មុខវិជ្ជាសិក្សា | ថ្នាក់ | សមាសធាតុ ICH | ប្រទេស | រយៈពេល |
|---|---|---|---|---|
| អប់រំកាយ ការសិក្សាសង្គម | ទី ៤ | ល្បែងប្រជាប្រិយ៖ Ak Terek Kok White Poplar Blue Poplar ) and Altynshakek ( ចិញ្ចៀនមាស ) | គៀជីស្ថាន | ១ វគ្គ |

### គោលបំណងមេរៀន៖

| | |
|---|---|
| **វិជ្ជាសម្បទា** | • ស្វែងយល់ពីអ្វីដែលជាបេតិកភណ្ឌរស់និងអ្វីជាបេតិកភណ្ឌវប្បធម៌អរូបី។<br>• ស្វែងយល់ពីច្បាប់នៃល្បែងប្រពៃណី *Ak Terek Kok Terek* ( White Poplar Blue Poplar ) និង *Altynshakek* ( ចិញ្ចៀនមាស )។<br>• ស្វែងយល់ពីអត្ថន័យ និងមុខងារសង្គមរបស់ល្បែង។ |
| **បំណិនសម្បទា** | • អភិវឌ្ឍជំនាញអំពីភាពអំណត់និងការសម្របសម្រួល។<br>• ពង្រឹងជំនាញទំនាក់ទំនង។<br>• អភិវឌ្ឍជំនាញការងារជាក្រុម។ |
| **ចរិយាសម្បទា** | • ទទួលបានអត្ថន័យនៃការទទួលខុសត្រូវក្នុងការថែរក្សាការពារបេតិកភណ្ឌវប្បធម៌របស់ប្រជាជន Kyrgyz។ |

### សកម្មភាព៖

- នៅក្នុងថ្នាក់រៀន គ្រូចាប់ផ្តើមមេរៀនដោយការពន្យល់ពីអ្វីដែលជាបេតិកភណ្ឌរស់ និងអ្វីជាបេតិកភណ្ឌវប្បធម៌អរូបី ដោយប្រើអត្ថបទសង្ខេបនៃកិច្ចតែងការបង្រៀនគំរូ៖ តើបេតិកភណ្ឌវប្បធម៌អរូបីជាអ្វី? ( ឧបករណ៍ ១ )
- គ្រូពន្យល់ពីច្បាប់ល្បែងប្រពៃណី *Ak Terek Kok Terek* ( White Poplar Blue Poplar ) និងពិពណ៌នាអំពីមុខងារសង្គមរបស់ល្បែងនេះ។
- ទាំងអស់គ្នាផ្លាស់ទៅកាន់ទីធ្លាសាលា។ គ្រូពិពណ៌នាអំពីល្បែង *Altynshakek* ( ចិញ្ចៀនមាស ) និងមុខងារសង្គមរបស់ល្បែងនេះ។

- សិស្សពិភាក្សាអំពីល្បែងប្រពៃណីផ្សេងទៀត ដែលលើកកម្ពស់កម្លាំងកាយ និងភាពក្លាហាន ហើយនោះក៏មានគោលបំណងឱ្យមនុស្សរួមសាមគ្គីគ្នាផងដែរ។
- សិស្សនិងគ្រូ ជ្រើសរើសគណៈវិនិច្ឆ័យ សមាជិកក្នុងចំណោមពួកគេ ហើយលេងល្បែងនេះ។
- សមាជិកគណៈវិនិច្ឆ័យ ដែលបានជ្រើសរើសវាយតម្លៃការសម្តែងរបស់ក្រុម និងប្រកាសអ្នកឈ្នះ។
- សិស្សពិភាក្សាអំពីអ្វីដែលពួកគេបានរៀន អ្វីដែលគួរឱ្យចាប់អារម្មណ៍ក្នុងថ្នាក់នេះ និងអ្វីដែលពួកគេចង់ដឹងបន្ថែមទៀតអំពីប្រធានបទនេះ។

*កិច្ចការផ្ទះ៖* សិស្សនិយាយជាមួយ ឪពុកម្តាយ និងជីដូនជីតារបស់ពួកគេអំពីល្បែងប្រពៃណីដែលពួកគេស្គាល់ និងលេងកាលពីវ័យកុមារភាព កត់ត្រា និងបង្ហាញលទ្ធផលរកឃើញរបស់ពួកគេនៅក្នុងមេរៀនបន្ទាប់។

**កិច្ចតែងការបង្រៀនទី ១៤៖ ការគោរពដល់រូបកាយរបស់យើង៖ ការបង្កើត** mandalas **សម្រាប់** Mha Puja

| មុខវិជ្ជាសិក្សា | ថ្នាក់ | សមាសធាតុ ICH | ប្រទេស | រយៈពេល |
|---|---|---|---|---|
| អប់រំសុខភាព និង អប់រំកាយ គណិតវិទ្យា និង សិក្សាសង្គម | ទី ៧ | ពិធីសាសនា Mha Puja - ការធ្វើ mandalas | នេប៉ាល់ | ៣ វគ្គ + ការតាំងពិព័រណ៍ |

## គោលបំណងមេរៀន៖

| | |
|---|---|
| **វិជ្ជាសម្បទា** | • ស្វែងយល់អំពីពិធីសាសនា *Mha Puja* និង *mandalas*។<br>• ស្វែងយល់ថា តើរបបអាហារមានតុល្យភាពគឺជាអ្វី ហើយហេតុអ្វីបានជាវាសំខាន់សម្រាប់សុខភាព។ |
| **បំណិនសម្បទា** | • អនុវត្តជំនាញវាស់វែង និងបែងចែក។<br>• រៀនពីរបៀបធ្វើស្តង់ស៊ីល *mandalas* និង អាហារ *mandalas*។ |
| **ចរិយាសម្បទា** | • គោរពរូបកាយខ្លួនឯង វប្បធម៌របស់អ្នកដទៃ និងចំណេះដឹងពីបេតិកភណ្ឌវប្បធម៌អរូបី។ |

**សម្ភារៈពិសេសដែលត្រូវការ៖** ក្រដាសក្រាស់សម្រាប់ស្តង់ស៊ីល ប្រភេទអាហារផ្សេងៗ (ដែលរៀបចំដោយសិស្ស ឬដោយសាលា)។

## សកម្មភាព៖

### វគ្គទី ១៖

- សិស្សបំពេញក្នុងបន្ទាត់បញ្ឈរពីរដំបូងនៃតារាង Know, Want, Learn (KWL) អំពីពិធីសាសនា *Mha Puja*។
- គ្រូបង្ហាញព័ត៌មានសំខាន់ៗអំពីពិធី *Mha Puja*។
- សិស្សវាស់វែង និងបង្កើតស្តង់ស៊ីល *mandala*។





**វគ្គទី ២៖**

- សិស្សពិពណ៌នាអំពីអាហារ ដែលមានសារជាតុចិញ្ចឹមដែលពួកគេបរិភោគនៅផ្ទះ និងតាមវប្បធម៌របស់ពួកគេ។
- ជាក្រុម សិស្សចាត់ថ្នាក់ និងគូសផែនទីប្រភេទអាហារដែលពួកគេបរិភោគ។
- ក្រុមនីមួយៗបង្ហាញលទ្ធផលរកឃើញរបស់ខ្លួន។
- ជាក្រុម សិស្សពិភាក្សាថា តើអ្នកណានឹងនាំយកអាហារប្រភេទណាខ្លះដើម្បីបង្កើតរបបអាហារមានតុល្យភាពស្តីពី *mandala*។
- សិស្សបន្តធ្វើការលើស្តង់ស៊ីល *mandala* របស់ពួកគេ។

**វគ្គទី ៣៖**

- សិស្សពិភាក្សាអំពីអាហារប្រចាំថ្ងៃរបស់ពួកគេ និងថាតើពួកគេបរិភោគរបបអាហារមានតុល្យភាពដែរឬទេ។
- សិស្សបញ្ចប់ mandala របស់ពួកគេ ដោយបន្ថែមអាហារទៅនឹង mandala ដែលតំណាងឱ្យរបបអាហារដែលមានតុល្យភាព។
- ពួកគេថតរូបពី *mandala* ដែលបានបញ្ចប់មុនពេលសម្អាត។
- ពួកគេបំពេញបន្ទាត់បញ្ឈរទីបីនៃតារាង KWL។

**វគ្គទី ៤៖**

- សិស្សរៀបចំការតាំងពិព័រណ៍រូបថត *mandala*។ ពួកគេរៀបចំកន្លែងតាំងពិព័រណ៍៖ សម្អាតបន្ទប់ ដំឡើងប្រព័ន្ធសំឡេង និងឧបករណ៍បញ្ចាំង (បើចាំបាច់) ប្រមូលរូបថតតាំងពិពរណ៍ បង្កើតស្លាកសញ្ញា និងព្យួររូបថត។
- ថ្នាក់អញ្ជើញសិស្សសាលា លោកគ្រូ អ្នកគ្រូ នាយកសាលា មាតាបិតា និងអ្នកជំនាញក្នុងស្រុកផ្សេងទៀតឱ្យចូលរួមក្នុងការតាំងពិព័រណ៍នេះ។ ក្នុងអំឡុងពេលតាំងពិព័រណ៍ សិស្សនៅក្បែររូបថតរបស់ពួកគេហើយពន្យល់ពីរូបទាំងនោះទៅកាន់អ្នកទស្សនា។

# ឯកសារទី ៤៖ ការប្រមូលព័ត៌មាន

## វិធីសាស្ត្រទូទៅនៃការប្រមូលព័ត៌មាន

មានវិធីជាច្រើនក្នុងការប្រមូលព័ត៌មាន។ វិធីសាស្ត្រទូទៅបំផុតគឺការស្រាវជ្រាវផ្ទាល់ និងការសម្ភាសន៍។

**ការស្រាវជ្រាវផ្ទាល់៖** វិធីសាស្ត្រនេះពាក់ព័ន្ធនឹងការប្រមូលព័ត៌មានដែលបានសរសេរ និងចងក្រងដោយមនុស្សផ្សេងទៀត។ ព័ត៌មានជាលាយលក្ខណ៍អក្សរត្រូវបានបោះពុម្ពជាសៀវភៅ និងអត្ថបទ និងនៅលើប្រព័ន្ធអ៊ីនធឺណិត។ អ្នកអាចស្វែងរកព័ត៌មាននៅកន្លែងផ្សេងៗគ្នា៖ បណ្ណាល័យ សារមន្ទីរ មជ្ឈមណ្ឌលសិក្សាសហគមន៍ សាកលវិទ្យាល័យ និងមជ្ឈមណ្ឌលស្រាវជ្រាវ ការិយាល័យរដ្ឋាភិបាល និងស្ថាប័នផ្សេងទៀត និងនៅលើប្រព័ន្ធអ៊ីនធឺណិត។

វាមានសារៈសំខាន់ណាស់ ក្នុងការវាយតម្លៃគុណភាព និងភាពជឿជាក់នៃព័ត៌មានដែលមានស្រាប់។ ធនធានអ៊ីនធឺណិតដែលអាចទុកចិត្តបានអំពីបេតិកភណ្ឌវប្បធម៌អរូបី រួមមានគេហទំព័ររបស់អង្គការយូណេស្កូស្តីពីអនុសញ្ញា ឆ្នាំ២០០៣ ដែលជាឧបករណ៍អន្តរកម្ម៖ "សូមទៅរកព័ត៌មានពីបេតិកភណ្ឌវប្បធម៌អរូបី" និងគេហទំព័រផ្លូវការរបស់បេតិកភណ្ឌវប្បធម៌អរូបីដែលកំណត់ចំពោះបេតិកភណ្ឌរស់នៅក្នុងប្រទេសរបស់អ្នក។

សូមចំណាំថា ព័ត៌មានទាំងនេះ ត្រូវបានប្រមូលតាមពេលវេលា និងទីកន្លែងជាក់លាក់ ហើយវាអាចនឹងមានការប្រែប្រួលខ្លះៗ នៅពេលបោះពុម្ពផ្សាយ។ គួរយល់ដឹងអំពីបរិបទនៃព័ត៌មានទាំងនេះ ហើយប្រើប្រាស់វាឱ្យបានត្រឹមត្រូវ។

តាមរយៈដំណើរការស្រាវជ្រាវផ្ទាល់ អ្នកអាចរកឃើញធនធានអំពីបេតិកភណ្ឌវប្បធម៌អរូបីដែលអនុវត្តដោយសហគមន៍ក្នុងតំបន់ និងប្រទេសផ្សេងៗ។ សមាសធាតុបេតិកភណ្ឌវប្បធម៌អរូបីមួយចំនួននៅកន្លែងផ្សេងទៀត អាចស្រដៀងនឹងសមាសធាតុដែលអ្នកកំពុងស្រាវជ្រាវ។ ការចែករំលែកព័ត៌មានបែបនេះជាមួយសិស្សរបស់អ្នកនឹងជួយពួកគេវាយតម្លៃបានថា វប្បធម៌គឺមានភាពចម្រុះ ប៉ុន្តែវាក៏មានភាពស្រដៀងគ្នាខ្លះដែរ ហើយយើងទាំងអស់គ្នាមានទំនាក់ទំនងនឹងគ្នា។

**ការសម្ភាសន៍៖** វិធីសាស្ត្រនេះពាក់ព័ន្ធនឹងការប្រមូលព័ត៌មានដោយផ្ទាល់ពីអ្នកដែលមានបទពិសោធន៍ផ្ទាល់ជាមួយបេតិកភណ្ឌរស់ ដូចជាមនុស្សដែលមកពីសហគមន៍ សិស្សានុសិស្ស និងសមាជិកគ្រួសាររបស់ពួកគេ តំណាងសមាគមវប្បធម៌ជាដើម។ ការសម្ភាសន៍អាចធ្វើឡើងជាមួយបុគ្គល ឬក្រុមតូចៗ។

អ្នកសម្ភាសន៍សួរសំណួរ ដើម្បីធ្វើឱ្យការយល់ដឹងរបស់ពួកគេកាន់តែស៊ីជម្រៅអំពីសមាសធាតុ និងពីអ្នកអនុវត្ត រួមទាំងសំណួរអំពីតម្លៃ និងអត្ថន័យនៃបេតិកភណ្ឌរស់។ ការសម្ភាសន៍រួមមានការពិចារណា ការស្តាប់ និងការសង្កេត។ ដំណើរការសម្ភាសន៍ក៏អាចពាក់ព័ន្ធនឹងការអនុវត្តសមាសធាតុបេតិកភណ្ឌរស់ផងដែរ។

ការសម្ភាសន៍អាចមានរៀបចំជារចនាសម្ព័ន្ធ ( ឧ. អ្នកសម្ភាសន៍រៀបចំ និងប្រើបញ្ជីសំណួរស្តង់ដារ ) ឬពាក់កណ្តាលរចនាសម្ព័ន្ធ (មានន័យថា អ្នកសម្ភាសន៍រៀបចំសំណួរមួយចំនួនជាមុន ប៉ុន្តែក៏សួរសំណួរផ្សេងទៀតដែលកើតឡើងដោយផ្អែកលើចម្លើយចំពោះសំណួរមុនៗដែរ )។ ការសម្ភាសន៍ដោយមិនបានរៀបចំរចនាសម្ព័ន្ធច្រើនតែងទទួលបានព័ត៌មាន ដែលអ្នកសម្ភាសន៍មិនបានរំពឹងទុក។

## ការណែនាំអំពីការធ្វើសម្ភាសន៍ និងដំណើរកម្សាន្ត

### ធ្វើការណាត់ជួប

ធ្វើការណាត់ជួបឲ្យហើយ មុនពេលចុះទៅជួបអ្នកអនុវត្ត និងសមាជិកសហគមន៍។ អ្នកអាចជួបពួកគាត់នៅតាមកន្លែង និងពេលណាដែលពួកគាត់អនុវត្តបេតិកភណ្ឌរស់របស់ខ្លួន។ ប្រសិនបើអ្នកមិនមែនមកពីសហគមន៍ទេ នោះ សំខាន់ត្រូវមានអ្នកទំនាក់ទំនងក្នុងសហគមន៍ ដែលអាចណែនាំអ្នកឱ្យស្គាល់មនុស្សដែលអនុវត្តបេតិកភណ្ឌវប្បធម៌អរូបី ដែលអ្នកចាប់អារម្មណ៍។ ពួកគាត់ក៏អាចជូនដំណឹងដល់អ្នកអំពីអ្វី ដែលគួរធ្វើនិងអ្វីដែលមិនគួរធ្វើ ដូច្នេះអ្នកនឹងដឹងពីរបៀបក្នុងការប្រព្រឹត្តដោយការគោរព។

### រៀបចំសំណួររបស់អ្នកជាមុន

នៅពេលអ្នកប្រមូលព័ត៌មានអំពីបេតិកភណ្ឌរស់ សូមសួរសំណួរអំពីសមាសធាតុ ការផ្ទេរ និងលទ្ធភាពជោគជ័យរបស់វា។ ឧទាហរណ៍៖

- តើបេតិកភណ្ឌរស់**ជាអ្វី**?
- **នរណា**ខ្លះអនុវត្តវា?
- តើបេតិកភណ្ឌរស់នេះត្រូវបានគេអនុវត្តនៅ**ពេលណា**?
- តើបេតិកភណ្ឌវប្បធម៌អរូបីនេះត្រូវបានអនុវត្ត**នៅកន្លែងណា**?
- **ហេតុអ្វី**បានជាបេតកកភណ្ឌវប្បធម៌អរូបីនេះមានសារៈសំខាន់សម្រាប់សហគមន៍?
- តើវាត្រូវបានអនុវត្តដោយ**របៀបណា**?

អាចសួរសំណួរលម្អិតបន្ថែមទៀតបានដើម្បីទទួលបានព័ត៌មានបន្ថែម។ បញ្ជីសំណួរមាននៅក្នុងផ្នែក "សិក្សាអំពីសមាសធាតុបេតិកភណ្ឌរស់" ខាងក្រោម។

### ប្រើវិធីសាស្ត្រប្រកបដោយក្រមសីលធម៌ក្នុងការសម្ភាសន៍

ការសម្ភាសន៍ និងសកម្មភាពស្រាវជ្រាវ និងកត់ត្រាជាឯកសារផ្សេងទៀតដែលពាក់ព័ន្ធនឹងសមាជិកសហគមន៍គួរត្រូវបានធ្វើឡើង ប្រកបដោយក្រមសីលធម៌ជានិច្ច។ នោះ គឺសកម្មភាពគួរតែអនុលោមតាមបទដ្ឋាន សម្រាប់អាកប្បកិរិយាដែលអាចទទួលយកបាននៅក្នុងសង្គម ឬសហគមន៍ដែលអ្នកកំពុងចុះទៅ។ គោលការណ៍សីលធម៌១២ចំណុចសម្រាប់ការថែរក្សាការពារបេតិកភណ្ឌវប្បធម៌អរូបី អាចផ្ដល់ការណែនាំដ៏មានប្រយោជន៍។ សូមមើលតាមរយៈ៖ CLICK



រាល់ទំនាក់ទំនងជាមួយសហគមន៍ ឬបុគ្គលគួរធ្វើឡើងក្នុងលក្ខណៈ **ស្មោះត្រង់** និង**តម្លាភាព** ហើយវាចាំបាច់ណាស់ក្នុងការមានការយល់ព្រមដោយ**សេរី ផ្ដល់ដំណឹងជាមុន និងឆ្លងកាត់ការថ្លឹងថ្លែងច្បាស់លាស់**។

| | |
|---|---|
| ដោយសេរី | ▶ គ្មាននរណាម្នាក់បង្ខំពួកគេឱ្យយល់ព្រមជាមួយសកម្មភាព ឬការសម្រេចចិត្តនោះទេ។ |
| ការយល់ព្រម | ▶ ពួកគេត្រូវបានជូនដំណឹង និងទទួលបានការយល់ព្រមមុនពេលមានសកម្មភាពណាមួយកើតឡើង។ |
| និងជូនដំណឹង | ▶ ពួកគេមានព័ត៌មានចាំបាច់មុនពេលធ្វើការសម្រេចចិត្ត។ |
| ជាមុន | ▶ ពួកគេយល់ព្រមសហការជាមួយអ្នក។ |

## *ប្រព្រឹត្តដោយគោរព*

ដំណើរការប្រមូលព័ត៌មាន គឺផ្អែកលើការគោរពគ្នាទៅវិញទៅមក ការសន្ទនា និងបរិយាបន្ន ។ នៅពេលអ្នកជួបសហគមន៍ ឬអ្នកអនុវត្ត សូមណែនាំពីខ្លួនអ្នក និងគោលបំណងនៃដំណើររបស់អ្នក។ ត្រូវប្រកាន់យកវប្បធម៌ និងធ្វើតាមទំនៀមទម្លាប់ក្នុងស្រុក។ ត្រូវដឹងពីភាពលម្អៀងណាមួយដែលអ្នកអាចមាន។ ការលម្អៀងអាចនាំឱ្យអ្នកបកស្រាយព័ត៌មានខុស។

## *ចូលរួមក្នុងការធ្វើផែនទីដែលមានការចូលរួម*

សមាជិកសហគមន៍ អាចរួមចំណែកដល់ដំណើរការប្រមូលព័ត៌មាន ដោយការចងក្រងចំណេះដឹង និងការយល់ឃើញរបស់ពួកគេអំពីបេតិកភណ្ឌវប្បធម៌អរូបីក្នុងទម្រង់ផែនទី។ ផែនទីលើផ្ទៃដី និងគំនូរព្រាងផ្ដល់ជូនសហគមន៍មូលដ្ឋាននូវមធ្យោបាយនៃការចងក្រង និងការមើលឃើញពីចំណេះដឹង និងការយល់ឃើញរបស់ពួកគេអំពីបេតិកភណ្ឌវប្បធម៌អរូបីទាក់ទងនឹងកន្លែងជុំវិញ។ ផែនទីទាំងនេះ គឺជាឯកសារទំនាក់ទំនងដ៏សាមញ្ញ និងមានប្រសិទ្ធភាព។ ការធ្វើផែនទីដែលមានការចូលរួមក៏អាចប្រើជាឧបករណ៍សម្រាប់វាយតម្លៃការយល់ដឹងរបស់សិស្សអំពីមេរៀន ឬវត្ថុបំណងនៃការសិក្សាផងដែរ។

## *ការកត់ត្រាព័ត៌មាន*

ដំណើរការស្រាវជ្រាវដែលមានការចូលរួម គឺមានតម្លៃខ្លាំងណាស់ ព្រោះវារួមចំណែកដល់កិច្ចការពារបេតិកភណ្ឌរស់។ ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការកត់ត្រាការសម្ភាសន៍ និងទំនាក់ទំនងផ្សេងទៀតឱ្យបានត្រឹមត្រូវ។ កំណត់ត្រាត្រឹមត្រូវនឹងមិនត្រឹមតែមានប្រយោជន៍ សម្រាប់សកម្មភាពរបស់សាលា ដែលអ្នកកំពុងរៀបចំផែនការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចមានប្រយោជន៍សម្រាប់សហគមន៍ ឬអ្នកអនុវត្តដែលពាក់ព័ន្ធផងដែរ (ប្រសិនបើពួកគេចង់ពិគ្រោះយោបល់នៅដំណាក់កាលក្រោយ)។

មានបច្ចេកទេសជាច្រើនសម្រាប់កត់ត្រាព័ត៌មាន៖

**ការកត់ត្រាកំណត់ហេតុ**

ក្រដាស និងប៊ិច គឺជាវិធីសាមញ្ញ និងមានប្រសិទ្ធភាពក្នុងការកត់ត្រាព័ត៌មាន។ សរសេរចម្លើយទាំងអស់ ព្យាយាមចាប់យកព័ត៌មានលម្អិតតាមដែលអាចធ្វើទៅបាន។ មនុស្សម្នាក់អាចទទួលខុសត្រូវក្នុងការកត់ត្រា ចំណែកមនុស្សម្នាក់ទៀត ជាអ្នកធ្វើបទសម្ភាសន៍។ បន្ទាប់មក អ្នកអាចសួរអ្នកផ្ដល់បទសម្ភាសន៍ ឱ្យពិនិត្យមើលកំណត់ហេតុរបស់អ្នក ដើម្បីឱ្យប្រាកដថា អ្នកយល់ពីគោលគំនិតនោះបានត្រឹមត្រូវ។

**ការថតសំឡេង**

ម៉ាស៊ីនកត់ត្រានិងកម្មវិធីទូរសព្ទ គឺជាឧបករណ៍ដ៏មានសារៈប្រយោជន៍សម្រាប់កត់ត្រាការសម្ភាសន៍។

ចំណុចសំខាន់ៗ ដើម្បីថតសំឡេងឲ្យបានល្អ៖

- នៅក្នុងផ្ទះ៖ បើអាច សូមរកមើលបន្ទប់ធំជាមួយនឹងវត្ថុ ដែលអាចស្រូបសំឡេងបាន ដូចជាកម្រាលព្រំ ឬវាំងនន ជាដើម។
- នៅខាងក្រៅ៖ ដាក់ឧបករណ៍ថតសំឡេង ឬមីក្រូហ្វូននៅកៀកនឹងដី។ បើអាចធ្វើបាន ជៀសវាងថ្ងៃដែលមានខ្យល់បក់ខ្លាំង និងកន្លែងដែលមានមនុស្សច្រើនកុះករ។

**ការថតរូបភាព**

ថតរូបត្រូវបានគេប្រើជាញឹកញាប់ដើម្បីបន្ថែមពីលើការថតសំឡេង ក្នុងការចងក្រងឯកសារពីការអនុវត្តបេតិកភណ្ឌវប្បធម៌អរូបី។ រូបថតអាចធ្វើការបកស្រាយរួមគ្នា ការនិទានរឿងបែបពន្យល់ អាចដាក់បញ្ចូលបន្ថែម ដើម្បីឱ្យមានការយល់ដឹងកាន់តែទូលំទូលាយ។ ឯកសារជារូបថត និងការវិភាគអាចអនុវត្តរួមគ្នាជាមួយសិស្ស។

**ការថតវីដេអូ**

វីដេអូគឺជាប្រព័ន្ធផ្សព្វផ្សាយដ៏ទូលំទូលាយមួយ ដោយចាប់យកទាំងសំឡេង និងរូបភាពដែលមានចលនា។ ការថតវីដេអូអាចធ្វើឡើយដោយគ្រូ សិស្ស ឬសមាជិកសហគមន៍។ ក្នុងការថតវីដេអូដែលមានការចូលរួម សមាជិកសហគមន៍រៀនប្រើបច្ចេកវិទ្យាថតវីដេអូ និងដំណើរការវាដោយខ្លួនឯង ផ្ទុយពីការថតវីដេអូដោយមនុស្សមកពីខាងក្រៅសហគមន៍របស់ពួកគេ (គ្រូបង្រៀន សិស្ស និងអ្នកបច្ចេកទេស)។ វិធីសាស្ត្រនេះអនុញ្ញាតឱ្យសហគមន៍បញ្ចេញសំឡេងរបស់ខ្លួន ដើម្បីរួមចំណែកដល់ដំណើរការនៃការអភិក្រមប្រកបដោយបរិយាបន្ន។

## *ការប្រមូលព័ត៌មានសម្រាប់សកម្មភាពរបស់សាលា*

សកម្មភាពប្រមូលព័ត៌មានអាចជួយអ្នក ឱ្យស្វែងយល់បន្ថែមអំពីសមាសធាតុបេតិកភណ្ឌវប្បធម៌អរូបី ដែលអ្នកបានជ្រើសរើស ទន្ទឹមនឹងនោះ ក៏បង្កើតបទពិសោធន៍គួរឱ្យចងចាំ និងទាក់ទាញសម្រាប់អ្នកចូលរួមផងដែរ។

ចំណុចសំខាន់ៗសម្រាប់ប្រមូលព័ត៌មាន៖

- នៅពេលណាដែលអាចធ្វើទៅបាន សូមចូលរួមជាមួយសិស្សរបស់អ្នកក្នុងការប្រមូលព័ត៌មានអំពីការអនុវត្តបេតិកភណ្ឌវប្បធម៌អរូបី ដែលបានជ្រើសរើស។ សិស្សអាចប្រមូលព័ត៌មានតាមវិធីផ្សេងៗ រួមទាំងការសម្ភាសន៍ជាមួយក្រុមគ្រួសារ និងសមាជិកសហគមន៍របស់ពួកគេ ទៅទស្សនារោងជាង និងស្ថាប័នវប្បធម៌ ដើម្បីសង្កេតមើលការអនុវត្ត និងធ្វើការកត់ត្រា។ ការចងក្រង និងវិភាគសម្ភារៈវីដេអូ និងការប្រមូលព័ត៌មានពីធនធានអនឡាញ ការបោះពុម្ពផ្សាយជាដើម ។ល។
- ប្រសិនបើអ្នកសហការជាមួយគ្រូផ្សេងទៀត ដើម្បីប្រមូលព័ត៌មាន សូមបែងចែកកិច្ចការ។ ឧទាហរណ៍ គ្រូរូបវិទ្យាអាចមើលក្នុងវិមាត្រវិទ្យាសាស្ត្រនៃសមាសធាតុ ចំណែកគ្រូបង្រៀនផ្នែកសិក្សាសង្គម អាចស្វែងរកព័ត៌មានទាក់ទងនឹងទិដ្ឋភាពប្រវត្តិសាស្ត្រនិងសង្គម ឧទាហរណ៍ តួនាទីយេនឌ័រទាក់ទងនឹងការអនុវត្តជាដើម។ ការងារជាក្រុមបែបនេះអាចឱ្យ អ្នកទទួលបានព័ត៌មានជាច្រើនប្រភេទអំពីសមាសធាតុបេតិកភណ្ឌវប្បធម៌អរូបី និងបង្កើតការយល់ដឹងកាន់តែស៊ីជម្រៅអំពីសមាសធាតុបេតិកភណ្ឌរស់។ នេះក៏អនុញ្ញាតឱ្យគ្រូបង្រៀនបង្កើតសកម្មភាពបំពេញបន្ថែមលើមុខវិជ្ជាមួយចំនួនផងដែរ។
- ក្រៅពីការសម្ភាសន៍សមាជិកសហគមន៍ អ្នកក៏អាចទៅមើលផ្ទះ និងរោងជាងរបស់ពួកគេ ដើម្បីស្វែងយល់បន្ថែមអំពីការអនុវត្តរបស់ពួកគេបានផងដែរ។

- បន្ទាប់ពីអ្នកបានពិនិត្យព័ត៌មាននិងរៀបចំសកម្មភាព និងសម្ភារៈសាលារបស់អ្នករួចហើយ អ្នកអាចស្នើសុំឱ្យសហគមន៍ផ្តល់មតិកែលម្អលើការប្រើប្រាស់ព័ត៌មាន។ ពួកគេនឹងអាចបញ្ជាក់បានថា តើព័ត៌មានត្រឹមត្រូវ ឬអត់ ប្រសិនបើវាត្រូវបានបង្ហាញក្នុងលក្ខណៈគួរឱ្យគោរព ហើយតំណាងឱ្យទស្សនៈផ្សេងៗក្នុងសហគមន៍ (មនុស្សដែលមានភេទ អាយុ ស្ថានភាពសង្គម និងក្រុមផ្សេងទៀត)។ មតិយោបល់ និងគំនិតរបស់ពួកគេនឹងជួយអ្នកបង្ហាញបេតិកភណ្ឌរស់របស់ពួកគេកាន់តែត្រឹមត្រូវ និងរៀបចំសកម្មភាពកាន់តែប្រសើរសម្រាប់សាលារបស់អ្នក។

កំណត់សម្គាល់៖ ការផលិតវីដេអូ ឬការតាំងពិពណ៌រូបថតដែលមានការចូលរួមអាចជំរុញសិស្សឱ្យធ្វើការស្រាវជ្រាវកាន់តែស៊ីជម្រៅបន្ថែមទៀត និងអាចឱ្យពួកគេសម្រេចបាននូវវត្ថុបំណងនៃការសិក្សាកាន់តែងាយស្រួល។

## វិធីសាស្ត្រទូទៅនៃការប្រមូលព័ត៌មាន

សំណួរដែលអាចសួរបានក្នុងការសម្ភាសន៍ និងណែនាំអ្នកនៅពេលប្រមូលព័ត៌មាន៖

**តើបេតិកភណ្ឌរស់ជាអ្វី?**

- តើវាត្រូវបានគេហៅថាដូចម្តេច?
- តើប្រភេទអ្វីត្រូវបានគេអនុវត្ត? (ឧ. របាំ ការអនុវត្តកសិកម្ម ពិធីសាសនា ពិធីបុណ្យ ចំណេះដឹងអំពីអាហារ ប្រព័ន្ធជំនឿ សិប្បកម្ម កីឡាប្រពៃណី។ល។)
- តើវាជាការរួមបញ្ចូលគ្នានៃសមាសធាតុបេតិកភណ្ឌរស់ឬ? (ឧ. ពិធីដែលពាក់ព័ន្ធនឹងវត្ថុសិប្បកម្មផ្សេងៗគ្នា និងការរៀបចំអាហារ។)

**តើនរណាអនុវត្ត?**

- តើសមាសធាតុបេតិកភណ្ឌរស់នេះត្រូវបានអនុវត្តដោយមនុស្សគ្រប់រូបនៅក្នុងសហគមន៍ ឬដោយមនុស្សមកពីក្រុមណាមួយ ឧទាហរណ៍ ក្រុមអាយុ សាសនា ឬភេទ? តើសមាសធាតុបេតិកភណ្ឌរស់ពង្រឹងតួនាទីយេនឌ័រដែរឬទេ?
- តើសិស្សរបស់អ្នក ឬក្រុមគ្រួសាររបស់ពួកគេអនុវត្តបេតិកភណ្ឌរស់នេះទេ?
- តើមនុស្សអនុវត្តបេតិកភណ្ឌមរតកវប្បធម៌អរូបីនេះ នៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេទេ? តើពួកគេប្រើបេតិកភណ្ឌរស់នេះ ដើម្បីប្រកបរបរចិញ្ចឹមជីវិតទេ?
- តើមានអ្នកជំនាញអំពីបេតិកភណ្ឌរស់នេះបានផ្ទេរចំណេះដឹងដល់អ្នកដទៃដែរឬទេ?
- តើមានការធ្លាក់ចុះក្នុងការចូលរួមរបស់សហគមន៍ ទាក់ទងនឹងបេតិកភណ្ឌរស់នេះដែរឬទេ? បើមាន តើហេតុអ្វី?

**តើបេតិកភណ្ឌរស់នេះអនុវត្តនៅពេលណា?**

- តើមនុស្សធ្វើជារៀងរាល់ថ្ងៃមែនទេ?
- តើមានពេលវេលាជាក់លាក់នៃឆ្នាំសម្រាប់វាទេ? (ឧ. តែនៅពេលខ្លះក្នុងវដ្តកសិកម្ម ឬតាមចន្ទគតិប៉ុណ្ណោះ)
- តើវាត្រូវបានអនុវត្តតែនៅពេលដែលមានហេតុផលពិសេសឬ?

**តើបេតិកភណ្ឌវប្បធម៌អរូបីត្រូវបានអនុវត្តនៅកន្លែងណា?**

- តើវាត្រូវបានអនុវត្ត ឬប្រតិបត្តិនៅក្នុងប្រភេទជាក់លាក់នៃទីធ្លា ឬទីតាំង? ឧទាហរណ៍ តើគេអនុវត្តតែនៅផ្ទះ តែក្នុងកន្លែងសាសនា ឬនៅតាមផ្លូវណាមួយតែប៉ុណ្ណោះឬ? ឬវាត្រូវបានអនុវត្តនៅទូទាំងតំបន់ភូមិសាស្ត្រទាំងមូល? (ឧ. នៅក្នុងភូមិណាមួយ នៅលើភ្នំណាមួយ នៅក្នុងខេត្តណាមួយ ឬនៅក្នុងក្រុមនៃប្រទេសណាមួយ)។

**តើគេអនុវត្តវាដោយរបៀបណា?**

- តើអ្វីខ្លះដែលមនុស្សគួរធ្វើ ឬអ្វីខ្លះដែលមនុស្សមិនគួរធ្វើ?
- តើឧបករណ៍ វត្ថុ ឬសម្ភារៈអ្វីខ្លះត្រូវបានគេប្រើដើម្បីធ្វើឱ្យវាកើតឡើង?
- តើប្រជាជនទទួលបានចំណេះដឹងនិងជំនាញដោយរបៀបណា? តើពួកគេផ្ទេរវាទៅអ្នកជំនាន់ក្រោយដោយរបៀបណា? តើមានវិធីសាស្ត្រប្រពៃណីក្នុងការផ្ទេរជំនាញ និងចំណេះដឹងដែលអាចជំរុញសកម្មភាពមួយចំនួននៅក្នុងសាលារបស់អ្នកដែរឬទេ?

**ហេតុអ្វីបានជាបេតិកភណ្ឌវប្បធម៌អរូបីសំខាន់ចំពោះសហគមន៍?**

- តើវាមានអត្ថន័យ និងតម្លៃអ្វីខ្លះសម្រាប់ពួកគេ?
- តើពួកគេមានអារម្មណ៍បែបណានៅពេលពួកគេអនុវត្តបេតិកភណ្ឌរស់នេះ?
- ហេតុអ្វីបានជាសហគមន៍ចង់បន្តការអនុវត្តនេះទៅថ្ងៃអនាគត?

# ឯកសារទី ៥៖ ការបង្រៀនបេតិកភណ្ឌរស់នៅក្នុងថ្នាក់រៀនពហុវប្បធម៌

អ្នកអាចកត់សម្គាល់ឃើញថាសិស្សរបស់អ្នកមានសាវតារសង្គមវប្បធម៌ ឬភូមិសាស្ត្រចម្រុះគ្នាជាច្រើន។ អាស្រ័យហេតុនេះ សិស្សអាចមានចំណុចខុសគ្នាជាច្រើននៅក្នុងន័យបេតិកភណ្ឌរស់របស់ពួកគេ ហើយនៅក្នុងក្រុមសិស្សទាំងអស់ គ្រួសារមួយចំនួនអាចមានការអនុវត្ត និងកម្រិតចំណេះដឹងខុសៗគ្នា។ នៅក្នុងបរិបទនេះ ប្រហែលជាមិនអាចជ្រើសរើសសមាសធាតុនៃបេតិកភណ្ឌរស់សម្រាប់សកម្មភាពសាលា ដែលសិស្សទាំងអស់សុទ្ធតែស្គាល់បានឡើយ។ ម្យ៉ាងវិញទៀត បរិយាកាសថ្នាក់រៀនពហុវប្បធម៌ មានឱកាសក្នុងការស្វែងយល់អំពីទស្សនៈជាច្រើន យល់ដឹងកាន់តែប្រសើរ និងគោរព ភាពចម្រុះ និងអភិវឌ្ឍស្មារតី ក្នុងនាមយើងជាមនុស្សជាតិតែមួយ។ ប្រធានបទទាំងនេះ គឺសុទ្ធសឹងតែជាផ្នែកនៃពលរដ្ឋវិទ្យាសកល។ ការបង្រៀននៅក្នុងបរិយាកាសពហុវប្បធម៌គឺជារឿងលំបាក ក៏ប៉ុន្តែវាអាចក្លាយជាទ្រព្យដ៏ប្រពៃសម្រាប់ការអប់រំ។ ការណែនាំខាងក្រោមនេះអាចជួយឱ្យអ្នក ប្រែក្លាយស្ថានភាពលំបាកទៅជាឱកាសសម្រាប់សិស្សរបស់អ្នក។

## វិធីសាស្ត្រទូទៅនៃការប្រមូលព័ត៌មាន

បេតិកភណ្ឌរស់មួយចំនួន ដូចជា ពិធីសាសនា និងការប្រារព្ធពិធីប្រជាប្រិយ ពីធីបុណ្យធំៗ និងការប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី គឺជាពិធីដែលអ្នកទាំងផងស្គាល់ជាទូទៅយ៉ាងទូលំទូលាយ។ សិស្សភាគច្រើនអាចស្គាល់ និងអាចផ្សារភ្ជាប់មេរៀនទៅនឹងប្រធានបទទាំងនេះ ទោះបីជាពួកគេមិនបានអនុវត្តប្រធានបទនេះផ្ទាល់ក៏ដោយ។ មេរៀននេះ អាចជំរុញឱ្យសិស្ស ដែលមិនបានអនុវត្តសមាសធាតុទាំងនេះអាចយល់ដឹងកាន់តែប្រសើរ និងឱ្យតម្លៃដល់សមាសធាតុទាំងនោះទៀតផង។



### ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនៅតំបន់អាស៊ីអាគ្នេយ៍

នៅតំបន់អាស៊ីអាគ្នេយ៍ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិហៅថា សង្ក្រាន នៅក្នុងប្រទេសថៃ នៅសាធារណរដ្ឋប្រជាមានិតឡាវហៅថា ភិម៉ៃ នៅក្នុងប្រទេសកម្ពុជាហៅថា បុណ្យចូលឆ្នាំខ្មែរ និងនៅប្រទេសមីយ៉ាន់ម៉ាហៅថា ធីងយ៉ាន។ បុណ្យចូលឆ្នាំថ្មី គឺប្រារព្ធធ្វើឡើងរយៈពេលពីរបីថ្ងៃ និងជាឱកាសសម្រាប់ប្រជាជនគ្រប់រូបធ្វើដំណើរកម្សាន្ត និងចូលរួមកម្មវិធីនានា។ ការប្រារព្ធពិធីនេះ រួមបញ្ចូលទាំងប្រពៃណីជួបជុំគ្នានៅតាមគ្រួសារផងដែរ។ ឧទាហរណ៍ ប្រជាជននាំគ្នាទៅលេងតាមប្រាង្គប្រាសាទជាមួយក្រុមគ្រួសារ បោសសម្អាត និងរៀបចំផ្ទះ និងបង្ហាញការគោរពដឹងគុណចំពោះជីដូនជីតារបស់ពួកគាត់។ ជាមួយគ្នានេះដែរ ក៏មានការរៀបចំកម្មវិធីវប្បធម៌ជាច្រើនផងដែរ។

សម្រាប់ជនបរទេស ទិដ្ឋភាពដែលល្បីបំផុតនៃការប្រារព្ធពីធីបុណ្យចូលឆ្នាំថ្មី គឺប្រហែលជាការបាញ់ទឹកដែលមនុស្សគ្រប់គ្នាសុទ្ធតែអាចចូលរួមលេង។

មេរៀន និងសកម្មភាពសាលាដែលផ្អែកលើការប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី គឺទំនងជានឹងទាក់ទាញចំណាប់អារម្មណ៍របស់សិស្សទាំងអស់។

## ការរៀបចំទិវា ការតាំងពិព័រណ៍ និងពិធីបុណ្យវប្បធម៌

ការរៀបចំពិធីទិវាវប្បធម៌ ឬការតាំងពិព័រណ៍វប្បធម៌ គឺមធ្យោបាយដ៏មានប្រសិទ្ធភាពមួយ ដើម្បីអបអរសាទរចំពោះភាពចម្រុះគ្នានៅក្នុងសាលា។ កម្មវិធីនៅក្នុងទិវាវប្បធម៌អាចរួមបញ្ចូល ការភ្លក្សម្ហូបអាហារ ការសម្តែងសិល្បៈ និងរោងសិប្បកម្ម។ សាលា ឬសហគមន៍អាចលើកឡើងនូវប្រធានបទមួយចំនួនដូចជា ឧទាហរណ៍ កីឡា ឬសម្លៀកបំពាក់ប្រពៃណី ជាដើម។ សិស្សានុសិស្ស និងគ្រួសាររបស់ពួកគេ សហគមន៍ និងគ្រូបង្រៀនមកពីគ្រប់មជ្ឈដ្ឋានទាំងអស់អាចចូលរួមបាន។ កម្មវិធីនេះក៏ផ្តល់ទស្សនៈយ៉ាងទូលាយអំពីសាលា ឬភាពចម្រុះនៃថ្នាក់រៀនផងដែរ។ ដូចគ្នានេះដែរ ព័ត៌មានដែលប្រមូលបាននៅក្នុងអំឡុងពេលប្រារព្ធកម្មវិធីនេះ ក៏អាចជំរុញឱ្យអ្នកបង្កើតសកម្មភាព និងមេរៀនថ្មីៗផងដែរ។

### ការបង្ហាញពីបេតិកភណ្ឌរបស់សិស្សនៅក្នុងការប្រារព្ធពិធីរបស់សាលា (ហ្វីលីពីន)

កម្មវិធីតន្ត្រី សិល្បៈ អប់រំកាយ និងសុខភាព (MAPEH) ប្រចាំឆ្នាំនៅវិទ្យាល័យ Pres. Sergio Osmeña រដ្ឋធានីម៉ានីល ប្រទេសហ្វីលីពីន គឺជាឱកាសមួយសម្រាប់សិស្សានុសិស្ស ក្នុងការចែករំលែកអំពីបេតិកភណ្ឌវប្បធម៌របស់ពួកគេជាមួយដៃគូ។ សិស្សនៅសាលានេះមកពីសាលាទូទាំងប្រទេស ដូច្នេះកម្មវិធី MAPEH រៀបចំប្រារព្ធកម្មវិធីរបាំ និងចម្រៀងប្រភេទចម្រុះគ្នា ដែលមានការចូលរួមពីតំបន់ និងក្រុមប្រជាជនភាគតិចផ្សេងៗគ្នានៃប្រទេសហ្វីលីពីន។ នៅក្នុងការរៀបចំពិធីនេះ ថ្នាក់នីមួយៗរៀបចំក្បាច់រាំដែលផ្អែកលើរបាំប្រពៃណីណាមួយរបស់សិស្ស។ សិស្សម្នាក់នេះដឹកនាំការបង្រៀនមិត្តរួមថ្នាក់របស់គាត់ ដែលបង្ហាញអំពីការពង្រឹងសិទ្ធិអំណាច។



## លើកទឹកចិត្តឱ្យសិស្សពិភាក្សាគ្នា និងផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក

សមាសធាតុនៃបេតិកភណ្ឌរស់មួយចំនួន អាចជាចំណុចចាប់ផ្តើមសម្រាប់សកម្មភាព និងការពិភាក្សាគ្នា។ ឧទាហរណ៍ មេរៀនអំពីម្ហូបអាហារដែលសហគមន៍មួយចំនួនរៀបចំសម្រាប់អាពាហ៍ពិពាហ៍ អាចជាឱកាសសម្រាប់ឱ្យសិស្សទាំងអស់នៅក្នុងថ្នាក់ធ្វើការពិភាក្សាអំពីប្រភេទម្ហូបអាហារ ដែលពួកគេរៀបចំសម្រាប់អាពាហ៍ពិពាហ៍នៅក្នុងសហគមន៍របស់ពួកគេ និងប្រៀបធៀបម្ហូបអាហារទាំងនោះដើម្បីស្វែងរកចំណុចដូចគ្នា និងខុសគ្នា។ ការផ្លាស់ប្តូរមតិទៅវិញទៅមកនេះ លើកទឹកចិត្តឱ្យសិស្សធ្វើការស្វែងយល់ និងផ្តល់តម្លៃចំពោះភាពចម្រុះ។ ចូរធ្វើយ៉ាងណាឱ្យសិស្សរក្សានូវភាពទន់ភ្លន់ និងការគោរពចំពោះគ្នាទៅវិញទៅមកជានិច្ច។ ដូច្នេះ ជាការសំខាន់ដែលត្រូវកំណត់បទបញ្ញាផ្ទៃក្នុងមុនចាប់ផ្តើមធ្វើការពិភាក្សា ដូចជាប្រាប់ឱ្យសិស្សធ្វើការពណ៌នាជាជាងការវាយតម្លៃ។

### ការប្រៀបធៀបសម្លៀកបំពាក់តាមតំបន់ផ្សេងៗគ្នា (ប៉ាគីស្ថាន)

នៅវិទ្យាល័យប៉ាគីស្ថាន គ្រូបង្រៀនម្នាក់ បានរៀបចំមេរៀនសិក្សាសង្គមអំពីការប៉ាក់ និងសម្លៀកបំពាក់ប្រពៃណីដើម្បីបង្ហាញអំពីភាពចម្រុះនៃវប្បធម៌ក្នុងតំបន់។ សិស្សធ្វើការស្រាវជ្រាវទៅលើសម្លៀកបំពាក់ប្រពៃណីនៅក្នុងតំបន់ និងបានពិនិត្យមើលគំរូនៃការប៉ាក់ផងដែរ។ ពួកគេបានធ្វើការពិភាក្សាអំពីភាពខុសគ្នារវាងសម្លៀកបំពាក់បុរស និងស្ត្រី ព្រមទាំងការប្រើប្រាស់ជាច្រើនប្រភេទផងដែរ។ ពួកគេក៏បានពាក់សម្លៀកបំពាក់ប្រពៃណីរបស់សហគមន៍មកសាលា និងបានពន្យល់អំពីលក្ខណៈពិសេស អត្ថន័យ និងគុណតម្លៃរបស់វាផងដែរ។



## លើកទឹកចិត្តឱ្យសិស្សចូលរួមនៅក្នុងការប្រមូលព័ត៌មាន

សិស្សភាគច្រើនអាចក្រេបជញ្ជក់ចំណេះដឹងកាន់តែច្រើន អំពីបេតិកភណ្ឌរស់នៅពេលដែលពួកគេចូលរួមនៅក្នុងការប្រមូលព័ត៌មានអំពីបេតិកភណ្ឌរស់នោះ។ កិច្ចការដែលសិស្សអាចធ្វើបាន គឺស្វែងរក និងចងក្រងជាឯកសារនូវការអនុវត្តវប្បធម៌ដែលគ្រួសារ ឬសហគមន៍របស់ពួកគេចូលរួម បន្ទាប់មក ធ្វើការចែករំលែកព័ត៌មាននេះជាមួយមិត្តរួមថ្នាក់។

### ឯកសារអំពីការអនុវត្តតាមតំបន់នៅពេលចុះដល់ទីតាំងផ្ទាល់ (ប្រទេសថៃ)

នៅក្នុងភូមិ Ban Mae Ngon Khilek នៅក្នុងប្រទេសថៃ សិស្សបានបំពេញទស្សនកិច្ចទៅកាន់សហគមន៍មួយចំនួន ដើម្បីធ្វើការប្រមូលព័ត៌មានអំពីតម្បាញ ឬស្បៃស័ក្តិសិទ្ធិ ដែលប្រជាជនចងព្យួរនៅមុខផ្ទះដើម្បីការពារផ្ទះរបស់ពួកគេ៖ ហៅថា *talaew*។ ពួកគេបានចងក្រងឯកសារដំបូងអំពី *talaew* ពីសហគមន៍ថៃយ៉ៃ។ បន្ទាប់មក គេបានពិភាក្សាអំពីវត្ថុស័ក្តិសិទ្ធិរបស់ក្រុមប្រជាជនភាគតិចផ្សេងៗទៀត ហើយប្រៀបធៀបវត្ថុស័ក្តិសិទ្ធិទាំងនោះដើម្បីស្វែងរកចំណុចដូចគ្នា និងខុសគ្នា។

## ជ្រើសរើសសមាសធាតុនៃបេតិកភណ្ឌរស់ពីសហគមន៍ផ្សេងៗនៅក្នុងតំបន់មូលដ្ឋាន

នៅក្នុងបរិបទពហុវប្បធម៌ ជាការសំខាន់ណាស់ដែលត្រូវផ្សារភ្ជាប់សាលាទៅនឹងបណ្តាសហគមន៍ទាំងអស់នៅក្នុងតំបន់មូលដ្ឋាន។ ដើម្បីបង្កើតបរិយាកាសដែលមានបរិយាបន្ននៅក្នុងថ្នាក់រៀន សូមរួមបញ្ចូលសមាសធាតុនៃបេតិកភណ្ឌរស់ពីបណ្តាក្រុមជនជាតិភាគតិច និងក្រុមវប្បធម៌ជាច្រើនរបស់សិស្សទៅក្នុងមេរៀន និងសកម្មភាពរបស់អ្នកនៅពេញមួយឆ្នាំសិក្សា។ ចូរធ្វើយ៉ាងណាកុំឱ្យមានការលម្អៀង ទៅលើក្រុមប្រជាជនភាគតិចណាមួយ



ជាងក្រុមជនជាតិភាគតិចផ្សេងទៀតឱ្យសោះ។ សូមអញ្ជើញវាគ្មិន ដូចជា ឪពុកម្តាយ និងអ្នកប្រតិបត្តិបេតិកភណ្ឌមកពីក្រុមប្រជាជនភាគតិច និងសហគមន៍នីមួយៗនៃសហគមន៍ទាំងនោះ ឱ្យចែករំលែកអំពីចំណេះដឹង និងការអនុវត្តរបស់ពួកគាត់។

### ការសិក្សាអំពីការអនុវត្តនៅក្នុងសហគមន៍តាម៉ាំង (ប្រទេសនេប៉ាល់)

នៅក្នុងប្រទេសនេប៉ាល់ សាលានានានៅក្នុងក្រុង គីរទីពួរ ដើមឡើយគឺមានចំណាប់អារម្មណ៍តែទៅលើបេតិកភណ្ឌវប្បធម៌អរូបីពីសហគមន៍ញូវ៉ាប៉ុណ្ណោះ។ ប៉ុន្តែ បន្ទាប់ពីពួកគេបានជួបជាមួយអ្នកតំណាងសហគមន៍មក ពួកគេបានឃើញកាន់តែច្បាស់ថា សហគមន៍ប្រជាជនតាម៉ាំងដ៏ធំមួយ ក៏រស់នៅក្នុងតំបន់នោះដែរ។ ជាលទ្ធផល ពួកគេបានសម្រេចចិត្តដាក់បញ្ចូលការប្រារព្ធពិធី សូម៉ាន លូឆារ (*Sonam Lhochhar*) របស់សហគមន៍តាម៉ាំងនៅក្នុងកម្មវិធីសិក្សាក្នុងមូលដ្ឋាន និងបង្កើតមេរៀនពាក់ព័ន្ធមួយចំនួនផងដែរ។

## ការជម្នះភាពខុសគ្នា

នៅក្នុងករណីមួយចំនួន ទោះបីជាអ្នកខិតខំប្រឹងប្រែងបង្កើតបរិបទពហុវប្បធម៌បើកចំហដែលស្វាគមន៍បេតិកភណ្ឌរស់ជាច្រើនប្រភេទក៏ដោយ ក៏សិស្សមួយចំនួនអាចមានអារម្មណ៍មិនល្អ ឬស្ទាក់ស្ទើរក្នុងការចូលរួមនៅក្នុងសកម្មភាព ដែលផ្សារភ្ជាប់ទៅនឹងសមាសធាតុនៃបេតិកភណ្ឌរស់មួយចំនួន។ កត្តានេះអាចបណ្តាលមកពីការអនុវត្តមួយចំនួនរបស់សហគមន៍ពួកគេ រឹតត្បិតទៅទៅលើក្រុមផ្សេងទៀត (ឧទាហរណ៍ តែបុរស ឬតែស្ត្រីមិនទាន់រៀបការប៉ុណ្ណោះ) ឬក៏ពួកគេមិនអនុវត្តទាល់តែសោះតែម្តង។ ក្នុងករណីនេះ ជាការសំខាន់ណាស់ដែលត្រូវពន្យល់ដល់សិស្សថា បេតិកភណ្ឌរស់អាចមានការវិវឌ្ឍតាមពេលវេលា ហើយការអនុវត្តក៏អាចមានការផ្លាស់ប្តូរដែរ។ ទោះបីជាមិនគួរបង្ខំសិស្សឱ្យចូលរួមនៅក្នុងសកម្មភាពនានា ដែលធ្វើឱ្យពួកគេមិនស្រួលក្នុងចិត្តក៏ដោយ ក៏ត្រូវប្រាប់ពួកគេឱ្យបានដឹងដែរថា ដើម្បីឱ្យសង្គមមានសន្តិភាព ជាការសំខាន់ណាស់ដែលត្រូវគោរពគ្នាទៅវិញទៅមក និងគោរពទៅលើរបៀបដែលពួកគេអនុវត្តបេតិកភណ្ឌរបស់ពួកគេ ទោះជាការអនុវត្តទាំងនោះ ខុសគ្នាពីការអនុវត្តរបស់ពួកគេក៏ដោយ។ ប្រសិនបើផ្តល់ឱកាស សិស្សនឹងស្វែងយល់ និងរៀនឱ្យតម្លៃដល់ភាពចម្រុះគ្នានៃវប្បធម៌។ ពួកគេក៏រៀនរស់នៅដោយសន្តិភាព ជាមួយនឹងមនុស្សដែលខុសពីពួកគេ ឲ្យចេះអត់ឱន និងគោរពចំពោះគ្នាទៅវិញទៅមក ដើម្បីអាចក្លាយទៅជាពលរដ្ឋសកលពិតប្រាកដ។

# ឯកសារទី ៦៖ ឆ្លើយសំណួរដែលអ្នកអាចមាន ...

| សំណួររបស់គ្រូ | ចម្លើយ/ដំណោះស្រាយ | សម្រាប់ព័ត៌មានបន្ថែម សូមមើលកូនសៀវភៅផ្សេងទៀតនៅក្នុងសៀវភៅនេះ |
|---|---|---|
| មុខវិជ្ជាដែលខ្ញុំបង្រៀនមិនពាក់ព័ន្ធនឹងវប្បធម៌នោះទេ។ តើវិធីសាស្ត្រនេះ (ការបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងការអប់រំ) មានប្រយោជន៍សម្រាប់ខ្ញុំដែរឬទេ? | ការបង្រៀនបេតិកភណ្ឌរស់ក្នុងសាលា មិនមែនមានន័យថា ជាការបង្រៀនអំពីបេតិកភណ្ឌរស់ និងវប្បធម៌ហ្នឹងនោះទេ តែក៏អាចមានន័យថាជាការប្រើប្រាស់បេតិកភណ្ឌរស់ដើម្បីបង្កើតមុខវិជ្ជាផ្សេងទៀត (ឧទាហរណ៍ មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ) ឱ្យកាន់តែងាយស្រួលយល់ ឬកាន់តែចាប់អារម្មណ៍សម្រាប់សិស្ស។ វិធីសាស្ត្រក៏ជួយសម្របសម្រួលបរិបទចូលទៅក្នុងមេរៀន និងសកម្មភាពផងដែរ។ វិធីសាស្ត្រនេះអាចអនុវត្តចំពោះមុខវិជ្ជា និងសកម្មភាពក្រៅកម្មវិធីសិក្សានានា។<br><br>'ខ្ញុំអញ្ជើញអ្នកទាំងអស់គ្នាឱ្យចូលរួមនៅក្នុងវិធីសាស្ត្រប្រភេទនេះ ស្វែងរកអ្វីថ្មីៗសម្រាប់ខ្លួនឯងក្នុងនាមជាគ្រូបង្រៀន។' Madina Bekenova គ្រូបង្រៀនមុខវិជ្ជាភាសា Kazakh និងអក្សរសាស្ត្រ សាលាអប់រំហ្វឹកហ្វឺន លេខ ៨ ប្រទេសកាហ្សាក់ស្ថាន។<br><br>'គម្រោងនេះបានជួយឱ្យខ្ញុំបង្កើតនូវភាពចម្រុះគ្នាសម្រាប់មេរៀនរបស់ខ្ញុំ ដោយទទួលបានចំណេះដឹងថ្មីៗ និងបទពិសោធន៍ដ៏មានតម្លៃ។ អនុវត្តវិធីសាស្ត្រនេះទៅ។' Rano Abdukova គ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា ភូមិវិទ្យា និងវិទ្យាសាស្ត្រសង្គម សាលា EC Ilim Complex ប្រទេសគៀជីស្ថាន។ | ដើម្បីសិក្សាបន្ថែមអំពីអត្ថន័យនៃការបង្រៀនជាមួយនឹងបេតិកភណ្ឌរស់ និងអត្ថប្រយោជន៍នៃវិធីសាស្ត្រនេះ សូមមើលកូនសៀវភៅទី ២។<br><br>សូមមើល ឯកសារ ២ និងឯកសារ ៣ សម្រាប់ឧទាហរណ៍អំពីរបៀបដាក់បញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងមុខវិជ្ជានានា។ |
| ខ្ញុំមិនដឹងអ្វីសោះអំពីវប្បធម៌។ តើវិធីសាស្ត្រនេះអាចអនុវត្តបានសម្រាប់ខ្ញុំដែរឬទេ? | ចំណុចចាប់ផ្តើមងាយស្រួលបំផុត គឺការបង្កើតសកម្មភាពដែលផ្សារភ្ជាប់បេតិកភណ្ឌរស់របស់អ្នកផ្ទាល់ទៅនឹងបេតិកភណ្ឌរស់របស់សិស្ស។ ពួកគេអាចចែករំលែកចំណេះដឹងជាមួយអ្នក និងជាមួយមិត្តរួមថ្នាក់។ ដៃគូជាច្រើនក៏អាចផ្តល់ព័ត៌មាន និងជំរុញទឹកចិត្តដល់អ្នកផងដែរ។ អ្នកអាចទៅរកគ្រូបង្រៀនផ្សេងទៀត ឪពុកម្តាយសិស្ស ប្រជាជនក្នុងសហគមន៍ សមាគម និងអ្នកជំនាញផ្នែកវប្បធម៌ ដើម្បីស្វែងរកការគាំទ្របន្ថែមទៀត។ | សូមមើលជំហានទី ១ នៅក្នុងកូនសៀវភៅទី ៤ ដើម្បីរៀនអំពីរបៀបកំណត់អត្តសញ្ញាណដៃគូ។ |

| សំណួររបស់គ្រូ | ចម្លើយ/ដំណោះស្រាយ | សម្រាប់ព័ត៌មានបន្ថែម សូមមើលកូនសៀវភៅផ្សេងទៀតនៅក្នុងសៀវភៅនេះ |
|---|---|---|
| | "ខ្ញុំតែងតែព្យាយាមបន្តឆ្ពោះទៅមុខ រៀនអ្វីថ្មីៗ និងបណ្តុះទឹកចិត្តរបស់សិស្ស ដើម្បីឱ្យមានការអភិវឌ្ឍ និងការរៀនសូត្រជានិច្ច។ ខ្ញុំក៏ចង់ឱ្យមេរៀនរបស់ខ្ញុំមានភាពចម្រុះ ណែនាំអ្វីថ្មីៗ និងជំរុញទឹកចិត្តដល់សិស្សរបស់ខ្ញុំផងដែរ។ ចំពោះខ្ញុំ ចំណុចគួរឱ្យចាប់អារម្មណ៍នោះ គឺការចូលរួមនៅក្នុងគម្រោងនេះ។ ខ្ញុំបានរៀនសូត្រយ៉ាងច្រើនអំពីបេតិកភណ្ឌវប្បធម៌ បេតិកភណ្ឌវប្បធម៌អរូបី និងវិធីសាស្ត្របង្រៀនថ្មីៗ។" Bakytbekkyzy Aisezim គ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យា សីលធម៌ និងអក្សរសាស្ត្រ សាលាលេខ៩៥ ប្រទេសគៀដីស្ថាន។ | |
| កម្មវិធីសិក្សានេះគឺពេញខ្លាំងណាស់។ តើវិធីសាស្ត្រនេះអាចរួមបញ្ចូលនូវមុខវិជ្ជាបន្ថែមអំពីបេតិកភណ្ឌរស់បានយ៉ាងដូចម្តេច? | ការបង្រៀនបេតិកភណ្ឌរស់ក្នុងសាលា មិនមែនមានន័យថាជាការបង្កើតមុខវិជ្ជាថ្មីនោះទេ។ ផ្ទុយមកវិញ វាគឺជាវិធីសាស្ត្រមួយដែលអាចអនុវត្តចំពោះមុខវិជ្ជា មេរៀន និងសកម្មភាពដែលមានស្រាប់នៅក្នុងសាលា។<br><br>មុខវិជ្ជាមួយចំនួននៅសាលារបស់អ្នក ហាក់បីដូចជាបានដាក់បញ្ចូលបេតិកភណ្ឌរស់រួចទៅហើយ ឧទាហរណ៍ សិល្បៈ ជាដើម។ ឧទាហរណ៍ នៅក្នុងប្រទេសកម្ពុជា មេរៀននៅក្នុងមុខវិជ្ជា "វប្បធម៌ និងអប់រំសិល្បៈ" គឺសម្បូរទៅដោយឧទាហរណ៍អំពីសិល្បៈ និងសិប្បកម្មនៅក្នុងមូលដ្ឋាន។<br><br>នៅក្នុងប្រទេសថៃ ការអនុវត្ត និងជំនឿពាក់ព័ន្ធនឹងវត្ថុស័ក្តិសិទ្ធិ ដែលធ្វើឡើងពីឫស្សីត្បាញ ត្រូវបានបញ្ចូលទៅក្នុងមុខវិជ្ជាចំនួនប្រាំបី៖ គណិតវិទ្យា (រាង និងទម្រង់ធរណីមាត្រ) អប់រំកាយ (ចលនារាងកាយ) វិទ្យាសាស្ត្រសង្គម (ជំនឿ និងការបង្រៀនសាសនា និងចំណងទំនាក់ទំនងសង្គម) សិល្បៈ (គំនូរ) វិទ្យាសាស្ត្រ (ធនធានធម្មជាតិ) ការអភិវឌ្ឍអាជីពការងារ (ការបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតាមសហគមន៍ និងការបង្កើតចំណូលសេដ្ឋកិច្ចតាមរយៈការលក់ *talaew*) ភាសាអង់គ្លេស និងចិន (វាក្យសព្ទពាក់ព័ន្ធ) និងភាសាថៃ (សារតារ និងប្រវត្តិសាស្ត្រ)។ | ដើម្បីសិក្សាបន្ថែមអំពីវិធីដាក់បញ្ចូលបេតិកភណ្ឌរស់ទៅក្នុងមេរៀន និងអំពីទំនាក់ទំនងដែលអាចមានជាមួយនឹងមុខវិជ្ជាមានស្រាប់ សូមមើល ឯកសារ ២ និងឯកសារ ៣ នៃកូនសៀវភៅនេះ (កូនសៀវភៅទី ៨)។ |

| សំណួររបស់គ្រូ | ចម្លើយ/ដំណោះស្រាយ | សម្រាប់ព័ត៌មានបន្ថែម សូមមើលកូនសៀវភៅផ្សេងទៀតនៅក្នុងសៀវភៅនេះ |
|---|---|---|
| កាលវិភាគរបស់ខ្ញុំពេញអស់ហើយ។ តើខ្ញុំធ្វើយ៉ាងម៉េច ដើម្បីអាចលៃពេល រៀបចំសកម្មភាពបន្ថែមទាំងនេះបាន? | ជាការពិតណាស់ដែលថាការរៀបចំសកម្មភាពថ្មីៗគឺតម្រូវឱ្យមានពេលវេលា ប៉ុន្តែនេះក៏ការ វិនិយោគពេលវេលាដ៏ល្អមួយផងដែរ។ នៅពេលដែលអ្នកបង្កើតសកម្មភាពរួចរាល់ហើយ អ្នកអាចអនុវត្តសកម្មភាពទាំងនោះឡើងវិញបាននៅឆ្នាំក្រោយ និងឆ្នាំក្រោយៗទៀត។ អ្នកមិនចាំបាច់ធ្វើការងារនេះតែម្នាក់ឯងនោះទេ។ ចូរអញ្ជើញគ្រូបង្រៀនផ្សេងទៀតនៅក្នុងសាលារបស់អ្នក ប្រជាជនក្នុងសហគមន៍ និងជំនាញការមកពីស្ថាប័នពាក់ព័ន្ធឱ្យធ្វើការចែករំលែកបន្ទុកការងាររៀបចំនេះ។<br><br>អ្នកអាចចំណេញពេលវេលាបាន ដោយស្វែងរកបេតិកភណ្ឌរស់មួយណា ដែលអ្នកធ្លាប់បានស្គាល់កន្លងមក។ អ្នកនឹងមានចំណេះដឹងស្រាប់មួយចំនួន ហើយអាចប្រមូលព័ត៌មានបន្ថែមពីមនុស្សនៅជុំវិញខ្លួនអ្នក ឬនៅក្នុងអំឡុងពេលកម្មវិធីវប្បធម៌ដែលអ្នកចូលរួមជាទូទៅ។<br><br>គ្រូបង្រៀនជនជាតិនេប៉ាល់ Sabitree Maharjan បានរកឃើញវិធីជំរុញទឹកចិត្តសម្រាប់មេរៀនមួយក្នុងចំណោមមេរៀនគណិតវិទ្យារបស់គាត់ នៅក្នុងការប្រារព្ធពិធីមួយដែលធ្វើឡើងនៅក្នុងគ្រួសាររបស់គាត់ផ្ទាល់។ ស្របពេលដែលគាត់បានជួយរៀបចំ គាត់បានចងក្រងជាឯកសារ និងប្រមូលព័ត៌មាន និងរូបថតអំពីពិធីបុណ្យ ដែលបន្ទាប់មក គាត់បានប្រើប្រាស់នៅក្នុងថ្នាក់របស់គាត់។ | សូមអនុវត្តតាមវិធីសាស្ត្រប្រាំមួយជំហាន (កូនសៀវភៅទី ៤)។<br><br>ឧទាហរណ៍ពីគ្រូបង្រៀនផ្សេងទៀតដែលបានផ្តល់ជូននៅក្នុងសៀវភៅនេះទាំងមូល គឺជាប្រភពជំរុញទឹកចិត្តដ៏ល្អ។ |
| សាលារបស់ខ្ញុំបានអនុវត្តកម្មវិធីអប់រំផ្សេងៗជាច្រើនរួចមកហើយ ដូចជាពលរដ្ឋវិទ្យាសកល ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព ការអប់រំភាសាកំណើត និងការសិក្សាអំពីសង្គម និងអារម្មណ៍។ តើការបង្រៀនដោយប្រើវិធីសាស្ត្របេតិកភណ្ឌរស់មានលក្ខណៈស្របគ្នា ឬទេ? | វិធីសាស្ត្រទាំងអស់នេះ មានគោលបំណងលើកកម្ពស់គុណភាពអប់រំ ដូច្នេះវិធីសាស្ត្រទាំងអស់គឺសុទ្ធតែសមស្រប។ ការបង្រៀនបេតិកភណ្ឌរស់ ក៏អាចពង្រឹងគោលការណ៍គរុកោសល្យដែលអ្នកបានអនុវត្តរួចមកហើយ និងសម្រេចបាននូវគោលដៅបន្ថែមនៃការគាំពារបេតិកភណ្ឌវប្បធម៌ផងដែរ។<br><br>នៅប្រទេសប៉ាគីស្ថាន ក្នុងសហគមន៍ Pukhtunwali សិស្សានុសិស្សនាំគ្នាអានរឿងនិទានអំពីសាច់រឿងក្នុងមូលដ្ឋាន។ ពួកគេបានស្រមើស្រមៃពីតួអង្គចំនួនពីរ និងសរសេររឿងដោយខ្លួនឯងដោយផ្អែកលើទំនៀមទម្លាប់របស់ Pukhtunwali។ បន្ទាប់មក ពួកគេធ្វើការពិចារណា និងពិភាក្សាអំពីទិដ្ឋភាពនៃវប្បធម៌ Pukhtunwali ដែលអាចគាំទ្រដល់ផ្នត់គំនិតអវិជ្ជមាន និងបំពានទៅលើសិទ្ធិនារី។ រឿងព្រេងនិទានក្នុងមូលដ្ឋាន គឺជាចំណុចចាប់ផ្តើមសម្រាប់ការផ្លាស់ប្តូរមតិទៅវិញទៅមកអំពីបញ្ហាសិទ្ធិមនុស្សកាន់តែទូលំទូលាយ។ | សិក្សាបន្ថែមអំពីចំណុចនេះនៅក្នុងកូនសៀវភៅទី៣។ |

| សំណួររបស់គ្រូ | ចម្លើយ/ដំណោះស្រាយ | សម្រាប់ព័ត៌មានបន្ថែម សូមមើលកូនសៀវភៅផ្សេងទៀតនៅក្នុងសៀវភៅនេះ |
|---|---|---|
| បន្ថែមពីលើការរៀបចំមេរៀនធម្មតារបស់ខ្ញុំ តើមានធនធានអ្វីខ្លះដែលខ្ញុំត្រូវការដើម្បីអនុវត្តសកម្មភាពសិក្សា និងសម្រេចឱ្យបានតាមគោលបំណងមេរៀន ?<br><br>តើខ្ញុំត្រូវការកញ្ចប់ថវិកាពិសេសដើម្បីអនុវត្តវិធីសាស្ត្រនេះឬទេ ? | អ្នកអាចនឹងត្រូវការធនធានមួយចំនួនសម្រាប់បង្កើតកម្មវិធីជាមួយនឹងបេតិកភណ្ឌរស់ ដូចជាសម្ភារៈសិក្សា បរិក្ខារ មធ្យោបាយដឹកជញ្ជូនជាដើម។ អ្នកអាចបញ្ចេញភាពច្នៃប្រឌិត និងប្រើប្រាស់អ្វីដែលអ្នកមានស្រាប់ (អ្នកប្រហែលជាបានប្រើប្រាស់ធនធានមួយចំនួនរួចហើយសម្រាប់សកម្មភាពផ្សេងៗ) ហើយអ្នកក៏អាចសហការជាមួយដៃគូដែលមានធនធានដែលត្រូវការចាំបាច់។<br><br>ការបង្រៀនបេតិកភណ្ឌរស់នៅសាលា មិនចាំបាច់ទាល់តែមានកញ្ចប់ថវិកាបន្ថែមនោះទេ។ ប្រសិនបើត្រូវការថវិកាសម្រាប់សកម្មភាពមួយចំនួន (ឧទាហរណ៍ ទូទាត់ថ្លៃមធ្យោបាយដឹកជញ្ជូនសម្រាប់ការបំពេញទស្សនកិច្ចសិក្សា) សូមពិគ្រោះជាមួយគណៈគ្រប់គ្រងសាលា និងមិត្តរួមការងាររបស់អ្នកដើម្បីពិនិត្យមើលឱកាសស្វែងរកមូលនិធិមានស្រាប់ នៅក្នុង និងក្រៅសាលា។<br><br>គ្រូបង្រៀនមកពីសាលា Ban Ku Ku នៅប្រទេសថៃបានបង្កើតបណ្តាញស្ថាប័នរដ្ឋាភិបាលក្នុងមូលដ្ឋាន និងអង្គការផ្សេងៗ ដែលអនុញ្ញាតឱ្យពួកគាត់អាចខ្ចីឧបករណ៍តន្ត្រី និងគ្រឿងសម្ភារៈវប្បធម៌ ដោយមិនអស់ថ្លៃចំណាយ។ សម្ភារៈទាំងនេះសម្រាប់ឱ្យសិស្សប្រើនៅពេលចូលរួមក្នុងការប្រារព្ធពិធីវប្បធម៌ និងមេរៀនពាក់ព័ន្ធ។ | សូមមើលកូនសៀវភៅទី ៤ ជំហានទី ២ |
| ថ្នាក់របស់ខ្ញុំមានសិស្សច្រើនណាស់។ តើខ្ញុំអាចអនុវត្តវិធីសាស្ត្រនេះដោយរបៀបណា ? | នៅក្នុងថ្នាក់មានសិស្សច្រើន សិស្សទំនងជាមានសាវតារចម្រុះ ព្រមទាំងមានចំណាប់អារម្មណ៍ និងជំនាញផ្សេងៗគ្នាជាច្រើនដែរ។ ការធ្វើយ៉ាងណាឱ្យសិស្សទាំងអស់ចូលរួមអាចមានការលំបាក ប៉ុន្តែការបង្រៀនបេតិកភណ្ឌរស់ក្នុងសាលារបស់អ្នកអាចជាទ្រព្យ ដោយសារតែវិធីសាស្ត្រនេះ ជារឿយៗ លើកទឹកចិត្តឱ្យសិស្សកាន់តែមានចំណាប់អារម្មណ៍ និងចូលរួមកាន់តែច្រើននៅក្នុងមេរៀន ហើយបន្ទាប់មក ពួកគេកាន់តែសហការ និងមានវិន័យជាងមុន។<br><br>គ្រូបង្រៀនម្នាក់ដែលបានចូលរួមបានលើកឡើងថា "បទពិសោធន៍នេះមានភាពសប្បាយរីករាយ។ សិស្សនៅតែអាចយកចិត្តទុកដាក់រយៈពេលវែង ហើយយើងគ្រប់គ្រងបានល្អ ទោះបីជាមានសិស្សច្រើនក៏ដោយ"។ | ដើម្បីគ្រប់គ្រងក្រុមចម្រុះវប្បធម៌ សូមមើលឯកសារ ៥ នៅក្នុងកូនសៀវភៅទី៨៖ ការបង្រៀនបេតិកភណ្ឌរស់នៅក្នុងបរិយាកាសថ្នាក់រៀនពហុវប្បធម៌។ |

| សំណួររបស់គ្រូ | ចម្លើយ/ដំណោះស្រាយ | សម្រាប់ព័ត៌មានបន្ថែម សូមមើលកូនសៀវភៅផ្សេងទៀតនៅក្នុងសៀវភៅនេះ |
|---|---|---|
| សិស្សរបស់ខ្ញុំមកពីវប្បធម៌ផ្សេងៗពីគ្នា។ តើសមាសធាតុនៃបេតិកភណ្ឌវប្បធម៌អរូបីណាមួយដែលខ្ញុំគួរជ្រើសរើសសម្រាប់សកម្មភាពរបស់ខ្ញុំ? | ការបង្រៀនសិស្សដែលមានវប្បធម៌ផ្សេងៗពីគ្នាអាចជាការលំបាក ប៉ុន្តែមានមធ្យោបាយជាច្រើនដែលអ្នកអាចកែប្រែការលំបាកនេះឱ្យទៅជាឱកាសសម្បូរបែបសម្រាប់សិស្សរបស់អ្នក។ ឧទាហរណ៍ អ្នកអាច៖<br>• ជ្រើសរើសសមាសធាតុដែលអនុវត្តទូលំទូលាយដែលសិស្សទាំងអស់ ឬភាគច្រើនធ្លាប់ស្គាល់។<br>• រៀបចំទិវា ការតាំងពិព័រណ៍ និងពិធីបុណ្យវប្បធម៌នានាដែលនៅក្នុងពេលនោះ សិស្សអាចតាំងបង្ហាញ ឬពណ៌នាអំពីការអនុវត្តវប្បធម៌របស់ពួកគេ។<br>• លើកទឹកចិត្តសិស្សឱ្យរៀនសូត្រអំពីបេតិកភណ្ឌរស់របស់ពួកគេផ្ទាល់ និងផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមកជាមួយមិត្តរួមថ្នាក់។<br>• តាំងបង្ហាញបេតិកភណ្ឌរស់មកពីសហគមន៍ចម្រុះពេញមួយឆ្នាំសិក្សា។<br>ការដាក់បញ្ចូលបេតិកភណ្ឌរស់នៅក្នុងសាលា គឺជាឱកាសមួយដើម្បីលើកកម្ពស់ការឱ្យតម្លៃកាន់តែខ្លាំងចំពោះភាពចម្រុះគ្នានៃវប្បធម៌ និងការចេះអធ្យាស្រ័យគ្នាកាន់តែខ្លាំងសម្រាប់ភាពខុសៗគ្នា។<br>នៅប្រទេសនេប៉ាល់ គ្រូបង្រៀនម្នាក់បានបង្កើតមេរៀនដោយផ្អែកលើចម្រៀងប្រជាប្រិយពីសហគមន៍តាម៉ាំង។ បន្ទាប់ពីសិក្សាចម្រៀងនេះរួច សិស្សដែលមកពីសហគមន៍ផ្សេងៗគ្នាមួយចំនួនបានចាប់ផ្តើមបង្រៀនគ្នាទៅវិញទៅមកអំពីចម្រៀងប្រជាប្រិយពីសហគមន៍របស់ពួកគេរៀងៗខ្លួន។ | សូមមើលកូនសៀវភៅទី៨<br>ឯកសារ ៥៖ ការបង្រៀនបេតិកភណ្ឌរស់នៅក្នុងបរិយាកាសថ្នាក់រៀនពហុវប្បធម៌។ |

| សំណួររបស់គ្រូ | ចម្លើយ/ដំណោះស្រាយ | សម្រាប់ព័ត៌មានបន្ថែម សូមមើលកូនសៀវភៅផ្សេងទៀតនៅក្នុងសៀវភៅនេះ |
| --- | --- | --- |
| សហគមន៍នៅជុំវិញសាលាមានប្រពៃណីក្នុងស្រុកគួរឱ្យចាប់អារម្មណ៍មួយ ប៉ុន្តែបេតិកភណ្ឌរស់នេះអនុវត្តតែដោយបុរសប៉ុណ្ណោះ (ឬដោយស្ត្រីតែប៉ុណ្ណោះ)។ តើខ្ញុំអាចបង្កើតសកម្មភាពសិក្សាផ្សារភ្ជាប់នឹងបេតិកភណ្ឌរស់នេះបានទេ? | សមាសធាតុនៃបេតិកភណ្ឌរស់មួយចំនួន អនុវត្តតាមបែបប្រពៃណីដោយក្រុមមួយចំនួននៅក្នុងសហគមន៍ ដូចជាអនុវត្តដោយក្រុមយេនឌ័រមួយប៉ុណ្ណោះ។ ប៉ុន្តែទោះបីជាបេតិកភណ្ឌរស់មានជាប់ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងតួនាទីយេនឌ័រជាច់ដោយឡែកនៅក្នុងសហគមន៍ក៏ដោយ ក៏គ្រូគួរតែលើកទឹកចិត្តឱ្យសិស្សស្រី និងសិស្សប្រុសចូលរួមធ្វើការងារដោយសហការគ្នានៅក្នុងសកម្មភាពទាំងនោះ។ គ្រូគួរតែពន្យល់ថា ការអនុវត្ត បទដ្ឋាន និងគុណតម្លៃវប្បធម៌ អាចមានការប្រែប្រួលតាមពេលវេលា។ តាមរយៈការរុករកឱ្យឃើញនូវភាពលម្អៀងយេនឌ័រ ដែលអាចកើតមាន និងពង្រឹងតួនាទីយេនឌ័រវិជ្ជមាន ការបង្រៀនបេតិកភណ្ឌរស់អាចក្លាយជាវិធីសាស្ត្រមួយនៃការលើកកម្ពស់ការយល់ដឹងអំពីវិសមភាព និងលើកកម្ពស់សមភាពយេនឌ័រនៅក្នុងសាលា។<br><br>នៅប្រទេសនេប៉ាល់ សិស្សទាំងអស់ គឺស្ម័គ្រចិត្តសាកល្បងការអនុវត្តដែលបានរក្សាទុកជាប្រពៃណីសម្រាប់បុរស (ឧទាហរណ៍ របរជាងឈើ) ឬសម្រាប់ស្ត្រី (ឧទាហរណ៍ ការចម្អិនម្ហូបអាហារជាដើម)។ សិស្សបានធ្វើការងារជាមួយគ្នាដើម្បីសម្រេចគោលដៅដែលបានកំណត់នៅក្នុងមេរៀន ហើយការធ្វើបែបនេះបានជួយឱ្យពួកគេជម្នះភាពលម្អៀងដែលមាននៅក្នុងសហគមន៍។ | សូមមើលកូនសៀវភៅទី ២ ឯកសារ ៣៖ អត្ថប្រយោជន៍នៃការបង្រៀន និងការសិក្សាអំពីបេតិកភណ្ឌរស់។ |
| វិធីសាស្ត្រប្រាំមួយជំហាន មើលទៅហាក់ដូចជាត្រូវចំណាយពេលវេលាច្រើនណាស់។ តើខ្ញុំអាចអនុវត្តសកម្មភាពនេះជាមួយនឹងពេលវេលាមានកំណត់បានដោយរបៀបណា? | ទោះបីជាយើងណែនាំឱ្យអ្នកបំពេញជំហានទាំងអស់នេះក៏ដោយ ក៏អ្នកនៅតែអាចសម្របសម្រួលជំហានទាំងនោះទៅតាមតម្រូវការ កាលវិភាគ និងធនធានរបស់អ្នកតាមការគួរ។ ឧទាហរណ៍ អ្នកអាចរំលងកិច្ចការរៀបចំមួយចំនួន អ្នកអាចសហការជាមួយគ្រូបង្រៀនផ្សេងទៀត ឬដៃគូដើម្បីធ្វើការចែករំលែកកិច្ចការរៀបចំមួយចំនួន អ្នកអាចជំនួសសមាសធាតុដែលមានភស្តុភារកម្មកម្រិតធ្ងន់ (ឧទាហរណ៍ ការធ្វើដំណើរទស្សនកិច្ចសិក្សា) ដោយសមាសធាតុដែលអាចគ្រប់គ្រងបាន (ឧទាហរណ៍ អ្នកអាចអញ្ជើញវាគ្មិនមកសាលា ឬចាក់បញ្ចាំងទៅកាន់សិស្សនូវវីដេអូមានស្រាប់អំពីប្រធានបទនេះ) ឬអ្នកអាចបង្កើតវីដេអូរបស់បុគ្គលធនធាននៅក្នុងអំឡុងពេលនៃសកម្មភាព និងប្រើប្រាស់វីដេអូនេះ (ជំនួសឱ្យការទស្សនកិច្ចមួយទៀត) សម្រាប់មេរៀនបន្តបន្ទាប់។ | សូមមើលកូនសៀវភៅទី៤ ឯកសារ ៧៖ សន្លឹកកិច្ចការ។ |

| សំណួររបស់គ្រូ | ចម្លើយ/ដំណោះស្រាយ | សម្រាប់ព័ត៌មានបន្ថែម សូមមើលកូនសៀវភៅផ្សេងទៀតនៅក្នុងសៀវភៅនេះ |
|---|---|---|
| | សកម្មភាពទីមួយដែលអ្នកត្រូវបង្កើត អាចចំណាយពេលវេលាច្រើន ប៉ុន្តែអ្នកអាចប្រើកិច្ចតែងការបង្រៀនដដែលបានច្រើនដង។ នៅពេលដែលអ្នកស៊ាំទៅនឹងវិធីសាស្ត្រនេះ និងបានយល់ដឹងអំពីបេតិកភណ្ឌរស់ជុំវិញខ្លួនអ្នកច្បាស់ ឬបានប្រមូលធនធានមួយចំនួនរួចអស់ហើយ អ្នកលែងចំណាយពេលយូរ ក្នុងការបង្កើតសកម្មភាពទៀតហើយនៅពេលក្រោយមកទៀត។ នៅពេលដែលអ្នកបន្តប្រើប្រាស់វិធីសាស្ត្រនេះ អ្នកនឹងរៀនអំពីរបៀបសម្របសម្រួលដំណើរការរៀបចំឱ្យកាន់តែសាមញ្ញ។<br><br>ចំណែកនៅប្រទេសវៀតណាមវិញ គ្រូបង្រៀនមួយក្រុមបានធ្វើការសិក្សា និងចងក្រងជាឯកសារអំពីសមាសធាតុនៃបេតិកភណ្ឌរស់មួយចំនួន។ ពួកគាត់បានសម្ភាសន៍អ្នកអនុវត្ត ព្រមទាំងថតរូបនិងវីដេអូផងដែរ។ ពួកគាត់បានប្រែក្លាយឯកសារទាំងនេះទៅជាវីដេអូឃ្លីបខ្លីៗដែលពួកគាត់អាចប្រើប្រាស់បានម្តងហើយម្តងទៀតនៅក្នុងថ្នាក់រៀនរបស់ពួកគាត់ជារៀងរាល់ឆ្នាំ។ | |
| តើខ្ញុំអាចបង្រៀនដោយប្រើបេតិកភណ្ឌ រស់នៅពេលណាក៏បានក្នុងអំឡុងឆ្នាំសិក្សាមែនទេ? | សមាសធាតុនៃបេតិកភណ្ឌរស់អនុវត្តពេញមួយឆ្នាំ ដូច្នេះអ្នកអាចស្វែងរកបេតិកភណ្ឌមួយដែលសមស្របទៅនឹងកាលវិភាគកម្មវិធីសិក្សារបស់អ្នកបាន។<br><br>ចំពោះការអនុវត្តបេតិកភណ្ឌរស់ ដែលអនុវត្តនៅពេលណាមួយនៅក្នុងឆ្នាំ (ឧទាហរណ៍ បេតិកភណ្ឌរស់ដែលពាក់ព័ន្ធនឹងរដូវកាលកសិកម្ម ឬ វដ្តព្រះចន្ទ) ហើយមិនអាចបន្សីទៅតាមកាលវិភាគកម្មវិធីសិក្សារបស់អ្នកបាន អ្នកគួរតែពិចារណាដោយប្រើប្រាស់បេតិកភណ្ឌរស់ទាំងនោះនៅក្នុងសកម្មភាពក្រៅកម្មវិធីសិក្សា គម្រប់កម្មវិធីសាលា ឬគម្រោងពិសេសនានា។<br><br>នៅសាធារណរដ្ឋកូរ៉េ សិស្សបានសិក្សាអំពីពិធីបុណ្យ Yeondeunghoe (ពិធីបុណ្យបង្ហោះគោម)។ គ្រូអាចផ្សារភ្ជាប់សកម្មភាពទាំងនេះ បានយ៉ាងងាយស្រួលក្នុងពិធីបុណ្យទៅនឹងមុខវិជ្ជាសិក្សាសង្គម និងមុខវិជ្ជាសិល្បៈ។ ឧទាហរណ៍ សិស្សបានបង្កើតគោមផ្ទាល់ខ្លួននៅក្នុងថ្នាក់សិល្បៈ។ សកម្មភាពនានារៀបចំនៅក្នុងរយៈពេលជិតដែលពិធីបុណ្យនេះមកដល់ដើម្បីបង្កើតចំណាប់អារម្មណ៍របស់សិស្សនៅក្នុងប្រធានបទ និងនៅក្នុងពិធីបុណ្យផ្ទាល់។ | សូមមើលកូនសៀវភៅទី ៤ ជំហានទី ១ តើអ្នកអាចរៀបចំកាលវិភាគមេរៀនដោយប្រើប្រាស់បេតិកភណ្ឌរស់ដោយរបៀបណា និងនៅពេលណា? |

| សំណួររបស់គ្រូ | ចម្លើយ/ដំណោះស្រាយ | សម្រាប់ព័ត៌មានបន្ថែម សូមមើលកូនសៀវភៅផ្សេងទៀតនៅក្នុងសៀវភៅនេះ |
|---|---|---|
| តើធ្វើដូចម្តេចទើបខ្ញុំអាចដឹងថា មធ្យោបាយបង្ហាញព័ត៌មានអំពីបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងមេរៀន ឬឯកសារ អាចទទួលយកបានដោយសហគមន៍? | នៅពេលដែលអ្នកឱ្យប្រជាជនក្នុងសហគមន៍ចូលរួមនៅក្នុងការរៀបចំសកម្មភាពរបស់អ្នក ហើយនៅក្នុងអំឡុងដំណើរការបង្រៀន អ្នកអាចទទួលបានមតិត្រលប់ពីពួកគាត់ ដើម្បីធានាថា សកម្មភាពរបស់អ្នកគឺអាចទទួលយកបាន។<br><br>អ្នកស្រី Dharmakala Neupane គ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យា បានទៅរកក្រុមគ្រួសាររបស់សិស្ស ដើម្បីរៀនអំពីរបៀបធ្វើ *Khapse* ដែលជាអាហារសម្រន់ក្នុងមូលដ្ឋាន ដែលគាត់ផ្តែកមេរៀនរបស់គាត់ទៅលើអាហារសម្រន់នេះ។ | សូមមើលកូនសៀវភៅទី ៤ ជំហានទី ១ តើអ្នកណាអាចជាដៃគូរបស់អ្នកនៅក្នុងសាលា សហគមន៍ និងលើសពីនេះទៀត?<br><br>ហើយសូមមើលរឿងរ៉ាវរបស់គ្រូបង្រៀន៖ ពង្រឹងការអប់រំ និងការគាំពារបេតិកភណ្ឌរស់តាមរយៈការចូលរួមរបស់សហគមន៍នៅក្នុងថ្នាក់រៀន (ប្រទេសនេប៉ាល់) |
| តើធ្វើដូចម្តេចទើបខ្ញុំដឹងថា គោលបំណងមេរៀន សកម្មភាព និងឯកសារគរុកោសល្យ ជាពិសេសឯកសារផ្សារភ្ជាប់ទៅនឹងបេតិកភណ្ឌវប្បធម៌អរូបីនេះសមស្របសម្រាប់កម្រិត ចំណាប់អារម្មណ៍ និងតម្រូវការរបស់សិស្សខ្ញុំ? | ការឱ្យសិស្សចូលរួមនៅក្នុងការរៀបចំ និងការអនុវត្តមេរៀន គឺមានប្រយោជន៍ណាស់។ តាមរយៈវិធីនេះ អ្នកអាចធ្វើតេស្តឯកសារគរុកោសល្យនៅមុនពេលមេរៀន ហើយអ្នកក៏អាចបង្កើតសកម្មភាពដែលសម្របទៅតាមក្រុម និងកម្រិតខុសៗគ្នាបានផងដែរ។<br><br>ទាំងនៅក្នុងប្រទេសនេប៉ាល់ និងប្រទេសថៃ សិស្សគឺបានចូលរួមនៅក្នុងការកំណត់រកព័ត៌មានអំពីសមាសធាតុនៃបេតិកភណ្ឌរស់។ ពួកគេបានទទួលការណែនាំពីគ្រូរបស់ពួកគេ ប៉ុន្តែពួកគេបានផ្តោតលើប្រធានបទ និងព័ត៌មានដែលពួកគាត់ចាប់អារម្មណ៍ជាពិសេស។ បន្ទាប់មក ប្រធានបទទាំងនេះគឺត្រូវបានគូសបញ្ជាក់នៅក្នុងមេរៀនបន្តបន្ទាប់ ដើម្បីធានាថាសិស្សនឹងចាប់អារម្មណ៍ ព្រមទាំងចូលរួមនៅក្នុងសកម្មភាព។ | |

| សំណួររបស់គ្រូ | ចម្លើយ/ដំណោះស្រាយ | សម្រាប់ព័ត៌មានបន្ថែម សូមមើលកូនសៀវភៅផ្សេងទៀតនៅក្នុងសៀវភៅនេះ |
| --- | --- | --- |
| តើធ្វើដូចម្ដេចទើបខ្ញុំដឹងថាសកម្មភាពរបស់ខ្ញុំចូលរួមចំណែកដល់ការលើកកម្ពស់ការយល់ដឹង និងការគាំពារបេតិកភណ្ឌវប្បធម៌អរូបី? | ក្រៅពីគោលដៅ និងគោលបំណងមានស្រាប់សម្រាប់មេរៀនរបស់អ្នក អ្នកអាចរួមបញ្ចូលគោលដៅ និងគោលបំណងបន្ថែមអំពីបេតិកភណ្ឌរស់ដែរ។ អ្នកក៏អាចដាក់បញ្ចូលសំណួរវាយតម្លៃពាក់ព័ន្ធនឹងការលើកកម្ពស់ការយល់ដឹងអំពីបេតិកភណ្ឌវប្បធម៌អរូបី (ឧទាហរណ៍ "ការពណ៌នាអំពីបេតិកភណ្ឌវប្បធម៌អរូបីដែលបានរៀននៅក្នុងអំឡុងពេលមេរៀន" ឬ "ពន្យល់អំពីមូលហេតុដែលបេតិកភណ្ឌវប្បធម៌អរូបីនេះមានសារៈសំខាន់សម្រាប់សហគមន៍របស់អ្នក"។<br><br>នៅចុងបញ្ចប់នៃមេរៀននីមួយៗ គ្រូបង្រៀនដែលជាជនជាតិគៀជីស្ថាន ពិភាក្សាជាមួយសិស្សរបស់ពួកគាត់អំពីអ្វីដែលពួកគេបានរៀនអំពីបេតិកភណ្ឌវប្បធម៌អរូបី។ នៅប្រទេសនេប៉ាល់ គ្រូបង្រៀនប្រើប្រាស់តារាង ដឹង-ចង់-រៀន (KWL) និង 'លិខិតបញ្ជាក់ (Exit Pass)' ដើម្បីវាយតម្លៃថាតើសិស្សបានទទួលការយល់ដឹងបន្ថែមអំពីបេតិកភណ្ឌវប្បធម៌អរូបី និងអំពីការគាំពារបេតិកភណ្ឌវប្បធម៌អរូបីឬទេ។ | សូមមើលកូនសៀវភៅទី៤ ជំហានទី ៤៖ កែសម្រួលឡើងវិញ ឬកំណត់គោលដៅមេរៀន និងគោលបំណងមេរៀន។<br><br>ហើយសូមមើលជំហានទី ៦៖ វាយតម្លៃលទ្ធផល។ |

# ឯកសារទី ៧៖ សន្លឹកកិច្ចការ៖ បង្កើតកិច្ចតែងការបង្រៀនដែលផ្សារភ្ជាប់បេតិកភណ្ឌរស់ជាមួយនឹងសកម្មភាពសាលា

**ការពិចារណាបឋមរបស់ខ្ញុំ៖**

- តើសកម្មភាពអ្វីខ្លះនៅក្នុងសាលារបស់ខ្ញុំដែលបានផ្សារភ្ជាប់ទៅនឹងបេតិកភណ្ឌរស់? (ឧទាហរណ៍ នៅក្នុងមុខវិជ្ជានៃកម្មវិធីសិក្សា សកម្មភាពក្រៅកម្មវិធីសិក្សា ការប្រារព្ធពិធីពិសេស។ល។)
- តើបេតិកភណ្ឌរស់ទាំងនោះមានអ្វីខ្លះ?

សូមបំពេញតារាងនេះ៖

| សកម្មភាព | បេតិកភណ្ឌរស់ |
|---|---|
| | |
| | |
| | |
| | |
| | |

- តើការបង្រៀនបេតិកភណ្ឌរស់ក្នុងថ្នាក់រៀនមានអត្ថប្រយោជន៍អ្វីខ្លះ ?

## ជំហានទី១៖ យល់ដឹងអំពីបរិបទរបស់អ្នក

### ការពិចារណារបស់ខ្ញុំ៖

ឧទាហរណ៍នៃសមាសធាតុបេតិកភណ្ឌរស់ដែលខ្ញុំអាចស្វែងរកបាននៅក្នុមូលដ្ឋានរបស់ ខ្ញុំមាន៖

*(បេតិកភណ្ឌនេះអាចជា៖ ប្រពៃណីនៃការនិយាយស្តី ការសម្តែងសិល្បៈ ពិធីសាសនា ការប្រារព្ធពិធី ចំណេះដឹងអំពីធម្មជាតិ ចំណេះដឹងអំពីសិប្បកម្ម កីឡា និងល្បែងប្រពៃណី។ល។)*

### សកម្មភាពនៅក្នុងសាលារបស់ខ្ញុំដែលស័ក្តិសមបំផុតក្នុងការផ្សារភ្ជាប់ជាមួយនឹងបេតិកភណ្ឌរស់៖

- ☐ មេរៀន
- ☐ សកម្មភាពក្រៅកម្មវិធីសិក្សា (ឧទាហរណ៍ ក្លឹបសាលា)
- ☐ គម្រោងសាលា ឬគម្រោងក្នុងថ្នាក់
- ☐ កម្មវិធីពិសេសដែលរៀបចំនៅសាលា
- ☐ ផ្សេងៗ (សូមបញ្ជាក់)

### ដៃគូសក្តានុពលរបស់ខ្ញុំ៖

## ជំហានទី២៖ ផ្សារភ្ជាប់ប្រធានបទសាលាជាមួយបេតិកភណ្ឌរស់

**ការពិចារណារបស់ខ្ញុំ៖**

---

---

---

| បេតិកភណ្ឌរស់ | សកម្មភាពសាលា (មេរៀន សកម្មភាពក្រៅកម្មវិធីសិក្សា កម្មវិធី។ល។) |
|---|---|
| ទិដ្ឋភាពជាក់លាក់នៃបេតិកភណ្ឌវប្បធម៌អរូបី ដែលអាចប្រើប្រាស់បាននៅក្នុងមេរៀន (អាចពិនិត្យមើលឡើងវិញបន្ទាប់ពីជំហានទី ៣) | កម្មវិធីសិក្សា ឬឯកសារយោងមេរៀន (ប្រសិនបើពាក់ព័ន្ធ)៖ |

ផ្សារភ្ជាប់ទៅនឹងកម្មវិធីផ្សេងៗ *(ប្រសិនបើពាក់ព័ន្ធ ឧទាហរណ៍ ការអប់រំពលរដ្ឋសកល (GCED) ការអប់រំសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព (ESD) ការសិក្សាសង្គម និងអារម្មណ៍ (SEL)។ល។)*

## ជំហានទី ៣៖ សិក្សាបន្ថែមអំពីបេតិកភណ្ឌវប្បធម៌អរូបី

### លទ្ធផលរកឃើញរបស់ខ្ញុំ៖

ស្វែងរកព័ត៌មានអំពីបេតិកភណ្ឌរស់ដែលអ្នកបានរៀបរាប់នៅក្នុងជំហានទី ២។ ព័ត៌មាននេះអាចដកស្រង់ចេញពីបទពិសោធន៍ផ្ទាល់របស់អ្នកពីឯកសារបោះពុម្ព ឯកសារយោងវីដេអូ ដែលអ្នករកឃើញនៅក្នុងការសម្ភាសន៍ (សូមចងចាំ៖ ទទួលការយល់ព្រមពីអ្នកផ្តល់សម្ភាសន៍ជាមុនសិនមុនធ្វើការសម្ភាសន៍) ។ល។

កត់ត្រាព័ត៌មានសំខាន់ៗដែលអ្នកបានរកឃើញ៖

បញ្ជីសំណួរនៅក្នុងឯកសារ ៤ អាចប្រើសម្រាប់ការជំរុញទឹកចិត្តបាន។ អ្នកអាចអនុវត្តតាមបញ្ជីទាំងមូល ឬគ្រាន់តែជ្រើសរើសសំណួរមួយចំនួនដែលអ្នកគិតថាពាក់ព័ន្ធខ្លាំងបំផុត ឬបង្កើតសំណួរបន្ថែមដោយខ្លួនឯង។

## ជំហានទី ៤៖ បង្កើតកិច្ចតែងការបង្រៀនរបស់អ្នក

### គោលដៅនៃមេរៀន ឬសកម្មភាព៖

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

### គោលបំណងមេរៀន៖

*បំពេញក្របខ័ណ្ឌចំណេះដឹង / ជំនាញ / ឥរិយាបថ ដូចខាងក្រោម ឬប្រើប្រាស់ទម្រង់ស្តង់ដារ ដែលបង្កើតឡើងដោយសាលារបស់អ្នក ឬប្រើប្រាស់នៅក្នុងប្រទេសរបស់អ្នក។*

| | |
|---|---|
| **វិជ្ជាសម្បទា** | |
| **បំណិនសម្បទា** | |
| **ចរិយាសម្បទា** | |

### ការពិចារណារបស់ខ្ញុំ៖

- ☐ តើគោលបំណងមេរៀនទាំងនេះរួមចំណែកដល់ការលើកកម្ពស់ការយល់ដឹងអំពីបេតិកភណ្ឌរស់ (បន្ថែមពីលើលទ្ធផលសិក្សារបស់មុខវិជ្ជា) ដែរឬទេ?
- ☐ តើគោលបំណងមេរៀនទាំងនេះបានផ្សារភ្ជាប់ទៅនឹងកម្មវិធីសិក្សាផ្អែកលើគុណតម្លៃផ្សេងៗ ដែលបានកំណត់ពីមុនដែរឬទេ (ឧទាហរណ៍ ពលរដ្ឋវិទ្យាសកល (GCED) ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (ESD) ការសិក្សាសង្គម និងអារម្មណ៍ (SEL) ។ល។)?

**សកម្មភាព** ( **សមាសធាតុនៃមេរៀន** )

ចូរសរសេររៀបរាប់នៅខាងក្រោមនេះអំពីសកម្មភាពដែលនឹងត្រូវអនុវត្តនៅក្នុងអំឡុងពេលមេរៀន ឬសកម្មភាពក្រៅកម្មវិធីសិក្សា។

ម្យ៉ាងវិញទៀត អ្នកអាចបំពេញទម្រង់កិច្ចតែងការបង្រៀនស្តង់ដារដែលប្រើនៅក្នុងសាលារបស់អ្នកបាន។

ប្រសិនបើអាច សូមបញ្ជាក់ចំណុចដូចខាងក្រោម៖

- តើអ្នកណាជាអ្នកនឹងដឹកនាំសកម្មភាព ? ( ឧទាហរណ៍ អ្នកខ្លួនឯង សិស្ស បុគ្គលធនធានខាងក្រៅ ។ល។ )
- តើវិធីសាស្ត្រគរុកោសល្យ និងធនធានអ្វីខ្លះដែលអ្នកគ្រោងប្រើប្រាស់ ?
- នៅពេលដែលសកម្មភាពគឺពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបេតិកភណ្ឌវប្បធម៌អរូបី តើព័ត៌មានអ្វីខ្លះដែលអ្នកនឹងចែករំលែក ឬពិភាក្សា ? តើផ្នែកណាខ្លះនៃការអនុវត្តដែលនឹងត្រូវយកមកបង្ហាញ ?

## ធនធានត្រូវការសម្រាប់សកម្មភាព

| | តើខ្ញុំត្រូវការអ្វីខ្លះ ? *សម្រាប់សិស្ស សម្រាប់សិស្សម្នាក់ៗ ក្រុមសិស្ស* | តើខ្ញុំមានធនធាននោះហើយឬនៅ ? តើខ្ញុំអាចយកធនធាននោះពីណា ? |
|---|---|---|
| **ឯកសារ និងសម្ភារៈសិក្សា** (សន្លឹកកិច្ចការ និងឯកសារសម្រាប់ចែកឱ្យហ្វឹត សម្ភារៈហត្ថកម្មវត្ថុពាក់ព័ន្ធនឹងការអនុវត្តបេតិកភណ្ឌវប្បធម៌អរូបី ។ល។) | | |
| **ឯកសារយោង** (ឯកសារបោះពុម្ពផ្សាយ រូបថត វីដេអូ បទបង្ហាញ -ល-) | | |
| **ភស្តុភារ និងបរិក្ខារ** (បរិក្ខារវីដេអូ មធ្យោបាយដឹកជញ្ជូន បន្ទប់ ឬទីធ្លា -ល-) | | |
| **បុគ្គលធនធាន** (ស្ថាប័នដៃគូ ប្រជាជនក្នុងសហគមន៍ មិត្តរួមការងារ -ល-) | | |
| **មូលនិធិ** | | |
| **នីតិវិធីរដ្ឋបាល និងការអនុញ្ញាត** | | |

សម្រាប់សកម្មភាពនីមួយៗ ចូរសួរខ្លួនឯង៖

- □ តើសកម្មភាពនេះមានភាពប្រាកដប្រជា និងអាចអនុវត្តបានដែរឬទេ?
- □ តើការផ្សារភ្ជាប់ទៅនឹងបេតិកភណ្ឌរស់ធ្វើឱ្យសកម្មភាព/មេរៀនរបស់ខ្ញុំកាន់តែសប្បាយ និងគួរឱ្យចាប់អារម្មណ៍ជាងមុនដែរឬទេ?
- □ តើសកម្មភាពនេះលើកកម្ពស់ការគោរព និងការឱ្យតម្លៃសម្រាប់ភាពចម្រុះនៃវប្បធម៌ឬទេ? តើសកម្មភាពនេះកាត់បន្ថយ ឬពង្រឹងការលម្អៀង? (ឧទាហរណ៍ ទម្រង់នានានៃការរើសអើងទៅលើភេទ អាយុ វប្បធម៌ ឬក្រុមសង្គម។)

## ជំហានទី ៥៖ ឯកសារ និងការចែករំលែក

តើវិធីសាស្ត្រអ្វីខ្លះដែលមានភាពងាយស្រួលជាងគេសម្រាប់ការប្លុកសរុបព័ត៌មានដែលខ្ញុំបានប្រមូល និងការពិចារណារបស់ខ្ញុំទៅលើមេរៀន ឬសកម្មភាពក្រៅកម្មវិធីសិក្សា?

តើខ្ញុំអាចចែករំលែកកិច្ចតែងការបង្រៀន និងបទពិសោធន៍របស់ខ្ញុំដូចម្តេច និងនៅកន្លែងណា?

## ជំហានទី ៦៖ បង្កើតយន្តការវាយតម្លៃ

### វិធីសាស្ត្រក្នុងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស៖

### ការពិចារណារបស់ខ្ញុំ៖

- តើយន្តការវាយតម្លៃដែលខ្ញុំបានកំណត់ខាងលើនឹងជួយខ្ញុំឆ្លើយនឹងសំណួរទាំងនេះដែរឬទេ ?
  - តើសិស្សយល់អំពីព័ត៌មានដែលបានបង្ហាញអំពីបេតិកភណ្ឌរស់ដែរឬទេ ?
  - តើសិស្សកាន់តែយល់ដឹងអំពីបេតិកភណ្ឌវប្បធម៌អរូបីដែរឬទេ ?
  - តើសកម្មភាពសាលា គោរពដល់គុណតម្លៃនៃការអនុវត្តបេតិកភណ្ឌវប្បធម៌អរូបីឬទេ ?

### ការពិចារណាចុងក្រោយ

វិធីសាស្ត្រគរុកោសល្យផ្សេងៗគ្នា ដូចជាពលរដ្ឋវិទ្យាសកល និងការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព អាចបន្ថែមគុណតម្លៃទៅលើមេរៀន និងសកម្មភាពក្រៅកម្មវិធីសិក្សា។

- តើវិធីសាស្ត្រណានៅក្នុងចំណោមវិធីសាស្ត្រទាំងនេះដែលអាចប្រើនៅក្នុងសាលារបស់អ្នកបាន ?
- តើវិធីសាស្ត្រទាំងនេះមានឥទ្ធិពលចំពោះកិច្ចតែងការបង្រៀនរបស់អ្នកដូចម្ដេចខ្លះ ?

ឥឡូវនេះ អ្នកបានអនុវត្តគ្រប់ជំហានទាំងអស់រួចហើយ អ្នកអាចមើលកំណត់សម្គាល់ឡើងវិញ និងបញ្ចប់កិច្ចតែងការបង្រៀនជាស្ថាពររបស់អ្នក។
សូមបង្រៀនដោយភាពសប្បាយរីករាយ !



**ការបញ្ចូលបេតិកភណ្ឌរស់**

ទៅក្នុងការសិក្សានៅអាស៊ីប៉ាស៊ីហ្វិក

សៀវភៅណែនាំ

កូនសៀវភៅ

# 9

# សាច់រឿងរបស់គ្រូបង្រៀន



**សៀវភៅនេះ** មានបំណងជួយគាំទ្រគ្រូបង្រៀន អ្នកគ្រប់គ្រងក្នុងវិស័យអប់រំ និងសហគមន៍ ក្នុងការដាក់បញ្ចូលបេតិកភណ្ឌក្នុងស្រុក ទៅក្នុងសកម្មភាពសិក្សា ឲ្យកាន់តែមានភាពប្រទាក់ក្រឡាគ្នា និងមានការចូលរួមកាន់តែច្រើនពីសំណាក់សិស្សានុសិស្ស និងការពារបេតិកភណ្ឌវប្បធម៌។

សៀវភៅនេះ មានកូនសៀវភៅចំនួនប្រាំបួន៖

- កូនសៀវភៅ 1 — តើបេតិកភណ្ឌរស់ជាអ្វី ?
- កូនសៀវភៅ 2 — ហេតុអ្វីត្រូវបង្រៀនជាមួយបេតិកភណ្ឌរស់ ?
- កូនសៀវភៅ 3 — ការរៀបចំឱ្យត្រូវគ្នាជាមួយអាទិភាពអប់រំ
- កូនសៀវភៅ 4 — វិធីសាស្ត្រប្រាំមួយជំហានសម្រាប់ជាមគ្គុទេសក៍ដល់គ្រូបង្រៀន
- កូនសៀវភៅ 5 — តួនាទីរបស់ឪពុកម្ដាយ អាណាព្យាបាល និងសមាជិកសហគមន៍
- កូនសៀវភៅ 6 — តួនាទីរបស់ថ្នាក់គ្រប់គ្រងសាលា
- កូនសៀវភៅ 7 — តួនាទីរបស់អ្នករៀបចំគោលនយោបាយ
- កូនសៀវភៅ 8 — ឯកសារ និងធនធាន
- ▶ កូនសៀវភៅ 9 — **សាច់រឿងរបស់គ្រូបង្រៀន**

កូនសៀវភៅ

9

# សាច់រឿងរបស់គ្រូបង្រៀន

## ការបង្កើនការអប់រំ និងការគាំពារបេតិកភណ្ឌរស់តាមរយៈ ការចូលរួមរបស់សហគមន៍នៅក្នុងថ្នាក់រៀន (ប្រទេសនេប៉ាល់)


**សេចក្ដីសង្ខេប**

*នៅប្រទេសនេប៉ាល់ គ្រូបង្រៀនបានសហការគ្នាយ៉ាងជិតស្និទ្ធជាមួយប្រជាជននៅក្នុងសហគមន៍ ដើម្បីបង្កើតមេរៀនដែលដាក់បញ្ចូលបេតិកភណ្ឌរស់នៅក្នុងមូលដ្ឋាន។ អ្នកចូលរួមចាប់ពីកម្រិតព្រឹទ្ធាចារ្យរហូតដល់ស្ត្រីមេផ្ទះ ប្រជាជនក្នុងមូលដ្ឋានបានចែករំលែកចំណេះដឹងដើម្បីការពារការអនុវត្តរបស់ពួកគាត់។ បន្ថែមពីលើការបង្កើតមេរៀនដែលមានលក្ខណៈចូលរួមពិតប្រាកដ ការសហការនេះក៏បានជួយបំបែករបាំងរាំងសង្គមមួយចំនួនផងដែរ។*


**ប្រទេស៖** នេប៉ាល់ (Kirtipur និង Budhanilkantha)

**មុខវិជ្ជាសិក្សា / ប្រធានបទ / ECA៖** ភាសាអង់គ្លេស គណិតវិទ្យា

**បេតិកភណ្ឌវប្បធម៌អរូបី៖** ពិធីបុណ្យក្នុងមូលដ្ឋាន

**កម្រិតថ្នាក់ និងអាយុសិស្ស៖** ថ្នាក់ទី ៨ អាយុ ១៤-១៦ ឆ្នាំ

**សាលា៖** អនុវិទ្យាល័យ Janasewa និងអនុវិទ្យាល័យ Ganesh

នៅប្រទេសនេប៉ាល់ សាលាចំនួនបួន សាលាពីរនៅក្រុង Budhanilkantha និងសាលាពីរនៅក្រុង Kirtipur បានធ្វើតេស្តវិធីសាស្ត្រគរុកោសល្យថ្មីមួយ៖ បង្រៀនមេរៀនមួយចំនួនរបស់ពួកគាត់ដោយប្រើបេតិកភណ្ឌវប្បធម៌អរូបី (ICH)។ សាលានីមួយៗបានកំណត់អត្តសញ្ញាណក្រុមគ្រូបង្រៀនមុខវិជ្ជាចំនួនបីនាក់ រដ្ឋបាលសាលាម្នាក់ និងប្រជាជនម្នាក់នៅក្នុងសហគមន៍។ បន្ទាប់ពីបានធ្វើការពិគ្រោះយោបល់ជាមួយប្រជាជននៅក្នុងសហគមន៍ គ្រូបង្រៀនជ្រើសរើសការអនុវត្តវប្បធម៌ ដែលពួកគាត់អាចដាក់បញ្ចូលទៅក្នុងមុខវិជ្ជារបស់ពួកគាត់បាន។ គ្រូបង្រៀនបានឱ្យសិស្សធ្វើការពិភាក្សាជាមួយសមាជិកគ្រួសាររបស់ពួកគេ និងប្រមូលព័ត៌មានអំពីការអនុវត្តបេតិកភណ្ឌរស់ផ្សេងៗនៅក្នុងផ្ទះរបស់ពួកគេ។ បន្ទាប់មក គ្រូបង្រៀនបានបូកសរុបព័ត៌មាននេះជាមួយសិស្ស និងបានធ្វើបញ្ជីសាពើភ័ណ្ឌបេតិកភណ្ឌវប្បធម៌អរូបី ដើម្បីរកមើលឱកាសជំរុញទឹកចិត្ត។

បន្ទាប់ពីបានបញ្ជីសារពើភ័ណ្ឌរួច គ្រូបង្រៀនជ្រើសរើសបេតិកភណ្ឌវប្បធម៌អរូបីមួយ ដែលសមស្របជាងគេសម្រាប់បង្រៀនមុខវិជ្ជារបស់ពួកគាត់។ ដើម្បីស្រាវជ្រាវបន្ថែមអំពីបេតិកភណ្ឌវប្បធម៌អរូបី និងជួយបង្កើតមេរៀន គ្រូបង្រៀនបានទាក់ទងជាមួយប្រជាជនមកពីសហគមន៍។ កិច្ចសហការជិតស្និទ្ធរវាងគ្រូបង្រៀន និងប្រជាជននៅក្នុងសហគមន៍ បានជួយយ៉ាងធំធេងដល់ការបង្កើតមេរៀន ដែលមានភាពច្នៃប្រឌិត។

ពេលខ្លះ ប្រជាជនក្នុងសហគមន៍ គឺជាបុគ្គលល្បី និងទទួលបានការគោរពជាខ្លាំងចំពោះចំណេះដឹង និងជំនាញវប្បធម៌របស់ពួកគាត់។ នៅពេលខ្លះទៀត ពួកគាត់មិនត្រូវបានគេស្គាល់ថាជាអ្នកជំនាញនោះទេ ប៉ុន្តែជាអ្នកដែលអនុវត្តបេតិកភណ្ឌរស់ជាប្រចាំថ្ងៃទៅវិញ។ ប្រជាជនទាំងពីរប្រភេទនេះជាផ្នែកនៃសហគមន៍ ដែលបានស្វប់ស្វែងយ៉ាងជ្រាលជ្រៅទៅលើគុណតម្លៃនៃបេតិកភណ្ឌរបស់ពួកគេ និងជឿថាមានប្រយោជន៍ណាស់ក្នុងការចែករំលែកបេតិកភណ្ឌនេះជាមួយប្រជាជនជំនាន់ក្រោយ។ ពួកគាត់បានផ្តល់ព័ត៌មានអំពីបេតិកភណ្ឌវប្បធម៌អរូបី កន្លែងដែលត្រូវទៅយកឯកសារដែលត្រូវការចាំបាច់ និងថែមទាំងជួយជាថវិកាថែមទៀតផង។ ពួកគាត់បានបង្កើតគំនិតសម្រាប់មេរៀន និងវិធីសាស្ត្រក្នុងការផ្សារភ្ជាប់បេតិកភណ្ឌវប្បធម៌អរូបីជាមួយមុខវិជ្ជា ព្រមទាំង គាំទ្រដល់ដំណើរការនៃការស្វែងរកការយល់ព្រមរបស់សហគមន៍។

គ្រូបង្រៀនដាក់បញ្ចូលចំណេះដឹងដ៏មានតម្លៃនេះនៅក្នុងកិច្ចតែងការបង្រៀន និងឯកសារនានា។ ពេលខ្លះ ពួកគាត់អញ្ជើញអ្នកអនុវត្តទាំងនេះមកក្នុងថ្នាក់រៀនជាបុគ្គលធនធាន និងថែមទាំងជាគ្រូបង្រៀនទៀតផង។

## អញ្ជើញអ្នកប្រតិបត្តិបេតិកភណ្ឌរស់មកក្នុងថ្នាក់រៀន

អ្នកស្រី Pabitra Shakya គឺជាគ្រូបង្រៀនភាសាអង់គ្លេសមកពីអនុវិទ្យាល័យ Janasewa នៅក្រុង Kirtipur។ អនុវិទ្យាល័យ Janasewa គឺមានទីតាំងស្ថិតនៅតំបន់ដែលរស់នៅភាគច្រើនដោយសហគមន៍ Newa ប៉ុន្តែសិស្សគឺមកពីសហគមន៍ចម្រុះមិនមែន Newa។ គាត់ជឿថា ការពន្យល់អំពីកម្មវិធី និងការអនុវត្តវប្បធម៌ Newa មួយចំនួននៅក្នុងថ្នាក់របស់គាត់នឹងជួយសិស្សឱ្យយល់ និងឱ្យតម្លៃដល់បរិស្ថានរបស់ពួកគេកាន់តែល្អប្រសើរ។

គាត់បានបង្កើតមេរៀនអំពីពិធីបុណ្យ *saparu* ឬហៅម្យ៉ាងទៀតថា *Gaijatra*។ កម្មវិធីនេះ គឺត្រូវបានប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំនៅ Kathmandu Valley ដោយសហគមន៍ Newa ដើម្បីឧទ្ទិសបូជា ដល់វិញ្ញាណក្ខន្ធរបស់បុព្វការីជន ដែលបានចែកឋាននៅក្នុងឆ្នាំតែមួយ។ ប្រជាជន Newa ជឿថា ច្រកទ្វារនៃឋានសួគ៌សម្រាប់អ្នកដែលបានចែកឋានគឺបើកនៅថ្ងៃនោះ។ ក្បួនដង្ហែរនៃពិធីបុណ្យ *Gaijatra* នឹងជួយឱ្យមនុស្សជាទីស្រឡាញ់របស់ពួកគាត់



បានទៅដល់ច្រកទ្វារឋានសួគ៌ ប្រសិនបើពួកគេដង្ហែរជុំវិញទីក្រុងដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធរបស់បុព្វបុរសរបស់ពួកគេដោយដើរជើងទទេ។ ប្រជាជនដែលមានសមាជិកណាម្នាក់ចែកឋានទៅហើយនៅឆ្នាំនោះ ឱ្យសមាជិកក្មេងជាងគេនៅក្នុងគ្រួសារស្លៀកពាក់សម្លៀកបំពាក់ដូចជាសត្វគោ និងពាក់ក្បាំងមុខគោផងដែរ។
បន្ទាប់ពីសាកសួរបុគ្គលធនធាននៅក្នុងពិធីបុណ្យ *Gaijatra* អ្នកស្រី Shakya បានអញ្ជើញលោក Rupendra Maharjan ឱ្យធ្វើការងារជាមួយគាត់សម្រាប់មេរៀននេះ។ លោក Maharjan ផលិតត្រា ( blockprint ) និងរបាំងមុខ *sakhwa-saparu* សម្រាប់អ្នកដែលចូលរួមពិធីបុណ្យ។ គាត់បានស្នងជំនាញនេះពីគ្រួសាររបស់គាត់ និងពាំនាំមកនូវចំណេះដឹងជាច្រើនជំនាន់មកចែករំលែកជាមួយ សិស្ស។ ឪពុករបស់គាត់គឺជាផ្នែកនៃស្ថាប័នសហគមន៍ Guthi។ នៅឆ្នាំ២០២០ នៅពេលដែលប្រជាជនកាត់បន្ថយការជួបជុំដោយសារតែការរីករាលដាលជាសកលជំងឺកូវីដ-១៩ គាត់គឺជាបុគ្គលម្នាក់ដែលប្រកាន់ជំហរប្រារព្ធពិធីបុណ្យ *saparu* នៅ Panga ដែលជាទីក្រុងមួយនៅក្នុងក្រុង Kirtipur។

លោក Maharjan មិនត្រឹមតែត្រូវបានគេស្គាល់ថាជាអ្នកប្រតិបត្តិបេតិកភណ្ឌវប្បធម៌អរូបីប៉ុណ្ណោះនោះទេ តែគាត់ថែមទាំងជាគ្រូបណ្តុះបណ្តាលនៅក្នុងអាជីពវិជ្ជាជីវៈរបស់គាត់ផងដែរ។ គាត់បានចូលរួមនៅពេញមេរៀនរយៈពេល ៣ ពេលអំពី *saparu* និងបានផ្តល់ការបង្រៀនខ្លីៗដើម្បីពន្យល់អំពីរបៀបប្រារព្ធពិធីបុណ្យ *saparu*។ សិស្សអាចពិភាក្សាជាមួយគាត់បាន និងអាចពិភាក្សានៅក្នុងចំណោមសិស្សក៏បាន។ ពួកគេបានធ្វើការស្រាវជ្រាវអំពីពិធីបុណ្យ *Gaijatra* និងបានសរសេរសំណេរមួយច្បាប់ជាភាសាអង់គ្លេស ដែលពួកគេធ្វើបទបង្ហាញដល់សិស្សនៅក្នុងថ្នាក់។ បន្ទាប់មកលោក Maharjan បានពន្យល់អំពីបច្ចេកទេសពាក់ព័ន្ធនឹងហត្ថកម្មនោះ។ នៅក្រោមការគ្រប់គ្រងរបស់លោក សិស្សបានទទួលឱកាសក្នុងការផាត់ពណ៌ និងបង់ផ្លិតក្រដាសព្រមទាំងផលិតរបាំងមុខរូបគោផងដែរ។ ការងារនេះទាមទារឱ្យមានការអត់ធ្មត់ និងភាពសុក្រឹតណាស់។ សិស្សកាន់តែយល់ដឹងបន្ថែមអំពីដំណើរការសិល្បៈតាមរយៈការបង្កើតស្នាដៃសិល្បៈផ្ទាល់ខ្លួន។ ពួកគេក៏បានដឹងច្រើន អំពីគុណតម្លៃនៃការបង្កើតអ្វីមួយសម្រាប់មនុស្សជាទីស្រឡាញ់ដែលបានចែកឋានទៅផងដែរ។ លោក Pabitra Shakya និងរូបលោកបានបង្កើតមេរៀនមួយដែលវិជ្ជាជីវៈ និងធនធានរបស់ Maharjan អនុញ្ញាតឱ្យមានការរួមបញ្ចូលគ្នាយ៉ាងល្អឥតខ្ចោះនៃការរៀនសូត្រ និងភាពរីករាយ។



ប្រជាជនក្នុងសហគមន៍មានតួនាទីចម្បងពីព្រោះប្រសិនបើមិនមានពួកគាត់ទេ យើងមិនអាចដឹងព័ត៌មាននេះបានទេ។ យើងគ្រាន់តែបានដឹងអំពីរូបរាងខាងក្រៅនៃបេតិកភណ្ឌវប្បធម៌អរូបីប៉ុណ្ណោះ ប៉ុន្តែនៅពេលដែលយើងជជែកជាមួយពួកគាត់ យើងទទួលបានការយល់ដឹងបន្ថែមអំពីព័ត៌មានលម្អិតនៃ jatra។ ការសហការនេះ បានជួយឱ្យខ្ញុំដឹងកាន់តែច្រើនអំពីវប្បធម៌របស់យើង។

*– Pabitra Shakya គ្រូបង្រៀន*
*អនុវិទ្យាល័យ Janasewa*

សិស្សបានចូលរួមពេញលេញនៅក្នុងវគ្គសិក្សាទាំងអស់ ដែលជួយពួកគេឱ្យបានយល់អំពីពិធីបុណ្យ gai jatra។ នេះជាវិធីសាស្ត្រនៃការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់។ សូម្បីតែសិស្សមកពីថ្នាក់ផ្សេងៗគ្នាក៏អាចអនុវត្តវគ្គសិក្សានេះនៅក្នុងថ្នាក់របស់ពួកគេដែរ។ សូម្បីតែយើងទាំងអស់គ្នា ក៏បានរៀនអំពីបេតិកភណ្ឌវប្បធម៌អរូបី និងរបៀបបញ្ចូលបេតិកភណ្ឌទាំងនោះចូលទៅក្នុងមុខវិជ្ជា និងមេរៀន។ ដូច្នេះ វគ្គសិក្សានេះពិតជាជួយទាំងគ្រូបង្រៀន និងសិស្ស។

*– Pabitra Shakya គ្រូបង្រៀន*
*អនុវិទ្យាល័យ Janasewa*

## ការចូលរួមរបស់ឪពុកម្ដាយនៅក្នុងថ្នាក់ដែលបង្រៀនអំពីបេតិកភណ្ឌរស់

អ្នកស្រី Dharmakala Neupane គឺជាគ្រូបង្រៀនគណិតវិទ្យានៅអនុវិទ្យាល័យ Ganesh នៅក្រុង Budhanilkantha។ សហគមន៍ប្រជាជនតាម៉ាំងធំមួយរស់នៅជុំវិញបរិវេណសាលា ដូច្នេះជាមួយនឹងមិត្តរួមការងារ ២ នាក់ ពួកគាត់ជ្រើសរើសបង្កើតមេរៀនអំពីការប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីតាម៉ាំង ហៅថាពិធីបុណ្យ *Lhosar*។ អ្នកស្រី Neupane បានបង្កើតមេរៀនអំពី *khapse* ដែលជាស្ករគ្រាប់ពិសេសដែលធ្វើឡើងនៅក្នុងអំឡុងពេលនេះ។ គ្រូបង្រៀនភាសាអង់គ្លេស បានស្នើឱ្យសិស្សរបស់គាត់អានអត្ថបទពាក់ព័ន្ធនឹង *Sonam Lhosar* និងអនុវត្តលំហាត់ពិនិត្យការយល់ដឹងមួយចំនួន។ គ្រូបង្រៀនមុខវិជ្ជាសិក្សាសង្គម បានណែនាំ តាម៉ាំង *selo* ជាចម្រៀងប្រជាប្រិយមួយដែលច្រៀងតាមចង្វាក់ និងលំនាំភ្លេងពិសេស ដែលត្រូវបានច្នៃប្រឌិតឡើងជារឿយៗ។

> បើប្រៀបធៀបទៅនឹងការបង្រៀន និងការរៀនសូត្របែបប្រពៃណី ដំណើរការនេះពិតជាបានជួយដល់សិស្សក្នុងការរីកចម្រើន និងគោរពដល់វប្បធម៌នីមួយៗ តាមរយៈការចែករំលែកជាមួយមិត្តភក្តិ។ ដំណើរការនេះក៏បានបង្កើនចំណាប់អារម្មណ៍របស់ពួកគេទៅលើប្រធានបទផងដែរ។
>
> *– Dharmakala Neupane គ្រូបង្រៀន អនុវិទ្យាល័យ Ganesh*



អ្នកស្រី Neupane បានទាក់ទងជាមួយម្ដាយរបស់សិស្សដើម្បីរៀនអំពីរបៀបធ្វើ *khapse*។ គាត់បានបង្កើតកិច្ចតែងការបង្រៀនពីចំណេះដឹងនេះ ដែលអនុវត្តលើរយៈពេល ៤ វគ្គ។ សិស្សនាំគ្នាធ្វើការពិភាក្សាអំពីពិធីបុណ្យចូលឆ្នាំថ្មី *Lhoshar* និងពិធីបុណ្យនានាពីសហគមន៍តាម៉ាំង និងសហគមន៍ផ្សេងៗទៀត។ ពួកគេបានធ្វើការស្រាវជ្រាវ និងចែករំលែកអំពីអាហារដែលពួកគេបានចម្អិន និងបានញ៉ាំអាហារនៅក្នុងអំឡុងពេលទាំងនេះ។ គ្រឿងផ្សំ និងឧបករណ៍ដែលប្រើសម្រាប់ការចម្អិន *khapse* បានប្រើប្រាស់សម្រាប់អនុវត្តរូបមន្តធរណីមាត្រដើម្បីធ្វើការគណនាផ្ទៃក្រឡា។ បន្ទាប់ពីអនុវត្តវប្បធម៌ និងគណិតវិទ្យា សិស្សទទួលបានពីថ្នាក់ចម្អិនអាហារ។ ម្ដាយមួយចំនួនរបស់សិស្សមកពីសហគមន៍តាម៉ាំង បានស្ម័គ្រចិត្តជួយដល់សិស្ស និងធ្វើការចែករំលែករូបមន្តធ្វើម្ហូបរបស់ពួកគាត់។ ទោះបីជានៅផ្ទះក៏ដោយ ក៏ស្ត្រីគឺជាអ្នកដែលទទួលខុសត្រូវលើការចម្អិនម្ហូបអាហារដែរ សិស្សប្រុស និងសិស្សស្រីធ្វើការងារជាមួយគ្នាយ៉ាងយកចិត្តទុកដាក់ដើម្បីអាចញ៉ាំអាហារដ៏ឈ្ងុយឆ្ងាញ់។ គំនិតផ្ដួចផ្ដើមនេះ គឺជាការពង្រឹងសិទ្ធិអំណាចយ៉ាងខ្លាំងសម្រាប់ស្ត្រី។ មេរៀននេះបង្ហាញឱ្យឃើញថា ស្ត្រីក៏ជាអ្នកថែរក្សា និងអ្នកផ្ទេរចំណេះដឹងដ៏មានតម្លៃផងដែរដែលមានតម្លៃលើសពីផ្ទះបាយរបស់ពួកគាត់ទៅទៀត និងថែមទាំងបន្ថែមគុណតម្លៃដល់ការអប់រំនៅសាលាទៀតផង។

គ្រូបង្រៀនបានដឹងថាពួកគាត់គឺជាផ្នែកមួយរបស់សហគមន៍ ហើយអាចពង្រឹងបន្ថែមទៅលើចំណេះដឹងរបស់ពួកគាត់ ឬទៅរកសាច់ញាតិរបស់ពួកគាត់។ Sabitree Maharjan ជាគ្រូបង្រៀនភាសាអង់គ្លេសម្នាក់នៅអនុវិទ្យាល័យ Mangal ក្នុងក្រុង Kirtipur បានបង្ហាញមេរៀនគណិតវិទ្យារបស់គាត់ដោយប្រើ janku ដែលជាពិធីបុណ្យប្រពៃណីពិសេសមួយដែលប្រារព្ធឡើងដើម្បីរំឭកគុណ និងអបអរជីដូន និងជីតាដែលបានឈានចូលអាយុ ៧៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ៧ ម៉ោង។ កូនប្រសាររបស់គាត់ទើបតែប្រារព្ធពិធី *janku*។ គាត់បានសម្ភាសន៍សមាជិកគ្រួសាររបស់គាត់ និងបានថតសកម្មភាពនៃដំណើរការទាំងមូលដើម្បីប្រើប្រាស់នៅក្នុងថ្នាក់របស់គាត់។

ការសហការគ្នារវាងគ្រូបង្រៀន និងប្រជាជននៅក្នុងសហគមន៍គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការនាំយកបេតិកភណ្ឌរស់ទៅបង្រៀននៅតាមសាលាទាំងនេះ។ ទោះបីជាត្រូវចំណាយពេលវេលាច្រើន និងការរៀបចំច្រើនក៏ដោយ ក៏សិស្សទទួលបានអត្ថប្រយោជន៍ជាច្រើនពីលំហាត់អនុវត្តផ្ទាល់ ហើយគ្រូបង្រៀនបានកត់សម្គាល់ឃើញមានលទ្ធផល និងការចូលរួមដ៏ល្អដែរ។ លើសពីនេះទៀត ក៏អាចជួយជម្នះរបាំងរាំងសង្គមមួយចំនួនទៅលើជាតិសាសន៍ តាមរយៈការអញ្ជើញបុគ្គលធនធានមកពីក្រុមប្រជាជនផ្សេងៗគ្នា និងទៅលើយេនឌ័រ តាមរយៈការបង្ហាញនូវចំណេះដឹងរបស់ស្ត្រី។ ប្រជាជនដែលទំនងមិនសូវមានការអើពើ ត្រូវបានទទួលស្គាល់ថាព្រឹទ្ធាចារ្យ និងអ្នកថែរក្សាចំណេះដឹងអំពីបេតិកភណ្ឌដ៏តម្លៃរបស់ពួកគាត់។

## ការរៀបចំការស្ទង់មតិអំពី talaew ជាមួយសិស្សនៅសាលា Ban Mae Ngon Khilek School (ប្រទេសថៃ)

### សេចក្តីសង្ខេប

*គ្រូបង្រៀនបានរៀបចំការស្ទង់មតិផ្ទាល់នៅក្នុងសហគមន៍មូលដ្ឋានជាមួយសិស្ស ដើម្បីកំណត់បេតិកភណ្ឌរស់សម្រាប់ការសិក្សារបស់ពួកគាត់។ Talaew ដែលជាវត្ថុស័ក្តិសិទ្ធិធ្វើពីឫស្សីត្បាញ គឺត្រូវបានជ្រើសរើសដោយផ្អែកលើការអង្កេតលក្ខណៈចូលរួមរបស់សិស្ស ដែលនាំឱ្យមានសកម្មភាពសម្បូរបែប និងមានការចូលរួម។*

**ប្រទេស៖** ថៃ (ឈៀងម៉ៃ)

**មុខវិជ្ជាសិក្សា / ប្រធានបទ / ECA៖** ការសិក្សាអំពី talaew

**សមាសធាតុនៃបេតិកភណ្ឌវប្បធម៌អរូបី៖** Talaew វត្ថុស័ក្តិសិទ្ធិធ្វើពីឫស្សី

**កម្រិតថ្នាក់ និងអាយុសិស្ស៖** ថ្នាក់ទី១-៦ អាយុ ៧-១៣ឆ្នាំ

**សាលា៖** Ban Mae Ngon Khilek School

*Talaew* គឺជាវត្ថុស័ក្តិសិទ្ធិការពារ ដែលធ្វើឡើងពីចម្រៀកឫស្សីស្តើងៗ និងតូចត្បាញចូលគ្នាជារាងរង្វង់។ ក្រុមប្រជាជនភាគតិចនៅក្នុងមូលដ្ឋាន ដែលប្រតិបត្តិពុទ្ធសាសនាខាងវិញ្ញាណជឿថា វត្ថុនេះអាចបណ្តេញវិញ្ញាណព្រាយបិសាចបាន។ Talaew ធ្វើឡើងជារាង និងទម្រង់ជាច្រើន ហើយជួនកាល តុបតែងជាមួយនឹងជី និងផ្កានៅក្នុងមូលដ្ឋាន។ វត្ថុនេះភាគច្រើនត្បាញទៅជារូបរាងមួយដែលមានប្រហោងកណ្តាលដើម្បីចាប់វិញ្ញាណអាក្រក់។







ផ្នែកសំខាន់មួយនៃដំណើរការនេះគឺការយកឫស្សីមកត្បាញទៅឱ្យព្រះសង្ឃពុទ្ធសាសនាធ្វើពិធីប្រោះព្រំ។ សហគមន៍មូលដ្ឋានព្យួរ *talaew* នៅតាមមាត់ទ្វារ ស៊ុមទ្វារខាងលើ និងគែមដំបូល ដើម្បីការពារពួកគាត់ពីវិញ្ញាណព្រាយបិសាច គ្រោះកាច ថែមទាំងជំងឺកូវីដ-១៩ ទៀតផង។ វត្ថុនេះផ្តល់ពួកគាត់នូវសន្តិភាពផ្លូវចិត្ត និងរំឭកពួកគាត់ឱ្យធ្វើអំពើល្អ។

សាលា Ban Mae Ngon Khilek School មានទីតាំងស្ថិតនៅ Amphoe Fang ខេត្តឈៀងម៉ៃ នៅតំបន់ភាគខាងជើងប្រទេសថៃ។ សាលានេះនៅក្រោមការគ្រប់គ្រងរបស់អង្គភាពរដ្ឋបាលខេត្តឈៀងម៉ៃដែលលើកកម្ពស់គោលនយោបាយអប់រំសម្រាប់វប្បធម៌ចម្រុះ។ សាលានេះទទួលស្វាគមន៍សិស្សមកពីក្រុមប្រជាជនភាគតិចចំនួន ៨ ពីតំបន់មូលដ្ឋាន និងផ្តល់គុណតម្លៃទៅលើពហុវប្បធម៌និយម។ ដោយសារតែភាពចម្រុះនេះហើយ ទើបសាលាមានបំណងទទួលបាននូវជំនាញ និងចំណេះដឹងដើម្បីកែលម្អសកម្មភាពអប់រំរបស់ខ្លួនពាក់ព័ន្ធនឹងបេតិកភណ្ឌរស់ និងពលរដ្ឋសកល។ សាលានេះក៏បានប្រើប្រាស់ការអប់រំជាមធ្យោបាយការពារដើម្បីចូលរួមចំណែកដល់លទ្ធភាពរស់រានមានជីវិតរបស់វប្បធម៌មូលដ្ឋាន។

គ្រូបង្រៀនចំនួនពីរនាក់ និងសិស្សសាលាបឋមសិក្សាចំនួន ២២៤ នាក់បានចូលរួមនៅក្នុងការពិសោធន៍ការសិក្សាផ្អែកលើគម្រោង ដែលរួមបញ្ចូលមុខវិជ្ជាចំនួន ៨។ គ្រូបង្រៀន និងសិស្សមកពីក្រុមប្រជាជនភាគតិចផ្សេងៗគ្នាដែលរស់នៅក្នុងតំបន់នេះ។ ភាពចម្រុះនៃវប្បធម៌នេះ បានបង្កើនបទពិសោធន៍សិក្សាឱ្យកាន់តែសម្បូរបែបជាពិសេស នៅពេលដែលពួកគេប្រៀបធៀប *talaew* ប្រភេទខុសៗគ្នាដែលធ្វើឡើង និងប្រើប្រាស់ដោយក្រុមប្រជាជនភាគតិចជាច្រើន។ ចំណុចដូចគ្នា និងចំណុចខុសគ្នានៅក្នុងអត្ថន័យ គុណតម្លៃ និងមុខងារ គឺត្រូវបានស្វែងយល់ជាមួយគ្នានឹងសហគមន៍។

> ប្រាជ្ញាក្នុងមូលដ្ឋាន គឺជាមូលដ្ឋានគ្រឹះនៃវប្បធម៌ដែលជក់ជាប់នៅក្នុងរបៀបរបបរស់នៅរបស់យើង។ គុណតម្លៃនៃប្រាជ្ញាគឺលើសពីតម្លៃហិរញ្ញវត្ថុទៅទៀត។ ដោយមានប្រវត្តិជាយូរលង់មកហើយនៅលើទឹកដីរបស់យើង យើងគួរតែរៀនអំពីប្រាជ្ញានេះ និងធានាឱ្យបាននូវអនាគតនៃប្រាជ្ញានេះ។
>
> *– អ្នកស្រី Puangphet Meema គ្រូបង្រៀន សាលា Ban Mae Ngon Khilek*

សាលាផ្តល់នូវមុខវិជ្ជាមួយចំនួនពាក់ព័ន្ធនឹងសុខភាព និងវប្បធម៌ក្នុងមូលដ្ឋាន។ សម្រាប់គម្រោងនេះ គ្រូបង្រៀននៅសាលាចំនួនពីររូប គឺអ្នកស្រី Puangphet Meema និងអ្នកស្រី Pattra Rakpong មានបំណងលើកកម្ពស់ការសិក្សាពហុវិស័យ និងការកសាងសន្តិភាពតាមរយៈបេតិកភណ្ឌវប្បធម៌។ នៅពេលចាប់ផ្តើម ពួកគាត់មិនទាន់ដឹងច្បាស់អំពីបេតិកភណ្ឌរស់ណាមួយ ដែលត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការសិក្សានៅឡើយនោះទេ។ ដូច្នេះជាដំបូង ពួកគាត់បានបំផុសគំនិតជាមួយសិស្ស ដើម្បីរៀបរាប់បេតិកភណ្ឌរស់ឱ្យបានច្រើនតាមដែលអាចអនុវត្តទៅបាន។ បន្ទាប់មក សិស្សបានជ្រើសរើសបេតិកភណ្ឌដែលចែករំលែកដោយជនជាតិភាគតិចជាច្រើន។

## រៀបចំសកម្មភាពស្រាវជ្រាវនៅតាមសហគមន៍ជាមួយសិស្ស

គ្រូបង្រៀនដែលបានចូលរួមនៅក្នុងសិក្ខាសាលា UNESCO-ICHCAP-APCEIU គឺមានការភ្ញាក់ផ្អើលចំពោះសញ្ញាណមួយដែលសម្គាល់ថា បេតិកភណ្ឌវប្បធម៌អរូបីអាចជាការអនុវត្តក្នុងជីវិតប្រចាំថ្ងៃ។ ដូច្នេះពួកគាត់បានលើកទឹកចិត្តឱ្យសិស្សអង្កេតអំពីបរិស្ថានជុំវិញរបស់ពួកគេ នៅពេលដើរទៅផ្ទះ និងកំណត់អត្តសញ្ញាណសមាសធាតុវប្បធម៌ញឹកញាប់។ ពួកគេបានរករកភូមិនៅជុំវិញ និងបង្កើតគំនិតមួយចំនួនសម្រាប់គម្រោង។ នៅពេលដែលពួកគេរស់នៅទីនោះ ប្រជាជនក្នុងសហគមន៍ បានស្គាល់ពួកគេ និងគ្រូរបស់ពួកគេដែលធ្វើឱ្យការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកកាន់តែងាយស្រួល។





សិស្សបានកត់សម្គាល់ឃើញថា ស្ទើរតែគ្រប់ផ្ទះទាំងអស់នៅក្នុងភូមិក្បែរសាលាគឺសុទ្ធតែមាន *talaew* មួយ ឬច្រើនព្យួរនៅច្រកចូល ឬនៅស៊ុមទ្វាររបស់ពួកគាត់។ សិស្សមួយចំនួនបានចុះទៅមើលភូមិផ្សេងៗទៀតនៃក្រុមប្រជាជនភាគតិចផ្សេងៗគ្នា និងបានរាយការណ៍អំពីការឃើញមាន *talaew* ក្នុងទម្រង់ស្រដៀងគ្នា។ ពួកគេភាគច្រើនថែមទាំងរកឃើញវត្ថុនេះមួយនៅក្នុងផ្ទះរបស់ពួកគេផ្ទាល់ផងដែរ។ ពួកគេចង់ដឹងខ្លាំងណាស់អំពីអត្ថន័យ និងមុខងាររបស់វត្ថុធ្វើពីឫស្សី ដូច្នេះពួកគេបានចែករំលែកចំណាប់អារម្មណ៍នេះជាមួយនឹងគ្រូបង្រៀន។ តាមរយៈការងារនេះ ពួកគេបានជ្រើសរើស *talaew* ជាបេតិកភណ្ឌរស់សម្រាប់ការសិក្សារបស់ពួកគេ ដែលនឹងពង្រីកដើម្បីគ្របដណ្ដប់លើកម្រិតផ្សេងទៀតទាំងអស់នៃថ្នាក់បឋមសិក្សា។

បន្ទាប់ពីបានជ្រើសរើសសមាសធាតុនៃបេតិកភណ្ឌរស់រួចរាល់ហើយ គ្រូបង្រៀនចំនួនពីរនាក់បានរៀបចំកិច្ចប្រជុំជាមួយគ្រូបន្ទុកថ្នាក់ចំនួនប្រាំបីនាក់ផ្សេងទៀត នាយកសាលា និងបញ្ញវន្តក្នុងមូលដ្ឋាននៅក្នុងភូមិចំនួនពីរនៅក្បែរខាងដើម្បីរៀបចំផែនការសម្រាប់ការងារនៅទីតាំងជាពីរដំណាក់កាល។

ដំណាក់កាលទីមួយ គឺការចុះទៅតាមផ្ទះរបស់សិស្ស។ នេះគឺជាការអនុវត្តទូទៅដើម្បីពិនិត្យមើលស្ថានភាពរស់នៅរបស់សិស្ស។ គ្រូបន្ទុកថ្នាក់ចំនួន ១០ នាក់បានរួមបញ្ចូលដំណាក់កាលនេះជាមួយនឹងការស្ទង់មតិអំពី *talaew*។ នៅក្នុងរយៈពេលមួយខែ ពួកគាត់បានជួបជាមួយគ្រួសារទាំងអស់ និងបានរកឃើញថា ៨០% មាន *talaew*។ នៅក្នុងអំឡុងពេលនៃដំណើរការនេះ ពួកគាត់គឺអាចកំណត់អត្តសញ្ញាណប្រជាជនក្នុងមូលដ្ឋានចំនួន ១៥ នាក់ដែលមានចំណេះដឹង និងជំនាញច្បាស់លាស់ពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌អរូបីនេះ។

នៅក្នុងដំណាក់កាលទីពីរ គ្រូបង្រៀនបានទាក់ទងនាយកសាលា និងបានកំណត់អត្តសញ្ញាណប្រជាជនក្នុងមូលដ្ឋានដើម្បីជូនដំណឹងដល់ពួកគាត់អំពីដំណើរទស្សនកិច្ចសិក្សារបស់សាលា និងស្នើសុំការយល់ព្រម និងការគាំទ្រពីពួកគាត់។

គ្រូបង្រៀនបានរៀបចំការទស្សនកិច្ចចំនួនពីរជុំ នៅក្នុង ១៥ គ្រួសារនៅភូមិចំនួនពីរ៖ ភូមិមួយរបស់ប្រជាជនភាគតិចថៃយ៉ៃ និងភូមិមួយទៀតរបស់ប្រជាជន Muang ឈៀងម៉ៃ។ សិស្សប្រមាណជា ១០០ នាក់ (ប្រាំថ្នាក់) បានចូលរួមនៅក្នុងដំណើរទស្សនកិច្ចនីមួយៗ។

សិស្សបានដើរជាជួរយ៉ាងវែង និងបានឈប់តាមផ្ទះនីមួយៗដើម្បីជជែកជាមួយអ្នកអនុវត្ត។ សន្តិសុខ ភូមិចំនួនបួននាក់ បានជួយគ្រប់គ្រងចរាចរណ៍ និងត្រួតពិនិត្យសុវត្ថិភាពរបស់សិស្ស។

គ្រូបង្រៀនបានអនុវត្តយកវិធីសាស្ត្របើកចំហ។ សេចក្តីណែនាំតែមួយប៉ុណ្ណោះដែលផ្តល់ឱ្យសិស្សគឺ "សួរអ្វីដែលកូនៗចង់ដឹងអំពី *talaew*។" សិស្សបានសួរសំណួរអំពីអត្ថន័យ គុណតម្លៃ មុខងារ សម្ភារៈ និងដំណើរការធ្វើ *talaew* និងបានកត់ត្រាជាលាយលក្ខណ៍អក្សរ។ ពួកគេថតរូប និងវីដេអូដើម្បីកត់ត្រាទុកនូវសំណួរខ្លីៗរបស់ពួកគេ និងចម្លើយរបស់ប្រជាជន។ ពួកគេក៏បានរៀនអំពីរបៀបធ្វើ *talaew* និងយកមួយទៅផ្ទះជាវត្ថុអនុស្សាវរីយ៍។

គ្រូបង្រៀនបានអនុវត្តយកវិធីសាស្ត្របើកចំហ។ សេចក្តីណែនាំតែមួយប៉ុណ្ណោះដែលផ្តល់ឱ្យសិស្សគឺ "សួរអ្វីដែលកូនៗចង់ដឹងអំពី *talaew*។"



## រួមបញ្ចូលព័ត៌មានដែលបានស្រាវជ្រាវទៅក្នុងសកម្មភាពសាលា

បន្ទាប់ពីដំណើរទស្សនកិច្ចផ្ទាល់នេះ គ្រូបង្រៀនបានពិភាក្សាអំពីប្រាជ្ញាក្នុងមូលដ្ឋានដែលបានឆ្លុះបញ្ចាំងតាមរយៈស្នាដៃហត្ថកម្មនៅក្នុងមុខវិជ្ជាចំនួនប្រាំបីផ្សេងៗគ្នា។

គ្រូបង្រៀនបានតម្រៀបព័ត៌មានដែលបានប្រមូលបាន ទៅជា ៥ ក្រុម៖

1. ជំនឿសាសនា និងការបង្រៀន
2. អាជីពការងារ និងការអភិវឌ្ឍសេដ្ឋកិច្ចផ្អែកលើសហគមន៍
3. ទំនាក់ទំនងសហគមន៍ និងការចងភ្ជាប់សង្គម
4. សាវតារប្រវត្តិសាស្ត្រនៃ *talaew* និងសហគមន៍
5. ភូមិសាស្ត្រ និងវិទ្យាសាស្ត្រសង្គម







ការងារមូលដ្ឋានសាមញ្ញ តែមានប្រសិទ្ធភាពក្នុងការដាក់បញ្ចូលខ្លឹមសារអំពី *talaew* ទៅក្នុងមុខវិជ្ជាចំនួនប្រាំបីមុខដូចជា គណិតវិទ្យា (រាង និងទម្រង់ធរណីមាត្រ) អប់រំកាយ (ចលនារាងកាយ) វិទ្យាសាស្ត្រសង្គម (ជំនឿ និងការបង្រៀនសាសនា និងចំណងទំនាក់ទំនងសង្គម) សិល្បៈ (គំនូរ) វិទ្យាសាស្ត្រ (ធនធានធម្មជាតិ) ការអភិវឌ្ឍអាជីពការងារ (ការបណ្តុះបណ្តាលវិជ្ជាជីវៈផ្អែកលើសហគមន៍ និងការបង្កើតចំណូលសេដ្ឋកិច្ចតាមរយៈការលក់ *talaew*) ភាសាអង់គ្លេស និងចិន (វាក្យសព្ទពាក់ព័ន្ធ) និងភាសាថៃ (សាវតារប្រវត្តិសាស្ត្រ)។

បន្ថែមពីលើវគ្គចែករំលែកព័ត៌មាននៅក្នុងថ្នាក់រៀន សាលាក៏បានរៀបចំកម្មវិធីវប្បធម៌ដែលប្រជាជនក្នុងសហគមន៍ថៃយ៉ៃ ក៏ត្រូវបានអញ្ជើញឱ្យបង្ហាញ និងចែករំលែកចំណេះដឹងរបស់ពួកគាត់អំពីការធ្វើ *talaew* ដល់សិស្សគ្រប់កម្រិតថ្នាក់ផងដែរ។ សិស្សដែលអាចនិយាយភាសាថៃយ៉ៃ បានស្ម័គ្រចិត្តធ្វើជាអ្នកបកប្រែដើម្បីជួយមិត្តនៅក្នុងសាលាប្រាស្រ័យទាក់ទងជាមួយនឹងសិប្បករដ៏ចំណាន។ កម្មវិធីនេះប្រែក្លាយទៅជាសកម្មភាពផ្ទេរចំណេះដឹងឆ្លងជំនាន់ដ៏រស់រវើកមួយ។ ការរៀនអំពីរបៀបធ្វើ talaew ក៏បានផ្តល់ឱ្យសិស្សនូវឱកាសបង្កើតប្រាក់ចំណូលនៅពេលដែលសហគមន៍ទិញវត្ថុនេះក្នុងតម្លៃមួយ ១០ បាត។

គ្រូបង្រៀនបានចែករំលែកថា ការប្រើប្រាស់ *talaew* នៅក្នុងមេរៀនរបស់ពួកគាត់ បានលើកកម្ពស់ទិដ្ឋភាពអប់រំយ៉ាងខ្លាំង ដែលធ្វើឱ្យការអប់រំកាន់តែទាក់ទាញ និងគួរឱ្យចាប់អារម្មណ៍សម្រាប់សិស្ស។ មេរៀននេះបានជួយលើកកម្ពស់ការយល់ដឹងយ៉ាងរឹងមាំអំពីគុណតម្លៃនៃបេតិកភណ្ឌរស់ ដូច្នេះចាំបាច់ត្រូវតែមានការបន្តអនុវត្តសម្រាប់ក្មេងៗជំនាន់ក្រោយ។

ប្រជាជនក្នុងសហគមន៍គឺមានអារម្មណ៍សប្បាយចិត្តជាខ្លាំងក្នុងការចូលរួមនៅក្នុងការស្រាវជ្រាវនៅមូលដ្ឋាន និងការបង្ហាញអំពីស្នាដៃសិប្បកម្ម។ ចាស់ព្រឹទ្ធាចារ្យបានចែករំលែកថា ពួកគាត់មានការស្ញើចសរសើរចំពោះគម្រោងនេះ ដោយសារតែពីមុនមក *talaew* គឺត្រូវបានយល់ឃើញថាជាការអនុវត្តសម្រាប់តែ និងដោយមនុស្សចាស់ប៉ុណ្ណោះ ប៉ុន្តែបន្ទាប់ពីការស្ទង់មតិក្នុងមូលដ្ឋាននេះមក ចៅៗរបស់ពួកគាត់បានចាប់អារម្មណ៍ទៅលើបេតិកភណ្ឌនេះ និងបន្តសួរសំណួរកាន់តែច្រើនដល់ពួកគាត់

អំពីបេតិកភណ្ឌមួយនេះ។ សហគមន៍មានអារម្មណ៍ទទួលបានការធានាអះអាងជាថ្មីថា ប្រពៃណីនេះនឹងបន្តនៅក្នុងចំណោមយុវជន។

សាលាបានជួបប្រទះបញ្ហាប្រឈមចម្បងៗចំនួនបីនៅក្នុងការអនុវត្តសកម្មភាព។ ទីមួយគឺការរីករាលដាលនៃជំងឺកូវីដ-១៩ រឹតត្បិតទៅលើការធ្វើដំណើរ និងរយៈពេលប្រតិបត្តិការរបស់សាលា។ បន្ទាប់មក ការរៀបចំកម្មវិធី និងសកម្មភាពសិក្សាទាមទារថវិកាមួយចំនួន។ ចុងក្រោយ សិស្សចាំបាច់ត្រូវទទួលបានការបណ្ដុះបណ្ដាលអំពីរបៀបសម្ភាសន៍ប្រជាជន។ សិស្សមួយចំនួនមានការខ្មាសអៀនក្នុងការនិយាយជាមួយប្រជាជនក្នុងសហគមន៍ដែលពួកគេមិនដែលស្គាល់។ ប៉ុន្តែពួកគេទទួលបានការសប្បាយរីករាយដើរតាមមិត្តភក្តិដែលពូកែនិយាយ និងចូលរួមនៅក្នុងសកម្មភាពនៅទីតាំងផ្ទាល់។ គ្រូបង្រៀន និងសិស្សទាំងអស់បានសន្និដ្ឋានថា ពួកគាត់ចាំបាច់ត្រូវអភិវឌ្ឍន៍ជំនាញស្រាវជ្រាវនៅតាមសហគមន៍បន្ថែមទៀត។

ការស្ទង់មតិអំពីបេតិកភណ្ឌរស់ជាមួយសិស្ស បានពង្រឹងសិទ្ធិអំណាចដល់ពួកគេឱ្យផ្លាស់ប្តូរពីតួអង្គអកម្មនៅក្នុងប្រព័ន្ធអប់រំឱ្យក្លាយទៅជាជនបង្គោលនៃការសិក្សា។ ជាមួយគ្នានឹងគ្រូរបស់ពួកគេ និងជាមួយនឹងធាតុចូលពីសហគមន៍ ពួកគេបានជ្រើសរើសសមាសធាតុដោយផ្អែកលើការអង្កេតលក្ខណៈចូលរួមរបស់ពួកគេនៅទីតាំងផ្ទាល់។ សិស្សបានធ្វើដំណើរតាមភូមិដើម្បីសម្ភាសន៍ និងជជែកក្រៅផ្លូវការជាមួយមនុស្សពេញវ័យពាក់ព័ន្ធនឹង *talaew*។ សកម្មភាពនេះបានធ្វើឱ្យពួកគេក្លាយជាអន្តរការីវប្បធម៌ប្រកបដោយប្រសិទ្ធភាពក្នុងកិច្ចការពារបេតិកភណ្ឌរបស់ពួកគេ និងផ្សារភ្ជាប់គម្លាតរវាងជំនាន់។ តួនាទីយ៉ាងសកម្មរបស់ពួកគេបានធ្វើឱ្យការសិក្សាអំពី និងដោយប្រើបេតិកភណ្ឌរស់នៅក្នុងមុខវិជ្ជាជាច្រើនកាន់តែស្របគ្នាទៅនឹងចំណាប់អារម្មណ៍របស់ពួកគេ ហើយធ្វើឱ្យមានការចូលរួមកាន់តែច្រើន។ សហគមន៍ក៏ទទួលបានអត្ថប្រយោជន៍ពីការចែករំលែកព័ត៌មាន និងអារម្មណ៍របស់ពួកគាត់ពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌នៅក្នុងការអប់រំក្នុងប្រព័ន្ធ។ សាលាបានគ្រោងបន្តគម្រោងនេះ និងគម្រោងស្រដៀងគ្នានានានៅពេលអនាគត។

## រៀបចំសន្និសីទសាលាដើម្បីសម្រួចចំណេះដឹងឱ្យកាន់តែស៊ីជម្រៅអំពីបេតិកភណ្ឌរស់ (ប្រទេសកាហ្សាក់ស្ថាន)

### សេចក្ដីសង្ខេប

*សាលាអប់រំហ្វឹកហ្វឺនកាហ្សាក់ស្ថានលេខ ១៥៣ បានរៀបចំសន្និសីទមួយស្តីពីប្រធានបទរុក្ខជាតិក្នុងមូលដ្ឋាន និងការប្រើប្រាស់រុក្ខជាតិទាំងនោះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ដោយមានការជួយពីគ្រួសារ និងប្រជាជនក្នុងសហគមន៍របស់ពួកគេ សិស្សបានធ្វើការស្រាវជ្រាវ និងធ្វើបទបង្ហាញអំពីលក្ខណៈជីវសាស្ត្ររបស់រុក្ខជាតិ គ្រឿងផ្សំក្នុងមូលដ្ឋាន និងសិប្បកម្មធម្មជាតិ។ កម្មវិធីក្រៅកម្មវិធីសិក្សា គឺជាវេទិកាដ៏មានប្រយោជន៍មួយដើម្បីលើកកម្ពស់ការយល់ដឹងអំពីបេតិកភណ្ឌរស់ផ្ទេរការអនុវត្តក្នុងមូលដ្ឋាន និង និងទទួលយកនូវបទពិសោធន៍នៃបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងដំណើរការបង្រៀន និងសិក្សា។*

**ប្រទេស៖** កាហ្សាក់ស្ថាន (ទីក្រុងអាលម៉ាទី)

**មុខវិជ្ជាសិក្សា / ប្រធានបទ / ECA៖** សន្និសីទវិទ្យាសាស្ត្រដឹកនាំដោយសិស្ស កិច្ចប្រជុំជាមួយអ្នកប្រតិបត្តិបេតិកភណ្ឌវប្បធម៌អរូបី

**សមាសធាតុនៃបេតិកភណ្ឌវប្បធម៌អរូបី៖** ចំណេះដឹងអំពីរុក្ខជាតិឱសថផុះនៅតំបន់ Zhetisu

**កម្រិតថ្នាក់ និងអាយុសិស្ស៖** ថ្នាក់បឋមសិក្សា អាយុ ៦-១០ឆ្នាំ

**សាលា៖** សាលាអប់រំហ្វឹកហ្វឺនលេខ ១៥៣ ដាក់ឈ្មោះតាម Abdulla Rozybakiev









សាលាអប់រំហ្វឹកហ្វឺនលេខ ១៥៣ ដាក់ឈ្មោះតាម Abdulla Rozybakiev គឺជាសាលាពហុភាសាដែលមានទីតាំងស្ថិតនៅក្នុងទីក្រុងអាលម៉ាទីក្នុងតំបន់ Zhetisu (កាហ្សាក់ស្ថានភាគអាគ្នេយ៍)។ តំបន់ប្រវត្តិសាស្រ្ត Zhetisu នេះមានព្រំប្រទល់រួមគ្នាជាមួយប្រទេសចិន និងប្រទេសគៀជីស្ថាន។ នៅមុនពេលសង្គ្រាមលោកលើកទី II ប្រជាជនជាច្រើនដែលមកពីតំបន់ផ្សេងៗគ្នាបានតាំងទីលំនៅនៅទីនោះ។ ជាលទ្ធផលសព្វថ្ងៃនេះ តំបន់ Zhetisu មានវប្បធម៌ចម្រុះ និងបេតិកភណ្ឌដ៏សម្បូរបែប។ នៅក្នុងសាលា សិស្សមកពីក្រុមជនជាតិដើមភាគតិច Uyghur, Tajik និង Uzbek មានឱកាសក្នុងការសិក្សាភាសាកំណើតរបស់ពួកគេនៅក្នុងបរិយាកាសពហុវប្បធម៌។

នៅពេលដែលពួកគេបានរកឃើញនូវវិធីសាស្រ្តដាក់បញ្ចូលបេតិកភណ្ឌរស់ ទៅក្នុងសកម្មភាពសាលារបស់ពួកគេ គ្រូបង្រៀនបានសម្លឹងឃើញឱកាសក្នុងការសាកល្បងសកម្មភាពថ្មីៗ ដើម្បីលើកកម្ពស់បេតិកភណ្ឌវប្បធម៌ចម្រុះនៅក្នុងសាលាតាមរយៈដំណើរការអប់រំ។ ពួកគាត់បានផ្តួចផ្តើមដំណើរការនេះឡើងជាមួយនឹងជនជាតិដើមភាគតិច Uyghur របស់សហគមន៍ ដែលជាអ្នកតំណាងល្អបំផុតនៅក្នុងចំណោមសិស្ស និងគ្រូបង្រៀននៅក្នុងសាលានេះ។

នៅនិទាឃរដូវ ធម្មជាតិរីកស្គុះស្គាយ ហើយប្រជាជនចាប់ផ្តើមសង្ឃឹមអ្វីថ្មី និងស្រស់ស្រាយ។ ហេតុដូច្នេះហើយទើបបានជាគណៈគ្រប់គ្រងសាលា បានសម្រេចចិត្តរៀបចំកម្មវិធីសាលា នៅក្នុងអំឡុង រយៈពេលដ៏សំខាន់នេះ។ ជារៀងរាល់ឆ្នាំ ពីធីបុណ្យអបអរសាទរដល់ទិដ្ឋភាពផ្សេងៗគ្នានៃបេតិកភណ្ឌវប្បធម៌នៃតំបន់ Zhetisu ដូចជា ចំណេះដឹងប្រពៃណីអំពីធម្មជាតិ ប្រពៃណីនៃការនិយាយស្តី សិប្បកម្ម ការអនុវត្តសង្គម និងការសម្តែងសិល្បៈ។ ពិធីបុណ្យនេះ ក៏ផ្តល់កិត្តយសដល់អ្នកដែលមានបុគ្គលិកលក្ខណៈដ៏លេចធ្លោរដែលបានកើតនៅក្នុងតំបន់ Zhetisu ឬបានចូលរួមចំណែកដល់ការអភិវឌ្ឍរបស់តំបន់។ សៀវភៅបោះពុម្ពឆ្នាំ២០២១ របស់សាលា បាននិពន្ធដាច់ដោយឡែកតែអំពីរុក្ខជាតិឱសថ និងរុក្ខជាតិដុះនៅក្នុងតំបន់ Zhetisu លក្ខណៈឱសថនៃរុក្ខជាតិទាំងនោះ និងការប្រើប្រាស់រុក្ខជាតិទាំងនោះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ តំបន់នេះទទួលបានអត្ថប្រយោជន៍ពីធាតុអាកាសអំណោលផល និងដីសម្បូរជីជាតិ ព្រមទាំងពូជរុក្ខជាតិ និងរុក្ខជាតិឱសថជាច្រើនដុះយ៉ាងសន្ធឹកនៅក្នុងតំបន់។ កាលពីមុន សហគមន៍ទាំងអស់បានពឹងផ្អែកទៅលើរុក្ខជាតិទាំងនេះដើម្បីព្យាបាលជំងឺរបស់ពួកគេ។

កាលពីឆ្នាំមុនៗ ពីធីបុណ្យនេះគឺជាកម្មវិធីទូទាំងសាលាដែលបើកទទួលសិស្សគ្រប់ថ្នាក់ទាំងអស់ និងគ្របដណ្តប់លើគ្រប់មុខវិជ្ជាទាំងអស់។ ប៉ុន្តែនៅក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ វិសាលភាពនៃពិធីបុណ្យនេះ ត្រូវបានកាត់បន្ថយត្រឹមសន្និសីទវិទ្យាសាស្រ្ត សម្រាប់សិស្សថ្នាក់បឋមសិក្សាប៉ុណ្ណោះ។ អ្នកចូលរួមក៏រួមមានគ្រូ និងជំនាញការពីខាងក្រៅផងដែរ។ នៅក្នុងចំណោមអ្នកស្ម័គ្រចិត្ត សិស្សចំនួនប្រាំមួយនាក់ គឺត្រូវបានជ្រើសរើសដោយគ្រូ ដោយផ្អែកលើសំណើប្រធានបទ និងជំនាញធ្វើបទបង្ហាញរបស់ពួកគេ។ ពួកគេបានស្រាវជ្រាវ និងបានរៀបចំបទបង្ហាញមួយអំពីរុក្ខជាតិ និងរុក្ខជាតិឱសថផ្សេងៗគ្នាដូចជាផ្កាសេរ៉ាប (Dandelions) ជីអង្កាម ស្មៅលក្ខណ៍ (dyer's woad) ដើម wild rue អំបូរឃ្លោក (gourd) -ល- តាមរយៈព្រីសនៃមុខវិជ្ជាផ្សេងៗគ្នា។ ប្រជាជនក្នុងសហគមន៍បានចែករំលែកអំពីគ្រឿងផ្សំប្រចាំគ្រួសាររបស់ពួកគាត់តាមរយៈការសម្ភាសន៍ដែលបានថតទុកជាមុន។



ប្រជាជនមួយចំនួនក៏បានចូលរួមសន្និសីទជាមួយនឹងសិស្ស និងបានបង្ហាញអំពីរបៀបដែលពួកគាត់ប្រើប្រាស់ផលិតផលចម្រាញ់ចេញពីរុក្ខជាតិ។

ការងាររបស់សិស្សបានផ្តោតលើទិដ្ឋភាពផ្សេងៗគ្នានៃរុក្ខជាតិ។ សិស្សមួយចំនួនបានសិក្សាអំពីរុក្ខជាតិពីទិដ្ឋភាពជីវសាស្ត្រ។ ពួកគេបានដាំគ្រាប់រុក្ខជាតិ និងបានអង្កេតមើលដំណើរការលូតលាស់ បរិមាណទឹក ពន្លឺព្រះអាទិត្យ និងពេលវេលាដែលត្រូវការចាំបាច់ដើម្បីទទួលបានរុក្ខជាតិដែលមានសុខភាពល្អ។ ពួកគេក៏បានសម្ភាសន៍ឪពុកម្តាយ និងជីដូនជីតារបស់ពួកគេអំពីការប្រើប្រាស់រុក្ខជាតិទាំងនេះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ និងលក្ខណៈឱសថនៃរុក្ខជាតិទាំងនេះផងដែរ។

សិស្សជ្រើសរើសសិក្សាអំពីផ្ទាំងធ្វើពីផ្លែឃ្លោក។ គាត់បានធ្វើការងារជាមួយនឹងគ្រូបង្រៀនភាសា Uyghur និងគ្រូមុខវិជ្ជាសិល្បៈរបស់គាត់។ គាត់បានរៀនអំពីលក្ខណៈនៃផ្លែឃ្លោក មូលហេតុដែលជនជាតិ Uyghurs ប្រើប្រាស់ផ្លែនេះមកធ្វើជាផ្ទាំង របៀបដាំផ្លែឃ្លោកដើម្បីឱ្យវាលូតលាស់មកក្លាយជារាងដូចផ្ទាំង និងរបៀបថែទាំផ្ទាំងនោះ។ ដោយមានការជួយពីសំណាក់គ្រូរបស់គាត់ គាត់បានអញ្ជើញសិប្បករដ៏ចំណានម្នាក់ដើម្បីណែនាំអំពីសិល្បៈនៃការតុបតែងផ្លែឃ្លោក។

គណៈគ្រប់គ្រងសាលា បានអញ្ជើញនិស្សិតថ្នាក់បណ្ឌិតផ្នែកគីមីវិទ្យាមួយរូប ឱ្យមកចូលរួមនៅក្នុងសន្និសីទ។ គាត់បានផ្តល់មតិយោបល់ទៅលើការធ្វើបទបង្ហាញនីមួយៗបញ្ជាក់សុពលភាព ឬបំពេញបន្ថែមនូវព័ត៌មានដែលផ្តល់ជូនដោយវាគ្មិនវ័យក្មេង។

ការបន្ថែមទិដ្ឋភាពបេតិកភណ្ឌវប្បធម៌អរូបីទៅលើការស្រាវជ្រាវ ការឱ្យប្រជាជនក្នុងសហគមន៍ និងដៃគូចូលរួមនៅក្នុងកម្មវិធីនេះ បានបន្ថែមគុណតម្លៃដល់មុខវិជ្ជាដែលបានសិក្សា។ ចំពោះសិស្ស និងគ្រូ វាច្បាស់ណាស់ដែលបទពិសោធន៍នៃការបង្រៀនដោយ

> ការរួមបញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងដំណើរការអប់រំ គឺមានសារៈសំខាន់ និងមានផលិតភាពជាខ្លាំងសម្រាប់ការអប់រំរបស់សិស្ស ក៏ដូចជាការរីកចម្រើនផ្ទាល់ខ្លួនរបស់ខ្ញុំក្នុងនាមជាគ្រូបង្រៀនម្នាក់ផងដែរ។
>
> *– Dilbar AITAKHUNOVA គ្រូបង្រៀន សាលាអប់រំហ្វឹកហ្វឺនលេខ ១៥៣ ដាក់ឈ្មោះតាម Abdulla Rozybakiev*

> ខ្ញុំមិនដឹងថាឃ្លោកគឺល្អសម្រាប់សុខភាពនោះទេ។
>
> *– សិស្សថ្នាក់ទី ៦ សាលាអប់រំហ្វឹកហ្វឺនលេខ ១៥៣ ដាក់ឈ្មោះតាម Abdulla Rozybakiev*



ប្រើបេតិកភណ្ឌវប្បធម៌អរូបីនេះ បានធ្វើឱ្យដំណើរការសិក្សាមានភាពចម្រុះ និងផ្សារភ្ជាប់ចំណេះដឹងបានរៀនក្នុងសាលាទៅនឹងជីវិតជាក់ស្តែងទៀតផង។

ពិធីបុណ្យនេះបានផ្តល់ឱកាសសម្រាប់សិស្ស គ្រួសាររបស់ពួកគេ ប្រជាជនក្នុងសហគមន៍ឱ្យចែករំលែកចំណេះដឹងដ៏មានតម្លៃ និងដើម្បីទទួលយកនូវបទពិសោធន៍នៃការដាក់បញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងការបង្រៀន និងដំណើរការសិក្សា។ ពួកគាត់បានដឹងថា កម្មវិធីក្រៅកម្មវិធីសិក្សាអាចជាវេទិកាមួយសម្រាប់ការលើកកម្ពស់ការយល់ដឹងអំពីបេតិកភណ្ឌរស់របស់ពួកគាត់ ព្រមទាំងផ្ទេរការអនុវត្តរបស់ពួកគាត់។

## មេរៀនពហុវិជ្ជាអំពីសិល្បៈនៃពង្សាវតារកាហ្សាក់ស្ថាន

### សេចក្តីសង្ខេប

*គ្រូបង្រៀនមុខវិជ្ជាជីវៈវិទ្យា ប្រវត្តិសាស្ត្រប្រទេសកាហ្សាក់ស្ថាន និងភាសាកាហ្សាក់ស្ថាន បានសហការគ្នាលើគម្រោងរួមគ្នាស្តីពីប្រធានបទ shezhire (ចំណេះដឹងអំពីពង្សាវតារ)។ សិស្សបានធ្វើការស្រាវជ្រាវ និងបានគូរមែកធាងគ្រួសាររបស់ពួកគេ។ តាមរយៈ shezhire ពួកគាត់បានរៀនអំពីតំណពូជមនុស្ស កូដនៃហ្សែន ប្រវត្តិការចាត់ថ្នាក់ zhuz (កុលសម្ព័ន្ធ) និងក្រុមសាច់ញាតិ។*

**ប្រទេស៖** កាហ្សាក់ស្ថាន (ទីក្រុងអាលម៉ាទី)

**មុខវិជ្ជាសិក្សា / ប្រធានបទ / ECA៖** ៖ ប្រវត្តិវិទ្យា ជីវវិទ្យា ភាសាកាហ្សាក់ស្ថាន

**សមាសធាតុនៃបេតិកភណ្ឌវប្បធម៌អរូបី៖** Shezhire (ចំណេះដឹងអំពីពង្សាវតារ)

**កម្រិតថ្នាក់ និងអាយុសិស្ស៖** អនុវិទ្យាល័យ និងវិទ្យាល័យ អាយុ ១២-១៦ឆ្នាំ

**សាលា៖** Dostar International School-Lyceum

សាលា Dostar International School-Lyceum គឺជាសាលាឯកជន និងជាផ្នែកមួយនៃបណ្តាញសាលារបស់អង្គការយូណេស្កូ (ASPNet) ផងដែរ។ សាលានេះមានទីតាំងស្ថិតនៅទីក្រុងអាលម៉ាទីដែលជាទីក្រុងមួយក្នុងចំណោមទីក្រុងធំ និងអភិវឌ្ឍន៍បំផុតនៅក្នុងប្រទេសកាហ្សាក់ស្ថាន។



គ្រូបង្រៀនមុខវិជ្ជាជីវៈវិទ្យា ប្រវត្តិសាស្ត្រប្រទេសកាហ្សាក់ស្ថាន និងភាសាកាហ្សាក់ស្ថានចំនួនបីនាក់បានមើលឃើញឱកាសក្នុងការរុករកវិធីសាស្ត្រថ្មីៗ និងវិធីសាស្ត្របង្រៀនដើម្បីបំពេញបន្ថែមទៅលើដំណើរការអប់រំឱ្យកាន់តែសម្បូរបែប និងដើម្បីចាកចេញឱ្យផុតពីក្របខ័ណ្ឌស្តង់ដារនៃមេរៀន។ ពួកគាត់បានជ្រើសរើស *shezhire* ដែលជាចំណេះដឹងអំពីពង្សាវតារ ដោយសារតែការអនុវត្តនេះគឺនៅតែមានភាពជាប់ពាក់ព័ន្ធ និងមានអត្ថន័យនៅក្នុងប្រទេសកាហ្សាក់ស្ថាន ហើយការអនុវត្តនេះផ្សារភ្ជាប់យ៉ាងរលូនទៅនឹងមុខវិជ្ជារបស់ពួកគាត់រៀងៗខ្លួន។ គ្រូបង្រៀនទាំងអស់ គឺសុទ្ធតែបានស្គាល់ *shezhire* និងអាចប្រើប្រាស់ចំណេះដឹងផ្ទាល់ខ្លួនរបស់ពួកគាត់ក្នុងការបង្កើតមេរៀនរបស់ពួកគាត់បាន។

> បេតិកភណ្ឌវប្បធម៌អរូបីគឺពិតជាទ្រព្យសម្បត្តិមួយមែន! បេតិកភណ្ឌនេះគឺនៅគ្រប់ទីកន្លែង និងមានវត្តមានជានិច្ច។ ជាការចាំបាច់ណាស់ដែលត្រូវឱ្យតម្លៃ និងអនុវត្តវានៅក្នុងជីវិត។
>
> *– Larisa Petrovna Ilyushkina*
> *គ្រូបង្រៀនមុខវិជ្ជាជីវៈវិទ្យា សាលា Dostar International School-Lyceum*

នៅក្នុងប្រទេសកាហ្សាក់ស្ថាន ផ្ទេរតាមពាក្យសម្ដីដល់កូនប្រុសនូវឈ្មោះ ចរិតលក្ខណៈ មុខរបរ សមិទ្ធផលលេចធ្លោរបស់បុព្វបុរសរបស់ពួកគេនៅក្នុងវង្សត្រកូលខាងឪពុក។ នៅប្រទេសកាហ្សាក់ស្ថាន ឪពុកគឺជាអ្នកដែលមានសិទ្ធិសម្រេចចិត្ត ឬអនុម័តលើការរៀបការរបស់កូនៗ និងការរៀបការរវាងមនុស្សពីរនាក់ដែលមានខ្សែលោហិតដូចគ្នារយៈពេលប្រាំពីរជំនាន់ គឺត្រូវបានហាមឃាត់។ ការស្គាល់អំពីពង្សាវតាររបស់គ្រួសារ ទប់ស្កាត់ការរៀបការខ្សែលោហិតតែមួយ និងការឆ្លងពូជពង្ស និងការពារពួកគេពីជំងឺហ្សែន និងជំងឺស្វ័យស៊ាំ។ រហូតមកទល់ពេលនេះ កូនប្រុសមានកាតព្វកិច្ចសិក្សាអំពីបុព្វបុរសរបស់ឪពុក និងផ្ទេរចំណេះដឹងនេះទៅកាន់ក្មេងៗជំនាន់ក្រោយនៅពេលដែលគាត់ក្លាយទៅជាឪពុក។ កូនស្រីគួរតែដឹងអំពីពង្សាវតារនៃគ្រួសាររបស់ពួកគេផងដែរ ដើម្បីចៀសវាងរៀបការជាមួយសាច់ញាតិសាច់ជិត។ គ្រួសារ និងកុលសម្ព័ន្ធមួយចំនួន ជាពិសេសមកពីតំបន់ភាគខាងត្បូងនៃប្រទេសកាហ្សាក់ស្ថាន រក្សា និងជួនកាលបោះពុម្ពផ្សាយទម្រង់ជាលាយលក្ខណ៍អក្សរនៃ *shezhire*។ គ្រួសារផ្សេងទៀតជួលអ្នកនិពន្ធ ឬប្រវត្តិវិទូឱ្យស្រាវជ្រាវ និងសរសេរប្រវត្តិគ្រួសាររបស់ពួកគេ។



នៅក្នុងមុខវិជ្ជាជីវៈវិទ្យា សិស្សបានស្វែងយល់អំពីលំនាំនៃតំណពូជរបស់មនុស្ស កូដនៃហ្សែន និង DNA។ គ្រូបានណែនាំអំពីវិធាន និងនិមិត្តសញ្ញាមូលដ្ឋានដែលប្រើប្រាស់នៅក្នុងពង្សាវតារ។ សិស្សបានវិភាគពង្សាវតារនៃមនុស្សល្បីៗ ដោយយកចិត្តទុកដាក់លើការផ្ទេរលក្ខណៈហ្សែន។ តាមរយៈការវិភាគទាំងនេះ និងឧទាហរណ៍ផ្ទាល់ខ្លួនរបស់ពួកគេ សិស្សបានដឹងថា *shezire* អនុញ្ញាតឱ្យមនុស្សគោរពដល់អនុស្សាវរីយ៍របស់បុព្វការីជនរបស់ពួកគេ មិនត្រឹមតែជាការដឹងគុណប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីឱ្យមានកូនដែលសុខភាពល្អ និងរឹងមាំផងដែរ។

ថ្នាក់ប្រវត្តិវិទ្យាបានដឹកនាំពួកគេទៅកាន់ការរៀបចំរចនាសម្ព័ន្ធព្រឹត្តិការណ៍ប្រវត្តិតាមរយៈព្រឹសនៃរឿងរ៉ាវគ្រួសាររបស់ពួកគេ។




ដើម្បីចងចាំ និងសូត្រអំពីទំនាក់ទំនងរវាងបុព្វបុរស សិស្សបានទទួលនូវពាក្យថ្មីៗអំពីសាច់ញាតិនៅក្នុងអំឡុងពេលម៉ោងភាសាកាហ្សាក់ស្ថានរបស់ពួកគេ។ សិស្សក៏មានអារម្មណ៍សប្បាយរីករាយផងដែរក្នុងការរកឃើញថា មិត្តរួមសាលារបស់ពួកគាត់ម្នាក់គឺជាកូនចៅជំនាន់ក្រោយរបស់កវីដ៏ល្បីម្នាក់ឈ្មោះថា Abay Kunanbayev។ គ្រូបង្រៀនបានចាប់យកឱកាសនេះ។ គាត់បានរៀបចំមេរៀនអនុស្សាវរីយ៍អំពី "ការណែនាំអំពីកុលសម្ព័ន្ធ និងនិមិត្តសញ្ញាកាហ្សាក់ស្ថានតាមរយៈស្នាដៃរបស់ Abay" ដែលនៅក្នុងអំឡុងពេលមេរៀននេះ សិស្សថ្នាក់ទី៦ អាចជួបជាមួយក្មេងប្រុសនោះ និងស្តាប់សាច់រឿងគ្រួសាររបស់ក្មេងប្រុសនោះ។

គម្រោងពហុវិជ្ជានេះបានបង្កើតឱ្យមាននូវការចូលរួមកម្រិតខ្ពស់ពីសិស្ស និងគ្រួសាររបស់ពួកគេ ដោយសារតែនេះគឺជាឧបសគ្គផ្ទាល់នៃចំណេះដឹង។ សិស្សបានសម្ភាសន៍សាច់ញាតិរបស់ពួកគេ។ តាមរយៈអ៊ីនធឺណិត និងបណ្តាញសង្គម សិស្សមួយចំនួនថែមទាំងអស់ផ្សារភ្ជាប់ទំនាក់ទំនងឡើងវិញជាមួយសមាជិកគ្រួសារសាច់ឆ្ងាយរបស់ពួកគេដែលពួកគេធ្លាប់ឈប់ទំនាក់ទំនងគ្នា ឧទាហរណ៍ នៅពេលដែលប្រជាជនធ្វើចំណាកស្រុកបន្ទាប់ពីសង្គ្រាមលោកលើកទី II។

សិស្សក៏បានដឹងថា ប្រជាជនកាហ្សាក់ស្ថាន គឺមិនត្រឹមតែជាប្រជាជនដែលផ្ទេរចំណេះដឹងអំពីបុព្វបុរសរបស់ពួកគេប៉ុណ្ណោះទេ។ កុមារមកពីសហគមន៍ផ្សេងទៀតក៏បានពន្យល់អំពីរបៀបផ្ទេរព័ត៌មានអំពីពង្សាវតារនៅក្នុងគ្រួសាររបស់ពួកគេផងដែរ។ ជាលទ្ធផល យុវជនបានដឹងថា មនុស្សផ្សេងៗគ្នាមានចំណុចដូចគ្នា និងយល់អំពីគុណតម្លៃនៃបេតិកភណ្ឌវប្បធម៌អរូបីរបស់ពួកគេ និងរបស់អ្នកដទៃ ព្រមទាំងសារៈសំខាន់នៃកិច្ចការពារបេតិកភណ្ឌវប្បធម៌អរូបីផងដែរ។

សិស្សគឺបានចូលរួមយ៉ាងពេញលេញនៅក្នុងគម្រោងនេះ។ ពួកគេគឺជាសិស្សផង និងជាគ្រូផងនៅពេល ដែលពួកគេបានស្វែងយល់អំពីមែកធាងពង្សាវតាររបស់ពួកគេនៅលើក្រដាសផ្សព្វផ្សាយ ចែករំលែកអំពីកុលសម្ព័ន្ធ និងក្រុមជនជាតិដែលពួកគេស្ថិតនៅ ព្រមទាំងបទពិសោធន៍នៃសាច់ញាតិរបស់ពួកគេនៅក្នុងអំឡុងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ។ សំខាន់ជាងនេះទៅទៀតនោះ ពួកគេបានធ្វើការស្រាវជ្រាវផ្ទាល់ខ្លួន និងបានរៀនពីបទពិសោធន៍របស់ពួកគេផ្ទាល់។ សកម្មភាពនេះអនុញ្ញាតឱ្យពួកគេយល់ដឹងកាន់តែល្អប្រសើរអំពីប្រធានបទស្មុគស្មាញមួយនេះ និងដើម្បីពិនិត្យមើលគ្រួសាររបស់ពួកគេតាមមធ្យោបាយផ្សេងៗ។

ការបង្រៀនដោយប្រើ *shezhire* ជាប្រធានបទជំនួសពិតជាបានជួយឱ្យសិស្សយល់ដឹងប្រធានបទទូលំទូលាយ និងមានភាពស្មុគស្មាញ ព្រមទាំងអាចផ្សារភ្ជាប់វិទ្យាសាស្ត្រ និងភាសា ថែមទាំងចំណេះដឹងអំពីជីវិតជាក់ស្តែងបានយ៉ាងល្អប្រសើរទៀងផង។

# ការសម្របសម្រួលបរិបទថ្នាក់សិក្សាសង្គមដើម្បីបង្កើនចំណាប់អារម្មណ៍ទៅលើ Yeondeunghoe ពិធីបុណ្យបង្ហោះគោម

## សេចក្តីសង្ខេប

*Yeondeunghoe (ឬពិធីបុណ្យបង្ហោះគោម) គឺជាពិធីបុណ្យវប្បធម៌ប្រពៃណីដែលបានផ្ទេរតមកអស់រយៈពេលជាងមួយសហសវត្សរ៍មកហើយ។ ចាប់តាំងពីបុរាណកាលមក បុព្វបុរសយើងបានចូលរួមនៅក្នុងការធ្វើគោមដើម្បីបួងសួងសុំបំណងប្រាថ្នារៀងៗខ្លួន ក៏ដូចជាសុំសន្តិភាពនៅក្នុងប្រទេសផងដែរ។ ប្រពៃណីនេះបានវិវឌ្ឍន៍ទៅជាពិធីបុណ្យមួយដ៏ស្អិតរមួតដែលនៅក្នុងពិធីបុណ្យនេះ មនុស្សគ្រប់គ្នាបានចូលរួមទាំងអស់គ្នា ដោយមិនគិតអំពីដើមកំណើត អាយុ ឬសាសនាឡើយ។ នៅក្នុងកម្មវិធីសាលានេះ សិស្សបានធ្វើគោមដោយខ្លួនឯង និងធ្វើលិខិតអញ្ជើញនៅក្នុងសាលា។ កិច្ចការនេះបានដឹកនាំពួកគេឱ្យចាប់អារម្មណ៍ចូលរួមក្នុងពិធីបុណ្យ yeondeunghoe ជាក់ស្តែង។*

**ប្រទេស៖** សាធារណរដ្ឋកូរ៉េ (ទីក្រុងក្វាងជូ)

**មុខវិជ្ជាសិក្សា៖** សិក្សាសង្គម សិល្បៈ

**សមាសធាតុនៃបេតិកភណ្ឌវប្បធម៌អរូបី៖**
Yeondeunghoe ពិធីបុណ្យបង្ហោះគោម

**កម្រិតថ្នាក់ និងអាយុសិស្ស៖**

ថ្នាក់ទី៣ អាយុ ៩ ឆ្នាំ

**សាលា៖** សាលាបឋមសិក្សា Wolgok

សាលាបឋមសិក្សា Wolgok គឺមានទីតាំងស្ថិតនៅទីក្រុងក្វាងជូ។ សាលានេះលើកកម្ពស់គុណតម្លៃសំខាន់ៗដូចជាគុណតម្លៃដែលផ្សារភ្ជាប់ទៅនឹងភាពជាពលរដ្ឋសកល។ សិស្សមកពីប្រទេសជាង ១០ ប្រទេសរួមបញ្ចូលទាំងប្រទេសហ្វីលីពីន រុស្ស៊ី និងវៀតណាម សិក្សារួមគ្នានៅក្នុងបរិយាកាសពហុវប្បធម៌មេត្រី។ សាលានេះ គឺជាទីតាំងសាកល្បងសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សាផ្តោតលើទីក្រុងក្វាងជូ។ ការបង្រៀនរួមបញ្ចូលនូវប្រធានបទនានាពាក់ព័ន្ធនឹងទីក្រុងក្វាងជូ ដូចជារូបសំណាកប្រវត្តិសាស្ត្រ វប្បធម៌ និងប្រវត្តិសាស្ត្រក្នុងមូលដ្ឋាន។ ការបង្រៀនបេតិកភណ្ឌវប្បធម៌អរូបីក្នុងសាលាបានផ្តល់នូវកម្លាំងជំរុញ ដើម្បីប្រមូលព័ត៌មាន និងបង្កើតសកម្មភាពពាក់ព័ន្ធនឹងបេតិកភណ្ឌរស់ក្នុងមូលដ្ឋាន។ សិស្សចំនួន ២៤ នាក់ រួមបញ្ចូលទាំងសិស្សពីរនាក់មកពីគ្រួសារពហុវប្បធម៌ និងសិស្សអប់រំពិសេសម្នាក់ គឺមានការចង់ចេះចង់ដឹង និងសកម្មនៅក្នុងថ្នាក់។









សកម្មភាពនៃពិធីបុណ្យ Yeongdeunghoe គឺត្រូវបានរៀបចំឡើងជាច្រើនពេល ដែលអនុញ្ញាតឱ្យសិស្សរុករកដោយឃើតៗ និងជ្រួតជ្រាបគំនិតជាច្រើនអំពីបេតិកភណ្ឌ មុននឹងចូលស៊ីជម្រៅទៅក្នុងពិធីបុណ្យនេះផ្ទាល់។

ពិធីបុណ្យ *Yeondeunghoe* ត្រូវបានប្រារព្ធឡើងជាង ១៣០០ ឆ្នាំមកហើយ។ ចំពោះបុណ្យវិសាខបូជា (ថ្ងៃប្រាំបីកើតនៃខែទីបួននៅក្នុងប្រតិទិនចន្ទគតិ) ប្រជាជនអុចគោមនៅតាមដងផ្លូវទាំងអស់ទូទាំងប្រទេស និងបួងសួង។ សមាគមការពារពិធីបុណ្យ *Yeondeunghoe* មានគោលបំណងផ្ទេររបៀបធ្វើគោម និងការពារការប្រារព្ធពិធីនេះ។ បច្ចុប្បន្ននេះ ការប្រារព្ធពិធីបុណ្យ *Yeondeunghoe* រួមបញ្ចូលនូវពិធីពុទ្ធសាសនា ក្បួនដង្ហែរគោម *hoehyang hanmadang* (ការអបអរក្រោយក្បួនដង្ហែរ) ព្រមទាំងការសម្តែង និងការតាំងពិព័រណ៍ចម្រុះជាតិសាសន៍ទៀតផង។ ព្រឹត្តិការណ៍ទាំងនេះទាក់ទាញប្រជាជនជាច្រើនដែលចង់ចូលរួមកម្មវិធីបុណ្យជាមួយគ្នា។ ពិធីបុណ្យនេះបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូនៅឆ្នាំ២០២០។ បេតិកភណ្ឌរស់ គឺត្រូវបានជ្រើសរើសដោយសារតែសិស្សភាគច្រើនគឺធ្លាប់បានស្គាល់ និងចាប់អារម្មណ៍រួចមកហើយ។ សកម្មភាពអំពីពិធីបុណ្យ *Yeongdeunghoe* អាចផ្សារភ្ជាប់យ៉ាងងាយស្រួលទៅនឹងមុខវិជ្ជាសិក្សាសង្គម និងមុខវិជ្ជាសិល្បៈ។ ជាពិសេស ពិធីបុណ្យនេះចូលរួមចំណែកបណ្តុះមោទនភាពនៅក្នុងភូមិ ដែលជាគោលដៅនៃជំពូកនៃមុខវិជ្ជាសិក្សាសង្គម "សាច់រឿងនៃភូមិរបស់យើង"។ សាច់រឿងនេះគឺត្រូវបានរៀបចំនៅក្នុងអំឡុងពេលជិតដល់ពិធីបុណ្យ ដើម្បីបង្កើតចំណាប់អារម្មណ៍របស់សិស្ស។ គោមគឺងាយស្រួលមើលឃើញនៅតាមដងផ្លូវ ហើយសិស្សបានដឹងថា ការអនុវត្តនេះគឺជាផ្នែកមួយពិតជាក់ស្តែងនៅក្នុងជីវិតរបស់ពួកគេ និងមិនមែនគ្រាន់តែជាអ្វីម្យ៉ាងដែលអ្នកអាច ហើយអនុវត្តនៅក្នុងសកម្មភាពសិក្សាប៉ុណ្ណោះទេ។ ថ្នាក់សិល្បៈបានបង្កើតចំណាប់អារម្មណ៍របស់សិស្សទៅលើសម្រស់នៃគោមប្រពៃណីដ៏ចំណាស់ និងបានបង្រៀនពួកគេអំពីរបៀបប្រើក្រដាសគោមប្រពៃណីហៅថា hanji ដើម្បីធ្វើគោមសាមញ្ញដោយខ្លួនឯង។ គ្រូបំពេញបន្ថែមចំណេះដឹងរបស់ពួកគេដោយប្រើព័ត៌មានបានមកពីវេបសាយត៍សម្រាប់ពិធីបុណ្យនេះ។ សកម្មភាពនៃពិធីបុណ្យ *Yeongdeunghoe* គឺត្រូវបានរៀបចំឡើងជាច្រើនពេល ដែលអនុញ្ញាតឱ្យសិស្សរុករកដោយឃើតៗ និងជ្រួតជ្រាបគំនិតជាច្រើនអំពីបេតិកភណ្ឌមុននឹងចូលស៊ីជម្រៅទៅក្នុងពិធីបុណ្យនេះផ្ទាល់។ ដំបូងឡើយ សិស្សស្វែងរកអត្ថន័យនៃបេតិកភណ្ឌវប្បធម៌តាមរយៈការអង្កេតមើលក្រដាសប្រាក់ និងបណ្ណដែលមានទីកន្លែងបេតិកភណ្ឌវប្បធម៌នៅក្នុងតំបន់ក្វាងជូ ប្រាសាទ សាលាខុងជឺ ទីតាំងបុរាណ និងបេតិកភណ្ឌអរូបី។ បន្ទាប់មកគ្រូបានអញ្ជើញសិស្សឱ្យស្រាវជ្រាវអំពីបេតិកភណ្ឌរស់ដែលពួកគេចាប់អារម្មណ៍។ ការស្រាវជ្រាវនេះអនុញ្ញាតឱ្យពួកគេស៊ើបសរសេរអំពីជីវភាពរស់នៅ ប្រាជ្ញា និងស្មារតីនៃសោភណ្ឌវិទ្យារបស់បុព្វបុរសរបស់ពួកគេ។ លើសពីនេះ ឧទាហរណ៍នៃបច្ចេកទេសសិប្បកម្ម និងចម្រៀងអំពីវីរភាពដែលកំពុងតែបាត់បង់ បានធ្វើឱ្យពួកគេផ្តល់តម្លៃលើកិច្ចខិតខំប្រឹងប្រែងការពារដោយសារតែក្មេងៗជំនាន់ក្រោយអាចនឹងមិនរីករាយជាមួយនឹងបេតិកភណ្ឌនេះបានទៀតទេ ប្រសិនបើមិនមានការផ្ទេរបេតិកភណ្ឌនេះ។




ដោយមាននូវវីដេអូ និងសៀវភៅ សិស្សអាចសិក្សាអំពីប្រវត្តិនៃពិធីបុណ្យ *Yeondeunghoe* នេះបាន។ ពួកគេអាចកំណត់អត្តសញ្ញាណតួអង្គឯកបានយ៉ាងងាយស្រួល ដែលស្របពេលជាមួយគ្នានោះមានការរំភើបចំពោះក្បួនដង្ហែរ ប៉ុន្តែមានការព្រួយបារម្ភចំពោះការមិនមានលទ្ធភាពធ្វើគោមដ៏ស្រស់ស្អាតមួយបាន។ ពេលវេលាមួយក្នុងចំណោមពេលវេលារីករាយបំផុត គឺនៅពេលដែលសិស្សសម្លឹងមើលទៅលើរចនាបទចាស់ៗ និងរចនាបទបែបសហសម័យជាច្រើន និងបានធ្វើគោមផ្ទាល់ខ្លួន ដែលពួកគេចងភ្ជាប់ក្រដាសប៉ង់ប្រាថ្នាមួយសម្រាប់ខ្លួនឯង អ្នកជិតខាងរបស់ពួកគេ ប្រទេស ឬសហគមន៍សកលរបស់ពួកគេ។ គោមទាំងអស់ដែលបានព្យួរនៅក្នុងថ្នាក់រៀន និងតាមច្រករបៀងសាលា បានបង្កើតនូវបរិយាកាសពិធីបុណ្យ *Yeondeunghoe* ដ៏អស្ចារ្យ។ ក្បួនដង្ហែរគោមនៅពេលដែលមនុស្សគ្រប់វ័យ គ្រប់យេនឌ័រ និងគ្រប់សាសនាទាំងអស់ច្រៀង និងរាំជាមួយគ្នា គឺជាលក្ខណៈពិសេសអចិន្ត្រៃយ៍របស់ពិធីបុណ្យនេះជាច្រើនសតវត្សរ៍មកហើយ។ ដើម្បីរក្សាស្មារតីពិតប្រាកដនៃសាមគ្គីភាព សិស្សបានអញ្ជើញមិត្តរួមសាលាទាំងអស់របស់ពួកគេឱ្យចូលរួមនៅក្នុងពិធីបុណ្យ ដើម្បីបញ្ចប់គម្រោងសិក្សានេះដោយភាពរស់រវើក។ ទោះបីជាពិធីបុណ្យ *Yeondeunghoe* បានវិវត្តន៍តាមពេលវេលាក៏ដោយ ក៏គុណតម្លៃនៃពិធីបុណ្យនេះគឺនៅតែផ្ទេរ និងទទួលបានការឱ្យតម្លៃនៅក្នុងចំណោមប្រជាជនជំនាន់ថ្មី។

បន្ទាប់ពីបញ្ចប់គម្រោងសិក្សានេះ គ្រូបានប្រៀបធៀបសិស្សចំនួនពីរក្រុម៖ ក្រុមដែលបានចូលរួមសកម្មភាពអំពី *Yeondeunghoe* ( តទៅនេះហៅកាត់ថា "ក្រុមសាកល្បង" ) និងក្រុមមួយទៀតដែលបានអនុវត្តតាមខ្លឹមសារនៃសៀវភៅពុម្ពច្បាប់ដើមស្តីពីប្រធានបទ "ការយល់អំពីបេតិកភណ្ឌវប្បធម៌ដ៏មានតម្លៃរបស់យើង" ( តទៅនេះហៅកាត់ថា "ក្រុមទូទៅ" )។ ស្របពេលដែលក្រុមទាំងពីរមានឥរិយាបថវិជ្ជមានរួមគ្នាចំពោះវប្បធម៌ និងបេតិកភណ្ឌរបស់ពួកគេ សិស្សចំនួន ៨៧% នៅក្នុងក្រុមសាកល្បង អាចពន្យល់អំពីអត្ថន័យនៃពិធីបុណ្យនេះបាន ធៀបនឹងសិស្សចំនួន ២១% នៃក្រុមទូទៅ។ នៅក្នុងក្រុមសាកល្បង សិស្សចំនួន ៨៥% មានចំណាប់ច្រើនជាងទៅលើបេតិកភណ្ឌក្នុងមូលដ្ឋានរបស់ពួកគេ ដែលមានចំនួនពីរដងច្រើនស្មើគ្នាទៅនឹងក្រុមផ្សេងទៀត។ ហើយសិស្សចំនួនពាក់កណ្តាលមានអារម្មណ៍ថាពួកគេមានការបំពាក់បំប៉នគ្រប់គ្រាន់ក្នុងកិច្ចការពារបេតិកភណ្ឌដ៏មានតម្លៃរបស់ពួកគេ ធៀបទៅនឹងមួយភាគបីនៃសិស្សរបស់ក្រុមទូទៅ។ ការពិសោធន៍នេះរួមបញ្ចូលនូវសំណាកគំរូតូចនៃសិស្សប៉ុណ្ណោះ ប៉ុន្តែវាបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ខ្លឹមសារដែលបានកែសម្រួល និងសកម្មភាពអនុវត្តផ្ទាល់បាននាំមកនូវចំណេះដឹង ព្រមទាំងបំណងក្នុងការធ្វើខ្លួនឱ្យកាន់តែសកម្មនៅក្នុងកិច្ចការពារវប្បធម៌ក្នុងមូលដ្ឋាន។

ថ្នាក់សិក្សាសង្គមមានទំនោរផ្តោតលើបេតិកភណ្ឌរូបីច្រើនជាងបេតិកភណ្ឌអរូបី ដោយសារតែងាយស្រួលរកធនធាន និងឯកសារជារូបភាពជាង។ បេតិកភណ្ឌរស់ទទួលបានអត្ថប្រយោជន៍ពីការដកពិសោធន៍ និងជួនកាលការអនុវត្តដែលជាមូលហេតុដែលពិធីបុណ្យល្បីដូចជា *Yeondeunghoe* ជាដើម គឺជាចំណុចចូលដ៏ល្អឥតខ្ចោះ។



គ្រូបង្រៀនចង់ឱ្យសិស្សផ្សារភ្ជាប់ពិធីបុណ្យ *Yeondeunghoe* ជាពិធីបុណ្យមួយដែលពួកគេចង់ចូលរួម ដូចទៅនឹងបុព្វបុរសរបស់ពួកគេទន្ទឹងរង់ចាំការប្រារព្ធពិធីប្រចាំរដូវដូច្នោះដែរ។ សព្វថ្ងៃនេះ សិស្សគឺជួបប្រទះនឹងទម្រង់ជាច្រើននៃការកម្សាន្ត រួមបញ្ចូលទាំងពិធីបុណ្យជាច្រើនផងដែរ។ ប៉ុន្តែពិធីបុណ្យ *Yeondeunghoe* គឺលើសពីការកម្សាន្តទៅទៀត។ ពិធីបុណ្យនេះបង្កប់នូវស្មារតីសហគមន៍ ជាកន្លែងដែលមនុស្សមិនត្រឹមតែបួងសួងសម្រាប់ខ្លួនឯងប៉ុណ្ណោះទេ តែថែមទាំងបួងសួងឱ្យអ្នកជិតខាង និងប្រជាជននៅក្នុងប្រទេសសុំសុខសន្តិភាព និងសុភមង្គលទៀតផង។ វាពិបាកណាស់ក្នុងការដឹងថាចំណេះដឹងរបស់សិស្សដែលបានមកពីការសិក្សាច្រើនកម្រិតណា ប៉ុន្តែសកម្មភាពទាំងនេះបានធ្វើឱ្យការយល់ដឹងរបស់ពួកគេកាន់តែស៊ីជម្រៅ។

ស្របពេលដែលពិធីបុណ្យ *Yeondeunghoe* ប្រារព្ធឡើងជារៀងរាល់ឆ្នាំ ហើយមនុស្សគ្រប់គ្នាចូលរួមបានយ៉ាងងាយស្រួល គម្រោងសិក្សាក៏បានទាញចំណាប់អារម្មណ៍សិស្សបានជោគជ័យទៅលើការអនុវត្តដែលមិនសូវមើលឃើញ និងកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់នៃការបាត់បង់។ អនុស្សាវរីយ៍រីករាយដែលផ្សារភ្ជាប់នឹងពិធីបុណ្យបង្ហោះគោមនេះ ជំរុញដល់ការចង់ចេះចង់ដឹងរបស់សិស្សអំពីបេតិកភណ្ឌរស់ផ្សេងៗទៀត។

មេរៀនអំពីពិធីបុណ្យ *Yeondeunghoe* ក៏បានបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា បេតិកភណ្ឌរស់ គឺមិនមែនស្ថិតនៅក្នុងអតីតកាលនោះទេ ប៉ុន្តែជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងជីវិតរស់នៅបច្ចុប្បន្នរបស់យើង និងជាពិសេសពលរដ្ឋសកលនាពេលអនាគត មានទំនួលខុសត្រូវផ្ទេរបេតិកភណ្ឌនេះទៅកាន់មនុស្សជំនាន់ក្រោយ។



# បង្កើតសារមន្ទីរបេតិកភណ្ឌវប្បធម៌អរូបីនៅសាលា

## សេចក្តីសង្ខេប

*នៅក្នុងប្រទេសកៀហ្ស៊ីស្ថាន ក្រុមគ្រូបង្រៀនភាសាបានខិតខំពុះពារដើម្បីរៀបចំបង្កើតសារមន្ទីរបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងសាលារបស់ពួកគេ។ សារមន្ទីរនេះ គឺជាគំនិតផ្តួចផ្តើមមួយក្នុងចំណោមគំនិតផ្តួចផ្តើមផ្សេងៗក្នុងការបញ្ចូលបេតិកភណ្ឌរស់ចូលទៅក្នុងប្រព័ន្ធអប់រំ។ ចាប់ពីដំណាក់កាលបំផុសគំនិតប្រកបដោយមហិច្ឆតា រហូតដល់ការរៀបចំជាបណ្តុំ និងការបង្កើតមេរៀនប្រកបដោយភាពច្នៃប្រឌិត កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារបាននាំទៅរកកិច្ចសហការប្រកបដោយផ្លែផ្ការវាងសាលារៀន ជាមួយនឹងសហគមន៍ និងមានការចូលរួមពីសិស្សានុសិស្សនៅក្នុងសកម្មភាពជំរុញទឹកចិត្តនៅក្នុងបរិយាកាសសិក្សាប្រកបដោយភាពរស់រវើកផងដែរ។*

**ប្រទេស៖** សាធារណរដ្ឋ Kyrgyz

**មុខវិជ្ជាសិក្សា៖** សារមន្ទីរ ICH

**សមាសធាតុនៃបេតិកភណ្ឌវប្បធម៌អរូបី៖**
ចំណេះដឹងអំពីការងារហត្ថកម្ម ល្បែង ទម្លាប់សាសនា តន្ត្រី

**កម្រិតថ្នាក់ និងអាយុសិស្ស៖**
ថ្នាក់មត្តេយ្យដល់ថ្នាក់វិទ្យាល័យ

**សាលា៖** Educational Complex "Ilim"

Educational Complex "Ilim" បានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៣ បន្ទាប់មកបានចូលរួមជាមួយ បណ្តាញគម្រោងសាលាយូណេស្កូ (ASPnet) ក្នុងឆ្នាំ១៩៩៥។ បច្ចុប្បន្ន សាលានេះ បានសម្របសម្រួលសកម្មភាពបណ្តាញក្នុងចំណោមសមាជិករបស់ខ្លួនចំនួន ១៥ នៅក្នុងប្រទេសកៀហ្ស៊ីស្ថាន។ Complex គឺមានថ្នាក់រៀនចាប់តាំងពីកម្រិតមត្តេយ្យសិក្សារហូតដល់ថ្នាក់វិទ្យាល័យ ហើយក៏ស្វាគមន៍គ្រូអន្តរជាតិ និងសិស្សានុសិស្សផងដែរ។ តាមរយៈការប្រើប្រាស់ថ្នាក់រៀនតូចៗ សាលារៀន មានគោលបំណងធានាថា សិស្សទាំងអស់យល់អំពីទស្សនាទានពេញលេញអំពីមុខវិជ្ជាដែលពួកគេសិក្សា និងជួយពួកគេក្នុងការអភិវឌ្ឍជំនាញថ្មីដែលអាចប្រើប្រាស់ក្នុងជីវិតរស់នៅប្រចាំថ្ងៃបាន។

ចាប់តាំងពីបានចូលរួមជាមួយនឹងបណ្តាញសាលា ASPnet មក "Ilim" បានក្លាយទៅជាអ្នកផ្សព្វផ្សាយគុណតម្លៃរបស់អង្គការយូណេស្កូយ៉ាងសំខាន់នៅក្នុងប្រទេសកៀហ្ស៊ីស្ថាន។ ដោយមានការគាំទ្រពេញលេញពីថ្នាក់គ្រប់គ្រងសាលា គ្រូបង្រៀនក្នុងសាលា"Ilim" ដែលមានការចាប់អារម្មណ៍មកលើបេសកកម្មរបស់អង្គការយូណេស្កូ បានកែប្រែទម្រង់មេរៀន និងអនុវត្តគម្រោងពហុវិស័យពាក់ព័ន្ធនឹងការសិក្សាអន្តរវប្បធម៌ សិទ្ធិមនុស្ស និងការអភិវឌ្ឍប្រកបដោយចីរភាព និងបានបើកដំណើរការសារមន្ទីរបេតិកភណ្ឌអរូបីនៅក្នុងសាលាទៀតផង។




គោលគំនិតក្នុងការបង្កើតសារមន្ទីរវប្បធម៌អរូបី គឺត្រូវបានបង្កើតឡើងនៅពេលដែលគ្រូបង្រៀនសាលា "Ilim" ចាប់ផ្តើមពិចារណាអំពីរបៀបដែលពួកគេអាចនាំយកនូវវប្បធម៌រស់ក្នុងស្រុក ចូលទៅក្នុងសាលារៀន។ ការស្វែងយល់អំពីសារមន្ទីរ គឺមិនសូវជាមានលក្ខណៈផ្លូវការដូចថ្នាក់រៀននោះទេ ហើយផ្តល់នូវឱកាសសម្រាប់ការសិក្សាដែលមានការណែនាំ និងការស្វែងយល់ដោយខ្លួនឯង។ គ្រូបង្រៀន បង្ហាញមតិយោបល់អំពីគំនិត និងបំផុសគំនិតជាមួយនឹងសហការី។ គ្រូភាសាចំនួនបួននាក់ បានឯកភាពគ្នាសហការបើកដំណើរការសារមន្ទីរ។ តាមរយៈការអនុវត្តតាមផែនទីបង្ហាញផ្លូវដ៏ច្បាស់លាស់នេះ គ្រូបង្រៀន៖

- បានបង្ហាញអំពីគំនិតអំពីការគ្រប់គ្រងសាលារៀន និងជានានូវការគាំទ្ររបស់ថ្នាក់គ្រប់គ្រង ក្នុងនោះរួមមានទាំងថ្នាក់រៀនដែលត្រូវរៀបចំក្នុងសារមន្ទីរ។
- បានរៀបចំបញ្ជីវត្ថុត្រៀមដើម្បីដាក់បញ្ចូលទៅក្នុងសមុច្ច័យរបស់សារមន្ទីរ។
- បានកំណត់រក និងទាក់ទងទៅកាន់ដៃគូ។
- បានរៀបចំថ្នាក់រៀន និងប្រមូលសមាសធាតុនានាសម្រាប់សារមន្ទីរ។
- បានស្រាវជ្រាវឯកសារបោះពុម្ពផ្សាយ និងសរសេរបាយការណ៍សម្រាប់វត្ថុដែលត្រូវបង្ហាញ។
- បានរៀបចំការបើកសារមន្ទីរ និងអញ្ជើញសហការីចូលរួម។
- ចាប់ផ្តើមបង្រៀនមេរៀននៅក្នុងសារមន្ទីរ។

ការបង្កើតសារមន្ទីរបេតិកភណ្ឌវប្បធមអរូបី មិនមែនធ្វើឡើងដោយគ្មានបញ្ហាប្រឈមឡើយ។ ទោះបីជាពួកគេចូលចិត្តគំនិតអំពីការរៀបសារមន្ទីរក្តី ប៉ុន្តែថ្នាក់គ្រប់គ្រងសាលាមានក្តីបារម្ភមួយចំនួនពាក់ព័ន្ធនឹងនិរន្តរភាពផងដែរ។ ប៉ុន្តែ ការអនុញ្ញាតឱ្យរៀបចំនេះ បានជំរុញដល់ទឹកចិត្តគ្រូបង្រៀនយ៉ាងខ្លាំង។ ការបង្កើតសមុច្ច័យរបស់សារមន្ទីរ គ្រូបង្រៀនត្រូវទៅជួបសិស្ស និងគ្រួសាររបស់ពួកគេ ក៏ដូចជាសមាជិកសហគមន៍។ គ្រូបានស្នើសុំឱ្យសិស្សពន្យល់ប្រាប់គ្រួសាររបស់ពួកគេអំពីសារមន្ទីរបេតិកភណ្ឌរស់។ ឪពុកម្តាយមួយចំនួន យល់ព្រមក្នុងការចែក



វិលែករបស់របរមួយចំនួនដែលជារបស់ពួកគេ ហើយអ្នកផ្សេងទៀតបានភ្ជាប់សាលារៀនទៅហត្ថករ និងសមាជិកសហគមន៍ផ្សេងទៀត។ ម្តាយរបស់គ្រូបង្រៀនម្នាក់ ដែលជាហត្ថករ បានជួយកៀគរសិប្បករជាច្រើន។ ជំងឺរាតត្បាតកូវីដ ១៩ បានធ្វើឱ្យការប្រាស្រ័យទាក់ទងមានការលំបាក ដោយសារតែសិប្បករមួយចំនួនបានចាកចេញពីរោងជាងនៅក្នុងទីក្រុងរបស់ពួកគាត់ទៅទីជនបទវិញ ហើយអ្នកខ្លះទៀតធ្លាក់ខ្លួនឈឺ។ ដូច្នេះសារមន្ទីរ គឺពោរពេញទៅដោយរបស់របរហត្ថកម្មច្រើនចម្រុះ ដូចជាកម្រាលជើង កម្រាលជញ្ជាំង កម្រាលស្នោម្នុល និងរបស់របរដែលធ្វើពីស្បែក រោមសត្វ ឬឈើ ក៏ដូចជាគ្រឿងអលង្ការចាស់ៗ បន្ទះក្តារល្បែង ឧបករណ៍តន្ត្រី និងសម្លៀកបំពាក់។

គ្រូមកពីសាលារៀន និងថ្នាក់មត្តេយ្យ ក៏ដូចជាអ្នកសម្របសម្រួលថ្នាក់ជាតិរបស់បណ្តាញសាលា ASPnet ក្នុងប្រទេសគៀជីស្ថានបានចូលរួមក្នុងថ្ងៃបើកសម្ពោធជាផ្លូវការរបស់សារមន្ទីរផងដែរ។ មេរៀនទីមួយអំពីប្រធានបទ "តើបេតិកភណ្ឌវប្បធម៌អរូបីជាអ្វី?" (សូមមើលឯកសារទី ១ នៃកូនសៀវភៅទី ៨) ត្រូវបានបង្រៀន ដើម្បីពន្យល់សិស្សអំពីគោលគំនិតនៅពីក្រោយសារមន្ទីរនេះ។ ក្រោមមក មេរៀនជាបន្តបន្ទាប់ គឺផ្តោតលើការស្វែងរកបេតិកភណ្ឌរស់បានរៀបចំឡើងនៅក្នុងកន្លែងសិក្សាពិសេស។

តាមរយៈអត្ថប្រយោជន៍នៃការភ្ជាប់ទំនាក់ទំនងនៃការសិក្សាជាមួយបេតិកភណ្ឌវប្បធម៌អរូបី និងការអប់រំពលរដ្ឋសាកល គ្រូបង្រៀនបានបង្កើតបណ្តុំមេរៀនផ្តោតលើសារមន្ទីរ សម្រាប់សិស្សគ្រប់ថ្នាក់ទាំងអស់ រួមទាំងថ្នាក់មត្តេយ្យផងដែរ។ ការបញ្ចូលមេរៀនបេតិកភណ្ឌវប្បធម៌រស់ទៅក្នុងថ្នាក់រៀនភាសា គឺមានភាពងាយស្រួលណាស់។ សិស្សអាចស្វែងយល់អំពីបេតិកភណ្ឌរស់តាមរយៈមេរៀន រួមទាំងការអាន និងការអនុវត្ត។ ពួកគេសិក្សាអំពីពាក្យថ្មី និងពិចារណាអំពីបេតិកភណ្ឌរស់ដោយខ្លួនឯង ដោយពាក្យសម្តី និងជាលាយលក្ខណ៍អក្សរ។ គ្រូបង្រៀនភាសា Kyrgyz បានផ្តោតទៅលើមេរៀន*អំពី* និង*ជាមួយ* ICH ដែលមានបញ្ចូលយ៉ាងសម្បូរបែបទៅក្នុងមាតិកា និងលើកកម្ពស់ការយល់ដឹងរបស់សិស្សអំពីមុខវិជ្ជានេះ។ ប្រសិនបើអាចអនុវត្តបាន អ្នកអនុវត្តបេតិកភណ្ឌរស់បានបង្ហាញអំពីហត្ថកម្ម ឬទម្លាប់សាសនាជាក់លាក់របស់ពួកគេ។ សិស្សមួយចំនួន ត្រូវបានហៅឱ្យមកធ្វើបទបង្ហាញអំពីគម្រោងស្រាវជ្រាវ ICH ផ្ទាល់ខ្លួន នៅទីនោះជំនួសឱ្យថ្នាក់រៀនធម្មតា។

តាមរយៈសកម្មភាពសិក្សានៅសារមន្ទីរ សិស្សសាលា "Ilim" ប្រែក្លាយជាចាប់អារម្មណ៍ និងមានមោទនភាពចំពោះបេតិកភណ្ឌវប្បធម៌។ សិស្សផ្តល់មតិយោបល់ថាបរិយាកាសនៅក្នុងសារមន្ទីរបានលើកទឹកចិត្តពួកគេ "ឱ្យស្វែងយល់ស៊ីជម្រៅទៅក្នុងបេតិកភណ្ឌវប្បធម៌អរូបី"។ ក្នុងនាមជាគ្រូស្ថាបនិក សង្ឃឹមថា សារមន្ទីរនឹងផ្តល់នូវទីធ្លាសិក្សា ដែលគ្រូបង្រៀនអាចប្រើប្រាស់វិធីសាស្ត្រថ្មីៗ ហើយ

> "សិស្សជាច្រើនមិនបានដឹងអំពីឈ្មោះ ICH មួយចំនួនជាភាសា Kyrgyz នោះទេ ដោយសារតែសិស្សមកពីប្រទេសផ្សេងៗគ្នា ហើយពួកគេពុំសូវស្គាល់វប្បធម៌ Kyrgyz នោះទេ។. ពួកគេបានឃើញរបស់របរហត្ថកម្មជាលើកទីមួយ (ala kiyiz, for example) ហើយសួរសំណួរជាច្រើន និងមើលទៅគឺពួកគេមានអារម្មណ៍ប្លែក។"
>
> *– Elmira Sarkulova, សិស្ស សាលា Educational Complex "Ilim"*









សិស្សចង់ចូលរួមស៊ីជម្រៅក្នុងប្រធានបទនៃមេរៀននេះ។ បេតិកភណ្ឌអរូបីបានបញ្ចូលទៅក្នុងកន្លែងអប់រំ ដើម្បីជួយផ្តល់នូវការសិក្សាអំពីវប្បធម៌។

ដើម្បីបញ្ជាក់អំពីនិរន្តរភាពនៃគំនិតផ្តួចផ្តើមនេះ គ្រូបង្រៀនបានចែករំលែកមតិយោបល់វិជ្ជមានជាមួយនឹងគណៈគ្រប់គ្រងសាលារៀន និងបង្កើតកិច្ចតែងការបង្រៀនសម្រាប់មេរៀនភាសា ប្រវត្តិសាស្ត្រ តន្ត្រី និងវិទ្យាសាស្ត្រសង្គម និងសកម្មភាពដែលត្រូវធ្វើឡើងនៅក្នុងសារមន្ទីររហូតទាល់តែបញ្ចប់ឆ្នាំសិក្សាបច្ចុប្បន្ន និងចូលទៅឆ្នាំសិក្សាថ្មី។ ឧទាហរណ៍ មេរៀនតន្ត្រីទូទៅដែលប្រើប្រាស់ឧបករណ៍បុរាណ នឹងត្រូវប្រើប្រាស់ជាប្រយោជន៍សម្រាប់សមុច្ច័យរបស់សារមន្ទីរ ហើយគ្រូ *toguz korgool* និងរៀបចំបង្កើតក្លឹបសិក្សាសម្រាប់ការបង្រៀន ការអនុវត្ត និងការរីករាយក្នុងការលេងអុកបុរាណ។

ការបង្កើតសារមន្ទីរបេតិកភណ្ឌរស់នេះ ទាមទារនូវការចំណាយពេលវេលា និងការខិតខំប្រឹងប្រែងពីភាគីពាក់ព័ន្ធជាច្រើន។ ការសហការ បានជួយសមាជិកក្រុមឱ្យជម្នះរាល់ឧបសគ្គទាំងនោះ តាមរយៈការរួមបញ្ចូលគ្នានូវការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងដែលនាំទៅរកលទ្ធផលវិជ្ជមាន និងប្រកបដោយនិរន្តរភាពសម្រាប់សិស្ស គ្រូបង្រៀនអណាព្យាបាល និងសមាជិសហគមន៍។ មេរៀនេះ បានដំណើរការទៅដោយរលូន ហើយកន្លែងសិក្សាក្រៅផ្លូវការបានជួយសិស្សឱ្យចូលរួមប្រកបដោយអត្ថន័យ និងប្រកបដោយភាពសកម្មទៅតាមមុខវិជ្ជាមេរៀន។ ហើយក៏បានពង្រឹងនូវការភ្ជាប់ទំនាក់ទំនងរវាងសាលារៀន និងគ្រួសារសិស្ស។ ការចង់បានរបស់សមាជិកសហគមន៍ ឱ្យចូលរួម និងការជួយ បានផ្តល់ឱកាសសិស្សចូលរួមដោយផ្ទាល់ជាមួយនឹងអ្នកអនុវត្តបេតិកភណ្ឌអរូបី ក្នុងអំឡុងពេលមេរៀន និងអនុវត្ត។ គ្រូបង្រៀនបានធ្វើសេចក្តីព្រាងផែនការការងារដើម្បីពង្រីកវិសាលភាពសមុច្ច័យ និងសកម្មភាពសារមន្ទីរ។ ទីធ្លានេះ បានក្លាយទៅជាទីកន្លែងសម្រាប់ការសន្ទនា និងលើកកម្ពស់ភាពស្និតស្នាលក្នុងសង្គម និងផ្តល់នូវក្របខ័ណ្ឌសម្រាប់ការសហការនាពេលអនាគតផងដែរ។

## បញ្ជីឈ្មោះអ្នកចូលរួមចំណែកក្នុងគម្រោង៖

**<u>ក្រុមការងារសហការថ្នាក់តំបន់</u>**

***UNESCO Bangkok***: Duong Bich Hanh, Hangying Li

***ICHCAP:*** Weonmo Park; Min Jung Kim; Jinyoung Seo

***APCEIU:*** Yangsook Lee

***អ្នកជំនាញដឹកនាំ៖*** Vanessa Achilles ( 2003 Convention accredited facilitator )

**<u>ក្រុមការងារសាកល្បង</u>**

*ប្រទេសកម្ពុជា*

*ការិយាល័យយូណេស្កូប្រចាំទីក្រុងភ្នំពេញ៖* Masanori Nagaoka; Carole Idczak; Hong Makara; Lay Vutha

*អង្គការសិល្បៈខ្មែរអមត (ដៃគូអនុវត្ត)៖* Phloeun Prim; Marie Christine Uguen; Song Seng; Kong Vollak; Ket Senghuy

*ក្រសួងវប្បធម៌ និងវិចិត្តសិល្បៈ៖* Siyonn Sophearith; Chey Chankethya

*ក្រសួងអប់រំ យុវជន និងកីឡា៖* Mok Sarom; Ngor Penglong; Meas Chutema

*អ្នកជំនាញ៖* Yun Khean; Proeung Chhieng; San Phalla; Hout Sithan; Chy Rotha

*វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ៖* Set Seng; Sam Chanphirun; Dork Chea; Hong Sovann; Kong Vollak; Sao Sovann; San Channthia; Norng Petresampiseth; Sambath Soksan; Ven Phatha; Mon Nevy; Chhim Sundalin; Mey Sophara

*វិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង៖* Bin Chhom; Ky Sokheng; Lam Bunmakara; Phou Sophal; Ok Peuv; Sem Savoeurn; Tim Chancheanith; Pheap Ratanak

*សាលាអនុវត្តអូរបែកក្អម៖* Pom Solida; Oum Pisey

*អនុវិទ្យាល័យអនុវត្តអូរបែកក្អម៖* Huot Sothy

*អនុវិទ្យាល័យអនុវត្តបាត់ដំបង៖* Nong Sithan

*អនុវិទ្យាល័យសោហ៊ី៖* Prak Sokhem

*សាលាជំនាន់ថ្មី៖* Sam Kamsann; Men Solaneth; Vong Raveth

*មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង៖* Yi Songky; Phok Rithea

### សាធារណរដ្ឋកូរ៉េ

*ICHCAP*៖ Weonmo PARK; Min Jung KIM; Jinyoung SEO

*អ្នកជំនាញ*៖ Geon Soo HAN ( សាកលវិទ្យាល័យ Kangwon ); Dawon KIM ( សាកលវិទ្យាល័យជាតិអប់រំ Gwangju ); Seung Bum LIM ( មជ្ឈមណ្ឌលបេតិកភណ្ឌអរូបីជាតិ ); Yong-Goo KIM ( រដ្ឋបាលបេតិកភណ្ឌអរូបី ); Sang mee BAK ( សាកលវិទ្យាល័យសិក្សាបរទេស Hankuk )

*បឋមសិក្សា Geomsan*៖ Ja Kyung KWON

*បឋមសិក្សា Shingal*៖ Ho Jeong KIM

*បឋមសិក្សា Wolgok*៖ Jeong YOON

*អនុវិទ្យាល័យ Geunyoung*៖ Eunkyung CHO

*អនុវិទ្យាល័យ Osan*៖ Myung Sook KIM

*សហគមន៍*៖ Yongil Jang

### ប្រទេសកាហ្សាក់ស្ថាន

*ការិយាល័យយូណេស្កូប្រចាំទីក្រុងអាលម៉ាទី*៖ Aigul Khalafova

*អ្នកជំនាញ*៖ Saniya Bazheneyeva ( 2003 Convention facilitator )

*Abdulla Rozybakiev Gymnasium No.153*: Shavkat Umarov; Aida Askarova; Dilbar Aitakhunova; Gulminam Duganova; Gulzaryam Masimova

*Gymnasium school No. 8*: Ardak Smagulova; Lyazat Galiyeva; Alua Nurmukhayeva; Madina Nurakhanova

*Dostar International School-Lyceum*: Svetlana Kuntsevich; Julia Kim; Natalia Pigaleva; Larisa Ilyushkina; Gulmira Ismailova

*សហគមន៍*៖ Serzhan Bashirov

### សាធារណរដ្ឋ Kyrgyz

*ការិយាល័យយូណេស្កូប្រចាំទីក្រុងអាលម៉ាទី*៖ Aigul Khalafova

*អ្នកជំនាញ*៖ Kamila Rashidova ( 2003 Convention accredited facilitator )

*សាលា Educational Complex "Ilim" ( UNESCO ASPnet School )*: Victoriya Borsheva;Elmira Sarkulova; T. Hudaiberdieva; N. Ermekbaeva; T. Kurmanova; Rano Abdukova; Artur Ahmetchin

*អគារសាលាលេខ #95*: Elena Glaubent; Bakytbek kyzy Aisezim; Nurzhamal Orozakunova; Nurgyz Aibekova

*សាលាអន្តរជាតិ Harvard*៖ Elza Beishekeeva; Saadat Zhaichibekova; Aizharkyn Kozhomberdieva

*បណ្តាញសាលា ASPnet យូណេស្កូ ក្នុងប្រទេសកាហ្សាក់ស្ថាន*៖ Guldzhamal Esenalieva; Gulnara Ibragimova

*គណៈកម្មាធិការជាតិនៃសាធារណរដ្ឋ Kyrgyz សម្រាប់អង្គការយូណេស្កូ*៖ Sabira Soltongeldieva

## នេប៉ាល់

*ការិយាល័យអង្គការយូណេស្កូប្រចាំទីក្រុង Kathmandu៖* Balaram Timalsina; Prativa Shrestha; Neerana Shakya; Nipuna Shrestha

*Srijanalaya (ដៃគូអនុវត្ត)៖* Sharareh Bajracharya; Manantuna Jyapoo; Subima Shrestha, Sanjeev Maharjan; Sushma Maharjan; Rumi Maharjan

*អនុវិទ្យាល័យ Janasewa (Kirtipur)៖* Devraj Maharjan; Mandira Gurung; Amita Dangol; Pabitra Shakya

*អនុវិទ្យាល័យ Mangal (Panga, Kirtipur)៖* Loklal Maharjan; Sabitree Maharjan; Dilip Kumar Maharjan; Sumitra Maharjan

*អនុវិទ្យាល័យ Shree Ganesh (Budhanilkantha)៖* Mim Kaji Shrestha; Prakash Dhakal; Dharmakala Bhurtel; Badri Bahadur Tamang

*អនុវិទ្យាល័យ Shree Naulin (Budhanilkantha)៖* Bishnu Kaji Shrestha; Hira Lal Budha; Jaya Kumar Shrestha; Samjhana Dhungel

*អ្នកសម្របសម្រួលពីសាលាក្រុង៖* Dharma Raj Dangol; Indra Prasad Dahal

*បុគ្គលធនធានសហគមន៍៖* Prayag Man Pradhan; Shree Krishna Maharjan; Asmita Theeng; Bishnu Bahadur Shrestha; Rupendra Maharjan; Ram Krishna Duwal; Ram Krishna Maharjan; Gautam Maharjan; Purna Bahadur Tamang; Nanda Kumari Maharjan; Nirmala Theeng; Hira Bahadur Maharjan; Temai Tamang; Prem Lopchan; Toksani Lama; Sonam Singi Lama; Santa Bhai Shrestha

## ប្រទេសថៃ

*UNESCO Bangkok៖* Montakarn Suvanatap Kittipaisalsilp

*អ្នកជំនាញ៖* Linina Phuttitan (អនុសញ្ញាឆ្នាំ២០០៣ ផ្ដល់ជូនដោយអ្នកសម្របសម្រួល); Athapol Anunthavorasakul (សាកលវិទ្យាល័យ Chulalongkorn)

*សាលាសាកល្បង៖* Ban Mae Ngon Khi Lek; Baan Sala; Mae Ai Witayakom; Ton Kaew Phadung Pittayalai; សាលា Wat Ketkaram

*អាជ្ញាធរក្នុងស្រុក និងអ្នកសម្របសម្រួល៖* ស្ថាប័នរដ្ឋបាលខេត្ត Chiang Mai (CMPAO); សាលាក្រុង Chiang Mai; វិទ្យាស្ថានស្រាវជ្រាវសង្គម, សាកលវិទ្យាល័យ Chiang Mai

*សហគមន៍៖* ភូមិ Phra Chao Nang Kon; ក្រុមជនជាតិដើម Tai Yai នៅភូមិ Pang Khwai; ភូមិ Ban Thawai Craft; សហគមន៍ Wat Ketkaram; សហគមន៍ Amphoe Mae Ai

យើងក៏សូមថ្លែងអំណរគុណចំពោះការគាំទ្ររបស់អ្នកជំនាញ និងសហការី៖ Kristy Bang; Farial Khan; Aditi Pathak; Maite Zeisser; Susanne Schnuttgen; Jihong Lee; Yunjeong Lee; Rahul Goswami; Waraporn Onnom; Korapat Praputum; Sirisak Chaiyasook; Santibhap Ussavasodhi

# បញ្ជីរូបភាព

| | |
|---|---|
| Front cover: | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 10-11: | © Nischal Thapa |
| Page 13: | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 14: | © Linina Phuttitarn |
| Page 15: | © Cheon Youngtaek/ICHCAP |
| Page 16 (top): | © Rustem Nuryyev/Shutterstock.com* |
| Page 16 (2nd): | © KETSIRI YINDEE/Shutterstock.com* |
| Page 16 (3rd): | © Saniya Bazheneyeva |
| Page 16 (4th): | © Pabitra Shakya |
| Page 16 (5th): | © Puangphet Meema |
| Page 17: | © Odua Images/Shutterstock.com* |
| Page 18 (left): | © Kamila Kenzhetaeva |
| Page 18 (right): | © Cheon Youngtaek/ICHCAP |
| Page 19: | © Yernar Almabek/Shutterstock.com* |
| Page 20-21: | © Cheon Youngtaek/ICHCAP |
| Page 23: | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 24: | © ICHCAP |
| Page 25: | © KET Senghuy |
| Page 26 (right & left): | © Kamila Kenzhetaeva |
| Page 27: | © Linina Phuttitarn |
| Page 28 (left): | © Kamila Kenzhetaeva |
| Page 28 (bottom): | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 29 (top): | © Cheon Youngtaek/ICHCAP |
| Page 29 (bottom): | © Nungning20/Shutterstock.com* |
| Page 30: | © Saniya Bazheneyeva |
| Page 31 (top & bottom): | © Nischal Thapa |
| Page 32 (top): | © Nischal Thapa |
| Page 32 (bottom): | © Sabitree Maharjan |
| Page 33 (top & bottom): | © Pabitra Shakya |
| Page 34: | © Kamila Kenzhetaeva |
| Page 35 (top): | © Kamila Kenzhetaeva |
| Page 35 (bottom): | © Saniya Bazheneyeva |
| Page 36: | © Nischal Thapa |
| Page 37 (right & left): | © Kamila Kenzhetaeva |
| Page 38 (top): | © Cheon Youngtaek/ICHCAP |
| Page 38 (bottom): | © Punnee Seeyarb |
| Page 39: | © UNESCO/Islamabad (The Citizens Archive of Pakistan) |
| Page 40-41: | © Amita Dangol |
| Page 43: | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 44: | © UNESCO/Islamabad (The Citizens Archive of Pakistan) |
| Page 46: | © Odua Images/Shutterstock.com* |
| Page 50 (top): | © Cheon Youngtaek/ICHCAP |
| Page 50 (bottom): | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 51: | © ICHCAP |
| Page 52: | © Cheon Youngtaek/ICHCAP |
| Page 54: | © BonNontawat/Shutterstock.com* |
| Page 55 (left): | © UNESCO Islamabad/Karachi Biennale Trust |
| Page 55 (right): | © UNESCO Islamabad |
| Page 56: | © Cheon Youngtaek/ICHCAP |
| Page 59: | © UNESCO/Islamabad (The Citizens Archive of Pakistan) |
| Page 60: | © UNESCO/Islamabad (The Citizens Archive of Pakistan) |
| Page 61: | © UNESCO Islamabad |
| Page 63: | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 65: | © Saniya Bazheneyeva |
| Page 66 (top): | © Sergey Malkov/Shutterstock.com* |
| Page 66 (middle): | © Nischal Thapa |
| Page 66 (bottom): | © Cheon Youngtaek/ICHCAP |
| Page 67: | © UNESCO Islamabad |
| Page 68: | © Saniya Bazheneyeva |
| Page 70: | © michel arnault/Shutterstock.com* |
| Page 71: | © UNESCO/Islamabad (The Citizens Archive of Pakistan) |
| Page 72: | © ICHCAP |
| Page 73 (top & bottom): | © Linina Phuttitarn |
| Page 74: | © Devraj Maharjan |
| Page 75 (top): | © Saniya Bazheneyeva |
| Page 75 (right middle): | © Linina Phuttitarn |
| Page 75 (bottom): | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 76: | © Odua Images/Shutterstock.com* |
| Page 77: | © Pabitra Shakya |
| Page 78 (top): | © Kamila Kenzhetaeva |
| Page 78 (bottom): | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 79: | © Linina Phuttitarn |
| Page 80: | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 82: | © Linina Phuttitarn |
| Page 84 (top): | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 84 (bottom): | © Kamila Kenzhetaeva |
| Page 87 (top & bottom): | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 88: | © Cheon Youngtaek/ICHCAP |
| Page 89 (top): | © Cheon Youngtaek/ICHCAP |
| Page 89 (bottom): | © TZIDO SUN/Shutterstock.com* |
| Page 90 (top): | © Puangphet Meema |
| Page 90 (bottom): | © Cheon Youngtaek/ICHCAP |
| Page 91: | © Devraj Maharjan |
| Page 92: | © Sharareh Bajracharya |
| Page 93 (top & bottom): | © Saniya Bazheneyeva |
| Page 94 (top): | © Nischal Thapa |
| Page 94 (bottom): | © UNESCO Islamabad |
| Page 95: | © UNESCO Islamabad |
| Page 96: | © UNESCO Islamabad/Karachi Biennale Trust |
| Page 97: | © Nischal Thapa |
| Page 98: | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 99 (top & bottom): | © Saniya Bazheneyeva |
| Page 100: | © Cheon Youngtaek/ICHCAP |
| Page 101: | © UNESCO Islamabad |
| Page 103: | © Nischal Thapa |
| Page 105: | © Cheon Youngtaek/ICHCAP |
| Page 106: | © Manantuna Jyapoo |
| Page 107 (top): | © Nischal Thapa |
| Page 107 (bottom): | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 108: | © Nischal Thapa |
| Page 109: | © Sushma Maharjan |
| Page 111: | © UNESCO Islamabad/Karachi Biennale Trust |
| Page 112 (top): | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 112 (bottom): | © Cheon Youngtaek/ICHCAP |
| Page 113 (top & bottom): | © Linina Phuttitarn |
| Page 114-115: | © Nischal Thapa |
| Page 117: | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 118 (top & bottom): | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 119 (top & bottom): | © Linina Phuttitarn |
| Page 120 (top): | © acarapi/Shutterstock.com* |
| Page 120 (bottom): | © Odua Images/Shutterstock.com* |
| Page 121 (top): | © Manantuna Jyapoo |
| Page 121 (2nd): | © Nischal Thapa |
| Page 121 (3rd): | © Nischal Thapa |
| Page 121 (bottom) : | © Pabitra Shakya |
| Page 122: | © UNESCO Islamabad |
| Page 123: | © UNESCO Islamabad/Karachi Biennale Trust |
| Page 125: | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |

| | |
|---|---|
| Page 126 (top): | © Kamila Kenzhetaeva |
| Page 126 (bottom): | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 127: | © Nischal Thapa |
| Page 128: | © Mandira Gurung |
| Page 129: | © thirawatana phaisalratana/Shutterstock.com* |
| Page 130 (top): | © Saniya Bazheneyeva |
| Page 130 (bottom): | © UNESCO/Islamabad (Department of Archeology and Museums Islamabad) |
| Page 131: | © UNESCO/Islamabad (Department of Archeology and Museums Islamabad) |
| Page 132-133: | © Cheon Youngtaek/ICHCAP |
| Page 135: | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 136: | © Linina Phuttitarn |
| Page 137: | © Linina Phuttitarn |
| Page 138: | © Torychemistry/Shutterstock.com* |
| Page 140-141: | © UNESCO/Islamabad (the Citizen Archives Pakistan) |
| Page 143: | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 174: | © Saniya Bazheneyeva |
| Page 181: | © Nischal Thapa |
| Page 185: | © Cheon Youngtaek/ICHCAP |
| Page 188: | © Cheon Youngtaek/ICHCAP |
| Page 193 (left & right): | © Nischal Thapa |
| Page 201: | © hijodeponggol/Shutterstock.com* |
| Page 202: | © UNESCO/Islamabad (the Citizen Archives Pakistan) |
| Page 203: | © Manantuna Jyapoo |
| Page 224-225: | © Nischal Thapa |
| Page 228: | © Nischal Thapa |
| Page 229: | © Pabitra Shakya |
| Page 230: | © Manantuna Jyapoo |
| Page 231 (top left): | © Puangphet Meema |
| Page 231 (bottom left): | © Puangphet Meema |
| Page 231 (right): | © Linina Phuttitarn |
| Page 233 (top): | © Puangphet Meema |
| Page 233 (middle): | © Puangphet Meema |
| Page 233 (bottom): | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 234 (top): | © Puangphet Meema |
| Page 234 (middle): | © Puangphet Meema |
| Page 234 (bottom): | © Puangphet Meema |
| Page 236 (top): | © Saniya Bazheneyeva |
| Page 236 (middle): | © Saniya Bazheneyeva |
| Page 236 (bottom): | © Saniya Bazheneyeva |
| Page 236: | © UNESCO Bangkok/Gang of the Unicorn Co., Ltd. |
| Page 237: | © Saniya Bazheneyeva |
| Page 238: | © Saniya Bazheneyeva |
| Page 239: | © Saniya Bazheneyeva |
| Page 240: | © Saniya Bazheneyeva |
| Page 241 (left & right): | © Cheon Youngtaek/ICHCAP |
| Page 242 (top & bottom): | © Cheon Youngtaek/ICHCAP |
| Page 243: | © Cheon Youngtaek/ICHCAP |
| Page 244 (top & bottom): | © Cheon Youngtaek/ICHCAP |
| Page 245 (left & right): | © Kamila Kenzhetaeva |
| Page 246: | © Kamila Kenzhetaeva |
| Page 247 (top & bottom): | © Kamila Kenzhetaeva |
| Page 248 (left & right): | © Kamila Kenzhetaeva |

unesco

ichcap APCEIU

# ការបញ្ចូលបេតិកភណ្ឌរស់

## ទៅក្នុងការសិក្សានៅអាស៊ីប៉ាស៊ីហ្វិក

## សៀវភៅណែនាំ

ការសិក្សាអំពីបេតិកភណ្ឌរស់អាចផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់សិស្ស គ្រូបង្រៀន និង ដើម្បីការពារនានាភាពនៃវប្បធម៌របស់មនុស្សជាតិ។ សូមអនុវត្តតាមសៀវភៅនេះ ដើម្បីទទួលបានសមត្ថភាព ឯកសារ និងវិធីសាស្រ្ត ដើម្បីសម្រេចឱ្យបាននូវការបង្រៀនបេតិកភណ្ឌរស់នៅក្នុងថ្នាក់រៀន។ សៀវភៅនេះ ត្រូវបានតាក់តែងឡើងមិនត្រឹមតែសម្រាប់គ្រូបង្រៀនប៉ុណ្ណោះទេ តែថែមទាំងសម្រាប់ឪពុកម្តាយ និងប្រជាជនក្នុងសហគមន៍ អ្នកគ្រប់គ្រងសាលា និងអ្នកបង្កើតគោលនយោបាយអប់រំផងដែរ។ សៀវភៅរួមមានឯកសារជាច្រើនប្រភេទដូចជា រូបគំនូរជីវចល អំពីការបង្កើនការយល់ដឹង គោលការណ៍ណែនាំជាជំហានៗ កម្មវិធីសិក្សាតាមអនឡាញ ករណីសិក្សា ឧទាហរណ៍ និងធនធានសម្រាប់ការជំរុញទឹកចិត្ត និងការកសាងចំណេះដឹង។

9 789230 002015